មហាវេស្សន្តរជាតក

ចម្លងនិងរៀបរៀងសាជាថ្មីដោយ

ភិក្ខុវិនយធរោ
(មហាពិន សឿន)

⁂

ព.ស. ២៥៣៤ គ.ស. ១៩៩១

មហាវេស្សន្តរជាតក

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ចម្លងនិងរៀបរៀងសាជាថ្មីដោយ

ភិក្ខុវិនយធរោ

(មហាឃិន នឿន)

* * *

បោះពុម្ពផ្សាយជាធម្មទាន
លើកទី ១
ចំនួន ១,០០០ ច្បាប់

ព.ស.២៥៣៤ គ.ស.១៩៩១

បញ្ជីរឿង

ទំព័រ

កថាមុខមហាវេស្សន្តរជាតក . . . . ពី ក ដល់ ញ

កណ្ឌទសពរ- ព្រះពុទ្ធជាម្ចាស់ស្តេចយាងទៅក្រុងកបិលពស្តុ—ទ្រង់ធ្វើបាដិហារ្យកើតមានភ្លៀងបោក្ខរព័ស៌—ទ្រង់សម្តែងរឿងវេស្សន្តរជាតក បុព្វកម្មនាងសុបារសុប្បតី —— ព្រះឥន្ទ្រត្រាស់តឿននាងសុបារសុប្បតី ឱ្យទទួលពរ នាងសុបារសុប្បតីក្រាបទូលសូមពរ ១០ ប្រការ ១

កណ្ឌហេមពាន្ត- នាងសុបារសុប្បតីច្យុត —បានជាអគ្គមហេសីព្រះបាទស្រីសញ្ជ័យ–ព្រះពោធិសត្វច្យុតមកកើតក្នុងមនុស្សលោកទ្រង់ព្រះនាមវេស្សន្តរ ទ្រង់បានដំរីបច្ច័យនាគសម្រាប់ប្រដាប់ព្រះបារមី–ទ្រង់បរិច្ចាគទាន–ទ្រង់បាននាងមទ្រីមកជាមហេសីនាងមទ្រីប្រសូតចៅជាលីនិងនាងក្រស្នា– ពួកព្រាហ្មណ៍កលិង្គរាស្ត្រមកទូលសូមដំរីបច្ច័យនាគព្រះវេស្សន្តរទ្រង់ប្រទានដំរី–ពួកអ្នកស្រុកស្រីពិរាស្ត្រនាំគ្នាខឹងក្រាបទូលព្រះបាទស្រីសញ្ជ័យឱ្យបំបរបង់ព្រះវេស្សន្តរទៅនៅព្រៃភ្នំគិរីវង្កត.....៣៧

កណ្ឌទានកណ្ឌ- ព្រះនាងសុបារសុប្បតីស្តេចថ្កានវេស្សន្តរ — ព្រះនាងក្រាបបង្គំទូលសូមទោសព្រះវេស្សន្តរ – ព្រះវេស្សន្តរទ្រង់បរិច្ចាគសត្តសតកមហាទាន— ព្រះវេស្សន្តរទូលលាព្រះជនកព្រះជននី – ព្រះបាទស្រីសញ្ជ័យ ទ្រង់ហាមនាងមទ្រី មិនឱ្យទៅតាមព្រះស្វាមី–ព្រះនាងមទ្រីពណ៌នាសភាព របស់ស្ត្រី

បញ្ជីរឿង ទំព័រ

មេម៉ាយ—ព្រះវេស្សន្តរស្តេចចេញចោលព្រះនគរ ជាមួយនឹងព្រះមហេសីព្រះរាជបុត្រា បុត្រី ហើយ ទ្រង់ប្រទានសេះនិងរាជរថ ៨៥

កណ្ឌវនប្បវេសន៍- ព្រះវេស្សន្តរស្តេចត្រាច់ទៅដល់ស្រុកចេតរាស្ត្រ ពួកស្តេចចេតរាស្ត្រក្រាបទូលអញ្ជើញ ឱ្យស្តេចគ្រងរាជសម្បត្តិ—ព្រះវេស្សន្តរមិនព្រមទទួលទ្រង់ត្រាស់សួរផ្លូវទៅភ្នំគិរីវង្កត—ស្តេចចេតរាស្ត្រពណ៌នាពីផ្លូវទៅភ្នំគិរីវង្កត—ព្រះវេស្សន្តរ ទ្រង់លា នាំព្រះនាងមទ្រីនិងជាលីក្រស្នាទៅទ្រង់ព្រះផ្នួសជាឥសីនៅភ្នំគិរីវង្កត ១៣៨

កណ្ឌជូជក- កំណើតជូជកព្រាហ្មណ៍—ជូជកស្ទូមដើរសូមទានគេដរាបបាននាងអមិត្តតាបនា— ពួកនាងព្រាហ្មណីជេរនាងអមិត្តតាបនា ៗ ប្រើជូជក ឱ្យទៅរកទាសាទាសី —ជូជកទៅរកព្រះវេស្សន្តរទូលសូមជាលីក្រស្នា- ជូជកចូលព្រៃជួបចេតបុត្រ ៗ នឹងសម្លាប់ជូជក ៗ ពោលមុសាវាទ រស់រួចជីវិត ១៦៩

កណ្ឌចូឡពន- ចេតបុត្រពណ៌នាពីផ្លូវទៅភ្នំគិរីវង្កត ឱ្យជូជកស្តាប់ហើយ ផ្តាំឱ្យជូជកទៅសួរព្រះអច្ចុតមហាឫសី ២១១

កណ្ឌមហាពន- ជូជកបានជួបនឹងព្រះអច្ចុតឫសី ៗ សង្ស័យជាព្រាហ្មណ៍ស្ទូមមកសូមជាលីក្រស្នា — ជូជកនិយាយកុហកបញ្ឆោតព្រះអច្ចុតឫសីទៀតអច្ចុតឫសីប្រាប់ផ្លូវទៅភ្នំគិរីវង្កត ២២៨

កណ្ឌកុមារបព៌- ជូជកដេកសម្ងំនៅខាងស្រះបោក្ខរណី— ព្រ

បញ្ជីរឿង ទំព័រ

នាងមទ្រីទ្រង់ព្រះសុបិន –ព្រះវេស្សន្តរ ទ្រង់ទំនាយសុបិន –ព្រះនាងមទ្រីចូលព្រៃ—ជូជកចូលគាល់ព្រះវេស្សន្តរ ក្រាបទូលសុំជាលីក្រស្នា–ជាលី ក្រស្នា រត់ទៅពួនក្នុងស្រះ–ព្រះវេស្សន្តរមានព្រះបន្ទូលហៅបុត្រាបុត្រី ហើយទ្រង់ប្រទានដល់ជូជក— ជូជកចងកុមារទាំងទ្វី វាយនាំបណ្តើរដរាបដល់ចេញពីទ្វារព្រៃទៅ...២៥៥

កណ្ឌមទ្រីបព្វ- ទេវបុត្រ ៣ អង្គនិម្មិតអាត្មាជាសត្វសាហាវរាំងពាំងផ្លូវព្រះនាងមទ្រី ៗ បង្វរសូមផ្លូវ– ដល់ព្រះអាទិត្យអស្តង្គតទៅ ព្រះចន្ទរះឡើង ទើបសត្វសាហាវបើកផ្លូវ –ព្រះនាងស្តេចយាងទៅអាស្រមបទ បាត់កុមារទាំងពីរ—ព្រះនាងទូលសួរព្រះស្វាមីព្រះវេស្សន្តរ ៗ មិនមានព្រះបន្ទូល —ព្រះនាងរត់រកព្រះរាជបុត្រទាំងរាត្រី–ព្រះនាងមានបន្ទូលតវ៉ាព្រះស្វាមី ៗ មិនត្រាស់តបសោះ –ព្រះនាងសន្លប់– ព្រះវេស្សន្តរមានបន្ទូលប្រាប់ពីរឿងបុត្រទាំងពីរ–ព្រះនាងមទ្រីអនុមោទនាបុត្តទាន ៣១៤

កណ្ឌសក្កបព្វ- ព្រះឥន្ទ្រនិមិត្តអាត្មាជាព្រាហ្មណ៍មកទូលសុំព្រះនាងមទ្រី–ព្រះវេស្សន្តរទ្រង់ប្រទានព្រះនាងមទ្រីដល់ឥន្ទ្រព្រាហ្មណ៍–ព្រះឥន្ទ្រប្រទានពរដល់ព្រះវេស្សន្តរ ៣៦០

កណ្ឌមហារាជបព្វ- ជូជកនាំកុមារទាំងពីរទៅដល់ស្រុកជេតុត្តរ–ព្រះបាទស្រីសញ្ជ័យ ទ្រង់លោះកុមារទាំងពីរ ពីជូជក–ព្រះជាលីកុមារ ទូលតំណាល ពីសេចក្តី

បញ្ជីរឿង ទំព័រ

លំបាកតោកយ៉ាក នៃព្រះវេស្សន្តរ និងព្រះនាងមទ្រី–ព្រះបាទស្រីសញ្ជ័យ ទ្រង់ចាត់ចែងលើកទ័ពទៅទទួលព្រះវេស្សន្តរឯភ្នំគិរីវង្កត . . . ៣៨៦

កណ្ឌឆក្សត្រ- ព្រះជាលីនាំពលទៅដល់ស្រះមុចលិន្ទ — ព្រះវេស្សន្តរទ្រង់ឮសូរស័ព្ទកងទ័ព ទ្រង់នាំព្រះនាងមទ្រីរត់ឡើងទៅលើភ្នំ–ព្រះនាងមទ្រីទូលរំលឹកព្រះវេស្សន្តរកុំឱ្យខ្លាច–ព្រះបាទស្រីសញ្ជ័យ និងព្រះនាងសុបារសុប្បតីស្ដេចទៅជួបព្រះវេស្សន្តរ-កុមារទាំងពីរបានជួយនឹងព្រះនាងមទ្រី – ក្សត្រទាំង ៦ អង្គ ព្រមទាំងពួកពលសន្លប់– ព្រះឥន្ទ្រទ្រង់បណ្ដាល ឱ្យមានភ្លៀងធ្លាក់ស្រោចស្រប់ក្សត្រនិងពលទាំងនោះឱ្យរស់ឡើងវិញ — អ្នកស្រុកស្រីពិរាស្ត្រទូលអញ្ជើញព្រះវេស្សន្តរ ឱ្យស្ដេចត្រឡប់ទៅគ្រងរាជសម្បត្តិ . . . ៤៣៨

កណ្ឌនគរកណ្ឌ- ព្រះវេស្សន្តរនិងព្រះនាងមទ្រីទ្រង់លាផ្នួស-ក្សត្រទាំង ៦ អង្គទ្រង់ប្រពាតព្រៃព្រឹក្សា –ក្សត្រទាំង ៦ អង្គលើកទ័ពត្រឡប់ព្រះនគរជេតុត្តរ . . ៤៥៨

ពាក្យអធិប្បាយស័ព្ទអំពីគ្រឿងប្រដាប់ និងការពោលសរសើរលំអព្រះនាងមទ្រី ក្នុងកណ្ឌនគរកណ្ឌ ៤៩២

ឧបត្តិកថា

របស់អ្នកចម្លង

ដោយយល់ឃើញថា សៀវភៅក្បួនច្បាប់គម្ពីរធម៌អាថ៌ខាងផ្នែកព្រះពុទ្ធសាសនាក្តី - ក្បួនច្បាប់ក្រៅអំពីនេះក្តី នៅពេលដែលប្រទេសកម្ពុជា ជាទីស្នេហារបស់យើង បានធ្លាក់ចូលទៅក្នុងភ្លើងសង្គ្រាម ស្ទើរតែរលាយរលត់ បាត់បង់អស់គ្មាននៅសេសសល់ មាននៅសល់ខ្លះ ៗ ដែរ តែសៀវភៅក្បួនច្បាប់ទាំងនោះ ក៏ពុំសូវមានល្អ ព្រោះការបោះពុម្ពចម្លងតគ្នាច្រើនលើកច្រើនគ្រា នាំឱ្យមានការរលុប មិនសូវច្បាស់ មានការបាត់លេខទំព័រជាដើម ដែលជាហេតុនាំឱ្យពិបាកក្នុងការយកទៅសិក្សារៀនសូត្រ ហើយមិនមានគ្រប់គ្រាន់ដល់ពុទ្ធសាសនិកជន អ្នកត្រូវការផងដែរ ។

ដើម្បីបំពេញនូវសេចក្តីត្រូវការរបស់ពុទ្ធសាសនិកជនផង និងដើម្បីថែរក្សានូវសៀវភៅក្បួនច្បាប់ដែលនៅសេសសល់នេះកុំឱ្យវិនាសបាត់បង់ទៅជាអសារឥតការផង ទើបខ្ញុំ ភិក្ខុវិនយធរោ (មហាយិន-នឿន) ខិតខំព្យាយាមប្រមែប្រមូលរកសៀវភៅក្បួនច្បាប់ផ្សេង ៗ មានសៀវភៅ **មហាវេស្សន្តរជាតក** នេះជាដើម ដែលពុទ្ធសាសនិកជនត្រូវការជាចាំបាច់ យកមកវាយចម្លងធ្វើសាឡើងជាថ្មីម្តងទៀត ដោយប្រើម៉ាស៊ីនកុំព្យូទ័រអក្សរខ្មែរតាមបែបសម័យនិយម ។

ក្នុងការវាយចម្លងសាឡើងជាថ្មីនេះ បើសិនជាមានខុសខាត

ភ្លេចភ្លាំងដោយអចេតនាត្រង់កន្លែងណានិមួយ សូមព្រះតេជះព្រះគុណ ព្រះថេរានុត្ថេរ អស់លោក-លោកស្រី មេត្តាខន្តីអភ័យទោសដល់ខ្ញុំអ្នកវាយចម្លងផងចុះ សង្ឃឹមថា ព្រះតេជះព្រះគុណអស់លោក-លោកស្រីនឹងអភ័យទោស... ហើយនឹងផ្តល់យោបល់ល្អ ៗ ដល់ខ្ញុំជាប្រាកដ ៗ

ខ្ញុំសូមឧទ្ទិសព្រះរាជកុសលនេះចំពោះសម្តេចព្រះសង្ឃរាជទាំងពីរគណៈ មានសម្តេចព្រះសង្ឃរាជ **ជួន-ណាត** ជាដើម ព្រមទាំងព្រះថេរានុត្ថេរគ្រប់ព្រះអង្គ និងសូមជូនបុណ្យកុសលនេះ ចំពោះអ្នកដ៏មានគុណមានមាតាបិតាជាដើម ព្រមទាំងសព្វសត្វ ដែលបានចែកឋានទៅហើយ សូមអនុមោទនាទទួលយកនូវព្រះរាជកុសល និងបុណ្យកុសលនេះ កុំបីឃ្លៀងឃ្លាតឡើយ ៗ

ភិក្ខុវិនយធរោ (មហាឃិន-នឿន)

វត្តខេមរពុទ្ធិការាម

2100 W. Willow St.
Long Beach, CA 90810
U.S.A.

ថ្ងៃសុក្រ ១៤ រោច ខែទុតិយាសាធ ព.ស.២៥៣៤
ត្រូវនឹង ថ្ងៃ ទី ៩ ខែសីហា គ.ស.១៩៩១

សេចក្តីថ្លែងអំណរព្រះគុណនិងអរគុណ

ខ្ញុំសូមថ្លែងសេចក្តីអំណរព្រះគុណនិងអរគុណដ៏ជ្រាលជ្រៅ ចំពោះព្រះតេជះគុណព្រះថេរានុត្ថេរៈ អស់លោក-លោកស្រី លោកយាយ លោកតា គ្រប់ព្រះអង្គគ្រប់គ្នាទាំងអស់ ដែលមានទឹកព្រះទ័យនិងសន្តានចិត្ត ដ៏ប្រកបដោយបសាទសទ្ធាជ្រះថ្លា ចំពោះព្រះបវរពុទ្ធសាសនា បានជួយឧបត្ថម្ភក្នុងការផ្សព្វផ្សាយព្រះពុទ្ធសាសនា មានការជួយដល់ការបោះពុម្ពសៀវភៅធម៌អាថ៌ផ្នែកព្រះធម្មវិន័យ ដើម្បីចែកផ្សព្វផ្សាយជាធម្មទាន ដូចជាសៀវភៅ *មហាវេស្សន្តរជាតក* នេះជាដើម ឱ្យបានសម្រេចជាស្ថាពរ ៗ

ជាពិសេសសូមថ្លែងអំណរព្រះគុណនិងអរគុណជាទីបំផុត
—ចំពោះ ព្រះតេជះគុណ **គង់ ឈាន** វត្តខេមរពុទ្ធិការាម ដែលបានផ្តល់នូវយោបល់ផ្សេង ៗ និងបានជួយជាបច្ច័យយកទៅជាគ្រឿងឧបករណ៍សម្រាប់ប្រើប្រាស់ក្នុងការធ្វើសៀវភៅនេះ ឱ្យបានសម្រេចឡើងជាស្ថាពរ ៗ
--ចំពោះ **ភិក្ខុធម្មបាលោ ឡោ ហ៊ោ** **ភិក្ខុធម្មទីបោ ប៉ាង ឃឿន** **ភិក្ខុចន្ទជោតោ សយ យ៉េន** ដែលបានជួយអានត្រួតពិនិត្យដោយយកព្រះទ័យទុកដាក់ជាទីបំផុត ៗ
--ចំពោះ លោក **សន ជ័យ សិទ្ធី** លោក **សែព ស៊ីសុវណ្ណ** និងលោក **ឃឹម ជ័យ** ដែលបានលះបង់ពេលវេលាជួយជួសជុលគ្រឿងកុំព្យូទ័រ ឱ្យប្រើការបានល្អប្រសើរឡើង ៗ

ដោយអំណាចនៃធម្មទានានិសង្សដ៏ប្រសើរនេះ សូមឱ្យព្រះតេជះគុណ ព្រះថេរានុត្ថេរៈ អស់លោក - លោកស្រី និងលោកយាយ លោកតា គ្រប់ព្រះអង្គ គ្រប់គ្នាទាំងអស់ បានប្រកបតែនឹងសេចក្តីសុខ - ចំរើនក្នុងព្រះពុទ្ធសាសនា គ្រប់ពេលវេលា កុំបីឃ្លៀងឃ្លាតឡើយ ៗ

សូមឱ្យព្រះពុទ្ធសាសនាបានរីកចំរើនរុងរឿង ពាសពេញសាកលលោក !

សូមឱ្យសព្វសត្វបានរួចផុតពីកម្មពៀរ ទាំងឡាយទាំងពួង !

សូមឱ្យសកលលោកបានប្រកបតែនឹងសុខសន្តិភាព!

****

កថាមុខ

មហាវេស្សន្តរជាតក

ទំនៀមរបស់ស្រុកខ្មែរ តែកាលណាចេញវស្សាហើយ គេតែងចាត់ឱ្យមានបុណ្យទេសនាមហាជាតក៍ រឿងមហាវេស្សន្តរជាតក ជាអឹកអធឹក ស្ទើរតែគ្រប់វត្ត ជាទំនៀមដែលអ្នកស្រុកធ្លាប់ធ្វើរាល់ ៗ ឆ្នាំ តាំងអំពីដើមរៀង ៗ មក ទើបតែជាង២០ ឆ្នាំមកនេះ ទំនៀមទេសន៍មហាជាតកនៅវត្តទាំងឡាយ ហាក់ដូចជារយាលសាបរលាប ឬលែងធ្វើសោះទៅក៏មាន ៗ

ក្នុងសម័យឥឡូវនេះ ទុកជាមានវត្តខ្លះ នៅនិយមធ្វើបុណ្យទេសន៍មហាជាតក៍ ក៏មិនជាការរុងរឿង ប៉ុន្មានទេ គ្រាន់តែនាំគ្នាធ្វើ សោះតែខានប៉ុណ្ណោះ, ម្ល៉ោះហើយ ទំនៀមទេសន៍រឿងមហាវេស្សន្តរជាតកនេះ ក៏ចេះតែរៀវរោយចុះទៅជាលំដាប់ វត្តខ្លះក៏ខានធ្វើសោះ វត្តខ្លះ ក៏ធ្វើគ្រាន់តែជាគម្រប់ការ ៗ ក្មេងវត្តជាន់ដើម ស្គាល់ជាក់ច្បាស់នូវពិធីធ្វើបុណ្យទេសន៍មហាជាតក៍នេះ ព្រមទាំងចេះដឹងសេចក្តីផ្ទៃរឿងមហាវេស្សន្តរជាតកដោយសព្វគ្រប់ផង ៗ ឯក្មេងវត្តក្នុងសម័យឥឡូវ កម្រមានការចេះដឹងរឿងរ៉ាវវេស្សន្តរជាតកនេះណាស់ ក្មេងខ្លះ មិនទាំងដែលឮគេនិយាយចេញឈ្មោះមហាជាតក៍នេះក៏សឹងមាន ៗ មនុស្សសម័យជំនាន់ដើម កុំបាច់និយាយដល់ក្មេងវត្ត សូម្បីក្មេងប្រុសស្រី នៅក្នុងស្រុក ក្នុងភូមិ ក៏ធ្លាប់តែបានឃើញ បានដឹងឮពិធីបុណ្យទេសន៍មហាជាតក៍ ឬរឿងរ៉ាវវេស្សន្តរជាតកនេះជាដំបូង ព្រោះជាបុណ្យចេញមុខចេញមាត់ របស់ប្រជាជន ជាងបុណ្យដទៃ ៗ ជាច្រើនយ៉ាងក្នុងសម័យនោះ ៗ

រីឯសេចក្ដីក្នុងផ្ទៃរឿងនៃមហាវេស្សន្តរជាតកនេះ តាមធម្មតា ច្រើនតែមានលំនាំសេចក្ដីពីរោះ ចាប់ចិត្តអ្នកស្ដាប់ទាំងព្រះសង្ឃ ទាំងគ្រហស្ថទូទៅ ដោយហេតុអស់លោកអ្នកប្រាជ្ញជាន់នោះ លោកខំប្រែរៀបរៀងពាក្យពេចន៍ ឱ្យមានសម្ផស្សពាក្យទន់ភ្លន់ ព្រមទាំងសំនួនវោហារណែងណង ទាក់ទងគ្នាជាពាក្យកម្រងកែវ ចងក្រងសេចក្ដី ឱ្យពីរោះស្ដាប់ចាប់ត្រចៀក មិនឱ្យអ្នកស្ដាប់មានចិត្តធុញទ្រាន់, ហេតុនេះហើយ បានជាមានពួកឧបាសកឧបាសិកា ដែលមានសទ្ធាជ្រះថ្លាជាច្រើន គេអាចនឹងអង្គុយស្ដាប់ទេសន៍មហាជាតកនេះ តាំងពីព្រលឹមរហូតដល់ព្រលប់ ឈប់សម្រាកតែពេលបរិភោគអាហារថ្ងៃត្រង់ប៉ុណ្ណោះ ហើយតាមធម្មតានោះ គេតែងចាត់ឱ្យមានបុណ្យទេសន៍មហាជាតក៍នេះ តែក្នុងមួយថ្ងៃ ឱ្យចប់សព្វគ្រប់ទាំង ១៣ កណ្ឌ ។

តាមទំនៀមរៀង ៗ មកនោះ តែជិតដល់រដូវទេសន៍មហាជាតក៍, មុនថ្ងៃទេសន៍ប្រមាណ ៧ ថ្ងៃ កន្លះខែ ឬមួយខែ អាចារ្យវត្តក៏ចាត់ចែងសរសេរស្លាកប្រគេនព្រះសង្ឃឱ្យចាប់, លោកណាចាប់ស្លាកត្រូវទៅលើកណ្ឌណា ក៏យកកណ្ឌនោះមកហាត់ទេសន៍ ឱ្យទាល់តែស្ទាត់មាត់ល្អទាំងបាលីទាំងសម្រាយ, ដល់វេលាឡើងទេសនា ក៏អាចទេសន៍បានហូរហែ មិនរអាក់រអួល ជាការនាំឱ្យបានស្រួលស្ដាប់ផង អាចបំរួញពេលឱ្យបានខ្លីថែមទៀតផង គឺថា អាចទេសន៍គម្ពីរវេស្សន្តរជាតកនេះ ចប់ទាំង ១៣ កណ្ឌ មុនថ្ងៃលិច ឬតាំងពីថ្ងៃរសៀលក៏មាន ។

ច្បាប់សាស្ត្រាមហាជាតក៍ទាំងឡាយ ដែលយើងបានពិនិត្យមើលជាច្រើនគម្ពីរ ក្នុងពួកគម្ពីរមហាជាតក៍ ដែលមាន

នៅក្នុងបណ្ណាល័យរបស់ពុទ្ធសាសនបណ្ឌិត្យដែលបានច្បាប់មកអំពីខែត្រនានានោះ ឃើញថាមានលំនាំសេចក្ដីខុសគ្នាខ្លះដោយអន្លើ ៗ ជួនកាលមានសេចក្ដីវែងខ្លីលើសខ្វះគ្នាក៏មានក្នុងគម្ពីរមហាជាតក៍តែមួយ មានកណ្ឌខ្លះ ខ្សែខ្លះ មានពាក្យពេចន៍ណែងណាងចាប់ចុងចួនគ្នាជាល្បើកក៏មាន មានកណ្ឌខ្លះគ្រាន់តែចងក្រងជាពាក្យកម្រងកែវក៏មាន កណ្ឌខ្លះមានបាលីគាថាពេញលេញក៏មាន កណ្ឌខ្លះសង្ខេបក៏មាន, ច្បាប់មហាជាតក៍ខ្លះ លើកយកបាលីគាថាមកដាក់តាំងជាច្រើន ៗ ទើបប្រែជាសម្រាយហូរហែទៅក៏មាន ច្បាប់មហាជាតក៍ខ្លះ លើកយកបាទគាថាមកតាំងជាគោលបន្តិចបន្តួច ហើយប្រែសេចក្ដីហូរហែទៅតែម្ដងក៏មាន ច្បាប់មហាជាតក៍ខ្លះ មានសេចក្ដីបរិយាយត្រង់កន្លែងខ្លះលើសកើនពីច្បាប់បាលីអដ្ឋកថាទៅក៏មាន មានកន្លែងខ្លះ លើកយកបាលីនិងសេចក្ដីប្រែពីគម្ពីរដទៃមកដាក់បញ្ចូលថែមក៏មាន ៗ ល ៗ ប្រហែលជាគម្ពីរទេសន៍មហាជាតក៍នេះ កាលចាប់ផ្ដើមធ្វើជាដំបូងនោះ ក្នុងមួយចប់មានលោកអ្នកតែងរៀបរៀងច្រើនរូប ឬតែមួយរូប ៗ ទេ ប៉ុន្តែនៅវត្តដោយខ្លួន នៅខែត្រដោយខ្លួន ឬមួយអស់លោកអ្នកផ្សៀងផ្ទាត់ជាន់ក្រោយ គិតកែសម្រួល តាមអត្តនោម័តិ ឬក៏កែតាមកាលសម័យជាន់នោះ ឬពុំនោះសោតអ្នកចារចម្លងជាន់ក្រោយ បានកែថែមថយដោយខ្លួនឯង បានជាច្បាប់មហាជាតក៍ទាំងឡាយ មានសំនួនវោហារប្លែកផ្សេងពីគ្នាខ្លះ ដោយអន្លើ ៗ ដូចមានសេចក្ដីសាស័ព្ទជាលំដាប់តទៅ ៗ

ដោយហេតុច្បាប់មហាជាតក៍ ជាទីនិយមរាប់អានសំរាប់ប្រើទេសនាក្នុងវត្តទួទៅក្នុងប្រទេសខ្មែរយើងនេះបានជាអស់លោកអាចារ្យជាន់នោះ គិតកែសម្រួលតម្រូវចិត្ត

មនុស្សក្នុងវត្តនីមួយ ៗ ដែលនិយមចូលចិត្តបែបណា ឬមួយកែសម្រួលតាមកាលវេលា គង់មានពួកឧបាសក ឧបាសិកាជើងវត្តខ្លះ ត្អូញត្អែរថា " ច្បាប់មហាជាតក៏ សម្រាយវត្តយើង នេះ ពិស្តារពេក ទេសនាតាំងពីព្រលឹមរហូតដល់ព្រលប់ នៅតែមិនទាន់ចប់ " ក៏ត្រូវការមហាជាតក៏សង្ខេប, ដោយហេតុនេះ បានជាមានច្បាប់មហាជាតក៏ខ្លះ កាត់បាលីគាថាចោលទៅជាច្រើនអន្លើ ច្បាប់ខ្លះ កាត់ទាំងបាលី ទាំងសម្រាយកាន់តែសង្ខេបខ្លីទៅទៀត ក៏មាន គ្រាន់តែប្រើទេសនា ក្នុង ១ កំណាត់ថ្ងៃ ក៏ចប់អស់ទាំង ១៣ កណ្ឌ ៗ ប៉ុន្តែ គង់មានវត្តខ្លះ ពួកឧបាសកឧបាសិកាជើងវត្ត ឬ ព្រះសង្ឃក្នុងវត្តនៅនិយមត្រូវការបែបពិស្តារក៏មាន បានជាមានច្បាប់មហាជាតក៏ខ្លះ មានសេចក្តីពិស្តារ ចងក្រងជាពាក្យល្បើក ហើយមានបរិយាយវែងឆ្ងាយ ចេញក្រៅ ពី អដ្ឋកថាមហាវេស្សន្តរជាតកទៅទៀត ក៏មាន ៗ

មួយវិញទៀត តួបាលីគាថាក្តី បាលីរាយមិនមែន ជាគាថាក្តី សេចក្តីប្រែ ជាសម្រាយក្តី ដែលល្អៀងឃ្លៀងឃ្លាត ឬភ្លាំងភ្លាត់ទៅជាច្រើននោះ មកអំពីពួកអ្នកចារចម្លងក៏មាន ព្រោះតាមធម្មតា ពួកអ្នកចារមិនមែនសុទ្ធតែជាអ្នកចេះបាលីទេ មានខ្លះ មិនសូវចេះដាក់អក្សរខ្មែរ ឱ្យបានត្រឹមត្រូវផងក៏មាន គ្រាន់តែជាអ្នកចេះចារអក្សរល្អប៉ុណ្ណោះ ហើយជាអ្នករកស៊ីចារសាស្ត្រាផង ម្ល៉ោះហើយ ច្បាប់ចារចម្លងទាំងនោះ ប្រសិនបើ មិនបានផ្ទៀងផ្ទាត់ថែមទៀត ក៏មិនបានជាត្រឹមត្រូវល្អទេ ថែមទាំងច្បាប់ដើមនោះ មានបើវិបត្តិសេចក្តី ឬវិបត្តិតួបាលីគាថា ជាច្រើនផង, ការចារចម្លងជាន់ក្រោយ ដោយពួកអ្នកស៊ីឈ្នួលចារទាំងនោះ ក៏កាន់តែ

នាំឱ្យមានការវិបត្តិច្រើន លើសពីច្បាប់ដើម ដែលមានវិបត្តិស្រាប់នោះទៅទៀត ។ កុំបាច់ពោលដល់ច្បាប់ ដែលចារចម្លងជាន់ក្រោយ ៗ ត ៗ មកទៀតនោះឡើយ ។ មួយទៀតគួរជ្រាបថា ច្បាប់មហាជាតក៏ទាំងឡាយ ដែលចារដោយស្លឹករឹតនោះ មិនមែនសុទ្ធតែមានខុសវិបត្តិទៅទាំងអស់ទេ ត្បិតនៅមានច្បាប់ខ្លះ ក៏ត្រឹមត្រូវល្អគួរសមដែរ, ប៉ុន្តែបើពោលដោយយេភុយ្យន័យនោះ មិនមែនតែច្បាប់សាស្ត្រាមហាជាតក៏មួយទេ សូម្បីច្បាប់ចារស្លឹករឹតដទៃ ៗ ទៀតក៏ច្រើនតែមានទំនងដូច្នេះដែរ ។

ឯគម្ពីរមហាវេស្សន្តរជាតក ដែលយើងបានរួបរួម បោះពុម្ពឡើងនេះ ក៏មិនមែនជាច្បាប់ដែលយើងចាប់ប្រែរៀបរៀងឡើងជាថ្មីទេ គឺ យើងគ្រាន់តែយកច្បាប់សាស្ត្រាមហាជាតក៏ស្លឹករឹត ទាំងនោះឯង មកពិនិត្យផ្ទៀងផ្ទាត់ ហើយចម្លងចេញបោះពុម្ពផ្សាយ ដើម្បីរក្សារបៀបរៀបរៀងសេចក្ដីជាន់ចាស់ទុក ឱ្យគង់វង់តទៅផង ដើម្បីជាប្រយោជន៍ដល់ពុទ្ធសាសនិកជនទាំងឡាយ ក្នុងសម័យឥឡូវ ដែលមិនសូវបានស្ដាប់ទេសន៍រឿងមហាវេស្សន្តរជាតកនេះផង ៗ មួយវិញទៀត សូមឱ្យអស់លោកអ្នក មើលច្បាប់មហាជាតក៏បោះពុម្ពនេះ ជ្រាបរបៀបរួបរួមផ្ទៀងផ្ទាត់បោះពុម្ពនេះ ដូចមានសេចក្ដីសាស័ព្ទតទៅនេះ ៖

១) តួបាលីគាថាក្ដី តួបាលីរាយមិនមែនជាគាថាក្ដី ក្នុងមហាវេស្សន្តរជាតកច្បាប់ស្លឹករឹតនោះ ឃើញមានវិបត្តិជាច្រើនអន្លើ ទើបយើងផ្ទៀងផ្ទាត់ កែសម្រួលឱ្យបានត្រឹមត្រូវឡើង តាមរបៀបបាលីក្នុងគម្ពីរអដ្ឋកថាមហាវេស្សន្តរជាតក និងច្បាប់បាលីដើម ៗ

២) សេចក្ដីប្រែរៀបរៀងជាសម្រាយនោះ យើងបានរក្សាទុកតាមច្បាប់ដើម ស្ទើរតែទាំងអស់ វៀរលែងតែច្បាប់ដើមដែលរំលងសេចក្ដីបាត់ទៅដោយអ្នកចារ ៗ ចម្លង ទើបយើងប្រែរៀបរៀងជាថ្មី បំពេញសេចក្ដីត្រង់ ដែលបាត់នោះ ៗ តួបាលីគាថាដែលរំលងបាត់ទៅ ក៏ស្រង់យកមកដាក់បំពេញដែរ ៗ

៣) ច្បាប់មហាជាតក៍ទាំងឡាយដែលមានសេចក្ដីប្លែកផ្សេងពីគ្នា ដោយសំនួនវោហារក្ដី ដោយសេចក្ដីលើសខ្វះពីគ្នាក្ដី ដោយរូបសេចក្ដីខុសគ្នា ទាំងបាលីទាំងសម្រាយ ក្ដី យើងក៏បានបង់លេខធ្វើនយលក្ខណៈទុកដោយអន្លើ ៗ បង្ហាញឱ្យឃើញសេចក្ដីប្លែកផ្សេងគ្នានោះ ៗ ៗ ត្រង់ដែលមានសេចក្ដីប្រែល្អៀងឃ្លៀងឃ្លាត ពីរូបបាលីទៅខ្លះ យើងក៏ធ្វើនយលក្ខណៈ ប្រែសេចក្ដីតាមរូបបាលី បង្ហាញឱ្យឃើញសេចក្ដីប្លែកផ្សេងគ្នាដែរ ៗ

៤) ត្រង់ដែលមានសេចក្ដីពណ៌នាអំពីព្រៃព្រឹក្សាលតាវល្លិ៍ក្ដី អំពីបក្សាបក្សីក្ដី អំពីសត្វទ្វិបាទចតុប្បាទក្ដី អំពីមច្ឆាជាតិទាំងឡាយក្ដី គប្បីយល់ថា សេចក្ដីប្រែរៀបរៀងរបស់លោកអំពីបុរាណរៀងមកនោះ មិនបានប្រិតប្រៀនឱ្យត្រឹមត្រូវតាមរូបបាលីប៉ុន្មានទេ គឺត្រូវការតែសេចក្ដី និងសម្ផស្សពាក្យចូនជាប្រមាណ ជាទំនងសេចក្ដីកម្រងកែវ ឬជាពាក្យល្បើកដែលនាំឱ្យពីរោះស្ដាប់ចាប់ចិត្តជនទាំងពួង ៗ

៥) ច្បាប់មហាជាតក៍បោះពុម្ពនេះ យើងបានកែអក្សរខុស-ត្រូវតម្រូវតាមរបៀបប្រើអក្សរ ក្នុងសម័យបច្ចុប្បន្ននេះ ព្រោះរបៀបអក្សរសាស្ត្រខ្មែរក្នុងសម័យសព្វថ្ងៃនេះ ក៏កាន់តែចម្រើនគួរសមហើយ មានវនានុក្រមខ្មែរ សម្រាប់ផ្ទៀង-

ផ្ទាត់ដាក់ពាក្យពេចន៍ឱ្យបានត្រឹមត្រូវហើយ ទើបគួរផ្លាស់របៀបដាក់អក្សរតាមបែបថ្មី តែសំនួនវោហារ និងសេចក្ដីរៀបរៀងទុកនៅតាមរបៀបជាន់ចាស់ដដែល គឺអក្សរសម័យថ្មី ឯសេចក្ដីសម័យចាស់ ។

៦) តាមច្បាប់មហាជាតក៏សម្រាយ ក្នុងមួយខ្សែៗ សុទ្ធតែមានចំណងជើងប្រាប់ចំនួនគាថា ថាមានគាថាប៉ុណ្ណោះៗ ប៉ុន្តែមិនសូវមានខ្សែណា មានចំនួនគាថាគ្រប់គ្រាន់តាមចំណងជើងនោះឡើយ ។ ឯច្បាប់មហាជាតក៏បោះពុម្ពនេះ យើងបានស្រង់យកតួបាលីគាថាមកដាក់បំពេញតាមច្បាប់បាលីដើមទាំងអស់ ដើម្បីបង្គ្រប់ចំនួនគាថាតាមចំណងជើងក្នុងកណ្ឌនីមួយៗ ។ (ដែលលោករាប់ជាមួយគាថាៗនោះ មិនសូវជាកំណត់ទៀងទាត់ទេ ព្រោះមានគាថាក្នុងកណ្ឌខ្លះ មាន ២ បាទ ៤ បាទ ៥ បាទ ៦ បាទ រាប់ជាមួយគាថាក៏មាន) ។ មួយវិញទៀត ការស្រង់យកបាលីគាថា មកដាក់បំពេញដូច្នេះ នាំឱ្យមើលឃើញតួបាលីច្រើនស្កេកស្កះ ដែលអាចនាំឱ្យមានសេចក្ដីធុញទ្រាន់ ដល់អ្នកទេសន៍និងអ្នកស្ដាប់ ឬអ្នកអានមើលច្បាប់មហាជាតក៏បោះពុម្ពនេះខ្លះមិនខាន ប៉ុន្តែហេតុទាស់ប៉ុណ្ណោះ មិនជាការក្រទេ គឺវេលាទេសន៍ ឬអានមើលអាចកាត់រំលងតួបាលីគាថាទៅ ទេសន៍ឬអានតែសម្រាយទទេក៏បានដែរ ជាការបង្រួញពេលវេលាឱ្យបានខ្លី តាមសេចក្ដីត្រូវការរបស់វត្តខ្លះ ។

៧) សេចក្ដីត្រង់ណា មិនមានរឿងសម្ដែងទុក ក្នុងគម្ពីរអដ្ឋកថា ឬក្នុងច្បាប់បាលីដើមទេ ប៉ុន្តែមានសេចក្ដីរៀបរៀងល្អស្ដាប់ ទាំងសមហេតុសមផលផង (ដូចជា

ក្នុងកណ្ឌជូជក តាំងពីចាប់ផ្ដើមសាស័ព្ទអំពីដំណើរជូជកដើរសុំទាន ដរាបដល់បាននាងអមិត្តតាបនា នាំទៅលំនៅអាត្មា ឯកលិង្គរាស្ត្រ) យើងក៏បានរក្សាទុក តាមច្បាប់ចាស់ទាំងអស់ ហើយធ្វើនយលក្ខណៈ ប្រែសេចក្ដីតាមរបៀបបាលីអដ្ឋកថាឱ្យបានដឹងផង ៗ វៀរលែងតែសេចក្ដីត្រង់ណាចេញក្រៅបាលី ហើយមិនសមហេតុផល ហើយជារឿងកំប្លែងលេងសើចទេ (ដូចជាក្នុងកណ្ឌមហារាជបព្វៈត្រង់រឿងជូជកបរិភោគអាហារ ទាល់តែចាក់ច្រាស ធ្លាយពោះស្លាប់) ក៏យើងមិនកាត់ចោលច្បាប់ចាស់ស្រឡះដែរ គឺធ្វើនយលក្ខណៈរក្សាទុកនៅខាងក្រោយកណ្ឌនោះ គ្រាន់តែមិនបានបញ្ចូលមកទុក ក្នុងផ្ទៃរឿងប៉ុណ្ណោះ ៗ

៨) របៀបប្រើពាក្យពេចន៍ ឬស័ព្ទសែង ក្នុងគម្ពីរមហាជាតក៏សម្រាយនេះ ពិតមែនតែជាគម្ពីរ ដែលបានប្រែមកពីអដ្ឋកថាមហាវេស្សន្តរជាតកបាលី ប៉ុន្តែមានជាប់សំដីសំស្ក្រឹតជាច្រើន ក្នុងសេចក្ដីប្រែជាសម្រាយ សូម្បីតែឈ្មោះមនុស្ស សត្វ ឬវត្ថុអ្វី ៗ ក៏កែប្រែទៅជាពាក្យសំស្ក្រឹតដែរ ដូចជាព្រះនាមព្រះវរមាតាព្រះបាទស្រីវេស្សន្តរ តាមស័ព្ទបាលីថា " ផុស្សតី " ក៏កែប្រែទៅជាស័ព្ទសំស្ក្រឹត ថា " សុបារសុប្បតី " (សំស្ក្រឹតក្លាយ ? គួរជា " ស្បត្ស្បីតី " ឬ " ស្បុត្ស្បីតី ") ៗ ព្រះនាមព្រះអគ្គមហេសី តាមស័ព្ទបាលីថា " មទ្ទី " កែជា " មទ្រី " ៗ ព្រះនាមព្រះរាជធីតាថា " កណ្ហា " ក៏កែជា " ក្រឹស្ណា " ឈ្មោះស្រុកថា " ចេតរដ្ឋ " ក៏កែជា " ចេតរាស្ត្រ " ដូច្នេះជាដើម ៗ (នេះសឱ្យឃើញនិស្ស័យសន្ដានចិត្តខ្មែរជាន់ដើមចូលចិត្តនិយមរាប់អានពាក្យសំស្ក្រឹត ជាងមគធភាសា ឬ

មួយជាប់ទម្លាប់មាត់ថាតាមសំស្ក្រឹតមកជាយូរអង្វែងហើយ ទុកជាគ្រាក្រោយបែរមកនិយមរៀនសូត្របាលីភាសាជាជំនួសសំស្ក្រឹតវិញហើយ ប៉ុន្តែទម្លាប់មាត់ថាតាមសំស្ក្រឹតនោះងាយស្រួលជាង ទាំងពីរោះពីសាជាងបាលី ដែលជាភាសាចំណូលថ្មី ទើបនៅតែចង់ប្រើពាក្យសំស្ក្រឹត ដូចជាន់មុនដដែល) ។

៨) គម្ពីរវេស្សន្តរជាតក ដែលបោះពុម្ពនេះ ចែកចេញជាកណ្ឌ មាន ១៣ កណ្ឌ គឺ កណ្ឌទសពរ ១ ហេមពាន្ត ១ ទានកណ្ឌ ១ វនប្បវេសន៍ ១ ជូជក ១ ចូឡពន ១ មហាពន ១ កុមារបព្វៈ ១ មទ្រីបព្វៈ ១ សក្កបព្វៈ ១ មហារាជបព្វៈ ១ ឆក្សត្រិយ៍ ១ នគរកណ្ឌ ១ ។

ក្នុងទីបំផុតនៃកថាមុខនេះ យើងមានសង្ឃឹម ទុកជាមុនថា អស់លោក - អ្នកស្វែងរកចំណេះចេះដឹង ខាងផ្លូវអក្សរសាស្ត្រខ្មែរ គង់មានសេចក្តីពេញចិត្ត ចំពោះសំនួនវោហាររបៀបរៀបរៀងសេចក្តី នៃច្បាប់មហាជាតក៏ជាន់ដើមនេះខ្លះ មិនខាន ព្រោះវិធីតែងសេចក្តី ឬរៀបរៀងប្រែរឿងអ្វី កាលពីជាន់ដើមនោះ មិនមែនជាថយខ្សោយរសជាតិជាងសម័យឥឡូវប៉ុន្មានទេ ។ ប្រសិនបើយើងយកចិត្តទុកដាក់ពិនិត្យដោយហ្មត់ចត់ទៅ នឹងឃើញថា របៀបរៀបរៀងសេចក្តីជាន់ដើម មានលំនាំសេចក្តីនិងសម្ផស្សពាក្យល្អជាងជាន់ឥឡូវទៅទៀត បើពោលចំពោះត្រង់សេចក្តីពណ៌នាអំពីព្រៃព្រឹក្សាបក្សាបក្សីផង ក៏កាន់តែមានសម្ផស្សពាក្យពីរោះស្តាប់ចាប់ចិត្ត ជាងជាន់ឥឡូវជាអនេកប្រការ សូម្បីសេចក្តីតែងជាពាក្យកាព្យ

ដែលលោកពោលពណ៌នាអំពីព្រៃព្រឹក្សាលតាវល្លិ៍ ក៏មានសម្ផស្សពាក្យល្អស្តាប់ចាប់ចិត្ត នៃចិន្តកវីជំនាន់ថ្មីនេះណាស់ដែរ ហើយច្រើនតែជារបៀបតែង ឬប្រែដោយចំណេះចេះដឹងតាមបែបខ្មែរសុទ្ធផង ទើបគួរតែអ្នកសិក្សាអក្សរសាស្ត្រខ្មែរ សម័យឥឡូវ ពិនិត្យមើលរបៀបតែងសេចក្តីជាន់ចាស់ខ្លះ ពុំគួររំលងចោលស្រឡះទៅទេ ។

អ្នករួបរួមផ្ទៀងផ្ទាត់

ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម

ពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ

មហាវេស្សន្តរជាតក

ទី ១



កណ្ឌទសពរ

ប្រដាប់ដោយគាថា ១៩



ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់សំដែងថ្លែងនូវព្រះធម្មវិសេសទេសនា
អំពីរឿងព្រះមហាវេស្សន្តរជាតក ប្រោសព្រះភិក្ខុសង្ឃនិងក្រុមពួក
ព្រះញាតិវង្សានុវង្សរបស់ព្រះអង្គ នៅទីក្រុងកបិលព័ស្តុបុរី ។

មហាវេស្សន្តរជាតក

ទី ១

កណ្ឌទសពរ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ផុស្សតី វរវណ្ណាភេតិ ឥទំ សត្ថា កបិលវត្ថុំ ឧបនិស្សាយ និគ្រោធារាមេ វិហរន្តោ បោក្ខរវស្សំ អារព្ភ កថេសិ ។

សត្ថា មោះ **សត្ថវាហោវ សត្ថនាយកោវ** វីព្រះអង្គដ៏ជាគ្រូប្រសើរក្រៃលែង តែងអាចនានាំ អស់ទេវតាមនុស្សសត្វ ផងទាំងឡាយ ក្បៀរគរបរប្រមូលបញ្ចូលទៅកាន់អម្រឹតបុរីស្រីមហានគរនិព្វាន ដ៏ជាឋានបរមសុខក្សេមក្សាន្តប្រេមប្រាសនិរាសទុក្ខប្រសើរហោង ៗ

វិហរន្តោ មោះ **ចតូសុ ឥរិយាបថេសុ ឋីតិនាមេន្តោ** ក៏ព្រះអង្គ គង់សម្រេចសម្រាន្តក្សាន្តនូវព្រះឥរិយាបថ ស្រេគត់ព្រះអង្គនោះ មានបួន ពុំឱ្យចួននូវសន្និះតម្រិះចិត្ត នៃទេវតាមនុស្សសត្វផងទាំងឡាយឡើយ **និគ្រោធារាមេ** ក៏ព្រះអង្គគង់ព្ធដ៏ឋានអារាមនាមហៅនិគ្រោធមហាវិហារ គឺចៅនិគ្រោធកុមារ ចាយវាយមាស ១២ កោដិតម្លឹង សាងថ្វាយព្រះអង្គ **ឧបនិស្សាយ** ក៏ព្រះអង្គអាស្រ័យយកព្រះបិណ្ឌបាត សង្វាតសន្តោសប្រោសសត្វផង

ទាំងឡាយ **កបិលវត្ថុំ** ព្ធដ៏ស្រុកកបិលពស្តុបុរីស្រីមហានគរបវររាជដ្ឋាន **អារព្ភ** មោះ **អារម្មណំ** **កត្វា** ទើបព្រះអង្គមានព្រះបន្ទូលធ្វើឱ្យជាហេតុជាអារម្មណ៍បន្តិចហើយ ទើបព្រះអង្គឆ្លោះបោក្ខរវស្សំ នឹងភ្លៀងសួគ៌មួយឈ្មោះបោក្ខរពស៌ **កថេសិ** មោះ **ធម្មំ ទេសេសិ** ទើបព្រះអង្គសម្តែង ថ្លែងព្រះធម៌វិសេសទេសនា **ឥទំ មហាវេស្សន្តរជាតកំ សហស្សគាថាបដិមណ្ឌិតំ** បពិត្រអើយ នេះនឹងនិទានដំណើរដំណាលកាលព្រះអង្គត្រាច់រង្គាត់នៅនាក្នុងវដ្តសង្សារ ត្រអាលយោនយកកំណើត កើតជាព្រះពោធិសត្វមួយព្រះអង្គទ្រង់ព្រះនាមករណ៍បវរ ហៅថា ព្រះមហាវេស្សន្តរ មហាវេស្សន្តរជាតកនេះ ដ៏ប្រដាប់ប្រដានូវព្រះគាថានោះ មួយពាន់ **អត្តនា** មោះ **ឧបលិក្ខិតេន** គឺកម្លាំងព្រះប្រាជ្ញាសព្វញ្ញពុទ្ធដ៏ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ព្រះអង្គអាចសម្គាល់ ដឹងបាន **អាទិគាថាបទេន** ដោយនូវគន្លងទំនងដើមបទ កំណាត់អក្សរបវរព្រះគាថានេះ ដ៏ជាអាទិ៍ **ផុស្សតី វរវណ្ណាភេតិ** នេះឯងគឺដ៏ជាប្រធានដើមបទ ព្រះអង្គកត់សម្គាល់ត្រង់ណោះឯងហោង ។

យទា ហិ សត្ថា បវត្តិតប្បវរធម្មចក្កោ អនុក្កមេន រាជគ្គហំ គន្ត្វា តត្ថ ហេមន្តំ វីតិនាមេត្វា ឧទាយិត្ថេរេន មគ្គុទ្ទេសកេន វីសតិសហស្សក្ខីណាសវបរិវុតោ បឋមគមនេ យាវ កបិលវត្ថុ អគមាសិ ។

បពិត្រអើយ នាកាលព្រះដ៏មានបុណ្យ ព្រះអង្គបានត្រាស់

ប្រាជ្ញាសពេ៌ជ្ញតាញ្ញាណជាបឋមនោះ ស្តេចលីលាទៅកាន់ព្រៃឥសិបតនមិគទាយពន ព្រះអង្គទេសនាព្រះធម្មចក្កប្បវត្តនៈដ៏ប្រសើរ ដំណើរសងគុណបញ្ចវគ្គិយភិក្ខុទាំង៥ មានព្រះអញ្ញាកោណ្ឌញ្ញត្ថេរជាប្រធាន បានលុះស្រោតាបត្តិផល មួយអន្លើនឹងមហាព្រហ្មទាំង១៨កោដិ សោតសឹងបានលុះស្រោតាបត្តិផលដល់ប្រាជ្ញាអរហត្តទីទៃៗស្រេចហើយនៃ ទើបស្តេចលីលាពីនោះឆ្ពោះទៅកាន់នគររាជគ្រឹះបុរី ប្រយោជន៍ដើម្បីនឹងដោះពាក្យប្តេជ្ញាព្រះបាទមគធរាជ (១) ដ៏ជាឧបាសកអំពីបុរាណ, កាលបើព្រះដ៏មានបុណ្យ ព្រះអង្គស្តេចទៅដល់នគររាជគ្រឹះនោះហើយ ព្រះអង្គសម្តែងថ្លែងព្រះធម៌វិសេសទេសនា ដោះពាក្យប្តេជ្ញាជាសណ្តាប់នៃព្រះបាទមគធរាជនោះហោង ។

បពិត្រអើយ កាលនោះ រីមហាជនផងទាំងឡាយ សឹងកាន់នីទៅនូវទៀនធូបគន្ធមាលា ផ្កាភ្ញី ចូលទៅបូជាព្រះដ៏មានបុណ្យនោះច្រើនក្រៃពេក ។ កាលណាបើបានបូជា ព្រះដ៏មានបុណ្យនោះស្រេចហើយ ក៏អង្គុយស្តាប់នូវស័ព្ទព្រះធម៌វិសេសទេសនា ដ៏ផ្អែមល្ហែមពីរោះដូច្នោះកូវ សឹងចូលចិត្ត ត្រេកអរសាទរ ហើយសរសើរថា ឱ! ធម៌ទេសនាព្រះដ៏មានបុណ្យអើយ! ពីរោះអ្វី

១- ពាក្យនេះមានច្បាប់មហាជាតក៏ជាច្រើនខុស ៗ គ្នា ច្បាប់ខ្លះថា មគុត្តរាជ ខ្លះថា មគ្គរាជ ខ្លះថា មឃរាជ (យល់ថាជាអក្ខរវិបត្តិ) ៗ ក្នុងទីនេះបានកែជាមគធរាជ សំដៅដល់ព្រះបាទពិម្ពិសារគ្រងក្រុងរាជគ្រឹះ ដែនមគធរដ្ឋ ។

មាល្បាយអេះ ! ម្ល៉ោះហើយ អស់មហាជនផងទាំងឡាយ ពុំអាចដើម្បីនឹងទប់ទល់តម្កល់អាត្មាភាពបានឡើយ សឹងពិតទូលសូមផ្នួសបួសក្នុងសម្នាក់ព្រះអង្គនោះ ប្រមាណមួយម៉ឺនជាបរិវារ ឰដ៏កាលនោះហោង ៗ

បពិត្រអើយ នាកាលព្រះដ៏មានបុណ្យ ស្ដេចទេសនា ជាសណ្ដាប់នៃព្រះបាទមគធរាជនោះស្រេចហើយ ស្ដេចគង់សម្រេចនូវព្រះក្រឹត្យជាព្រះពុទ្ធ ចំហុតអស់ខែហេមន្តរដូវកូវ ក៏មិនកំបាំងបាត់ស្វាត់ ប៉ុន្តែក្នុងកម្លុងស្រុករាជគ្រឹះនោះឡើយ ក៏ឮជ្រួតជ្រាបដរាបទៅដល់ព្រះស្រោតទិព្វថ្លៃ នៃព្រះបាទស្រីសុទ្ធោទនមហារាជជាសម្ដេចព្រះវររាជបិតា ព្រះអង្គទ្រង់ជ្រាបហើយ ព្រះអង្គទ្រង់ព្រះចិន្ដាពិចារណាថា ឱ! ឥឡូវនេះ អ្នកសិទ្ធាថ៌កុមារកូនអញ អញគិតស្មានជាអ្នកទៅបួសបាត់ស្វាត់ទៅហៈ ក៏ឥឡូវនេះ លេចឮដំណឹងថា អ្នកបានត្រាស់ប្រាជ្ញាសពេ៌ជ្ញូតាញាណជាព្រះពុទ្ធហើយ អ្នកគង់នៅនារាជគ្រឹះបុរី ហើយអ្នកទេសនាជាសណ្ដាប់ព្រះបាទមគធរាជ ឥឡូវ អញរលឹកកូនអញណាស់ ថាបើដូច្នោះ ធ្វើម្ដេចអញនឹងបានឃើញកូនអញហៈ នេះមានតែអញនឹងប្រើទូតទៅនិមន្តអ្នកមកក៏បានអេះ ព្រះអង្គទ្រង់ព្រះចិន្ដាពិចារណានូវប្រការអម្បាលណោះហើយ ទើបមានព្រះបន្ទូលត្រាស់ប្រើរាជអាមាត្យមួយដ៏ជាធំថា នៃរាជអាមាត្យ អញឮថា អ្នកសិទ្ធាថ៌កូនអញមិញ អ្នកបានត្រាស់ប្រាជ្ញាសពេ៌ជ្ញូតាញាណហើយ អ្នកមកគង់នៅនានគររាជ-

គ្រឹះហើយ ក៏ឥឡូវនេះ អញនឹងប្រើបាឯង នាំពលមួយពាន់ ទៅអារាធនានិមន្តអ្នកមកឥឡូវហោង ៗ នៃអាមាត្យ ថាបើអ្នកទទួលនិមន្តន៍ ក៏ចូរបាននាំអ្នកមកឱ្យឆាប់ កុំបីយូរឡើយ ៗ រាជអាមាត្យទទួលព្រះបន្ទូលព្រះមហាក្សត្រ ហើយក្រាបថ្វាយបង្គំលា នាំបរិវារមួយពាន់ដើររៀងរាប ដរាបទៅដល់នគររាជគ្រឹះនោះឯង ៗ កាលបើបានដល់ហើយ ក៏ចូលទៅក្រាបថ្វាយបង្គំប្រណម្យព្រះដ៏មានបុណ្យ ប្រយោជន៍ដើម្បីនឹងសូមអារាធនានិមន្តដូចព្រះបណ្តាំព្រះមហាក្សត្រាធិរាជនោះ កាលណាបានឮព្រះធម៌ទេសនាដ៏ពីរោះផ្អែមល្ហែមដូចច្នោះកូវ រាជអាមាត្យ មួយអន្លើនឹងពលមួយពាន់នោះ ក៏ភ្លេចភ្លាំងស្មារតី ពុំអាចដើម្បីនឹងពិតទូល អំពីព្រះបណ្តាំព្រះមហាក្សត្រនោះឡើយ ក៏ខ្វែប្រែជាពិតទូលសូមផ្នួសបួសអស់ទាំងមួយពាន់នោះវិញហោង ៗ

បពិត្រអើយ រីរាជអាមាត្យទាំងមួយពាន់នោះសោត កាលបើបានបួសស្រេចហើយកូវនៅជាសុខសប្បាយ ពុំភ្លឹករលឹកអំពីព្រះបណ្តាំព្រះមហាក្សត្រនោះឡើយ ៗ រីឯព្រះបាទស្រីសុទ្ធោទនមហារាជ ទន្ទឹងយល់បាត់ស្ងាត់ហើយ ស្តេចប្រើរាជអាមាត្យមួយវិញទៀតឱ្យនាំពល ១.០០០ ទៅទៀត លុះទៅដល់យល់ព្រះអង្គហើយក៏ពិតទូលសូមផ្នួសបួសអស់ទាំង ១.០០០ នោះឯងហោង ៗ

ព្រះបាទស្រីសុទ្ធោទនមហារាជព្រះអង្គទ្រង់ប្រើបណ្តើររៀង ៗ ទៅ លុះគម្រប់ជា ៩ ដង អស់រាជអាមាត្យទាំង ៩ ពាន់នោះ

សឹងតែព្រះអង្គបំបួសអស់ ឥតសេសសល់ សំណល់មួយឡើយ ៗ រីឯព្រះបាទស្រីសុទ្ធោទនមហារាជមិញ ទ្រង់ទន្ទឹងយល់បាត់ស្ងាត់អម្បាលណោះហើយ ទើបព្រះអង្គប្រើរាជអាមាត្យមួយវិញទៀតឈ្មោះឧទាយិអាមាត្យថា ម្នាលឧទាយិអាមាត្យអើយ អញចង់ប្រើបាឯងទៅនិមន្តអ្នកសិទ្ធាថ៌កូនអញបន្តិចហៈ ត្បិតអញប្រើអស់រាជអាមាត្យអំពីមុននោះ ៩ ពាន់ បាត់ស្ងាត់អស់ ទាំងអម្បាលណោះ មិនបានរួចមកដល់មួយនាក់ឡើយ ក៏ឥឡូវនេះ អញយល់តែបាឯងមានគំនិតស្មារតី បានដឹងចិត្តគំនិតអញៗ នឹងប្រើបាឯងនាំពល ១.០០០ ទៅកាន់រាជគ្រឹះនគរនាយនោះ ថាបើបាបានទៅដល់យល់អ្នកហើយ ក៏ចូរបាសូមអារាធនានិមន្តអ្នកមកឱ្យឆាប់ កុំបីយូរឡើយ ៗ ឧទាយិអាមាត្យទទួលយកព្រះបន្ទូលមហាក្សត្រាធិរាជនោះស្រេចហើយ ក្រាបថ្វាយបង្គំលានាំបរិវារពល ១.០០០ ដើររៀងរាបងរាបទៅដល់រាជគ្រឹះបុរីស្រីមហានគរបវររាជដ្ឋាននោះឯងហោង ៗ កាលណាបានទៅដល់ យល់ព្រះដ៏មានបុណ្យហើយ ក៏ចូលទៅក្រាបថ្វាយបង្គំប្រណម្យ ប្រយោជន៍ដើម្បី នឹងសូមអារាធនានិមន្តដូចព្រះបណ្ដាំព្រះមហាក្សត្រនោះមិញ លុះឮឯព្រះធម៌ទេសនាព្រះអង្គពីរោះដូច្នោះកូវ ឧទាយិអាមាត្យមួយអន្លើនឹងពលទាំងមួយពាន់នោះ ក៏ភ្លេចភ្លាំងស្មារតី ពុំអាចដើម្បីនឹងពិតទូលអំពីបណ្ដាំព្រះមហាក្សត្រានោះបានឡើយ ហើយខ្វែប្រែជាពិតទូលសូមផ្នួស បួសអស់ទាំងមួយពាន់នោះវិញហោង ៗ

រីព្រះអង្គបំបួសនាក្នុងកម្លុងរាជគ្រឹះនោះ មួយម៉ឺន ព្រះបាទស្រីសុទ្ធោទនមហារាជ ប្រើទៅនោះ មួយម៉ឺន ព្រះអង្គបំបួសទាំងអស់ត្រូវជាពីរម៉ឺនហោង ៗ ឧទាយិអាមាត្យបានបួសរួចហើយឡើងព្រះនាមជា ព្រះមហាឧទាយិត្ថេរ ទើបភ្ញាក់ស្មារតីគិតពិចារណាថា ឱ! អញអើយ អញឥតគំនិត ឥតស្មារតី អ្វីមាល្បាយអេះព្រះមហាក្សត្រា ព្រះអង្គប្រើអញមកនិមន្តព្រះរាជបុត្រលោក ម្ដេចឡើយក៏អញបានជាមកបួស បើបួសហើយ ម្ដេចឡើយក៏មកនៅស្ងៀមព្រងើយកន្តើយដូច្នេះហ៎ះ ឱ! អញអើយ ចំណេរទៅឯក្នែកហើយ យល់ជានឹងត្រូវព្រះរាជទណ្ឌនៃព្រះមហាក្សត្រានោះទៀងប្រាកដមិនទេឡើយ ក៏ថាបើដូច្នោះ អញនឹងនៅយូរឯណាបានឡើយ គួរអញនឹងចូលទៅក្រាបថ្វាយបង្គំប្រណម្យព្រះដ៏មានបុណ្យ ហើយសូមអារាធនានិមន្តព្រះអង្គទៅឆាប់ ក៏បានអេះ ៗ ព្រះមហាឧទាយិត្ថេរ គិតពិចារណាស្រេចនូវប្រការអម្បាលណោះហើយ ក៏ចូលទៅក្រាបថ្វាបង្គំប្រណម្យព្រះដ៏មានបុណ្យ ហើយពុំហ៊ានទូលស្មោះន្តោះត្រង់សោះឡើយ ទូលធ្វើជាហេតុបន្តិច ថាភន្តេ ភគវ បពិត្រព្រះដ៏មានបុណ្យប្រសើរអើយ រីខែនេះជាកាលខែហេមន្តរដូវ រីផ្លូវនឹងទៅកាន់កបិលពស្តុបុរីស្រីមហានគរនោះសោត ស្រណុកសុខសប្បាយពណ្ណរាយក្រៃពេក ៗ រីអស់ថ្មើរព្រៃផងទាំងឡាយសោត សឹងដើរត្រាច់រង្គាត់ ច្រវាត់ទៅមករកបរបាញ់ ហើយអុជភ្លើងព្រៃ ដ៏មានប្រឆេះនោះពិដោរ

ឈ្វយឈ្វប់ត្រឡប់ឡើងទៅនាកណ្ដាលអាកាសវេហាស៍ មិនប៉ុន្តែ ម្ល៉ោះសោត វីឈើព្រៃព្រឹក្សាលតាវល្លិ៍ផងទាំងឡាយ សឹងដ៏ដុះ ជាជួររៀងរាយដោយនូវពណ៌ទីទៃៗ សឹងមានដើមនោះល្អ សឹង ដ៏ល្ហូតលាស់លំពង់ ដ៏ទ្រង់នូវមែកសាខាបុប្ផសន្លឹក អធិកនីទៅនូវ ផ្លែផ្កានោះ ដ៏វីកស្គុសស្គាយពណ្ណរាយល្អ បីដូចអ្នកយកសំពត់ទុកូលពស្ត្រ មកគ្របអំពីចុង សំយុងដល់ដើម វីកេសរផ្កាផងទាំងឡាយ នោះសោត ដ៏ពិដោរឈ្វេងត្រឡប់អប់ឡើងទៅដល់នាកណ្ដាល អាកាស បពិត្រព្រះដ៏មានបុណ្យប្រសើរអើយ ថាបើស្ដេចលីលា យាត្រាទៅឥឡូវនេះហើយ សមនឹងជាសុខសប្បាយ វីអស់ភិក្ខុសង្ឃអង្គអរហន្តាខីណាស្រពផងទាំងឡាយនោះ ក៏ច្រើនពេក បពិត្រព្រះដ៏មានបុណ្យប្រសើរអើយ វីផ្លូវនឹងទៅកាន់កបិលពស្ដុបុរី ស្រីមហានគរ ក៏សឹងជាសុខសប្បាយក្រៃពេកហោង ៗ

កាលព្រះដ៏មានបុណ្យព្រះអង្គស្ដាប់ពាក្យព្រះមហាឧទាយិត្ថេរ ទូលដូច្នោះកូវ ព្រះអង្គទ្រង់ព្រះចិន្តាពិចារណាថា ឱវ ឥឡូវនេះ សម្ដេចព្រះវរបិតាអ្នកប្រើព្រះមហាឧទាយិត្ថេរ មកនិមន្តអញតថាគត ហើយហៈហ្ន៎ ថាបើដូច្នោះ គួរអញតថាគតនឹងទៅកាន់កបិលពស្ដុ បុរីស្រីមហានគរបវររាជដ្ឋាន ឱ្យបានដល់យល់សម្ដេចព្រះវរបិតា អញតថាគតហោង ៗ ព្រះដ៏មានបុណ្យ ព្រះអង្គទ្រង់ព្រះចិន្តា ពិចារណានូវប្រការអម្បាលណោះហើយ ទើបព្រះអង្គមានព្រះ បន្ទូលនឹងព្រះមហាឧទាយិត្ថេរថា ម្នាលឧទាយិត្ថេរអើយ ថាបើ

ដូច្នោះ ចូរបាទៅប្រាមប្រាប់បង្គាប់អស់ភិក្ខុផងទាំងឡាយ ឱ្យប្រដាប់ប្រដារអាត្មាទីទៃៗ ឱ្យឆាប់ៗ កុំបីយូរឡើយ ។

ព្រះមហាឧទាយិត្ថេរ ស្តាប់ព្រះបន្ទូលថ្លៃវិសេសនៃព្រះដ៏មានបុណ្យហើយ ក៏ទៅប្រាមប្រាប់អស់ភិក្ខុផងទាំងឡាយថា ម្នាលភិក្ខុផងទាំងឡាយអើយ ឥឡូវនេះ ព្រះដ៏មានបុណ្យ ព្រះអង្គស្តេចនឹងលីលាទៅកាន់កបិលពស្តុបុរីស្រីមហានគរនោះ ឱ្យអស់ភិក្ខុផងទាំងឡាយរៀបប្រដាប់ប្រដាអាត្មាទីទៃៗ កុំបីយូរឡើយ ។

កាលនោះ រីអស់ភិក្ខុផងទាំងឡាយ ស្តាប់ពាក្យព្រះមហាឧទាយិត្ថេរដូច្នោះហើយ សឹងដ៏ប្រដាប់ប្រដាអាត្មាទីទៃ ៗ ស្រេចហើយនៃ ទើបព្រះដ៏មានបុណ្យព្រះអង្គលីលាយាត្រាទៅអំពីនគររាជគ្រឹះបុរី រៀងរាបដរាបទៅដល់កបិលពស្តុបុរី ស្រីមហានគរ ដោយនូវព្រះដំណើរជាបឋម មួយអន្លើនឹងអស់ភិក្ខុសង្ឃ អង្គអរហន្តាខីណាស្រពផងទាំងឡាយនោះ ប្រមាណពីរម៉ឺនជាបរិវារ មានព្រះមហាឧទាយិត្ថេរឯង ជាមគ្គុទ្ទេសក៍ ដ៏វិសេសតែងនឹងនាំផ្លូវព្រះអង្គហោង ។

តទា សក្យរាជានោ មយំ ឥមំ សិទ្ធត្ថកុមារំ អម្ហាកំ ញាតិសេដ្ឋំ បស្សិស្សាមាតិ សន្និបតិត្វា បពិត្រអើយ ព្ទដ៏ កាលនោះ រីអស់ស្តេចសាក្យរាជផងទាំងឡាយ ដ៏ជាព្រះញាតិនឹងព្រះបាទស្រីសុទ្ធោទនមហារាជនោះ ៨ ម៉ឺន ៤ ពាន់ មានព្រះបាទស្រីសុទ្ធោទនៈឯងជាប្រធាន សឹងដ៏មានចំណង់នឹងចង់យល់

ព្រះដ៏មានបុណ្យនោះ ក៏មកជំនុំពិចារណាស្វែងរកឋានលំនៅឱ្យជាឧត្តមសមគួរនឹងឱ្យព្រះអង្គគង់ ទើបមកកត់សម្គាល់ យល់តែឋានចៅនិគ្រោធកុមារនោះឯង ដ៏សុខសប្បាយគាប់ចិត្តប្រពៃហើយនែ ទើបស្តេចឱ្យចូកចាំងជម្រះលុបថ្លុកជង្ហុកប្លៀងរលៀងអំបែងចេះ អំបែងចាន គ្រួសរវានផង់ផុយធូលីដីខ្សាច់ ប្រាប់ឱ្យរាបស្មើ ធ្វើឱ្យប្រពៃស្រេចហើយនែ ទើបឱ្យក្រាលនីទៅនូវកម្រាលចៀមចំព្រែព្រំ ដ៏ទន់ល្មន់ ប្រដាប់ស្រេចហើយ ទើបឱ្យទៅនិមន្តព្រះដ៏មានបុណ្យ ព្រះអង្គលីលាទៅគង់ស្រេចបរិបូណ៌ ព្ធដ៏ក្សិណនោះ ពុំយូរឡើយ ៗ រីអស់ស្តេចសាក្យរាជផងទាំងឡាយ ហេតុមានកំណើតនោះ សឹងមានះរឹងត្អឹងមហិមា ហេតុតែដ៏ជាស្តេចធំសមនូវយសសម្បត្តិនោះច្រើន មកគិតពិចារណាថា ព្រះសិទ្ធាថ៌កុមារនោះ គាត់ក្មេងក្រែលែងនឹងអស់យើងទាំងឡាយអម្បាលណោះ គាត់ជាប្អូន ជាកូនក្មួយ ជាចៅយើងទេកូវ ម្តេចឡើយ យើងនឹងទៅសំពះគាត់នោះយល់ពុំគួរឡើយ ៗ រីអស់ស្តេចសាក្យរាជខ្លះឮហើយឆ្លើយថា ទេ! មិនសំពះគាត់ឯណាក៏បាន មិនដូចគាត់ជាគ្រហស្ថឡើយ គាត់នេះ ជាអ្នកបួស រីធម្មតាជាអ្នកបួសនោះ ទោះចាស់ក្តី ទោះក្មេងក្តី ត្រូវតែសំពះគាត់ដដែលឯងអេះ ថាបើអស់យើងទាំងអម្បាលណោះ មិនសំពះគាត់ហើយ តើគាត់មិនថាយើងមានអំនួតទៅហើយហៈ ៗ អ្នកខ្លះឮហើយឆ្លើយថា អើបើដូច្នោះ អ្នកលងគិតមើល តើយើងនឹងគិតធ្វើដូចម្តេច ឱ្យសមគួរនឹងគាត់ហ៏ៈ ៗ

ស្តេចសាក្យរាជខ្លះឮហើយឆ្លើយថា ទេគំនិតនោះ វានឹងក្រអឺអ្នកទាំងឡាយ វាងាយទេ ៗ អ្នកខ្លះឮហើយឆ្លើយថា អើបើដូច្នោះអ្នកគិតទៅលងមើលអ្នក ថាបើអ្នកប្រើអញគិតហើយ អញគិតក៏បានអេះ នាអញគិតនោះមាន គឺឱ្យរកកុមារប្រុស-ស្រី ឱ្យមានដៃកាន់នីទៅនូវទៀនធូបគន្ធមាលាភ្ញីផ្កា ស្លាម្លូ ស្រេចហើយយើងនឹងឱ្យដំណើរទៅមុន ហើយឱ្យបូជាថ្វាយបង្គំប្រណម្យគាត់ រីអស់យើងសោត សឹងដ៏ដើរតាមដោយចន្លោះលង្វែក ផ្សំច្រឡំនៅក្នុងក្មេងផងទាំងឡាយនោះ តែយើងកុំអាលសំពះគាត់ឡើយ កាលបើស្តេចសាក្យរាជផងទាំងឡាយ ជំនុំនឹងគ្នាព្រមល្មមស្រេចហើយ ក៏ធ្វើដូចព្រះចិន្តាគិតនោះឯងហោង ៗ

ភគវា តេសំ អជ្ឈាសយំ ឱលោកេត្វា ន មំ ញាតយោ វន្ទន្តិ រីព្រះដ៏មានបុណ្យ ព្រះអង្គដឹងអធ្យាស្រ័យនៃចិត្តអស់ព្រះញាតិផងទាំងឡាយ មិនថ្វាយបង្គំប្រណម្យព្រះអង្គដូច្នោះហើយ ក៏ស្តេចទ្រង់ព្រះចិន្តាពិចារណាថា ឱ! ឥឡូវនេះ អស់ព្រះញាតិអញតថាគតនេះ មិនទាន់ដឹងថា អញតថាគត បានត្រាស់ជាព្រះពុទ្ធទេហ្ន៎ ក៏ថាបើដូច្នោះ អញតថាគត នឹងសម្តែងនូវកំណើតប្រាជ្ញាអរិយសប្បុរសឱ្យប្រាកដ ដូចព្រះពុទ្ធអំពីបុរាណរៀងមក ឱ្យស្តេចសាក្យរាជទាំងឡាយថ្វាយបង្គំប្រណម្យអញតថាគត ក្នុងកាលឥឡូវនេះឯងហោង ៗ ព្រះដ៏មានបុណ្យ ព្រះអង្គទ្រង់ព្រះចិន្តាពិចារណាស្រេចនូវប្រការអម្បាលណោះហើយ ទើបស្តេចចូល

ចតុត្ថជ្ឈានអភិញ្ញាសមាបត្តិ ហោះផ្លោះឡើងទៅ នាកណ្តាលអាកាស ដ៏ឱភាសនូវពន្លឺរស្មីនោះរុងរឿងភ្លឺព្រោងព្រាយពណ្ណរាយឆាឆាយក្តួចគ្រលួចឡើង ចេញអំពីព្រះបាទទាំងពីរ យល់ដូចផង់ផុយធូលីដីខ្សាច់ គិតដ៏អ្នកប្រាយរាយចុះមកលើព្រះកេសស្តេច សាក្យរាជទាំងឡាយ ប្រហែលដូចកាលព្រះអង្គ ធ្វើយមកបាដិហារិយ៍ ឮដ៏នាដើមគណ្ឌាម្ពព្រឹក្ស អធិកនូវព្រះរស្មី ឱ្យដំបូន្មានអន្សត្តិរ្តិយនោះ ឯងហោង ៗ

តទា សុទ្ធោទនមហារាជា តំ អច្ឆរិយំ ទិស្វា អាហ
ឮដ៏កាលនោះ ព្រះបាទស្រីសុទ្ធោទនមហារាជដ៏ជាសម្តេចព្រះវរបិតាធិរាជ យល់ជាអស្ចារ្យប្រាកដដូច្នោះកូវ ពុំអាចដើម្បីនឹងទប់ទល់តម្កល់ព្រះអង្គនោះបានឡើយ សឹងដ៏លើកកម្បង់អញ្ជលី ដាក់លើព្រះកេសវិសេសថ្វាយបង្គំប្រណម្យព្រះដ៏មានបុណ្យ ហើយសរសើរគុណបុណ្យព្រះសម្ភារបារមីថា **ភន្តេ ភគវា** បពិត្រព្រះដ៏មានបុណ្យប្រសើរអើយ កាលនោះ មានមហាឫសីមួយឈ្មោះ **កាឡទេវិលជដិលតាបស** អ្នកមានរិទ្ធីអានុភាពនោះច្រើនក្រៃលែង នាកាលសម័យថ្ងៃព្រះអង្គកើតនោះឯង អស់មេនំផងទាំងឡាយ វានាំព្រះអង្គចេញមកប្រយោជន៍ ដើម្បីនឹងឱ្យនមស្ការថ្វាយបង្គំ សូមពរអំពីកាឡទេពិលជដិលមហាឫសីនោះ ក៏ព្រះអង្គមិនថ្វាយបង្គំឡើយ វិលប្រែក្រឡាប់ឡើងទៅគង់លើក្បាលមហាឫសីនោះវិញហោង ៗ បពិត្រអើយ ខ្ញុំយល់ជាអស្ចារ្យប្រាកដដូច្នោះហើយ

ខ្ញុំថ្វាយបង្គំប្រណម្យព្រះអង្គជាបឋមហោង ៗ មួយសោត កាលថ្ងៃច្រត់ព្រះនង្គ័ល ជាមង្គលអំពល់នូវសុខសួស្តីប្រសើរ កបនូវដំណើរឫក្សពារពេលាឆាយាប្រពៃ នាថ្ងៃនោះឯង មេនំផង វានាំព្រះអង្គទៅផ្ទំលើគ្រែក្រឡាព្រះបន្ទំបរមសុខសួស្តី នាក្រោមម្លប់ជម្ពូព្រឹក្សនោះ ៗ រីស្រមោលជម្ពូព្រឹក្សនោះសោត ពុំជ្រេជ្រៀងល្អៀងទៅដោយនូវដំណើរព្រះអាទិត្យនោះឡើយ(១) ខ្ញុំយល់អស្ចារ្យ កាលនោះ ខ្ញុំថ្វាយបង្គំប្រណម្យព្រះអង្គជាគម្រប់ពីរដង ៗ ហើយឥឡូវនេះវិញសោតទៀត អំពីមុនមក ខ្ញុំពុំដែលបានយល់នូវយមកបាដិហារិយ៍ត្រកាលជាអស្ចារ្យដូច្នេះទេ ទើបខ្ញុំថ្វាយបង្គំព្រះអង្គ ជាគម្រប់បីដងហោង ៗ កាលណាបើព្រះបាទស្រីសុទ្ធោទនមហារាជលើកកម្បង់អញ្ជលីថ្វាយបង្គំប្រណម្យហើយ សូម្បីស្តេចសាក្យរាជឯណាមួយ នឹងទប់ទល់តម្កល់ចិត្តរឹងត្អឹងមិនព្រមថ្វាយបង្គំប្រណម្យព្រះអង្គនោះ ឥតអង្គីមានឡើយ ៗ

និសិន្នេ បន ភគវតិ សិក្ខប្បត្តោ ញាតិសមាគមោ អហោសិ ៗ សព្វេបិ ឯកគ្គចិត្តា ហុត្វា និសីទឹសុ ៗ រីសម្តេចព្រះស្រីសពេ៌ជ្ញូតាញាណ ព្រះអង្គឱ្យដំបូន្មានអស់ព្រះញាតិផងទាំងឡាយ ឱ្យបានថ្វាយបង្គំប្រណម្យព្រះអង្គនូវប្រការអម្បាលណោះហើយ ទើបព្រះអង្គហោះចុះមកអំពីកណ្តាលអាកាស ស្តេច

១- ច្បាប់ខ្លះថា ពុំជ្រៀងជ្រេរសៀលរៀលអំពីក្រឡាបន្ទំ តាមដោយនូវដំណើរព្រះអាទិត្យនោះឡើយ ៗ

មកគង់លើគ្រែបវរពុទ្ធាសនាក្រឡាសម្រាប់ គិតដ៏អ្នកប្រដាប់ក្រាលនូវកម្រាលផងប្រពៃ ឰដ៏កណ្ដាលជំនុំអស់ព្រះញាតិផងទាំងឡាយ សឹងលុះដោយនូវដំបូន្មានព្រះអង្គ ក្នុងកាលនោះហោង ៗ ឰដ៏កាលនោះ រីអស់ស្ដេចសាក្យរាជផងទាំងឡាយ សឹងដ៏មានព្រះរាជហឫទ័យនោះត្រេកអរសាទរព្រមជាមួយនឹងគ្នា ៗ អណ្ដាប់នោះមហាមេឃឯង ក៏បង្អុរនូវភ្លៀងសួគ៌មួយឈ្មោះ **បោក្ខរវស្សំ** ជាអស្ចារ្យកណ្ដាលជំនុំព្រះញាតិផងទាំងឡាយ ថាបើអ្នកឯណាចង់ទទឹក អើក៏ភ្លៀងនោះទទឹក ថាបើអ្នកឯណាពុំចង់ទទឹក អើក៏ភ្លៀងនោះពុំជិតដល់សុរិលអ្នកនោះដល់តិចឡើយ ៗ

តំ ទិស្វា សព្វេ អច្ឆរិយព្ភុតជាតា អហេសុំ កាលនោះអស់មហាជនផងទាំងឡាយ យល់អស្ចារ្យប្រាកដកើតមានដូច្នោះហើយ សឹងសរសើរព្រះបារមីនៃព្រះដ៏មានបុណ្យថា ឱ! ព្រះពុទ្ធអើយ ព្រះអង្គមានព្រះបារមីរិទ្ធីអានុភាពច្រើន អ្វីមាល្បាយអេះ ភ្លៀងបង្អុរចុះមកអំពីកណ្ដាលអាកាស ធ្លាក់ចុះទៅនាកណ្ដាលជំនុំព្រះញាតិផងទាំងឡាយ អ្នកឯណាចង់ទទឹក អើក៏ភ្លៀងនោះទទឹក អ្នកឯណាពុំចង់ទទឹក អើក៏ភ្លៀងនោះពុំទទឹកឡើយ ដូចទឹកធ្លាក់ទៅលើស្លឹកឈូកហោង ៗ

តេ ភិក្ខូ ធម្មសភាយំ កថំ សមុដ្ឋាបេសុំ ឰដ៏កាលនោះ រីអស់ភិក្ខុផងទាំងឡាយ បប្ចូលគ្នាទៅជំនុំ នៅឰដ៏ធម្មសភា-

សាលា ថា(១) **អាវុសោ** ម្នាលភិក្ខុផងទាំងឡាយអើយ រីព្រះដ៏មានបុណ្យជាអម្ចាស់យើងនេះ ព្រះអង្គមានរិទ្ធីអានុភាពច្រើនជាអស្ចារ្យ ព្ធដ៏លោកនេះអ្វីមាល្បាយអេះ អំពីមុនមក ពុំដែលយល់ដូច្នេះ ក៏ឥឡូវនេះ មហាមេឃឯង បង្អុរនូវភ្លៀងបោក្ខរព័ស៌ ជាអស្ចារ្យ នាកណ្តាលជំនុំព្រះញាតិនោះឯង ។

តំ សុត្វា សត្ថា កាយនុត្ថ ភិក្ខវេ ឯតរហិ កថាយ សន្និសិន្នាតិ បុច្ឆិត្វា រីពត៏មានអស់ភិក្ខុផងទាំងឡាយនោះ មិនបាត់ស្ងាត់ ប៉ុន្តែប្រលុងក្នុងធម្មសភាសាលានោះឡើយ ក៏ព្រួជ្រួតជ្រាប ដរាបទៅដល់ព្រះស្រោត្រទិព្វថ្លៃនៃព្រះដ៏មានបុណ្យ ព្រះអង្គជ្រាប ដោយនូវអស់អាថ៌សេចក្តីនៃភិក្ខុផងទាំងឡាយនោះហើយ ស្តេចទ្រង់ព្រះចិន្តាពិចារណាថា **ខោ** ឥឡូវនេះ អស់ភិក្ខុផងទាំងឡាយ បប្អូលគ្នាទៅជំនុំ នៅនាធម្មសភាសាលា សឹងស្រដីសរសើរអំពីប្រាជ្ញាបារមីនៃអញតថាគតនេះហ្ន៎ ក៏ថាបើដូច្នោះ អញតថាគតនឹងទៅស្តាប់ជំនុំនៃភិក្ខុផងទាំងឡាយបន្តិចក៏បានអេះ ថាបើ អញតថាគត មិនទៅស្តាប់ជំនុំនៃភិក្ខុសង្ឃផងទាំងឡាយឥឡូវនេះហើយ ក៏នាកាលអញតថាគតយោនយកកំណើត កើតជាពោធិសត្វ មុនមួយព្រះអង្គ ទ្រង់ព្រះនាមករណីបវរឈ្មោះ ថា **មហាវេស្សន្តរ**

១- មានច្បាប់ខ្លះពិស្តារបន្តិចទៀតថា មានភិក្ខុចាស់អង្គ ១ ឋិតនៅជាដើមអាសន៍ ស្រដីបណ្តាលនូវពាក្យនោះ ទៅនឹងភិក្ខុកំឡោះទាំងឡាយថា...។

នោះនឹងកំបាំងបាត់ស្វាត់ ពុំឆ្ងាយទូលាយទៅឯក្អែកឡើយៗ ព្រះដ៏បុណ្យ ព្រះអង្គទ្រង់ព្រះចិន្តាពិចារណានូវប្រការអម្បាលនោះហើយ ទើបស្តេចលីលាមកអំពីព្រះសុគន្ធកុដីស្រីមហាវិហារ ទៅកាន់ធម្មសភាសាលា ដ៏មានព្រះដំណើរសីហនាទគតាត ឥតភ្លឹក បីដូចកេសររាជសីហ៍ចេញអំពីគុហាមាស ឰដ៏កណ្តាលពួកម្រឹគគណនិករផងទាំងឡាយ នោះមានប្រការម្តេចមិញ ក៏ស្តេចទៅគង់លើគ្រែអាសនាក្រឡាសម្តេច មានឰដ៏កណ្តាលជំនុំចតុព្វិធបរិសទ្យទាំង៤ចំពូក ព្រះអង្គមានព្រះបន្ទូលប្រកបនូវព្រះសូរមធូរជ្រៅជ្រះស្រឡះពីរោះស្មោះស្មើ ដណ្តឹងទៅកាន់ភិក្ខុទាំងឡាយថា **ភិក្ខវេ** ម្ចាលភិក្ខុទាំងឡាយអើយ នាអ្នកទាំងឡាយមកជំនុំគ្នានៅនេះ តើស្រដីដោយនូវពាក្យអ្វីនោឡ្យា ឰដ៏ធម្មសភាសាលានេះ ក៏មិនដោះដាលត្រូវអាលឡើងទៅរកចម្រើនមេត្តាភាវនា វិបស្សនាកម្មដ្ឋានឱ្យបានមគ្គផល ដល់សម្បត្តិព្រះនិព្វាន ដ៏ជាឋានពំនាក់អាត្មាទីទៃ ៗ ហ៊ឹះ ៗ

ឥមាយ នវមាវតិ ខុត្តេ ទើបអស់ភិក្ខុផងទាំងឡាយក្រាបថ្វាយបង្គំប្រណម្យទូលថា **ភន្តេ ភគវា** បពិត្រព្រះដ៏មានបុណ្យប្រសើរអើយ វីអស់យើងខ្ញុំមកជំនុំគ្នា នៅនាធម្មសភាសាលានេះមិនគឺនឹងស្រដីនូវឥត្ថីភាពបុរិសភាព ឱ្យជាមន្ទិលក្នុងព្រះសាសនាព្រះអង្គនេះឡើយ សឹងតែស្រដីសរសើរដំណើរអំពីព្រះបារមី ថ្លៃនៃព្រះអង្គឯង ត្បិតមានភ្លៀងបោក្ខរព័ស៏ បង្អុរចុះមក ជាអស្ចារ្យក្រៃ

ដូចន័យព្រះអង្គជ្រាបក្នុងព្រះរាជហឫទ័យស្រាប់នោះឯង ។ ព្រះដ៏មានបុណ្យព្រះអង្គជ្រាបហើយ មានព្រះបន្ទូលថា ម្នាលភិក្ខុទាំងឡាយអើយ នាភ្លៀងបោក្ខរព័ស៏នេះ មិនប៉ុន្តែឥឡូវនេះឡើយ នាកាលតថាគតយោនយកកំណើតកើតជាពោធិសត្វមួយអង្គ ទ្រង់ព្រះនាមករណ៍បវរហៅថា *មហាវេស្សន្តរ* នោះ ក៏មហាមេឃឯងបង្អុរនូវភ្លៀងបោក្ខរព័ស៏ ជាអស្ចារ្យក្រៃ ឮដ៏កណ្តាលជំនុំព្រះញាតិផងទាំងឡាយ នោះក៏អស្ចារ្យក្រៃអេះ ត្បិតប្រាជ្ញាមិនទាន់ចាស់បារមីពុំទាន់ទុំ ក៏ឥឡូវនេះ តថាគតបានត្រាស់ប្រាជ្ញាសពើជ្ញូតាញាណជាព្រះពុទ្ធហើយ វិស័យដូចព្រះពុទ្ធអំពីមុនរៀងមក តែងនឹងមានបារមីដូច្នេះឯង ។

ទត្វា តុណ្ហី អហោសិ ព្រះអង្គមានព្រះបន្ទូលតែមួយព្រះឱស្ឋពីរព្រះឱស្ឋដូច្នោះហើយ ព្រះអង្គគង់ស្ងៀមទៅវិញហោង① ។

---

① - តអំពីនេះទៅ សេចក្តីបុច្ឆា-វិសជ្ជនា តែមិនមានក្នុងបាលីអដ្ឋកថាជាតកទេ មានតែក្នុងច្បាប់មហាជាតក៏សម្រាយដូច្នោះថា

បុច្ឆាចារ្យ ចោទដណ្តឹងសួរថា អើ! អ្នកអើយ នាព្រះដ៏មានព្រះភាគ មានព្រះបន្ទូលតែមួយព្រះឱស្ឋពីរព្រះឱស្ឋដូច្នោះហើយ ក៏ព្រះអង្គគង់នៅស្ងៀមវិញ តើជាធម៌ទេសនាព្រះអង្គអស់តែម្លេះឯងហើយ ឬហៈ ។

វិសជ្ជនាចារ្យ ឮហើយ ឆ្លើយថា ទេ! ធម៌ទេសនាព្រះអង្គ ៨ ម៉ឺន ៤ ពាន់ អ្វីឡើយ ក៏នឹងទៅចេះអស់ងាយដោយដូច្នោះហៈ ។

-អើថា បើមិនចេះអស់ដូច្នោះទេ តើជាព្រះអង្គខ្ជិលឬអ្វីហៈ ។ ឆ្លង...

តេហិ យាចិតោ អតីតំ អាហរិ អណ្តាប់នោះ អស់ភិក្ខុផងទាំងឡាយ ដឹងហេតុព្រះដ៏មានបុណ្យនូវប្រការអម្បាលណោះហើយ សឹងមានចំណង់នឹងចង់ស្តាប់ព្រះធម៌វិសេសទេសនានោះ ហើយទើបនាំគ្នាលុតជង្គង់លើកកម្បង់អញ្ជលីដាក់លើសិរសាអាត្មាភាព ក្រាបថ្វាយបង្គំប្រណម្យទូលថា **ភន្តេ ភគវា** បពិត្រព្រះដ៏មានបុណ្យប្រសើរអើយ ព្រះអង្គមានព្រះបន្ទូលអម្បាញ់មិញនោះថា នាកាលព្រះអង្គ យោនយកកំណើត កើតជាព្រះពោធិសត្វ ១ ព្រះអង្គ ទ្រង់ព្រះនាមព្រះមហាវេស្សន្តរនោះ អស់យើងខ្ញុំ គ្រាន់តែបានឮព្រះបន្ទូលអម្បាលណោះ វីនឹងដឹងជាតិសន្តានកន្លងរំលង ទៅហើយនោះ យើងខ្ញុំពុំទាន់ដឹងឡើយ បពិត្រព្រះដ៏មានបុណ្យអើយ សូមព្រះអង្គយកព្រះប្រាជ្ញាទិព្វវិសេសមួយឈ្មោះបុព្វេនិវាសានុស្សតិញ្ញាណទៅឱបក្រសោបអស់ធម៌ផងទាំងឡាយ ដែលកន្លងរំលងទៅហើយនោះ នាំមកសម្តែងថ្លែង ទេសនាជាសណ្តាប់ប្រាប់ អស់យើងខ្ញុំទាំងអម្បាលណេះហោង ៗ

ព្រះដ៏មានបុណ្យ ព្រះអង្គជ្រាបហើយ ព្រះអង្គនឹងនាំនូវព្រះធម៌វិសេសទេសនាឱ្យជាសណ្តាប់ ប្រាប់សម្តេចព្រះវរបិតា នូវអស់ព្រះញាតិផងទាំងពួង នូវអស់ភិក្ខុសង្ឃអង្គអរហន្តាខីណាស្រពផង

- ព្រះអង្គមិនខ្ជិលទេ តែព្រះអង្គគង់នៅស្ងៀមនោះ បទព្រះអង្គចង់ឱ្យភិក្ខុផងទាំងឡាយក្រាបទូលអារាធនាព្រះអង្គទេតើ ៗ

ទាំងឡាយ ឱ្យឆ្ងាយកន្លងរំលងទៅនោះ ក៏ព្រះអង្គបើកព្រះឱស្ឋរត្ត បន្ទូល ដ៏មានព្រះសូរនោះមូលក្រាងក្រអៅជ្រៅជ្រះស្រឡះពីរោះ ឧបមាបីដូចសំឡេងព្រហ្ម ទ្រង់សូត្រនូវបទព្រះបាលីដូច្នេះថា (១)

អតីតេ ភិក្ខវេ សិវិរដ្ឋេ ជេតុត្តរនគរេ សិវិមហារាជា(២) **នាម រជ្ជំ ការេន្តោ សញ្ជយំ នាម បុត្តំ បដិលភិ** ភិក្ខុអើយ នាកាលភព្តន្តរខណ្ឌកប្បកល្បខាំងកំបាំងបាត់ស្វាត់កន្លង រំលងទៅហើយនោះ កាលនោះ មានព្រះមហាក្សត្រាធិរាជ មួយព្រះអង្គ ទ្រង់ព្រះនាមករណ៍បវរថាព្រះបាទ**សិវិមហារាជ** សោយរាជសម្បត្តិបិតនៅមួយអន្លើនឹងព្រះរាជទេពីស្រីព្រះស្នំក្រមការបរិពារផង ទាំងឡាយ នៅឰដ៏កំឡុងស្រុកជេតុត្តរនគរ ។ ភិក្ខុអើយ រីព្រះមហាក្សត្រាធិរាជនោះសោត មានព្រះរាជបុត្រមួយព្រះនាម ចៅ**សញ្ជ័យកុមារ** លុះចៅសញ្ជ័យកុមារនោះ ចម្រើនព្រះជន្មឡើងបាន ១៦ វស្សាបរិបូណ៌ហើយ ទើបព្រះបាទសិវិមហារាជ ស្តេចឱ្យទៅនាំព្រះរាជបុត្រីស្រីវ័ត្ថកញ្ញានៃព្រះបាទមទ្ទរាជអំពីមាតុលនគរ ព្រះ

១- មានច្បាប់ខ្លះ មានសេចក្តីខ្លីថា " ព្រះដ៏មានបុណ្យ ព្រះអង្គទទួលយកនិមន្តន៍អស់ភិក្ខុផងទាំងឡាយនោះហើយ ទើបព្រះអង្គថ្លែងសម្តែងព្រះធម៌វិសេសទេសនាជាសណ្តាប់ ប្រាប់អស់ភិក្ខុផងទាំងឡាយ បន្ទូលសូត្រជាបទព្រះបាលីដូច្នេះ អតីតេ ... " ដូច្នេះក៏មាន ។

២- ច្បាប់ខ្លះថា " . . . សិវីមហារាជា នាម រជ្ជំ ការេសិ " ដូច្នេះក៏មាន ។

នាមព្រះនាង សុធារសុប្បតី (១) យកមកផ្សំនឹងចៅសញ្ជ័យកុមារ អភិសេកឱ្យសោយរាជសម្បត្តិស្នងគ្រងប្រពៃណីអំពីបុរាណ សម្តេចព្រះវររាជបិតាធិរាជតម្កល់ព្រះនាងឱ្យជាឧត្តម កន្លងក្រៃលែងអស់ស្រីព្រះស្នំផងទាំងឡាយ មួយម៉ឺនប្រាំមួយពាន់នោះឯងហោង(២) ។

តស្សាបិ អយំ បុព្វប្បយោគោ ។ ឥតោ ហិ ឯកនវុតិកប្បាវសានេ វិបស្សី នាម សត្ថា លោកេ ឧទបាទិ ។

បពិត្រអើយ នេះនឹងស្រដីសរសើរដំណើរដំណាល កាលព្រះនាងសុបារសុប្បតីទេវីសាងបារមីអំពីជាតិមុន ឱ្យប្រាកដប្រកប ជួបចូលមិត្តមូល មកនិយាយបទឯចុងនេះវិញ ។ នាកាលអំណើះកប្បទាំងឡាយកន្លងរំលងទៅហើយ រាប់ថយក្រោយទៅបាន ៩១ កប្ប រៀងរាបដរាបមកដល់ភទ្ទកប្បយើងនេះ កាលនោះ មានព្រះពុទ្ធមួយព្រះអង្គ ទ្រង់ព្រះនាមករណ៍បវរឈ្មោះព្រះពុទ្ធវិបស្សីសិរីសម្មាសម្ពុទ្ធ ស្តេចបានត្រាស់សព៌ជ្ញូតាញាណ ពុទ្ធដ៏លោកនេះ ព្រះអង្គនាំព្រះធម៌វិសេសទេសនាប្រោសសត្វផងទាំងឡាយ ឱ្យបានមគ្គផលដល់សម្បត្តិសួគ៌សម្បត្តិនិព្វានដ៏ជាឋានក្សេមប្រសើរ ហើយស្តេចគង់នៅពុទ្ធដ៏ព្រៃខេមមិគទាយពន (៣) ស្តេចអាស្រ័យយកព្រះ

១- ពាក្យនេះតាមស័ព្ទបាលីថា " ផុស្សតី កុមារី " ។ ២- ឯចំនួន " មួយម៉ឺន ៦ ពាន់ " នេះ មិនមានក្នុងច្បាប់បាលី ឬអដ្ឋកថានៃវេស្សន្តរជាតកនេះឡើយ ។ ៣- សេចក្តីពណ៌នាសរសើរអំពីព្រៃខេមមិគទាយពន

ឆ្លង ...

បិណ្ឌបាតសង្ខាតសន្តោសប្រោសសត្វផងទាំងឡាយ នៅព្ឋដ៏ស្រុកពន្ធុមតី ស្រីមហានគរបវររាជដ្ឋាន ។

តទា ពន្ធុមតីនគរេ ពន្ធុមោ នាម រាជា រជ្ជំ ការេសិ ។ តស្មឹ ពន្ធុមតីនគរំ ឧបនិស្សាយ ខេមេ មិគទាយេ វិហរន្តេ តស្មឹ កាលេ ឯកោ រាជា រញ្ញោ

ដូចមាននយលក្ខណៈខាងក្រោមនេះ ទាំងបាលីទាំងសម្រាយ មិនមានក្នុងច្បាប់អដ្ឋកថាជាតកបាលីទេ មានតែក្នុងច្បាប់មហាជាតក៏សម្រាយខ្លះដូច្នេះ ៖

មិគទាយវនរុប្ប ទស្សនីយា មនោរម្មា នានាវិហារបក្ខីនំ សព្វទា ភគ្គសោភនំ ។ កិក្ខុអើយ វីព្រៃខេមមិគទាយពននោះសោត ដ៏មានពណ៌នោះល្អមហិមា មុខគួរឱ្យពិតពិលរមិលមើលយល់ល្អ ដ៏ស្រណុកសុខសប្បាយពណ្ណរាយ ដ៏ជាលំនៅនៃសត្វបក្សីផងទាំងឡាយផ្សេង ៗ ដ៏ជាដើម គឺ ៖ ខ្លែង, ទុង, ទោម, ក្ង, ក្ងោក, ប៉ោលតោក, តាវ៉ៅ, ស្វិតចៅ, ដ៏ច្រឡំនីទៅនូវ មាន់ទឹក, ប្រវឹក, មាន់ទោ, ទទា, ក្រសារ, ហង្ស, ក្រួច, ក្រៀល, ចង្កៀលខ្យង, ត្រយង, កងកេង, សូរស័ព្ទសំឡេងពិរោះសោះសា មាន ត្រុម, ត្លុម, តាដក់, ក្ក, ជីវក, ជីវាក, ចាក្រពាក, វនាល, សារិកា, សេកសោម, សេកយា, មានប្រការនោះផ្សេង ៗ ។ ឯចំណែកភូមិឋាននោះសោត ក៏រាបស្មើប្រពៃក្រៃពេក ដ៏ប្រកបនូវស្រះបោក្ខរណីផង ដ៏មានឆ្នេរនោះត្រង់ មានកំពង់នោះរាបស្មើ អធិកពន្លឹកដ៏មានទឹកនោះជ្រៅជ្រះ ត្រចះថ្លា ដ៏មានផ្កាកុមុទ, ឧត្បល, លំចង់, ស្បង្កំជ, សឹងដ៏រំលេចនូវឈូកស ឈូកច្រាល ណាស់ណាន់តាន់តាប់ ដ៏ប្រដាប់នូវដើមឈើផងទាំងឡាយ ជាដើមគឺ ស្វាយ, ខ្វិត, ក្រសាំង, ខ្នុរណាំង, ខ្នុរបាយស្រា, ព្នៅ, បង្កៅ, ពង្រ, ដកពណ៌, កណ្ណិការ, ពពូល, សត្បារ, ថ្នរ, ញរ, ធ្នង់, ក្លែងគង់, បាយម៉ាត, ប៉ាំងចចាត, ត្នាតទ្រាន, ស្តៅ, ស្តាន់, ទ្រា, ទហឹង, កំភ្លឹង, កន្ទុត,

ឆ្លូង ...

ពន្ធុមស្ស អនគ្ឃេន ចន្ទនសារេន សទ្ធឹ សតសហស្សគ្ឃនិកំ សុវណ្ណមាលំ បេសេសិ ឰដ៏កាលនោះ មានព្រះមហាក្សត្រាធិរាជ ១ ព្រះអង្គទ្រង់ព្រះនាមព្រះបាទពន្ធុមរាជ សោយរាជសម្បត្តិ ឋិតឰដ៏ស្រុកពន្ធុមតីស្រីមហានគរនោះ ៗ កាលនោះសោត មានព្រះមហាក្សត្រាធិរាជមួយព្រះអង្គទៀត ជាស្ដេចទ្រង់ព្រះនាមព្រះបាទសាមន្តរាជ(១) ស្ដេចឱ្យរាជអាមាត្យមួយនាក់យកសុពណ៌មាលា

ក្រកោះ, លំពោះ, លំពាន់, ក្រវាន់, ត្រៀលស្វា, ហរ, ស្លែង, ភ្នីភ្នែង, ច្រកែងទូយ, ជ្រួយ, ខ្ទះ, ច្រមះ, ស្កុកស្កុរ, បុសនាគ, សំយាកសំយុង ដ៏ទ្រង់នីទៅនូវផ្លែផ្កាសន្លឹក អធិកនូវមែកនោះសាខាលូតលាស់ខៀវខ្ចី ៗ រីឯឈើផងទាំងឡាយដទៃក្រៃលែងអំពីនោះទៅ សឹងជាអនេកអនន្ត នឹងគណនាត្រារាប់ពុំអស់ឡើយ ហើយសឹងដ៏ដុះជាជួររៀបរៀងដោយនូវកំពែងថ្នល់មណ្ឌលស្រះ សឹងមានដើមនោះមូលសសូលត្រង់ល្អ ហើយកបនូវមែកសាខាបុប្ផាសន្លឹក លូតលាស់លំពង់ដ៏ទ្រង់នូវផ្លែផ្កានោះ រីកស្គុសស្គាយពណ្ណរាយ ល្អអំពីដើមដរាបដល់ចុង ហាក់បីដូចអ្នកចងក្រងសំយុងព្យួររំយោលចុះមក ដ៏មានក្លិននោះពិដោរផុំហួង ស្រឡប់ទាំងទិសានុទិសទាំងឡាយ ៗ មួយសោត រីមនុស្សទេវតាឯណាមួយ ថាបើមានទុក្ខដល់ ១០០ ឆ្នាំ បើបានចូលទៅដល់យល់ដងព្រៃនោះហើយ រីអស់ទុក្ខសោកទាំងអម្បាលណោះ ក៏សឹងរសាយរលាយបាត់អស់ សឹងកើតជាស្រណុកចិត្តក្រៃពេកវិញហោង ៗ

១- ក្នុងច្បាប់ជាតកបាលី មិនប្រាកដព្រះនាមស្ដេចនេះទេ គ្រាន់តែពោលថា " ឯកោ រាជា " ប្រែថា " ស្ដេច ១ អង្គ " ប៉ុណ្ណោះ តែច្បាប់សម្រាយសុទ្ធតែចេញឈ្មោះថា " ព្រះបាទសាមន្តរាជ " ទាំងអស់ ប្រហែលមិនមែនជាព្រះនាមស្ដេចណានីមួយទេ គ្រាន់តែជាព្រះនាមសម្រាប់សម្គាល់ដល់ស្ដេច ដែលនៅនគរជិតខាង ៗ

ដ៏មានតម្លៃនោះមួយសែនតម្លឹង មួយអន្លើនូវខ្លឹមច័ន្ទន៍ សឹងដ៏មានតម្លៃនោះច្រើន ឱ្យនាំមកថ្វាយព្រះបាទពន្ធុមរាជ ៗ រីព្រះបាទពន្ធុមរាជសោត ស្តេចមានព្រះរាជបុត្រីស្រីកញ្ញានោះពីរព្រះអង្គ ហើយទ្រង់ព្រះរាជទានខ្លឹមច័ន្ទន៍នោះទៅព្រះរាជបុត្រីដ៏ជាច្បង រីសុពណ៌មាលាមាសនោះ ស្តេចព្រះរាជទានឱ្យទៅព្រះរាជបុត្រីដ៏ជាប្អូន ៗ ឯព្រះរាជកុមារីទាំងពីរអង្គនោះសោត មកគិតពិចារណានឹងគ្នាថា នាងអើយ រីខ្លឹមច័ន្ទន៍និងសុពណ៌មាលាមាសនេះ សម្តេចព្រះវរបិតាអ្នកប្រទានមកយើងនេះ ឯគ្រឿងប្រដាប់ទាំងនេះ មិនគួរបីបើយើងនឹងប្រដាប់សម្រាប់អាត្មានៃយើងឡើយ ថាបើដូច្នោះយើងនឹងយកទៅថ្វាយបូជាព្រះដ៏មានបុណ្យវិញ នោះជាគុណបុណ្យប្រសើរពេកហោង ៗ រីព្រះរាជកញ្ញាទាំងពីរគិតពិចារណានូវប្រការអម្បាលណោះហើយកូរ ក៏ចូលទៅក្រាបទូលសម្តេចព្រះវររាជបិតាថា បពិត្រសម្តេចព្រះវរបិតានៃយើងខ្ញុំ ទាំងពីរអើយ នាខ្លឹមច័ន្ទន៍និងសុពណ៌មាលាមាសនេះ យើងខ្ញុំម្ចាស់ទាំងពីរនេះចង់យកទៅថ្វាយបូជាព្រះដ៏មានបុណ្យវិញ ៗ រីព្រះមហាក្សត្រាធិរាជ ស្តាប់ពាក្យនាងកញ្ញាទាំងពីរនូវប្រការអម្បាលណោះហើយស្តេចមានព្រះរាជហឫទ័យនោះពេញនូវក្តីអំណរអរទទួលយកពាក្យព្រះរាជធីតា ហើយទ្រង់អនុមោទនាថា សាធុ ៗ ពីរោះ ៗ ពេកថាបើដូច្នោះ ចូរនាងយកទៅថ្វាយបូជាព្រះពុទ្ធវិបស្សីនោះ ជាបុណ្យប្រសើរក្រៃពេកហោង ៗ រីព្រះរាជកញ្ញា ដ៏ជាច្បងនោះ

ត្រាស់ប្រើរាជអាមាត្យមួយឱ្យយកខ្លឹមច័ន្ទន៍នោះទៅបុកឱ្យល្អិតជាផង់ធូលីប្រពៃហើយនៃ ឱ្យដាក់ក្នុងប្រអប់មាស ឱ្យស្រីសៅដៃមួយជាអ្នកកំណាន់កាន់ប្រអប់មាសនោះ ។ រីឯនាងកញ្ញាដ៏ជាប្អូននោះសោត ក៏ឱ្យយកសុពណ៌មាលាមាស ឱ្យទៅជាងរចនាធ្វើជាគ្រឿងប្រដាប់ព្រះឱរា ហើយទុកក្នុងប្រអប់មាសប្រពៃហើយនៃ ឱ្យស្រីសៅដៃមួយជាអ្នកកំណាន់កាន់រក្សាស្រេចហើយ ទើបព្រះរាជកញ្ញាទាំងពីរនោះលីលាយាត្រាចេញអំពីប្រាសាទព្រះរាជមន្ទីរ មួយអន្លើនូវអស់បរិវារស្រីផងទាំងឡាយនោះច្រើន ស្មោះឆ្ពោះមុខទៅកាន់ព្រៃខេមមិគទាយពនមហាវិហារនោះហោង ។ រីព្រះរាជកញ្ញាដ៏ជាច្បងនោះ នាងថ្កមប្រអប់មាសខ្លឹមច័ន្ទន៍ ចូលទៅថ្វាយបូជាព្រះពុទ្ធវិបស្សី ហើយនាងលាបស្រលាប អស់ទាំងគ្រែក្រឡាបន្ទំបរមសុខសួស្តី ក្នុងព្រះសុគន្ធកុដីនោះ រីសំណល់សល់អំពីនោះសោត នាងឱ្យលាបស្រលាបអស់ទាំងសសរស្តម្ភព្រះសុគន្ធកុដីស្រីមហាវិហារនោះ ទើបនាងធ្វើប្រណិធានសូត្រជាបាទព្រះគាថាដូច្នេះថា

ឯសា ចន្ទនចុណ្ណេន បូជា តុម្ហេសុ មេ កតា
តុម្ហានិសស្ស ពុទ្ធស្ស មាតា ហេស្ស អនាគតេតិ ។

ភន្តេ ភគវា បពិត្រព្រះដ៏មានបុណ្យប្រសើរអើយ ហេតុតែតែជះផលអានិសង្សនៃអញខ្ញុំម្ចាស់ យកលម្អិតខ្លឹមច័ន្ទន៍ មកថ្វាយបូជាព្រះអង្គនេះ លុះអនាគតកាលទៅឯក្នែក ខ្ញុំសូមឱ្យបានជាព្រះកន្លោងព្រះពុទ្ធ ប្រាកដមានសភាពដូចព្រះអង្គនេះឯងហោង ។

រីនាងកញ្ញា ដ៏ជាប្អូននោះសោត នាងចូលទៅបូជាសុពណ៌ មាលាមាស ដ៏ជាគ្រឿងប្រដាប់ព្រះឧរា ដល់ព្រះពុទ្ធវិបស្សី ស្រេច ហើយនៃ នាងធ្វើសច្ចាធិដ្ឋានសូត្រនូវបាទព្រះគាថាដូច្នេះថា

ភន្តេ សុវណ្ណមាលាយ មយា ត្វំ បូជិតោ អសិ
តេន មយ្ហំ ឧរេ ហោតុ មាលាបូជាយ(១) និម្មិតាតិ ។

ភន្តេ ភគវា បពិត្រព្រះដ៏មានបុណ្យប្រសើរអើយ ហេតុតែ តេជះផលអានិសង្សនៃអញខ្ញុំថ្វាយបូជាសុពណ៌មាលាមាស ដ៏ជា គ្រឿងប្រដាប់ព្រះឧរាព្រះអង្គនេះ ទោះខ្ញុំម្ចាស់នេះនឹងអន្ទោលទៅ វិញទៅមក យោនយកកំណើតកើតដល់មួយរយជាតិក្តី មួយពាន់ ជាតិក្តី មួយសែនជាតិក្តី រីសុពណ៌មាលាមាសនេះ សូមកុំឱ្យប្រាស អំពីទ្រូងខ្ញុំម្ចាស់ឡើយ ឱ្យបានរៀងរាបដរាបដល់និព្វានហោង ។

រីព្រះពុទ្ធវិបស្សី ព្រះអង្គទ្រង់ព្រះសណ្តាប់ព្រះរាជកញ្ញាទាំង ពីរប្រាថ្នាដូច្នោះហើយ ព្រះអង្គទ្រង់ធ្វើនូវអនុមោទនា ដល់ព្រះរាជ កញ្ញាទាំងពីរសូត្រនូវបាទព្រះគាថា ដូច្នេះ

យា ចេត្ត ទ្វីហិ តុម្ហេហិ បូជា មយ្ហំ បតិដ្ឋិតា
តាយ ឥជ្ឈន្តុ តុម្ហាកំ យថា ចេវ បត្ថនា តថាតិ ។

ថាហៃរាជកញ្ញាទាំងពីរអើយ រីក្តីប្រាថ្នាឧបាសិកា ទាំងពីរ ដែលមកបូជាប្រតិស្ឋានដល់អញតថាគតនេះ ចូរឱ្យនាងបានសំរេច បរិបូណ៌ ដូចក្តីបំណងប្រាថ្នាឧបាសិកាហោង ។

១- ច្បាប់ខ្លះថា មាលាបុញ្ញេន ដូច្នេះក៏មាន ។

រីឯព្រះរាជកញ្ញាទាំងពីរ ស្តាប់អនុមោទនា នៃព្រះតថាគត នូវប្រការអម្បាលណោះហើយ ព្រះនាងទាំងពីរក៏មានព្រះហឫទ័យនោះត្រេកអរ លើកកម្បង់អញ្ជលីដាក់លើសិរសី ថ្វាយបង្គំប្រណម្យក្រាបលា មកកាន់ព្រះរាជមន្ទីរវិញ ៗ រីព្រះនាងទាំងពីរឋិតនៅនាមនុស្សលោកនេះ ដរាបលុះរំលាងព្រះជន្មាយុ អំពីមនុស្សលោកនេះ ស្មោះឆ្ពោះបានទៅកើតឰដ៏សួគ៌ទេពលោកនាយ លុះច្យុតអំពីសួគ៌ទេពលោកនាយនោះមកកើត ឰដ៏មនុស្សលោកនេះ លុះរំលាងបញ្ចក្ខន្ធអំពីមនុស្សលោកនេះក៏បានទៅកើតឰដ៏សួគ៌ទេពលោកនាយវិញទៀត រៀងរាបដរាប លុះអំណើះអស់កាល ៩១ កប្បហោង ៗ

រីនាងកញ្ញាដ៏ជាច្បងសោត មកបានជាព្រះកន្លោងព្រះពុទ្ធប្រាកដព្រះនាម ព្រះនាងស្រីមហាមាយាទេវី ៗ រីនាងកញ្ញា ដ៏ជាប្អូននោះសោត នាងអន្ទោលទៅវិញទៅមក លុះដល់ព្រះពុទ្ធកស្សបៈ ព្រះអង្គបានត្រាស់ហើយ នាងច្យុតចុះមកចាប់បដិសន្ធិជាព្រះរាជបុត្រី នៃព្រះបាទកីកិស្សរាជ ហេតុតែតេជះផលអានិសង្ស នាងបានយកសុពណ៌មាលាមាស ទៅថ្វាយបូជាព្រះពុទ្ធវិបស្សីនោះមិញ នាកាលនាងចាកចេញអំពីព្រះឧទរបវរព្រះមាតានោះ ហាក់បីដូចអ្នកយកសុពណ៌មាលាមាស ជាគ្រឿងប្រដាប់ព្រះឧរា មកប្រដាប់ស្រោបនូវព្រះអង្គនាងនោះឯង ហេតុតែនិមិត្តនោះឯង ទើបអស់ព្រះញាតិវង្សផង មកសន្មតកត់ព្រះនាមករណ៍ថា ព្រះនាងឧរច្ឆទារាជកុមារី ៗ លុះព្រះនាងចម្រើនវ័យធំឡើងបានព្រះជន្ម ១៦

វស្សា ព្រះនាងបានស្ដាប់ភត្តានុមោទនា របស់ព្រះតថាគត ជាអម្ចាស់ នាងបានលុះសោតាបត្តិផល ។ ចំណេរអំពីនោះទៅ ព្រះនាងបានស្ដាប់ភត្តានុមោទនាមួយអន្លើនឹងព្រះវររាជបិតា ព្រះនាងបានលុះដល់ប្រាជ្ញាអរហត្ត(១) ហើយព្រះនាងបួសជាភិក្ខុនី(២) បានចូលនិព្វានដ៏ជាឋានបរមសុខក្សេមប្រសើរនោះទៀងប្រាកដ ហោង

សមណី សមណគុត្តា ភិក្ខុនី ភិក្ខុទាសិកា
ធម្មា ចេវ សុធម្មា ច សង្ឃទាសី ច សត្តមាតិ ។

រីព្រះបាទកីកិស្សរាជ ស្ដេចមានព្រះរាជបុត្រី ដទៃទៀត នោះ ៧ អង្គ ឈ្មោះនាងសមណី ១ ឈ្មោះនាងសមណគុត្តា ១ ឈ្មោះនាងភិក្ខុនី ១ ឈ្មោះនាងភិក្ខុទាសិកា ១ ឈ្មោះនាងធម្មា ១ ឈ្មោះនាងសុធម្មា ១ ឈ្មោះនាងសង្ឃទាសី ១ ។ រីព្រះរាជធីតា ទាំង ៧ នោះ សឹងបានកើតទាន់ព្រះពុទ្ធុប្បាទព្រះសមណគោតម បរមបពិត្រ ជាអម្ចាស់វិសេសនៃយើងនេះ ។

ខេមា ច ឧប្បលវណ្ណា បដាចារា ច គោតមី
ធម្មទិន្នា មហាមាយា វិសាខា ចាបិ សត្តមាតិ ។

រីព្រះនាងមួយអង្គនោះ បាននាមហៅថា នាងខេមាភិក្ខុនី

១- ក្នុងបាលីជាតកវណ្ណនា មានសេចក្ដីលើសពីសម្រាយបន្តិចថា នាងបានសម្រេចប្រាជ្ញាអរហត្ត ក្នុងថ្ងៃដែលព្រះវររាជបិតានាងបានសម្រេចសោតាបត្តិផល ។ ២- ក្នុងបាលីជាតកវណ្ណនា មានសម្ដែងថា នាងមិនបានបួសជាភិក្ខុនីទេ គ្រាន់តែសម្ដែងថា នាងបានសម្រេចអរហត្តហើយបរិនិព្វានទៅ ។

នាងមួយបាននាមហៅថា នាងឧប្បលវណ្ណាទេវី   នាងមួយបាននាមហៅថា នាងបដាចារា   នាងមួយ បាននាមហៅ ថា នាងគោតមី នាងមួយបាននាមហៅថា នាងធម្មទិន្នា នាងមួយបាននាមហៅថា នាងមហាមាយា   នាងមួយបាននាមហៅ ថា នាងវិសាខា ៗ   រីព្រះនាងទាំង ៦ នោះ យើងមិនស្រដីឡើយ   យើងនឹងស្រដីតែព្រះនាងសុធម្មាមួយប៉ុណ្ណោះ ព្រះនាងនោះ អន្ទោលទៅវិញទៅមក នៅនាព្ធដ៏សួគ៌ទេពលោកនាយក្តី នៅនាមនុស្សលោកនេះក្តី ហេតុតែផលអានិសង្សដែលព្រះនាង បានយកលម្អិតខ្លឹមច័ន្ទន៍ ទៅថ្វាយបូជាព្រះពុទ្ធវិបស្សីនោះមិញ កាលណាបើព្រះនាងចាកចេញ អំពីព្រះឧទរព្រះវរមាតា   ដ៏មានព្រះអង្គព្រះនាងនោះ ធុំក្លិនពិដោរ បីដូចអ្នកលាបស្រលាបនូវលម្អិតខ្លឹមច័ន្ទន៍ ក្រហម ហេតុតែនិមិត្តដូច្នោះហោង   ទើបព្រះនាងបានព្រះនាម ថា ព្រះនាង *សុពារសុប្បភី* ៗ   ចំណេរអំពីនោះទៅ ព្រះនាងបានជាអគ្គមហេសីនៃព្រះឥន្ទ្រាធិរាជ នៅព្ធដ៏ពិភពត្រៃត្រឹង្ស នាកាលព្រះនាងសោយព្រះវិលាល័យក្ស័យព្រះជន្មាយុ   ដោយកំណត់អាយុសួគ៌ទេវលោកនាយនោះកូវ ក៏កើតមានបុព្វនិមិត្ត ៥ ប្រការហោង ៗ

តេនាហ   ភគវា   ទិព្វបុប្ផា   មិលាយន្តិ   សំកិលិស្សន្តិ វត្ថា   កុច្ឆិតោ   សេទា   មុច្ចន្តិ   កាយោ   ទុព្វលរូបោ កីសោ   ទេវាសនេ   នាភិរមន្តិ   ទេវានំ   ចុតិ

ឆម្ភតាតិ (១) បពិត្រអើយ ហេតុតែនិមិត្តនោះឯង ទើបព្រះដ៏មានបុណ្យ ព្រះអង្គមានព្រះបន្ទូលនឹងភិក្ខុផងទាំងឡាយ ថា ភិក្ខវេ ម្នាលភិក្ខុផងទាំងឡាយអើយ រីផ្កាភ្វីសួគ៌ទិព្វនោះស្រស់ល្អ ពុំដែលស្វិតស្រពោនមិញ ក៏ខ្វែប្រែជាស្វិតស្រពោនអាក្រក់វិញ រីសំពត់ទិព្វ ពុំដែលនឹងដិតក្អែលជាមន្ទិលមិញ ក៏ខ្វែប្រែជា មានមន្ទិលវិញ រីញើសក្អែល ពុំដែលនឹងកើតមានមិញ ក៏ខ្វែប្រែ ជាហូរចេញមកអំពីក្លៀក មានជាមន្ទិលវិញ រីខ្លួនព្រះនាងនោះ ពុំដែលថយកម្លាំងមិញ ក៏ខ្វែប្រែជាស្គាំងស្គម ថមថយកម្លាំងវិញ ហើយព្រះនាងនឹងគង់លើគ្រែក្រឡាអាស្នាសម្តេច ពុំស្រណុកឡើយ ភិក្ខុអើយ នេះជាសភាពនៃទេវតាផងទាំងឡាយនឹងច្យុត សឹងតែដូច្នេះឯង ៗ រីសម្តេចព្រះឥន្ទ្រាធិរាជ ស្តេចជ្រាបសភាពជាព្រះនាងសុបារសុប្បតី នឹងអស់ព្រះជន្មាយុអំពីសួគ៌ទេពលោកនោះកូវ ទើបស្តេចនាំព្រះនាងទៅកាន់នន្ទវ័នឧទ្យាន ដ៏ជាឋានបំបាត់ទុក្ខសោក មួយអន្លើនូវស្រីស្រឹង្គារបរិវារផងជាច្រើន ព្រះនាងសុបារសុប្បតី ផ្ទំលើគ្រែក្រឡាបន្ទំបរមសុខសួស្តី មានព្ធដ៏នន្ទវ័នឧទ្យាន ព្រះឥន្ទ្រាធិរាជឯង ស្តេចគង់ខាងគ្រែក្រឡាបន្ទំព្រះនាង ហើយ

១- បាលីនេះ មិនមានប្រាកដក្នុងបាលីអដ្ឋកថានិងដីការបស់វេស្សន្តរជាតកទេ តែលោកអ្នកប្រាជ្ញបុរាណ ដែលតែងរឿងវេស្សន្តរជាតក ស្រង់យកអំពីគម្ពីរដទៃ មកដាក់ក្នុងទីនេះ ដើម្បីអធិប្បាយពន្យល់អំពីបុព្វនិមិត្តទាំង ៥ ប្រការ ។

ស្ដេចមានព្រះបន្ទូលថា ហៃនាងសុបារសុប្បតីទេវីអើយ អញនឹងបង្វែរឱ្យពរទាំង ១០ ប្រការឱ្យនាង ចូរនាងទទួលយកពរនេះឯងហោង ។ ព្រះឥន្ទ្រាធិរាជ កាលណាបើនឹងប្រទានពរព្រះនាង ក៏សូត្រនូវបាទព្រះគាថាជាបឋម មាននៅក្នុងព្រះមហាវេស្សន្តរជាតក ដ៏ប្រដាប់នីទៅនូវព្រះគាថានោះមួយពាន់ ដូច្នេះថា

ផុស្សតី វរវណ្ណាភេ វរស្សុ ទសធា វរេ
បថព្យា ចារុបុព្វង្គី យំ តុយ្ហំ មនសា បិយន្តិ ។

ផុស្សតិ ថាហៃនាងសុបារសុប្បតី ដ៏ប្រកបនូវបញ្ចពិធកល្យាណី ដ៏មានរស្មីដូចមាស ចូរនាងទទួលយកពរ ទាំង ១០ ប្រការនេះ ពរឯណា ដ៏ជាសំឡាញ់ពេញនូវអំណរ នៃមនុស្សសត្វផងទាំងឡាយ ឮដ៏ផ្ទៃក្រោមទាំងមូល នាមនុស្សលោកនាយ ក៏ចូរនាងទទួលយកពរនោះហោង ។

ព្រះនាងសុបារសុប្បតី ទ្រង់ស្ដាប់ ពុំជ្រាបសភាព ជាព្រះនាងនឹងច្យុតឡើយ ហេតុតែព្រះនាងភ្លេចស្មារតី ទើបព្រះនាងទូលទៅព្រះឥន្ទ្រាធិរាជវិញ សូត្រនូវព្រះគាថា ជាគម្រប់ពីរ ថា

ទេវរាជ នមោ ត្យត្ថុ កឹ បាបំ បកតំ មយា
រម្ហា ចាវេសិ មំ ឋានា វាតោវ ធរណីរុហន្តិ ។

ទេវរាជ បពិត្រសម្ដេចព្រះឥន្ទ្រាធិរាជ ប្រសើរអើយ ខ្ញុំអម្ចាស់សូមថ្វាយបង្គំប្រណម្យព្រះអង្គ តើ គឺ អញខ្ញុំម្ចាស់ ធ្វើនូវអំពើអ្វីជាប្រាកដ គួរអន់អាក់ថ្នាក់ ក្នុងព្រះរាជហឫទ័យ នៃព្រះអង្គ

ទើបព្រះអង្គមកកម្ចាត់បង់ខ្ញុំម្ចាស់ អំពីឋានសួគ៌ ឋានសុខស្រណុកមហិមា ឧបមាបីដូចជាខ្យល់មាលុតវាត បក់ពន្លកឱ្យភ្លូក រលើងឈើផងទាំងឡាយ នៅព្ធដ៏ផ្ទៃក្រោមមនុស្សលោកនាយ ៗ ព្រះឥន្ទ្រាធិរាជស្តេចជ្រាបសភាពជាព្រះនាងភ្លេចស្មារតីដូច្នោះហើយ ទើបព្រះអង្គមានព្រះបន្ទូល សូត្រជាបាទព្រះគាថា ដូច្នេះ ថា

ន ចេវ តេ កតំ បាបំ　　ន ច មេ ត្វមសិ អប្បិយា
បុញ្ញញ្ច តេ បរិក្ខីណំ　　យេន តេវំ វទាមិហន្តិ ៗ

ផុស្សតិ ថាហៃនាងសុបារសុប្បតីទេវីអើយ រីអំពើបាបអ្វី នាងនឹងធ្វើឱ្យអន់អាក់ថ្នាក់ចិត្តអញនោះ ឥតអង្គីមានឡើយ នាងអើយ ហេតុតែអញយល់សភាពក្តីព្រាត់ប្រាសនឹងច្យុត ដូច្នោះឯងហេតុនោះហោង ចូរនាងទទួលយកពរទាំង ១០ ប្រការនេះ អំពីអញ អញនឹងបង្វែរឱ្យនាងហោង ៗ អណ្តាប់នោះ ព្រះនាងសុបារសុប្បតី ទ្រង់ជ្រាបសភាពថា អាត្មាព្រះនាងនឹងច្យុត ស្រុតចុះមក ព្ធដ៏មនុស្សលោកនេះ ដូច្នោះហើយ ទើបព្រះនាងទទួលយកពរទាំង ១០ ប្រការ អំពីសម្តេចព្រះឥន្ទ្រាធិរាជ ក្រាបទូលជាបាទព្រះគាថា ដូច្នេះ ថា

វរញ្ចេ មេ អទោ សក្ក　　សព្វភូតានមិស្សរ
សិវិរាជស្ស ភទ្ទន្តេ　　តត្ថ អស្សំ និវេសនេ ៗ
នីលនេត្តា នីលភមូ　　នីលក្ខី ច យថា មិគី
ផុស្សតី នាម នាមេន　　តត្ថ អស្សំ បុរិន្ទទ ៗ

បុត្តំ លភេថ វរទំ   យាចយោគំ អមច្ឆរឹ
បូជិតំ បដិរាជូហិ   កិត្តិមន្តំ យសស្សិនំ ។
គព្ភំ មេ ធារយន្តិយា   មជ្ឈិមង្គំ អនុន្នតំ
កុច្ឆិ អនុន្នតោ អស្ស   ចាបំវ លិខិតំ សមំ ។
ថនា មេ នប្បតេយ្យុំ   បលិតា នស្សន្តុ វាសវ
កាយេ រជោ ន លិម្បេថ   វជ្ឈញ្ចាបិ បមោចយេ ។
មយូរកោញ្ចាភិរុទេ   នារីវរគណាយុតេ
ខុជ្ជចេលាវកាកិណ្ណេ   សូតមាគធវណ្ណិតេ ។
ចិត្តគ្គឡេរុឃុសិតេ   សុរាមំសប្បពោធនេ
សិវិរាជស្ស ភទ្ទន្តេ   តត្ថ អស្សំ មហេសិយាតិ ។

បពិត្រសម្តេចព្រះឥន្ទ្រាធិរាជ ដ៏មានអំណាច អាចជាឥស្សរកំពូលនៃអស់ទេវតាផងទាំងឡាយអើយ ខ្ញុំអម្ចាស់ សូមឱ្យបានជាអាយិអគ្គមហេសីនៃព្រះមហាក្សត្រព្រះបាទសិវិរាជ ដែលគង់គ្រងព្រះរាជមន្ទីរ ឰដ៏ស្រុកជេតុត្តរនគរ ព្រះពរមួយនេះ ជាបឋម ៗ ព្រះពរមួយសោត ខ្ញុំអម្ចាស់ សូមឱ្យមានភ្នែកនោះ មូលខ្មៅយង់ ឧបមាបីដូចកូនម្រឹគ ទើបកើតបានតែឆ្នាំមួយ ហើយឱ្យមានភូមោនោះ កោងទ្រទេសទ្រទួយ បីដូចចង្កួយកៅទ័ណ្ឌ ពុំនោះសោតបីដូចព្រះពិស្ណុការ កាន់ដងជក់ជ្រលក់ខ្មៅ មកគូរ មកវាសហោង ព្រះពរនេះឯងជាគម្រប់ពីរ ៗ ព្រះពរមួយសោត ខ្ញុំអម្ចាស់ សូមឱ្យបានឈ្មោះថា សុបារសុប្បតី ដូចដែលប្រក្រតី នៅឰដ៏ត្រៃត្រឹង្ស-

ពិភព ព្រះពរនេះឯង ជាគម្រប់បី ៗ ព្រះពរមួយសោត ខ្ញុំអម្ចាស់ សូមឱ្យមានកូនប្រុស ដ៏ប្រកបនូវកិត្តិយស ឱ្យឮទូទ័រអស្ចារ្យទាំងប្រលុងសកលជម្ពូទ្វីប អាចកាត់អំណោយទានជាឋានពំនាក់នៃស្មូមយាចកផងទាំងឡាយ ព្រះពរនេះឯង ជាគម្រប់ ៤ ៗ បពិត្រសម្តេចព្រះឥន្ទ្រាធិរាជអើយ ខ្ញុំអម្ចាស់សូមកាលណាបើខ្ញុំអម្ចាស់នឹងទ្រង់គភ៌នោះ កុំឱ្យមានផ្ទៃពោះនោះ ធំប៉ោងប៉ើស ច្រលើសលើសនឹងចុងដង្ហើមនោះឡើយ ឱ្យរាបសុភាពល្អ បីដូច អ្នកយកកាំធ្នូច្រកក្នុងបំពង់នោះឯង ព្រះពរនេះឯង ជាគម្រប់ ៥ ៗ ព្រះពរមួយសោត ខ្ញុំអម្ចាស់ សូមកុំបីមានដោះសណ្ដាយ ជាសំណើចនៃអ្នកផងទាំងឡាយឡើយ សូមឱ្យមានដោះក្បោះក្បំ សមនឹងឧរាដូចផ្លែទម្លាប់មាស អ្នកយកមកផ្ទាប់ នៅព្ធដ៏ទ្រូង របស់ខ្ញុំអម្ចាស់ ព្រះពរនេះឯង ជាគម្រប់ ៦ ៗ ព្រះពរមួយសោត ខ្ញុំអម្ចាស់សូមកុំឱ្យមានសក់ស្កូវ អាស្រូវអាក្រក់ សូមឱ្យមានសក់ខ្មៅយង់រលង់រលើប ដូចស្លាបភមរា ព្រះពរនេះឯង ជាគម្រប់ ៧ ៗ ព្រះពរមួយសោត ខ្ញុំអម្ចាស់សូមឱ្យមានសម្បុរនោះល្អិតល្អ បីដូចពពិលមាស គិតដ៏អ្នកដុសខាត់ កុំបីឱ្យមានដិតដល់នូវផង់ធូលីដីខ្សាច់ឡើយ ព្រះពរនេះឯង ជាគម្រប់ ៨ ៗ ព្រះពរមួយសោត ខ្ញុំអម្ចាស់ សូមបានដោះស្រាយសត្វផងទាំងឡាយ ឱ្យរួចចេញអំពីទុក្ខទោស គឺលោកដាក់ទ្រុងច្រួលច្រវាក់ ខ្នោះឃ្នាងគុកតារាងនាំទៅនឹងសម្លាប់នោះក្តី ខ្ញុំសូមឱ្យបានដោះអ្នកទោសនោះឯង

ឱ្យបានរួចចេញអំពីទុក្ខភ័យ ព្រះពរនេះឯងជាគម្រប់ ៩ ។ ព្រះពរមួយសោតទៀត ខ្ញុំអម្ចាស់ សូមឱ្យមានសព្វសត្វគឺ ហង្ស ក្រៀល ក្ងាន ក្ងោក សឹងហើរឆ្វាត់ឆ្វៀលបន្លឺនូវស័ព្ទនោះ ឮល្វេងល្វើយពីរោះ ឮដ៏ព្រះរាជមន្ទីរ ដ៏ពេញមីរដេរដាសណាស់ណាន់តាន់តាប់ នីទៅនូវគមគាក់ទំពួនទម្លៃ តឿ ខ្ទៃ ខ្ទើយ ជាស្រីស្រឹង្គារផងច្រើន ហើយសូមឱ្យមានអ្នកប្រាជ្ញ រាជបណ្ឌិតចេះធម៌អាថ៌ប្រស្នា បីដូចអ្នកសុរាទំពាសាច់ កុំបីឱ្យដាច់អំពីព្រះរាជមន្ទីររបស់ខ្ញុំអម្ចាស់ឡើយ ព្រះពរនេះឯង ជាគម្រប់ ១០ ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណា ពុំទាន់ប្រាកដ បទព្រះបាលីឯណា ពុំទាន់ចែងច្បាស់ លុះព្រះអង្គបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលនឹងអស់ភិក្ខុផងទាំងឡាយ សូត្រនូវបាទព្រះគាថា ដូច្នេះ ថា

ឥទំ វត្វាន មឃវា ទេវរាជា សុជម្បតិ
ផុស្សតិយា វរំ ទត្វា អនុមោទិត្ថ វាសវោតិ ។

ភិក្ខវេ ម្នាលភិក្ខុផងទាំងឡាយអើយ រីសម្ដេចព្រះឥន្ទ្រាធិរាជ ជាឥស្សរកំពូលនៃអស់ទេវតាផងទាំងឡាយ ព្រះអង្គបង្វែរពរ ប្រទានព្រះនាងសុបារសុប្បតីទេវី ស្រេចនូវប្រការអម្បាលណោះហើយ មានព្រះរាជហឫទ័យនោះដ៏ពេញនូវអំណរអរក្រៃពេកហោង ។

ទសវរគាថាវណ្ណនា និដ្ឋិតា បពិត្រអើយ អាត្មាភាពសម្តែងថ្លែងព្រះធម៌វិសេសទេសនាមហាវេស្សន្តរជាតក **កណ្ឌទសពរ** ដ៏ប្រដាប់ប្រដានីទៅនូវគាថា ១៩ នេះមិញ ក៏សូរេចដោយនូវវេលាកាល ដ៏សមគួរបរិបូណ៌ ម្ល៉េះឯងហោង ៗ

ចប់ កណ្ឌទសពរ ទី ១ តែប៉ុណ្ណោះ ៗ

⁂

ចម្លងចប់នៅថ្ងៃ ២ រោច ខែចេត្រ ព.ស. ២៥៣៣
ត្រូវនឹងថ្ងៃពុធ ទី ១១ ខែមេសា គ.ស. ១៩៩០

មហាវេស្សន្តរជាតក

ទី ២



កណ្ឌហេមពាន្ត

ប្រដាប់ដោយគាថា ១៣៤

មហាវេស្សន្តរជាតក

ទី២

កណ្ឌហេមពាន្ត

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ឥតិ សា វរេ គហេត្វា តតោ ចុតា មទ្ទរញ្ញោ អគ្គមហេសិយា កុច្ឆិម្ហិ និព្វត្តិ ។ ឰដ៏កាលនោះ រីឯព្រះនាងសុបារសុប្បតីដ៏ជាស្រីល្អអស់អង្គ ទ្រង់នូវរូបមានលក្ខណាប្រសើរនោះ ព្រះនាងទទួលយកព្រះពរទាំង ១០ ប្រការអំពីព្រះឥន្ទ្រាធិរាជហើយ ក៏ច្យុតស្រុតចុះមកចាប់បដិសន្ធិ ឰដ៏ផ្ទៃអគ្គមហេសីនៃព្រះបាទមទ្ទរាជ ឰដ៏មាតុលនគរ ។

តាយ ជាយមានាយ ចន្ទនចុណ្ណេន បរិប្ផោសិតេន វិយ សរីរេន ជាតត្តា រីព្រះនាងសុបារសុប្បតីសោត កាលណាព្រះនាងប្រសូតចេញមក អំពីផ្ទៃនៃព្រះអគ្គមហេសីព្រះបាទមទ្ទរាជនោះហើយ ក៏មានសម្បុរនោះល្អ បីដូចអ្នកយកនូវលម្អិតខ្លឹមច័ន្ទន៍(១) មកលាបស្រឡាបអស់អង្គ ហេតុតែព្រះនាងមានកំណើតដូច្នោះ ទើបលោកមកសន្មតកត់សម្គាល់នូវព្រះនាមនាងថា" ព្រះនាងសុបារសុប្បតីកុមារី " លុះព្រះនាងចម្រើនធំឡើង ព្រមនូវអស់បរិវារ

១- មានច្បាប់ខ្លះ " បីដូចអ្នកយកមាសមកលាប ច្រឡំនីទៅនូវលម្អិតខ្លឹមច័ន្ទន៍ " ដូច្នេះក៏មាន ។

ផងទាំងឡាយច្រើន មានព្រះរូបឆោមនោះល្អ បីដូចស្រីទេពអប្សរបវរកញ្ញា នៅនាសួគ៌នាយហោង ។

អថ នំ សិរិមហារាជា អត្តនោ⁽¹⁾ **បុត្តស្ស សញ្ជយកុមារស្ស អត្ថាយ អានេត្វា** បពិត្រអើយ រីព្រះនាងសុបារសុប្បតីកុមារី លុះព្រះនាងមានព្រះជន្មបាន ១៦ ព្រះវស្សាបរិបូណ៌ ហើយកូវ ព្រះបាទសិរិមហារាជ ឱ្យទៅអញ្ជើញព្រះនាង មកអភិសេក មួយអន្លើនឹងចៅសញ្ជ័យកុមារ ឱ្យឡើងសោយរាជសម្បត្តិ ទុកព្រះនាងជាអគ្គមហេសីធំក្រៃលែង អស់ស្រីព្រះស្នំផងទាំងឡាយ ១៦ ពាន់ **តេន វុត្តំ** ហេតុនោះហោង ព្រះអង្គមានព្រះបន្ទូលនឹងព្រះសារីបុត្តត្ថេរ សូត្រនូវបាទព្រះគាថាដូច្នេះថា

តតោ ចុតា សា ផុស្សតី ខត្តិយេ ឧបបជ្ជថ
ជេតុត្តរម្ហិ នគរេ សញ្ជយេន សមាគមីតិ ។

ភោ សារីបុត្ត ហែធម្មសេនាបតីស្រីសារីបុត្តអើយ រីព្រះនាងសុបារសុប្បតីទេវី ព្រះនាងច្យុតស្រុតចាកទេវលោក ក៏បានមកកើតក្នុងត្រកូលក្សត្រខត្តិយវង្ស ហើយបានជាអង្គអគ្គមហេសីនៃព្រះបាទស្រីសញ្ជ័យជាក្សត្រថ្លៃប្រសើរ សោយរាជសម្បត្តិ ឋិតនៅនាជេតុត្តរនគរ ។

អថ នំ សក្កោ គ្រានោះ សម្តេចសក្កទេវរាជ ឋិតនៅនាសួគ៌ត្រៃត្រឹង្សទេវលោក ស្តេចបើកទិព្វចក្ខុ រមិលមើលចុះមក

១- ច្បាប់ខ្លះគ្មានបទ " អត្តនោ " នេះទេ ។

យល់ព្រះនាងសំរីទ្ធីនូវព្រះពរទាំង ៩ ប្រការ បរិបូណ៌ដូចព្រះនាងប្រាថ្នានោះកូរ ព្រះឥន្ទ្រ ក៏ទ្រង់រំពឹងដូច្នេះថា ឱ! ពរ ១០ ប្រការដែលអញប្រសិទ្ធីឱ្យព្រះនាងសុបារសុប្បតីទេវីនោះមិញ នាពរទាំង ៩ ប្រការនោះ ព្រះនាងបានបរិបូណ៌ហើយ នៅសល់ខានតែពរមួយ ព្រះនាងប្រាថ្នាឱ្យបានព្រះរាជបុត្រប្រុស នោះមិញ ពុំទាន់បានបរិបូណ៌នៅឡើយ ថាបើដូច្នោះកូរ អញនឹងបំពេញឱ្យបានដូចក្ដីប្រាថ្នានោះហោង ៗ

កាលនោះ ព្រះបរមពោធិសត្វមហាបុរសរ័ត្ន ស្ដេចឋិតនៅនាពិភពត្រៃត្រឹង្សនាយ ៗ សម្ដេចព្រះឥន្ទ្រាធិរាជ ស្ដេចទ្រង់ជ្រាបសភាពព្រះជន្មព្រះពោធិសត្វ ថានឹងសំរីទ្ធីបរិបូណ៌ហើយ ព្រះឥន្ទ្រាធិរាជ ក៏ចូលទៅកាន់ព្រះពោធិសត្វ ហើយនិមន្ត ដោយបទបាលីថា **មារិស តយា មនុស្សលោកំ គន្តុំ វដ្ដតិ** ៗ **មារិស** បពិត្រព្រះអង្គដ៏មានបុណ្យបារមីច្រើនអើយ សូមអារាធនានិមន្តព្រះអង្គ ស្ដេចលីលាចុះទៅទូន្មានសត្វផងទាំងឡាយ នៅនាមនុស្សលោកនាយ ថាបើព្រះអង្គលីលាចុះទៅហើយ ព្រះបារមីព្រះអង្គនឹងសំរីទ្ធីបរិបូណ៌ប្រាកដហោង ៗ

កាលនោះ ព្រះបរមពោធិសត្វ ស្ដេចទទួលនិមន្តសម្ដេចព្រះឥន្ទ្រាធិរាជហើយ ទើបព្រះអង្គច្យុតស្រុតចុះមកអំពីសួគ៌ទេវលោកនាយ មកចាប់បដិសន្ធិព្ធដ៏ព្រះមាតុទរបវរ នៃព្រះនាងសុបារសុប្បតីដ៏ជាព្រះអគ្គមហេសីថ្លៃនៃព្រះបាទស្រីសញ្ជ័យ ដែលទ្រង់សោយ

រាជសម្បត្តិ ឋិតឰដ៏ជេតុត្តរនគរនោះហោង ។

តស្ស ចេវ អញ្ញេសញ្ច ចវនធម្មានំ សដ្ឋីសហស្សានំ ទេវបុត្តានំ បដិញ្ញំ គហេត្វា សម្តេចព្រះឥន្ទ្រាធិរាជ ប្តេជ្ញានិមន្ត មិនប៉ុន្តែព្រះពោធិសត្វឯងឡើយ ហើយនិមន្តអស់ទេវបុត្រផងដទៃនោះច្រើន ប្រមាណ ៦ ម៉ឺន ឱ្យច្យុតព្រមមួយអន្លើនឹងព្រះពោធិសត្វនោះឯង **សក្កដ្ឋានមេវ គតោ** លុះព្រះឥន្ទ្រាធិរាជនិមន្តស្រេចហើយ ក៏ស្តេចហោះទៅកាន់ឋានលំនៅព្រះអង្គវិញហោង ។ បពិត្រអើយ រីអស់ទេវបុត្រសំណល់ក្រៅលែងនោះ សឹងច្យុតចុះមកចាប់បដិសន្ធិឰដ៏ផ្ទៃប្រពន្ធរាជអាមាត្យផង អស់សព្វគ្រប់ទាំង ៦ ម៉ឺននោះឯង ។ ហេតុតែព្រះបារមីនៃព្រះបរមពោធិសត្វមហាបុរសរ័ត្នវិសេស មកចាប់បដិសន្ធិ ឰដ៏ព្រះមាតុទរបវរព្រះកន្លោងគឺព្រះនាងសុបារសុប្បតី ព្រះនាងមានព្រះរាជហឫទ័យនោះ ជ្រះថ្លាសទ្ធា ចង់ឱ្យទានស្មូមយាចកអ្នកកម្សត់ទុគ៌តផងទាំងឡាយ ព្រះនាងឱ្យប្រដាប់សាលាទានទាំង ៦ សាលាទាន ៤ នោះនៅនាទ្វារព្រះនគរទាំង ៤ សាលាមួយនោះ នៅនាមុខព្រះលាន សាលាមួយទៀតនោះ នៅនាក្នុងព្រះរាជវាំង ហើយព្រះនាងឱ្យចាយអស់មាសប្រាក់កែវកងសព្វពិធរ័ត្ន① ផង ឱ្យទៅជាទាន ដល់អស់ស្មូមយាចក អ្នកកម្សត់ទុគ៌តផងទាំងឡាយ ក្នុងមួយថ្ងៃៗនោះ ៦ សែនតម្លឹងមាស ។

១- គួរថាសប្តពិធរ័ត្ន ឬ សត្តពិធរ័ត្ន ។

កាលណាបើជ្រាបទៅដល់ព្រះបាទស្រីសញ្ជ័យ បរមបពិត្រក្សត្រប្រសើរនោះហើយ ស្តេចមានព្រះបន្ទូលឱ្យហៅអស់ព្រាហ្មណ៍ដែលចេះទាយនិមិត្តនោះមកហើយ មានព្រះបន្ទូលដណ្តឹងថា ព្រាហ្មណ៍អើយ ចាប់ដើមតាំងអំពីព្រះនាងទេវីទ្រង់គភ៌ ព្រះនាងមាន ព្រះរាជហឫទ័យនោះជ្រះថ្លាសទ្ធាចង់តែឱ្យទាននោះ តើមានហេតុដូចម្តេច ៗ ទើបព្រាហ្មណ៍ចេះទាយនិមិត្តនោះ ក្រាបបង្គំទូល ថាបពិត្រព្រះសម្មតិទេពក្សត្រថ្លៃប្រសើរអើយ នេះហេតុអំណាច ព្រះរាជបុត្របិតនៅក្នុងព្រះមាតុទរ ទើបមានព្រះរាជហឫទ័យ សទ្ធាចង់តែឱ្យទាន បពិត្រមហារាជអើយ រីសម្តេចព្រះរាជបុត្រនោះមិនគឺស្រីឡើយ គឺប្រុសឯងមិនទេឡើយ មកបិតនៅក្នុងព្រះរាជឧទរ ថាបើចាកចេញអំពីព្រះមាតុទរព្រះវររាជមាតាកាលឯណាហើយ ព្រះអង្គមានព្រះបារមីនោះរុងរឿងថ្កើងទូទាំងទៅ អស់ស្តេចទាំងសកលជម្ពូទ្វីប សឹងដ៏នាំដង្វាយភ្លាសសួយរ៉ៃ មកថ្វាយព្រះអង្គនោះច្រើនហោង ៗ

តំ សុត្វា រាជា តុដ្ឋមានសោ ហុត្វា ទុត្តប្បការា ឆ ឆានសាលាយោ ការាបេត្វា ទុត្តប្បការំ ឆានំ បដ្ឋបេសិ

ព្រះមហាក្សត្រាធិរាជ ទ្រង់ព្រះសណ្តាប់ពាក្យព្រាហ្មណ៍ ក្រាបបង្គំទូលដូច្នោះហើយ ស្តេចមានព្រះរាជហឫទ័យនោះ ត្រេកអរសាទរក្រៃពេក ទ្រង់ឱ្យយកព្រះរាជទ្រព្យផងទាំងពួង ព្រះរាជទានទៅព្រះនាងច្រើនក្រៃពេក ជាអនេកប្រការ ៗ

ពោធិសត្តស្ស បដិសន្ធិគ្គហណកាលតោ បដ្ឋាយ រញ្ញោ អាយុប្បមាណំ នាម នាហោសិ រីនឹងស្រដីកាលព្រះពោធិសត្វមហាបុរសរ័ត្នវិសេស មកចាប់បដិសន្ធិក្នុងព្រះមាតុទរបវរព្រះមាតានោះ ហេតុតែព្រះបារមីនៃព្រះពោធិសត្វនោះមិញ រីអស់ស្តេចសកលជម្ពូទ្វីប សឹងតែនាំមាសប្រាក់កែវកងសព្វពិធរ័ត្ន មកថ្វាយសម្តេចព្រះវររាជបិតានោះច្រើន នឹងរាប់គណនាពុំបានឡើយ ៗ

ទេវី មហន្តេន បរិវារេន គព្ភំ ធារេន្តី រីព្រះនាងទេវីទ្រង់គភ៌ព្រះពោធិសត្វ មួយអន្លើនូវអស់បរិវារផងច្រើន បរិបូណ៌បាន ១០ ខែហើយ ព្រះនាងមានព្រះចំណង់ នឹងចង់ទៅទតរមិលមើលព្រះនគរ ទើបព្រះនាងឱ្យទៅក្រាបបង្គំទូលព្រះមហាក្សត្រាធិរាជ ទ្រង់ជ្រាប ហើយមានព្រះរាជហឫទ័យនោះត្រេកអរ ក្រៃពេក ស្តេចឱ្យប្រដាប់ប្រដាព្រះនគរនោះ ល្អបីដូចពិមាននៃទេវតានាឋានសួគ៌នាយ ហើយព្រះអង្គប្រើអាមាត្យ ឱ្យទៅយកសុវណ្ណសិវិកា(១) នាំមកឱ្យព្រះនាង ៗ ឋិតនៅលើគ្រែសុពណ៌សិវិកានោះហើយ ក៏លីលាទៅទតរមិលមើល ហើយធ្វើប្រទក្សិណព្រះនគរ ៣ ជុំ ទើបព្រះនាងត្រឡប់មកដល់កណ្តាលផ្លូវឈ្នួញធំកូវ ខ្យល់កម្មជវាត ក៏បក់កម្រើកផ្ទៃព្រះឧទរ នឹងប្រសូតព្រះពោធិសត្វ ព្ឌ៏កាលណោះ ៗ

ទើបពួកអាមាត្យ នាំសេចក្តីទៅក្រាបបង្គំទូលសម្តេចព្រះ-

១- ប្រែថា " រមាស " ឬ " ព្រះសាល្យេងមាស " តែក្នុងជាតកបាលីថា " រថវរំ " ប្រែថា " រាជរថដ៏ប្រសើរ " ដូច្នេះទៅវិញ ៗ

មហាក្សត្រ ស្ដេចទ្រង់ជ្រាបដំណឹងនោះហើយ ទើបទ្រង់ចាត់ឱ្យសង់ព្រះដំណាក់ជាទីប្រថាប់សម្រាប់ប្រសូត ព្រះនាងក៏ប្រសូតព្រះបរមពោធិសត្វ ពួដ៏ឋាននោះឯងហោង ។

តេន វុត្តំ ហេតុនោះ ព្រះអង្គមានព្រះបន្ទូលនឹងព្រះមហាសារីបុត្តត្ថេរ ថា

ទស មាសេ ធារយិត្វា ករោន្តី បុរបទក្ខិណំ
វេស្សានំ វីថិយា មជ្ឈេ ជនេសិ ផុស្សតី មមន្តិ ៗ

ហៃបាសារីបុត្តអើយ រីព្រះនាងសុបាៈសុប្បតីទេវី ទ្រង់គក៏អញ្ញតថាគត បរិបូណ៌បានខែ ១០ ហើយ ព្រះនាងទៅទតមើលព្រះនគរ ប្រទក្សិណ ៣ ជុំរួចហើយ ព្រះនាងត្រឡប់វិលមកដល់កណ្ដាលផ្លូវហើយ ក៏ប្រសូតអញ្ញតថាគត នៅកណ្ដាលឈ្នួញធំ ។

មហាសត្តោ មាតុកុច្ឆិតោ និក្ខមន្តោ វិសុទ្ធោ ហុត្វា អក្ខីនិ ឧម្មិលេត្វា ច ន័ទ្ធមិ កាលណាបើព្រះមហាសត្វនោះប្រសូតចាកចេញអំពីព្រះមាតុទរបវរព្រះកន្លោងដ៏មានព្រះអង្គនោះល្អបរិសុទ្ធ បីដូចតម្បារមាស រីព្រះនេត្រទាំងពីរនោះសោត សឹងដ៏ថ្លាស្រឡះ ហើយទតរមិលមើលទៅកាន់ព្រះកន្លោង ថ្វាយបង្គំប្រណម្យទូលថា បពិត្រព្រះមេដ៏មានគុណធ្ងន់ប្រសើរអើយ តើអ្នកមានមាសដឹងអើយ ខ្ញុំនឹងចង់ឱ្យទានបន្តិចហៈ ។ សម្ដេចព្រះវររាជមាតាឮហើយ មានព្រះបន្ទូលថា តាត បិយបុត្តក ម្នាលកូនស្ងួនសំឡាញ់មាសម្ដាយអើយ នឹងក្រអឺមាសនោះឡើយ ព្រះនាង

ទេវីមានព្រះបន្ទូលម្ល៉ោះហើយ ព្រះនាងយកមាស ១ ពាន់ តម្លឹង ដាក់ទៅលើព្រះហស្តព្រះពោធិសត្វព្ឋដ៏កាលនោះហោង ។ នាកាល ព្រះពោធិសត្វចាកចេញអំពីព្រះមាតុទរនោះ បានទទួលយកមាស អំពីព្រះកន្លោងហើយ ព្រះអង្គឱ្យទៅជាទាន មួយរំពេចនោះឯង ៗ វីព្រះបរមពោធិសត្វកាលចាកចេញអំពីព្រះឧទរបវរព្រះកន្លោងហើយ មានព្រះបន្ទូលនឹងព្រះវររាជមាតានោះ មាន ៣ ដង គឺ កាលជា ព្រះមហោសថម្ដង កាលជាព្រះវេស្សន្តរនេះម្ដង កាលជាព្រះ សិទ្ធាថ៌នោះម្ដង ៗ បពិត្រអើយ នាកាលសម័យនឹងសន្មតកត់ ព្រះនាមព្រះបរមពោធិសត្វនោះ ហេតុនិមិត្តព្រះអង្គកើតនៅនា កណ្ដាលផ្លូវឈ្មួញកូវ អស់ព្រះញាតិផងទាំងឡាយ ក៏សន្មតព្រះ នាមករណ៏ចម្រើនព្រះពរហៅថា " *ព្រះវេស្សន្តរកុមារ* " ៗ

តេន វុត្តំ ហេតុនោះ លុះព្រះអង្គបានត្រាស់ហើយ មាន ព្រះបន្ទូលនឹងព្រះមហាសារីបុត្តត្ថេរ សូត្រជាបទព្រះគាថាដូច្នេះថា

ន មយ្ហំ មាតិកំ នាមំ នបិ បេតិកសម្ភវំ
ជាតោម្ហិ វេស្សវីថិយា តស្មា វេស្សន្តរោ អហូតិ ៗ

សារីបុត្ត ហៃបាសារីបុត្តអើយ នាកាលតថាគតកើតមកបាន ឈ្មោះថា ព្រះវេស្សន្តរនោះ មិនមែនជាប់ដោយព្រះនាមមាតាបិតាឡើយ ដោយហេតុតែតថាគតកើតនាកណ្ដាលផ្លូវឈ្មួញធំ ក៏ អស់ព្រះញាតិផង គេមកសន្មតកត់ព្រះនាមតថាគតថា " ព្រះមហាវេស្សន្តរកុមារ " ដូច្នេះហោង ៗ នាកាលថ្ងៃព្រះអង្គចាកចេញ

អំពីព្រះមាតុទរបវរថ្លៃនៃព្រះកន្លោងព្រះមាតានោះ ឰដ៏កាលនោះ មានដំរីញីមួយមានប្រក្រតីតែងតែដើរ ឰដ៏កណ្ដាលអាកាស នាំកូនដំរីឈ្មោលមួយមកថ្វាយព្រះបរមពោធិសត្វ ហើយមេដំរីនោះក៏ហោះបាត់វិញទៅ ។ ដំរីនោះកើតមកជាបច្ច័យ នៃព្រះមហាសត្វ ទើបអស់មហាជនផងទាំងឡាយ សន្មតនាមដំរីនោះថា " បច្ច័យនាគេន្ទ្រ ① " ហោង ។

រាជា មហាសត្តស្ស អតិទីឃាទិទោសវជ្ជិតា អលម្ពត្ថនិយោ មធុរខីរាយោ ចតុស្សដ្ឋី ធាតិយោ ឧបេសិ ② ទើបមហាក្សត្រាធិរាជ ស្ដេចឱ្យស្រាវជ្រើសរើសរកមេនំ ឱ្យបាន ៦៤ នាក់ វៀរលែងនូវទោស ជាដើម គឺ ខ្ពស់ពេក ទាបពេក ទោះបីដោះសណ្ដាយ ក៏ស្ដេចពុំឱ្យយកឡើយ ឱ្យយកតែដោះក្បំ សមនូវរូបនោះល្អប្រពៃ ទើបព្រះអង្គឱ្យយកមកជាមេនំ បម្រើព្រះបរមពោធិសត្វនោះ ហើយស្ដេចឱ្យមេនំទៅអស់ក្មេង ទាំង ៦ ម៉ឺននោះ មួយ ៗ ម្នាក់ សព្វគ្រប់ទាំង ៦ ម៉ឺន ។ លុះព្រះពោធិសត្វចម្រើនធំឡើង ទើបព្រះមហាក្សត្រាធិរាជ ស្ដេចឱ្យប្រដាប់នូវគ្រឿងអលង្ការ មានតម្លៃ ១ សែនតម្លឹង ឱ្យព្រះបរមពោធិសត្វ ៗ ទ្រង់បន្តិចហើយ ស្ដេចដោះឱ្យទៅជាទានអស់មេនំផងទាំងឡាយ

១- ក្នុងជាតកវណ្ណនាបាលីថា " បច្ចយោតិ នាមំ ករឹសុ " តាំងឈ្មោះថា " បច្ច័យ " ដូច្នេះ តែច្បាប់សម្រាយស្លឹករឹត ដោយច្រើនសរសេរថា " បច្ច័យនាគេន្ទ្រ " ហើយមានច្បាប់ខ្លះទៀតថា " បច្ច័យនាគេន្ទ្រនរេន្ទ្រគជសារ " ដូច្នេះក៏មាន ។ ២- ច្បាប់ខ្លះថា " ឧបដ្ឋបេសិ " ។

ហើយព្រះមហាក្សត្រាធិរាជ ទ្រង់ឱ្យប្រដាប់ថ្វាយដល់ព្រះបរមពោធិសត្វវិញទៀត ព្រះអង្គទ្រង់បន្តិច ហើយស្ដេចដោះប្រទានទៅមេនំផងវិញទៀត ៗ នាកាលព្រះអង្គនៅក្មេងនៅឡើយនោះ តែងនឹងដោះគ្រឿងប្រដាប់ ឱ្យទៅជាទានមេនំផងទាំងឡាយរៀង ៗ ទៅជាគម្រប់ ៩ ដងហោង ៗ

សោ អដ្ឋវស្សិកកាលេ បន បាសាទវរគតោ សយនប្បិដ្ឋេ និសិន្នោ ចិន្តេសិ លុះព្រះអង្គចម្រើនធំឡើង បានព្រះជន្ម ៨ ព្រះវស្សាហើយ ស្ដេចឡើងទៅលើប្រាសាទរ័ត្ន គង់លើខ្នងកម្រាលជាប្រដាប់ដ៏ប្រសើរ កើតព្រះតម្រិះក្នុងព្រះរាជហឫទ័យ នឹងចង់ឱ្យអជ្ឈត្តិកទាន គឺទានក្នុងខ្លួនព្រះអង្គឯងថា នរអ្នកឯណាមួយជាស្មូមយាចក មកសូមក្បាលអញក្ដី ទោះវាមកសូមភ្នែកអញក្ដី ទោះវាសូមថ្លើមអញក្ដី សាច់ស្អួតឈាមអញក្ដី ក៏អញនឹងកាត់ក្បាលឆ្កៀលយកភ្នែក ពុះទ្រូងរូងយកថ្លើម អារសាច់សម្រក់ឈាម ឱ្យទៅជាទានស្មូមផងទាំងឡាយនោះ ទោះស្មូមឯណាមួយវាមកស្រដីថានែព្រះវេស្សន្តរអើយ អ្នកទៅនៅបម្រើអញ ក៏អញនឹងលួងលោមអាត្មាអញ ឱ្យទៅនៅជាខ្ញុំបម្រើអ្នកនោះហោង ៗ

តស្សេវំ សភាវំ សរសចិត្តេ ចិន្តេន្តស្ស ចតុនហុតាធិកទ្វិយោជនសតសហស្សពហលា អយំ មហាបថវី មត្តវរវារណោ វិយ គជ្ជមានា កម្បិ ៗ សិនេរុបព្វតរាជា សុសេទិតវេត្តង្កុរោ វិយ ឱនមិត្វា ជេតុត្តរនគរាភិមុខោ

អដ្ឋាសិ កាលនោះ ព្រះអង្គត្រិះរិះ ក្នុងព្រះរាជហឫទ័យ នឹងឱ្យអជ្ឈត្តិកទាននោះ ក៏កើតជាអស្ចារ្យក្រៃពេក រីក្រឡាមហាប្រឹថពីឯង មានកម្រាស់នោះ ២ សែន ដ៏អធិកនីទៅនូវ ៤ ម៉ឺនយោជន៍ ក៏ពុំអាចដើម្បីនឹងទប់ទល់តម្កល់អាត្មាភាពនោះបានឡើយ សឹងដ៏ករក្រើក រំពើកបញ្ចោញនូវស័ព្ទសម្រែកនោះ ស្មើរមហិមាក្រៃពេក មិនប៉ុន្តែម្ល៉ោះសោត រីឯមហាសមុទ្រឯង ដ៏មានទឹកនោះពុះពោរផោរឡើង រំជិរំជែងបោកបែកផ្កាត្រែង រលករលង មកលើមាត់ច្រាំង រីភ្នំសិនេរុបព្វតរាជនោះសោត សឹងដ៏មានកំពូលនោះទន់ល្វន់ល្វាសទៅមក បីដូចចុងដំបងទងផ្តៅ គិតដ៏អ្នកកាត់ចុងដើមបោះទៅក្នុងពពុះភ្លើង ហើយយកមកបោចបកបញ្ឈរឡើងទន់ល្វន់ល្វាសនោះ មានប្រការដូចម្តេចមិញ រីភ្នំព្រះសិនេរុរាជនោះ ក៏ឱនលំទោន ឆ្ពោះទៅកាន់ជេតុត្តរនគរនោះ មានប្រការដូច្នោះហោង ៗ រីបណ្តាភ្នំទាំងពួងសោត សឹងដ៏មានកំពូលនោះរណ្តំគ្នា បន្លឺនូវស័ព្ទឮសូរគឹកកងក្រៃពេក ៗ រីផ្គរសោត ដ៏លាន់ឮនូវស័ព្ទនោះកងរំពង រីផ្លេកបន្ទោរ ពុំជូកាល សឹងដ៏ដាលច្រវាត់ចាលចាញ់សម្ភារបារមីនៃព្រះបរមពោធិសត្វ ព្ធដ៏កាលនោះ ព្រះឥន្ទ្រាធិរាជ ក៏ទះព្រះហស្តថ្វាយស័ព្ទសាធុការ ទាំងមហាព្រហ្ម ក៏ស្លុតីថ្វាយជ័យមង្គល រីស័ព្ទកោលាហល ក៏កើតប្រាកដដរាបដល់ព្រហ្មលោកនាយហោង ៗ

(ទុត្តម្បិ ចេត្តំ សេចក្តីនេះ សមដូចព្រះពុទ្ធដីកាដែលព្រះ

អង្គ មានព្រះបន្ទូលជាបាទព្រះគាថា ដូច្នេះ

យទាហំ ទារកោ ហោមិ ជាតិយា អដ្ឋវស្សិកោ
តទា និសជ្ជ បាសាទេ ទានំ ទាតុំ វិចិន្តយឹ ។
ហទយំ ទទេយ្យំ ចក្ខុំ មំសំបិ រុធិរំបិ ច
ទទេយ្យំ កាយំ សាវេត្វា យទិកោ យាចយេ មមន្តិ ។
សភាវំ ចិន្តយន្តស្ស អកម្បិតមសណ្ឋិតំ
អកម្បិ តត្ថ បឋវី សិនេរុវនវដំសកាតិ ។

កាលអញ្ញតថាគតនៅជាទារក កើតមកបានអាយុ ៨ ខួប អង្គុយគិតនៅក្នុងប្រាសាទ ដើម្បីនឹងឱ្យទាន ក្នុងវេលាគ្រានោះ ប្រសិនណាបើមានស្មូមមកសូមបេះដូង ភ្នែក សាច់សួត លោហិត ឬរាងកាយក្តី អញ្ញតថាគត ក៏នឹងពុះវះកាត់ឱ្យជាទានទាំងអស់ កាលអញ្ញតថាគតកំពុងគិតត្រិះរិះដូច្នេះ ចិត្តតថាគតឥតមានរំភើបញាប់ញ័រ រន្ធត់តក់ស្លុតឡើយ ក្នុងសម័យនោះ ផ្ទៃផែនដី ដែលមានភ្នំសិនេរុរាជ និងព្រៃហេមពាន្ត ជាគ្រឿងប្រដាប់ ក៏កក្រើកញាប់ញ័រ ជាចលាចលអស្ចារ្យ (១)) ។

ពោធិសត្តោ (២) **សោឡសវស្សិកកាលេយេវ សព្វសិប្បានំ និប្ផត្តឹ បាបុណិ** លុះព្រះបរមពោធិសត្វ ចម្រើនឡើង

១- ក្នុងវង់ក្រចកនេះ ទាំងបាលីទាំងសេចក្តីប្រែ មិនមានក្នុងច្បាប់មហាជាតក៏សម្រាយទេ ឃើញមានតែក្នុងមហាវេស្សន្តរជាតកបាលី ទើបស្រង់យកមកប្រែបំពេញតាមច្បាប់បាលី ។ ២- មានច្បាប់ខ្លះថា " មហាសត្តោ " ដូច្នេះក៏មាន ។

បានព្រះជន្ម ១៦ ព្រះវស្សា ព្រះអង្គរៀនចប់ត្រៃវេទផងទាំងឡាយ ឥតទើសទាល់សល់នឹងប្រាជ្ញាទិព្វវិសេសនោះឡើយ ។ អណ្ដាប់នោះ សម្ដេចព្រះវររាជបិតា ទ្រង់មានព្រះបំណងនឹងព្រះរាជទានរាជ្យទៅព្រះពោធិសត្វ ទ្រង់ប្រឹក្សានឹងព្រះនាងសុបារសុប្បតីទេវីស្រេចហើយ ស្ដេចឱ្យទៅនាំនាងខត្តិយកញ្ញាមួយឈ្មោះនាងមទ្រីទេវីសោភា អំពីមាតុលនគរ ដ៏ជាព្រះរាជត្រកូលនៃសម្ដេចមទ្ទរាស្ត្រ មកហើយ ទើបព្រះមហាក្សត្រ តម្កល់ព្រះនាងមទ្រីទេវីនោះឱ្យជាអាយ៏អគ្គមហេសី ជាអធិបតីនៃអស់ស្ត្រីទាំង ១ មុឺន ៦ ពាន់នោះ ហើយអភិសេកព្រះបរមពោធិសត្វ ឱ្យសោយរាជសម្បត្តិបិតស្នងគ្រងព្រះរាជប្រពៃណី តអំពីសម្ដេចព្រះវររាជបិតាធិរាជនោះឯងហោង ។

មហាសត្តោ រជ្ជេ បតិដ្ឋិតកាលតោ បដ្ឋាយ ទេវសិកំ ទេវសិកំ ឆ សតសហស្សានិ វិសជ្ជេន្តោ មហាទានំ បវត្តេសិ ចាប់ដើមអំពីកាលព្រះបរមពោធិសត្វ មហាបុរសវ័ត្ថវិសេស បានសោយរាជសម្បត្តិហើយ ក៏ស្ដេចចាយព្រះរាជទ្រព្យ ឱ្យជាទានអស់ស្មូមយាចក អ្នកកម្សត់ទុគ៌តទាំងឡាយ ក្នុងមួយថ្ងៃ ៗ នោះ ប្រាំមួយសែនតម្លឹង គ្រប់សព្វសាលាទានទាំង ៦ នោះ ៗ លុះយូរលង់បន្តិចទៅកូវ សម្ដេចព្រះភគវតីមទ្រីទេវីទ្រង់គភ៌ខែ ១០ គ្រប់បរិបូណ៌ ពុំយូរឡើយ ព្រះនាងប្រសូតព្រះរាជបុត្រមួយបរិសុទ្ធកន្លង រីពពួកព្រះញាតិទាំងឡាយ ទទួលព្រះរាជ

កុមារនឹងបណ្តាញមាស ហេតុនោះហោង ក៏សន្មតព្រះនាមហៅថា " **ចៅជាលីកុមារ** " ៗ លុះចៅជាលីកុមារ ចេះចាប់សៀវដើរទេងទោង ឈោងវារបន្តិច ៗ ហើយកូវ ព្រះនាងប្រសូតព្រះរាជបុត្រីមួយវិញទៀត អស់ព្រះញាតិផងទាំងឡាយ នាំគ្នាទទួលព្រះរាជបុត្រីនោះនឹងស្បែកខ្លាឃ្មុំ រាយផ្កាយសឹងមាស ហេតុនោះឯង ទើបសន្មតកត់ហៅថា " **នាងក្រស្នាកុមារី** ① " ដូច្នេះ ៗ

មហាសត្តោ មាសស្ស ឆក្ខត្តុំ អលង្កតហត្ថិក្ខន្ធវរគតោ ឆ ទានសាលាយោ ឱលោកេសិ ព្រះមហាសត្វ ព្រះអង្គឡើងគង់លើដំរីរ័ត្នមង្គលដ៏ប្រសើរ ស្តេចទៅទតសាលាទានទាំង ៦ ក្នុង ១ ខែ ៦ ដងសព្វៗខែរៀងទៅ ៗ

តទា កលិង្គរដ្ឋេ ទុព្វុដ្ឋិកា អហោសិ ពួដ៏កាលនោះ មានស្រុកស្តេចព្រាហ្មណ៍មួយ ឈ្មោះកលិង្គរាស្ត្រ នៅពួដ៏ទុព្វុដ្ឋិគ្រាម (២) កើតទុរ្ភិក្ស រាំងភ្លៀងអត់បាយ រីទន្ស្រាយសោត សឹងដ៏កាត់ស្រូវ ដង្កូវរោមផ្លែពេញទាំងស្រែ ឯស្រូវនោះ ក៏វាស្កកស្លាប់អស់ មិនមានសល់ដល់តិចឡើយ អស់មហាជនផងទាំងឡាយ សឹងកើតជាចោរខ្ជួយអស់ហោង (៣)

១- ពាក្យនេះតាមស័ព្ទបាលីហៅថា " កណ្ហាជិនា " ៗ ២- ទុព្វុដ្ឋិគ្រាម កើតទុរ្ភិក្សរាំងភ្លៀង មានឈ្មោះតែក្នុងច្បាប់មហាជាតក៏សម្រាយ ឯច្បាប់មហាជាតក៏បាលី មិនមានឈ្មោះនេះទេ ៗ ៣- មានច្បាប់មហាជាតក៏សម្រាយខ្លះ បានបរិយាយកើនលើសបន្តិចទៅទៀតថា ៖ បើអ្នកឯណាមួយ មានស្រូវដល់ ១ ដោក

ឆ្លង...

ហើយកើតជាកោលាហលវរល់ ក្នុងព្រះនគរ ក្រៅព្រះនគរ ឥតសុខសប្បាយដល់តិចឡើយ ទើបអស់នាម៉ឺនមន្ត្រី សេនាបតី រាជបណ្ឌិត អាមាត្យ កវី អ្នកប្រាជ្ញ រាជបុរោហិត ព្រាហ្មណ៍ព្រឹទ្ធ ផងទាំងពួង បបួលគ្នាជំនុំ នៅនាកណ្ដាលមុខព្រះលាន ហើយ ទើបក្រាបបង្គំទូលព្រះមហាក្សត្រាធិរាជ ថា បពិត្រព្រះសម្មតិទេពក្សត្រថ្លៃប្រសើរអើយ ឥឡូវនេះ វាកើតកោលាហលវរល់ដូច្នេះ តើយើងខ្ញុំនឹងធ្វើដូចម្ដេច ក៏នឹងបានភ្លៀងបង្អុរចុះមកបាន សូមទានព្រះមេត្តាប្រោស ព្រះអង្គគិត (រកឧបាយ) ក៏បានអេះ ថាបើព្រះអង្គមិនទ្រង់គិតហើយ អស់មហាជនផងទាំងឡាយ មុខជាអត់បាយស្លាប់អស់មិនទេឡើយ ។

តំ សុត្វា រាជា ភី តាវតិ ទុត្តេ ព្រះមហាក្សត្រាធិរាជ ទ្រង់ព្រះសណ្ដាប់ហើយ មានព្រះបន្ទូល ថា ម្នាលអ្នកទាំងឡាយអើយ ថាបើដូច្នោះ រង់ចាំអញសិនឱ្យបាន៧ថ្ងៃ សូមភ្លៀងនោះលមើល ។ ព្រះមហាក្សត្រាធិរាជមានព្រះបន្ទូលម្ល៉ោះហើយ ឱ្យដំណើរអស់មុខមន្ត្រីផងទាំងឡាយ ទៅកាន់ឋានលំនៅអាត្មាទីទៃៗ នោះវៀងខ្លួនហោង ។ ឯក្រោយនោះឯង ព្រះមហា-

---

១ ជាលក្ដី សឹងឡើងប្លន់ កាប់សម្លាប់ម្ចាស់ស្រូវនោះ ដណ្ដើមយកទៅធី ដោយហោចអំពីនោះទៅ ទោះយោបីនឹងដណ្ដាំបាយក្ដី ថាបើប្រហែសហើយ វាធ្វើលំងកច្រកកន្ធាំ ភើចកន្ត្រាក់ទម្លាក់ទៅធី មិនគិតឡើយ ហើយកើតជាកោលាហល ។

ក្សត្រាធិរាជ ព្រះអង្គឡើងទៅគង់លើប្រាសាទរ័ត្នដ៏ប្រសើរ ទ្រង់នូវព្រះពស្ត្រស បរិសុទ្ធ មកស្ពាយឆៀងប្រពៃ ហើយតាំងចាំសីលឧបោសថ ៧ ថ្ងៃ នោះក្តី សូម្បីនឹងមានភ្លៀងស្រក់ចុះមក ១ តំណក់នោះ ក៏គ្មានឡើយ ៗ អស់មុខមន្ត្រីផង ទៅជំនុំគ្នាវិញទៀត ទើបព្រះមហាក្សត្រាធិរាជ មានព្រះបន្ទូលថា ម្នាលអ្នកទាំងឡាយអើយឥឡូវនេះ អញចាំសីលឧបោសថនោះ ជាគម្រប់ ៧ ថ្ងៃ ថ្ងៃនេះហើយ សូម្បីនឹងមានភ្លៀងធ្លាក់ចុះមកដល់ ១ តំណក់នោះ ក៏គ្មានឡើយ ដូច្នេះ តើយើងនឹងគិតធ្វើដូចម្តេច តអំពីនេះទៅទៀត ៗ ទើបអស់មុខមន្ត្រីផងទាំងឡាយ ក្រាបបង្គំទូលថា សូមទានព្រះមេត្តាប្រោស យើងខ្ញុំអម្ចាស់បានដឹងឮថា ព្រះបាទស្រីវេស្សន្តរ ជាព្រះរាជបុត្រព្រះបាទស្រីសញ្ជ័យ នៅនាជេតុត្តរនគរសព្វថ្ងៃនេះ តែងនឹងយកមាសប្រាក់ឱ្យទានស្មូមយាចកផងទាំងឡាយ មិនដែលដាច់ឡើយ យើងខ្ញុំឮថា ព្រះអង្គមានដំរីរ័ត្នមង្គលមួយឈ្មោះ បច្ច័យនាគេន្ទ្រ ៗ រីឯដំរីនោះសោត ថាបើដួចដល់ទៅឋានឯណា ៗ ហើយ ភ្លៀងក៏តែងបង្អុរធ្លាក់ចុះ ក្នុងទីនោះ ៗ ៗ រីស្រូវ អង្ករសណ្តែក ល្ង នោះ ក៏កើតមានឡើងប្រាកដ ទាំងមាសប្រាក់កែវកងសម្បត្តិសម្បូណ៌សោត ក៏កើតមានឯងច្រើន ៗ សូមទ្រង់ព្រះមេត្តាប្រោស មានតែព្រះអង្គប្រើព្រាហ្មណ៍ ទៅសូមដំរីនោះ នាំយកមកឥឡូវនេះហោង ៗ ព្រះមហាក្សត្រ ទ្រង់ព្រះសណ្តាប់ហើយ មានព្រះរាជហឫទ័យនោះ ត្រេកអរក្រៃពេក ទើបស្រាវ

ជ្រើសរើសអស់ព្រាហ្មណ៍ផងទាំងឡាយនោះ បាន ៨ នាក់ **តេសំ នាមានិ** រីឈ្មោះព្រាហ្មណ៍ទាំង ៨ នាក់នោះ មួយឈ្មោះរាមព្រាហ្មណ៍ មួយឈ្មោះធជព្រាហ្មណ៍ មួយឈ្មោះលក្ខណព្រាហ្មណ៍ មួយឈ្មោះសុជាតិមន្តព្រាហ្មណ៍ មួយឈ្មោះយញ្ញព្រាហ្មណ៍ មួយឈ្មោះសុជាតព្រាហ្មណ៍ មួយឈ្មោះកោណ្ឌញ្ញព្រាហ្មណ៍ មួយឈ្មោះសុយាមព្រាហ្មណ៍ ព្រះមហាក្សត្រាធិរាជមានព្រះបន្ទូលផ្ដាំដោយនូវដំណើរនោះស្រេចហើយ ឱ្យដំណើរព្រាហ្មណ៍ទាំង ៨ នាក់នោះទៅហោង ៗ

អថ តេ ព្រាហ្មណា(១) **អនុបុព្វេន ជេតុត្តរនគរំ បត្វា សាលគ្គេ ភត្តំ ភុញ្ជិត្វា** ព្រាហ្មណ៍ទាំង ៨ នាក់នោះ ដើរទៅតាមអណ្ដាប់អណ្ដោយ ទៅដល់នគរជេតុត្តរនោះ ព្រាហ្មណ៍ហូបបាយល្ងាច នៅសាលាទាន ហើយដេកសម្រាន្ត នៅនាឋាននោះ នាកាលព្រាហ្មណ៍នឹងដេកនោះ មកគិតពិចារណានឹងគ្នាថា ម្នាលគ្នាយើងអើយ មានតែយើងយកល្អងធូលីដីខ្សាច់ លាបស្រឡាបអស់ទាំងខ្លួនយើងនោះ ទើបព្រះអង្គទតរមិលមើលមកយើង ស្គាល់ជាក់ថា ព្រាហ្មណ៍ ព្រាហ្មណ៍គិតនឹងគ្នាម្ល៉ោះហើយ ក៏ដេកលក់ស្រមុកខឺ ៗ ខុរ ៗ ដរាបដល់ថ្ងៃហោង ៗ បពិត្រអើយ លុះព្រឹកព្រហាមឡើងនោះឯង ព្រះបាទស្រីវេស្សន្តរ ព្រះអង្គស្រង់ជម្រះស្រេចហើយ ទើបសោយនូវភោជនាហារត្រកាល មានឱជារស

១- ច្បាប់ខ្លះថា " អដ្ឋ ព្រាហ្មណា " ដូច្នេះក៏មាន ៗ

ពីសាផ្សេង ៗ ទើបព្រះអង្គទ្រង់គ្រឿងប្រដាប់សម្រាប់ប្រពៃ ស្រេចហើយនៃ ស្តេចឡើងគង់លើបាដំរីរ័ត្នមង្គលប្រសើរ ស្តេចលីលាទៅទតសាលាទានទាំង ៦ នោះ ស្តេចចែកចាយព្រះរាជទ្រព្យ ព្រះរាជទានស្មូមយាចកផងទាំងឡាយ ៗ រីព្រាហ្មណ៍ទាំង ៨ នាក់នោះយល់ស្មូមផងទទួលយកទាននោះ ឆោឡោចង្អៀតទាំងសាលានឹងចូលទៅសូមដំរីបច្ច័យនាគេន្ទ្រពួដ៏ឋាននោះពុំបានឡើយ ហើយបបួលគ្នាដើរទៅកាន់សាលាទានឯត្បូង ឈរលើដំបូកបានបន្តិចក្លូវព្រះមហាក្សត្រាធិរាជ ស្តេចបរដំរីទៅទតសាលាទាន ពួដ៏ទ្វារឯត្បូងនោះ ហើយព្រាហ្មណ៍ទាំង ៨ នាក់នោះ រមិលមើលទៅយល់ព្រះមហាក្សត្រាធិរាជ ក៏នាំគ្នាលើកដៃដាក់លើសិរសា ក្រាបបង្គំទូលសេចក្តីដូច្នេះថា **ជយតុ ភវំ ជយតុ ភវំ វេស្សន្តរ** សូមព្រះបាទស្រីវេស្សន្តរ ដ៏ជាមហាក្សត្រប្រសើរ ព្រះអង្គមានជ័យជម្នះ ព្រះអង្គមានជ័យជម្នះ ឈ្នះអស់សត្រូវផងទាំងពួង ៗ ព្រះមហាក្សត្រ ស្តេចទតយល់ព្រាហ្មណ៍ទាំង ៨ នោះហើយ មានព្រះបន្ទូលដណ្តឹងសួរ ជាបាទព្រះគាថា ដូច្នេះ ថា

បរុឡ្ហកច្ឆនខលោមា បង្កទន្តា រជស្សិរា
បគ្គយ្ហ ទក្ខិណំ ពាហុំ កឹ មំ យាចន្តិ ព្រាហ្មណាតិ ៗ

ម្នាលប្រស្តែងព្រាហ្មណ៍អើយ អញពិតពិល រមិលមើល ទៅប្រស្តែងនេះហើយ យល់អាក្រក់អ្វីមាល្បាយអេះ សឹងប្រឡាក់នូវផង់ធូលីដុំខ្សាច់ ដ៏មានធ្មេញស ប្រស្តែងលើកនូវដៃស្តាំ ដាក់លើ

ក្បាល ហើយពោលដូច្នេះថា **ជយតុ ភវំ ជយតុ ភវំ** នោះតើប្រស្តែងមានបើចង់សូមទ្រព្យអ្វីអំពីអញហៈ ។ ព្រាហ្មណ៍ទាំង ៨ នាក់នោះឮហើយ ក្រាបថ្វាយបង្គំប្រណម្យទូល ជាបាទគាថាដូច្នេះ ថា

រតនំ នេវ យាចាម សិវីនំ រដ្ឋវឌ្ឍនំ
ទទាហិ បវរំ នាគំ ឦសាទន្តំ ឧរុឡ្ហវន្តិ ។

បពិត្រព្រះនារាយណ៍នរបតី ស្រីសម្មតិទេពមហារាជប្រសើរអើយ យើងខ្ញុំមកសូមដំរីរ័ត្នប្រសើរ តែងនឹងចម្រើនសិរីសួស្តី អ្នកស្រីពិរាស្ត្រផងទាំងពួង ដ៏មានភ្លុកស្តាំនោះងទន្ទាំ កំពុងពេញកម្លាំង ដ៏មានចាមរនោះល្អាយល្អង វាំងគន្លង បោសព្រះធរណី សូមព្រះអង្គព្រះរាជទានមកយើងខ្ញុំព្រះអង្គហោង ។

តំ សុត្វា មហាសត្តោ អហំ សីសមាទី កត្វា អជ្ឈត្តិកទានំ ទាតុកាមោម្ហិ ព្រះមហាក្សត្រ ស្តេចស្តាប់ពាក្យព្រាហ្មណ៍ហើយ ព្រះអង្គទ្រង់ព្រះចិន្តាពិចារណាថា អញនៅសព្វថ្ងៃនេះ គិតតែនឹងចង់ឱ្យអជ្ឈត្តិកទាន គឺទានក្នុងខ្លួនអញ ក៏ឥឡូវនេះ ព្រាហ្មណ៍សូមដំរីបច្ច័យនាគេន្ទ្រនេះ ហៅថា ពាហិរកទាន ក្រៅខ្លួនអញ ក៏អញនឹងឱ្យឥឡូវនេះឯង ។ ព្រះបរមពោធិសត្វទ្រង់ព្រះចិន្តាពិចារណានូវប្រការអម្បាលណោះហើយ ទើបមានព្រះបន្ទូលទៅនឹងព្រាហ្មណ៍ទាំង ៨ នោះ សូត្រជាបាទព្រះគាថាដូច្នេះ ថា

ទទាមិ ន វិកម្បាមិ យំ មំ យាចន្តិ ព្រាហ្មណា
បភិន្នំ កុញ្ជរំ ទន្តី ឱបគុយ្ហំ គជុត្តមន្តិ ។

ហែប្រស្តែងព្រាហ្មណ៍អើយ អញនៅសព្វថ្ងៃនេះ ពុំមានចិត្តរន្ធត់ទៅដោយចិត្តកំណាញ់ឡើយ មួយសោត អញនៅសព្វថ្ងៃនេះពុំមានសំណល់សំចៃលាក់នូវទ្រព្យល្អអ្វីមួយ នឹងស្នូមនោះ ឥតអន្តីមានឡើយ ឥឡូវនេះ ប្រស្តែងមកសូមដំរីរ័ត្នមង្គល ដ៏ជាដំរីឧត្តមសមជារាជពាហនៈ ដ៏ប្រសើរ អំពីអញ ៗ នឹងប្រទានឱ្យប្រស្តែងឥឡូវនេះហោង ។

តេន វុត្តំ ហេតុនោះហោង ព្រះអង្គបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលនឹងព្រះមហាសារីបុត្តត្ថេរ ថា

ហត្ថិក្ខន្ធតោ ឱរុយ្ហ រាជា ចាគាធិមានសោ
ព្រាហ្មណានំ អទា ទានំ សិវីនំ រដ្ឋវឌ្ឍនន្តិ ។

ហែបាសារីបុត្ត អើយ កាលនោះ ព្រះបាទស្រីវេស្សន្តរបរមក្សត្រ តែងមានព្រះរាជហឫទ័យសទ្ធាជ្រះថ្លា ទ្រង់ព្រះរាជទានដំរីបច្ច័យនាគេន្ទ្រស្រេចហើយ ស្ដេចចុះអំពីកដំរីរ័ត្នមង្គល ទ្រង់ប្រទក្សិណ ៣ ជុំ ហើយស្ដេចទតមើលឋានឯណា ពុំទាន់ប្រដាប់សព្វគ្រប់មិញ ព្រះអង្គក៏ឱ្យប្រដាប់បំពេញអស់ឋានទាំងនោះ ឱ្យពេញបរិបូណ៌ រួចទ្រង់មានព្រះបន្ទូលហៅពួកព្រាហ្មណ៍ទាំងអស់នោះឱ្យចូលមក ហើយស្ដេចចាប់ប្រមោយដំរីរ័ត្ន មានឧបមាបីដូចកម្រងផ្កាប្រាក់ ស្ដេចដាក់លើដៃព្រាហ្មណ៍ហើយស្រេច ស្ដេចយកនូវទឹក

គណ្ឌីមាស ក៏ពេញនីទៅនូវទឹកអប់ត្រឡប់នូវគន្ធពិដោរ ព្រះអង្គទ្រង់ច្រួចទឹកលើដៃព្រាហ្មណ៍ ហើយព្រះរាជទានដំរីរ័ត្នមង្គលនោះទៅព្រាហ្មណ៍ទាំងនោះហោង ។

ហៃបាសារីបុត្តអើយ រីឯគ្រឿងប្រដាប់ជើងដំរីទាំង ៤ នោះសោត មានតម្លៃ ៤ សែនតម្លឹង រីគ្រឿងប្រដាប់សម្រាប់ សងខាងជើងដំរីនោះសោត មានតម្លៃ ២ សែនតម្លឹង រីសំពត់រាយផ្កាយមាសពាសព្ធដ៏ផ្ទៃដំរីនោះសោត មានតម្លៃមួយសែនតម្លឹង រីឯបណ្តាញរ័ត្នទាំង ៣ ជាគ្រឿងប្រដាប់រំយោលលើខ្នងដំរីនោះ មានតម្លៃ ៣ សែនតម្លឹង រីគ្រឿងប្រដាប់ថ្ពាល់ដំរី ទាំងសងខាងនោះ មានតម្លៃ ២ សែនតម្លឹង រីសំពត់រត្តកម្ពល ពាសក្រោលលើខ្នងដំរីនោះ មានតម្លៃ ១ សែនតម្លឹង រីគ្រឿងប្រដាប់ពោងដំរីនោះ មានតម្លៃ ១ សែនតម្លឹង រីមណីរ័ត្នទាំង ៣ ប្រដាប់ចង្កាដំរីនោះ មានតម្លៃ ៣ សែនតម្លឹង ឯគ្រឿងប្រដាប់ទាំងសងខាងត្រចៀតដំរីនោះ មានតម្លៃ ២ សែនតម្លឹង រីគ្រឿងប្រដាប់ភ្លុកដំរីទាំងសងខាងនោះ មានតម្លៃ ២ សែនតម្លឹង រីមណីរ័ត្នជាគ្រឿងប្រដាប់ប្រមោយដំរីនោះ មានតម្លៃ ១ សែនតម្លឹង រីមណីរ័ត្នប្រដាប់កន្ទុយដំរីនោះ មានតម្លៃ ១ សែនតម្លឹង រីមណីរ័ត្ន ប្រដាប់ជើងជណ្តើរ តែងនឹងឡើងដំរីនោះ មានតម្លៃ១ សែនតម្លឹង រីខ្ទះដណ្តាំបាយឱ្យដំរីសព្វថ្ងៃនោះ មានតម្លៃ ៩ តម្លឹង រីនឹងស្រដីអស់ទ្រព្យគ្រឿងប្រដាប់សម្រាប់ដំរីនោះ មកផ្សំអស់ទាំងអម្បាលណោះ ត្រូវ

ជាមាស២ លាន និង៤សែនតម្លឹងហោង ៗ ឯទ្រព្យក្រៅអំពីនោះទៅ រីមណីរ័ត្នប្រដាប់កង្វេរនោះក្តី រីមុក្តារ័ត្នប្រដាប់ខ្សែរំយោលស្វេតច្ឆ័ត្រសម្រាប់ដំរីនោះក្តី សឹងមានតម្លៃ នឹងកាត់ថ្លៃនោះពុំបានឡើយ ព្រះអង្គឱ្យទានមិនប៉ុន្តែដំរី និងគ្រឿងប្រដាប់នោះឡើយ ហើយស្តេចប្រទានអស់ទាំងពេទ្យហ្មទ្រមាក់រក្សា ទាំង ៥០០ ស្តេចឱ្យទៅជាទាន មួយអន្លើនឹងដំរីនោះឯង ៗ កាលនោះសេចក្តីអស្ចារ្យកើតមានប្រាកដ ទាំងក្រឡាមហាប្រឹថពីឯង ក៏កក្រើកជាដើម ដូចន័យដែលបានពោលរួចមកហើយ ៗ

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណា ពុំទាន់ប្រាកដ បទព្រះបាលីឯណា ពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលនឹងភិក្ខុផងទាំងឡាយ សូត្រជាបាទព្រះគាថា ដូច្នេះ

តទាសិ យំ ភឹសនកំ តទាសិ លោមហំសនំ
ហត្ថិនាគេ បទិន្នម្ហិ មេទនី សមកម្បថ ។
តទាសិ យំ ភឹសនកំ តទាសិ លោមហំសនំ
ហត្ថិនាគេ បទិន្នម្ហិ ខុភិត្ថ នគរំ តទា ។
សមាកុលំ បុរំ អាសិ ឃោសោ ច វិបុលោ មហា
ហត្ថិនាគេ បទិន្នម្ហិ សិវីនំ រដ្ឋវឌ្ឍនេតិ ។

ភិក្ខវេ ហៃភិក្ខុផងទាំងឡាយអើយ នាកាលព្រះវេស្សន្តរព្រះរាជទានដំរីបច្ច័យនាគេន្ទ្រ ទៅព្រាហ្មណ៍ទាំង ៨ នាក់នោះ

ក៏កើតអស្ចារ្យ ជាពន្លឹកមុខគួរខ្លាច នាំឱ្យព្រឺព្រួចអស់ទាំងលោមា អស់ទាំងអ្នកនគរ ក៏ភ្ញាក់ផ្អើលវរវីក សូរស័ព្ទអឺកធឹកលាន់ឮរំពង ជាអស្ចារ្យក្រៃលែង ក្នុងកាលដែលព្រះវេស្សន្តរព្រះរាជទានដំរី ដ៏ប្រសើរ តែងធ្វើនូវសេចក្តីចម្រើនដល់អ្នកស្រុកស្រីពិរាស្ត្រព្នដ៏កាលនោះហោង ៗ

ព្រាហ្មណា កិរ ឧត្តរទ្វារេ ហត្ថឹ លភិត្វា ហត្ថិប្បិដ្ឋេ និសីទិត្វា មហាជនបរិវុតា នគរមជ្ឈេន បាយឹសុ កាលនោះ ព្រាហ្មណ៍ទាំង ៨ នាក់ មកសូមដំរីបច្ច័យនាគេន្ទ្រ នៅទ្វារឯត្បូងនោះ បានហើយ ក៏នាំគ្នាឡើងជិះអំពីក្បាល វៀងទៅដល់កន្សៀ បរចេញទៅមួយអន្លើនូវអស់បរិវារផងទាំងឡាយប្រមាណ ៥០០ នាកណ្តាលព្រះនគរនោះឯង ៗ រីអស់មហាជនរមិលមើលទៅយល់ដំរីរ័ត្នមង្គលហើយ ក៏ស្រដីទៅវិញទៅមកកាន់គ្នា ថា អ្នកទាំងឡាយអើយ ព្រាហ្មណ៍នេះ វាបានដំរីអំពីឯណាបរទៅនោះអេះ អ្នកខ្លះរត់ទៅស្រែកដណ្តឹងសួរថា វុយព្រាហ្មណ៍ប្រ់ស្តែងបានដំរីនោះអំពីឯណា ក៏បរទៅព្រងើយ ដូច្នេះហ៊ឹះ ៗ រាមព្រាហ្មណ៍ ស្តាប់ហើយឆ្លើយថា ប្រ់ស្តែងដណ្តឹងធ្វើអ្វី ដំរីប្រ់ស្តែងឬអ្វីហាៈ ដំរីនេះ ព្រះបាទស្រីវេស្សន្តរព្រះអង្គឱ្យទានយើងៗ យកជិះបរទៅឯងអេះ ងារការអ្វីនឹងប្រ់ស្តែង ក៏ប្រ់ស្តែងមកដណ្តឹងហ៊ឹះ ៗ អ្នកខ្លះបូញមាត់ បត់ដុំដៃបង្ហាញទៅ ថា នែប្រ់ស្តែងដណ្តឹងរកដុំដៃដៅខ្នង ឬមួយនឹងចង់ស៊ីផ្លែស្រម៉ដៅក្បាលវិញហាៈ

ព្រាហ្មណ៍ស្រដីតែម្ល៉ោះហើយ ក៏បរដំរីនោះចេញទៅដោយនូវទ្វារឯជើងព្រះនគរនោះហោង ។

រីអស់អ្នកនគរផងទាំងឡាយ ហេតុតែទេវតា មកអាភៀសចិត្តនោះមិញណា ក៏សឹងតែខឹងនឹងព្រះពោធិសត្វនោះ មហិមាក្រៃពេក ហើយបប្អួលគ្នាទៅជំនុំនៅនាមុខព្រះលាន ស្រដីនូវពាក្យនោះកងរំពង ឮទៅនាកណ្ដាលអាកាស តេន វុត្តំ ហេតុនោះហោង ព្រះអង្គបានត្រាស់ប្រាជ្ញាសព៌ជ្ញតាញ្ញាណ ព្រះអង្គមានព្រះបន្ទូលនឹងព្រះមហាសារីបុត្តត្ថេរ សូត្រជាបាទព្រះគាថា ដូច្នេះ ថា

អថេត្ថ វត្តតិ សទ្ទោ   តុមុលោ ភេរវោ មហា
ហត្ថិនាគេ បទិន្នម្ហិ   ខុភិត្ថ នគរំ តទា ៗ
អថេត្ថ វត្តតិ សទ្ទោ   តុមុលោ ភេរវោ មហា
ហត្ថិនាគេ បទិន្នម្ហិ   សិវីនំ រដ្ឋវឌ្ឍនេតិ ៗ

ថាហៃបាសារីបុត្តអើយ ឮដ៏កាលនោះ រីអស់អ្នកនគរផងទាំងឡាយគេខឹងនឹងអញតថាគត ត្បិតតែឱ្យទានដំរីមង្គលប្រសើរទៅព្រាហ្មណ៍ ហាក់ដូចនឹងរបើករលើងទាំងព្រះនគរនោះឯងហោង ៗ ម្នាលបាសារីបុត្តអើយ នាកាលអញតថាគតប្រទានដំរីមង្គល តែងធ្វើនូវសេចក្ដីចម្រើនដល់អ្នកស្រុកស្រីពិរាស្ត្រ កាលនោះ មានសូរស័ព្ទកងរំពងទាំងនគរស្រីពិរាស្ត្រនោះ មុខគួរស្ញប់ស្ញែងជាពន្លឹក ៗ គ្រានោះ ពួកអ្នកនគរ មានចិត្តខេខឹងនឹងព្រះពោធិសត្វ ព្រោះតែព្រះអង្គព្រះរាជទានដំរីបច្ច័យនាគេន្ទ្រនោះ

ទើបនាំគ្នាឡើងក្រាបបង្គំទូលដល់ព្រះបាទស្រីសញ្ជ័យមហារាជ ដ៏ជាសម្តេចព្រះវររាជបិតា តេន ទុត្តំ ហេតុនោះហោង ព្រះអង្គមានព្រះបន្ទូលសូត្រជាបាទព្រះគាថាដូច្នេះថា

ឧគ្គា(១) ច រាជបុត្តា ច វេសិយានា ច ព្រាហ្មណា
ហត្ថារោហា អនីកដ្ឋា រថិកា បត្តិការកា ។
កេវលោ ចាបិ និគមោ សិវិយោ ចាបិ សមាគតា
ទិស្វា នាគំ នីយមានំ តេ រញ្ញោ បដិវេទយុំ ។
វិធមំ ទេវ តេ រដ្ឋំ បុត្តោ វេស្សន្តរោ តវ
កថំ នោ ហត្ថិនំ ទជ្ជា នាគំ រដ្ឋស្ស បូជិតំ ។
កថំ នោ កុញ្ជរំ ទជ្ជា ឦសាទន្តំ ឧរុឡ្ហវំ
ខេត្តញ្ញុំ សព្វយុទ្ធានំ សព្វសេតំ គជុត្តមំ ។
បណ្ឌុកម្ពលសញ្ឆន្នំ បភិន្នំ សត្តុមទ្ទនំ
ទន្តឹ សវាលវីជនឹ សេតំ កេលាសសាទិសំ ។
សសេតច្ឆត្តំ សុបត្ថេយ្យំ សាថព្វនំ សហត្ថិបំ
អគ្គយានំ រាជវាហឹ ព្រាហ្មណានំ អទា ធនន្តិ ។

១- មានច្បាប់មហាវេស្សន្តរខ្លះប្រែថា បុត្រអាមាត្យ ។ ក្នុងអភិធានប្បទីបិកាថាកើតអំពីក្សត្រនិងនាងសុទ្ទះ គឺចំណែកខាងបិតាជាក្សត្រ ចំណែកខាងមាតាជាសុទ្ទៈ តែសេចក្តីកែអត្ថ ក្នុងអដ្ឋកថាមហាវេស្សន្តរជាតកថា តត្ថ ឧគ្គាតិ ឧគ្គតា បញ្ញាតា បាកដា ។ ប្រែថា ជាអ្នកល្បីល្បាញ-ប្រាកដ ។

កាលនោះ ពួករាជបុត្រដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញ ពួកឈ្មួញ ពួកព្រាហ្មណ៍ ពួកពលដំរី ពួកពលសេះ ពួកពលរថ ពួកពលថ្មើរជើង រួមទាំងពួកអ្នកនិគមកុដុម្ពីក៍ ពួកអ្នកស្រុកស្រីពិរាស្ត្រ កាលបានឃើញព្រាហ្មណ៍បរដំរីចេញទៅដូច្នោះ ក៏មកប្រជុំព្រមល្មម ជាមួយគ្នា ហើយក្រាបទូលព្រះមហាក្សត្រថា ទេវ បពិត្រព្រះសម្មតិទេពក្សត្រថ្លៃប្រសើរអើយ រីព្រះបាទស្រីវេស្សន្តរ ជាព្រះរាជបុត្ររបស់ព្រះអង្គ មិនបិតដោយនូវគន្លងធម៌ ម្តេចឡើយ ក៏មកយក ឯដំរីរ័ត្នមង្គលដ៏ប្រសើររបស់យើងខ្ញុំព្រះរាជទានទៅជាទានព្រាហ្មណ៍ នាដំរីនោះ មានរស្មីភ្លឺផ្លេកៗ មានចាមរល្ដាយល្ដង រាំងគន្លងបោសព្រះធរណី ហើយមានភ្លុកឯស្តាំនោះងទន្ទាំ អាចញាំញីអស់សត្រូវផង សមនូវស្វេតច្ឆ័ត្រ ជារាជយានដ៏ប្រសើរ តែងនឹងនាំព្រះមហាក្សត្រ ដ៏មានខ្លួននោះសប្រហែលនឹងភ្នំកៃលាសបព៌ត ដ៏ជាបាដំរីប្រសើរ ម្តេចឡើយ ក៏លើកឱ្យទៅជាទានព្រាហ្មណ៍ សមអ្វីនឹងព្រាហ្មណ៍នោះហឹះ ឱ្យទានតែដំរីនោះទៅវ៉ា ម្តេចឡើយ ក៏ឱ្យទាំងស្វេតច្ឆ័ត្រ គ្រឿងប្រដាប់ពេទ្យហ្លួទម័កទាំង៥០០នោះ ទៅផង វាអស់សោះរលីងជាម្តងហោង ៗ

លុះអ្នកនគរទាំងនោះ ក្រាបបង្គំទូលយ៉ាងនេះហើយ ទើបក្រាបទូល សូត្រជាបាទគាថា ដូច្នេះទៀត ថា

(អន្នបានញ្ច សោ ទជ្ជា   វត្ថសេនាសនានិ ច
ឯតំ ខោ ទានបតិរូបំ   ឯតំ ខោ ព្រាហ្មណារហំ ៗ

អយំ តេ វសរាជានោ សិវីនំ រដ្ឋវឌ្ឍនោ
កថំ វេស្សន្តរោ បុត្តោ គជំ ភាជេតិ សញ្ជយ
សចេ ត្វំ ន ករិស្សសិ សិវីនំ វចនំ ឥទំ
មញ្ញេ តំ សហ បុត្តេន សិវិហត្ថេ ករិស្សរេតិ ។

បពិត្រព្រះសម្មតិទេពក្សត្រថ្លៃប្រសើរអើយ ព្រះបាទស្រីវេស្សន្តរនោះ ព្រះអង្គគួរតែព្រះរាជទានបាយ ទឹក សំពត់ អាវ សាវ ស្បៃ ទីដេក ទីអង្គុយផងទាំងពួង ត្បិតរបស់អស់នេះ សឹងសមគួរដល់ទាន ទាំងជារបស់ជាសមគួរដល់ពួកព្រាហ្មណ៍ផង ។ បពិត្រព្រះបាទស្រីសញ្ជ័យមហារាជអើយ ព្រះបាទស្រីវេស្សន្តរជាព្រះរាជបុត្ររបស់ព្រះអង្គ បានឡើងគ្រងរាជ្យតព្រះវង្ស តែងទ្រង់ធ្វើសេចក្ដីចម្រើនដល់អ្នកស្រីពិរាស្ត្រទាំងឡាយ ម្ដេចឡើយ ក៏មកយកដំរីរ័ត្នមង្គល ទៅព្រះរាជទានដល់ព្រាហ្មណ៍ ។ ល្គឹកណាតែព្រះអង្គមិនព្រមធ្វើតាមពាក្យអ្នកស្រីពិរាស្ត្រនេះទេ អ្នកស្រីពិរាស្ត្រ នឹងធ្វើព្រះអង្គព្រមទាំងព្រះរាជបុត្រ ឱ្យលុះនៅក្នុងកណ្ដាប់ដៃគេ មិនទេឡើយ① ។)

(ព្រះបាទស្រីសញ្ជ័យមហារាជ ព្រះអង្គទ្រង់ព្រះសណ្ដាប់សម្ដីអ្នកស្រីពិរាស្ត្រអស់នោះហើយ ក៏ទ្រង់ព្រះចិន្តាថា មនុស្សអស់នេះ

១- ទាំងបាលីទាំងសម្រាយក្នុងវង់ក្រចកនេះ មិនមានក្នុងច្បាប់មហាជាតក៏សម្រាយទេ ក្នុងទីនេះ អ្នកពិនិត្យផ្ទៀងផ្ទាត់ បានដកស្រង់យកមកប្រែបំពេញតាមច្បាប់ជាតកបាលី ដើម្បីកុំឱ្យរំលងពីច្បាប់បាលីដើមច្រើនពេក ។

ប្រាថ្នានឹងសម្លាប់បាវេស្សន្តរកូនអញ ទើបទ្រង់មានព្រះរាជឱង្ការ សូត្រជាបាទព្រះគាថា ដូច្នេះ ថា

កាមំ ជនបទោ ហសិ រដ្ឋញ្ចាបិ វិនស្សតុ
នាហំ សិវីនំ វចនា រាជបុត្តំ អទូសកំ ។
បព្វាជេយ្យំ សកា រដ្ឋា បុត្តោ ហិ មម ឱរសោ
កាមំ ជនបទោ ហសិ រដ្ឋញ្ចាបិ វិនស្សតុ ។
នាហំ សិវីនំ វចនា រាជបុត្តំ អទូសកំ
បព្វាជេយ្យំ សកា រដ្ឋា បុត្តោ ហិ មម អត្រជោ ។
ន ចាហំ តស្មិ ទុព្ភេយ្យ អរិយសីលវតោ ហិ សោ
អសិលោកោបិ មេ អស្ស បាបញ្ច បសវេ ពហុំ
កថំ វេស្សន្តរំ បុត្តំ សត្ថេន ឃាតយាមសេតិ ។

ទោះយោបីជនបទដែនដី វិនាសបាត់បង់ទៅ យ៉ាងណា ក៏ដោយ អញមិនព្រមបណ្តេញរាជបុត្រ ជាអ្នកឥតទោស ឱ្យចេញចាកដែនដីស្រីពិរាស្ត្រ តាមពាក្យអ្នកស្រីពិរាស្ត្រ ផងទាំងឡាយឡើយ ព្រោះបាវេស្សន្តរ ជាបុត្រកើតពីទ្រូងរបស់អញ កើតអំពីខ្លួនអញ ។ មួយវិញទៀត អញមិនគួរប្រទូសរ៉ាយនឹងបាវេស្សន្តរឡើយ ព្រោះបាវេស្សន្តរនោះជាអ្នកមានសីលដ៏ប្រសើរ ចុះឱ្យអញសម្លាប់បាវេស្សន្តរដោយគ្រឿងសស្ត្រាវុធដូចម្តេចបាន⑴ ។

១- ទាំងបាលីទាំងសម្រាយក្នុងវង់ក្រចកនេះ មិនមានក្នុងច្បាប់មហាជាតក៏ សម្រាយទេ ក្នុងទីនេះ បានស្រង់យកមកពីច្បាប់បាលី ហើយប្រែសេចក្តីជាសម្រាយ បំពេញតាមច្បាប់បាលីដើម ។

ពួកអ្នកស្រីពិរាស្រ្ត បានស្តាប់ព្រះរាជតម្រាស់នោះហើយ ទើបនាំគ្នាក្រាបបង្គំទូលព្រះបាទស្រីសញ្ជ័យ ថា

មា នំ ទណ្ឌេន សត្ថេន   ន ហិ សោ ពន្ធនារហោ
បព្វាជេហិ ច នំ រដ្ឋា   វង្កេ វសតុ បព្វតេតិ ៗ

បពិត្រព្រះសម្មតិទេពក្សត្រថ្លៃប្រសើរអើយ រីព្រះបាទស្រីវេស្សន្តរ ដ៏ជាព្រះរាជឱរសរបស់ព្រះអង្គនោះ មិនគួរកាប់នឹងដាវ វាយនឹងដំបង ចងនឹងខ្សែទេ គ្រាន់តែនឹងបណ្តេញឱ្យទៅនៅឯភ្នំគិរីវង្កតបព៌តប៉ុណ្ណោះបានហើយ ៗ ព្រះបាទស្រីសញ្ជ័យ ទ្រង់ព្រះសណ្តាប់ពាក្យអ្នកស្រីពិរាស្រ្តទាំងនោះ ក្រាបទូលដូច្នោះហើយ ទើបទ្រង់មានព្រះបន្ទូល សូត្រជាបាទព្រះគាថា ដូច្នេះ ថា

ឯសោ ចេ សិវីនំ ឆន្ទោ   ឆន្ទំ ន បនុទាមសេ
ឥមំ សោ វសតុ រត្តឹ   កាមេ ច បរិភុញ្ជតុ ៗ
តតោ រត្យា វិវសានេ   សុរិយស្សុគ្គមនំ បតិ
សមគ្គា សិវិយោ ហុត្វា   រដ្ឋា បព្វាជយន្តុ តន្តិ ៗ

ម្នាលអ្នកទាំងឡាយអើយ នាបាវេស្សន្តរមានទោសនឹងអ្នកទាំងឡាយ នឹងបណ្តេញគាត់ចេញ អញនឹងថាអ្វីឡើយ តែសូមឱ្យអ្នកទាំងឡាយអត់ទោសគាត់ នារាត្រីនេះសិន ចាំដល់ព្រឹកស្អែកឡើង សឹមអ្នកទាំងឡាយ មកប្រជុំព្រមលួមជាមួយគ្នា ហើយបណ្តេញគាត់ចេញទៅហោង ៗ រីព្រះបាទស្រីសញ្ជ័យ ព្រះអង្គមានព្រះបន្ទូលម្ល៉ោះហើយ ក៏ឱ្យដំណើរពួកអ្នកស្រីពិរាស្រ្ត ទៅ

កាន់ឋានលំនៅអាត្មាទីទៃ ៗ ៗ ឯក្រោយនោះឯង ព្រះអង្គមានព្រះបន្ទូលប្រើរាជអាមាត្យមួយ ឱ្យនាំពត៌មានទៅថ្កានព្រះរាជបុត្រ អាមាត្យនោះទទួលព្រះរាជឱង្ការហើយ ក៏ទៅកាន់ព្រះរាជនិវេសន៍ព្រះបាទស្រីវេស្សន្តរ ក្រាបទូលពត៌មាននោះសព្វគ្រប់ ៗ

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណា ពុំទាន់ប្រាកដ បទព្រះបាលីឯណា ពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលនឹងភិក្ខុផងទាំងឡាយ សូត្រជាបាទព្រះគាថា ដូច្នេះ ថា

ឧដ្ឋេហិ កត្តេ តរមានោ   គន្ត្វា វេស្សន្តរំ វទ ៗ
សិវិយោ ទេវ តេ កុទ្ធា   នេគមា ច សមាគតា
ឧគ្គា ច រាជបុត្តា ច   វេសិយានា ច ព្រាហ្មណា ៗ
ហត្ថារោហា អនីកដ្ឋា   រថិកា បត្តិការកា
កេវលោ ចាបិ និគមោ   សិវិយោ ចាបិ សមាគតា ៗ
អស្មា រត្យា វិវសនេ   សុរិយស្សុគ្គមនំ បតិ
សមគ្គា សិវិយោ ហុត្វា   រដ្ឋា បព្វាជយន្តិ តំ ៗ
ស កត្តា តរមានោ វ   សិវិរាជេន បេសិតោ
អាមុត្តសព្វាភរណោ   សុវត្ថោ ចន្ទនភូសិតោ ៗ
សីសំ នហាតោ ឧទកេ សោ   អាមុត្តមណិកុណ្ឌលោ
ឧបាគមិ បុរំ រម្មំ   វេស្សន្តរនិវេសនំ ①

១- បើប្រែតាមរូបបាលីជាលំដាប់ទៅ មានសេចក្ដីដូច្នេះ ៖ ឆ្លង ...

តត្ថទ្ទស កុមារំ សោ   រម្មមានំ សកេ បុរេ
បរិកិណ្ណំ អមច្ចេហិ   តិទសានំវ វាសវំ ។
សោ តត្ថ គន្ត្វា រម្មមានំ   ភត្តា វេស្សន្តរមព្រវិ
ទុក្ខំ តេ វេទយិស្សាមិ   មា មេ កុជ្ឈ រថេសភ ។
វន្ទិត្វា រោទមានោ សោ   ភត្តា រាជានមព្រវិ
ភត្តា មេសិ មហារាជ   សព្វកាមរសាហរោ
ទុក្ខំ តេ វេទយិស្សាមិ   តត្ថ អស្សាសយន្តុ មំ ។
សិវិយោ ទេវ តេ កុទ្ធា   នេគមា ច សមាគតា (១)
ឧគ្គា ច រាជបុត្តា ច   វេសិយានា ច ព្រាហ្មណា

" រាជអាមាត្យនោះ ព្រះបាទស្រីសញ្ជ័យទ្រង់ចាត់បញ្ជូនទៅ ដោយព្រះតម្រាស់ថា ម្នាលអាមាត្យ ចូរអ្នកក្រោកឡើង ទៅក្រាបទូលបាវេស្សន្តរ ជាប្រញាប់ថា បពិត្រព្រះសម្មតិទេពក្សត្រថ្លៃប្រសើរអើយ រីអ្នកស្រីពិរាស្ត្រ អ្នកនិគម គេនាំគ្នាខឹងនឹងព្រះអង្គ ជនពួកឧគ្គៈ ពួករាជបុត្រ ពួកឈ្មួញ ពួកព្រាហ្មណ៍ ពួកពលដំរី ពួកពលសេះ ពួកពលរថ ពួកពលថ្មើរជើង ពួកអ្នកនិគម រួមទាំងអ្នកស្រីពិរាស្ត្រទាំងអស់មកប្រជុំគ្នាហើយ កាលរាត្រីនេះកន្លងផុតអស់ទៅ ព្រះអាទិត្យរះឡើងហើយ ពួកអ្នកស្រីពិរាស្ត្រ នឹងមកប្រជុំព្រមគ្នា បណ្តេញព្រះអង្គឱ្យថយចេញចាកដែនដីនេះ ។ រាជអាមាត្យនោះ ស្លៀកពាក់រៀបរយ ពាក់នូវគ្រឿងប្រដាប់ទាំងពួង លាបស្រឡាបដោយខ្លឹមច័ន្ទន៍ ជម្រះលាងក្បាលនឹងទឹករួចហើយ ពាក់កុណ្ឌលកែវមណី ហើយចូលទៅកាន់ព្រះរាជវាំងជាទីប្រថាប់របស់ព្រះបាទស្រីវេស្សន្តរ ។

១- លុះចូលទៅដល់ហើយ ក៏បានឃើញព្រះរាជកុមារស្តេចគង់ក្នុងព្រះរាជវាំងរបស់ព្រះអង្គមានពួករាជអាមាត្យគង់គាល់ត្រៀបត្រា ហាក់ដូចជាព្រះឥន្ទ្រាធិរាជនៃត្រៃត្រឹង្សសួគ៌ា ទើបរាជអាមាត្យក្រាបបង្គំទូលព្រះបាទស្រីវេស្សន្តរថា បពិត្រព្រះ

ឆ្លង ...

ហត្ថារោហា អនីកដ្ឋា រថិកា បត្តិការកា
កេវលោ ចាបិ និគមោ សិវិយោ ចាបិ សមាគតា ៗ
អស្ថា រត្យា វិវសនេ សុរិយស្សុគ្គមនំ បតិ
សមគ្គា សិវិយោ ហុត្វា រដ្ឋា បព្វាជយន្តិ តន្តិ(១) ៗ

ភិក្ខវេ ម្នាលភិក្ខុផងទាំងឡាយអើយ កាលនោះព្រះបាទស្រីសញ្ជ័យ ព្រះអង្គមានព្រះបន្ទូលនឹងរាជអាមាត្យ ថា ម្នាលរាជអាមាត្យអើយ ចូរបាទៅប្រាប់បាវេស្សន្តរ ឥឡូវនេះឯង ថា អ្នកស្រីពិរាស្ត្រផងទាំងពួង គេខឹងនឹងបាវេស្សន្តរ ត្បិតតែអ្នកឱ្យទានដំរីរ័ត្នមង្គលប្រសើរទៅព្រាហ្មណ៍ ៗ រីរាជអាមាត្យ ទទួលយកព្រះបន្ទូលថ្លៃពិសេសហើយ ក្រាបថ្វាយបង្គំលាទៅកាន់សម្នាក់

អង្គដ៏ប្រសើរអើយ ខ្ញុំព្រះអង្គមកក្រាបបង្គំទូលសេចក្តីទុក្ខដល់ព្រះអង្គ សូមព្រះអង្គកុំបីក្រេវក្រោធដល់ខ្ញុំព្រះអង្គឡើយ " រាជអាមាត្យថ្វាយបង្គំហើយ ក៏យំខ្សឹកខ្សួលក្រាបបង្គំទូលព្រះរាជាថា " បពិត្រមហារាជប្រសើរអើយ ព្រះអង្គជប់ល្បៀងទូលបង្គំជាខ្ញុំមកហើយ ទ្រង់តែងនាំមកនូវកាមរសទាំងពួង ខ្ញុំព្រះអង្គនឹងក្រាបបង្គំទូលសេចក្តីទុក្ខរបស់ព្រះអង្គ សូមព្រះអង្គទ្រង់ព្រះមេត្តាប្រោសខ្ញុំព្រះអង្គ ក្នុងដំណឹងទុក្ខនោះ ឱ្យទានផង, បពិត្រព្រះសម្មតិទេពក្សត្រថ្លៃប្រសើរអើយ រីពួកអ្នកស្រីពិរាស្ត្រ និងពួកអ្នកនិគម គេនាំគ្នាខឹងនឹងព្រះអង្គ ទាំងពួកឧគ្គៈ ពួករាជបុត្រ ពួកឈ្មួញ ពួកព្រាហ្មណ៍

១- ពួកពលដំរី ពួកពលសេះ ពួកពលរថ ពួកពលថ្មើរជើង រួមទាំងពួកអ្នកនិគម អ្នកស្រីពិរាស្ត្រផង គេនាំគ្នាមកប្រជុំព្រមគ្នាអស់ហើយ កាលអស់ផុតរាត្រីនេះ ព្រះអាទិត្យរះឡើងទៅហើយ អស់ពួកអ្នកស្រីពិរាស្ត្រផង ព្រមព្រៀងគ្នាបំបរបង់ព្រះអង្គឱ្យចេញចាករាជអាណាចក្រទៅ ៗ

ព្រះបរមពោធិសត្វ ក្រាបទូលព្រះបាទស្រីវេស្សន្តរ ថា បពិត្រក្សត្រថ្លៃប្រសើរអើយ ក៏ឥឡូវនេះ អស់អ្នកស្រីពិរាស្ត្រផង ទាំងឡាយគេខឹងនឹងព្រះអង្គនេះណាស់ ទោះព្រះរាជទេពីក្តី ព្រះរាជបុត្រក្តីនូវអស់ស្រីព្រះស្នំ ក្រមការ ភ្នាក់ងារ ស្រុកស្រែក្រៅលំនៅជនបទកំណត់ស្រុកតូចស្រុកធំ សមណព្រាហ្មណាចារ្យ ភ្នាក់ងារ នាយដំរី នាយសេះ នាយរទេះ គេសឹងតែខឹងនឹងព្រះអង្គ ព្រមល្មម អស់ទៅហើយ ៗ បពិត្រមហារាជអើយ នាព្រឹកស្អែកនេះឯង លុះព្រះអាទិត្យរះឡើងហើយ គេនឹងបំបរបង់ព្រះអង្គចេញទៅហោង ៗ

មហាសត្តោ អាហ① ព្រះមហាសត្វព្រះអង្គមានព្រះបន្ទូលទៅនឹងរាជអាមាត្យ ថា

កិស្មឹ មេ សិវិយោ កុទ្ធា យោ ន បស្សាមិ ទុក្កដំ
តំ មេ កត្តេ វិយាចិក្ខ កស្មា បព្វាជយន្តិ មន្តិ② ៗ

ថា ម្នាលរាជអាមាត្យអើយ ព្រោះរឿងអ្វីបានជាពួកអ្នកស្រីពិរាស្ត្រ គេខឹងនឹងយើង យើងមើលមិនឃើញអំពើអាក្រក់អ្វីឡើយ ចូរអ្នកប្រាប់អំពើអាក្រក់នោះឱ្យយើងបានដឹងផង ចុះហេតុអ្វីបានជាគេនាំគ្នាបំបរបង់យើងចេញ ៗ រាជអាមាត្យនោះក្រាបបង្គំទូលស្នង ថា

១- ច្បាប់ខ្លះ " តំ សុត្វា មហាសត្តោ អាហ " ប្រែថា " ព្រះមហាសត្វទ្រង់ព្រះសណ្តាប់ពាក្យនោះហើយមានព្រះបន្ទូលថា " ៗ ២- ទាំងតួគាថាទាំងសេចក្តីប្រែមិនមានក្នុងច្បាប់មហាជាតក៏សម្រាយទេ បានស្រង់យកពីបាលីមហាជាតក៏មកដាក់ប្រែបំពេញ ៗ

ឧគ្គា ច រាជបុត្តា ច វេសិយានា ច ព្រាហ្មណា
ហត្ថារោហា អនីកដ្ឋា រថិកា បត្តិការកា
នាគនាគេន ខីយន្តិ តស្មា បព្វាជយន្តិ តន្តិ ។

ពួកឧគ្គជន ពួករាជបុត្រ ពួកឈ្មួញ ពួកព្រាហ្មណ៍ ពួកពលដំរី ពួកពលសេះ ពួកពលរថ ពួកពលថ្មើរជើង នាំគ្នាត្អះតិះដៀល ខឹងនឹងព្រះអង្គ ព្រោះតែទ្រង់ព្រះរាជទានដំរីបច្ច័យនាគេន្ទ្រ ហេតុហ្នឹងហើយ បានជាគេនាំគ្នាបំបរបង់ព្រះអង្គចេញ ។

ព្រះមហាសត្វ ទ្រង់ស្ដាប់ហេតុភេទនោះហើយ មានព្រះទ័យសោមនស្ស ត្រាស់ថា

(ហទយំ ចក្ខុម្បហំ ទជ្ជំ កឹ មេ ពាហិរកំ ធនំ
ហិរញ្ញំ វា សុវណ្ណំ វា មុត្តា វេឡុរិយា មណី ។
ទក្ខិណំ វាមហំ ពាហុំ ទិស្វា យាចកមាគតេ
ទទេយ្យំ ន វិកម្បេយ្យំ ទានេ មេ រមតី មនោ ។
កាមំ មំ សិវិយោ សព្វេ បព្វាជេន្តុ ហនន្តុ វា
នេវ ទានា វិរមិស្សំ កាមំ ឆិន្ទន្តុ សត្តធាតិ ។

ថាម្នាលរាជអាមាត្យអើយ កុំថាតែដំរីបច្ច័យនាគេន្ទ្រ ដែលអញឱ្យទៅជាទានព្រាណ៍នោះឡើយ អញគិតសព្វថ្ងៃនេះ ចង់តែនឹងឱ្យ អជ្ឈត្តិកទាន គឺទានក្នុងខ្លួនអញឯងហៈ ឥឡូវនេះ ព្រាហ្មណ៍វាមកសូមដំរីបច្ច័យនាគេន្ទ្រ ហៅពាហិរកទាន គឺទានក្រៅអំពីខ្លួនអញ ៗ នឹងស្ដាយថ្វីចៅអាមាត្យអើយ អស់អ្នកស្រីពិរាស្ត្រផង

គេខឹងនឹងអញ ត្បិតអញឱ្យទាននោះ ទោះគេនឹងកាត់ខ្លួនអញជា ៧ កំណាត់ក្ដី ក៏អញមិនភ្លេចត្រង់ឱ្យទាននោះឡើយ(១) ។)

តំ សុត្វា កត្តា នេវ រញ្ញា ច ន នាគរេហិ ទិន្នំ អត្តនោ មតិយា ឯវ អបរំបិ សាសនំ កថេន្តោ អាហ

រាជអាមាត្យ ស្ដាប់ព្រះបន្ទូលព្រះបរមពោធិសត្វហើយ ក្រាបថ្វាយបង្គំប្រណម្យទូលពត៌មានដទៃវិញទៀត ហេតុអាមាត្យនោះ ស្រឡាញ់ព្រះបរមពោធិសត្វនោះឯង ទើបក្រាបទូលជាបាទគាថាដូច្នេះ ថា

ឯវន្តំ សិវិយោ អាហុ នេគមា ច សមាគតា
កោន្តិមារាយ តីរេន គិរិមារញ្ជរំ បតិ
យេន បព្វាជិតា យន្តិ តេន គច្ឆតុ សុព្វតោតិ ។

បពិត្រមហារាជអើយ រីអស់អ្នកស្រីពិរាស្ត្រផងទាំងឡាយ គេជនុំព្រមល្មមហើយ គេនឹងបណ្ដេញព្រះអង្គ ឱ្យទៅនៅភ្នំអរញ្ញបព៌ត អាស្រ័យនឹងស្ទឹងកោន្តិមារានទីហោង ។

តំ សុត្វា ពោធិសត្តោ ព្រះបរមពោធិសត្វទ្រង់ស្ដាប់ពាក្យរាជអាមាត្យនោះហើយ មានព្រះបន្ទូលថា ប្រពៃហើយ រាជអាមាត្យ យើងនឹងដើរទៅ តាមផ្លូវជាដំណើរ នៃព្រះមហាក្សត្រ ដែលធ្វើខុសទាំងឡាយ ប៉ុន្តែឥឡូវនេះ ពួកអ្នកនគរគេបំបរបង់យើង

១- តួគាថាក្នុងវង់ក្រចកនេះ មិនមានក្នុងច្បាប់មហាជាតក៏សម្រាយទេ ក្នុងទីនេះ បានស្រង់យកពីបាលីមហាជាតក៏ មកដាក់ប្រែបំពេញ ។

មិនមែនដោយទោសដទៃឡើយ ព្រោះតែយើងឱ្យដំរីរត្ន ទៅជាទានព្រាហ្មណ៍ បើដូច្នេះ ទុកបង្អង់ឱ្យយើងឱ្យសត្តសតកមហាទានបាន ១ ថ្ងៃសិន សូមឱ្យអ្នកនគរ បង្អង់ទុកឱកាសឱ្យយើង ១ ថ្ងៃសិន ដល់ព្រឹកស្អែក យើងបានឱ្យទានរួចហើយ សឹមយើងទៅក្នុងថ្ងៃខានស្អែក ហើយទ្រង់សូត្រជាបាទគាថា ដូច្នេះ ថា

សោហំ តេន គមិស្សាមិ យេន គច្ឆន្តិ ទូសកា
រត្តិន្ទិវំ មេ ខមថ យាវ ទានំ ទទាមិហន្តិ ។

យើងនឹងទៅតាមផ្លូវរបស់ក្សត្រដែលធ្វើខុស សូមអ្នកទាំងឡាយ អត់ទោសបង្អង់ឱ្យយើង ១ យប់ ១ ថ្ងៃសិន ទម្រាំយើងឱ្យទានស្រេច ។

តំ សុត្វា ភត្តា រាជអាមាត្យ ស្ដាប់ព្រះបន្ទូលថ្លៃ នៃព្រះពោធិសត្វហើយ ក៏ទទួលយកព្រះបន្ទូលពិសេស ទៅក្រាបបង្គំទូលព្រះបាទស្រីសញ្ជ័យ មួយអន្លើនឹងអស់អ្នកស្រីពិរាស្ត្រផងទាំងពួង ។

កាលនោះ ព្រះបរមពោធិសត្វមហាបុរសរ័ត្នវិសេស ព្រះអង្គឱ្យដំណើររាជអាមាត្យនោះទៅហើយ ឯក្រោយនោះឯង ព្រះអង្គមានព្រះបន្ទូលបង្គាប់ប្រើសេនាបតីមួយដ៏ជាធំ ថា ហៃសេនាបតីដ៏ជាធំអើយ ចូរព្រះស្ដែងទៅប្រដាប់នូវដំរីនោះបាន ៧០០ សេះ ៧០០ រទេះ ៧០០ ស្រីកញ្ញា ៧០០ មេគោឆ្នាត់ ៧០០ គោឧសភរាជ ៧០០ ខ្ញុំស្រី ៧០០ ខ្ញុំប្រុស ៧០០ មួយអន្លើនូវបាយទឹក សំពត់អាវសារស្បៃ មាសប្រាក់ កែវកងសព្វពិធរ័ត្នផងទាំងពួង

ដោយហោចទៅ សូម្បីសុរាជារបស់មិនគួរឱ្យជាទាន ចូរព្រះស្តែងប្រដាប់មហាទានឱ្យមានសព្វគ្រប់ ៗ នាព្រឹកស្អែកនេះ អញនឹងចេញចាយសត្តសតកមហាទានស្រេចហើយ លុះព្រឹកខានស្អែកឡើង អញនឹងចេញអំពីស្រុកនេះទៅហើយ ៗ ម្ល៉ោះហើយ ព្រះអង្គឱ្យដំណើរសេនាបតីនោះទៅកាន់លំនៅអាត្មាវិញហោង ៗ

ឯកកោ ច មទ្ទិយា វសនដ្ឋានំ គន្ត្វា សិរិសយនប្បិដ្ឋេ និសីទិត្វា តាយ សទ្ធឹ កថំ បវត្តេសិ ឯក្រោយនោះឯងព្រះបរមពោធិសត្វ ព្រះអង្គលីលាទៅកាន់ឋានលំនៅនាងមទ្រីទេវី តែមួយព្រះអង្គ ទ្រង់គង់លើខ្នងកម្រាលមានសិរីសួស្តី ហើយសំណេះសំណាលជាមួយនឹងព្រះនាងមទ្រី នាកាលណោះហោង ៗ

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណា ពុំប្រាកដ បទព្រះបាលីឯណា ពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គបន្ទូលនឹងភិក្ខុផងទាំងឡាយ សូត្រជាបាទគាថាដូច្នេះ ថា

អាមន្តយិត្ថ រាជា នំ មទ្ទឹ សព្វង្គសោភនំ
យំ តេ កិញ្ចិ មយា ទិន្នំ ធនធញ្ញញ្ច វិជ្ជតិ
ហិរញ្ញំ វា សុវណ្ណំ វា មុត្តា វេឡុរិយា ពហូ
សព្វន្តំ និទ្ធហេយ្យាសិ យញ្ច តេ បេតិកំ ធនន្តិ ៗ

ភិក្ខវេ ម្នាលភិក្ខុផងទាំងឡាយអើយ ឰដ៏កាលនោះ ព្រះបាទស្រីវេស្សន្តរ ស្តេចមានព្រះបន្ទូលទៅនឹងព្រះនាងមទ្រីទេវី ថា

ម្នាលមទ្រីនាងអើយ វីទ្រព្យឯណានីមួយ ទោះមាសក្តី ប្រាក់ក្តី កែវមុក្តាក្តី កែវពៃទូរ្យជាច្រើនក្តី ទោះបីទ្រព្យឯណាដែលសម្តេចព្រះវររាជបិតាប្រទានឱ្យនាងក្តី ក៏ចូរនាងកប់ទុកឱ្យល្អប្រពៃសព្វគ្រប់ហោង ។

តមព្រវិ រាជបុត្តី មទ្ទី សព្វង្គសោភណា
កុហឹ ទេវ និទហេស្សាមិ តំ មេ អក្ខាហិ បុច្ឆិតោតិ ។

សម្តេចព្រះភគវតី ព្រះនាងមទ្រីដ៏ទ្រង់នូវលក្ខណា ដ៏ប្រសើរទ្រង់ស្តាប់ហើយ ព្រះនាងក្រាបទូលព្រះរាជស្វាមីថា បពិត្រក្សត្រថ្លៃប្រសើរអើយ អញ្ញខ្ញុំសូមទូលសួរ សូមទ្រង់ថ្លែងប្រាប់ វីទ្រព្យទាំងអម្បាលណោះ តើអញ្ញខ្ញុំនឹងគ្រប់គ្រងកប់ទុក ក្នុងទីណា ។ ព្រះបាទស្រីវេស្សន្តរ ទ្រង់ស្តាប់ហើយ ទ្រង់មានព្រះបន្ទូល ថា

សីលវន្តេសុ ទជ្ជាសិ ទានំ មទ្ទិ យថារហំ
ន ហិ ទានា បរំ អត្ថិ បតិដ្ឋា សព្វបាណិនន្តិ ។

ថា មទ្រីទេវីនាងអើយ ចូរនាងឱ្យទានដល់សមណព្រាហ្មណាចារ្យ ស្មូមយាចក អ្នកកម្សត់ទុគ៌តផងទាំងឡាយចុះ ព្រោះទានជាទីពឹងទីពំនាក់របស់សព្វសត្វទាំងឡាយ មិនមានទីពឹងដទៃក្រៅពីទានឡើយ ។

ព្រះនាងមទ្រីទ្រង់ស្តាប់ហើយ ថ្វាយបង្គំប្រណម្យទូលថា បពិត្រព្រះបាទស្រីវេស្សន្តរដ៏ជាស្វាមីខ្ញុំអើយ ព្រះអង្គមានព្រះបន្ទូលនោះគាប់ប្រពៃពិតពេកណាស់ហោង ។ ទើបព្រះមហាសត្វ

ប្រទានឱវាទដំបូន្មានតទៅទៀត ថា

បុត្តេសុ មទ្ទិ ទយេសិ សស្សុយា សស្សុរម្ហិ ច
យោ ច តំ ភត្តា មញ្ញេយ្យ សក្កច្ចំ ឧបដ្ឋហិ ៗ

ថា ម្នាលនាងមទ្រីអើយ អំណើះអត់នឹងអញទៅហើយ ក៏ចូរនាងរក្សាកូនទាំងពីរឯក្រោយ ហើយឱ្យនាងបម្រើអ្នកទាំងពីរ ដ៏ជាមេក្មេក បាក្មេក និងអ្នកដែលមកជាភស្តារបស់នាង ដោយនូវវត្តប្រតិបត្តិទាំងពួងហោង ៗ

នោ ចេ តំ ភត្តា មញ្ញេយ្យ មយា វិប្បវសេន តេ
អញ្ញំ ភត្តារំ បរិយេសិ មា កិលិត្ថ មយា វិនាតិ ៗ

ថា ម្នាលនាងមទ្រីអើយ កាលណា បើអំណើះអំពីអញទៅហើយ ទោះយោបីមានអ្នកឯណាមួយ គេប្រាថ្នាចង់បាននាងជាប្រពន្ធ ក៏ចូរនាងទៅនៅបម្រើគេជាភស្តាថ្មីចុះ កុំបីមានសេចក្ដីព្រួយលំបាក ព្រោះការព្រាត់ប្រាសចាកអញនេះឡើយ ៗ

ព្រះនាងមទ្រីទ្រង់ស្ដាប់ ទ្រង់ព្រះតម្រិះ ថា ហេតុអ្វីហ្ន៎ ក៏ព្រះរាជស្វាមីត្រាស់ព្រះវាចាដូច្នេះ ទើបព្រះនាងក្រាបបង្គំទូល ថា បពិត្រព្រះសម្មតិទេពក្សត្រថ្លៃប្រសើរអើយ ហេតុអ្វី ក៏ព្រះអង្គមានព្រះបន្ទូលនូវពាក្យមិនគួរគប្បីដូច្នេះ ៗ ទើបព្រះមហាសត្វ មានព្រះបន្ទូលតប ថា មទ្រីនាងអើយ ឥឡូវនេះ អ្នកស្រីពិរាស្ត្រផងទាំងឡាយ គេខឹងនឹងអញ ត្បិតតែអញឱ្យទានដំរីវ័ត្តមង្គលប្រសើរនោះ ឥឡូវ គេបណ្ដេញអញចេញចាកស្រុកនេះ អញនៅតែ

ថ្ងៃនេះឯង នាថ្ងៃព្រឹកស្អែកនោះ អញនឹងឱ្យសត្តសតកមហាទាន លុះថ្ងៃគម្រប់បី អញនឹងចេញចាកស្រុកនេះទៅហោង ហើយព្រះអង្គមានព្រះបន្ទូល ជាបាទគាថា ដូច្នេះ ថា

អហំ ហិ វនំ គច្ឆាមិ ឃោរំ វាឡមិគាយុតំ
សំសយោ ជីវិតំ មយ្ហំ ឯកកស្ស ព្រហាវនេតិ ។

ម្នាលនាងមទ្រីអើយ អញនឹងចេញទៅនៅនាព្រៃហេមពាន្តនាយ ច្រឡំនីទៅនូវសត្វម្រឹគ បក្សីផងទាំងឡាយច្រើន ជាដើម គឺរាជសីហ៍ ដំរីព្រៃ រមាំង រមាស ដេរឆាសនីទៅនូវខ្លាធំ ខ្លាដំបង ទន្សោងខ្លាង គោព្រៃផងច្រើន មទ្រីនាងអើយ ជីវិតអញមួយនេះ អញនឹងសង្ស័យ ថា រស់នៅនោះ ពុំមានឡើយ ។ តេន វុត្តំ ហេតុនោះហោង ព្រះអង្គបានត្រាស់ហើយ មានព្រះបន្ទូលនឹងភិក្ខុផងទាំងឡាយ សូត្រជាបាទគាថា ដូច្នេះ ថា

តមព្រវិ រាជបុត្តី មទ្ទី សព្វង្គសោភណា
អភុម្មេ កថំ នុ ភណសិ បាបកំ វត ភាសសិ ។
នេស ធម្មោ មហារាជ យំ ត្វំ គច្ឆេយ្យ ឯកកោ
អហំបិ តេន គច្ឆាមិ យេន គច្ឆសិ ខត្តិយ ។
មរណំ វា តយា សទ្ធិំ ជីវិតំ វា តយា វិនា
តទេវ មរណំ សេយ្យោ យញ្ចេ ជីវេ តយា វិនា ។
អគ្គិំ ឧជ្ជាលយិត្វាន ឯកជាលសមាហិតំ
តត្ថ មរណំ សេយ្យោ យញ្ចេ ជីវេ តយា វិនា ។

យថា អារញ្ញិកំ នាគំ ទន្តឹ អន្វេតិ ហត្ថិនី
ជេស្សន្តំ គិរិទុគ្គេសុ សមេសុ វិសមេសុ ច ។
ឯវន្តំ អនុគច្ឆាមិ បុត្តេ អាទាយ បច្ឆតោ
សុភរា តេ ភវិស្សាមិ ន តេ ហេស្សាមិ ទុព្ភរាតិ ។

ភោ សារីបុត្ត ហៃសារីបុត្តអើយ រីសម្តេចព្រះភគវតីនាងមទ្រី ដ៏ប្រកបនូវបញ្ចពិធកល្យាណី ជាព្រះរាជបុត្រីស្រ្តីត្រកូលអំបូរជាតិព្រះបាទមទ្ទរាស្រ្តនោះ ព្រះនាងឮព្រះបន្ទូលព្រះបរមពោធិសត្វហើយ ព្រះនាងទ្រង់ព្រះកន្សែងសោយសោកថា បពិត្រព្រះសម្មតិទេពមហារាជក្សត្រថ្លៃប្រសើរអើយ រីព្រះបន្ទូលព្រះអង្គនោះយល់អាក្រក់ក្រៃពេក មិនសុភាពដោយនូវគន្លងធម៌ឡើយ អម្ចាស់វិសេសខ្ញុំអើយ ព្រះអង្គនឹងស្តេចដើរទៅត្រង់ឋានឯណាមិញ ក៏អញខ្ញុំនឹងពរមក្រស្នា បណ្តើរបាជាលី ទៅដោយនូវផ្លូវនោះហោង ៗ បពិត្រក្សត្រថ្លៃប្រសើរអើយ ថាបើអញខ្ញុំប្រាសនិរាសពីព្រះអង្គហើយ អញខ្ញុំនឹងយកឧសមកគរប្រមាណកម្ពស់ភ្នំ ហើយអញខ្ញុំ នឹងយកភ្លើងមកដុតឱ្យឆេះឡើង ដ៏មានអណ្តាតនោះស្មើគ្នាល្អហើយ ខ្ញុំនឹងលោតចុះក្នុងភ្លើងនោះ ឱ្យស្លាប់ទៅវិញ ក៏ប្រសើរក្រៃពេកហោង ៗ បពិត្រព្រះបាទស្រីវេស្សន្តរអម្ចាស់វិសេសខ្ញុំអើយ ព្រះអង្គដូចជាបាដំរី ដើរត្រាច់ក្នុងព្រៃសព្វជ្រោះជ្រលងដងភ្នំផងទាំងពួង ឯខ្ញុំម្ចាស់សោតដូចមេដំរីបណ្តើរកូនទាំងពីរតាមដោយគន្លងព្រៃភ្នំទាំងពួងនោះដែរ ៗ

ឯវំ វត្វា បុន សា ទិដ្ឋបុត្តំ វិយ ហិមវន្តប្បទេសំ

ខណ្ណេន្តិ អាហ រីសម្តេចព្រះភគវតីនាងមទ្រីព្រះនាងទ្រង់ព្រះកន្សែងម៉្លោះហើយកូវ ព្រះនាងសរសើរព្រៃហេមពាន្តឋានប្រទេស មានប្រការនោះផ្សេង ៗ ទូលព្រះពោធិសត្វ ហាក់ដូចជាព្រះនាង បានយល់ពីមុនមកហើយ ទ្រង់សូត្រជាបាទគាថាទាំងឡាយ ដូច្នេះ

ឥមេ កុមារេ បស្សន្តោ មញ្ជុកេ បិយភាណិនេ
អាសិនេ វនគុម្ពស្មឹ ន រជ្ជស្ស សរិស្សសិ ។
ឥមេ កុមារេ បស្សន្តោ មញ្ជុកេ បិយភាណិនេ
កីឡន្តេ វនគុម្ពស្មឹ ន រជ្ជស្ស សរិស្សសិ ។
ឥមេ កុមារេ បស្សន្តោ មញ្ជុកេ បិយភាណិនេ
អស្សមេ រម្មណីយម្ហិ ន រជ្ជស្ស សរិស្សសិ ។
ឥមេ កុមារេ បស្សន្តោ មញ្ជុកេ បិយភាណិនេ
កីឡន្តេ អស្សមេ រម្មេ ន រជ្ជស្ស សរិស្សសិ ។
ឥមេ កុមារេ បស្សន្តោ មាលធារី អលង្កតេ
អស្សមេ រម្មណីយម្ហិ ន រជ្ជស្ស សរិស្សសិ ។
ឥមេ កុមារេ បស្សន្តោ មាលធារី អលង្កតេ
កីឡន្តេ អស្សមេ រម្មេ ន រជ្ជស្ស សរិស្សសិ ។
យទា ទក្ខសិ នច្ចន្តេ កុមារេ មាលធារិនេ
អស្សមេ រម្មណីយម្ហិ ន រជ្ជស្ស សរិស្សសិ ។
យទា ទក្ខសិ នច្ចន្តេ កុមារេ មាលធារិនេ
កីឡន្តេ អស្សមេ រម្មេ ន រជ្ជស្ស សរិស្សសិ ។
យទា ទក្ខសិ មាតង្គំ កុញ្ជរំ សដ្ឋិហាយនំ

ឯកំ អរញ្ញេ វិចរន្តំ   ន រជ្ជស្ស សរិស្សសិ ។
យទា ទក្ខសិ មាតង្គំ   កុញ្ជរំ សដ្ឋិហាយនំ
សាយំ បាតោ វិចរន្តំ   ន រជ្ជស្ស សរិស្សសិ ។
យទា ករេណុសង្ឃស្ស   យូថស្ស បុរតោ រជំ
កោញ្ចំ កាហតិ មាតង្គោ   កុញ្ជរោ សដ្ឋិហាយនោ
តស្ស តំ នទតោ សុត្វា   ន រជ្ជស្ស សរិស្សសិ ។
ឧភតោ វនវិកាសេ   យទា ទក្ខសិ កាមទំ
វនេ ពាឡមិគាកិណ្ណេ   ន រជ្ជស្ស សរិស្សសិ ។
មិគំ ទិស្វាន សាយណ្ហំ   បញ្ចមាលិនិមាគតំ
កីបុរិសេ ច នច្ចន្តេ   ន រជ្ជស្ស សរិស្សសិ ។
យទា សោស្សសិ និគ្ឃោសំ   សន្ទមានាយ សិន្ធុយា
គីតំ កីបុរិសានញ្ច   ន រជ្ជស្ស សរិស្សសិ ។
យទា សោស្សសិ និគ្ឃោសំ   គិរិគព្ភរចារិនោ
វសមានស្សុលូកស្ស   ន រជ្ជស្ស សរិស្សសិ ។
យទា សីហស្ស ព្យគ្ឃស្ស   ខគ្គស្ស គវយស្ស ច
វនេ សោស្សសិ ពាឡានំ   ន រជ្ជស្ស សរិស្សសិ ។
យទា មោរីហិ បរិកិណ្ណំ   វរហិនំ មត្ថកាសិនំ
មោរំ ទក្ខសិ នច្ចន្តំ   ន រជ្ជស្ស សរិស្សសិ ។
យទា មោរីហិ បរិកិណ្ណំ   អណ្ឌជំ ចិត្របេក្ខុនំ
មោរំ ទក្ខសិ នច្ចន្តំ   ន រជ្ជស្ស សរិស្សសិ ។
យទា មោរីហិ បរិកិណ្ណំ   និលគីវំ សិខិណ្ឌិនំ

ឯវំ ទក្ខសិ នច្ចន្តំ ន រជ្ជស្ស សរិស្សសិ ។
យទា ទក្ខសិ ហេមន្តេ បុប្ផិតេ ធរណីរុហេ
សុរភិសម្បវាយន្តេ ន រជ្ជស្ស សរិស្សសិ ។
យទា ហេមន្តកេ មាសេ ហរិតំ ទក្ខសិ មេទនី
ឥន្ទគោបកសញ្ឆន្នំ ន រជ្ជស្ស សរិស្សសិ ។
យទា ទក្ខសិ ហេមន្តេ បុប្ផិតេ ធរណីរុហេ
កុដជំ ពិម្ពជាលញ្ច បុប្ផិតំ លោទ្ទបទ្ទកំ
សុរភិសម្បវាយន្តេ ន រជ្ជស្ស សរិស្សសិ ។
យទា ហេមន្តកេ មាសេ វនំ ទក្ខសិ បុប្ផិតំ
ឧបុប្ផានិ បទុមានិ ន រជ្ជស្ស សរិស្សសីតិ ។

បពិត្រមហារាជក្សត្រថ្លៃប្រសើរអើយ រីព្រៃហេមពាន្តនោះសប្បាយក្តាត់ហោង ៗ កាលបើយើងទៅដល់ហើយ រីក្មេងទាំងពីរនេះ នាកាលថ្ងៃរសៀល វានឹងច្រៀងរាំលេង ដោយនៅនាដង្គុំព្រៃនោះ មានសំឡេងមូលសសូល ក្រាំងក្រអៅជ្រៅជ្រះ សមនូវស័ព្ទដ៏ពីរោះ សមព្រះអង្គនឹងសប្បាយក្នុងព្រះរាជហឫទ័យ ម្រាងឡើយ ព្រះអង្គនឹងនឹករលឹកមកកាន់រាជសម្បត្តិឯអាយ ៗ

បពិត្រមហារាជក្សត្រថ្លៃប្រសើរអើយ រីបាដំរីព្រៃដ៏ល្អ ដ៏មានចាមរនោះល្អាយល្អងរាំងគន្លងបោសព្រះធរណី ដ៏មានសម្បុរនោះខៀវ បីដូចផ្ទៃមហាមេឃ ដ៏មានភ្លុកធំល្អ ទោះល្ងាចក្តី ព្រឹកក្តី វាដើរទៅមុនញីខ្លោងទាំងឡាយ ហើយវារំស្រែកស្មៀវសំឡេង

ដូចក្រៀល សមនឹងសប្បាយព្រះរាជហឫទ័យ ម្រាងឡើយ ក៏នឹងនឹករលឹកមកកាន់រាជសម្បត្តិឯអាយ ។

រីពពួកកិន្នរផងទាំងឡាយសោត បីដូចនូវមនុស្សសឹងដ៏មានរូបឆោមនោះល្អស្រឡះស្រលួត ល្ពួតល្ពៅ ស្រងៅស្រងើ ខ្លះរាំ ខ្លះច្រៀង ខ្លះបណ្តើរគ្នាលេង ដោយសងខាងមុចលិន្ទទី ដ៏មីរដេរដាស បីដូចជារបាំរាំពេន មានព្ទដ៏ជេតុត្តរនគរនោះឯងហោង ថាបើព្រះអង្គយល់ហើយ ម្រាងឡើយ នឹងនឹករលឹកមកកាន់រាជសម្បត្តិឯអាយ ។

បពិត្រមហាក្សត្រថ្លៃប្រសើរអើយ រីភ្នំគិរីវង្កតបព៌តនោះមានប្រាសាទគុហា សឹងមាសដាស សឹងប្រាក់ផងច្រើន ច្រឡំនីទៅនូវក្លោក ប៉ោលតោក តាវៅ រីទឹកនោះសោត សឹងហូរមកដ៏មានសូរស័ព្ទនោះពីរោះស្មោះស្មើ បីដូចអ្នកសេពសម ផ្លុំប្រគំនូវតូរ្យតន្ត្រី ព្ទដ៏ជេតុត្តរនគរនោះហោង ថាបើព្រះអង្គយល់ហើយ ម្រាងឡើយ នឹងនឹករលឹកមកកាន់រាជសម្បត្តិឯអាយ ។

បពិត្រមហាក្សត្រថ្លៃប្រសើរអើយ រីម្រឹគផងទាំងឡាយច្រើនជាដើម គឺ រាជសីហ៍ ដំរីព្រៃ រមាំង រមាស ខ្លាធំ ខ្លាដំបងគោព្រៃផងផ្សេង ៗ សឹងដ៏អួតជល់គ្នាទៅវិញទៅមកបោលដេញគ្នាលេង ថាបើព្រះអង្គបានយល់ហើយ ម្រាងឡើយនឹងនឹករលឹកមកកាន់រាជសម្បត្តិឯអាយ ។

មួយនីសោត ទោះល្ងាចក្តី ព្រឹកក្តី អម្ចាស់នឹងលីលាទៅ

ក្រសាលនៅក្រោមម្លប់ជ្រៃក្តី ម្លប់ព្រីងក្តី អម្ចាស់ទតរមិលមើលទៅពពួកក្ងោកញី ឈ្មោលទាំងឡាយ សឹងដ៏ច្រើនក្តាត់ហោង សឹងដ៏មានរបៀបស្លាបនូវកន្ទុយនោះល្អ មានផ្គត់កនោះខៀវ មានសិរនោះវែង មានកំណើតនោះពីរដង គឺថាពងហើយញាស់ចេញជាកូន រីឯក្ងោកឈ្មោលសោត តែងនឹងពង់កម្ទារក្ងោកញីៗ បរិពារតែងនឹងរាំពេនពង់លេង ថាបើអម្ចាស់បានយល់ហើយសមអម្ចាស់សប្បាយក្នុងព្រះរាជហឫទ័យ ម្រាងឡើយ នឹងទ្រង់នឹករលឹកមក កាន់រាជសម្បត្តិឯអាយ ៗ

បពិត្រមហារាជអើយ រីឈើផងទាំងឡាយ ដុះព្ទដ៏សងខាងផ្លូវថ្នល់នោះសោត ដ៏មានខ្លែងគង់ បំពង់កាំ ផ្តាំស ពុំសែនទេស កាកេស កណ្ណិការ ក្តាំងងា ខ្ទឹង ក្ទម្ព សមនូវសូរភី ចម្ប៉ា ចំប៉ី សឹងដ៏មានក្លិននោះពិដោរ កាលណាបើខ្យល់បក់ហើយ ធុំហួង ត្រឡប់ក្រៃពេក ៗ

មួយនីសោត បើអម្ចាស់នឹងចង្ក្រមព្ទដ៏ថ្នល់មុចលិន្ទស្រះ ក៏ព្រះអង្គនឹងទតរមិលមើលទៅព្ទដ៏ផ្ទៃស្រះនោះ ដ៏មានផ្កាឈូកច្រាលឈូកស ដ៏រីករន្ទាលនីទៅនូវស្បង្ក័ជ ឧត្បុល ចង្កុលណី ព្រលិតលំចង់ សឹងដ៏រីកស្គុសស្គាយពណ្ណរាយ សោភា សឹងដ៏មានទឹកនោះថ្លាត្រជាក់ ជាពំនាក់នៃត្រីផង ដ៏មានច្រាំងនោះទាបកំពង់នោះរាប បីដូចនូវស្រះមានព្ទដ៏ជេតុត្តរនគរ នេះឯងហោង ៗ

ឯទំ មន្ទី ហេមទន្តវាសិនី ទិយ ឯត្តភាហិ គាវទាហិ

ហិមវន្តំ វណ្ណេសិ រីសម្តេចព្រះភគវតីព្រះនាងមទ្រី ដ៏ប្រកបនូវបញ្ចាពិធកល្យាណី ដ៏ជាស្រីរ័ត្នឧត្តមសមនូវទម្រង់កម្ពស់ប្រពៃ បានអភិសេកជាឯកអគ្គមហេសី ព្រះនាងសរសើរព្រៃហេមពាន្ត ហាក់ដូចព្រះនាងធ្លាប់គង់នៅក្នុងព្រៃហេមពាន្ត មកជាយូរអង្វែងហើយ ទើបព្រះនាងសម្តែងថ្លែងដំណើរ និយាយស្រាយ ប្រាយប្រាប់ព្រះមហាក្សត្រ សូត្រជាបាទគាថានូវប្រការអម្បាលណោះឯងហោង ។

ហិមវន្តំ និដ្ឋិតំ បពិត្រអើយ អាត្មាភាពសម្តែងថ្លែងព្រះធម៌វិសេសទេសនា ព្រះមហាជាតក៏ **កណ្ឌហេមវន្ត** នេះមិញ ដ៏ប្រដាប់ប្រដានីទៅនូវគាថា ១៣៤ គាថា ក៏ចប់បរិបូណ៌សមគួរដោយនូវវេលានេះឯងហោង ។

ចប់ កណ្ឌហេមពាន្ត ទី ២ តែប៉ុណ្ណេះ ។

⁂

ចម្លងចប់នៅថ្ងៃ ៣ រោច ខែពិសាខ ព.ស. ២៥៣៣
ត្រូវនឹងថ្ងៃសុក្រ ទី ១១ ខែឧសភា គ.ស. ១៩៩០

មហាវេស្សន្តរជាតក

ទី ៣



ទានកណ្ឌ

ប្រដាប់ដោយគាថា ២០៩

មហាវេស្សន្តរជាតក

ទី ៣

ទានកណ្ឌ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ផុស្សតីបិ ខោ ទេវី បុត្តស្ស មេ កដុកសាសនំ
អាគតំ កិន្នុ ខោ ករោតិ អហំ គន្ត្វា ជានិស្សាមីតិ ។

ភោ សាធវោ ហៃសាធុសប្បុរសផងទាំងឡាយអើយ រីព្រះនាងសុបារសុប្បតីទេវី ដ៏ជាស្រីមានលក្ខណាប្រសើរ បានឮពត៌មានពុំក្សេមក្សាន្ត អំពីព្រះវេស្សន្តរ ដ៏ជាសម្តេចព្រះរាជបុត្រនោះហើយកូវ ព្រះនាងទ្រង់ព្រះចិន្តាដូច្នេះថា ឱ! ដូចអញគិតនេះហើយ ធ្វើម្តេចអញនឹងបានដឹងទុក្ខកូនអញនេះឱ្យច្បាស់ ព្រះនាងទ្រង់ព្រះចិន្តាដូច្នោះហើយ មានព្រះបន្ទូលហៅនាយរាជរថ ឱ្យទឹមនូវសេះអាជានេយ្យដ៏ប្រសើរមកហើយ ឱ្យយកកម្រាលដ៏វិចិត្រទៅក្រាល ហើយឱ្យបាំងនីទៅនូវស្វេតច្ឆ័ត្រដ៏ប្រសើរ ទើបព្រះនាងឡើងគង់លើរាជរថនោះ ហើយបរទៅដាក់នៅមុខព្រះលានទៀបទ្វារព្រះរាជមន្ទីរនៃព្រះបាទស្រីវេស្សន្តរ ដ៏ជាព្រះរាជបុត្រដ៏មានសិរីសួស្តីប្រសើរនោះ ព្រះនាងឮសព្ទយោបំព្រះវេស្សន្តរនូវព្រះនាងមទ្រីទ្រង់ព្រះកន្សែង ឮសូររងំផ្សំនូវស្រីស្នំ ក្រមការបម្រើផងនោះ មុខគួរអាសូរករុណាក្រៃពេកហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណា ពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់សពេ៌ជ្ញូតាញ្ញាណហើយ មានព្រះបន្ទូលសូត្រជាបាទគាថាដូច្នេះថា

តេសំ លាលបិតំ សុត្វា បុត្តស្ស សុណិសាយ ច
កលូនំ បរិទេវេសិ រាជបុត្តី យសស្សិនី ។
សេយ្យោ វិសំ មេ ខាយិតំ បបាតា បបតេយ្យាហំ
រជ្ជុយា ពជ្ឈ មិយាហំ . . . .
កស្មា វេស្សន្តរំ បុត្តំ បព្វាជេន្តិ អទូសកំ ។
អជ្ឈាយិកំ ទានបតឹ យាចយោគំ អមច្ឆរឹ
បូជិតំ បដិរាជូហិ កិត្តិមន្តំ យសស្សិនំ
កស្មា វេស្សន្តរំ បុត្តំ បព្វាជេន្តិ អទូសកំ ។
មាតាបេតិភរំ ជន្តុំ កុលេ ជេដ្ឋាបចាយិនំ
កស្មា វេស្សន្តរំ បុត្តំ បព្វាជេន្តិ អទូសកំ ។
រញ្ញោ ហិតំ ទេវហិតំ ញាតីនំ សខិនំ ហិតំ
ហិតំ សព្វស្ស រដ្ឋស្ស . . . .
កស្មា វេស្សន្តរំ បុត្តំ បព្វាជេន្តិ អទូសកន្តិ ។

ហៃភិក្ខុផងទាំងឡាយអើយ រីព្រះនាងសុបារសុប្បតីទេវីដ៏ជារាជបុត្រីស្តេចមទ្ទរាស្ត្រ ដ៏មានយសបរិវារច្រើននោះ ព្រះនាងឮសព្ទទំនួញយោបំព្រះវេស្សន្តរ ដ៏ជាសម្តេចរាជបុត្រក្តី សម្តេចព្រះ

រាជមទ្រី ន៏ជាបុត្រីប្រសាក្តី សឹងទួញយំជាទុក្ខ មុខគួរឱ្យអាសូរករុណាក្រៃពេក ៗ ហៃសាធុសប្បុរសផងទាំងឡាយអើយ វីព្រះនាងសុបារសុប្បតីក្សត្រីឧត្តម ទ្រង់ព្រះកន្សែងស្រដីឯងដូច្នេះថា ឱ! នរណាអើយ ដឹងថ្នាំពិសនោះ ក៏យកមកឱ្យអញ ៗ នឹងផឹឱ្យស្លាប់ទៅជាការគាប់ប្រសើរក្រៃលែង បើអញនឹងរស់នៅវិញនោះ ពុំប្រសើរឡើយ ពុំនោះសោត អញនឹងឡើងទៅលើដំបូលប្រាសាទនោះហើយ ក៏អញនឹងយកស្បៃមួយចងឱ្យខ្ជាប់ ហើយអញបម្រះឱ្យធ្លាក់ចុះឱ្យស្លាប់ទៅ ប្រសើរក្រៃលែងជាងរស់នៅជាមនុស្សនេះវិញ ៗ ឱ! ហេតុអ្វីអើយ ក៏អ្នកស្រីពិរាស្ត្រផងទាំងឡាយ គេបំបរបង់បាវេស្សន្តរកូនអញ ជាអ្នកឥតទោសនេះ ឱ្យប្រាស លែងនៅស្រុក ៗ ឱ!ដូចអញគិតនេះហើយ ព្រះវេស្សន្តរកូនអញនេះ ជាអ្នកឥតទោស ជាអ្នកមានអធ្យាស្រ័យអាល័យចង់តែឱ្យទាន ពុំចេះមានកំណាញ់ទ្រព្យអ្វីឡើយ ៗ ឱ! បាវេស្សន្តរកូនអញនេះ ជាអ្នកមានយសបរិវារ ឮល្បីប្រាកដសព្វប្រទេស ៗ សឹងនាំដង្វាយមកថ្វាយជាច្រើន ៗ ឱ! បាវេស្សន្តរអើយ បាជាអ្នកឥតទោស ហេតុអ្វីក៏អ្នកស្រីពិរាស្ត្រផងទាំងឡាយ មកបំបរបង់ចេញ អំពីស្រុកនេះមួយនីសោត បាវេស្សន្តរ ជាអ្នកឥតទោស នៅសព្វថ្ងៃនេះ តែងនឹងបម្រើម្តាយឪពុក ទំនុកបម្រុងចាស់ព្រឹទ្ធាចារ្យ មួយសោត បាវេស្សន្តរ ជាអ្នកឥតទោស នៅសព្វថ្ងៃនេះ ជាអ្នកអាល័យចង់ធ្វើប្រយោជន៏នៃទេវតានិងមហាក្សត្រ ទំនុកបម្រុងញាតិមិត្រផង

ទាំងឡាយ ជាអ្នកធ្វើប្រយោជន៏ដល់ផែនដីទាំងមូល ចុះហេតុអ្វី ក៏ អស់អ្នកស្រីពិរាស្ត្រ មកបំបរបង់បាវេស្សន្តរចេញអំពីស្រុកនេះ ។

ឥតិ សា កលូនំ បរិទេវិត្វា បុត្តញ្ច សុណិសញ្ច អស្សាសេត្វា រញ្ញោ សន្តិកំ គន្ត្វា អាហ ហៃសប្បុរសផង ទាំងឡាយអើយ រីព្រះនាងសុបារសុប្បតីដ៏ជាស្រីប្រកបនូវលក្ខណា ដ៏ប្រសើរ ព្រះនាងទ្រង់ព្រះកន្សែងរួចហើយ ព្រះនាងលួងលោមព្រះវេស្សន្តរនូវព្រះនាងមទ្រី ដ៏ជាព្រះរាជបុត្រីប្រសានោះថា ហៃអ្នក ទាំងពីរអម្ចាស់ម្ដាយអើយ ម្ដាយនឹងទៅកាន់ព្រះបាទស្រីសញ្ជ័យ ដ៏ជាព្រះវរបិតាអ្នកទាំងពីរ ហើយម្ដាយនឹងស្រដីលោមព្រះបាទស្រី សញ្ជ័យ កុំឱ្យយកពាក្យអ្នកស្រីពិរាស្ត្រនោះឡើយ ។ ហៃសប្បុរស ផងទាំងឡាយអើយ រីព្រះនាងសុបារសុប្បតី លួងលោមព្រះរាជបុត្រាបុត្រីទាំងពីរនោះហើយ ទើបព្រះនាងទៅទូលព្រះបាទស្រី សញ្ជ័យ ដោយបាទព្រះគាថា ដូច្នេះ ថា

មធូនេវ បឡិតានិ អម្ពាវ បតិតា ឆមា
ឯវំ ហេស្សតិ តេ រដ្ឋំ បព្វាជេន្តិ អទូសកំ ។
ហំសោ និក្ខីណបត្តោវ បល្លលស្មឹ អនូទកេ
អបវិទ្ធោ អមច្ចេហិ ឯកោ រាជា វិហញ្ញតិ ។
តំ តំ ព្រូមិ មហារាជ អត្ថោ តេ មា ឧបច្ចគា
មា នំ សិវីនំ វចនា បព្វាជេសិ អទូសកន្តិ ។

បពិត្រព្រះបាទ ស្រីសញ្ជ័យដ៏ជាមហាក្សត្រប្រសើរអើយ ចូរ

អម្ចាស់ស្តាប់ពាក្យអញខ្ញុំដូច្នេះ អម្ចាស់អើយ បើឥតនឹងបាវេស្សន្តរ ដ៏ជាព្រះរាជបុត្រនោះហើយ រីរាជសម្បត្តិអម្ចាស់នេះនឹងអន្តរធានហោង ហើយអស់មនុស្សផងទាំងឡាយ វានឹងមើលងាយ ដូចឃ្មុំឥតមេ ទំនើងសត្វផងទាំងឡាយនឹងយកឆីងាយក្តាត់ហោងៗ មួយសោត បីដូចផ្លែស្វាយទុំ ហើយជ្រុះចុះលើក្រឡាមហាប្រឹថពីនោះ នឹងជាចំណីនៃសត្វទាំងឡាយ វាឆីរាត់រាយខ្ចាត់ខ្ចាយទៅៗ បពិត្រអម្ចាស់អើយ រីបាវេស្សន្តរ ដ៏ជាព្រះរាជបុត្រនេះ ជាអ្នកឥតទោស ដ៏មានសំដីនោះពីរោះផ្អែមល្ហែមណាស់ មិនគួរបំបរបង់គាត់ តាមដោយនូវពាក្យអ្នកស្រីពិរាស្ត្រនោះឡើយ មួយសោត អម្ចាស់អើយ នៅសព្វថ្ងៃនេះ បីដូចរាជហង្សដ៏មីរដេរដាសដោយបរិវារផងទាំងឡាយនោះពីរម៉ឺន កាលណារាជហង្សនោះ បាក់ចំអេងរលីងស្លាប ដួលស្រប៉ាបនៅលើភក់នោះ លំបាកម្តេចមិញ អម្ចាស់អើយ ថាបើព្រះអង្គឥតនឹងបាវេស្សន្តរ ដ៏ជាព្រះរាជបុត្រនោះហើយ អម្ចាស់នឹងស្តេចគង់នៅតែមួយព្រះអង្គឯង នោះសមនឹងស្ងាត់ ឥតអាមាត្យមកគាល់បម្រើដល់មួយឡើយ បពិត្រមហារាជអើយ រីបាវេស្សន្តរ ជាអ្នកឥតទោស ពុំគួរនឹងឃ្លាតឱ្យឆ្ងាយអំពីអម្ចាស់ កុំអម្ចាស់តាមដោយនូវពាក្យអ្នកស្រីពិរាស្ត្រនោះឡើយ ៗ

តំ សុត្វា រាជា អាហ ព្រះបាទស្រីសញ្ជ័យ ទ្រង់ព្រះសណ្តាប់ពាក្យព្រះនាងសុបារសុប្បតីនោះហើយ ទើបមានព្រះបន្ទូលដូច្នេះវិញថា

ធម្មស្សាបចិតឹ កុម្មិ   សិវីនំ វិនយំ ធជំ
បព្វាជេមិ សកំ បុត្តំ   បាណា បិយតរោ ហិ មេតិ(១) ។

ហៃនាងសុបារសុប្បតីអើយ វីបារវេស្សន្តរនោះ ជាកូនកើតអំពីឧទរបិតនៅដោយធម៌ប្រាកដ ជាសំឡាញ់នៃអ្នកផង ៗ សឹងទុកជាត្រើយ នាងអើយ បើអញទុកនៅហើយ វានឹងអាស្រូវភាស បើអញមិនដោយតាមពាក្យអ្នកស្រីពិរាស្ត្រនោះ ឃើញជាគេមិនទុកជីវិតអញឡើយ ៗ

សា តំ សុត្វា បរិទេវមានា អាហ ហៃសាធុសប្បុរសផងទាំងឡាយអើយ វីព្រះនាងសុបារសុប្បតីទេវី ស្តាប់ព្រះបន្ទូលព្រះបាទស្រីសញ្ជ័យនោះហើយ ព្រះនាងរឹងរឹតតែទ្រង់ព្រះកន្សែងយោបំច្រើនឡើងទៀត ថាដូច្នេះ

យស្ស បុព្វេ ធជគ្គានិ   កណិការាវ បុប្ផិតា
យាយន្តមនុយាយន្តិ   ស្វាជ្ជេកោវ គមិស្សតិ ។
យស្ស បុព្វេ ធជគ្គានិ   កណិការវនានិវ
យាយន្តមនុយាយន្តិ   ស្វាជ្ជេកោវ គមិស្សតិ ។

១- បើប្រែតាមរូបបាលី មានទំនងសេចក្តីដូច្នេះ " យើងធ្វើសេចក្តីគោរពដល់ព្រះរាជធម្មប្រពៃណី ទើបបំបរបង់ព្រះរាជបុត្ររបស់ខ្លួន ដែលជាទង់ជ័យអ្នកស្រីពិរាស្ត្រផងទាំងឡាយ ទុកជាព្រះរាជបុត្រនោះ ជាទីស្រឡាញ់ពេញចិត្តក្រៃលែងជាងជីវិតរបស់អញទៅទៀតក៏ដោយ " ។

យស្ស បុព្វេ អនីកានិ　　កណិការាវ បុប្ផិតា
យាយន្តមនុយា យន្តិ　　ស្វាជ្ជេកោវ គមិស្សតិ ។
យស្ស បុព្វេ អនីកានិ　　កណិការវនានិវ
យាយន្តមនុយា យន្តិ　　ស្វាជ្ជេកោវ គមិស្សតិ ។
ឥន្ទគោបកវណ្ណាភា　　គន្ធារា បណ្ឌុកម្ពលា
យាយន្តមនុយា យន្តិ　　ស្វាជ្ជេកោវ គមិស្សតិ ។
យោ បុព្វេ ហត្ថិនា យាតិ　　សិវិកាយ រថេន ច
ស្វាជ្ជ វេស្សន្តរោ រាជា　　កថំ គច្ឆតិ បត្តិកោ ។
កថំ ចន្ទនលិត្តង្គោ　　នច្ចគីតប្បពោធនោ
ខរាជិនំ ផរសុញ្ច　　ខារិកាជញ្ច ហារតិ ។
កស្មា នាភិហរីយន្តិ　　កាសាវា អជិនានិ ច
បវិសន្តំ ព្រហារញ្ញំ　　កស្មា ចីរំ ន ពជ្ឈរេ ។
កថំ នុ ចីរំ ធារេន្តិ　　រាជបព្វជិតា ជនា
កថំ កុសមយំ ចីរំ　　មទ្ទី បរិទហេស្សតិ ។
កាសិយានិ ធារេត្វា　　ខោមកោទុម្ពរានិ ច
កុសចីរានិ ធារេន្តី　　កថំ មទ្ទី ករិស្សតិ ។
វ្យហាហិ បរិយាយិត្វា　　សិវិកាយ រថេន ច
សា កថជ្ជ អនុជ្ឈង្គី　　បថំ គច្ឆតិ បត្តិកា ។
យស្សា មុទុតលា ហត្ថា　　ចលនាវ សុខេ ឋិតា
សា កថជ្ជ អនុជ្ឈង្គី　　បថំ គច្ឆតិ បត្តិកា ។

យស្សា មុទុតលា ហត្ថា   ចលនាច សុខេធិតា
បាទុកាហិ សុវណ្ណាហិ   បីឡមានាវ គច្ឆតិ ។
សា កថជ្ជ អនុច្ឆវី   បថំ គច្ឆតិ បត្តិកា
យស្សុ ឥត្ថីសហស្សស្ស   បុរតោ គច្ឆតិ ហសិនី ។
សា កថជ្ជ អនុច្ឆវី   វនំ គច្ឆតិ ឯកិកា
យា សា សិវាយ សុត្វាន   មហុំ ឧត្រសតេ បុរេ ។
សា កថជ្ជ អនុច្ឆវី   វនំ គច្ឆតិ ភីរុកា
យា សា ឥន្ទសគោត្តស្ស   ឧលូកស្សបវស្សតោ ។
សុត្វាន នទតោ ភីតា   វារិណីវ បវេធតិ
សា កថជ្ជ អនុច្ឆវី   វនំ គច្ឆតិ ភីរុកា ។
សកុណី ហតបុត្តាវ   សុញ្ញំ ទិស្វា កុលាវកំ
ចិរំ ទុក្ខេន ឈាយិស្សំ   សុញ្ញំ អាគម្មិមំ បុរំ ។
សកុណី ហតបុត្តាវ   សុញ្ញំ ទិស្វា កុលាវកំ
កីសា បណ្ឌុ ភវិស្សាមិ   បិយេ បុត្តេ អបស្សតី ។
សកុណី ហតបុត្តាវ   សុញ្ញំ ទិស្វា កុលាវកំ
តេន តេន បធាវិស្សំ   បិយេ បុត្តេ អបស្សតី ។
កុរុរីវ ហតច្ឆាបា   សុញ្ញំ ទិស្វា កុលាវកំ
ចិរំ ទុក្ខេន ឈាយិស្សំ   សុញ្ញំ អាគម្មិមំ បុរំ ។
កុរុរីវ ហតច្ឆាបា   សុញ្ញំ ទិស្វា កុលាវកំ
កីសា បណ្ឌុ ភវិស្សាមិ   បិយេ បុត្តេ អបស្សតី ។

កុរុវីវ ហតច្ឆាបា   សុញ្ញំ ទិស្វា កុលាវកំ
តេន តេន បធាវិស្សំ   បិយេ បុត្តេ អបស្សតី ៗ
សា នូន ចាកវាកីវ   បល្លលស្មឹ អនូទកេ
ចិរំ ទុក្ខេន ឈាយិស្សំ   សុញ្ញំ អាគម្មិមំ បុរំ ៗ
សា នូន ចាកវាកីវ   បល្លលស្មឹ អនូទកេ
កីសា បណ្ឌុ ភវិស្សាមិ   បិយេ បុត្តេ អបស្សតី ៗ
សា នូន ចាកវាកីវ   បល្លលស្មឹ អនូទកេ
តេន តេន បធាវិស្សំ   បិយេ បុត្តេ អបស្សតី ៗ
ឯវញ្ច មេ វិលបន្តិយា   រាជបុត្តំ អនូសកំ
បព្វាជេសិ ច នំ រដ្ឋា   មញ្ញេ ហេស្សាមិ ជីវិតន្តិ ៗ

បពិត្រព្រះបាទស្រីសញ្ជ័យជាអម្ចាស់ខ្ញុំអើយ រីបាវេស្សន្តរ ដ៏ជាព្រះរាជបុត្រ ទ្រង់មានដំណើរទៅកាន់ឋានឯណានីមួយ សឹងដ៏ប្រកបដោយពពួកពលសកលយោធាសេនាទាហាន គឺនាយដំរី នាយសេះ នាយរទេះ នាយពាជីរាជរថ នាយពលថ្មើរជើងផងទាំងឡាយនោះ សឹងដ៏ប្រកបនូវសម្លៀកបំពាក់មានពណ៌នោះផ្សេង ៗ ខ្លះស្លៀកស ខ្លះស្លៀកខ្មៅ ខ្លះស្លៀកលឿង ដ៏មានពណ៌នោះល្អដូចខ្នងអណ្តើកមាស ដែលហើរទៅមកក្រោមដើមកណ្ណិការ ដ៏មានផ្ការីកស្គុសស្គាយ ៗ មួយសោត បាវេស្សន្តរ ជាអ្នកតែងស្លៀកនូវសំពត់វត្ថកម្ពល ដ៏មានពណ៌នោះល្អ បីដូចផ្កាចម្បា ហើយហែហមអមទាំងសងខាងទៅលេងនាព្រៃឧទ្យាន នាកាលមុនមិញ ក៏ឥឡូវនេះ

បាវេស្សន្តរ នឹងទៅត្រមោចតែម្នាក់ឯង ដើរទៅតែជើងទទេ ដោយនូវផ្លូវនោះដូចម្តេចបាន ។

ឱ! បាវេស្សន្តរអើយ បើនឹងទៅលេងឯណានោះ រមែងតែងជិះដំរី ជិះសេះ ជិះរាជរថ បរទៅលេងនាព្រៃឧទ្យាន កម្សាន្តព្រះទ័យ នាកាលមុនមិញ ឥឡូវនេះ នឹងដើរទៅតែជើងទទេម្នាក់ឯង ដោយនូវផ្លូវនោះហោង ។

ឱ! បាវេស្សន្តរអើយ អ្នកធ្លាប់តែងលាបនូវសុគន្ធពិដោរ ជាដើម គឺ លម្អិតខ្លឹមច័ន្ទន៍ ក្រឹស្នា ក្លាំពាក់ ក្លាំពា ឈ្មុសទេស ម្សៅ ធ្លាប់នៅស្រណុក ពុំដែលស្គាល់ទុក្ខ តែងទ្រង់ស្តាប់នូវសូរស័ព្ទភ្លេង តូរ្យតន្ត្រីរបាំ ចម្រៀងផងទាំងឡាយ ឥឡូវនេះ ម្តេចឡើយ ក៏ទៅស្លៀកឯសំពត់សំបកឈើ គឺអ្នកក្រងនីទៅនូវស្បូវភ្លាំង ហើយស្ពាយឆៀងស្បែកខ្លាឃ្មុំទាំងក្រចក ទ្រង់នូវញើសក្អែល ចូលទៅក្នុងកំឡុងព្រៃធំនោះតែម្នាក់ឯង ។

ឱ! អញអើយ បើដូចអញគិតនេះហើយ នាបីហៅថា ជាកូនស្តេចដែលគេបំបរបង់ចេញអំពីស្រុកទៅនៅនាព្រៃនោះ ទោះធ្លាប់តែស្លៀកសំពត់កាសិកពស្ត្រ កោទុម្ពរពស្ត្រ ខោមពស្ត្រ ធ្លាប់នៅស្រណុកយ៉ាងណា ក៏ឥឡូវនេះ នឹងទៅនៅជាទុក្ខ នាក្នុងព្រៃនោះហោង ។

ឱ! ដូចអញគិតនេះហើយ រីនាងមទ្រី ធ្លាប់តែនៅស្រណុក ឥឡូវនេះ ក៏វែងទ្រង់នូវសំពត់កាសិកពស្ត្រ កោទុម្ពរពស្ត្រ

ខោមពស្ត្រ ម្ដេចឡើយ ក៏នឹងទៅស្លៀកឯសំពត់សំបកឈើ គឺដ៏អ្នកក្រងនីទៅនូវស្បូវភ្លាំង ហើយទៅនៅនាព្រៃនោះបាន ៗ

ឱ! ដូចអញគិតនេះហើយ រីនាងមទ្រី ថាបើនឹងទៅប្រពាតក្រសាលឯណាៗក្ដី ធ្លាប់វែងជិះគ្រែស្នែង ជិះរាជរថ ឥឡូវនេះ ម្ដេចឡើយ ក៏នឹងទៅតែជើងទទេដោយផ្លូវនោះបាន ៗ

ឱ! ដូចអញគិតនេះហើយ រីនាងមទ្រី មានចង្កេះរៀវក្លៀវក្លំ សមនូវជើងដែនោះទន់ល្វន់ល្វាស ធ្លាប់តែនៅស្រណុក ពុំដែលប្រសព្វនូវទុក្ខសោកសោះឡើយ ឥឡូវនេះ នាងនឹងទៅតែជើងទទេ ឥតសុពណ៌បាទុក នឹងប្រដាប់ព្ធដ៏ព្រះបាទនោះ ក៏នឹងដើរទៅឆ្ងាយពុំបានឡើយ ៗ

បពិត្រព្រះបាទស្រីសញ្ជ័យអើយ រីនាងមទ្រី ថាបើនាងនឹងយាងទៅទីឯណា ៗ នោះ មានស្រីព្រះស្នំ ១ពាន់ ដើរមុខ ១ពាន់ ដើរក្រោយ អម្ចាស់អើយ រីនាងមទ្រី ធ្លាប់នៅស្រណុក ជាមួយនឹងរាជបរិពារដូច្នេះ ឥឡូវនេះ ម្ដេចឡើយ នាងនឹងដើរទៅជើងទទេតែម្នាក់ឯង នៅនាក្នុងព្រៃនោះបាន ៗ

បពិត្រព្រះបាទស្រីសញ្ជ័យអើយ រីនាងមទ្រីសព្វថ្ងៃនេះ នាងធ្លាប់តែនៅក្នុងព្រះរាជមន្ទីរ គ្រាន់តែឮសម្រែកចចក តុកកែ ឆ្កែព្រៃក្ដី មៀម ទីទុយ ខ្លែងខ្លោចក្ដី សឹងដ៏មានខ្លួនញ័រចំប្រប់បីដូចមេមត់ជាន់រូប ឥឡូវនេះ ម្ដេចឡើយ ក៏នឹងទៅតែម្នាក់ឯង នៅនាព្រៃទុគ៌មស្ងាត់នោះបានឡើយ ៗ

បពិត្រព្រះបាទស្រីសញ្ជ័យអើយ មេបក្សីទាំងឡាយក្ររើនតែរកចំណីទៅព្រៃឆ្ងាយ លះបង់កូនតូចនៅអាយ នាកន្យោមសំបុកនោះ អ្នកផ្ជើរព្រៃផងទាំងឡាយ គេសម្លាប់កូននោះបង់ហើយ រីឯមេបក្សី យល់កន្យោមសំបុកស្ងាត់បាត់កូននោះហើយ ជាទុក្ខច្រើនក្រៃ ម្តេចមិញ ៗ រីឯអញខ្ញុំសោត ក៏នឹងជាទុក្ខក្រៀមក្រំ យល់តែព្រះរាជមន្ទីរនោះ សូន្យស្ងាត់បាត់កូនសំឡាញ់ហើយ ក៏នឹងជាទុក្ខដូច្នោះហោង ៗ មួយសោត បីដូចមេសត្វករវិក តែងនឹងហើររកចំណី ចេញទៅព្រៃឆ្ងាយ គេយកកូនឯអាយ ហើយមកយល់តែកន្យោមសំបុកដ៏ស្ងាត់ នោះជាទុក្ខច្រើនក្រៃ ម្តេចមិញ ឯអញខ្ញុំសោត មកយល់ព្រះរាជមន្ទីរនោះ សូន្យស្ងាត់ បាត់កូនសំឡាញ់ទាំងពីរ នឹងជាទុក្ខដូច្នោះហោង ៗ មួយនីសោត បីដូចមេសត្វប្រវឹកតែងហើរទៅរកចំណីនៅព្រៃឆ្ងាយ គេយកកូនឯអាយ ត្រឡប់មកយល់តែកន្យោមសំបុក រកកូនមិញសូន្យស្ងាត់បាត់ ពុំឃើញសោះឡើយ រីមេសត្វនោះ ជាទុក្ខបម្រះននៀល នៅលើកន្យោមសំបុកនោះ ម្តេចមិញ ៗ រីអញខ្ញុំសោត នឹងយល់តែព្រះរាជមន្ទីរនោះសូន្យស្ងាត់បាត់កូនសំឡាញ់ទាំងពីរ ក៏នឹងជាទុក្ខ នៅក្នុងព្រះរាជមន្ទីរ បីដូច្នោះហោង ៗ មួយនីសោត រីមេសត្វចាក្រពាក មេអក មេទុង មេហង្ស មេក្រៀលក្តី កាលណាបើបាក់ចំអេងរលីងស្លាប ដួលស្រប៉ាបនៅលើភក់ តែងលំបាកតែម្នាក់ឯង ម្តេចមិញ អញខ្ញុំសោត ក៏ជាទុក្ខតែម្នាក់ឯង នៅក្នុងព្រះរាជមន្ទីរ

មានឧបមាបីដូច្នេះហោង ៗ

ហៃសាធុសប្បុរសផងទាំងឡាយអើយ រីព្រះនាងសុបារសុប្បតីទេវី ទ្រង់ព្រះកន្សែងដូច្នេះទៀតថា ឱ! ហេតុអ្វីអើយ ក៏គេមកបំបរបង់បាវេស្សន្តរ ដ៏ជាអ្នកឥតទោស ដោយនូវពាក្យអ្នកស្រីពិរាស្ត្រនេះ ឱ! ដូចអញគិតនេះហើយ ថាបើឥតនឹងបាវេស្សន្តរហើយ សមជីវិតអញនឹងក្ស័យមែនហោង ៗ ហៃសប្បុរសផងទាំងឡាយអើយ កាលណាព្រះនាងសុបារសុប្បតីទេវី ទ្រង់ព្រះកន្សែងយោបំដូច្នោះហើយ ក្សិណនោះ រីអស់ទាំងស្រីព្រះស្នំ ក្រមការ បរិពារបម្រើទាំងអម្បាលម៉ាន នៅក្នុងព្រះរាជមន្ទីរនោះក្តី នៅក្រៅព្រះរាជមន្ទីរព្រះបាទស្រីវេស្សន្តរក្តី កាលណាបើឮសព្ទយោបំព្រះនាងសុបារសុប្បតីទ្រង់ព្រះកន្សែងហើយ រីអស់ស្រីស្នំទាំងអម្បាលនោះ សឹងមកជំនុំព្រមនឹងគ្នាហើយ សឹងដ៏លើកដៃដាក់លើត្បូងដៃមួយគក់ទ្រូងទួញយំសោកស្រណោះ អាឡោះអាល័យក្សត្រថ្លៃទាំងពីរព្រះអង្គនោះ ពុំអាចនឹងទប់ទល់ តម្កល់អាត្មាភាព បានឡើយ សឹងដ៏មានខ្លួនញ័រចំប្រប់ សន្លប់ដួលទៅ នៅនាព្រះរាជមន្ទីរ បីដូចព្រៃសាលវ័ន ដួលទៅ ដោយអំណាចខ្យល់បក់បំភ្លូកដូច្នោះហោង ៗ

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណា ពុំទាន់ប្រាកដ បទព្រះបាលីឯណា ពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គឈ្នះមារ ស្តេចមានព្រះបន្ទូល សូត្រសានូវ

បាទគាថាទាំងឡាយដូច្នេះថា :

តស្សា សាលបិតំ សុត្វា   សព្វា អន្តេបុរេ អហុ
ពាហា បគ្គយ្ហ បក្កន្ទុំ   សិវិកញ្ញា សមាគតា ។
សាលាវ សម្បមទ្ទិតា   មាលុតេន បមទ្ទិតា
សេន្តិ បុត្តា ច ទារា ច   វេស្សន្តរនិវេសនេ ។
ឱរោធា ច កុមារា ច   វេសិយានា ច ព្រាហ្មណា
ពាហា បគ្គយ្ហ បក្កន្ទុំ   វេស្សន្តរនិវេសនេ ។
ហត្ថារោហា អនីកដ្ឋា   រថិកា បត្តិការកា
ពាហា បគ្គយ្ហ បក្កន្ទុំ   វេស្សន្តរនិវេសនេ ។
តតោ រត្យា វិវសនេ   សុរិយស្សុគ្គមនំ បតិ
អថ វេស្សន្តរោ រាជា   ទានំ ទាតុំ ឧបាគមិ ។
វត្ថានិ វត្ថកាមានំ   សោណ្ឌានំ ទេថ វារុណី
ភោជនំ ភោជនត្ថីនំ   សម្មទេវ បវេច្ឆថ ។
មា ច កិញ្ចិ វណិព្វកេ   ហេឋយិត្ថ ឥធាគតេ
តប្បេថ អន្នបានេន   គច្ឆន្តុ បដិបូជិតា ។
តេ សុ មត្តា កិលន្តាវ   សម្បតន្តិ វណិព្វកា
និក្ខមន្តេ មហារាជេ   សិវីនំ រដ្ឋវឌ្ឍនេ ។
អច្ឆេច្ឆុំ វត ភោ រុក្ខំ   នានាផលធំ ទុមំ
យថា វេស្សន្តរំ រដ្ឋា   បព្វាជេន្តិ អទូសកំ ។
អច្ឆេច្ឆុំ វត ភោ រុក្ខំ   នានាផលធរំ ទុមំ
យថា វេស្សន្តរំ រដ្ឋា   បព្វាជេន្តិ អទូសកំ ។

អច្ឆេច្ឆុំ វត ភោ រុក្ខំ　　សព្វកាមទទំ ទុមំ
យថា វេស្សន្តរំ រដ្ឋា　　បព្វាជេន្តិ អទូសកំ ។
អច្ឆេច្ឆុំ វត ភោ រុក្ខំ　　សព្វកាមរសាហរំ
យថា វេស្សន្តរំ រដ្ឋា　　បព្វាជេន្តិ អទូសកំ ។
យេ វុឌ្ឍា យេ ច ទហរា　　យេ ច មជ្ឈិមបោរិសា
ពាហា បគ្គយ្ហ បក្កន្ទុំ　　. . . . .។
និក្ខមន្តេ មហារាជេ　　សិវីនំ រដ្ឋវឌ្ឍនេ
អតិយក្ខា រស្សវរា　　ឥត្ថាគារា ច រាជិនោ ។
ពាហា បគ្គយ្ហ បក្កន្ទុំ　　. . . . .
និក្ខមន្តេ មហារាជេ　　សិវីនំ រដ្ឋវឌ្ឍនេ ។
ឱយោបិ តត្ថ បក្កន្ទុំ　　យា តម្ហិ នគរេ អហុ
និក្ខមន្តេ មហារាជេ　　សិវីនំ រដ្ឋវឌ្ឍនេ ។
យេ ព្រាហ្មណា យេ ច សមណា អញ្ញេវាបិ វណិព្វកា
ពាហា បគ្គយ្ហ បក្កន្ទុំ　　អធម្មោ កិរ ភោ ឥតិ ។
យថា វេស្សន្តរោ រាជា　　យជមានោ សកេ បុរេ
សិវីនំ វចនត្ថេន　　សម្ហា រដ្ឋា និរជ្ជតិ ។
សត្តហត្ថិសតេ ទត្វា　　សព្វាលង្ការភូសិតេ
សុវណ្ណកច្ឆេ មាតង្គេ　　ហេមកប្បនិវាសសេ ។
អារុឡ្ហេ គាមណីយេភិ　　តោមរង្កុសបាណិភិ
ឯស វេស្សន្តរោ រាជា　　សម្ហា រដ្ឋា និរជ្ជតិ ។
សត្តអស្សសតេ ទត្វា　　សព្វាលង្ការភូសិតេ

អាជានីយេ ច ជាតិយា   សិន្ធវេ សីឃពាហនេ
អារុឡ្ហេ គាមណីយេភិ   ឥល្លិយាចាបធារិភិ
ឯស វេស្សន្តរោ រាជា   សម្ហា រដ្ឋា និរជ្ជតិ ។
សត្តរថសតេ ទត្វា   សន្នទ្ធេ ឧស្សិតទ្ធជេ
ទីបេ អថោបិ វេយ្យគ្ឃេ   សព្វាលង្ការភូសិតេ
អារុឡ្ហេ គាមណីយេភិ   ចាបហត្ថេហិ ចម្មិភិ
ឯស វេស្សន្តរោ រាជា   សម្ហា រដ្ឋា និរជ្ជតិ ។
សត្តឥត្ថីសតេ ទត្វា   ឯកមេកា រថេ ឋិតា
សន្នទ្ធា និក្ខរជ្ជូហិ   សុវណ្ណេន អលង្កតា
បីតាលង្ការា បីតវសនា   បីតាភរណភូសិតា
អាឡ្បារប្បមុខា ហសុលា   សុសញ្ញា តនុមជ្ឈិមា
ឯស វេស្សន្តរោ រាជា   សម្ហា រដ្ឋា និរជ្ជតិ ។
សត្តធេនុសតេ ទត្វា   សព្វា កំសុបធារិនោ
ឯស វេស្សន្តរោ រាជា   សម្ហា រដ្ឋា និរជ្ជតិ ។
សត្តទាសីសតេ ទត្វា   សត្តទាសសតានិ ច
ឯស វេស្សន្តរោ រាជា   សម្ហា រដ្ឋា និរជ្ជតិ ។
ហត្ថី អស្សេ រថេ ទត្វា   នារិយោ ច អលង្កតា
ឯស វេស្សន្តរោ រាជា   សម្ហា រដ្ឋា និរជ្ជតិ ។
តទាសិ យំ ភឹសនកំ   តទាសិ លោមហំសនំ
មហាទានេ បទិន្នម្ហិ   មេទនី សមកម្បថ ។

នទាសិ យំ ភីសនកំ   នទាសិ លោមហំសនំ
យំ បញ្ជលីកតោ រាជា   សម្មា រដ្ឋា និវត្តីតិ(១) ។

ហៃភិក្ខុផងទាំងឡាយអើយ រីអស់អ្នកទាំងអម្បាលណោះ ដែលមាននៅក្នុងកំឡុងព្រះនគរនោះក្តី ទោះស្រីស្នំក្រមការ អ្នកបម្រើនោះក្តី ទោះកូនអាមាត្យក្តី, ទោះព្រះរាជបុត្រក្តី, ទោះអ្នកឈ្នួញជួញប្រែក្តី, ទោះព្រាហ្មណ៍ព្រឹទ្ធបណ្ឌិតក៏អ្នកប្រាជ្ញក្តី មិនប៉ុន្តែប៉ុណ្ណោះឡើយ ទោះនាយដំរី នាយរទេះ នាយពាជី នាយរាជរថ នាយពលថ្មើរជើងក្តី ទោះអ្នកស្រុកក្រៅលំនៅជនបទផងទាំងឡាយក្តី រីអ្នកទាំងអម្បាលណោះ កាលណាបើឮសព្ទយោបំ សំឡេងទ្រង់ព្រះកន្សែងនៃព្រះនាងសុបារសុប្បតីទេវីហើយ ក៏ពុំអាចដើម្បីទប់ទល់តម្កល់អាត្មាភាពនោះបានឡើយ សឹងដ៏លើកដៃដាក់លើត្បូង ដៃមួយគក់ទ្រូងទួញយំ ដ៏មានសព្ទសំឡេងនោះមហិមាក្រៃពេក មុខគួរឱ្យខ្លាច មានឮដ៏ស្រុកជេតុត្តរនគរនោះហោង ។

១- តាមច្បាប់មហាជាតក៏សម្រាយទាំងឡាយ មិនមានបាលីគាថាច្រើនពេញលេញដូចក្នុងទីនេះទេ ច្រើនឃើញមានបាលី-គាថាត្រឹម ២-៣ គាថា ឬពីរ-បីបាទក៏មាន ក្នុងទីនេះ បានស្រង់យកបាលីគាថា មកដាក់បំពេញតាមច្បាប់មហាជាតក៏បាលី ឯសេចក្តីប្រែ បានរក្សាទុកតាមច្បាប់មហាជាតក៏សម្រាយទាំងអស់ ។

ហៃសាធុសប្បុរសផងទាំងឡាយអើយ អណ្ដាប់នោះ ព្រះអាទិត្យ រះភ្លឺឡើងហើយកូវ ព្រះមហាសត្វស្ដេចដោះឡើងកក់ជម្រះព្រះអង្គស្រង់ស្រេចហើយ ទ្រង់នូវគ្រឿងប្រដាប់សព្វប្រការ ហើយស្ដេចសោយភោជនាហារ ដ៏មានរសពីសាផ្សេង ៗ ទើបស្ដេចលីលាទៅកាន់សាលាទាន មួយអន្លើនឹងអាមាត្យផងទាំងឡាយជាបរិវារ ស្ដេចមានព្រះចំណង់ចង់ឱ្យសត្តសតកមហាទាន ៗ

ភិក្ខុអើយ នាកាលបើអំណើះដំណើរព្រះអាទិត្យ រះឡើងហើយនោះ ក្សិណនោះ ព្រះបាទស្រីវេស្សន្តរដ៏ជាក្សត្រប្រសើរស្ដេចទៅកាន់សាលាទាន មួយអន្លើនឹងអស់អាមាត្យទាំង ៦ ម៉ឺនកូវ ទ្រង់ឱ្យរណ្ដាប់ទាននឹងឱ្យស្មូមយាចកផងទាំងឡាយ ដូច្នេះថា ហៃអាមាត្យអើយ ថាបើស្មូមឯណាមួយ វាមកសាលាទាននេះហើយ បើវាចង់បានសំពត់ ក៏ចូរប្រស្ដែងរណ្ដាប់សំពត់ ឱ្យទានស្មូមនោះហោង ៗ បើស្មូមឯណាមួយ វាចង់ហូបបាយក្ដី ចូរប្រស្ដែងរណ្ដាប់បាយឱ្យស្មូមនោះហូបឱ្យឆ្អែត ហើយឱ្យទានដោយចំណង់ចិត្តស្មូមនោះហោង ៗ

ហៃសប្បុរសផងទាំងឡាយអើយ រីព្រះបាទស្រីវេស្សន្តរ ដ៏ជាក្សត្រប្រសើរ តែងទ្រង់ចម្រើនអ្នកស្រុកស្រីពិរាស្ត្រ ស្ដេចឱ្យទានស្រេច ព្រះអង្គនឹងចេញទៅអំពីស្រុកជេតុត្តរនគរ កាលឯណាកូវ ឯស្មូមផងទាំងឡាយ មកទទួលយកព្រះរាជទានហើយ បបួលគ្នាមកឈរជាចំពូក ៗ ហើយស្រដីដូច្នេះថា

ភោវន្តោ ម្នាលគ្នាយើងទាំងឡាយអើយ រីព្រះបាទស្រីវេស្សន្តរ នេះជាពំនាក់អស់ស្មូមផងទាំងឡាយ ឧបមាបីដូចអ្វី ជាឧបមាបី ដូចដើមឈើណាមួយមានផ្លែផ្កា ដ៏ជាពំនាក់នៃសត្វផងទាំងឡាយ វារហើរមកអំពីចម្ងាយ ឃ្លានបាយចំណី ក៏ចង់បរិភោគ ឱ្យទាល់តែឆ្អែត ។

ឱ ! ព្រះបាទស្រីវេស្សន្តរអើយ ព្រះអង្គហោង ជាអ្នកឥតទោស ហេតុអ្វីឡើយ ក៏អ្នកស្រីពិរាស្ត្រមកបំបរបង់ព្រះអង្គ ឱ្យខ្លាយចេញ អំពីស្រុកដូច្នេះ ។

ភោវន្តោ ម្នាលគ្នាយើងទាំងឡាយអើយ រីអ្នកស្រីពិរាស្ត្រ នេះ ឧបមាបីដូចអ្នកកន្ទ្រឹសឬស្សា មកកាប់ដើមឈើ សឹងដ៏មានផ្លែផ្កា សឹងជាពំនាក់នៃសត្វផងទាំងឡាយនោះឱ្យអន្តរាយ ពុំឱ្យសត្វផងទាំងឡាយពឹងបានឡើយ ឱ! ព្រះវេស្សន្តរ ជាអ្នកឥតទោស ជាពំនាក់នៃស្មូមផងទាំងឡាយ ទោះស្មូមឯណានឹងប្រាថ្នាអ្វីៗ ឥតទើសទាល់សល់ក្រអ្វីឡើយ ។

ឱ ! អ្នកទាំងឡាយអើយ ទោះអ្នកឯណាមួយ ទោះក្មេង(១) ពាលកណ្តាល ចាស់នោះ តែបានមកដល់ហើយប្រាថ្នាត្រង់ឯណាមិញ សឹងបានដូចបំណងត្រង់ណោះហោង ។ អ្នកទាំងឡាយអើយ អំពីថ្ងៃនេះទៅហើយ រីស្មូមផងទាំងឡាយ ឥតបើពំនាក់

១- ច្បាប់ខ្លះថា " ទោះអ្នកឯណាមួយជាក្លោះ ពាល កណ្តាល ចាស់ក្តី " ។

ឡើយ រីសព្វយោបំនោះ មិនប៉ុន្តែស្លូមនោះឡើយ ទោះអ្នកផ្លូលមេមត់(១) ក្តី ទោះអ្នកក្រៅលំនៅជនបទក្តី អ្នកចេះរក្សាភូមិផ្ទៃក្រោមក្តី អ្នកថែទាំចាំឃ្លាំង ចាំវាំងព្រះរាជមន្ទីរក្តី ទោះស្រីព្រះស្នំក្រមការអ្នកបម្រើក្តី ទោះព្រាហ្មណ៍ព្រឹទ្ធបណ្ឌិតកវីក្តី រីអស់អ្នកអម្បាលណោះ សឹងមកជំនុំព្រមគ្នា សឹងលើកដៃដាក់លើត្បូងដៃមួយគក់ទ្រូងទួញយំ សឹងឮសព្ទយោបំយំនោះច្រើនមហិមា ថា ឱ! អ្នកទាំងឡាយអើយ រីអ្នកស្រីពិរាស្ត្រផងទាំងឡាយនេះហៅថាជាអ្នកឥតធម៌ពិតហោង ម្តេចឡើយ ក៏មកបំបរបង់ព្រះបាទស្រីវេស្សន្តរ ជាអ្នកឥតទោស ឱ្យប្រាសនិរាសចេញអំពីស្រុកដូច្នេះ ៗ

ឱ! ព្រះបាទស្រីវេស្សន្តរក្សត្រថ្លៃប្រសើរនៃយើងខ្ញុំទាំងឡាយអើយ ឥឡូវនេះ ព្រះអង្គនៅតែឱ្យទាន ហើយស្តេចនឹងចេញទៅអំពីស្រុកនេះដោយនូវពាក្យអ្នកស្រីពិរាស្ត្រគេបំបរបង់នោះហោង ៗ

រីព្រះបាទស្រីវេស្សន្តរ ដ៏ជាក្សត្រប្រសើរនោះ ស្តេចឱ្យទានដំរីនោះ ៧០០ រីដំរីនោះសោត សឹងប្រដាប់នីទៅនូវខ្សែក្រពាត់លំញ៉ាង សំអាងមុខ ស្រោមភ្លុកសឹងដ៏មាស ដ៏មានកម្រាលលើខ្នងនោះសោត ដ៏ល្អនីទៅនូវកែវសព្វពិធរ័ត្ន រីទម័កនោះសោត សឹងដ៏ពាក់នីទៅនូវមួកមាស ខោស្នាប់ភ្លៅ ក្រោះក្រោយរាយផ្កាយមាសទាំងពួងដ៏មានដៃកាន់នីទៅនូវកង្វេរមាស ហើយ

១- ច្បាប់ខ្លះថា " ទោះអ្នកផ្លូលមេមត់អ្នកចេះសែនខ្មោចក្តី, ឯពាក្យថា ផ្លូល គឺ អ្នកដែលចេះបួល " ៗ

ឱ្យឡើងជិះព្រមគ្នា ទើបស្ដេចលើកឱ្យទៅជាទាន ហើយស្ដេចចេញទៅ ដោយនូវពាក្យអ្នកស្រីពិរាស្ត្រនោះហោង ។

រីព្រះមហាក្សត្រ ព្រះអង្គឱ្យទានសេះ ៧០០ រីសេះនោះសោត ដ៏ប្រដាប់នូវគ្រឿងទាំងពួង សឹងជាសេះអាជានេយ្យប្រសើរ សឹងកើតអំពីសន្ធវប្រទេស មានកម្លាំងស្មើខ្យល់ រីទម័កសេះនោះសោត មានក្បាលពាក់ម្កុក ដ៏មានដៃកាន់រំពាត់ផ្ដៅ កៅទ័ណ្ឌ ហើយឡើងជិះព្រមគ្នា ហើយស្ដេចលើកឱ្យទៅជាទានស្រេចបរិបូណ៌ពុំយូរឡើយ ទើបស្ដេចចេញទៅដោយនូវពាក្យអ្នកស្រីពិរាស្ត្រនោះហោង ។

ព្រះមហាក្សត្រ ព្រះអង្គឱ្យរាជរថ ៧០០ ដ៏ប្រដាប់នូវកម្រាលថៀមចំព្រៃព្រំ ដែរដាស ពាសពេញនីទៅនូវស្បែកខ្លាឃ្មុំ ស្បែករាជសីហ៍ សំយាកទាំងសងខាង រីទ្រូងនោះសោតសឹងបណ្ដាញមាស ហើយមានចងចង្ក្រង់នាគ ប្រដាប់នូវត្បូងនោះសោត សឹងមាស រីនាយរាជរថនោះសោត ដ៏ប្រដាប់នូវគ្រឿងធ្នឹមអម្ពរ ដ៏មានដៃកាន់នូវគ្រឿងធ្នូសេលោហ៍ ក្បាលពាក់ម្កុក ហើយឡើងជិះព្រមគ្នា ស្ដេចលើកឱ្យទានស្រេចហើយ ស្ដេចចេញទៅដោយនូវពាក្យអ្នកស្រីពិរាស្ត្រគេបំបរបង់នោះហោង ។

ស្ដេចឱ្យទានស្រីព្រះស្នំនោះ ៧០០ រីស្រីព្រះស្នំនោះសោតឱ្យជិះលើរាជរថមួយ ៗ គ្រប់រាជរថ រីស្រីព្រះស្នំអស់នោះ សឹងដ៏មានរូបនោះល្អ ដ៏ប្រដាប់នីទៅនូវមកុដអារាម សឹងដ៏ទ្រង់នីទៅ

នូវគ្រឿងអម្ពររំលេចរចនាសឹងមាស សឹងដ៏មានចង្កេះរៀវក្បៀវក្លំ សមនូវបង្គុយនោះរាបសុភាព មានមាត់នោះញញឹមប្រិមប្រិយ ហើយបើនឹងស្រដី ហាក់បីដូចស្រីទេពអប្សរនៅនាត្រៃត្រឹង្សសួគ៌ មុខគួរតែបម្រើព្រះមហាក្សត្រនោះហោង ៗ

ហៃសប្បុរសផងទាំងឡាយអើយ មិនប៉ុន្តែម្ល៉ោះឡើយ ព្រះអង្គឱ្យទានខ្ញុំស្រីនោះ ៧០០ ខ្ញុំប្រុសនោះ ៧០០ ព្រះអង្គឱ្យទានគោបាព្រោះនោះ ៧០០ មេគោឆ្នាត់នោះ ៧០០ នូវអាងតែងរងក្សីរ សឹងមាសនោះ ៧០០ ស្រេចហើយ ទើបព្រះអង្គស្តេចចេញទៅដោយនូវពាក្យអ្នកស្រីពិរាស្ត្រនោះហោង ៗ

ហៃសាធុសប្បុរសផងទាំងឡាយអើយ រីព្រះពោធិសត្វ ព្រះអង្គឱ្យទានស្រេចហើយ ព្រះអង្គប្រាថ្នាយកប្រាជ្ញាសព៌ជ្ញតាញ្ញាណទុកជាចំណាង កាលណាមិញ រីពន្លឹកស័ព្ទអស្ចារ្យមហិមាក្រៃពេក ក៏កក្រើករំពើកទៅដល់ទេពនិករអមរផង ដ៏មានខ្លួនញ័រចំប្រប់ព្រឺព្រួចអស់លោមា កើតមាននៅនាជេតុត្តរនគរ ឮដ៏កាលណោះហោង ៗ

តទា បន ទេវតា ជម្ពូទីបតលេ រាជូនំ ទេស្សន្តរេ រាជា ខត្តិយកញ្ញាទិកំ មហាទានំ ទេតីតិ អារោចយឹសុ

ហៃសាធុសប្បុរសផងទាំងឡាយអើយ នាកាលព្រះមហាក្សត្រអ្នកឱ្យសត្តសតកមហាទាននោះ ទោះបីទេវតា នៅនាឆកាមាវចរសួគ៌នាយក្តី ទោះបីទេវតាឋិតនៅនាជម្ពូទ្វីប ផ្ទៃ

ក្រោមនេះក្ដី សឹងមកជ្រោមជ្រែងជួយបំពេញទានព្រះបរមពោធិសត្វ រីអស់ទេវតាទាំងនោះ ទៅស្រដីឃោសនាប្រាប់អស់មហាក្សត្រមាននៅនាជម្ពូទ្វីបនេះថា **ភោវន្តោ** ម្នាលអស់ស្ដេចផងទាំងឡាយអើយ ឥឡូវនេះ ព្រះបាទស្រីវេស្សន្តរព្រះអង្គឱ្យសត្តសតកមហាទានប្រដាប់នូវស្រីព្រះស្នំក្រមការនោះល្អៗ សូមអញ្ជើញអ្នកទៅទទួលយកទានព្រះបាទស្រីវេស្សន្តរនោះហោង ។

ហៃអស់សប្បុរសផងទាំងឡាយអើយ ហេតុតែអានុភាពទេវតាឃោសនានោះកូវ អស់ស្ដេចផងទាំងឡាយ ក៏មកទទួលយកស្រីកញ្ញាអំពីព្រះមហាក្សត្រឱ្យទាននោះ នាំទៅកាន់ឋានលំនៅអាត្មាទីទៃៗ ទៅហោង ។ បពិត្រអើយ រីអស់អ្នកផងទាំងពួងអម្បាលម៉ាណ នៅនាជេតុត្តរនគរនោះ ទោះស្ដេចក្ដី ព្រាហ្មណ៍ក្ដី ឈ្មួញក្ដី អស់អ្នកទាំងអម្បាលនោះ សឹងមកទទួលយកទាននោះថាដូច្នេះ បពិត្រព្រះវេស្សន្តរអើយ រីអស់អ្នកស្រីពិរាស្ដ្រ ផងទាំងឡាយ គេបំបរបង់អម្ចាស់ បទតែឱ្យទាននេះឯង ក៏អម្ចាស់រឹងជាឱ្យទានមួយសាសោតហោង ① ។

១- មានច្បាប់មហាជាតក៏ខ្លះ មានបាលីនិងសេចក្ដីលើសកើនបន្ថិចទៅទៀតថា" តេន វុត្តំ " ហេតុនោះហោង ព្រះអង្គបន្ទូលសូត្រសានូវបាទគាថាដូច្នេះ " ភោ សារីបុត្ត " ហៃសារីបុត្តអើយ នាកាលព្រះវេស្សន្តរស្ដេចឱ្យទាននោះ រីសព្ទទាននោះ វាឮខ្ទរខ្ទារ អស់អ្នកជេតុត្តរនគរនោះរឹងជាខឹងអម្បាលម៉ានក្ដី ក៏ព្រះអង្គពុំលែង ត្រង់ឱ្យទាននោះ

ឆ្លង . . .

កាលណាព្រះអង្គឱ្យទានស្រេចហើយ លុះថ្ងៃល្ងាច ស្ដេចចូលទៅនាព្រះរាជមន្ទីរព្រះអង្គហើយ ព្រះអង្គទ្រង់ព្រះចិន្តាថា នៅថ្ងៃស្អែកនេះឯង អញនឹងទៅថ្វាយបង្គំលាព្រះវរមាតាបិតាអញ ។

បុនទិវសេ មហាសត្តោ រីព្រះមហាសត្វ លុះព្រឹកឡើង ស្ដេចឡើងគង់លើរាជរថ គិតដ៏អ្នកប្រដាប់ដ៏ប្រសើរ ក្សិណានោះ សម្ដេចព្រះរាជមទ្រី ព ព្រះរាជកុមារទាំងពីរទៅគង់លើរាជរថ រួចស្ដេចទៅកាន់មេក្មេក បាក្មេក សូមឱ្យអ្នកអនុញ្ញាតឱ្យដំណើរទៅនឹងព្រះបាទស្រីវេស្សន្តរនោះហោង ។

មហាសត្តោ បិតរំ វន្ទិត្វា អត្តនោ គមនភាវំ កថេសិ

ឡើយ ព្រះអង្គរឹងជាឱ្យទានមួយសាវិញទៀត រីស្នូមផងទាំងឡាយ អម្បាលដែលមកទទួលព្រះរាជទាននោះ ក៏សឹងដណ្ដឹងគ្នាដូច្នេះថា គ្នាយើងអើយ ឱ ! ដូចយើងគិតនេះ រីព្រះបាទស្រីវេស្សន្តរព្រះអង្គឱ្យទានហើយ ក៏ស្ដេចនឹងចេញទៅគង់ព្នដ៏ព្រៃនោះហោង ។ ឱ ! អំពីនេះទៅហើយ យើងឥតបើពំនាក់ឡើយ រីអស់ស្នូមផងទាំងឡាយនោះ ក៏គក់ទ្រូងទួញយំជាចំពួកទីទៃ ៗ ហាក់ដូចជាគេកាត់សន្លាក់ជើងដៃទទេ ៗ ៗ. តមត្ថំ បកាសេន្តោ សត្ថា អាហ ភិក្ខុអើយ រីព្រះបាទស្រីវេស្សន្តរ ដ៏ជាស្ដេចធំ តែងចម្រើនស្រុកអ្នកស្រីពិរាស្ត្រនោះ ស្ដេចឱ្យទានស្រេចហើយ ក៏ស្ដេចនឹងចេញទៅពីស្រុកនោះ រីអស់ស្នូមផងទាំងឡាយ ក៏សឹងទុក្ខទួញយំខ្សឹកខ្សួលរំជួលទីទៃ ៗ ឧបមាបីដូចឱពុកម្ដាយកំព្រាព្រាត់ប្រាស និរាសបាត់បង់យួរលង់នោះហោង ៗ (សេចក្ដីប៉ុណ្ណេះ មិនមានក្នុងអដ្ឋកថាមហាវេស្សន្តរជាតកបាលីទេ) ។

វីព្រះមហាសត្វ ស្តេចថ្វាយបង្គំលាព្រះវររាជបិតា ក្រាបទូលដោយដំណើរស្តេចនឹងទៅនោះឯង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ វីអាថ៌ធម៌ឯណា ពុំទាន់ប្រាកដ បទព្រះបាលីឯណា ពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គឈ្នះនូវមារាធិរាជ អាចមានព្រះបន្ទូលនូវបាទព្រះគាថា ដូច្នេះ ថា

អាមន្តយិត្ថ រាជានំ   សញ្ជយំ ធម្មិកំ វរំ
អវរុទ្ធសិ មំ ទេវ   វង្កំ គច្ឆាមិ បព្វតំ ។
យេ ហិ កេចិ មហារាជ   ភូតា យេ ច ភវិស្សរេ
អតិត្តាយេវ កាមេហិ   គច្ឆន្តិ យមសាធនំ ។
សោហំ សកេ អភិសសី   យជមានោ សកេ បុរេ
សិវីនំ វចនត្ថេន   សម្ហា រដ្ឋា និរជ្ជហំ ។
អឃន្តំ បដិសេវិស   វនេ វាឡមិគាកិណ្ណេ
. . . .   ខគ្គទីបិនិសេវិតេ
អហំ បុញ្ញានិ ករោមិ   តុម្ហេ បង្កម្ហិ សីទថាតិ ។

ភិក្ខុអើយ វីព្រះបាទស្រីវេស្សន្តរ កាលណាស្តេចនឹងចេញអំពីជេតុត្តរនគរនោះ ព្រះអង្គក្រាបទូលព្រះបាទស្រីសញ្ជ័យ ដែលព្រះអង្គតែងសោយរាជ្យបិតនៅដោយគន្លងធម៌ដ៏ប្រសើរ ថា បពិត្រព្រះសម្មតិទេពក្សត្រថ្លៃប្រសើរអើយ ព្រះអង្គបំបរបង់អញ្ញខ្ញុំចេញ

ក៏អញខ្ញុំនឹងចេញទៅសាងព្រះផ្នួស បួសនៅនាភ្នំវង្កតបព៌តនោះឯងហោង ៗ បពិត្រព្រះមហារាជ ដ៏ជាស្ដេចធំប្រសើរអើយ បើអ្នកឯណាមួយកើតឡើងឰដ៏លោកនេះ ចំពាក់នឹងកាមគុណហើយ ក៏អ្នកនោះឯង នឹងលុះក្នុងចំណាងព្រះយមរាជមិនខាន ៗ អញខ្ញុំនឹងទៅទូន្មានអាត្មាខ្ញុំឯង ហើយនឹងសាងព្រះផ្នួស ចម្រើនមេត្តាភាវនា នៅនាភ្នំវង្កតបព៌ត ដោយនូវអ្នកស្រីពិរាស្ដ្រ គេបំបរបង់អញខ្ញុំហោង ៗ បពិត្រព្រះមហាក្សត្រថ្លៃប្រសើរអើយ អញខ្ញុំនឹងទៅនៅនាព្រៃនោះ មួយអន្លើនឹងម្រឹគពាឡសាហាវ ជាដើម គឺរាជសីហ៍ ដំរីព្រៃ ខ្លាធំ ខ្លាដំបងផង អញខ្ញុំនឹងសូត្រមន្តចម្រើនភាវនានៅនាព្រៃនោះ ៗ បពិត្រព្រះជនកអើយ សូមឱ្យអម្ចាស់គង់នៅនារាជសម្បត្តិ ជាសុខសប្បាយទៅហោង ៗ

ឥតិ មហាសត្តោ បិតរ សទ្ធឹ ឥមាហិ ចតូហិ គាថាហិ កថេត្វា មាតុ សន្តិកំ គន្ត្វា វន្ទិត្វា បព្វជ្ជំ អនុជានាបេន្តោ ព្រះមហាសត្វ ទូលព្រះវរបិតា ដោយនូវព្រះគាថា ៤ ព្រះគាថានោះហើយ ស្ដេចក៏ក្រាបថ្វាយបង្គំលាទៅកាន់សម្នាក់ព្រះនាងសុបារសុប្បតី ដ៏ជាព្រះវរមាតា ដើម្បីនឹងសូមទ្រង់អនុញ្ញាតផ្នួសនៃអាត្មា ក្រាបទូលសូត្រនូវបាទព្រះគាថាដូច្នេះ

អនុជានាហិ មំ អម្ម   បព្វជ្ជា មម រុច្ចតិ
សោវហំ សកេ អភិសសឹ   យជមានោ សកេ បុរេ
សិវីនំ វចនត្ថេន   សម្ហា រដ្ឋា និរជ្ជហំ ៗ

អយន្តំ បដិសេវិស្សំ　　វនេ វាឡមិគាកិណ្ណេ
. . . .　　ខគ្គទីបិនិសេវិតេ
អហំ បុញ្ញានិ ករោមិ　　វនំ គច្ឆាមិ បព្វតន្តិ ។

បពិត្រព្រះវររាជមាតាជាអម្ចាស់ខ្ញុំអើយ សូមទានអម្ចាស់អនុញ្ញាតផ្នួសឱ្យអញខ្ញុំៗ គាប់ចិត្តនឹងផ្នួសនោះណាស់ អម្បាលអញខ្ញុំធ្វើទានតែក្នុងប្រាសាទរបស់ខ្លួន នៅឈ្មោះថាជាអ្នកបៀតបៀនអ្នកស្រុកអ្នកនគរ ដូច្នេះអញខ្ញុំក្រាបទូលសូមលាទៅនៅភ្នំវង្កតបព៌ត នាព្រៃព្រះហេមពាន្ត តាមពាក្យអ្នកស្រីពិរាស្ត្រ ផងទាំងឡាយ អម្ចាស់អើយ វីឋាននោះដ៏ពេញនីទៅនូវម្រឹគឃោរឃៅដ៏សាហាវពន្លឹក ជាដើម គឺ រាជសីហ៍ ដំរីព្រៃ ខ្លាធំ ខ្លាដំបង រមាំង រមាស ទន្សោង គោព្រៃ អម្ចាស់អើយ ខ្ញុំនឹងទៅសាងផ្នួសបួសជាមហាឫសី យកសត្វអស់នោះជាគ្នា ខ្ញុំនឹងចម្រើនមេត្តាភាវនា រក្សាផ្នួសនៅហោង ។

តំ សុត្វា ផុស្សតី ទេវី អាហ វីព្រះនាងសុបារសុប្បតី ដ៏ជាអគ្គមហេសីនៃព្រះបាទស្រីសញ្ជ័យ ទ្រង់ស្តាប់ព្រះរាជបុត្រទូលដូច្នោះហើយ មានសេចក្តីព្រឺព្រួច គ្រលួចក្នុងព្រះហឫទ័យ ត្រេកអរសាទរនឹងផ្នួសក្រៃពេក ក៏មានបន្ទូលនូវព្រះគាថា ដូច្នេះ

អនុជានាមិ តំ បុត្ត　　បព្វជ្ជា តេ សមិជ្ឈតុ
អយញ្ច មទ្ទី កល្យាណី　　សុសញ្ញា តនុមជ្ឈិមា
អច្ឆតំ សហ បុត្តេហិ　　កឹ អរញ្ញេ ករិស្សតីតិ ។

ហៃកូនស្ងួនសំឡាញ់ម្ដាយអើយ រីត្រង់ផ្នួសនោះ ម្ដាយនឹងអនុញ្ញាតឱ្យព្ធដ៏អ្នកហើយ បាអើយ ប៉ុន្តែនាងមទ្រីដ៏ជាស្រីប្រកបនូវលក្ខណាទាំងឡាយ ធ្លាប់តែនៅស្រណុកសុខសប្បាយ ចូរបាឱ្យនាងនៅឯអាយនឹងម្ដាយថែរក្សាកូន បាអើយ នាងមទ្រីនេះជាស្រីមិនធ្លាប់ប្រសព្វនូវទុក្ខអ្វីមួយ ម្ដេចឡើយ នឹងទៅនៅនាព្រៃនោះបាន ។

វេស្សន្តរោ អាហ រីព្រះបាទស្រីវេស្សន្តរស្ដាប់ព្រះបន្ទូលព្រះវរមាតាហើយ ទូលតបស្នងវិញថា ដូច្នេះ

នាហំ អកាមា ទាសិបិ អរញ្ញំ នេតុមុស្សហេ
សចេ ឥច្ឆសិ អន្វេតុ សចេ នេច្ឆតិ អច្ឆតូតិ ។

បពិត្រព្រះមាតាអម្ចាស់ខ្ញុំអើយ កុំថាតែនាងមទ្រីឡើយ ទោះដល់ខ្ញុំស្រីឯណាមួយ វាចង់ទៅនឹងអញខ្ញុំ ក៏អញខ្ញុំនឹងយកវាទៅនាព្រៃនោះ ថាបើវាមិនចង់ទៅសោត ក៏ឱ្យវានៅហោង រីនាងមទ្រីសោត ថាបើនាងពុំចង់ទៅទេ ក៏នឹងឱ្យនាងនៅនឹងអម្ចាស់ឯអាយ រក្សាកូនទាំងពីរហោង ។

តតោ រាជា បុត្តស្ស កថំ សុត្វា សុណ្ហំ យាចិតុំ បដិបជ្ជិ ព្ធដ៏កាលនោះ ព្រះបាទស្រីសញ្ជ័យ ជាព្រះវររាជបិតាទ្រង់បានព្រះសណ្ដាប់ស័ព្ទព្រះវាចារបស់ព្រះរាជបុត្រាដូច្នោះហើយទើបស្ដេចបែរទៅមានព្រះបន្ទូលលួងលោមសម្ដេចព្រះនាងមទ្រី ដ៏ជាព្រះរាជបុត្រីប្រសាវិញ ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណា ពុំទាន់ថែងច្បាស់ លុះព្រះអង្គបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលសូត្រសានូវព្រះគាថា ដូច្នេះ

តតោ សុណ្ហំ មហារាជា   យាចិតុំ បដិបជ្ជថ
មា ចន្ទនសមាចារេ   រជោជល្លំ អធារយិ ៗ
កាសិយានិ បធារេត្វា   កុសចីរមធារយិ
ទុក្ខោ វាសោ អរញ្ញស្មី   មា ហិ ត្វំ លក្ខណេ គមីតិ ៗ

ភិក្ខុអើយ រីព្រះបាទស្រីសញ្ជ័យ ដ៏ជាស្ដេចធំប្រសើរនោះ មានព្រះបន្ទូលនឹងសម្ដេចព្រះរាជមទ្រីថា ហៃមទ្រីដ៏មានលក្ខណាប្រសើរអើយ នាងសព្វថ្ងៃ ធ្លាប់លាបនូវសុគន្ធពិដោរលម្អិតខ្លឹមច័ន្ទន៍ក្រចេះម្សៅ ធ្លាប់ស្លៀកសំពត់ខោមពស្ត្រ កាសិកពស្ត្រ ម្ដេចឡើយ នាងនឹងទៅទ្រង់នីទៅនូវញើសក្អែល ហើយស្លៀកនីទៅនូវសំពត់សំបកឈើ គិតដ៏អ្នកក្រងមួយអន្លើនូវស្បូវក្លាំង នឹងជាទុក្ខស្រអ័ញស្រអុក ព្រោះសំពត់នៅនាព្រៃនោះ ដូចម្ដេចបានឡើយ ៗ

តមព្រវិ រាជបុត្តី   មទ្ទី សព្វង្គសោភណា
នាហន្តំ សុខមិច្ឆេយ្យំ   យំ មេ វេស្សន្តរំ វិនាតិ ៗ

ក្សិណនោះកូវ សម្ដេចព្រះរាជមទ្រី ដ៏ជាក្សត្រីប្រសើរ នាងក្រាបទូលស្នងព្រះរាជឱង្ការវិញថា បពិត្រក្សត្រថ្លៃប្រសើរអើយ រីស្រុកជេតុត្តរនគរនេះ គួរគប្បីអញខ្ញុំត្រេកអរចង់នៅនាឋានសុខនេះ តែអញខ្ញុំពុំប្រាថ្នាចង់នៅដល់តិចឡើយ បើព្រាត់ប្រាសព្រះ-

បាទស្រីវេស្សន្តរឱ្យទ្រង់ទៅនៅលំបាក តែមួយព្រះអង្គឯង ឯព្រៃនោះ ពុំសមគួរឡើយ ។

តមព្រវិ មហារាជា សិវីនំ រដ្ឋវឌ្ឍនោ
ឥង្ឃ មទ្ទិ និសាមេហិ វនេ យេ ហោន្តិ ទុស្សហា ។
ពហូ កីដា បដង្គា ច មកសា មធុមក្ខិកា
តេបិ តំ តត្ថ ហឹសេយ្យុំ តន្តេ ទុក្ខតរំ សិយា ។
អបរេ បស្ស សន្តាសេ នទីនូបនិសេវិតេ
សប្បា អជគរា នាម អវិសា តេ មហព្វលា ។
តេ មនុស្សំ មិគំ វាបិ អបិចាសន្នមាគតំ
បរិក្ខិបិត្វា ភោគេហិ វសមានេន្តិ អត្តនោ ។
អញ្ញេបិ កណ្ហា ជដិនោ អច្ឆា នាម អឃម្មិគា
ន តេហិ បុរិសោ ទិដ្ឋោ រុក្ខមារុយ្ហ មុច្ចតិ ។
សឃដ្ដយន្តា សិង្គានិ តិក្ខគ្គានិ បហារិនោ
មហិសា វិចរន្តេត្ថ នទី សោតុម្ពរំ បតិ ។
ទិស្វា មិគានំ យូថានំ គវំ សញ្ចរតំ វនេ
ធេនុវ វច្ឆគិទ្ធាវ កថំ មទ្ទិ ករិស្សសិ ។
ទិស្វា សម្បតិតេ ឃោរេ ទុមគ្គេសុ ប្លវង្គមេ
អក្ខេត្តញ្ញាយ តេ មទ្ទិ ភវិស្សតេ មហព្ភយំ ។
យា ត្វំ សិវាយ សុត្វាន មុហុំ ឧត្តសតេ បុរេ
សា ត្វំ វង្កំ អនុប្បត្តា កថំ មទ្ទិ ករិស្សសិ ។
ឋិតេ មជ្ឈន្តិកេ កាលេ សន្និសិន្នេសុ បក្ខិសុ

សុណាតេថ ព្រហាវរញ្ញំ តត្ត គី គន្តុមិច្ឆសីតិ ។

ព្ធដ៏ក្សិណានោះកូវ វីព្រះបាទស្រីសញ្ជ័យដ៏ជាស្តេចធំប្រសើរ មានព្រះបន្ទូលថា ហៃនាងមទ្រីអើយ អាពុកនឹងស្រដីប្រាប់មេ មេអើយ វីកំណើតព្រៃព្រះហេមពាន្តនោះ កម្រក្តាត់ ដ៏ពាស ពេញនីទៅនូវសត្វម្រឹគសឹងតែសាហាវច្រើន ទោះតាឱ ឱម៉ាល់ក្តី ទោះស្រាំង ឃ្មុំក្តី មេអើយ វីសត្វអស់នោះមកចោមរោម នៅ ជាច្រើន មានព្ធដ៏ព្រៃនោះហោង ។

មួយសោតវីសត្វឯទៀតក៏មានជាច្រើនមុខគួរឱ្យខ្លាចពន់ពេក វីពស់មួយនោះ លោកហៅថា ពស់ថ្លាន់ ដ៏មានកម្លាំងច្រើនក្តាត់ វាបានយល់មនុស្សក្តី សត្វអ្វី ៗ នីមួយក្តី ដែលចូលមកអាស្រ័យ នា ទឹកស្ទឹងមុចលិន្ទនទី កាលណាបើពស់នោះវាយល់ហើយ វាដេញ ដោយនូវកម្លាំងរបស់វា ទោះនឹងឡើងចុងឈើខ្ពស់អម្បាលម៉ាន ក្តី ក៏មិនរួចនឹងវាឡើយ កាលបើវាទាន់ហើយ វាព័ន្ធព័ទ្ធរឹត នឹងក្ធែនកន្ទុយ វានោះល្អិតឆ្អឹងអស់ ហើយវាលេបដោយនូវអំណាច វាហោង ។

មួយសោត មេអើយ វីសត្វមួយនោះ លោកហៅថា ខ្លាឃ្មុំ ដ៏មានរោមនោះខ្មៅគគ្រាត កាលណាបើវាយល់មនុស្សឯណា មួយដើរទៅហើយ ទោះបីរត់ឡើងដើមឈើខ្ពស់អម្បាលម៉ានក្តី ក៏មិនរួចនឹងវាឡើយ បើវាចាប់បានហើយ វាជញ្ជក់យកឈាម ស្ងួតក្រៀមទៅ ថាបើមេនឹងទៅនោះ លំបាកពេកហោង ។

មួយសោត រីក្របីព្រៃ ដ៏មានស្នែងនោះវែងស្រួចក្តាត់ កាលណា បើវាយល់មនុស្សហើយ វារត់ដេញវ័ធមុតមែនក្តាត់ ៗ ទោះបីពេលព្រឹកក្តី ល្ងាចក្តី វាតែងបណ្តើរកូនទៅត្រាំទឹកស្ទឹង បឹង សាគរនទីនោះ នៅត្រង់នាផ្លូវនឹងដើរទៅកាន់ព្រៃព្រះហេមពាន្ត ដ៏ជាឋានលំនៅលំបាកនោះហោង ៗ

មួយសោត មទ្រីអើយ រីទន្សោងគោព្រៃ កាលថ្ងៃរសៀលទន់ ៗ វាជល់គ្នាលេងដោយផ្លូវ វាស្រែករោទ៏ប្រដេញគ្នាទៅមក មុខគួរឱ្យខ្លាចពេក ៗ មួយសោត រីផ្លូវហ្វុងស្វាផងទាំងឡាយ វាយល់មនុស្សនៅនាព្រៃស្ងាត់ដូច្នោះ វានឹងមកចោមរោមសម្លឹម មុខគួរខ្លាច គួរស្ញើមពេក ៗ ហៃនាងមទ្រីអើយ នាព្រលប់នោះ សោត រីឯសត្វបក្សី គឺ មៀម ទីទុយ ខ្លែងស្រាក ចចក លលកខ្មោច ទោច ឪឡ ភូវាំង ស្ទាំង គូក វានឹងហើរមកទំស្រែកយំ នៅនាដើមឈើក្បែរខាងលំនៅនោះ មុខគួរស្ញើមពេកហោង ៗ

ហៃនាងមទ្រី ជាក្សត្រីប្រសើរអើយ នាភ័យទាំងអម្បាលណោះ ហេតុតែនាងមិនដែលឮ មិនដែលឃើញមិញ ថាបើ នាងបានឮ បានឃើញហើយ ក៏នាងនឹងស្ញើមព្រឺប្រុងសម្រុង សរិលអស់ទាំងខ្លួន នាងនឹងយំបម្រះអន្ទះអន្ទែង គ្រាំញែងឯង លំបាកពន់ពេក ម្រាងឡើយ នាងនឹងទៅនៅនាភ្នំគិរីវង្កតបព៌ត នោះបាន ចូរនាងនៅអោយជាមួយនឹងមេក្មេក បាក្មេកនេះហោង ៗ

តមព្រវិ រាជបុត្តី មទ្ទី សព្វង្គសោភណា

យានិ ឯតានិ អក្ខាសិ　　វនេ បដិភយានិ មេ
សព្វានិ អភិសម្ភោស្សំ　　គច្ឆញ្ញេវ រថេសភ ។
កាសំ កុសំ បោតកិលំ　　ឧសិរំ មុញ្ជបព្វជំ
ឧរសា បនូទហេស្សាមិ　　នាស្សហេស្សាមិ ទុន្នយា ។
ពហូហិ វត្តចរិយាហិ　　កុមារី វិន្ទតេ បតី
ឧទរស្សុបរោធេន　　គោហនុវេដ្ឋនេន ច
អគ្គិស្ស បារិចរិយាយ　　ឧទកុម្មុជ្ជនេន ច
វេធព្យំ កដុកំ លោកេ　　គច្ឆញ្ញេវ រថេសភ ។
អបិស្សា ហោតិ អប្បត្តោ　　ឧច្ឆិដ្ឋំ បរិភុញ្ជិតុំ
យោ នំ ហត្ថេ គហេត្វាន　　អកាមំ បរិកឌ្ឍតិ
វេធព្យំ កដុកំ លោកេ　　គច្ឆញ្ញេវ រថេសភ ។
កេសគ្គហណមុក្ខេបា　　ភូម្យា ច បរិសុម្ភនា
ទត្វា ច នោ បក្កមតិ　　ពហុំ ទុក្ខំ អនប្បកំ
វេធព្យំ កដុកំ លោកេ　　គច្ឆញ្ញេវ រថេសភ ។
សុក្កច្ឆវី វេធវេរា　　ទត្វា សុភគ្គមានិនោ
អកាមំ បរិកឌ្ឍន្តិ　　ឧលូកញ្ញេវ វាយសា
វេធព្យំ កដុកំ លោកេ　　គច្ឆញ្ញេវ រថេសភ ។
អបិ ញាតិកុលេ ផីតេ　　កំសបជ្ជោតនេ វសំ
នេវាតិវាក្យំ ន លភេ　　ភាតូហិ សខិនីហិ ច
វេធព្យំ កដុកំ លោកេ　　គច្ឆញ្ញេវ រថេសភ ។
នគ្គា នទី អនូទកា　　នគ្គំ រដ្ឋំ អរាជិកំ

ឥត្ថីបិ វិធវា នគ្គា   យស្សាបិ ទស ភាតរោ
វេធព្យំ កដុកំ លោកេ   គច្ឆញ្ញេវ រថេសភ ។
ធជោ រថស្ស បញ្ញាណំ   ធូមោ បញ្ញាណមគ្គិនោ
រាជា រដ្ឋស្ស បញ្ញាណំ   ភត្តា បញ្ញាណមិត្ថិយា
វេធព្យំ កដុកំ លោកេ   គច្ឆញ្ញេវ រថេសភ ។
យា ទលិទ្ទី ទលិទ្ទស្ស   អឌ្ឍា អឌ្ឍស្ស កិត្តិមា
តំ វេ ទេវា បសំសន្តិ   ទុក្ករំ ហិ ករោតិ សា ។
សាមិកំ អនុពន្ធិស្សំ   សទា កាសាយវាសិនី
បថព្យាបិ អភិជ្ជន្ត្យា   វេធព្យំ កដុកិត្ថិយា ។
អបិ សាគរបរិយន្ត   បហុវិត្តធរំ មហឹ
នានារតនបរិបូរំ   និច្ឆេ វេស្សន្តរំ វិនា ។
កថន្នុ តាសំ ហទយំ   សុខរា វត ឥត្ថិយោ
យា សាមិកេ ទុក្ខិតម្ហិ   សុខមិច្ឆន្តិ អត្តនោ ។
និក្ខមន្តេ មហារាជេ   សិវីនំ រដ្ឋវឌ្ឍនេ
តមហំ អនុពន្ធិស្សំ   សព្វកាមទទោ ហិ មេតិ ។

ក្សិណនោះកូវ សម្តេចព្រះរាជមទ្រីរាជបុត្រីស្រីវ័ត្ត ដ៏ប្រកបនូវលក្ខណាដ៏ប្រសើរ ព្រះនាងលើកព្រះហស្តប្រណម្យ ក្រាបទូលថា បពិត្រព្រះមហាក្សត្រាធិរាជប្រសើរអើយ ព្រះអង្គ តែងទ្រង់ចម្រើនអ្នកស្រីពិរាស្ត្រ ទ្រង់មានព្រះបន្ទូលនោះ ពីរោះក្តាត់ ៗ បពិត្រអម្ចាស់អើយ វីត្រង់ទុក្ខភ័យនោះ អញខ្ញុំនឹងអធ្យោគ ទៅនឹងប្តីអញខ្ញុំ ៗ នឹងចងក្សិនឱ្យខ្ជាប់ ហើយអញខ្ញុំនឹងដើរទៅមុន

ព្រះបាទស្រីវេស្សន្តរ នឹងពារបញ្ជាន់បែនកិនទៅ ទោះទាំងព្រៃបបុស ត្រែង អំពៅព្រៃក្តី ស្មៅសសិត ស្បូវភ្លាំង ស្បូវណ្ដាស ស្មៅដំណេកទន្សាយក្តី ស្មៅយាប្លងក្តី ក៏អញខ្ញុំនឹងទន្ទ្រានច្រានពានទៅមុន មិនឱ្យដិតត្រូវព្រះបាទាព្រះបាទស្រីវេស្សន្តរព្រះស្វាមី អញខ្ញុំជាព្រះរាជបុត្រព្រះអង្គនេះឡើយ ។ បពិត្រអម្ចាស់អើយ អ្វីកម្រនៅនាព្រៃនោះ ក៏អញខ្ញុំមិនឱ្យព្រះអង្គព្រួយ លំបាកឡើយ រីក្តីលំបាកមាននៅត្រង់ណា ក៏អញខ្ញុំធានាត្រង់ណោះ មិនឱ្យព្រះរាជបុត្រអម្ចាស់លំបាកតែមួយព្រះអង្គឯងឡើយ ។

- បពិត្រព្រះមហាក្សត្រថ្លៃប្រសើរអើយ អញខ្ញុំម្ចាស់នេះ មានឧបមាបីដូចក្រមុំផងទាំងឡាយ នៅសព្វថ្ងៃនេះ សង្វាតចង់បានប្ដីឱ្យជាទីគាប់ចិត្តនោះ អញខ្ញុំអម្ចាស់ងោះឡើងអំពីព្រឹក ហើយបបួលគ្នាទៅកាច់ស្ទន់មកទន់ ហើយអង្គុយនៅមាត់ទឹក ហើយស្រដី ① អំភ្លាងគាងទៅគាងមក ដូចកល់ស្នែងគោ ហើយចុះងូតទឹកជម្រះខ្លួន រួចទៅផ្ទះ យកប្រេងម្សៅលាបហើយ ហូបបាយពុំឱ្យឆ្អែតពេក ខ្លាចក្រែងវាធាត់រលកន្ទ្រល មិនគួរស្រឡាញ់ ។ អម្ចាស់អើយ ធ្វើទាំងអម្បាលណោះនែ ទើបបានប្ដីជាទីគាប់ចិត្ត ក៏ឥឡូវនេះ អញខ្ញុំបានប្ដីជាទីគាប់ចិត្តដូចប្រាថ្នាហើយ ម្ដេចឡើយ ក៏អញខ្ញុំនឹងនៅជាមេម៉ាយ ។

១- ច្បាប់ខ្លះថា " ហើយនីស្លាស្រដីអំភ្លាង " ។

អម្ចាស់អើយ ត្រង់ស្រី(១) មេម៉ាយនោះ ប្រុសទាំងឡាយ គេមើលងាយ នាលោកកិយនេះពេកក្តាត់ ៗ បទអ្វីអញខ្ញុំពោល ថាដូច្នេះ អម្ចាស់អើយ រីស្រីមេម៉ាយផងទាំងឡាយ សព្វថ្ងៃនេះ ទោះបីដើរទៅទីឯណានីមួយក្តី ទោះអង្គុយនៅក្តី ទោះជួនជាហូបបាយក្តី ធ្វើការក្តី ក៏ប្រុសឯណាមួយបានយល់ជាទីគាប់ចិត្តវាហើយ វានឹងមើលងាយតាមចំណង់ចិត្តវា ហើយវានឹងមកចាប់ដៃទង់ទៅ បើពុំទៅដោយចិត្តវាហើយ ក៏វានឹងចាប់សក់ គក់ត្បកកើចទង់ទៅឱ្យតែបាន មានឧបមាបីដូចអ្វី ថាឧបមាបីដូចកូនក្អែក ចឹកកូនមេម្យម(២) ទង់ចេញអំពីសំបុកនោះឯង ៗ បពិត្រអម្ចាស់អើយ ហេតុនេះ អញខ្ញុំមិននៅជាស្រីមេម៉ាយនេះឡើយ អញខ្ញុំនឹងទៅតាមព្រះបាទស្រីវេស្សន្តរជាប្តីអញខ្ញុំហោងៗ

បពិត្រក្សត្រថ្លៃប្រសើរអើយ រីស្រីមេម៉ាយនេះ ទោះបីមានរូបឆោមអម្បាលម៉ានក្តី ទោះលាបប្រេងម្សៅក្រចេះចួងច័ន្ទន៍ មានគន្ធពិដោរក្តី ទោះមានគ្រឿងមាសគ្រឿងប្រាក់ក្តី ទោះនៅ

១- ច្បាប់ខ្លះថា រីត្រង់ហៅស្រីមេម៉ាយនេះ ជាចំណាយមាត់គេ ទោះនឹងដើរក្តី នឹងអង្គុយក្តី នឹងហូបបាយក្តី នឹងដេកក្តីនោះ ប្រុសពាលកំឡោះវារមែងតែងនឹងមើលងាយ ដោយនូវចំណង់ចិត្តវាហោង ៗ ២- ច្បាប់ខ្លះថា " ចឹកកូនមាន់ " ៗ

ក្នុងត្រកូលស្តេចក្តី គេយល់ថា ឥតប្តីហើយ គេនឹងថា ជាស្រីមេម៉ាយដែលហោង (១) ។ បពិត្រអម្ចាស់អើយ ហេតុតែដំណើរដូច្នេះឯង ក៏អញខ្ញុំនឹងសង្វាតទៅតាមព្រះវេស្សន្តរ ជាម្ចាស់លើត្បូងនៃអញខ្ញុំ ។

បពិត្រអម្ចាស់អើយ **នទី** រីស្ទឹងឯណា **អនូទកា** គឺឥតទឹកឡើយ **នគ្គា** ហៅថា ស្ទឹងទទេ ។ **រដ្ឋំ** រីនគរមណ្ឌលរាស្ត្ររដ្ឋផងទាំងឡាយ **អរាជិកំ** ថាបើឥតស្តេចគង់ហើយ **នគ្គំ** ហៅថា ស្រុកទទេ ពុំហៅនគរប្រសើរឡើយ ។ **អបិ** មួយនីសោត **យា ឥត្ថី** រីស្រីឯណា **វិធវា** បើឥតនឹងប្តីហៅថា ស្រីមេម៉ាយហោង ។ **រថេសភ** បពិត្រអម្ចាស់អើយ **វេធព្យំ** រីភាពជាស្រីមេម៉ាយនេះ **កដុកំ** មុខគួរឱ្យជាទុក្ខពេក (២) **លោកេ** ឰដ៏លោកនេះ ។ **តេន** ហេតុនោះហោង **អហំ** រីអញខ្ញុំ **គច្ឆញ្ញេវ** នឹងទៅតាមព្រះបាទស្រីវេស្សន្តរដ៏ជាព្រះរាជស្វាមីនៃអញខ្ញុំ ជាប្រាកដហោង ។

បពិត្រមហារាជដ៏ជាក្សត្រធំ ឧត្តមប្រសើរអើយ រីរាជរថដ៏ប្រដាប់នីទៅនូវទង់ចង្ក្រង់នាគកណ្តឹងនោះនែ ទើបប្រាកដហៅថា រាជរថ ។ រីភ្លើងសោត បើមានផ្សែងឡើងនោះនែ ទើបប្រាកដហៅថា ជាភ្លើង ដូចស្រុកនគរសោត ថាបើមានស្តេច

១- ច្បាប់ខ្លះថា " គេថាជាស្រីមេម៉ាយ គង់តែចំណាយមាត់គេដដែលហោង "។

២- អដ្ឋកថាជាតកថា " កដុកន្តិ អសាតំ " ប្រែថា ឥតត្រេកអរ ឥតសប្បាយ ។

សោយរាជ្យស្កល់នៅនោះនៃ ទើបហៅថា ជាស្រុកប្រសើរនគរប្រសើរ ៗ រីឯស្រី សព្វថ្ងៃនេះ ថាបើមានប្ដីនោះនៃ ទើបហៅថា ជាស្រីប្រសើរ ថាបើឥតប្ដីហើយ គេក៏ហៅជាស្រីមេម៉ាយហោង ៗ ហេតុនោះ បពិត្រអម្ចាស់អើយ ធម្មតាស្រីមេម៉ាយនេះ ជាចំណាយមាត់អ្នកផងក្ដាត់ហោង រីស្រីព្ធដ៏លោកិយ សព្វថ្ងៃនេះ បើប្ដីខ្សត់ហើយ ប្រពន្ធនោះក៏ខ្សត់ផង ៗ បើប្ដីមានយសស័ក្ដិហើយ ស្រីនោះក៏នៅនឹងយសស័ក្ដិសម្បត្តិប្ដីនោះ ៗ បពិត្រអម្ចាស់អើយ បើស្រីឯណា ឧស្សាហ៍អធ្យោគបម្រើប្ដី នាលោកិយនេះ ក៏ប្រសើរឥតហ្មង លុះដល់អនាគតកាលទៅឯភ្នែកសោត តែងនឹងបានសម្បត្តិសួគ៌ រួចដល់និព្វាននោះទៀងប្រាកដហោង ៗ បពិត្រក្សត្រថ្លៃប្រសើរអើយ ហេតុនេះហោង អញខ្ញុំនឹងទៅស្លៀកសំពត់សំបកឈើ គិតដ៏អ្នកក្រងនីទៅនូវស្បូវក្លាំង ហើយនឹងស្ពាយឆៀងនូវស្បែកខ្លា ឥតក្រយាស្ងោយក្ដី ក៏អញខ្ញុំ សង្វាតទៅតាមព្រះបាទស្រីវេស្សន្តរ ជាព្រះរាជស្វាមីអញខ្ញុំ ៗ អម្ចាស់អើយ អញខ្ញុំបានព្រះបាទស្រីវេស្សន្តរជាព្រះរាជស្វាមី ព្ធដ៏លោកិយនេះ មិនឱ្យអ្នកឯណាមួយមកដៀលថា ជាស្រីមេម៉ាយបានឡើយ ហេតុនេះ អញខ្ញុំនឹងទៅតាមព្រះបាទស្រីវេស្សន្តរជាព្រះរាជស្វាមីសំឡាញ់នៃអញខ្ញុំហោង ៗ

បពិត្រអម្ចាស់អើយ រីសម្បត្តិឯណា មានព្ធដ៏ជេតុត្តរនគរពេញនីទៅនូវរ័ត្នទាំង ៧ ក្ដី ទោះទ្រព្យឯណាផ្សេងៗក្ដី នោះ

អញខ្ញុំនឹងស្រឡាញ់អាល័យសម្បត្តិនោះ ឥតអង្គីមានឡើយ បើព្រាត់ប្រាសព្រះបាទស្រីវេស្សន្តរចេញទៅនោះ វាក្តៅផ្សាជាទុក្ខនៅតែម្នាក់ឯង ៗ បពិត្រអម្ចាស់អើយ រីព្រះបាទស្រីវេស្សន្តរអ្នកចេញទៅអំពីស្រុកនេះ នាកាលថ្ងៃឯណាមិញ ក៏អញខ្ញុំនឹងចងក្បិនឱ្យខ្ជាប់ ហើយអញខ្ញុំនឹងពកូនទាំងពីរទៅតាមព្រះបាទស្រីវេស្សន្តរ ជាព្រះរាជស្វាមីអញខ្ញុំ នាថ្ងៃនោះហោង ៗ

តមព្រវិ មហារាជា មទ្ទី សព្វង្គសោភណាំ
ឥមេ តេ ទហរា បុត្តា ជាលី កណ្ហាជិនា ចុភោ
និក្ខិប្ប លក្ខណេ គច្ឆ មយន្តេ បោសយាមសេតិ ៗ

ហៃសប្បុរសផងទាំងឡាយអើយ រីព្រះបាទស្រីសញ្ជ័យដ៏ជាស្តេចធំប្រសើរនោះ ទ្រង់ស្រដីលួងលោមសម្តេចព្រះរាជមទ្រី ក៏ព្រះនាងពុំព្រមនៅឡើយ ទើបស្តេចមានព្រះបន្ទូលវិញទៀតថា ហៃនាងមទ្រីអើយ បើនាងពុំយកពាក្យឪពុកហើយ នាងនឹងទៅតាមបាវេស្សន្តរ ក៏តាមតែចំណង់ចិត្តនាងចុះ រីកូនទាំងពីរគឺចៅជាលីនិងមេក្រស្នា ចូរនាងទុកនៅអាយ យើងជាម្តាយឪពុក នឹងចិញ្ចឹមរក្សាហោង ៗ

តមព្រវិ រាជបុត្តី មទ្ទី សព្វង្គសោភណា
បិយា មេ បុត្តកា ទេវ ជាលី កណ្ហាជិនា ចុភោ
ត្យម្ហំ តត្ថ រមិស្សន្តិ អរញ្ញេ ជីវិសោកិនន្តិ ៗ

រីសម្តេចព្រះរាជមទ្រី ដ៏ជាព្រះរាជបុត្រីស្រីរ័តន៏ ដ៏មាន

លក្ខណាប្រសើរនោះ ព្រះនាងស្តាប់ព្រះបន្ទូលហើយក្រាបទូលថា បពិត្រព្រះសម្មតិទេពក្សត្រថ្លៃប្រសើរអើយ រីកូនទាំងពីរចៅជាលី និងមេក្រស្នា នេះមិញ មិនមែនជាកូនសម្អប់ អញខ្ញុំមិនព្រមឱ្យប្រាសចេញអំពីទ្រូងអញខ្ញុំអម្ចាស់ឡើយ ។ ហេតុនេះ អញខ្ញុំចិញ្ចឹមជីវិតរស់នៅដោយប្រការដូចម្តេចមិញ នាងអញខ្ញុំនឹងរកចិញ្ចឹមកូនអញខ្ញុំទាំងពីរ ឱ្យមានជីវិតរស់នៅ ដោយប្រការដូច្នោះហោង ។

តមព្រវិ មហារាជា សិវីនំ រដ្ឋវឌ្ឍនោ
សាលីនមោទនំ ភុត្វា សុចិមំសូបសេចនំ
រុក្ខផលានិ ភុញ្ជន្តា កថំ កាហន្តិ ទារកា ។
ភុត្វា សតបលេ កំសេ សោវណ្ណេ សតរាជិកេ
រុក្ខបត្តេសុ ភុញ្ជន្តា កថំ កាហន្តិ ទារកា ។
កាសិយានិ ធារេត្វា ខោមកោទុម្ពរានិ ច
កុសចីរានិ ធារេន្តា កថំ កាហន្តិ ទារកា ។
វយ្ហាហិ បរិយាយិត្វា សិវិកាយ រថេន ច
បត្តិកា បរិធាវន្តា កថំ កាហន្តិ ទារកា ។
កូដាគារេ សយិត្វាន និវាតេ ផុស្សិតគ្គឡេ
សយន្តា រុក្ខមូលស្មឹ កថំ កាហន្តិ ទារកា ។
បល្លង្កេសុ សយិត្វាន គោនកេ ចិត្រសន្ថតេ
សយន្តា តិណសន្ថរេ កថំ កាហន្តិ ទារកា ។

គន្ធកេន វិលិម្បិត្វា អគ្គលុចន្ទនេន ច
រជោជល្លានិ ធារេន្តា កថំ កាហន្តិ ទារកា ៗ
ចាមរីមោរហត្ថេហិ វិជិតង្គា សុខេ ឋិតា
ផុដ្ឋា ឌំសេហិ មកសេហិ កថំ កាហន្តិ ទារកាតិ ៗ

កាលនោះ ព្រះបាទស្រីសញ្ជ័យមានព្រះបន្ទូលវិញទៀត ថា ហៃនាងមទ្រីអើយ រីក្មេងទាំងពីរនេះ ធ្លាប់បរិភោគនូវភោជ្ជសាលីសល្អបរិសុទ្ធ ដ៏ប្រដាប់នីទៅនូវត្រីសាច់ ញាំ ភ្លា សាកប់ផង តម្កល់ទុកលើភាជន៍មាស គិតដ៏អ្នកគួរកាច់ រចនានូវក្បាច់មួយរយជាន់ ទើបក្មេងទាំងពីរនេះបរិភោគបាន ឥឡូវនេះ នឹងនាំទៅឱ្យបរិភោគនូវផ្លែឈើមើមឈើដាក់លើដី នាព្រៃនោះ ធ្វើម្ដេចក្មេងទាំងពីរនឹងបរិភោគបាន ៗ មួយសោត ក្មេងទាំងពីរធ្លាប់ទ្រទ្រង់នូវសំពត់ខោមពស្ត្រ កោទុម្ពរពស្ត្រ ធ្លាប់ជិះគ្រែស្នែង រមែងជិះរាជរថពាជីដ៏រីប្រសើរ ឥឡូវនេះ មេនឹងនាំក្មេងទាំងពីរទៅតែជើងទទេ ហើយឱ្យស្លៀកសំពត់សំបកឈើ គិតដ៏អ្នកច្រៀកក្រងនីទៅនូវស្បូវភ្លាំង ហើយស្ពាយឆៀងស្បែកខ្លា ទាំងក្រចក បរិភោគនូវផ្លែឈើស្លឹកឈើ នៅនាព្រៃនោះ ដូចម្ដេចបាន មួយសោត មទ្រីអើយ រីក្មេងទាំងពីរនេះ ធ្លាប់ដេកក្នុងព្រះរាជមន្ទីរ ដ៏ប្រដាប់នីទៅនូវគ្រែទៃនកែវ ដ៏ត្រកាល ពាសពេញនីទៅនូវចៀមចំ ព្រៃព្រំ រនាំង វាំងននពុំលេចខ្យល់ ទើបក្មេងទាំងពីរដេកលក់ស្រណុកសុខសប្បាយ ៗ មួយសោត រីក្មេងទាំងពីរនេះ

ធ្លាប់តែងមែងលាបស្រឡាបនីទៅនូវប្រេងម្សៅក្រចេះលម្អិតខ្លឹមច័ន្ទន៍ក្រស្នា ក្លាំពាក់ ធ្លាប់ឱ្យបក់នីទៅនូវផ្លិតចាមរ ព្រុយក្ងោក ទើបដេកលក់ស្រណុកសុខសប្បាយ ៗ មទ្រីអើយ ឥឡូវនេះ នាងនឹងនាំក្មេងទាំងពីរនេះទៅប្រឡាក់នូវផង់ធូលីដីខ្សាច់ ញើសក្អែល ហើយឱ្យដេកលើកម្រាលស្លឹកឈើលើដី នៅនាព្រៃនោះ ត្រូវខ្យល់ភ្លៀងផង ធ្វើម្តេចឡើយ នឹងដេកនៅស្រណុក សមនឹងយំជាទុក្ខក្រៃពេក ឰដ៏ព្រៃនោះហោង ៗ

ឯវំ តេសំ សល្លបន្តានញ្ញេវ រត្តិ វិភាយិ សុរិយោ ឧគ្គច្ឆតិ រីក្សត្រទាំងបីព្រះអង្គ ស្រដីផងគ្នានូវប្រការអម្បាលនោះហើយកូវ ព្រះអាទិត្យក៏រះឡើង ក្សិណនោះ អាមាត្យនាយរាជរថ ប្រដាប់ទឹមនូវសេះអាជានេយ្យទាំង ៤ បរទៅដាក់ នៅទ្វារព្រះរាជវាំងព្រះមហាសត្វ ៗ ក្សិណនោះកូវ សម្តេចព្រះរាជមទ្រី ក្រាបថ្វាយបង្គំលា មេក្មេក បាក្មេកហើយ ស្រដីផ្តាំអស់ស្រីព្រះស្នំទាំងអម្បាលនោះហើយ ទើបព្រះនាងពយកព្រះរាជបុត្រទាំងពីរ ឡើងទៅគង់លើព្រះរាជរថនោះ មុនព្រះមហាក្សត្រ ជាព្រះរាជស្វាមីហោង ៗ

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះបរមសាស្តា ទ្រង់មានព្រះបន្ទូលសូត្រសានូវគាថាដូច្នេះ

តមព្រវិ រាជបុត្តី   មទ្ទី សព្វង្គសោភណា
មា ទេវ បរិទេវេសិ   មា ច ត្វំ វិមនោ អហុ
យថា មយំ ភវិស្សាម   តថា ហេស្សន្តិ ទារកា ។
ឥទំ វត្វាន បក្កាមិ   មទ្ទី សព្វង្គសោភណា
សិវិមគ្គេន អន្វេសិ   បុត្តេ អាទាយ លក្ខណាតិ។

ភិក្ខុអើយ ឰដ៏កាលនោះ សម្តេចព្រះរាជមទ្រី ជាព្រះរាជបុត្រីស្រីរ័តន៍ប្រសើរ ព្រះនាងក្រាបទូលព្រះបាទស្រីសញ្ជ័យ ជាបាក្មេក ដូច្នេះថា បពិត្រក្សត្រថ្លៃប្រសើរអើយ កុំអម្ចាស់គិតអាណិតខ្សឹកខ្សួលរំជួលក្នុងព្រះរាជហឫទ័យ នឹងព្រះចៅអម្ចាស់ទាំងពីរនេះឡើយ រីយើងខ្ញុំទាំងពីរនឹងទៅចិញ្ចឹមជីវិតរស់នៅ ដូចម្តេចមិញ ក៏ចៅអម្ចាស់ទាំងពីរ រស់នៅដូច្នោះហោង ។

តតោ វេស្សន្តរោ រាជា   ទានំ ទត្វាន ខត្តិយោ
បិតុមាតុញ្ច វន្ទិត្វា   កត្វា ច នំ បទក្ខិណំ ។
ចតុវាហឹ រថំ យុត្តំ   សីឃមារុយ្ហ សន្ទនំ
អាទាយ បុត្តទារញ្ច   វង្កំ បាយាសិ បព្វតន្តិ ។

ឰដ៏ក្សិណនោះ ព្រះបាទស្រីវេស្សន្តរ ក្រាបថ្វាយបង្គំលាព្រះវរមាតាបិតាហើយ ស្តេចដោះឡើងប្រទក្សិណ ៣ ជុំ ហើយឡើងទៅគង់លើរាជរថទឹមនីទៅនូវសេះអាជានេយ្យទាំង ៤ បរនាំព្រះរាជបុត្រព្រះរាជទេពីទៅដោយនូវផ្លូវទៅកាន់ភ្នំគិរីវង្កតបព៌ត តាមពាក្យអ្នកស្រីពិរាស្ត្រ គេបណ្តោញនោះហោង ។

តតោ វេស្សន្តរោ រាជា   យេនាសិ ពហុកោ ជនោ
អាមន្ត ខោ តំ គច្ឆាម   អរោគា ហោន្តុ ញាតយោតិ ។

ឮដ៏ក្សិណនោះ ព្រះបាទស្រីវេស្សន្តរទ្រង់ទតយល់ទីណាមានមហាជនជំនុំគ្នាច្រើន ស្ដេចក៏បររាជរថទៅកាន់ទីនោះទ្រង់មានព្រះបន្ទូលលាថា ម្នាលញាតិទាំងឡាយអើយ សូមឱ្យអ្នកទាំងឡាយ កុំបីមានរោគាព្យាធិបៀតបៀនយាយី សូមឱ្យបានក្ដីសុខសប្បាយរាល់ៗ គ្នាទៅហោង ។

គច្ឆន្តេ ពោធិសត្តស្ស មាតា បុត្តោ (មេ) ទានចិត្តកោ ទានំ ទេតូតិ អាភរណេហិ សទ្ធឹ សត្តរតនបូរានិ សកដានិ ឧភោសុ បស្សេសុ បេសេសិ កាលបើព្រះពោធិសត្វ ទ្រង់បររាជរថឆ្ពោះទៅរកព្រះនាងសុបារសុប្បតី ដ៏ជាព្រះមាតាព្រះពោធិសត្វនោះ ព្រះនាងមានព្រះបន្ទូល នឹងអាមាត្យថា ម្នាលអាមាត្យអើយ រីកូនអញនេះជាអ្នកស្រឡាញ់ទាននោះច្រើន ចូរអ្នកយកផ្ដឹមអម្ពរស្បៃគ្រឿងប្រដាប់ នូវរ័ត្នទាំង ៧ ប្រការ ទៅបំពេញកំឡុងក្នុងរាជរថ ឱ្យពាសពេញកំពុងទាំងសងខាងរាជរថ (១) កុំបីឱ្យខ្វះឡើយ ។

រីព្រះបាទស្រីវេស្សន្តរ ដ៏ជាក្សត្រប្រសើរនោះ បររាជរថទៅយល់អស់មហាជនផងទាំងឡាយជំនុំជុំគ្នា ត្រង់ឋានឯណាច្រើនមិញ ក៏ព្រះអង្គបររាជរថ តម្រង់ទៅឋាននោះហោង ។ ព្រះអង្គ

១- ច្បាប់ខ្លះថា ឱ្យពេញសាយពាសទ្រពងទាំងសងខាងនោះហោង ។

ព្រះរាជទានគ្រឿងប្រដាប់ទៅជាទានដល់មហាជនផងទាំងឡាយ ហើយព្រះអង្គឱ្យដំបូន្មានថា ហៃញាតិផងទាំងឡាយអើយ អ្នកនៅឯក្រោយ ចូរឱ្យស្រណុកសុខសប្បាយ កុំបីមានជំងឺតម្កាត់ឡើយ ហៃអស់ញាតិផងទាំងឡាយអើយ ចូរអ្នកទាំងឡាយកាន់សីលឱ្យទាន កុំបីធ្វេសប្រហែសឡើយ ព្រះពោធិសត្វ មានព្រះបន្ទូលដូច្នេះហើយ ទើបស្តេចបររាជរថចេញអំពីព្រះនគរទៅ ព្រះពោធិសត្វមហាបុរសរ័ត្នវិសេសប្រសើរ ស្តេចឱ្យទានរៀងទៅដោយនូវផ្លូវនោះឯង ជាគម្រប់ ១៨ ដង ដរាបលុះអស់ឥតអ្វីជាសំណល់ឡើយ ។ ក្សិណនោះ ព្រះពោធិសត្វស្តេចបង្វិលរាជរថចេញអំពីព្រះនគរ ហើយបែរព្រះនេត្រទតមកកាន់ព្រះនគរវិញ ។ ក្សិណនោះ មហាប្រឹថពីឯង ក៏សព្វៀកប្រេះបែកជា៧ភាគទំហំប៉ុនកង់រាជរថ មានត្រង់នាឋានព្រះមហាក្សត្រស្តេចបង្វិលរាជរថនោះឯង ។

តេន វុត្តំ ហេតុនោះហោង ព្រះអង្គបានត្រាស់ប្រាជ្ញាសព៌ជ្ញុតាញាណ មានព្រះបន្ទូលសូត្រសានូវព្រះគាថា នឹងព្រះសារីបុត្តត្ថេរ ថា

និក្ខមិត្វាន នគរា　　និវត្តិត្វា វិលោកិតេ
តទាបិ បថវី កម្បិ　　សិនេរុវនវដំសកាតិ ។

ហៃសារីបុត្តត្ថេរអើយ នាកាលអញតថាគត នៅជាព្រះវេស្សន្តរនោះ ស្តេចបង្វិលរាជរថ ចេញអំពីជេតុត្តរនគរនោះហើយ

ទ្រង់រមិលមើលទៅកាន់ពិភពព្រះវរមាតាបិតា កាលឯណាមិញ ក៏អស្ចារ្យកើតមាន នាគ្រានោះមហិមាប្រាកដ រីមហាប្រឹថពីមានកម្រាស់នោះពីរសែន អធិកនីទៅនូវ ៤ ម៉ឺនយោជន៍ សឹងកក្រើកញាប់ញ័រ រីភ្នំព្រះសិនេរុរាជនោះមានកម្ពស់ ៨ ម៉ឺន ៤ ពាន់យោជន៍ក្តី ភ្នំហេមពាន្តក្តី ភ្នំសត្តបរិភណ្ឌក្តី សឹងដ៏មានកំពូលឱនលំទោនទន់ល្មន់ល្មាស ទៅកាន់ជេតុត្តរនគរនោះហោង ៗ

សោ បន សយំ ឱលោកេត្វា មទ្ទឹបិ ឱលោកាបេតុំ គាថមាហ ឮដ៏កាលនោះ ព្រះមហាក្សត្រ ទ្រង់រមិលមើលអាត្មាព្រះអង្គឯងហើយ ទើបស្តេចទតមើលទៅព្រះនាងមទ្រីយល់ត្រមោចម្នាក់ឯង ឥតមានអ្នកឯណាមួយជាគ្នាឡើយកូវ ទើបស្តេចមានព្រះបន្ទូលនឹងព្រះនាងមទ្រី ជាបាទគាថាដូច្នេះ

ឥង្ឃ មទ្ទិ និសាមេហិ　　រម្មរូបំច(១) ទិស្សតិ
អាវាសោ សិវិសេដ្ឋស្ស　　បេត្តិកំ ភវនំ មមន្តិ ៗ

ហៃនាងមទ្រីអើយ ចូរនាងពិតពិលរមិលមើលទៅឯពិភពលំនៅព្រះវរមាតាបិតានៃយើង នូវអ្នកស្រីពិរាស្ត្រផងទាំងឡាយ យល់ល្អប្រសើរក្រៃពេកហោង ៗ ឮដ៏កាលនោះ ព្រះមហាក្សត្រ កាលស្តេចបររាជរថអំពីនោះទៅហើយ ស្តេចមានបន្ទូលទៅនឹងអាមាត្យទាំង ៦ ម៉ឺន អម្បាលដែលកើតថ្ងៃជាមួយនឹងព្រះអង្គនោះ ទើបស្តេចមានព្រះបន្ទូលនឹងមហាជនផង នាថ្ងៃដែលហៃ

១- ច្បាប់ខ្លះថា រម្មរូបំវ ទិស្សតិ ៗ

ជូនព្រះអង្គ ស្ដេចបររាជរថអំពីនោះទៅបន្តិចកូវ ក៏ស្ដេចមានព្រះបន្ទូលនឹងនាងមទ្រី ថាដូច្នេះ

ភទ្ទេ សចេ បច្ឆតោ យាចកា អាគច្ឆន្តិ ឧបធារេយ្យាសីតិ ថាហៃនាងមទ្រីអើយ នាងជិះរាជរថបែរមុខទៅឯក្រោយ មើលឱ្យដឹង ក្រែងមានស្មូមតាមមកសូមយើងហោង ។

អថស្ស សត្តសតកមហាទានំ សម្បាបុណិតុំ អសក្កោន្តា ចត្តារោ ព្រាហ្មណា នគរំ គន្ត្វា កុហឹ រាជាតិ បុច្ឆិត្វា... អស្សេ នំ យាចិស្សាមាតិ អនុពន្ធឹសុ ព្ធដ៏កាលនោះ មានព្រាហ្មណ៍៤នាក់ ពុំទាន់បានទទួលសត្តសតកមហាទាន អំពីព្រះមហាក្សត្រនៅឡើយ ព្រាហ្មណ៍ទាំង ៤ នាក់នោះ ក៏ដើរចូលទៅក្នុងកម្លុងព្រះនគរនោះ ហើយដណ្ដឹងសួរអស់មហាជនផងទាំងឡាយ ថា ហៃអ្នកទាំងឡាយអើយ រីព្រះបាទស្រីវេស្សន្តរ ស្ដេចទៅកាន់ឋានឯណាបាត់ហើយ ។ ក្សិណនោះ មហាជនផងស្ដាប់ហើយ ឆ្លើយថា ហៃព្រាហ្មណ៍អើយ ព្រះបាទស្រីវេស្សន្តរជាម្ចាស់នៃយើងនេះ អ្នកឱ្យទានស្រេចហើយកូវ ស្ដេចចេញទៅអំពីព្រះនគរនេះហើយ ឥឡូវនេះ ប្រស្ដែងមកដណ្ដឹងរកនរណាវិញទៀតហ៎ះ ។ ព្រាហ្មណ៍ដណ្ដឹងសួរទៀតថា បើដូច្នោះអ្នកមានបើយកអ្វីទៅខ្លះ ។ អស់មហាជនផងស្ដាប់ហើយ ឆ្លើយថា ហៃព្រាហ្មណ៍អើយ ស្ដេចមានតែរាជរថនោះឯង គ្រាន់តែផាក់ព្រះរាជទេពីប៉ុណ្ណោះ ។ ក្សិណនោះ ព្រាហ្មណ៍ទាំង៤នាក់

គិតព្រមគ្នាថា ហៃគ្នាយើងអើយ មក! យើងនឹងទៅតាមសុំយកសេះអាជានេយ្យទាំង ៤ ដែលអ្នកទឹមយកទៅនោះហោង ៗ

អថ មទ្ទី តេ អាគច្ឆន្តេ ទិស្វា យាចកា អាគច្ឆន្តិ ទេវាតិ អារោចេសិ ឰដ៏កាលនោះ សម្តេចព្រះនាងមទ្រី រមិលមើលទៅយល់ព្រាហ្មណ៍ទាំង ៤ នាក់ ដើរមកដូច្នោះកូវ ព្រះនាងទូលព្រះពោធិសត្វ មហាបុរសរ័ត្ន ថា បពិត្រអម្ចាស់អើយ ឥឡូវនេះ មានស្ទូមដើរមកតាមក្រោយយើង ៗ

អថ មហាសត្តោ រថំ ឋបេសិ ក្សិណនោះ ព្រះមហាសត្វ ព្រះអង្គបញ្ឈប់រាជរថដាក់រង់ចាំព្រាហ្មណ៍ លុះព្រាហ្មណ៍អស់នោះដើរទៅដល់ព្រះពោធិសត្វហើយ ក៏ទូលសូមសេះអាជានេយ្យទាំង ៤ ស្តេចក៏ដោះចេញអំពីព្រះរាជរថ ហើយឱ្យទៅជាទានព្រាហ្មណ៍ ពុំមានស្តាយឡើយ ៗ

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណា ពុំទាន់ប្រាកដ បទព្រះបាលីឯណា ពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គបន្ទូលសូត្រសានូវព្រះគាថា ដូច្នេះ

តំ ព្រាហ្មណា អន្វាគមុំ តេ តំ អស្សេ អយាចិសុំ
យាចិតោ បដិយាទេសិ ចតុន្នំ ចតុរោ ហយេតិ ៗ

ភិក្ខុអើយ កាលព្រាហ្មណ៍ទាំង ៤ នាក់ ទៅតាមសុំសេះអាជានេយ្យទាំង ៤ នោះកូវ ព្រះអង្គដោះសេះអាជានេយ្យទាំង ៤ អំពីរាជរថ ឱ្យទៅជាទាន ឰដ៏ក្សិណនោះពុំក្រដល់តិចឡើយ ៗ

អស្សេសុ បន និន្នេសុ រថធុរំ អាកាសេយេវ អដ្ឋាសិ ហៃភិក្ខុអើយ កាលព្រះមហាក្សត្រឱ្យទានសេះអាជានេយ្យទាំង ៤ ក្នុងកាលឯណាមិញ រីត្បូងរាជរថនោះក៏ងើយចំពោះស្មោះទៅ នាកណ្ដាលអាកាសហោង ៗ

អថ ព្រាហ្មណេសុ គតមត្តេសុយេវ ចត្តារោ ទេវបុត្តា រោហិតមិគវណ្ណេនាគន្ត្វា រថធុរំ សម្បដិច្ឆិត្វា អគមំសុ ភិក្ខុអើយ ឰដ៏កាលនោះ ព្រះមហាក្សត្រ ស្ដេចឱ្យទានសេះអាជានេយ្យទាំង ៤ ទៅជាទានព្រាហ្មណ៍ទាំង ៤ នោះហើយ ក្សិណនោះ មានទេវបុត្រទាំង ៤ និម្មិតអាត្មា យកភៀសជារមាំងមាសទាំង ៤ មកទទួលរាជរថព្រះមហាសត្វ ហើយនាំព្រះអង្គទៅហោង ៗ

មហាសត្តោ តេសំ ទេវបុត្តភាវំ ញត្វា ឥមំ គាថមាហ ព្រះមហាសត្វ ទ្រង់ជ្រាបនូវភាពនៃម្រឹគអស់នោះជាទេវបុត្រហើយ ទើបព្រះអង្គមានព្រះបន្ទូលនឹងសម្ដេច ព្រះរាជមទ្រី ដោយនូវបាទព្រះគាថា ដូច្នេះ

ឥង្ឃ មទ្ទិ និសាមេហិ ចិត្តរូបំវ ទិស្សតិ
មិគា រោហិច្ចវណ្ណេន ទក្ខិណស្សា វហន្តិ មន្តិ ៗ

ហៃនាងមទ្រីអើយ ចូរនាងរមិលមើល ទៅយល់រមាំងមាសទាំង ៤ នោះ ល្អដូចសេះអាជានេយ្យ គឺដ៏អ្នកឱ្យសិក្សាប្រពៃហើយ មកនាំរាជរថយើងនេះទៅ ៗ

អថ នំ ឯទំ គន្ត្វា អបរោ ព្រាហ្មណោ អាគន្ត្វា រថំ យាចិ ព្ធដ៏កាលនោះ មានព្រាហ្មណ៍មួយវិញទៀត មកសុំរាជរថ អំពីព្រះមហាក្សត្រនោះសោត ព្រះអង្គក៏ដាក់ព្រះរាជបុត្រនិងព្រះរាជទេពី អំពីរាជរថនោះហើយកូវ ស្ដេចក៏ឱ្យរាជរថនោះទៅជាទានព្រាហ្មណ៍នោះឯង ។ កាលបើព្រះអង្គឱ្យទានរាជរថនោះហើយកូវ រីអស់ទេវបុត្រនោះមិញ ក៏និម្មិតបំបាំងអាត្មាភៀសចៀសបាត់ទៅហោង ។

រថស្ស បន ទិន្នភាវំ បកាសេន្តោ សត្ថា អាហ រីព្រះស្រីសព៌ជ្ញ ស្ដេចបានត្រាស់ប្រាជ្ញាសព៌ជ្ញុតាញាណ នាំនិទាន អាស្រ័យព្រះរាជរថ ឱ្យប្រាកដបទព្រះបាលីឯក្រោយ អំពីកាលព្រះមហាក្សត្រឱ្យទានព្រាហ្មណ៍នោះកូវ ព្រះបន្ទូលសូត្រសានូវព្រះគាថា ដូច្នេះ

អថេត្ថ បញ្ចមោ អាគា សោ តំ រថមយាចតិ
តស្ស តំ បដិយាទេសិ ន ចស្សុ បហតោ មនោ ។
តតោ វេស្សន្តរោ រាជា ឱរោបេត្វា សកំ ជនំ
អស្សាសយិ អស្សរថំ ព្រាហ្មណស្ស ធនេសិនោតិ ។

ហៃភិក្ខុអើយ កាលព្រះបាទស្រីវេស្សន្តរបវរពោធិសត្វមហាបុរសរ័ត្ន ស្ដេចចេញទៅអំពីស្រុកពិជ័យជេតុត្តរ មហានគរនោះ ព្រាហ្មណ៍ ៤ នាក់រត់ទៅតាមសុំសេះអាជានេយ្យ មានព្រាហ្មណ៍ម្នាក់ទៀតជាគម្រប់ ៥ ទៅតាមសុំរាជរថ ព្រះអង្គក៏ព្រះរាជទាន

ឱ្យព្រាហ្មណ៍នោះ ទុកជាការកម្រអម្បាលម៉ានក្ដី ក៏ព្រះពោធិសត្វនឹងមានព្រះរាជហឫទ័យ កក្រើកដោយនូវចិត្តកំណាញ់នោះ ឥតអង្ដីមានឡើយ ហេតុតែព្រះអង្គនឹងបានត្រាស់ជាព្រះពុទ្ធនោះ ទៀងប្រាកដហោង ។

កាលព្រះបាទស្រីវេស្សន្តរ ដ៏ជាស្ដេចធំ តែងចម្រើនដល់អ្នកស្រុកស្រីពិរាស្ដ្រ ស្ដេចឱ្យទានរាជរថទឹមនីទៅនូវសេះអាជានេយ្យទាំង៤ ទៅព្រាហ្មណ៍ស្ទួមនោះកូវ ព្រះអង្គដាក់ព្រះរាជបុត្រ ព្រះរាជទេពីចុះអំពីរាជរថនោះ ហើយព្រះអង្គលួងលោមបណ្ដើរទៅ តែដោយនូវព្រះបាទាទទេហោង ។

អថ មហាសត្តោ មទ្ទឹ អវោច អណ្ដាប់នោះ ព្រះមហាសត្វ ស្ដេចបន្ទូលនឹងសម្ដេចព្រះរាជមទ្រី ថា ដូច្នេះ

ត្វំ មទ្ទិ កណ្ហាជិនំ គណ្ហាហិ លហុកា ឯសា កនិដ្ឋកា
អហំ ជាលី គណ្ហិស្សាមិ គរុកោ ភាតិកោ ហិ សោតិ ។

ហៃនាងមទ្រីអើយ ចូរនាងពមេក្រស្នា ដ៏ជាក្មេងស្រីតូចស្រាល ឯអញនឹងពរចៅជាលី ដ៏ជាបងច្បង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណា ពុំទាន់ប្រាកដ នឹងបទព្រះបាលីឯក្រោយ ព្រះដ៏ជាគ្រូបានត្រាស់ហើយ មានព្រះបន្ទូលសូត្រសានូវព្រះគាថា ដូច្នេះ

រាជា កុមារំ អាទាយ រាជបុត្តី ច ទារិកំ
សម្មោទមានា បក្កាមុំ អញ្ញមញ្ញំ បិយំ វទាតិ ។

ហៃភិក្ខុអើយ រីព្រះបាទស្រីវេស្សន្តរ ដ៏ជាក្សត្រប្រសើរ នោះ ស្ដេចពចៅជាលីដ៏ជាកូនច្បង រីសម្ដេចរាជមទ្រីពនាង ក្រស្ណាដ៏ជាកូនស្រីក្មេងតូចនោះ ៗ រីក្សត្រទាំងពីរព្រះអង្គមាន ព្រះទ័យស្រណុក មិនជាទុក្ខឡើយ ហើយមានពាក្យពីរោះស្រដី ទៅមក ដោយនូវដំណើរទៅតាមផ្លូវនោះហោង ៗ

ទានកណ្ឌំ រីនឹងស្រដីសរសើរនូវដំណើរ **ទានកណ្ឌ** នេះមិញ ដ៏ប្រដាប់នីទៅនូវព្រះគាថាទាំងឡាយ ២០៩ ព្រះគាថា **និដ្ឋិតំ** ក៏ចប់ជាសូរេច ដោយនូវប្រការ អម្បាលណោះឯងហោង ៗ

ចប់ កណ្ឌទានកណ្ឌ ទី ៣ តែប៉ុណ្ណោះ ៗ

⁂

ចម្លងចប់នៅថ្ងៃ ៩ កើត ខែជេស្ឋ ព.ស. ២៥៣៣
ត្រូវនឹងថ្ងៃសុក្រ ទី ១ ខែមិថុនា គ.ស. ១៩៩០

មហាវេស្សន្តរជាតក

ទី៤

កណ្ឌវនប្បវេសន៍

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

តេ បដិបថេ អាគច្ឆន្តេ មនុស្សេ ទិស្វា កុហឹ វង្កតបព្វតោតិ បុច្ឆន្តិ ។

បពិត្រអើយ រីក្សត្រទាំង ៤ អង្គ ស្តេចលីលាយាត្រាទៅប្រទះនឹងអស់មហាជនផងទាំងឡាយដើរទៅដើរមក ទើបព្រះអង្គដណ្តឹងសួររកផ្លូវទៅកាន់គិរីវង្កតបព៌ត ថាដូច្នេះ ម្នាលអ្នកទាំងឡាយអើយ រីផ្លូវទៅកាន់ភ្នំវង្កតបព៌តនោះ នៅឯណា ៗ **ទូរេតិ វទន្តិ** រីអស់មហាជនផងទាំងឡាយ ស្តាប់ព្រះបន្ទូលព្រះមហាក្សត្រហើយ មុខគួរអាសូរករុណា ក្រាបទូលថាដូច្នេះ បពិត្រក្សត្រថ្លៃប្រសើរអើយ រីផ្លូវទៅកាន់ភ្នំគិរីវង្កតបព៌តនោះ ឆ្ងាយក្តាត់ហោង ៗ **តេន វុត្តំ** ហេតុនោះហោងព្រះអង្គមានព្រះបន្ទូលនឹងព្រះមហាសារីបុត្តត្ថេរ សូត្រជាបាទព្រះគាថា ដូច្នេះ

យទិ កេចិ មនុជា ឯន្តិ   អនុមគ្គេ បដិបថេ
មគ្គន្តេ បដិបុច្ឆាម   កុហឹ វង្កតបព្វតោ ។
តេ តត្ថ អម្ហេ បស្សិត្វា   ករុណំ បរិទេវយុំ

មហាវេស្សន្តរជាតក

ទី ៤



កណ្ឌវនប្បវេសន៍

ប្រដាប់ដោយគាថា ៥៧

ទុក្ខន្តេ បដិវេទេន្តិ ទូរេ វង្កតបព្វតោតិ ។

ភោ សារីបុត្ត ហៃសារីបុត្តអើយ វីកាលតថាគត នៅជាព្រះវេស្សន្តរ ស្តេចចេញទៅអំពីជេតុត្តរនគរនោះ ប្រទះនឹងមហាជនផងទាំងឡាយដើរទៅដើរមក ដោយនូវផ្លូវជើងតូច ជើងធំ ច្រឡំនូវជើងច្រើនក្តី ក៏ព្រះអង្គមានព្រះបន្ទូលដណ្តឹងសួរថា ម្នាលអ្នកទាំងឡាយអើយ ផ្លូវឯណាទៅកាន់ភ្នំគិរីវង្កតបព៌តនោះ ចូរអ្នកទាំងឡាយប្រាប់អញផង ៗ វីអស់មហាជនផងទាំងឡាយស្តាប់ព្រះបន្ទូលព្រះមហាក្សត្រហើយ ក៏នាំគ្នាទួញយំ អាសូរករុណាព្រះបរមពោធិសត្វ ហើយទូលនូវពាក្យដូច្នេះថា បពិត្រក្សត្រថ្លៃប្រសើរអើយ វីផ្លូវទៅកាន់ភ្នំគិរីវង្កតបព៌តនោះ ឆ្ងាយក្តាត់ហោង ៗ

មគ្គស្ស ឧភោសុ បស្សេសុ វិវិធផលធារិនោ រុក្ខេ ទិស្វា ទារកា រោទន្តិ កាលស្តេចលីលាទៅនោះ សឹងដ៏មានឈើទាំងសងខាងផ្លូវនោះច្រើន ដ៏ទ្រង់នូវផ្លែផ្កានានាលច្រាលផ្សេង ៗ ព្រះរាជកុមារទាំងពីរយល់ហើយ អង្វរព្រះបិតាឱ្យបេះឱ្យ ព្ឋដ៏កាលនោះ ៗ ហេតុតែអានុភាពនៃព្រះមហាក្សត្រនោះមិញ វីឈើផងទាំងឡាយដ៏ខ្ពស់ក្រៃ ដែដំរីនឹងឈោងមិនដល់ហេតុតែព្រះបារមីព្រះពោធិសត្វ វីឈើទាំងនោះ ក៏ឱនលំទោនមកទៀបព្រះហស្ត ហើយស្តេចបេះឱ្យព្រះរាជបុត្រទាំងពីរបរិភោគ ព្ឋដ៏កាលនោះហោង ៗ ព្រះនាងមទ្រីយល់ជាអស្ចារ្យ ប្រាកដដូច្នោះ ព្រះនាងក៏សរសើរព្រះបារមីព្រះពោធិសត្វ ៗ តេន វុត្តំ

ហេតុនោះហោង ព្រះអង្គមានព្រះបន្ទូលនឹងព្រះមហាសារីបុត្តត្ថេរ សូត្រជាបាទព្រះគាថា ដូច្នេះ

យទិ បស្សន្តិ បវនេ   ទារកា ផលិកេ ទុមេ
តេសំ ផលានំ ហេតុម្ហិ   ឧបរោទន្តិ ទារកា ។
រោទន្តេ ទារកេ ទិស្វា   ឧព្វិគ្គា វិបុលា ទុមា
សយមេវោនមិត្វាន   ឧបគច្ឆន្តិ ទារកេ ។
ឥទំ អច្ឆេរកំ ទិស្វា   អព្ភុតំ លោមហំសនំ
សាធុការំ បវត្តេសិ   មទ្ទី សព្វង្គសោភណា ។
អច្ឆេរំ វត លោកស្មឹ   អព្ភុតំ លោមហំសនំ
វេស្សន្តរស្ស តេជេន   សយមេវោនតា ទុមាតិ ។

ភោ សារីបុត្ត ហៃសារីបុត្តអើយ ឰដ៏កាលនោះ ព្រះរាជកុមារទាំងពីរ ទ្រង់ទតឃើញព្រៃព្រឹក្សាមានផ្លែត្រកាល ក្នុងព្រៃធំ ក៏ទ្រង់ព្រះកន្សែងយំទារ ចង់បានផ្លែឈើទាំងនោះ ឯព្រៃព្រឹក្សាធំខ្ពស់ ហាក់ដូចបានឃើញព្រះរាជកុមារ ទ្រង់ព្រះកន្សែងសោយសោក ហាក់មានចិត្តអាសូរករុណា ក៏បង្អោនមែកចុះមករកព្រះកុមារទាំងពីរព្រះអង្គ ៗ រីឯសម្តេចព្រះរាជមទ្រី ដ៏ទ្រង់នូវលក្ខណាល្អព្រម ទ្រង់ទតយល់ហេតុអស្ចារ្យដូច្នោះហើយ ក៏កើតព្រឺព្រួចព្រះលោមា ទើបថ្វាយព្រះពរសព្ទសាធុការថា អស្ចារ្យអ្វីមាល្បាយ មិនដែលមានក្នុងលោកនេះឡើយ ហេតុតែតេជះបុណ្យបារមីនៃព្រះវេស្សន្តរមហាសត្វ រីឈើឯណា

ខ្ពស់មិញ ក៏បង្អោនមែកចុះមកឯង ៗ

ឥតិ ជេតុត្តរនគរតោ សុវណ្ណគិរិតាលោ នាម បព្វតោ បញ្ច យោជនានិ បពិត្រអើយ រីនឹងស្រដី គណនាឯចម្ងាយផ្លូវចេញទៅ អំពីជេតុត្តរនគរនោះ ទៅដល់ភ្នំមួយឈ្មោះសុវណ្ណគិរីតាលបព៌តនោះ ចម្ងាយ ៥ យោជន៍ អំពីកោន្តិមារានទី ទៅដល់ភ្នំមួយ ឈ្មោះ អញ្ជនគិរីបព៌ត នោះ ចម្ងាយ ៥ យោជន៍ អំពីនោះទៅដល់ស្រុកព្រាហ្មណ៍មួយឈ្មោះ ទុន្នវិដ្ឋនាលិទណ្ឌគ្រាម ចម្ងាយ ៥ យោជន៍ តអំពីនោះទៅដល់ មាតុលនគរ ចម្ងាយ ១០ យោជន៍ហោង ៗ

ឥតិ តំ រដ្ឋំ ជេតុត្តរនគរតោ តឹសយោជនានិ ហោតិ ថាបើនឹងគណនាចម្ងាយផ្លូវអំពីជេតុត្តរនគរនោះ ៣០ យោជន៍ ហេតុទេវតាអាសូរករុណាព្រះរាជបុត្រពុំងានោះមិញ ក៏កង្កាញ់ផ្លូវឱ្យទៀបជិត ស្តេចដើរអំពីព្រឹកព្រហាម លុះដល់រសៀលបន្តិច ស្តេចដល់មាតុលនគរនោះ ៗ **តេន វុត្តំ** ហេតុនោះហោង ព្រះអង្គមានព្រះបន្ទូលនឹងព្រះមហាសារីបុត្តត្ថេរ សូត្រជាបាទព្រះគាថា ដូច្នេះ

សទ្ធិបីសុ បថំ យន្ធា អនុកម្បាយ នារកេ
និក្ខន្តជិតសេនេច ចេតរដ្ឋមុបាគមុន្តិ ៗ

ហៃសារីបុត្តអើយ រីព្រះមហាក្សត្រទាំង ៤ ព្រះអង្គ ស្តេចចេញអំពីជេតុត្តរនគរនោះ ដោយនូវផ្លូវឆ្ងាយអម្បាលណោះក្តី

ហេតុតែទេវតាអាសូរករុណាព្រះរាជបុត្រពុំងានោះមិញ ក៏កង្កាញ់ផ្លូវឱ្យទៀបជិត ថ្វាយព្រះមហាក្សត្រ ស្តេចលីលាចេញអំពីព្រឹក លុះដល់ថ្ងៃរសៀលបន្តិច ស្តេចដល់នគរចេតរាស្ត្រនោះហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គបន្ទូលនឹងភិក្ខុផងទាំងឡាយ សូត្រសាជាអាថ៌បាទព្រះគាថា ដូច្នេះ

តេ គន្ត្វា និយមទ្វារំ ចេតរដ្ឋមុបាគមុំ
ឥទ្ធំ ផីតំ ជនបទំ ពហុមំសសុរោទនន្តិ (១)។

ភិក្ខុអើយ កាលក្សត្រទាំង ៤ អង្គ ស្តេចដើរដោយនូវផ្លូវឆ្ងាយដរាបទៅដល់ចេតរាស្ត្រនោះ ។ រីក្នុងស្រុកនោះសោត សឹងដ៏សំរឹទ្ធិបរិបូណ៌នូវអស់រាស្ត្រ ប្រជាជនផងទាំងឡាយ ដ៏ក្សេមក្សាន្តស្រណុក ប្រកបនូវបាយទឹក មាសប្រាក់រតនាករផងដ៏ច្រើន (២) ។

តទា មាតុលនគរេ សដ្ឋិ ខត្តិយសហស្សានិ វសន្តិ ឰដ៏កាលនោះ រីក្នុងមាតុលនគរនោះឯង មានមហាក្សត្រទាំង ៦ ម៉ឺន សោយរាជសម្បត្តិ ឋិតនៅនានគរនោះឯង

១- ច្បាប់ជាតកខ្លះថា " ពហុមំសំ សុរោទកន្តិ " ដូច្នេះក៏មាន ។ ច្បាប់ខ្លះ ថា ពហុមូលំ សុរោទកន្តិ " ដូច្នេះក៏មាន ។ ២- ច្បាប់ខ្លះថា " .... ស្រណុកប្រកបនូវបាយសសម្លពិសា ដ៏ប្រដាប់នីទៅនូវត្រីសាច់ ញាំភ្លា សាកប់ផងច្រើន " ។

នាកាលព្រះមហាក្សត្រទាំង ៤ ព្រះអង្គទៅដល់ហើយ ស្តេចពុំចូលទៅក្នុងនគរនោះ ព្រះអង្គឡើងទៅគង់លើសាលាមួយ នៅពួដ៏ទ្វារនគរនោះហោង ៗ កាលនោះ សម្តេចព្រះរាជមទ្រី ដ៏ជាអគ្គមហេសីស្រីរ័ត្នប្រសើរ នាងចូលទៅបោសផង់ធូលីដីខ្សាច់ច្របាច់គក់ព្រះបាទាព្រះពោធិសត្វហើយ នាងថ្វាយបង្គំមកឋិតនៅខាងទ្វារសាលានោះ ឆ្ពោះត្រង់ព្រះភក្ត្រ នៃព្រះមហាក្សត្រនោះឯង ៗ រីអស់មហាជនផងទាំងឡាយ ទោះប្រុសក្តី ស្រីក្តី ដើរចូលទៅក្នុងព្រះនគរនោះហើយ តែងរមិលមើលមកព្រះនាងមទ្រី ហើយស្គាល់ជាក្សត្រីប្រកបនូវលក្ខណាដ៏ប្រសើរ ហើយស្រីទាំងនោះ ក៏ចូលទៅថ្វាយបង្គំ នៅជាបរិវារបម្រើព្រះនាងហោង ៗ

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គសូត្រជាបាទគាថានឹងភិក្ខុផងទាំងឡាយថាដូច្នេះ

ចេតិយោ បរិករីសុ ទិស្វា លក្ខណមាគតំ
សុខុមាលី អយំ អយ្យា① បត្តិកា បរិចារតិ ។
វយ្ហាហិ បរិយាយិត្វា សិវិកាយ រថេន ច

១- ជាតកបាលីថា " វតាយយ្យា " ដូច្នេះក៏មាន ។

សាជ្ជ មន្ទី អរញ្ញស្មឹ បត្តិកា បរិធាវតីតិ ។

ហៃអស់ភិក្ខុផងទាំងឡាយអើយ រីអស់ស្រីផងទាំងឡាយមកបម្រើជាបរិវារ ហើយទូលថា បពិត្រអ្នកនាងដ៏មានបុណ្យប្រសើរអើយ ព្រះនាងធ្លាប់គង់នៅស្រណុកសុខសប្បាយ ឥឡូវនេះ អម្ចាស់មានទុក្ខអ្វីមកបៀតបៀនអម្ចាស់ ក៏អម្ចាស់មកតែព្រះបាទទទេ ឥតសុពណ៌បាទុក នឹងពាក់ឰដ៏ព្រះបាទ បពិត្រក្សត្រីមានលក្ខណាប្រសើរអើយ រីគ្រែសុពណ៌ សិវិកាក្តី រាជរថក្តី ដំរី ពាជី ពលថ្មើរជើងក្តី អម្ចាស់ទុកនៅឋានឯណា ក៏អម្ចាស់ស្តេចមកតែព្រះអង្គឯង ដោយនូវផ្លូវព្រៃធំនេះអម្ចាស់ ៗ បពិត្រអើយ រីអស់អ្នកនគរផងទាំងឡាយនោះ យល់ព្រះមហាក្សត្រទាំង ៤ ព្រះអង្គ លំបាកត្រមោចត្រមង់ឥតពំនាក់ដូច្នោះហើយ ក៏នាំគ្នាទួញយំរត់ចូលទៅទូលព្រះមហាក្សត្រទាំង ៦ ម៉ឺននោះ ៗ រីអស់មហាក្សត្រទាំង ៦ ម៉ឺននោះសោត ទ្រង់ស្តាប់អស់ពាក្យមហាជនផងទូលដូច្នោះហើយ សឹងដ៏លើកព្រះហស្តដាក់លើត្បូង គត់ព្រះឱរាទ្រង់ព្រះកន្សែង ស្តេចរត់ទៅកាន់សំណាក់ព្រះពោធិសត្វមហាបុរសរ័ត្ន ឰដ៏កាលនោះហោង ៗ

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គបន្ទូលនឹងអស់ភិក្ខុផងទាំងឡាយថា ដូច្នេះ

តំ ទិស្វា ចេតបាមោក្ខា   រោទមានា ឧបាគមុំ
កច្ចិ នុ ទេវ កុសលំ   កច្ចិ ទេវ អនាមយំ
កច្ចិ បិតា អរោគោ តេ①   សិវីនញ្ច អនាមយំ
កោ តេ ពលំ មហារាជ   កោ នុ តេ រថមណ្ឌលំ
អនស្សកោ អរថកោ   ទីឃមទ្ធានមាគតោ
កច្ចាមិត្តេហិ បកតោ   អនុបត្តោ ឥមំ ទិសំ ។

ភិក្ខុអើយ ឮដ៏កាលនោះ រីអស់មហាជនផងនិងស្តេចចេតរាស្ត្រទាំង ៦ ម៉ឺន លុះឮពត៌មានអំពីព្រះពោធិសត្វហើយ ក៏ម្ដីម្ដាយកសំពត់អាវរតនាករ មកថ្វាយព្រះពោធិសត្វមួយរំពេច ហើយសឹងទ្រង់ព្រះកន្សែងដំឧរា អាសូរករុណាព្រះមហាក្សត្របុរសរ័ត្ននិងព្រះនាងមទ្រីស្តេចលីលាមក ដោយនូវព្រួយលំបាកពេកក្តាត់ អស់ស្តេចចេតរាស្ត្រផងទាំងឡាយ ថ្វាយបង្គំព្រះពោធិសត្វបុរសរ័ត្នហើយ សំណេះសំណាលក្រាបទូលសាកសួរថា បពិត្រក្សត្រថ្លៃប្រសើរអើយ ព្រះអង្គនៅសព្វថ្ងៃនេះ សភាពឥតជំងឺតម្កាត់ឬជាទុក្ខអផ្សុកក្នុងព្រះទ័យនៃមហារាជ ញ៉ាំងមានឬមួយព្រះអង្គនៅជាសុខសប្បាយពណ្ណរាយជាទេ រីស្រីសួស្តី តើញ៉ាំងមានឬទេ រីសម្តេចព្រះវររាជមាតាបិតាព្រះអង្គ ឯនាយ តើញ៉ាំងមានព្យាធិរោគា ជរាជំងឺមកបៀតបៀនឬទេ

១- ច្បាប់ជាតកបាលីថា " កច្ចិ បិតា អរោគា តេ " ដូច្នេះក៏មាន ប្រែថា ព្រះរាជមាតាព្រះរាជបិតារបស់ព្រះអង្គឥតជំងឺតម្កាត់ទេឬ ? ។

រីអស់អ្នកស្រីពិរាស្ត្រ នូវពលសកលយោធាសេនាមាត្យផង ទាំងឡាយនោះ តើញ៉ាំងជាសុខសប្បាយ ឬទេ រីសេនាដំរី សេនាសេះ សេនារទេះ សេនាពលថ្មើរជើង គ្រែសុពណ៌សិវិកា តើព្រះអង្គទុកនៅនាឋានឯណា ក៏ព្រះអង្គស្តេចលីលាយាត្រាមកតែព្រះអង្គឯង ដោយនូវផ្លូវឆ្ងាយដូច្នេះ ក្រែងសត្រូវអ្វីមួយវាមកបៀតបៀនព្រះអង្គ ឬមួយគង់នៅសុខសប្បាយជាទេ ។

អថ នេសំ សដ្ឋីសហស្សានំ រាជូនំ មហាសត្តោ អត្តនោ អាគតការណំ កថេន្តោ អាហ ព្ទដ៏កាលនោះ ព្រះពោធិសត្វ ស្តាប់ពាក្យអស់ស្តេចចេតរាស្ត្រទាំង ៦ម៉ឺននោះហើយ ព្រះអង្គសម្តែងថ្លែងនូវសភាពអាការព្រះអង្គលីលាមកនោះ ទ្រង់មានព្រះបន្ទូលសូត្រនូវបាទព្រះគាថា ដូច្នេះ

កុសលញ្ច មេ សម្ម អថោ សម្ម អនាមយំ
អថោ បិតា អរោគោ មេ សិវីនញ្ច អនាមយំ ។
អហំ ហិ កុញ្ជរំ ទជ្ជំ ឦសាទន្តំ ឧរុឡ្ហវំ
ខេត្តញ្ញុំ សព្វយុទ្ធានំ សព្វស្យេតំ គជុត្តមំ ។
បណ្ឌុកម្ពលសញ្ឆន្នំ បភិន្នំ សត្តុមទ្ទនំ
ទន្តី សវាលវីជនី សេតំ កេលាសសាទិសំ
សស្យេតច្ឆត្តំ សុបត្ថេយ្យំ សាថព្វនំ សហត្ថិបំ
អគ្គយានំ រាជវាហី ព្រាហ្មណានំ អទា ធនំ
តស្មី មេ សិវិយោ កុទ្ធា បិតា ចុបហតោ មនោ

អថរុទ្ធសិ មំ រដ្ឋា ចត្តំ គច្ឆាមិ បព្វតំ
ឱកាសំ សម្មា ជានាថ ចនេ យត្ថ ចសេម្ហសេតិ ។

ហៃមហារាជអើយ រីសភាពជាទុក្ខអផ្សុកនោះ ឥតអន្តីមានឡើយ មហាមិត្រអើយ រីស្រីសួស្តី សឹងមានដល់អញ ៗ មហាមិត្រអើយ ប្រការមួយសោត សម្តេចព្រះវររាជមាតាបិតានៃយើង ឥតព្យាធិរោគាជរាមកបៀតបៀនព្រះអង្គឡើយ រីអ្នកស្រីពិរាស្ត្រសោត សឹងឥតជំងឺតម្កាត់ទេ សំឡាញ់អើយ រីដំណើរអញមកនេះ ត្បិតតែអញឱ្យទានដំរីបច្ច័យនាគេន្ទ្រនោះ ទៅព្រាហ្មណ៍ទាំង ៨ នាក់ រីដំរីនោះសោត ធំចម្រើនឡើងពេញកម្លាំង ដ៏មានភ្លុកងងស្តាំ ហើយឈ្លាស ដឹងសារពើចម្បាំងទាំងពួង ដ៏ជាបាដំរីធំប្រសើរក្រៃ អាចបុកបែន កិនញាំញីនូវសឹកសត្រូវផង ដ៏មានខ្លួននោះល្អ សដូចភ្នំកៃលាសបព៌ត មានកន្ទុយល្អាយល្អងវាំងគន្លងបោសព្រះធរណី ដ៏ជាបាដំរីប្រសើរ សមនឹងស្វេតច្ឆ័ត្ររាជសម្បត្តិ គួរជាជំនិះជំនាន់នៃមហាក្សត្រាធិរាជ ៗ ហៃមហាមិត្រអើយ ត្បិតតែអញឱ្យដំរីបច្ច័យនាគេន្ទ្រនោះទៅជាទានព្រាហ្មណ៍ បានជាពួកអ្នកស្រីពិរាស្ត្រផងទាំងឡាយនាំគ្នាខឹង ទាំងសម្តេចព្រះវររាជបិតា ក៏ទ្រង់ព្រះពិរោធនឹងអញ ហើយបំបរបង់អញ អំពីស្រុក ឱ្យទៅនៅនាភ្នំគិរីវង្កតបព៌តនោះហោង ៗ

តតោ(១) រាជានោ អាហំសុ ឮដ៏កាលនោះ រីអស់ស្ដេចចេតរាស្ដ្រទាំង ៦ ម៉ឺន ស្ដាប់ព្រះបន្ទូលព្រះពោធិសត្វហើយ ក្រាបទូលថាដូច្នេះ

ស្វាគតន្តេ មហារាជ អថោ តេ អទុរាគតំ
ឥស្សរោសិ អនុប្បត្តោ យំ ឥធត្ថិ បវេទយ ។
សាកំ ភិសំ មធុមំសំ សុទ្ធសាលិនមោទនំ
បរិភុញ្ជ មហារាជ បាហុនោ នោសិ អាគតោតិ ។

បពិត្រក្សត្រថ្លៃប្រសើរអើយ នាដំណើរព្រះអង្គលីលាមកនេះ ក៏យល់ប្រសើរក្រៃពេកណាស់ មិនហាក់ជាព្រះអង្គលីលាមកអំពីចម្ងាយនោះឡើយ ហាក់ដូចព្រះអង្គនៅអាយ មួយអន្លើនូវអស់យើងខ្ញុំ ៗ បពិត្រមហារាជអើយ ទោះក្រអៅឈូកក្ដី ព្រលិតលំចង់ក្រចាប់ក្ដី យកមកច្រឡំនីទៅនូវទឹកឃ្មុំ ដ៏ប្រកបនូវបាយទឹកភោជ្ជសាលីបរិសុទ្ធ សឹងសល្អប្រពៃ ដ៏ប្រកបនីទៅនូវត្រីសាច់ញាំភ្លាផងទាំងឡាយច្រើន សូមអញ្ជើញព្រះអង្គសោយរាជសម្បត្តិ ឋិតនៅជាឥស្សរកំពូលនៃយើងខ្ញុំ នៅនានគរនេះហោង ៗ ព្រះបាទស្រីវេស្សន្តរបវរពោធិសត្វ ស្ដាប់ពាក្យស្ដេចចេតរាស្ដ្រទាំង ៦ ម៉ឺននោះហើយ ព្រះអង្គមានព្រះបន្ទូលវិញ ជាបាទព្រះគាថាដូច្នេះ

បដិគ្គហិតំ យំ ទិន្នំ សព្វស្ស អគ្ឃិយំ កតំ

១- ច្បាប់ខ្លះថា " តេ រាជានោ អាហំសុ " ដូច្នេះក៏មាន ៗ

អវរុទ្ធសិ មំ រាជា វង្កំ គច្ឆាមិ បព្វតំ
ឱកាសំ សម្មា ជានាថ វនេ យត្ថ វសេម្ហសេតិ ៗ

សម្មា ហៃសម្លាញ់ទាំងឡាយអើយ រីទ្រព្យឯណាមិញ ជាទ្រព្យទទួលភ្ញៀវ ក៏មហាមិត្រយកមកឱ្យយើង ៗ នឹងទទួលយកដែរ ប៉ុន្តែសម្តេចព្រះមហាក្សត្រទ្រង់ព្រះពិរោធនឹងយើងៗ ត្រូវទៅកាន់ភ្នំគិរីវង្កត សុំឱ្យមហាមិត្រណែផ្លូវយើងៗទៅនៅភ្នំគិរីវង្កតបព៌តនោះហោង ៗ

តេ រាជានោ អាហំសុ អស់ស្តេចចេតរាស្ត្រផងទាំងឡាយ ស្តាប់ព្រះបន្ទូលព្រះបរមពោធិសត្វ ហើយក្រាបបង្គំទូលវិញ សូត្រជាបាទព្រះគាថាដូច្នេះ

ឥធេវ តាវ អច្ឆស្សុ ចេតរដ្ឋេ រថេសភ
យាវ ចេតា គមិស្សន្តិ រញ្ញោ សន្តិកយាចិតុំ
និជ្ឈាបេតុំ មហារាជំ សិវីនំ រដ្ឋវឌ្ឍនំ
តំ តំ ចេតា បុរក្ខិត្វា បីតិតា លទ្ធប្បច្ចយា
បរិវារេត្វាន គច្ឆន្តិ ឯវំ ជានាហិ ខត្តិយាតិ ៗ

បពិត្រព្រះសម្មតិទេព មហាក្សត្រប្រសើរអើយ សូមទានអម្ចាស់សោយរាជ្យនៅនានគរយើងខ្ញុំនេះ ៗ ក៏យើងខ្ញុំទាំង ៦ ម៉ឺននេះ នឹងទៅទូលព្រះបាទស្រីសញ្ជ័យ ប្រាប់អស់អ្នកស្រីពិរាស្ត្រផងទាំងឡាយ ឱ្យគេអត់ទោសព្រះអង្គ ៗ បពិត្រមហារាជអើយ រីអស់អ្នកស្រីពិរាស្ត្រនោះ កាលបើគេនឹង

ជាព្រះបាទស្រីសញ្ជ័យអត់ទោសព្រះអង្គហើយ ក៏អ្នកស្រីពិរាស្ត្រ គេនឹងមកចោមរោមបម្រើជាបរិវារព្រះអង្គនោះ ច្រើនក្តាត់ហោង ៗ មហាសត្តោ អាហ ព្រះមហាសត្វ ស្តាប់ពាក្យអស់ស្តេចចេតរាស្ត្រនោះហើយ ព្រះអង្គមានព្រះបន្ទូលស្មូត្រនូវអាថ៌បាទព្រះគាថាដូច្នេះ

មា វោ រុចិត្ថ គមនំ រញ្ញោ សន្តិកយាចិតុំ
និជ្ឈាបេតុំ មហារាជំ រាជា តត្ថ ន ឥស្សរោ
អច្ចុគ្គតា ហិ សិវិយោ ពលគ្គា នេគមា ច យេ
តេ បធំសេតុមិច្ឆន្តិ រាជានំ មម ការណាតិ ៗ

ហៃមហាមិត្រអើយ ចូរអ្នកទាំងឡាយស្តាប់ពាក្យយើង យើងនឹងសម្តែងថ្លែងប្រាប់ ថាបើយើងបានទទួលសោយរាជសម្បត្តិ នៅនានគរនោះហើយ រីដំនៀលពីរប្រការនឹងកើតមានប្រាកដ គឺអ្នកស្រីពិរាស្ត្រ គេនឹងត្អះតិះដៀលយើងថា ឱ! ព្រះវេស្សន្តរអើយ សោយរាជសម្បត្តិមិនឋិតនៅដោយគន្លងធម៌ គេយល់ដូច្នោះហើយ បានជាគេបំបរបង់ចេញអំពីស្រុក ឱ្យទៅនៅភ្នំគិរីវង្កតបព៌តឆ្ងាយប្រការមួយ ហើយប្រការមួយទៀត ឥឡូវនេះ មកយល់តែគេឃាត់ឱ្យសោយរាជ្យដូច្នោះកូវ ក៏សោយរាជ្យព្រងើយ ហៃមហាមិត្រអើយ រីអស់អ្នកថានឹងទៅទូលព្រះបាទស្រីសញ្ជ័យ ឱ្យអ្នកអត់ទោសយើងនោះ ពុំគួរដល់អ្នកទាំងឡាយទៀយ រីព្រះបាទស្រី-

សញ្ជ័យ ព្រះអង្គជាស្តេចធំ ឧត្តមប្រសើរ កន្លងរំលងអស់រាស្ត្រប្រជាផងទាំងឡាយមែនពិត គឺមោះ អស់អ្នកស្រីពិរាស្ត្រផងទាំងឡាយ គេខឹងហើយ គេជំនុំគ្នានូវអស់នាយដំរី នាយសេះ នាយរទេះ នាយពល ក្រៅលំនៅជនបទផងទាំងឡាយ គេនឹងសម្លាប់ព្រះអង្គ ត្បិតតែយើងនេះឯង ទើបយើងរត់មកឥឡូវនេះ ។ ហៃមហាមិត្រអើយ ថាបើនឹងព្រៃឯណាស្រណុកសុខសប្បាយ ចូរអ្នកទាំងឡាយប្រាប់យើង ៗ នឹងទៅនៅនាព្រៃនោះហោង ។

តតោ រាជានោ អាហំសុ អណ្តាប់នោះ អស់ស្តេចចេតរាស្ត្រផងទាំងឡាយ ស្តាប់ព្រះបន្ទូលព្រះបរមពោធិសត្វហើយ ទូលជាបាទព្រះគាថា ថា

សចេ ឯសា បវត្តេត្ថ　រដ្ឋស្មឹ រដ្ឋវឌ្ឍន
ត្វមេវ រជ្ជំ ការេហិ　ចេតេហិ បរិចារិតោ
ឥទ្ធំ ផីតញ្ចិទំ រដ្ឋំ　ឥទ្ធោ ជនបទោ មហា
មតឹ ករោហិ ត្វំ ទេវ　រជ្ជស្សមនុសាសិតុន្តិ ។

បពិត្រព្រះអង្គ តែងទ្រង់ធ្វើសេចក្តីចម្រើនដល់អ្នកស្រីពិរាស្ត្រអើយ បើមានហេតុកើតឡើងក្នុងដែននុ៎ះកូវ សូមព្រះអង្គគ្រងរាជសម្បត្តិ ក្នុងនគរនៃយើងខ្ញុំនេះ សឹងមានស្តេចចេតរាស្ត្រទាំងឡាយចោមរោមជារាជបរិវារ ៗ មួយសោត ដែនចេតរាស្ត្រនេះ ក៏ធំទូលាយស្តុកស្តម្ភសម្បូរណ៍

បពិត្រក្សត្រថ្លៃប្រសើរអើយ សូមព្រះអង្គព្រមទទួល ដើម្បីគ្រប់គ្រងរាជសម្បត្តិ ជាឥស្សរនៃយើងខ្ញុំហោង ។

តតោ វេស្សន្តរោ អាហ បពិត្រអើយ រីព្រះបាទស្រីវេស្សន្តរបរមពោធិសត្វ ស្ដេចស្ដាប់អស់ពាក្យស្ដេចចេតរាស្ដ្រទាំង ៦ ម៉ឺន ទូលអង្វរអញ្ជើញព្រះអង្គ ឱ្យសោយរាជសម្បត្តិស្វេតច្ឆត្រ គ្រងព្រះនគរដូច្នោះក្ដី ព្រះអង្គមានព្រះបន្ទូលដោះសានឹងអស់ស្ដេចចេតរាស្ដ្រផងទាំងឡាយ ថា

ន មេ ឆន្ទោ មតិ អត្ថិ   រជ្ជស្សមនុសាសិតុំ
បព្វាជិតស្ស រដ្ឋស្មា   ចេតបុត្តា សុណាថ មេ ។
អតុដ្ឋា សិវិយោ អស្សុ   ពលគ្គា នេគមា ច យេ
បព្វាជិតស្ស រដ្ឋស្មា   ចេតា រជ្ជេភិសេចយុំ ។
អសម្មោទិយំបិ វោ អស្ស   អច្ចន្តំ មម ការណា
សិវីហិ ភណ្ឌនញ្ចាបិ   វិគ្គហោ មេ ន រុច្ចតិ ។
អថស្ស ភណ្ឌនំ ឃោរំ   សម្បហារោ អនប្បកោ
ឯកស្ស ការណា មយ្ហំ   ហឹសេយ្យ ពហុកោ ជនោ ។
បដិគ្គហិតំ យំ ទិន្នំ   សព្វស្ស អគ្ឃិយំ កតំ
អវរុទ្ធសិ មំ រាជា   វង្កំ គច្ឆាមិ បព្វតំ
ឱភាសំ សម្មា ជានាថ   វនេ យត្ថ វសេម្ហសេតិ ។

ហៃមហាមិត្រអើយ បើយើងសោយរាជសម្បត្តិ នៅនានគរនេះហើយ សមអ្នកស្រីពិរាស្ដ្រផងទាំងឡាយ គេនឹងបរ

ពលសកលយោធាសេនាមាត្យ លើកទ័ពមីរដេរដាសពាសពេញទាំងក្រឡាមហាប្រឹថពី ខ្មីឃ្មាតសង្វាតមកចោមរោមមាតុលនគរនេះ ប្រាកដមិនទេឡើយ ៗ ហៃសំឡាញ់អើយ ម្ល៉ោះហើយ ក៏វានឹងកើតជាកោលាហលអំពល់ នូវចម្បាំងរាំងជលប្រកាប់ប្រចាក់គ្នា រីអស់មនុស្សម្នាមហាជនផងទាំងឡាយនោះ សឹងស្លាប់ច្រើនពុំខានឡើយ ហេតុនោះហោង វាមិនកើតមកអំពីអ្នកណាឡើយ វាកើតត្បិតយើងមកសោយរាជសម្បត្តិនេះឯង ហេតុនេះ យើងមិនទើងនៅ សោយរាជសម្បត្តិឡើយ សំឡាញ់អើយ ថាបើសំឡាញ់ អាសូរយើងហើយ ក៏យើងសូមតែស្បៀងនីរៀង ៗ ទៅដោយផ្លូវ ៗ ត្បិតអ្នកស្រីពិរាស្ត្រ គេបំបរបង់យើងចេញ ក៏យើងនឹងទៅនៅនាភ្នំគិរីវង្កតបព៌តនាយហោង ៗ

ឯវម្បិ បន វត្វា មហាសត្តោ អនេកបរិយាយេន យាចិតោបិ រជ្ជំ ន ឥច្ឆិ រីព្រះមហាសត្វ ព្រះអង្គនាំបរិយាយនិយាយមកជាសណ្ដាប់ ប្រាប់អស់ស្ដេចចេតរាស្ត្រផងទាំងឡាយនោះច្រើន ហេតុតែព្រះអង្គមិនចង់នៅសោយរាជសម្បត្តិឡើយ ហើយអស់ស្ដេចចេតរាស្ត្រផងទាំងឡាយ សឹងបូជាឱ្យសព្ទសាធុការ ដល់មហាបុរសរ័ត្ននោះច្រើន ហើយក្រាលនីទៅនូវកម្រោលចៀមចំព្រៃព្រំ បាំងនូវរនាំងវាំងននការពារពិភ័ក្តិរក្សាព្រះបរមពោធិសត្វនៅនាសាលានុ៎ះហោង ៗ

បពិត្រអើយ លុះព្រឹកព្រហាមឡើងវិញ ព្រះអង្គស្តេចលីលាទៅកក់ស្រង់ជម្រះនូវព្រះកេសា ប្រដាប់អាត្មា អំពីព្រហាមស្រេច ស្តេចសោយនូវភោជនាហារ ដ៏មានរសពីសាស្រេចហើយ ស្តេចលីលាចេញទៅអំពីសាលា មួយអន្លើនឹងអស់ស្តេចចេតរាស្ត្រផងទាំងឡាយ សឹងមកចោមរោម ជារាជបរិវារហោង ៗ ព្រះបរមពោធិសត្វ និង អស់ស្តេចចេតរាស្ត្រទាំង ៦ ម៉ឺនស្តេចលីលាទៅដល់ទ្វារព្រៃភ្នំគិរីវង្កតបព៌ត ដ៏មានចម្ងាយផ្លូវនោះ ១៥ យោជន៍ កាលអស់ស្តេចចេតរាស្ត្រក្រាបទូលណែផ្លូវព្រះពោធិសត្វទៅខាងមុខ សឹងដ៏មានចម្ងាយ ១៥ យោជន៍ ទើបសូត្រជាបាទព្រះគាថា ដូច្នេះ

តគ្ឃ តេ មយមក្ខាម យថាបិ កុសលា តថា
រាជិសី យត្ថ សម្មន្តិ អាហុតគ្គី សមាហិតា ៗ
ឯស សេលោ មហារាជ បព្វតោ គន្ធមាទនោ
យត្ថ ត្វំ សហ បុត្តេហិ សហ ភរិយាយ ចច្ឆសិ ៗ
តំ ចេតា អនុសាសីសុ អស្សុនេត្តា រុទម្មុខា
ឥតោ គច្ឆ មហារាជ ឧជុំ យេនុត្តរា មុខោ ៗ
អថ ទក្ខសិ ភទ្ទន្តេ វិបុលំ នាម បព្វតំ
នានាទុមគណាកិណ្ណំ សីតច្ឆាយំ មនោរមំ ៗ
តមតិក្កម្ម ភទ្ទន្តេ អថ ទក្ខសិ អាបកំ
នទី កេតុមតី នាម គម្ភីរំ គិរិគព្ភរំ ៗ

បុថុលោមមច្ឆាកិណ្ណំ　　សុបតិត្ថំ មហោទកំ
តត្ថ ន្ហាត្វា បិបិត្វា ច　　អស្សាសេត្វា សបុត្តកេ
អថ ទក្ខសិ ភទ្ទន្តេ　　និគ្រោធំ មធុបិប្ផលំ ៗ
រម្មកេ សិខរេ ជាតំ　　សីតច្ឆាយំ មនោរមំ
អថ ទក្ខសិ ភទ្ទន្តេ　　នាលិកំ នាម បព្វតំ ៗ
នានាទិជគណាកិណ្ណំ　　សេលំ កឹបុរិសាយុតំ
តស្ស ឧត្តរបុព្វេន　　មុចលិន្ទោ នាម សោ សរោ ៗ
បុណ្ឌរីកេហិ សញ្ឆន្នោ　　សេតសោគន្ធិយេហិ ច
សោ វនំ មេឃសង្កាសំ　　ធុវំ ហរិតសទ្ទលំ ៗ
សីហោវាមិសបេក្ខីវ　　វនសណ្ឌំ វិគាហិយ
បុប្ផរុក្ខេហិ សញ្ឆន្នំ　　ផលរុក្ខេហិ ចូភយំ ៗ
តត្ថ ពិន្ទុស្សរា វគ្គូ　　នានាវណ្ណា ពហូ ទិជា
កូជន្តមុបកូជន្តិ　　ឧតុសម្បុប្ផិតេ ទុមេ ៗ
គន្ត្វា គិរិវិទុគ្គានិ　　នទីនំ បភវានិ ច
សោ អទ្ទស បោក្ខរណី　　ករញ្ជកកុធាយុតំ ៗ
បុថុលោមមច្ឆាកិណ្ណំ　　សុបតិត្ថំ មហោទកំ
សមញ្ច ចតុរស្សញ្ច　　សាធុំ អប្បដិគន្ធិយំ ៗ
តស្សា ឧត្តរបុព្វេន　　បណ្ណសាលំ អមាបយ
បណ្ណសាលំ អមាបេត្វា　　ឧញ្ឆាចរិយាយ ឦហថាតិ ៗ

បពិត្រព្រះសម្មតិទេពក្សត្រថ្លៃប្រសើរអើយ ព្រះអង្គរមិលមើលទៅភ្នំនោះយល់ប្រាកដ លោកសន្មតហៅភ្នំគន្ធមាទន៍បព៌ត

ព្រះអង្គស្តេចអំពីនោះទៅបន្តិច នឹងដល់ភ្នំមួយឈ្មោះវិបុលបព៌ត ដ៏មីរដេរដាសនីទៅនូវដើមឈើតូចធំផងទាំងពួងនោះច្រើន ដ៏មានមែកនោះវែងលលាយត្រសាយសាខាបុប្ផាសន្លឹក ដ៏មានម្លប់នោះត្រជាក់ស្រណុកសុខសប្បាយ ៗ មួយសោត វីជាតមាណពផងទាំងឡាយ សឹងដ៏អាស្រ័យពំនាក់នៅនាឋាននោះហោង ហើយព្រះអង្គកន្លងរំលងអំពីនោះទៅទៀត ព្រះអង្គនឹងបានដល់យល់ស្ទឹងមួយ ឈ្មោះ កេតុមតីនទី ដ៏មានទឹកនោះជ្រៅថ្លាត្រជាក់ស្រណុកសុខសប្បាយ ប្រាសចាកស្លែសារាយសម្រាមព្រាំ ផងទាំងឡាយ ដ៏មីរដេរដាសពាសពេញនីទៅនូវត្រីផងទាំងឡាយ សឹងដ៏ធំ ៗ ហើយមានច្រាំងនោះទាបមានកំពង់នោះរាបស្មើ ដ៏មានទឹកនោះច្រើន សូមព្រះអង្គស្រង់ជម្រះព្រះវរកាយ លោមព្រះរាជបុត្រព្រះរាជទេពី រួចសឹមស្តេចលីលាចេញអំពីនោះទៅបន្តិច នឹងបានយល់ដើមជ្រៃ ១ ធំ ដ៏មានផ្លែនោះទុំក្រហមច្រាលរន្ទាល មានឱជារសផ្អែមបីដូចទឹកឃ្មុំ ដ៏មានមែកនោះត្រសាយសាខា(១) មានម្លប់ត្រជាក់ស្រណុកសុខសប្បាយ ហើយអម្ចាស់នឹងសោយផ្លែជ្រៃនោះមួយអន្លើនឹងព្រះរាជបុត្រព្រះរាជទេពីនៅនាឋាននោះហោង ៗ មួយសោត ព្រះអង្គស្តេចអំពីនោះទៅ នឹងបានយល់ភ្នំមួយឈ្មោះ នាលិកបព៌ត ដ៏ដេរដាសសឹងដ៏ថ្កល្អប្រពៃ ពេញនីទៅ

១- ច្បាប់ខ្លះថា " ដ៏មានមែកនោះវែងលលាយត្រសាយសាខា " ដូច្នេះក៏មាន ៗ

នូវបក្សីផងទាំងឡាយ គឺកិន្នរី កិន្នរា សឹងដ៏ច្រៀងរាំ បីដូចភ្លេងល្បែងរបាំ មាននៅនាសួគ៌ទេពលោកនាយហោង ៗ

បពិត្រអើយ បើស្តេចលីលាទៅដោយប្របជើងភ្នំនាលិកបព៌ត ដោយនូវខាងទិសឧត្តរនោះ ស្តេចនឹងបានយល់ស្រះ ១ លោកហៅថា មុចលិន្ទស្រះ ដ៏ដាសពាសពេញនីទៅនូវឈូកស ឈូកច្រាល កុមុទ ឧត្បល លំចង់ ស្បង្ក័ជ ស្គន់ ព្រលិត ត្រកួន កំពីងពួយ ផងទាំងឡាយច្រើន អម្ចាស់ចូលទៅក្នុងកំឡុងព្រៃនោះហើយ ក៏នឹងបានយល់ស្មៅជើងក្រាស សឹងដ៏ដុះដាសពេញ មានពណ៌ខ្មៅ ខៀវខ្ចី បីដូចផ្ទៃមហាមេឃ រីស្មៅនោះសោត ក៏ដុះដាសពាសពេញទាំងព្រៃនោះ សឹងជាលំនៅនៃរាជសីហ៍ ដំរីព្រៃផងទាំងឡាយនោះ ៗ មួយសោត បពិត្រក្សត្រថ្លៃប្រសើរអើយ រីបក្សីផងទាំងឡាយនោះ សឹងមានកំណើតពីរដង គឺជាពង ហើយញាស់ជាកូន នៅសងខាងដងព្រៃនោះ សឹងដ៏ស្រែកកញ្ជ្រៀវខ្ញៀវខ្ញារ ដ៏មានសំឡេងនោះពីរោះផ្សេង ៗ ហើយយំទំលើឈើ មានផ្លែផ្ការីកស្គុសស្គាយដោយរដូវហោង ៗ បពិត្រអម្ចាស់អើយ រីព្រៃនោះសោត ដ៏ប្រកបនីទៅនូវឈើផងមានពីរចំពូក មួយគឺឈើមានផ្លែ មួយគឺឈើមានផ្កា ថាបើអ្នកឯណាមួយ បានទៅដល់យល់ឈើនោះហើយ សឹងដ៏មានចិត្តនោះស្រណុកសុខសប្បាយពណ្ណារាយក្រៃពេក សឹងដ៏មានក្លិននោះ ពិដោរក្រៃលែងនៃ

ភ្ញីផ្កាផងទាំងឡាយហោង ៗ បពិត្រអម្ចាស់អើយ ស្តេចនឹងបានយល់ស្ទឹងមួយ ដ៏មានទឹកនោះហូរចុះមកអំពីភ្នំវង្កតនោះឯង អណ្តាប់នោះ ស្តេចនឹងបានយល់ស្រះបោក្ខរណី ដ៏មានទន្លាស្នាយទឹក ពេញនីទៅនូវត្រីផងទាំងឡាយសឹងដ៏ធំ ៗ ស្រះនោះសោត មានមុំ ៤ មានច្រាំងទាប មានកំពង់រាបស្រណុក មានទឹកនោះច្រើន ដ៏ប្រកបនីទៅនូវក្លិនភ្ញីផ្កាផងទាំងឡាយ ៗ បពិត្រអម្ចាស់អើយ កាលបើអម្ចាស់ទៅដល់ឋាននោះហើយ ចូរអម្ចាស់សម្រាន្ត នៅនាទិសឯជើងនៃស្រះបោក្ខរណីនោះ អម្ចាស់ស្វែងរកមើមឈើ ផ្លែឈើទាំងឡាយ សោយចិញ្ចឹមជីវិត នៅនាឋាននោះឯង ស្រណុកសុខសប្បាយ មហិមាក្រៃពេកហោង ៗ

ឯវំ ចេតរាជានោ តស្ស បណ្ណាសយោជនមគ្គំ អាចិក្ខិត្វា បពិត្រអើយ រីអស់ស្តេចចេតរាស្ត្រ ផងទាំងឡាយ ទូលបង្ហាញផ្លូវ ១៥ យោជន៍ ប្រាប់ព្រះពោធិសត្វមហាបុរសរ័ត្នស្រេចហើយ ក៏ជូនដំណើរព្រះពោធិសត្វទៅ ៗ រីព្រះពោធិសត្វសោត ទ្រង់ស្តាប់ពាក្យស្តេចចេតរាស្ត្រហើយ ក៏ស្តេចមានព្រះបន្ទូលលា លីលាទៅហោង ៗ ពួដ៏កាលនោះ រីអស់ស្តេចចេតរាស្ត្រទាំង ៦ មុឺននោះ មកពិចារណាថាដូច្នេះ ភោន្តោ រាជានោ ហៃអស់មហាក្សត្រផងទាំងឡាយអើយ បើដោយយើងគិតនេះហើយ សមសត្រូវ

ផងទាំងឡាយ ខ្លាចក្រែងវាតាមមកធ្វើទុក្ខ ធ្វើទោសព្រះអង្គនៅនាកម្លុងព្រៃនោះហោង ៗ មហាក្សត្រទាំង ៦ មុឺននោះ គិតព្រមគ្នាដូច្នោះហើយ ស្ដេចឱ្យជ្រើសរើសយកកូនអ្នកស្រុកចេតរាស្ត្រមួយនាក់ ឈ្មោះចេតបុត្ត ជាអ្នកឈ្លាសខាងសិល្បៈធ្នូ បាញ់មុតមែនក្វែនស្ទាត់ ស្ដេចបន្ទូលផ្ដាំដូច្នេះថា ហៃបាចេតបុត្តអើយ បាឯងជាអ្នកឧស្សាហ៍ព្យាយាមដើរត្រាច់រង្គាត់ច្រវាត់ទៅមក រកបរបាញ់ម្រឹគបក្សី ចូរបាយកអាសាយើងទៅនៅនាទ្វារព្រៃនោះហើយ បាពិចារណាឱ្យដឹងអស់សេចក្ដីទោះអ្នកឯណាមួយដើរចូលទៅក្ដី ទោះយោបីអ្នកដំណើរថ្មើរព្រៃក្ដី ក៏ចូរបាពិចារណាឱ្យជាក់ ខ្លាចវាទៅធ្វើទុក្ខ ធ្វើទោសព្រះបាទស្រីវេស្សន្តរនោះហោង ៗ បពិត្រអើយ រីក្សត្រទាំង ៦ មុឺននោះ គិតជំនុំព្រមគ្នាដូច្នោះហើយ ប្រើចៅចេតបុត្តឱ្យទៅនៅចាំរក្សាទ្វារព្រៃនោះហើយកូវ ក៏វិលត្រឡប់ទៅកាន់ព្រះនគរអាត្មាវិញហោង ៗ

វេស្សន្តរោបិ សបុត្តទារោ គន្ធមាទនំ បត្វា

បពិត្រអើយ ព្ធដ៏កាលនោះ ព្រះបាទស្រីវេស្សន្តរ ស្ដេចចេញទៅមួយអន្លើនឹងព្រះរាជបុត្រព្រះរាជទេពី ទៅឈប់សម្រាន្តព្ធដ៏ភ្នំគន្ធមាទន៍បព៌ត លុះព្រឹកព្រហាមឡើង ស្ដេចលីលាឆ្ពោះទៅដោយទិសឧត្ដរ ខាងឯជើងភ្នំវិបុលបព៌តនោះហោង ៗ ស្ដេចទៅគង់នាឆ្នេរស្ទឹងកេតុមតីនទី កាលនោះ មានថ្មើរ-

ព្រៃ ១ មកថ្វាយសាច់ក្រៀមនិងទឹកឃ្មុំផ្លិត ព្រះអង្គសោយលោមព្រះរាជបុត្រព្រះរាជទេពី ហើយព្រះអង្គស្ទាបព្រះកេសាប្រវាយកងស្នៀតសក់មាសមួយមក ព្រះរាជទានទៅថ្មើរព្រៃនោះហើយ ស្ដេចនាំព្រះរាជបុត្រព្រះរាជទេពីចុះទៅស្រង់ទឹកបន្ទោបង់នូវញើសក្អែលស្រេចហើយ ស្ដេចឡើងមកគង់សម្រាន្តបន្តិចនាម្លប់ជ្រៃមានព្ធដ៏ខាងភ្នំនោះ ស្ដេចឈោងបេះផ្លែឈើមកសោយ មួយអន្លើនឹងព្រះរាជបុត្រព្រះរាជទេពី ស្រេចហើយស្ដេចទៅដល់ភ្នំនាលិកបព៌ត ស្ដេចដើរកន្លងអំពីនោះទៅដល់មុចលិន្ទស្រះស្រង់ ត្រង់មុំឧត្តរ ស្ដេចដើរដោយព្រៃនោះទៅកូវ យល់ផ្លូវមួយចុះតែជើងអ្នកមួយដើរទៅបានហោង ស្ដេចដើរកន្លងពីទីនោះទៅដល់ជ្រោះភ្នំមួយ ដ៏ជាកំណើតនៃស្ទឹងផងទាំងឡាយ ដ៏មានទឹកនោះហូរពុំដែលដាច់ឡើយ ហើយព្រះអង្គដើរកន្លងរំលងអំពីនោះទៅឯភ្នែក ដល់ឆ្នេរស្រះបោក្ខរណីនោះហោង ។

តស្មឹ ខណេ សក្កភទនំ ឧណ្ហាការំ ឧស្សេសិ បពិត្រអើយ កាលណាបើព្រះពោធិសត្វមហាបុរសរ័ត្នវិសេសស្ដេចចូលទៅដល់ភ្នំវង្កតបព៌តនោះហើយ រីបណ្ឌុកម្ពលសិលាអាសន៍ ដ៏ជាអាសនៈនៃសម្ដេចអមរិន្ទ្រាធិរាជ ដ៏ជាក្រឡាគម្ដែងនៃព្រះនាងសុជាតា ក៏កើតជានិមិត្តក្ដៅក្រហាយ នឹងគង់នៅជាសុខសប្បាយពុំបានឡើយ ។ ក្សិណនោះ ព្រះ

ឥន្ទ្រាធិរាជ ដ៏ជាអម្ចាស់នៃទេវតាផងទាំងឡាយ ស្តេចទ្រង់ព្រះចិន្តាពិចារណាថា ឱ! នាកើតកោលាហលវល់អស្ចារ្យទាំងម្ល៉េះ សមជាព្រះមហាក្សត្រស្តេចចូលមកកាន់ព្រៃព្រះហេមពាន្តនេះឯង ៗ ឱ! ដូចអញគិតនេះហើយ រីឋាននេះ ក៏សមគួរនឹងព្រះមហាក្សត្រព្រះអង្គគង់សាងព្រះផ្នួសហោង ៗ កាលនោះ សម្តេចព្រះឥន្ទ្រាធិរាជ តែងនឹងទ្រង់បំពេញបារមីនៃព្រះពោធិសត្វរៀងមក ស្តេចបន្ទូលហៅព្រះវិស្សកម្មទេវបុត្រថាដូច្នេះ **គច្ឆ តាត ត្វំ វង្កតបព្វតកុច្ឆិម្ហិ រម្មណីយេ ឋានេ អស្សមបទំ មាបេត្វា ឯហីតិ វិស្សកម្មំ បេសេសិ** ថាម្នាលវិស្សកម្មទេវបុត្រអើយ ចូរអ្នកទៅកាន់ឋានមនុស្សលោក ហើយសាងអាស្រមបទនៅនាចង្កេះភ្នំគិរីវង្កត ឱ្យជាទីក្សេមសម្រាន្តព្រះទ័យនៃព្រះមហាសត្វហោង ៗ

សោ សាធូតិ សម្បដិច្ឆិត្វា ទេវលោកតោ ឱតរិត្វា បពិត្រអើយ រីព្រះវិស្សកម្មទេវបុត្រទទួលនូវព្រះបន្ទូលសម្តេចព្រះឥន្ទ្រាធិរាជហើយ ឆ្លើយថា សាធុ ៗ គាប់ហោង ស្រេចហើយហោះមកអំពីសួគ៌ទេពលោកនាយ ចូលទៅកាន់កម្លុងក្នុងព្រៃភ្នំវង្កតបព៌តនោះ ហើយនិម្មិតបរមសាលានោះពីរ ឋានចង្ក្រមនោះពីរ គឺមួយជាលំនៅយប់ មួយជាឋានក្រសាលថ្ងៃ រីចុងចង្ក្រមន៏សោត ដ៏ប្រដាប់នីទៅនូវឈើផងទាំងឡាយ ដ៏វិចិត្រនូវផ្លែផ្កានោះផ្សេង ៗ ដ៏ប្រកបនីទៅនូវចេកស្អែង ចេក-

ដងខ្លែង ចេកកាបូរ ចេកឥតត្រយូង ចេកអំបូង ចេកស្នែងពពែ ចេករាជសីហ៍ ចេកមហាថ្លៃ ចេកម្រាមដៃនាង ចេកផេះ ចេកនួន ចេកពងមាន់ ដ៏មាននូវអំពៅតំឡាន់ អំពៅក្ដាម អំពៅត្រែង ដ៏ប្រកបនីទៅនូវដំឡូងទៀន ដំឡូងទឹក ដំឡូងពងលលក ដំឡូងពងប្រវឹក ដំឡូងបាស ដំឡូងក្រាមរមាស ដំឡូងដៃខ្លា ដំឡូងខ្យា ដំឡូងស្រំ ផ្សំនូវដំឡូងស្រូវ ដំឡូងឈាមមាន់ រាជព័ន្ធនូវដំឡូងពស់ ដំឡូងផ្កា ស្រេចសព្វគ្រប់ព្រមទាំងគ្រឿងបរិក្ខារអ្នកបួសនោះហោង ៗ ស្រេចហើយ ក៏សរសេរត្រាត្រួចផ្ដួចធ្វើជាអក្ខរានៅនាខ្លោងទ្វារព្រះបរមសាលានោះថាដូច្នេះ យេ កេចិ បព្វជិតុកាមា តេ ឥមេ គណ្ហន្តុ រីជនទាំងឡាយឯណានីមួយ មានប្រាថ្នានឹងបួសនៅឰដ៏ឋាននេះ សូមឱ្យជនអស់នោះគួរគប្បីទទួលយកទីឋានអស់នេះចុះ ៗ រួចព្រះវិស្សកម្មទេវបុត្រ ក៏ដេញបង្អើលអស់ខ្មោចបិសាច នូវម្រឹគបក្សីសាហាវទ្រើសឃ្នង គួរគប្បីស្ញើម គួរគប្បីខ្ពើមខ្លាច ក៏បណ្ដេញឱ្យទៅនៅនាព្រៃឆ្ងាយអំពីព្រះបរមសាលាព្រះមហាបុរសរ័ត្ននោះហោង ៗ

សោ វិស្សកម្មោ សកដ្ឋានមេវ គតោ បពិត្រអើយរីព្រះវិស្សកម្មទេវបុត្រ ប្រដាប់ស្រេចនូវប្រការ អម្បាលនោះហើយ ហោះផ្សងទៅកាន់សួគ៌ទេពលោកនាយ ដ៏ជាឋានពិមាននៃអាត្មាវិញហោង ៗ

មហាសត្តោបិ ឯកបទិកមគ្គំ ទិស្វា បព្វជិតានំ វសនដ្ឋានំ ភវិស្សតីតិ សល្លក្ខេត្វា បពិត្រអើយ ឰដ៏កាលនោះ រីព្រះមហាសត្វ ស្តេចយល់ផ្លូវចុះតែជើងអ្នកមួយដើរចូលទៅនោះហើយ ព្រះអង្គគិតថា ឱ! ឋាននេះអើយ គួរតែជាលំនៅនៃអ្នកបួស ពិតប្រាកដ ៗ ព្រះមហាក្សត្រ ទ្រង់រំពឹងពិចារណានូវប្រការអម្បាលនោះហើយ ព្រះអង្គទុកសម្តេចព្រះរាជមទ្រីទេពី នូវព្រះរាជបុត្រទាំងពីរ នៅឰដ៏ទ្វារអាស្រមបទនោះ ហើយស្តេចចូលទៅតែមួយព្រះអង្គឯង ទ្រង់រមិលមើលយល់អក្សរនៅឰដ៏ខ្លោងទ្វារព្រះបរមសាលានោះកូរ ស្តេចទ្រង់ព្រះចិន្តាពិចារណាថា ឱ! ឋាននេះហើយ មិនអង្គី អ្នកឯណាឡើយ គឺព្រះឥន្ទ្រាធិរាជឯង លោកមករណ្តាប់ឱ្យជាឋានលំនៅអ្នកបួសហោង ស្តេចទ្រង់ព្រះចិន្តាដូច្នោះហើយ ក៏បើកទ្វារព្រះបរមសាលា ចូលទៅដាក់ព្រះខ័ននិងបំពង់ យកព្រះកៅទណ្ឌអំពីព្រះអង្សាចេញហើយ ស្តេចផ្លាស់សំពត់បរិសុទ្ធនោះចេញ ស្តេចយកសំពត់ជ្រលក់អម្ពត់នោះមកទ្រង់ ស្រេចហើយ ព្រះអង្គយកស្បែកខ្លាទាំងក្រចកមកស្ពាយឆៀង ឰដ៏ស្មាឆ្វេង ហើយចងព្រះកេសាជដាមណ្ឌល ជាមហាឥសីទ្រង់ឈើច្រត់ឫសីក្រហមល្អបីដូចផ្លែព្នៅទុំ ហើយស្តេចចេញអំពីក្នុងបរមសាលា មកគង់នៅនាថ្មដា ① ឰដ៏ទ្វារបរម-

---

① ច្បាប់ខ្លះថា " គង់នៅនាក្តារថ្ម " ដូច្នេះក៏មាន ។

សាលានោះ ស្តេចមានសេចក្តីបីតិត្រេកអរថា **អហោ** ឱដូចអញ្ចគិតនេះហើយ រីផ្នួសអញ្ចនេះ បរិបូណ៌ក្សេមប្រសើរ ពេកណាស់ ៗ ក្សិណនោះ ស្តេចឡើងលើថានចង្ក្រម ហើយស្តេចដើរចង្ក្រមទៅទៀប ព្រះរាជបុត្រ ព្រះរាជទេពី យល់ល្អដូចព្រះបច្ចេកពោធិ ប្រពៃពេកហោង ៗ

មទ្ទី ទេវីបិ ឱលោកេន្តី សព្វានិត្វា មហាសត្តស្ស បាទេសុ និបតិត្វា បពិត្រអើយ ព្ធដ៏កាលនោះ សម្តេចព្រះភគវតីព្រះនាងមទ្រី ដ៏ជាក្សត្រីមានលក្ខណាប្រពៃ ព្រះនាងរមិលមើលទៅយល់ព្រះមហាក្សត្រហើយ ព្រះនាងទ្រង់ព្រះកន្សែងសោកា ហើយចូលទៅក្រាបនៅក្រោមព្រះបាទព្រះមហាក្សត្រ ហើយព្រះនាងបណ្តើរព្រះរាជបុត្រទាំងពីរទៅនៅនាព្រះបរមសាលាដ៏សមគួរនឹងអាត្មា ទើបព្រះនាងទ្រង់នូវសំពត់សំបកឈើគិតដ៏អ្នកក្រងនីទៅនូវស្បូវភ្លាំង ស្លាយឆៀងនូវស្បែកខ្លាទាំងក្រចក ក្រវាត់ស្បូវភ្លាំងជាវត្ថពន្ធ ហើយនាងចងព្រះកេសាជដាមណ្ឌលតម្កល់ជាឫសី បរិបូណ៌ស្រេចហើយ ទើបបំបួសរាជកុមារទាំងពីរ ជាតាបសកុមារ ឯក្រោយហោង ៗ

ចត្តារោ ខត្តិយា វង្កបព្វតកុច្ឆិយំ វសឹសុ រីក្សត្រទាំង ៤ ព្រះអង្គ ស្តេចយាងទៅសាងព្រះផ្នួសបួសជាតាបសឫសី នៅនាព្រៃភ្នំគិរីវង្កតបព៌ត ៗ អណ្តាប់នោះ ព្រះនាងមទ្រីទេវី ក្រាបទូលសូមបម្រើព្រះមហាក្សត្រថាដូច្នេះ បពិត្រព្រះមហាឫសី

អើយ ចាប់ដើមតាំងអំពីថ្ងៃនេះទៅ កុំបីព្រួយព្រះរាជហឫទ័យទៅព្រៃស្វែងរកផ្លែឈើមើមឈើនោះឡើយ ចូរអម្ចាស់បន្លែងក្មេងទាំងពីរនៅនាអាស្រមបទ ធានាលើខ្លួនខ្ញុំអម្ចាស់ឯងនឹងដើរទៅស្វែងរកផ្លែឈើមើមឈើ នាំមកចិញ្ចឹមអ្នកទាំងបី នៅឰដ៏អាស្រមបទនេះហោង ៗ ឰដ៏កាលនោះ ព្រះមហាក្សត្រព្រះអង្គ បន្ទូលនូវក្រឹត្យផ្ដួសនឹងព្រះនាងមទ្រីវិញថា ហៃនាងអើយ ចាប់ដើមអំពីថ្ងៃនេះទៅ ថាបើពុំជូកាល កុំអាលមកកាន់អញណា ត្បិតយើងទាំងពីរនេះ បានបួសជាមហាឫសីហើយ នាងអើយ នាបីហៅថាស្ត្រីទាំងឡាយនោះ រមែងតែងនឹងជាមន្ទិលនៃអ្នកបួសក្ដាត់ហោង នាងអើយ ចាប់ដើមតាំងអំពីថ្ងៃនេះទៅ ថាបើពុំជូកាល កុំអាលនាងមកកាន់អញឡើយ ៗ ក្សិណនោះ សម្ដេចព្រះរាជមទ្រីទទួលយកព្រះបន្ទូលថា សាធុ ៗ ពីរោះពេកហោង ៗ

មហាសត្តស្ស មេត្តានុភាវេន សមន្តា តិយោជនដ្ឋានេ សព្វេ តិរច្ឆានាបិ អញ្ញមញ្ញំ មេត្តចិត្តំ បដិលភឹសុ ឰដ៏កាលនោះ ព្រះមហាសត្វព្រះអង្គសឹងសូត្រមន្តចម្រើនមេត្តាភាវនា នៅនាព្រៃនោះកាលឯណាមិញ វីអស់សត្វតិរច្ឆានផងទាំងឡាយអម្បាលម៉ាន ពីដើមនោះ វែងតែងនឹងបៀតបៀនគ្នា ក៏ប្រែខ្វៃជាមិត្រមេត្រីទៅមកកាន់គ្នាវិញ ៗ បពិត្រអើយ វីអស់សត្វតិរច្ឆានទាំងឡាយ នៅឰដ៏ឋានជុំវិញ

មានចម្ងាយនោះបីយោជន៍ ហេតុតែដោយនូវអានុភាពព្រះមហាក្សត្រចម្រើនមេត្តាភាវនា អស់ម្រឹគាសឹងតែបណ្ដាលជាមេត្រីនឹងគ្នា ទៅវិញទៅមកហោង ។

មទ្ទី ទេវី បាតោ ច ឧដ្ឋាយ បានីយំ បរិភោជនីយំ ឧបដ្ឋបេត្វា បពិត្រអើយ រីនឹងស្រដីឯក្រឹត្យសម្ដេចព្រះភគវតីព្រះនាងមទ្រី បម្រើព្រះបរមពោធិសត្វនោះ នាកាលព្រឹកព្រហាមអរុណោទ័យថ្ងៃរះឡើង ព្រះនាងដោះឡើង ទៅបោសអាស្រមបទ ហើយដងទឹកស្រង់ទឹកឆាន់ លើកទឹកស្ងន្តទៅប្រគេនព្រះមហាក្សត្រ ស្រេចហើយ ទើបព្រះនាងក្រឡាប់វិលមកប្រវាឱបក្រសោបព្រះរាជបុត្រទាំងពីរនោះថើប ហើយផ្ដាំថា តាត បិយបុត្តក ថាហៃកូនស្ងួនសំឡាញ់ម្ដាយទាំងពីរអើយ កុំបាប្រហែសធ្វេស ទៅលេងឆ្ងាយ អំពីព្រះជនកបាឡើយ ព្រះនាងផ្ដាំដូច្នោះហើយ ក៏ទ្រង់ពនាងក្រស្នា បណ្ដើរបាជាលី នាំទៅផ្ញើនឹងព្រះមហាក្សត្រ ហើយទូលថា បពិត្រព្រះរាជឫសីអើយ កុំបីព្រះអង្គប្រហែសព្រះរាជបុត្រ ទាំងពីរឡើយ កុំឱ្យទៅលេងឆ្ងាយពីព្រះបាទព្រះអង្គឡើយ ។ ព្រះនាងទូលផ្ដាំព្រះមហាក្សត្រស្រេចហើយ ព្រះនាងយកកញ្ឆើសង្រែក ដងវែក ដាក់លើព្រះអង្សា ព្រះហស្ដប្រវាកាន់ទម្លក់និងជ្រនីក ម្ដីម្ដាចូលទៅក្នុងកម្លុងព្រៃ ស្វែងរកផ្លែឈើ មើមឈើ បានពេញកញ្ឆើនាំមកដាក់នៅអាស្រមបទនោះ ស្រេច

ហើយ ទើបព្រះនាងពព្រះរាជបុត្រទាំងពីរទៅផ្ងូតទឹកពពឹកភ្នែក ស្រេចហើយ ព្រះនាងពឡើងមកហោង ៗ បពិត្រអើយ រីក្សត្រទាំង ៤ ព្រះអង្គ សឹងទៅជំនុំគ្នា នាព្រះបរមសាលាហើយ ក៏សោយនូវផ្លែឈើមើមឈើទុំខ្ចីនោះហោង ៗ

តតោ មទ្ទី ទ្វេ បុត្តេ គហេត្វា អត្តនោ បណ្ណសាលំ គច្ឆតិ បពិត្រអើយ រីក្សត្រទាំង ៤ អង្គ ទ្រង់សោយស្រេច ហើយ ទើបព្រះនាងបណ្តើរព្រះរាជបុត្រទាំងពីរ ទៅសិង ឯបរមសាលារបស់ព្រះនាងវិញ ៗ

ឥមិនា ច និយាមេន តេបិ ចត្តារោ ខត្តិយា វង្កតបព្វតកុច្ឆិម្ហិ សត្ត មាសេ វសីសុ បពិត្រអើយ រីក្សត្រទាំង ៤ ព្រះអង្គនោះ ទៅសិងនៅព្ឋដ៏ភ្នំគិរីវង្កតបព៌តនោះ កំណត់ ៧ ខែ ដោយនូវដំណើរនិទាន ដែលយើងបានស្រដីមកនេះឯង ៗ

វនប្បវេសនកណ្ឌំ និដ្ឋិតំ បពិត្រអើយ អាត្មាភាពសំដែងថ្លែងព្រះធម៌វិសេសទេសនា ព្រះមហាជាតក៏ **កណ្ឌវនប្បវេសន៍** ដ៏ប្រដាប់ប្រដានូវព្រះគាថា ៥៧ ព្រះគាថា ក៏ចប់បរិបូណ៌ដោយសមគួរ នៅវេលានេះឯងហោង ៗ

ចប់ កណ្ឌវនប្បវេសន៍ ទី ៤ តែប៉ុណ្ណោះ ៗ

ចម្លងចប់នៅថ្ងៃ ១៤ រោច ខែអាសាធ ព.ស. ២៥៣៣
ត្រូវនឹងថ្ងៃសៅរ៍ ទី ២១ ខែកក្កដា គ.ស. ១៩៩០

មហាវេស្សន្តរជាតក

ទី ៥



កណ្ឌជូជក

ប្រដាប់ដោយគាថា ៥៩

មហាវេស្សន្តរជាតក

ទី ៥

កណ្ឌជូជក

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

តទា កលិង្គរដ្ឋេ ទុន្និវិដ្ឋព្រាហ្មណគាមវាសី ជូជកោ នាម ព្រាហ្មណោ ភិក្ខាចរិយាយ កហាបណសតំ លភិត្វា ឯកស្មឹ ព្រាហ្មណកុលេ ឋបេត្វា បុន ធនំ បរិយេសនត្ថាយ គតោ ។ តស្មឹ ចិរាយន្តេ ព្រាហ្មណកុលំ កហាបណេ វលញ្ជេត្វា បច្ឆា ឥតរេន អាគន្ត្វា ចោទិយមានំ កហាបណេ ទាតុំ អសក្កោន្តំ អមិត្តតាបនំ នាម ធីតរំ តស្ស អទាសិ ។

តទា កាលេ នាកាលព្រះបរមពុទ្ធង្កុរបណ្តូលជិនវង្សដ៏ជាអង្គព្រះជិនស្រី ក្សត្រាក្សត្រីទាំង ៤ ព្រះអង្គ ស្តេចចេញចោលព្រះញាតិវង្ស ទៅទ្រង់ព្រឹទ្ធនៅភ្នំគិរីវង្កត ដ៏ជាទីរហោឋាន ពុំមានម្រឹគពាឡយង់ឃ្នង មកបៀតបៀនពាធា ។ ឯកោ ព្រាហ្មណោ មានព្រាហ្មណ៍ម្នាក់ ឈ្មោះ ជូជក ព្រឹទ្ធាចារ្យ រូបអន្ធការ ស្គមច្រងោង ច្រមុះកោង ទ្រូងសឹងតែឆ្អឹង សក់រឹងក្រញាង ពោះធំកំប៉ោង លោងសំពៀត ដំបារ

ត្រចៀកយុរយារក្រាស់ ដូចឃ្លង់ភ្លើង ជើងកោង ដូចជើងសេក ភ្នែកស្រលៀងស្រលើ សាច់ពកដូចគេផ្ញើ រដិបរដុបយុរយារប៉ុនផ្លែក្រសាំងផ្លែស្រម៉ ធ្មេញស ក្បាលវែងតូចម្ខាង ដូចផ្លែព្នៅ គាត់នៅស្រុកទុន្នវិដ្ឋព្រាហ្មណគ្រាម ជិតនឹងស្រុកកលិង្គរាស្ត្រ គាត់តែងនឹងដើរសូមទានគេ ថាបើពុំបានឯស្រុក គាត់ទៅឯវត្តអ្នកយើង ពុំបានឯជើង គាត់ទៅឯត្បូង ពុំបានឯទ្រទូង គាត់ទៅឯសាមណោរ ពុំបានឯថេរ គាត់ទៅឯដូនជី គាត់ដើរសូមតែគេឆីដោយសព្វជើងជណ្តើរ គាត់សូមទាំងត្រីឆ្អើរ ត្រីងៀត ត្រីប្រែ ស្លឹកគ្រៃ ខ្ទី ម្រេច ម្ទេស អំបិល ក្រសាំង អំពិល ពុំឱ្យសល់ដល់មួយមុខឡើយ គាត់សូមបានមកស្រេចហើយ គាត់សន្សំច្រកទុកក្នុងថង់យាមធំ គាត់ដើររកសូមគ្រប់ផ្សារផ្សោ គ្រប់ស្រុក សូមទាំងប្រហុកផ្អកម៉ាំ សន្សំច្រកទុកក្នុងផ្អាំង សូមទាំងស្លាម្លូ ស្លាផ្វា កំបោរ ថ្នាំ តាមតែចិត្តនឹក សូមទាំងផ្លូវទឹកផ្លូវគោត ហើយគាត់ដឹង ទាំងយាមយោគយាត្រា ចេះគូរជតារាសី ចេះស្រដីផ្សែផ្សំបញ្ចូលចិត្ត គាត់ដើរសូមមួយថ្ងៃ ១០ ត្រឡប់ លុះតែបានគ្រប់ហ្មងស្លឹង គិតជាមាសបាន ១០០ តម្លឹង ជាលាភតាព្រឹទ្ធាចារ្យ គាត់នឹងរាប់ទុកក្រែងវាខូចអសារឥតការ នឹងផ្ញើទុកនៅអ្នកឯណាពុំបាន នឹងយកជាប់ទៅដោយខ្លួនប្រាណក៏តែម្នាក់ឯង ក្រែងជួនប្រទះនឹងសត្រូវវាប្លន់យក ។

សហាយគោ (១) អើ ! សំឡាញ់យើង ក៏មាននៅនាឋាននោះ លួមទុកចិត្តផ្ញើទ្រព្យ ក៏បានអេះ គាត់គិតស្រេចដូច្នោះហើយ ទើបគាត់យកមាសមកច្រកផង់ចងខ្ចាប់ ស្រេចហើយ ពុំលង់ឡើយ តាព្រឹទ្ធាចារ្យ យកទៅផ្ញើនឹងត្រកូលព្រាហ្មណ៍ប្តីប្រពន្ធទាំងពីរនាក់ ទើបតាជូជក គាត់និយាយផ្តាំថា នែសំឡាញ់អើយ មាសអញ ១០០ តម្លឹងនេះ អញសុំផ្ញើនឹងអ្នក បើអញសុខសប្បាយ ពុំគ្រុនរងាទេ អញវិលមកដល់កាលណា អញនឹងសុំយកអំពីអ្នក ក្នុងកាលនោះ ៗ ឯត្រកូលព្រាហ្មណ៍ទាំងពីរ រាប់មើលឃើញជាក់ហើយ ក៏ទទួលយកមាសតាព្រឹទ្ធាចារ្យទៅរក្សាទុក ៗ ឯតាជូជក គាត់ទៅស្វែងរកលាភសព្វឋាន ឱ្យបានវិញទៀតហោង ៗ បពិត្រអើយ រីឯមាសតាជូជកដែលគាត់ផ្ញើឱ្យត្រកូលព្រាហ្មណ៍ទាំងពីររក្សាទុកនោះ ឧបមាបីដូចអ្នកយកភ្លើងមកដាក់ក្នុងផ្ទះ ឱ្យកើតក្តៅក្រហាយពុំក្សេមក្សាន្ត ទោះទ្រព្យរបស់អំពីដើមប៉ុន្មាន ៗ ក្តី ក៏យកចេញចាយ ពុំមានសេសសល់សំណល់ ដល់តិចឡើយ ហើយវាកើតជាទុព៌លពន់ប្រមាណ មានតែខ្លួនប្រាណប្តីប្រពន្ធនិងកូនក្រមុំមួយជាបីនាក់ ទើបគិតថា មាសតាព្រឹទ្ធាចារ្យដែលគាត់ផ្ញើនឹងយើងនោះ ឥឡូវ គាត់បាត់យូរឆ្នាំណាស់ហើយ

១- ស័ត្វនេះមិនឃើញមានប្រាកដក្នុងជាតកបាលីទេ តែច្បាប់មហាជាតក៏សម្រាយ តែងតែឃើញមានស័ត្វនេះ ជាច្រើនច្បាប់ ៗ

ពុំនោះឡើយ ក្រែងគាត់ស្លាប់បាត់ខ្ចាត់ខ្ចាយ ទើបពុំឃើញវិលមកទារមាសវិញឡើយ បើដូច្នោះហើយ មានតែយើងនឹងយកមាសដែលគាត់ផ្ញើទុកទៅទិញឦចុកលក់ទន្និញ បើគាត់វិលមកកាលណាមិញ សន្សឹមយើង រកសងឱ្យគាត់ គិតស្រេចដូច្នោះហើយ ពុំលង់ឡើយ ក៏យកមាសទៅចាយវាយ ឦចុកអស់ទៅ ឥតសេសសល់សំណល់ដល់តិចឡើយ ៗ

បច្ឆា ឥតរេន អាគន្ត្វា បពិត្រអើយ រីឯតាជូជកចាស់ជរា ស្វែងរកទ្រព្យ រៀង ៗ មក បានគ្រប់ហើយ គាត់ត្រឡប់វិលមករកត្រកូលព្រាហ្មណ៍ទាំងពីរវិញ ហើយទើបដណ្ដឹងថា អើសំឡាញ់ អើសំឡាញ់ មាសអញដែលផ្ញើទុកនឹងអ្នក អញសុំយកអំពីអ្នក ឥឡូវនេះហោង ៗ ឯត្រកូលព្រាហ្មណ៍ប្ដីប្រពន្ធធ្វើជាស្រដីថា អើ ! អ្នកតាមកដល់ហើយហៈ ឱ ! អ្នកតាអើយ ពីក្រោយអ្នកតាទៅនោះ ខ្ញុំមានសេចក្ដីក្រីក្រលំបាកតោកយ៉ាកពេកពន់ប្រមាណ អម្ចាស់ខ្ញុំអើយនឹងរកអ្វីឦបន្តិចបន្តួចក៏ពុំបាន ពីដួចខ្ញុំកើតមក ពុំដែលខ្សត់ដល់ម្ល៉េះឡើយ អម្ចាស់ខ្ញុំអើយ មាសដែលអម្ចាស់ផ្ញើទុកនឹងខ្ញុំនោះ ខ្ញុំយកទៅលក់ដូរឦចុកអស់ហើយ អម្ចាស់ខ្ញុំអើយថាបើដល់ឆ្នាំថ្មី ត្រជាក់ជើងដៃ ខ្ញុំបានស្រូវស្រែ ស្រូវចំការ ដួញប្រែលលក់ទន្និញបានកាលណាមិញ សន្សឹមខ្ញុំសងអ្នកតាកាលនោះ ៗ

ឯជូជកព្រាហ្មណ៍ពោលឡើងថា ស្រដីដូច្នោះ ទេហ្ន៎ះ ព្រាហ្មណ៍ក្រេវក្រោធចងចិញ្ចើមជិត ដៃចាប់ឈើច្រត់និងយាម ស្រដីគម្រាមគង្គួន គាត់ធ្វើជាមួនទួនមាំទាំ ខាំមាត់ក្រអឺត ស្លើតទាំងត្របកភ្នែក ដូចគេហែកឡើងទៅលើ គាត់ធ្វើមែនទែន មាំទាំទៀងទាត់ គាត់លាត់ទាំងសំពត់បង្ហាញទាំងដុំដៃទៅ ព្រាហ្មណ៍ ស្រដីគម្រាមថា ① នែបើពុំបានឱ្យអញៗពុំលែងឡើយ បើអញចូលទៅហើយ អញនឹងទៅប្ដឹងចៅក្រម ឱ្យមកចាប់យកទៅជំនុំពិចារណាពិភាក្សា ចៅក្រមសាលាអញស្គាល់អស់ហើយ ឱព្រាហ្មណ៍អើយ ពុំដែលស្គាល់គុកតាងរាងខ្នោះឃ្នាងច្រូលច្រវាក់ តើអ្នកនឹងទប់ម្ដេចបាន ភ្នាក់ងារទាហាន ក៏នឹងវាយដំបែកជាឈាម ជូជកស្រដីគម្រាម ឱ្យតែព្រាហ្មណ៍ខ្លាចតែដោយនូវវាចា ឧបមាបីដូចគូររូបខ្លា

១- សាស្ត្រាច្បាប់ខ្លះ មានបរិយាយប្លែកគ្នាដូច្នេះ " នែបើពុំបានឱ្យអញៗពុំលែងឡើយ បើអញចូលទៅហើយ អញនឹងទៅប្ដឹងឧកញ៉ាសុភាមន្ត្រីទេពភក្ដី នូវជំទប់នឹមសឹមអញទៅប្ដឹងឯអាជ្ញាសាលាអាច អញគេចទៅឯឧកញ៉ាក្រឡាពាសសៅ ហៅភ្នាក់ងារទាហានមាននូវកួយបាឡាត់ តែងបញ្ជាក់ដណ្ដឹងសព្វសេចក្ដី ឯការវាយដំធាក់ទៅលើនាយវ៉ា បើវាយខ្វាប់មកត្រង់ណា វាផ្សា រលេញ វាឆ្វាញ់បង្ហួញរញ្ញអស់ទាំងខ្លួន ស្ដៀតសង្កៀតទាំងធ្មេញ រីឯព្រលឹងទាំង ១៩ នោះមិញ ក៏រត់ព្រាត់ព្រាយប្រញាប់ចេញទៅស្ទើរពុំគង់នៅនឹងខ្លួន ៗ ជូជកស្រដីគង្គួនគម្រាម ឱ្យតែព្រាហ្មណ៍ខ្លាចដោយវាចា ឧបមាបីដូចគូររូបខ្លាឱ្យគេខ្លាច ៗ

ឱ្យគោខ្លាច ៗ ឯត្រកូលទាំងពីរនោះ ពុំអាចនឹងទប់ទល់បានឡើយ ហើយគិតគ្នាថា យើងបានទ្រព្យអ្វី នឹងយកទៅលក់ឱ្យតាជូជកនេះ សំពត់នៅចង្កេះក៏ចាស់ដាច់ដាច ថាសផ្តិល ក៏បែកបាក់ ប្រណាកអកកំបោរ ក៏ឆែបឆា ជាទ្រព្យអន្ធការ នឹងចាយវាយពុំបាន នឹងលក់ខ្លួនប្រាណ ក៏ពុំដាច់ បើដូច្នេះ តើនឹងគិតធ្វើដូចម្តេច ភាណាអើយ បើគិតទៅហើយ មានតែកូនសំឡាញ់យើង គឺនាងអមិត្តតាបនានេះមិញ ជាកូនសំឡាញ់យើង ៗ នឹងលើកឱ្យតាជូជកចាស់ជរា ជាភរិយាគាត់សិនចុះ បើដូច្នោះ យល់ជាគាត់នឹងត្រេកអរពេញចិត្ត ត្បិតគាត់ក៏ចាស់ជរា ឯភរិយា ក៏ក្រមុំព្រហ្មចារី យល់បានដូចសេចក្តីប្រាថ្នាគាត់ គាត់ស្លាប់កាលណា សឹមយកកូនយើងមកវិញអេះ ត្បិតព្រាហ្មណ៍នេះ គាត់ក៏ចាស់ជរាណាស់ហើយ កាលណាឡើយ ក៏គាត់រស់នៅជាមនុស្សយឺនយូរទៅឯមុខ ទុកជាគេនិន្ទាថា នាងអមិត្តតាបនា បានប្តីចាស់ក៏ដោយកលអេះ ឱ្យតែបានរួចអំពល់អំពីទ្រព្យគាត់ ៗ កាលនោះ តាជូជក គាត់ខឹងអង្គុយទ្រមឹង ពុំនាំពា ខារតែស្លានោះ ពួតែក្រខោក ៗ គោះប៉ោក ៗ លើកឡើងពមឆី ① ទើបនាងព្រាហ្មណី ស្រដី

---

① - ច្បាប់ខ្លះមានបរិយាយវែងតទៅទៀតថា " ...ភ្នែកមមីធ្មេញស្មេញអាក្រក់ សក់ប៉ុននឹងល្អសទង់ដែង កណ្តាលក្បាលរលីងមដ្ឋ បីដូចក្បាលតាដក់ខ្មោច ដូចគេបោចឆ្លង...

ប្រាប់តែដោយសេចក្តីថា នឹងឱ្យបុត្រីជាភរិយា ទើបជូជកសួរថា កូនអ្នកនោះ តើខ្មៅឬស ល្អឬអាក្រក់ តាជូជកគ្រាន់រីករាយ ៗ ឯនាងព្រាហ្មណី ក៏អធិប្បាយដោយដំណើរសរសើរអ្នកបុត្រីនៃអាត្មាថា ល្អណាស់អម្ចាស់អើយ ល្អដូចអ្នកគួរវាស នឹងយកស្រីទាំងផ្កាសមកប្រៀបផ្ទឹម ពុំបានឡើយ ៗ ជូជកស្តាប់ហើយថា អើ បើដូច្នោះយកមកមើលអេះ ៗ ទើបព្រាហ្មណីយកកូនទៅផ្ងូតទឹក លាបម្សៅប្រេងជាសូរេចស្រេច ស្លៀកសំពត់ដណ្តប់ស្បៃប៉ប្រែប៉ប្រឹម ញញឹមស្រស់ចរចាពីរោះ មានក្លិនពិដោរ ដូចអ្នកអប់ផ្កានាំទៅ ៗ ឯតាជូជកល្មួចគន់មើលតែកន្ទុយភ្នែក ក្រឡេកមើលម្តង ៗ យល់បានដូចបំណងចិត្ត គាត់គិតនឹកតែក្នុងចិត្តថា អេះ ល្អម្ល៉េះជាម្តងហ្ន៎ មើលទៅយល់ជាគួគាប់ សក្តិសមមែនទែន វៃខ្វនរៀបប្រដាប់ដាក់ទុក ទំនុកបម្រុងនៅក្នុងវត្តសង្ឃារ អើ យល់ជាប្រសើរពិត បើនឹងឱបនឹងរឹត ក៏វាពេញដើមទ្រូង តាជូជកគិតដូច្នោះហើយ ធ្វើកលជាមាយាស្រដីថា យើងនេះមកសុំតែ

រោលភ្លើង ដៃជើងនោះរួញ ទំពាតែស្លាប្លេញប្លោញ ៗ មើលទៅមុខស្រមូញ ដូចមុខស្វា នឹងគន់ទៅច្រមុះនិងចង្កានោះខុបខ្វេរស្មើរដល់គ្នា នឹងគន់ទៅលលាដ៏ក្បាល វាត្រងោលគ្មានសក់ វាអាក្រក់ទាំងមុខ វាពព្លក់ដូចគេប្រឡាក់ផែះប្រសេះប្រសុះ នឹងគន់ទៅរន្ធច្រមុះប៉ុនផ្ចិតដៃ រន្ធច្រមុះម្ខាង ៗ នោះក្អែបខ្ទយ ៣ - ៤ ប្រាំដំបរនៅបាន រាងក្រអួញក្រឌិះ ពោះធំកំប៉ោង កោងវៀចទាំងឆ្អឹងជំនីរ ៗ ទើបនាង...

ព្រទ្យគាប់ អ្នកថាលំបាកហើយ គិតយកបុត្រីមក ឱ្យជាភរិយា យើងៗ ក៏ពុំសូវប្រាថ្នាទេ តែថាអ្នកឱ្យយើងហើយ នឹងលែងទទួលពុំបាន យើងនឹងលាថ្កានឋានយើងឯនាយ ឥឡូវនេះឯងហោង ៗ ទើបនាងព្រាហ្មណីជាម្ដាយ មកស្រដីផ្ដែផ្ដាំផ្ដាក់ផ្ញើបុត្រីលើតាជូជក តាមតែអាសូរករុណា នាងអមិត្តតាបនា ហើយបបោសអង្អែលថា ឱ! កូនពិសីសំឡាញ់មាសម្ដាយអើយ ម្ដាយពុំមានទ្រព្យអ្វីឱ្យឡើយ ម្ដាយនៅសព្វថ្ងៃនេះក្រខ្សត់ពេកណាស់ ម្ចាស់ម្ដាយអើយ ចូរនាងទៅនៅនឹងតាជូជក កុំបីមានទុក្ខសោករោគភ័យ ជំងឺតម្កាត់មកបៀតបៀនឡើយ ៗ ជូជកស្ដាប់ហើយឆ្លើយថា ម៉ែៗ កុំគិតឡើយ ខ្ញុំធានារក្សាឱ្យដូចមាតាបិតាទាំងពីរ ចំណេរទៅមុខ មាតាបិតានឹងបានជាមុខទុកជាកេរ្តិ៍ អង្វែងវែងឆ្ងាយ ៗ ជូជករោះរាយក្សេមក្សាន្ត នាំនាងអមិត្តតាបនាអំពីឋាននោះទៅតាមផ្លូវមាគ៌ា នាងអមិត្តតាបនា ក៏ស្ដាយយាមតាម តាព្រឹទ្ធាចារ្យពីក្រោយ ៗ ឯតាជូជក ដើរទៅហើយក្រឡេកមើលរឿយ ៗ ហាក់ដូចពុំនឿយហត់ឡើយ ហើយឱ្យនាងអមិត្តតាបនាដើរទៅមុនវិញ នឹងបានគន់មើលឱ្យស្កប់ចិត្ត គាត់គិតក្រែងក្មេងកំឡោះ វាមកតម្បូច លួចសើចលេងនឹងនាងអមិត្តតាបនា ជូជកជាទុក្ខនឹងដើរទៅឯមុខ ពុំបាន នឹងឱ្យខានដើរជាក្រោយ ក្រែងវាមកជំលេញ

លេង តែក្នុងចិត្តគិតឱ្យដើរទៅឯមុខ ហើយជូជកដើរពីក្រោយ ក្សិណហើយស្រូតឡើងទៅខាង ៗ សរសើរថា ល្អមែន (១) ជូជកដើរវិលទៅវិលមក ដូចជាបាទខ្មៅ នាំទៅដល់លំនៅ ប្រដៅឱ្យធ្វើការងារ រកអីតាមប្រពៃណីនោះ

១- មានច្បាប់ខ្លះមានបរិយាយប្លែកផ្សេងដូច្នេះថា "... ហើយស្រូតឡើងទៅខាង ឮហៅថា នាងអមិត្តតាបនា អម្ចាស់តា យកថង់យាមអំពីស្មា បុកស្លាឱ្យតាបានមួយម៉ាត់ ទើបនាងអមិត្តតាបនាស្រដីថា អើតានេះស្រដីអ្វីដូច្នេះ មិនចេះខ្មាសគេ ៗ មកនៅមិនទាន់បានប៉ុន្មានថ្ងៃ ក៏ហ៊ានប្រើគេឱ្យបុកស្លាឱ្យផី ទើបជូជកគាត់សំណេះថា អមិត្តតាបនាម្ចាស់បង បែរមកឯណេះ អេះខ្នងឱ្យបងបន្តិច ទើបនាងអមិត្តតាបនា ស្ទុះមកក្តិចខ្វារស្ទើរតែនឹងដាច់ខ្នងកំពក ជូជកគាត់បែរមកម្ទីម្ទាស្រែកថា អូយ្យៈ អូយ្យូយ ឮយ៉ា អមិត្តតាបនាម្ចាស់តាអើយ ស្លាប់តាហើយ ស្រាប់តែរត់ទៅមុននាងអមិត្តតាបនា ជូជកភ្លាត់ជើងដួលផ្ងារ ដូចគេចោល ឮសូរខ្ទាកស្ទើរធ្លាយលោង ដូចគេកោសខ្នងទាល់តែចេញឈាម ដូចគេវណ្តាំឯថង់យាម នឹងថ្ពាល់គូថ ឮតែប៉ុងរខោក ៗ ធ្លាក់ឯអកកំបោរប្រណាកទាល់តែហ្មត់ ជូជកគាត់ទ្រាំងឺពុំបានថ្ងូរថា ហឺហឺ ឈឺណាស់ ៗ ឯនាងអមិត្តតាបនា ដើរទៅពីក្រោយ ក៏ភ្ញាក់ ដូចគេកន្ត្រាក់ស្មា ក្រឡេកមើលតាជូជកដួលផ្ងារ ប្រឡាក់ភក់ពេញខ្លួនស្រមួញ ទាំងបែកក្បាល ឈាមច្រាលទាំងច្រមុះសុសអស់ទាំងខ្លួន មិនមានសល់ដល់តិចឡើយ បពិត្រអើយ តាជូជកម្ទីម្ទា បោសខ្លួនប្រាណក្រោកឡើងឈរ ដៃកាន់ឈើច្រត់រើសថង់យាមមកពាក់លើស្មា គាត់ខ្មាសនាងអមិត្តតាបនា ពន់ប្រមាណ ត្បិតបានជាខុសគំនិត ជូជកគាត់ដើរវិលទៅវិលមក ដូចជាបាទខ្មៅ ហើយនាំនាងអមិត្តតាបនាទៅលំនៅ."..ៗ

ឯងហោង ៗ ព្ទដ៏កាលនោះ ឯនាងអមិត្តតាបនាប្រណិប័តន៍រក្សាតាព្រឹទ្ធាចារ្យ ដ៏ជាស្វាមី ពុំហ៊ានស្រដីខ្ញីខ្ញា ទ្រគោះឱ្យព្រាហ្មណ៍នោះ រកឧសចឹសស្រូវ ដណ្តាំបាយ ដងទឹកព្រឹកល្ងាចសព្វទិនទិវា ៗ ឯព្រាហ្មណ៍ចាស់ជរា ក៏មានចិត្តស្រឡាញ់នាងអមិត្តតាបនានោះមិញ ស្មើរនឹងលេបបាន ពុំឱ្យនាងអមិត្តតាបនានោះអាក់អន់ចិត្ត ដល់តិចឡើយ ៗ

អថ សព្វេ អញ្ញេ តរុណព្រាហ្មណា បពិត្រអើយ ឯអស់ព្រាហ្មណ៍កំឡោះផងទាំងឡាយ វាយល់នាងអមិត្តតាបនា ប្រណិប័តន៍រក្សាតាជូជក ជាមនុស្សអាក្រក់ អន្ធការ ទើបបណ្តាលឱ្យខឹងនឹងភរិយារបស់អាត្មារាល់គ្នា ហើយជេរថា មេជ្ជជាតិ ឥតខ្មាស ហងដឹងតែដើរផ្តាសឥតស័ព្ទ ម្តេចក៏ហងមិនត្រាប់នាងអមិត្តតាបនា ស្អាងតែអាត្មា ថាតែមាត់មិនគិតធ្វើការងាររកឆីចុក មិនដងទឹកកាប់ឧស អង្គុយតែដុសក្រចកធ្វើខ្លួនលាបតែក្រមួនឆីស្លា បន្តិចថាជាបន្តិចថាឈឺថ្កាត់ យកតែរន្ទះមាត់នោះមកគ្របលើប្តី នឹងលក់ដូរអ្វីក៏ខាតទុនស៊ុនទាំងចំណេញ បើនឹងរវៃមិញ បីថ្ងៃបីយប់ទើបបាន ១ ចែក បើនឹងត្បាញសំពត់វិញ តែមួយនឹងគេនោះកន្លះខែប្លាយ រវល់តែកាច់កនិយាយបព្ជើប្រុស មេកព្ញើផ្លុះ វាយកតែពាក្យនោះជាទំនិញលលក់ លាបប្រេងផាត់មុខមួយថ្ងៃ ពីរបីស្របក់ ផ្លុះកញ្ចក់ពីរបីវេលា គំនិតវាស្ទុត-

ទ្រុឌ ទំនើងតែដើរលេងដោយរាល់ផ្ទះ នឹងរកអ្វីច្រាស ក៏គ្មាន រៀនតែជឿគេឥតពុំគិតវែងឆ្ងាយ អញនឹងលែងក្បាលហាងឱ្យជាមេម៉ាយ ពុំស្តាយឡើយ អញនឹងរកទៀត ហើយឱ្យមានឥរិយាដូចនាងអមិត្តតាបនា ភរិយាតាជូជកនោះឯងហោង (១) ។

តមត្ថំ បកាសេន្តោ សត្ថា អាហ ។ យំ អត្ថំ រីអាថ៌ធម៌ឯណា **ន បាកដំ** ពុំទាន់ប្រាកដ **សត្ថា** រីព្រះបរមសាស្តាចារ្យ **បកាសេន្តោ** កាលព្រះអង្គទ្រង់ប្រកាស **តំ អត្ថំ** នូវអត្ថនោះ **បាកដំ** ឱ្យប្រាកដច្បាស់ **អាហ**

១- បើប្រែតាមរូបបាលីអដ្ឋកថាមហាវេស្សន្តរជាតក តាំងពីដើមរហូតដល់ត្រឹមនេះ ថា " កាលនោះ មានព្រាហ្មណ៍ម្នាក់ឈ្មោះជូជក នៅស្រុកទុន្នវិដ្ឋព្រាហ្មណគ្រាម ក្នុងដែនកលិង្គរាស្ត្រ ដើរសុំទានគេបានប្រាក់ ១០០ កហាបណៈ យកទៅផ្ញើទុកត្រកូលព្រាហ្មណ៍មួយ ហើយចេញទៅស្វែងរកធនធានទៀត ។ លុះអំណើះកាលតមក ត្រកូលព្រាហ្មណ៍នេះ ក៏ចាយវាយកហាបណៈរបស់ជូជកអស់ទៅ តមកគ្រាក្រោយ ជូជកមកទារយកកហាបណៈនោះ ត្រកូលព្រាហ្មណ៍រកសងមិនបានទើបលើកកូនក្រមុំឈ្មោះនាងអមិត្តតាបនាឱ្យទៅជូជក ៗ នាំនាងទៅកាន់ទុន្នវិដ្ឋព្រាហ្មណគ្រាម ដែនកលិង្គរាស្ត្រ នាងអមិត្តតាបនាគោរពប្រតិបត្តិព្រាហ្មណ៍ដោយប្រពៃ ។ ឯអស់ព្រាហ្មណ៍កំឡោះ ៗ ទាំងពួងបានឃើញនាងអមិត្តតាបនាមានកិរិយាមារយាទល្អ ក៏មានចិត្តច្រណែន ទើបជេរវាយដំប្រពន្ធរបស់ខ្លួន ៗ ថា នាងអមិត្តតាបនាចេះផ្គត់ផ្គង់ព្រាហ្មណ៍កញ្ជាស់យ៉ាងចំណាប់ ចុះហាងឯងបានធ្វើអ្វីឱ្យអញ ។

ក៏ទ្រង់សូត្រសាជាបាទព្រះគាថា ដូច្នេះ

អហុ វាសី កលិង្គេសុ   ជូជកោ នាម ព្រាហ្មណោ
តស្សាបិ ទហរា ភរិយា   នាមេនាមិត្តតាបនា ។
តា នំ តត្ថ គតាវោចុំ   នទី ឧទកហារិយា
ថិយោ នំ បរិភាសឹសុ   សមាគន្ត្វា កុតូហលា ។
អមិត្តា នូន តេ មាតា   អមិត្តោ នូន តេ បិតា
យេ តំ ជិណ្ណស្ស បាទំសុ   ឯវំ ទហរិយំ សតី ។
អហិតំ វត តេ ញាតី   មន្តយឹសុ រហោគតា
យេ តំ ជិណ្ណស្ស បាទំសុ   ឯវំ ទហរិយំ សតី ។
ទុក្ខំ វត តេ ញាតី   មន្តយឹសុ រហោគតា
យេ តំ ជិណ្ណស្ស បាទំសុ   ឯវំ ទហរិយំ សតី ។
បាបកំ វត តេ ញាតី   មន្តយឹសុ រហោគតា
យេ តំ ជិណ្ណស្ស បាទំសុ   ឯវំ ទហរិយំ សតី ។
អមនាបំ វត តេ ញាតី   មន្តយឹសុ រហោគតា
យេ តំ ជិណ្ណស្ស បាទំសុ   ឯវំ ទហរិយំ សតី ។
អមនាបវាសំ វសិ   ជិណ្ណេន បតិនា សហ
យា ត្វំ វសសិ ជិណ្ណស្ស   មតន្តេ ជីវិតា វរំ ។
ន ហិ នូន តុយ្ហំ កល្យាណី   បិតា មាតា ច សោភណេ
អញ្ញំ ភត្តារំ វិន្ទឹសុ
យេ តំ ជិណ្ណស្ស បាទំសុ   ឯវំ ទហរិយំ សតី ។

នុយិដ្ឋន្តេ នវមិយំ　　អសតំ (១) អគ្គិហុត្តកំ
យោ តំ ជិណ្ណស្ស បាទំសុ　ឯវំ ទហរិយំ សតី ។
សមណោ ព្រាហ្មណោ នូន　ព្រហ្មចរិយបរាយនេ
សា ត្វំ លោកេ អភិស្សសិ　សីលវន្តេ ពហុស្សុតេ ។
យា ត្វំ វសសិ ជិណ្ណស្ស　ឯវំ ទហរិយំ សតី
ន ទុក្ខំ អហិនា ទដ្ឋំ　　ន ទុក្ខំ សត្តិយា ហតំ
តញ្ច ទុក្ខញ្ច តិប្បញ្ច　　យំ បស្សេ ជិណ្ណកំ បតី ។
នត្ថិ ខិឌ្ឌា នត្ថិ រតិ　　ជិណ្ណេន បតិនា សហ
នត្ថិ អល្លាបសល្លាបោ　　ជគ្ឃិតម្បិ ន សោភតិ ។
យទា ទហរោ ទហរា (២)　មន្តយឹសុ រហោគតា
សព្វេ សោកា វិនស្សន្តិ　យេកេចិ ហទយស្សិតា
ទហរា ត្វំ រូបវតី　　បុរិសានំភិបត្ថិតា
គច្ឆ ញាតិកុលេ អច្ឆ　　កី ជិណ្ណោ រមយិស្សតីតិ ។

ភិក្ខវេ ម្នាលសង្ឃទ្រង់សីលសង្វរផងទាំងឡាយអើយ ឥត្ថិយោ រីនាងព្រាហ្មណីផងទាំងឡាយ មានសេចក្តីអាស្រូវភាសខ្មាសគេ ត្បិតស្វាមីជេរកណ្តាលជំនុំ ទើបមកក្តុំគ្នានិន្ទានាងអមិត្តតាបនាថា ពីដើមស្វាមីយើងនេះ ពុំដែលខឹងឃោរជេរពោលយើងដល់ម្ល៉េះ ឥឡូវនេះ ប្តីយើង

១- កត្ថចិ ហោត្តកេ អកតន្តិបិ បាឋោ ។ ២- កត្ថចិ យទា ច ទហរោ ទហរាតិបិ បាឋោ ។

ខឹងឃោរជេរពោលជាកោលាហល អំពល់ទាំងស្រុកភូមិ ព្រោះមេប្រពន្ធព្រាហ្មណ៍ស្ទូមវាមកនៅនេះ ទើបប្ដីយើងកើតក្ដៅក្រហាយជេរវាយយើងរាល់គ្នា ថាបើយើងឱ្យមេនេះវានៅទៅឯមុខ យើងនឹងកើតទុក្ខទោសច្រើនគ្រប់គ្នា កាលណាឡើយយើងនឹងបានសុខសប្បាយ មកយើងនឹងបបួលគ្នាទៅជេរវាយស្រដីត្មះតិះដៀលវា ដោយនូវតម្រិះប្រាជ្ញា រំអាឱ្យវាខ្លាច ទើបបាន កុំឱ្យវានៅឋាននេះនឹងយើងបានឡើយ បើឱ្យវានៅនេះហើយ ប្ដីយើងនឹងជេរវាយយើង ព្រោះមេប្រពន្ធព្រាហ្មណ៍ចង្រៃនេះឯង ជាប្រាកដពុំខានឡើយ មកយើងនាំគ្នាទៅចាំឯកំពង់ទឹកជាមុនឱ្យហើយ ពុំលង់ឡើយ ក៏បបួលគ្នាចុះទៅឯកំពង់ទឹកនោះ លុះនាងអមិត្តតាបនាកណ្ដៀតក្អម ទៅដងទឹកនឹងយកទៅឱ្យតាជីងូតផឹកជាប្រក្រតី ៗ ឯអស់នាងព្រាហ្មណីយល់ហើយ ក៏ជេរទ្រគោះបញ្ឆោះនាងអមិត្តតាបនាលេង ជាឆោឡោអឹងកង បីដូចសត្វក្អែកឃើញចំណី ខ្លះស្រដីពីមុខ ខ្លះស្រដីពីខ្នង ខ្លះឈោងចាប់ដៃ ជេរផ្ដាលប្រទេចផ្ដាសា ដៀលដល់ម្ដាយឪពុក ដល់ត្រកូលវង្ស ស្រដីថា **ភោតិ** នែនាងអមិត្តតាបនាអើយ ហងមានរូបរាងដូចជាងគូរវាស ទោះហងយាងយាសលីលាយាត្រា ភក្ត្រាស្រេចស្រស់ បើប្រុសឯណាគេឃើញ ស្ទើរនឹងសន្លប់ទប់ពុំបាន អើ ! ម្ដេចក៏ហងឋកមានប្ដីចាស់ជូជាតិ ស្មើគេយកខ្មោចឧត្បាតចង្រៃ មកដាក់

ប្រាណដូច្នេះ ៗ ឯហាងបានជាស៊ុនខ្លួនធួនគ្រោះ តែគឺមោះចិត្តហាងនោះពុំប្រាថ្នា វីហាងនេះជាស្រីខ្ជីខ្ជាអប្រិយ ជាស្រីអប្បយស ឃើញតែប្រុសក៏ត្រេកអរ ដូចជាគេឃើញស្ករនិងទឹកឃ្មុំ ពុំធ្វើការងាររកអីមកជាអម្រស់ អស់ក៏ពុំដឹង គង់ក៏ពុំដឹង គិតតែដើរលេងដោយផ្ទះគេ ពុំដឹងទិសដំបន់ឡើយ លុះតែល្ងាចហើយ ទើបវិលមកផ្ទះអាត្មាវិញ ៗ **មន្តឃីសុរហោគតា** វីអស់ញាតិកា ម្តាយឪពុក នឹងទុកដាក់ហាង ពុំបាន ក្រែងមានអាស្រូវភាស ទើបគេលើកហាងឱ្យតាជូជកចាស់ជរា ជាមនុស្សពិការអសោចិ៍ ដូចគេយកខ្មោច មកធ្វើជាប្តី យល់អប្រិយពុំសម ឬហាងយកមកបន្ទំលេងទេ ម្តេចមិនមើលមុខមើលក្រោយ ហាងឃើញតែប្រុសក៏ដោយងាយ ៗ ឱ្យបង់ខ្លួនដូច្នោះ ឬមួយក្រែងកំឡោះគេពុំប្រាថ្នា គេយល់ហាងជាមនុស្សឥតសព្ទឥតសារ ៗ **ឧក្កដំ** មិនជាការប្រយោជន៍ ឱ្យតែអសោចិ៍អាស្រូវ ត្បិតចិត្តហាងពុំត្រូវនឹងអស់ចិត្តស្រី ៗ នឹងរក្សាចិត្តប្តីពុំបាន ជាមនុស្សឥតសន្តានទុជ៌នពន់ពេក ទើបគេពុំយក ៗ **អញ្ញំ ភត្តារំ** ចូរហាងស្វែងរកប្តីឯណា ឱ្យល្មមសមគួរ ឱ្យត្រូវចិត្តពិតប្រសើរពេកក្រៃលែងនឹងចាស់ជរានេះវិញ ៗ **ឧឃិដ្ឋន្តេ** វីហាងនេះធ្វើបូជាហោមពិធីមិនល្អ **នចមិយំ** ក្នុងតិថីថ្ងៃគម្រប់ ប្រាំបួន ទើបគេលើកឱ្យទៅតាជូជកចាស់ជរា ឧបមាបីដូច

ក្អែកកញ្ជ្រាស់ នាំយកពងមាន់ទៅផី ⑴ ឬមួយហងបានប្រមាថសមណព្រាហ្មណ៍ជីផែរភិក្ខុសង្ឃ ពុំកាន់ទៀងត្រង់តាមប្រពៃណី ទើបហងបានប្ដីចាស់ទៀបនឹងចូលលោង ⑵ ខ្នងកោងក្ងក់ដូចទម្លក់ឈើ តើក្នុងព្រះនគរនេះ មិនមានប្រុសទេឬ អើ! អមិត្តតាបនាអើយ ហងស្ដាយថ្វីជីវិតរស់នៅ សូវស្លាប់ទៅជាខ្មោចប្រសើរជាង ។ **អហិនា ឧដ្ឋំ** ថាបើអាសិរពិសវានឹងខាំឱ្យអស់ជីវិត គួរអធិដ្ឋានទៅតាមផល កុំអំពល់នឹងខ្លួនឡើយ ។ **សត្តិយា ហតំ** ថាបើហងដើរយប់ ចេញពីផ្ទះទៅហើយ ទៅប្រទះនឹងអ្នកពិឃាតជីវិតបង់ក៏ប្រសើរក្រៃលែងនឹងរស់នៅជាមនុស្សវិញ ។ **ឧហរេវ ឧហរវ** ពាក្យបុរាណលោកពោលរៀងៗមកថា បើប្រពន្ធក្រមុំ ទើបសមនឹងប្ដីកំឡោះ គួរគប្បីកាន់កោះរួមស្នេហា ។ **រហោគតា** តាមប្រពៃណីនាទីស្ងាត់ ឥឡូវនេះ ហងមកបានប្ដីមនុស្សសាត់ព្រាត់ ដូចយក្ខដូចមារ បើនឹងស្រដីសំណេះសំណាល ដូចគេខឹងគ្នា បើនឹងស្រដីជានា ដូចគេខម បើនឹងស្រដីលោម ដូចជាគេខាំ នេះហេតុតែកម្មហងឯង នាំមកឱ្យប្រទះ ហេតុនេះ ចូរហងឯងវិលទៅផ្ទះវិញ រកញាតិកា

១- តាមន័យបាលីអដ្ឋកថាមហាវេស្សន្តរជាតក មានសេចក្ដីថា ហងបូជាយញ្ញាមិនល្អក្នុងថ្ងៃគម្រប់ ៩ ដ៏ប្រាកដជាបាយបិណ្ឌរបស់ហងឯង មានក្អែកកញ្ជ្រាស់ពាំនាំយកទៅផីបាត់តាំងពីដំបូង ។ ២- លោង ពាក្យសៀម ប្រែថា ក្ដារមឈូស ។

ម្តាយឪពុក គេនឹងរៀបទុកដាក់ហាង ឱ្យមានប្ដីទៀត ឱ្យសក្តិសមនឹងប្រាណ ឱ្យបានរក្សាគ្នាជាយឺនយូរបរិបូណ៌ ទៅឯមុខ ឯងហោង ។

សា តាសំ សន្តិកា បរិភាសំ លភិត្វា រីនាងអមិត្តតាបនា កាលណាបើបានឮអស់នាងព្រាហ្មណី គេស្រដីឌឹងឃោរឃៅជេរពោលវាយដំ ត្មះតិះដៀលដូច្នោះហើយ រីប្រមាត់នាងស្មើរនឹងបែកសព្លោក ប្រេះចេញ ឯក្អមទឹកនោះមិញ ក៏ទម្លាក់ព្រួសអំពីចង្កេះ ថាអេះចាំអញទៅប្រាប់តាអញហ៎ះ វានឹងធ្វើអ្វីអញ វាម្ដេញនឹងអញថ្វី បើគាត់ចាស់ក្ដី គ្រាន់រកចិញ្ចឹមគ្នាតាមក្រ បើរូបល្អ តើនឹងលាងទឹកផឹកឆ្អែតកាលណា ហើយនាងអមិត្តតាបនា ដើរទៅដោយផ្លូវយំរង៉ូវ ៗ ឯតាជូជកនោះកូវ គាត់អង្គុយនៅបង្អួច ឃើញតែរោមស្រមូវ បីដូចស្វាព្រាហ្មណ៍នៅលើឈើ លុះឮនាងអមិត្តតាបនាស្រដីយំបណ្ដើរ ហើយគាត់ដណ្ដឹងថា អមិត្តតាបនាសំឡាញ់តាអើយ ថ្វីហើយក៏បានជាយំ ព្រាហ្មណ៍ខំសួរខ្សឹកខ្សួល អួលក្នុងចិត្ត អាណិតភរិយាសំឡាញ់ ទឹកភ្នែកនោះមិញ វាហូរសស្រាក់ **ព្រាហ្មណេន បុដ្ឋា** អួលអាក់អម្ដេញ ដណ្ដឹងទៅវិញទៀតថា ថ្វីហើយ ថ្វីហ៎ះ ម្ចាស់តា ក៏បានជាយំ អ្នកណាគេធ្វើនាង ចូរនាងប្រាប់តាមើលណា៎ មាសតា ៗ ទើបនាងអមិត្តតាបនាឆ្លើយថា អើវាល្អហើយ **បរិភាសន្តិ**

នៃតាចាស់អើយ អស់ប្រពន្ធព្រាហ្មណ៍កំឡោះ វាក៏គ្នាមកវាយជេរអញ ហាក់ដូចខ្ញុំលោះនឹងប្រាក់ចាក់អំពីថង់ ពុំស្មើឡើយ ៗ

ន តេ ព្រាហ្មណ គច្ឆាមិ នទឹ ឧទកហារិយា
ថិយោ មំ បរិភាសន្តិ តយា ជិណ្ណេន ព្រាហ្មណាតិ ។

ព្រាហ្មណ៍អើយ ម្ល៉េះហើយអញមិនទៅឯកំពង់ទឹកដូចសព្វមួយដងវិញទៀតឡើយ ទាំងទឹកទាំងឧស ក៏អញពុំទៅដងរកទៀតឡើយ ព្រាហ្មណ៍អើយ ព្រោះតែអញមកនៅបម្រើប្តីចាស់ហើយ ទើបអស់ប្រពន្ធព្រាហ្មណ៍កំឡោះ ផងទាំងឡាយវាមកកំហែងជេរវាយអញ ហាក់ដូចគេដណ្តើមប្តី ឬសហាយវាជេរទាំងម្តាយឪពុក ត្មះតិះដៀលមិនមានក្រោតក្រែង ថាជាស្រីអប្រិយ មានប្តីកញ្ជាស់នេះឯង អញខឹងណាស់លើសអ្វីៗ ណ៎ាតា អើ ! ទាំងនេះព្រោះនរណា ព្រោះតែអញមកនៅនឹងតា នាឋាននេះឯង ៗ

មា មំ ត្វំ អករា កម្មំ មា មេ ឧទកមាហរិ
អហំ ឧទកមាហិស្សំ មា ភោតី កុប្បិតា អហូតិ ។

ទើបជូជក សំណេះសំណាលស្រដីលោមថា ម្ល៉ោះហើយនាងកុំចេញទៅធ្វើការអ្វី ចូរនៅតែក្នុងផ្ទះណាម្ចាស់តា ទាំងទឹកនូវឧសនូវអស់បណ្ណាការអាហារផង នាងកុំទៅរកឡើយ ជាងារតាឯងហើយ នឹងធានាខ្វល់ខ្វាយទៅដងទៅរកមកឱ្យនាងបរិភោគឱ្យជាសុខ កុំនាងជាទុក្ខឡើយ ណ៎ាអមិត្តតាបនា

ចូរនាងរក្សាតែឈើច្រត់នូវយាមឱ្យល្អ គ្រាន់តាដើររកជាអម្រស់អម្រ ឯរបស់នៅផ្ទះ កុំឱ្យខូចបាត់បង់ឡើយ ។

ឯនាងអមិត្តតាបនាស្ដាប់ហើយ ក៏ពុំត្រូវចិត្ត គិតក្ដៅរោលរាលដូចភ្លើងអ្នកបំពក់ឱ្យឆុរឆេះព្រៃ ទើបនាងអមិត្តតាបនាពោលថា តាកុំស្រដីពាក្យនេះ អញពុំយកពាក្យតាទេ ។

នាហំ តម្ហិ កុលេ ជាតា យំ ត្វំ ឧទកមាហរេ
ឯតំ ព្រាហ្មណ ជានាហិ ន តេ វច្ឆាមិហំ ឃរេ ។
សចេ មេ ទាសំ ទាសី វា នានយិស្សសិ ព្រាហ្មណ
ឯតំ ព្រាហ្មណ ជានាហិ ន តេ វច្ឆាមិ សន្តិកេតិ ។

មានច្បាប់ឯណាប្រើប្ដីតាងខ្ញុំ កុំស្រដីដូច្នោះឡើយ នែតាអើយ ទុកប្ដីស្មើឪពុកជាទីគោរព ប្រណិប័តន៍កោតខ្លាចឯស្រីកំណាចជួជាតិអប្រិយ ទើបយកប្ដីជាខ្ញុំ ពុំត្រូវច្បាប់ជេរសាប់ដូចជ្រញ់ បើតាស្រឡាញ់អញនេះ តាកុំនៅ ចូរទៅរកខ្ញុំស្រីខ្ញុំប្រុសមកឱ្យអញប្រើ ជាគ្នាជាដៃជាជើង ចូរតាទៅកុំខាន បើតារកពុំបាន អញនឹងរត់ទៅឋានលំនៅអញ ឥឡូវនេះឯងហោង ។ ជូជកោ អាហ

នត្ថិ មេ សិប្បដ្ឋានំ វា ធនំ ធញ្ញញ្ច ព្រាហ្មណិ
កុតោហំ ទាសំ ទាសី វា អានយិស្សាមិ ភោតិយា
អហំ ភោតី ឧបដ្ឋិស្សំ មា ភោតី កុបិតា អហូតិ ។

រីឯជូជកព្រឹទ្ធាចារ្យ លុះឮភរិយាស្រដីដូច្នោះហើយ ធ្វើ

កលមាយាស្រដីអួតអំពីទ្រព្យធន ឱ្យប្រពន្ធស្តាប់ថា ពីដើមមកវែងមានទ្រព្យ មួយជញ្ជីងពីរជញ្ជីង ទុកសម្រាប់ចាយប្រើនៅលើផ្ទះ ពុំដែលក្រ ខ្ញុំកំដរក៏មាន ឥឡូវនេះ តាមកបានក្តីក្រីក្រលំបាក ទាំងស្រូវអង្ករនឹងរកអីក៏គ្មាន អន្តរធានទាំងទ្រព្យ ត្បិតភ្លើងឆេះផ្ទះអស់ពុំគង់ ប្រពន្ធក៏ស្លាប់ បង់ចោលគ្នាកំព្រានៅតែម្នាក់ឯង សព្វថ្ងៃ អីក៏ពុំឆ្អែតឆ្អន់ នាងក៏យល់នឹងភ្នែកស្រាប់ហើយ ៗ នត្ថិ មេ សិប្បដ្ឋានំ ខរ ទាំងសិល្បវិជ្ជាការ ក៏សាបសូន្យភ្លាំងភ្លាត់ ទាំងប្រក្រតិទិន ក៏ពុំចាំស្ទាត់ដូចក្បួនខ្នាត ភ្លេចទាំងសូរ្យាត្រដួងជតា នឹងគុណនឹងហារ ក៏វិលវល់ពុំអស់សេចក្តី នឹងគន់គូរមើលជតារាសី ក៏មិនឆុតដូចតម្រា ខំតែថាផ្សែផ្សំ នឹងមើលអគ្នេយ៍ចាក់អារក្សធំ ក៏ពុំប្រាកដដូចមុនមាន សព្វថ្ងៃនេះ អាងតែដើរសូមទានគេមកចិញ្ចឹមអាត្មា ចូរនាងប្រើតាតែនៅអាយ តានឹងខ្វល់ខ្វាយតាមនាងប្រើតានោះឯងហោង ៗ

បពិត្រអើយ ព្ធដ៏កាលនោះ រីអ្ហូត្យុដែលនៅចាំតៀនអាយុតាព្រឹទ្ធាចារ្យ បណ្តាលឱ្យនាងអមិត្តតាបនា នឹកទៅដល់ព្រះបាទស្រីវេស្សន្តរបវរពោធិសត្វទៅសាងព្រឹទ្ធ នៅក្នុងព្រៃ ទើបនាងអមិត្តតាបនា ស្រដីនឹងតាព្រឹទ្ធាចារ្យ សូត្រជាបាទគាថា ដូច្នេះ

ឯហិ តេ អហមក្ខិស្សំ យថា មេ ខចនំ សុតំ

ឯស វេស្សន្តរោ រាជា វង្កេ វសតិ បព្វតេ ។
តំ ត្វំ គន្ត្វាន យាចស្សុ ទាសំ ទាសិញ្ច ព្រាហ្មណ
សោ តេ ទស្សតិ យាចិតោ ទាសំ ទាសិញ្ច ខត្តិយោតិ ។

ហៃព្រាហ្មណ៍អើយ អញឮដោយពាក្យគេថា វេស្សន្តរោ រាជា មានព្រះមហាក្សត្រាធិរាជមួយព្រះអង្គ ទ្រង់ព្រះនាមព្រះបាទស្រីវេស្សន្តរ ស្តេចគ្រងព្រះនគរធំ អស់ក្សត្រផងតែងមកបង្គំជាប្រក្រតី ព្រះអង្គមានព្រះរាជហឫទ័យ កាត់តម្លាសទ្ធា មេត្តាករុណាអស់ស្មូមយាចកតោកយ៉ាកផង តែងមកអាស្រ័យព្រះអង្គ បើនឹងសូមអ្វីក៏បានដូចចិត្តបំណងប៉ងប្រាថ្នា ព្រះអង្គតែងទ្រង់ព្រះរាជសទ្ធាព្រះរាជទាន ពុំរួញរា ព្រះរាជទានទាំងដំរីគជសារឱ្យទានទៅព្រាហ្មណ៍ តាមចិត្តពុំគិតស្តាយឡើយ ។ នែតាព្រាហ្មណ៍អើយ ទើបអស់អ្នកស្រុក គេញុះញង់សម្តេចព្រះវររាជបិតាព្រះអង្គ ឱ្យទ្រង់ព្រះក្រោធ បណ្តេញព្រះអង្គឱ្យចេញចាកជេតុត្តរបុរី ព្រះអង្គនាំព្រះអគ្គមហេសី នូវព្រះរាជបុត្រ ទៅនៅនាភ្នំគិរីវង្កតបព៌ត ថាបើតាជី តាមទៅសុំព្រះរាជទានខ្ញុំប្រុសស្រី យល់ជាព្រះអង្គព្រះរាជទាន ពុំខានឡើយ ។

កាលនោះ តាជូជកព្រឹទ្ធាចារ្យ ស្តាប់ភរិយាប្រាប់ដូច្នោះហើយ នឹងនៅស្ងៀមពុំបាន នឹងខានខ្លាចប្រពន្ធជេរ ទើបគាត់ប្រែភក្ត្រ រកកលអធិប្បាយដោយយោបល់ថា

ជិណ្ណោហមស្មិ ទុព្វលោ ទីឃោ ចទ្ធា សុទុគ្គមោ
មា ភោតី បរិទេវេសិ មា ភោតី វិមនា អហុ
អហំ ភោតី ឧបដ្ឋិស្សំ មា ភោតី កុប្បិតា អហូតិ ។

ហៃអមិត្តតាបនាសំឡាញ់តាអើយ តានេះ ចាស់ហើយ ទាំងភ្នែកក៏ងងឹត ទាំងត្រចៀកក៏ថ្លង់ ឯរោគក្នុងអង្គក៏ច្រើន បន្តិចគ្រុន បន្តិចរងា បន្តិចជា បន្តិចឈឺ វារអប់ឡប់ តែក្នុងប្រាណ តែងសូមទានគេតែដោយរៀងអាយ ក៏ស្ទើរកកាយនឹងដៃ នឹងឡើងឈើព្រៃក៏ពុំរហ័ស រីឯផ្លូវដែលនឹងទៅនោះ ក៏ឆ្ងាយណាស់ សឹងតែត្រោកដំបូកក្រួសរវាន ស្ទើរនឹងដើរពុំបានឡើយ បើប្រទះនឹងសត្វកំណាចហើយ នឹងស្លាប់ឥតការ ឯខ្លួននាងនឹងនៅអសារជាមេម៉ាយ វិមនា អមិត្តតាបនាសំឡាញ់តាអើយ នាងកុំជាទុក្ខពេកឡើយ ធានាលើតាឯងហើយ នឹងទៅរកមកចិញ្ចឹមនាង កុំបីនាងព្រួយចិត្តខឹងសម្បានឹងតាឡើយ ។

ឯនាងអមិត្តតាបនា កាលណាបានស្ដាប់ពាក្យតាជូជកព្រឹទ្ធាចារ្យស្រដីត្អូញត្អែរ ពុំចង់ទៅ ថាផ្លូវកម្រឆ្ងាយ ទើបនាងស្រដីឧបមាឱ្យប្ដីស្ដាប់ថា

យថា អគន្ត្វា សង្គាមំ អយុជ្ឈេវ បរាជិតោ
ឯវមេវ តុវំ ព្រហ្មេ អគន្ត្វា វ បរាជិតោ ។
សចេ មេ ទាសំ ទាសី វា នានយិស្សសិ ព្រាហ្មណ

ឯវំ ព្រាហ្មណ ជានាហិ   ន តេ វច្ឆាមិហំ ឃរេ
អមនាបន្តេ ករិស្សាមិ   តន្តេ ទុក្ខំ ភវិស្សតិ ។
នក្ខត្តេ ឧតុបុព្វេសុ   យទា មំ ទក្ខសិលង្កតំ
អញ្ញេហិ សទ្ធឹ រម្មមានំ   តន្តេ ទុក្ខំ ភវិស្សតិ ។
អទស្សនេន មយ្ហន្តេ   ជិណ្ណស្ស បរិទេវតោ
ភិយ្យោ វង្កា បលិតា ច ពហូ ហេស្សន្តិ ព្រាហ្មណាតិ ។

ហៃតាជីអើយ មានឧបមាបីដូចសេនាសេនីយ៍ ស្រដីតែមាត់ចិត្តកម្លាច ស្រដីថាពុំខ្លាចត្រង់ស្លាប់ឡើយ លុះលើកទ័ពចេញទៅហើយ យល់ឯផង់ផុយធូលី ក៏ថាគេលើកទ័ព ចូលមកតតាំង ទើបបញ្ឈប់ទ័ព រើសរកទាហានអាសា បញ្ជូនតែសេនាទៅមុខ ទម្រាំគេលើកទៅស៊ុន ទើបឯងធ្វើជាទ័ពនុនឯក្រោយ ឱ្យគេថាឯងជាទាហានហានក្លា ឧបមាបីដូចតាជូជក ពុំទាន់ចេញផុតពីផ្ទះ ក៏ត្អូញត្អែរបណ្តើរ ពុំទាន់ចុះផុតអំពីជើងជណ្តើរ ក៏ត្អូញថា ផ្លូវឆ្ងាយដាច់ស្រយាល បើដូច្នេះ អញនឹងផាយរត់ទៅឯផ្ទះអញវិញហើយ នក្ខត្តេ បើដល់ចូលឆ្នាំថ្មីមិញ អញនឹងទៅលេងជាមួយនឹងអស់កំឡោះផង មំ ទក្ខសិលង្កតំ អញនឹងចុកចងស្អៀតសក់ ដណ្តាប់ស្បៃពណ៌ សៀតផ្កានួនស្រី នូវអស់ផ្កាផងទាំងឡាយ ស្លៀកសំពត់ឱ្យជជាយ ជជួរ ឱ្យស្រួលចិត្ត ឱ្យជូជកព្រាហ្មណ៍ គាត់អង្គុយពក្លក់យំ កើតទុក្ខតែម្នាក់ឯង ដរាបលុះតែស្លាប់

ទៅហោង ៗ ព្រាហ្មណ៍អើយ ថារបើព្រះស្តែងទៅរក ទាសំ ទាសី ច ខ្ញុំប្រុសខ្ញុំស្រីមកបម្រើអញហើយ ព្រាហ្មណ៍អើយ អញនឹងនៅធ្វើការចាំព្រះស្តែងឯផ្ទះ បិទសម្រាស់ស្រាស់របង មិនឱ្យអ្នកផងមើលងាយអញ នោះតានឹងសប្បាយចិត្ត ត្បិតពុំបារម្ភមកផ្ទះឡើយ ៗ

តំ សុត្វា ព្រាហ្មណោ ឯតាជូជកព្រឹទ្ធាចារ្យ លុះឮភរិយាស្រដីដូច្នោះហើយ ក៏កើតចិត្តទាហានពុំមានខ្លាចព្រៃ ព្រោះគាត់លុះក្នុងអំណាចស្ត្រី ដោយក្តីមាតុគ្រាមតណ្ហា ៗ

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គសម្តែងនូវបាទព្រះគាថាដូច្នេះ

តតោ សោ ព្រាហ្មណោ ភីតោ ព្រាហ្មណិយា វសានុគោ
អដ្ដិតោ កាមរាគេន ព្រាហ្មណឹ ឯតទព្រវិ ៗ
បាថេយ្យំ មេ ករោហិ ត្វំ សក្ខលា សក្ខុឡ្យានិ ច
មធុបិណ្ឌិកា សុកតាយោ សត្តុភត្តញ្ច ព្រាហ្មណិ ៗ
អានយិស្សំ មេថុនកេ ឧភោ ទាសំ កុមារកេ
តេ តំ បរិចរិស្សន្តិ រត្តិន្ទិវមតន្ទិតាតិ ៗ

ភិក្ខវេ ម្នាលសង្ឃដ៏ទ្រង់សីលសង្វរទាំងឡាយ ឯតាជូជកព្រឹទ្ធាចារ្យនោះ លុះក្នុងអំណាចនាងព្រាហ្មណី ដោយក្តីមាតុគ្រាមតណ្ហា ឮតែភរិយាស្រដីដូច្នោះ ក៏ភ័យខ្លាចប្រពន្ធ

មិនស្រឡាញ់ ទើបស្រដីនឹងនាងព្រាហ្មណីដូច្នេះថា បាថេយ្យំ មេ ករោហិ ចូរនាងអមិត្តតាបនារណ្ដាប់ស្បៀង ដាក់ថង់យាម តាមមានតាមបាន តានឹងយកទៅ ទាំងទ្រាបលាជទ្រាបល្ង ទាំងសដូវដុំ សដូវផង់ មិនដូចនូវផ្លូវជិតវៀងអាយនឹងបានវិលមកវិញឆាប់ តានឹងប្រញាប់ទៅក្រាបទូលសុំព្រះរាជកុមារទាំងពីរព្រះអង្គមកធ្វើជាទាសាទាសី ។ នៃអមិត្តតាបនាសំឡាញ់ចៅតាអើយ ព្រះរាជកុមារទាំងពីរ ពុំមានសេចក្ដីខ្ពិលច្រអូស នឹងមកនៅបម្រើនាង ទាំងយប់ទាំងថ្ងៃកុំឱ្យសំឡាញ់តាព្រួញចិត្តពេកឡើយ ។

សា ខិប្បំ បាថេយ្យំ បដិយាទេត្វា ឯនាងអមិត្តតាបនាឮថា តាជូជកនឹងទៅនាថ្ងៃនោះ នាងក៏ខ្វល់ខ្វាយចាយទិញ ហាក់ដូចមានការអាពាហ៍ពិពាហ៍ ម្ហូម្ហាមករណ្ដាប់ឱ្យតាជូជក ដោយសព្វគ្រប់ប្រការ ។

រីឯតាជូជកព្រឹទ្ធាចារ្យ ព្រួយចិត្តគិតតែនាងអមិត្តតាបនាស្រដីថា អញព្រួញចិត្តស្ថិតទៅយូរឆ្នាំ ពុំមានប្រុសនៅចាំផ្ទះសោះ ក្រែងគ្រាន់កក់ក្ដៅ ហើយគាត់ឈ្វោកទៅក្នុងគ្រឹហា គេហេ ទុព្វលដ្ឋានំ យល់ជញ្ជាំងក៏ដាច់ ទ្វារក៏បាក់ ផ្ទៀងក៏ធ្លាក់ដូចគេរាយដោយដី ថិរំ កត្វា ជូជក ក៏ជួសឡើងជាថ្មីវិញ ទ្វារំ បដិសង្ខរិត្វា ជួសជុលទាំងទ្វារជណ្ដើរផ្ទះស្រាស់របង ហើយទៅដងទឹកមកទុកឱ្យផឹកឱ្យងូត បូរេត្វា

ពេញទាំងក្រឡពិន្ទងពុំមានឱ្យសល់ ហើយទូន្មាននាងអមិត្តតាបនា ដ៏ជាភរិយាសំឡាញ់ **យាវជ្ជតនា** តាំងពីថ្ងៃនេះ រៀងទៅមុខ **អប្បមត្តា** ចូរនាងកុំប្រហែស ចូរនាងប្រយ័ត្នខ្លួន ស្ងួនរក្សា ក្រែងកើតមានភ័យ ត្បិតប្ដីទៅឆ្ងាយ ក្រែងគេមើលងាយ មួយសោត កុំដើរដោយផ្ទះព្រៀងពុំជា គេនឹងនិន្ទាជាអាស្រូវ ចូរនាងនៅផ្ទះសង្វាតតែរកធី ទម្រាំប្ដីមកដល់ ហើយតាជូជកទប់ទល់ពុំបាន ក៏ប្រះប្រាណឃុំសោក ស្រណោះអាឡោះអាល័យ ហើយអង្អែលភក្ត្រាបបោសខ្នងនាងអមិត្តតាបនា ផ្ដាំស្រេចហើយ ពុំយូរឡើយ តាជីក៏យកថង់ស្បៀងដាក់លើស្មា ហត្ថាចាប់ឈើច្រត់ **បទក្ខិណំ កត្វា** ហើយដើរប្រទក្សិណ ៣ ជុំ **នេត្តេហិ អស្សុបុណ្ណេហិ** ហើយគាត់ឈានជើងចេញដើរទៅ ទឹកភ្នែកក៏ហូរសស្រាក់ ឥតស្បើយ **បក្កាមិ** ពុំយូរឡើយ គាត់ដើរចេញទៅអំពីឋានលំនៅនោះ ឯងហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលសូត្រសានូវបាទព្រះគាថាដូច្នេះ

ឥទំ វត្វា ព្រហ្មពន្ធុ បដិមុញ្ចិ ឧបាហនំ
តតោ សោ មន្តយិត្វាន ភរិយំ កត្វា បទក្ខិណំ ។
បក្កាមិ សោ រុណ្ណមុខោ ព្រាហ្មណោ សហិតព្វតោ

សិវីនំ នគរំ ផីតំ ទាសបរិយេសនញ្ចរន្តិ ៗ

ជូជក ជាពូជពង្សវង្សត្រកូលព្រាហ្មណ៍ ពោលពាក្យផ្តាំផ្ញើនាងអមិត្តតាបនាស្រេចហើយ ក៏ពាក់ស្បែកជើង ដើរប្រទក្សិណភរិយា តាព្រាហ្មណ៍ ក៏មានទឹកភ្នែកហូរសស្រាក់ សមាទានវត្តជាតាបសឥសីហើយ ត្រាច់ចារិកទៅកាន់នគរអ្នកស្រុកស្រីពិរាស្ត្រ ដ៏ជាស្រុកធំទូលាយស្តុកស្តម្ភ ដើម្បីដើររកសុំទាសាទាសី លុះតាជីដើរងងុលជជ្រុលជជ្រក ដោយផ្លូវទៅដល់ជេតុត្តរនគរបវររាជឋានហើយ បានឃើញមហាជនគេអង្គុយជួបជុំគ្នា ក៏ចូលទៅសួររកព្រះបាទស្រីវេស្សន្តរ ថា កុហឹ វេស្សន្តរោ រាជា រីព្រះបាទស្រីវេស្សន្តរបវរខត្តិយវង្ស តើព្រះអង្គគង់នៅឋានឯណាហ៎ះ អ្នកអើយ អ្នកទាំងឡាយ ប្រាប់ខ្ញុំឱ្យបានដឹងផង ៗ

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលសូត្រសាន្នូវបាទព្រះគាថាដូច្នេះ

សោ តត្ថ គន្ត្វា អវច   យេ តត្ថាសុំ សមាគតា
កុហឹ វេស្សន្តរោ រាជា   កត្ថ បស្សេមុ ខត្តិយំ ៗ
តេ ជនា តំ អវចីសុ   យេ តត្ថាសុំ សមាគតា
តុម្ហេហិ ព្រហ្មេ បកតោ   អតិទានេន ខត្តិយោ
បព្វាជិតោ សកា រដ្ឋា   វង្កេ វសតិ បព្វតេ ៗ

តុម្ហេហិ ព្រហ្មេ បកតោ អតិទានេន ខត្តិយោ
អាទាយ បុត្តទារេច វង្កេ វសតិ បព្វតេតិ (១)ៗ

នគរវាសិនោ រីអស់អ្នកនគរទាំងឡាយនោះ លុះបានស្តាប់ពាក្យតាជីសួរអំពីព្រះបាទស្រីវេស្សន្តរបវរពោធិសត្វ ក៏មានចិត្តខឹងឃោរនឹងតាព្រាហ្មណ៍ ជេរតាមសព្វអំពើ ថា អើ ! តាព្រាហ្មណ៍នេះឯងហើយ វាតែងមកបៀតបៀនយាយីព្រះអង្គ វាពុំចង់រកឆីចុកលលក់ទន្និញ ចង់សុំអ្វីមិញក៏សុំទាល់តែបាន ឯព្រះអង្គតែងទ្រង់ព្រះរាជទានសំពត់អាវ ព្រៃព្រាំនឹងអ្វីៗ ពុំដែលខាន សូមទាំងដំរីបច្ច័យនាគេន្ទ្រ ដ៏ជាដំរីមង្គល នាំឱ្យកើតអំពល់ដល់បណ្តារាស្ត្រ គេនាំគ្នាខឹងអស់ទាំងព្រះនគរ ទាល់តែព្រះវររាជបិតា ទ្រង់ព្រះក្រេវក្រោធនឹងព្រះអង្គ ទើបស្តេចឱ្យបំបរបង់ចេញអំពីព្រះរាជដ្ឋាន ឯព្រះរាជហឫទ័យ ពុំមានរួញរា ពួកព្រាហ្មណ៍អស់នេះ វា

១- បើប្រែតាមរូបបាលីនៃគាថានេះមានទំនងសេចក្តីដូច្នេះ " តាព្រាហ្មណ៍ បានទៅដល់នគរនោះហើយ បានសាកសួរប្រជាជនដែលជំនុំគ្នាក្នុងទីនោះ ៗ ថា ព្រះបាទស្រីវេស្សន្តរ ស្តេចគង់នៅក្នុងទីណា យើងសូមចូលគាល់ព្រះអង្គ ដ៏ជាក្សត្រខត្តិយវង្ស ក្នុងទីណា ៗ ប្រជាជនដែលប្រជុំគ្នាក្នុងទីនោះ បានពោលតបទៅព្រាហ្មណ៍ថា ម្នាលតាព្រាហ្មណ៍ ព្រះបរមក្សត្រត្រូវពួកតាឯងបៀតបៀន ដោយសារតែព្រះរាជទានគជរ័ត្ន ដ៏ប្រសើរ ទើបគេនាំគ្នានិរទេសព្រះអង្គឱ្យចេញចាកដែនដីទៅនៅភ្នំវង្កតបព៌ត ឥឡូវនេះ ព្រះអង្គតោងនាំយកព្រះឱរសព្រះធីតា ព្រះអគ្គជាយាចេញទៅនៅភ្នំគិរីវង្កតបព៌តហើយ " ៗ

បបួលគ្នាទៅតាមសុំព្រះរាជរថ និងសេះអាជានេយ្យទាំង ៤ ពុំមានចិត្តអាណិតប្រណីព្រះអង្គឡើយ ព្រាហ្មណ៍នេះឯងហើយវាក្បត់នឹងផ្ទៃក្រោម នៃគ្នាយើងអើយ មកយើងចោមចាប់សម្លាប់វាឱ្យហើយ ទើបផ្ទៃក្រោមយើងនឹងរាប លេឌ្ឌុទណ្ឌាទិហត្ថា ខ្លះក្រោកឡើងប្រវាចាប់បានឈើព្រៃដុំដីនូវឥដ្ឋដេញប្រកិតតាមទៅ ឯតាជូជករត់ចូលទៅក្នុងព្រៃ ហាត់ស្ទើរតែនឹងក្ស័យជីវិតដោយភិតភ័យ ហេតុតែទេវតាបញ្ចូលចិត្ត ទើបគាត់ដើរទៅជួបនឹងផ្លូវដែលទៅភ្នំគិរីវង្កតបព៌តនោះ ឯងហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលស្មូត្រសាន្នូវបាទព្រះគាថាដូច្នេះ

សោ ចោទិតោ ព្រាហ្មណិយា ព្រាហ្មណោ កាមគិទ្ធិមា
អយន្តំ បដិសេវិត្ថ
វនេ វាឡមិគាកិណ្ណេ ខគ្គទីបិនិសេវិតេ ។
អាទាយ បេលុវំ ទណ្ឌំ អគ្គិហុត្តំ កមណ្ឌលុំ
សោ បាវិសិ ព្រហារញ្ញំ យត្ថ អស្សោសិ កាមទំ ។
តំ បវិដ្ឋំ ព្រហារញ្ញំ កោកា នំ បរិវារយុំ
វិក្កន្ទិ សោ វិប្បនដ្ឋោ ទូរេ បន្ថា អបក្កមិ ។
តតោ សោ ព្រាហ្មណោ គន្ត្វា ភោគលុទ្ធោ អសញ្ញតោ

ចក្ខុស្សោហរណោ នដ្ឋោ [សុនខេហិ បរិវារិតោ រុក្ខស្មិព្វា និសិន្នោ ច] ឥមា គាថា អភាសថាតិ។

ភិក្ខវេ ម្នាលសង្ឃដ៏ខ្លាចភ័យក្នុងវដ្តសង្សារអើយ **សោ ជូជកោ** រីឯតាជូជកព្រឹទ្ធាចារ្យ ជាអ្នកហិនហោច ដើរត្រមោច ចូលទៅក្នុងព្រៃព្រឹក្សា យំសោកពិលាបអនាថអាណិត **ភវមគិទ្ធិមា** ព្រោះត្បិតតណ្ហាវារោលរាលក្នុងមនោទ្វារ ទើបគាត់យកភេទជាតាជី ដើរសុកប៉ប្រុកទាំងទុក្ខ ពភ្លាក់ពភ្លើ **ខេលុខំ ឧណ្ណំ** កាន់ឈើច្រត់ពណ៌លឿងទុំ ស្មាស្ពាយយាម តតែងតតោង ដូចគេធ្វើលេង ជូជកឈឺចិត្តខ្លួនឯងពន់កម្លាំង **ធាទិសិ ព្រហារញ្ញំ** គាត់ក៏ដើររលះរលាំងចូលទៅក្នុងព្រៃធំ ដង្គុំរបោះចន្លោះជើងភ្នំ តាមច្រកតូច-ធំ ជ្រោះជ្រលងដងស្ទឹង បឹងបួ ញាតស្បាតស្បូវ ផ្លូវចន្លោះឫស្សីដុះសាញ សឹងបន្លា មាគ៌ាក៏ចង្អៀត ជូជកខំដើរច្រៀតតែម្នាក់ឯង ក្រែងខ្លាចភ័យ ភ្នែកតែងរំពៃទៅមុខក្រោយ ឆ្វេងស្តាំ ក្រែងប្រទះនឹងខ្លា ដំរី ក្របីព្រៃ រមាស សឹងបន្លឺស័ព្ទសំឡេងងាសពាសពេញទាំងព្រៃ ជូជកមានភ័យនឹងស័ព្ទសត្វ ស្ទើរបាត់ព្រលឹង គាត់ខំតែប្រឹងដើរជែកញែកបន្លាស្បូវស្បាត ឱ្យបានរំលងទ្វារព្រៃទៅអំពីផ្លូវកម្រ **កោកា នំ បរិវារយុំ** ជូជកដើរជជ្រុលជជ្រកទៅ ពុំលង់ឡើយ ក៏ស្រាប់តែប្រទះនឹងឆ្កែចេតបុត្រ វារត់មកដេញព្រាហ្មណ៍នោះមិញ វាចោមព្រុសជុំវិញ ឯតា-

ជូជកខំរត់ខ្សាញ់សស្លើតសស្លក់ភិតភ័យ ហើយស្រែកថា ឆ្កែ ៗ ឯឆ្កែរឹងជាដេញព្រុសប្រកិត តាជីខំរត់ ដែកាន់ឈើច្រត់លើកឡើងយារ រាំងរាប្រយ័ត្ន ហត់ហ ហុះ ពោះនោះផើតផត ៗ ភ្នែកសស្លឹង ប្រឹងលោតឡើងទៅលើចុងព្រឹក្សា ហើយស្រែកទួញយំរកព្រះបាទស្រីវេស្សន្តរបវរពោធិសត្វ សូត្រជាបាទព្រះគាថាដូច្នេះ

កោ រាជបុត្តំ និសភំ   ជយន្តមបរាជិតំ
ភយេ ខេមស្ស ទាតារំ   កោ មេ វេស្សន្តរំ វិទូ ៗ
យោ យាចតំ បតិដ្ឋាសិ   ភូតានំ ធរណីរិវ
ធរណូបមំ មហារាជំ   កោ មេ វេស្សន្តរំ វិទូ ៗ
យោ យាចតំ គតី អាសិ   សវន្តីនំវ សាគរោ
ឧទធូបមំ មហារាជំ   កោ មេ វេស្សន្តរំ វិទូ ៗ
កល្យាណតិត្ថំ សុបិចំ   សីតូទកំ មនោរមំ
បុណ្ឌរីកេហិ សញ្ឆន្នំ   យុត្តំ កិញ្ជក្ខរេណុនា
រហទូបមំ មហារាជំ   កោ មេ វេស្សន្តរំ វិទូ ៗ
អស្សត្ថំវ បថេ ជាតំ   សីតច្ឆាយំ មនោរមំ
សន្តានំ វិសមេតានំ   កិលន្តានំ បដិគ្គហំ
តថូបមំ មហារាជំ   កោ មេ វេស្សន្តរំ វិទូ ៗ
និគ្រោធំវ បថេ ជាតំ   សីតច្ឆាយំ មនោរមំ
សន្តានំ វិសមេតានំ   កិលន្តានំ បដិគ្គហំ

តថូបមំ មហារាជំ កោ មេ វេស្សន្តរំ វិទូ ៗ
អម្ពំ វិយ បថេ ជាតំ សីតច្ឆាយំ មនោរមំ
សន្តានំ វិសមេតានំ កិលន្តានំ បដិគ្គហំ
តថូបមំ មហារាជំ កោ មេ វេស្សន្តរំ វិទូ ៗ
សាលំ វិយ បថេ ជាតំ សីតច្ឆាយំ មនោរមំ
សន្តានំ វិសមេតានំ កិលន្តានំ បដិគ្គហំ
តថូបមំ មហារាជំ កោ មេ វេស្សន្តរំ វិទូ ៗ
ទុមំ វិយ បថេ ជាតំ សីតច្ឆាយំ មនោរមំ
សន្តានំ វិសមេតានំ កិលន្តានំ បដិគ្គហំ
តថូបមំ មហារាជំ កោ មេ វេស្សន្តរំ វិទូ ៗ
ឯវញ្ច មេ វិលបតោ បវិដ្ឋស្ស ព្រហាវនេ
អហំ ជានន្តិ យោ វជ្ជា នន្ទី សោ ជនយេ មមំ ៗ
ឯវញ្ច មេ វិលបតោ បវិដ្ឋស្ស ព្រហាវនេ
អហំ ជានន្តិ យោ វជ្ជា វេស្សន្តរនិវាសនំ
តាយ សោ ឯកវាចាយ បសវេ បុញ្ញំ អនប្បកន្តិ ៗ

កោ បុគ្គលោ ឱ! បុគ្គលឯណាអើយ ញ៉ាំងមានដំណឹងនឹងទីលំនៅអាស្រមព្រះបរមវេស្សន្តរបវរពោធិសត្វ ព្រះអង្គមកសាងព្រះផ្នួសបួសជាឥសី ជយន្តមបរាជិតំ ព្រះអង្គឈ្មះមច្ឆរិយធម៌ ដ៏ជាអន្ទាក់ច្រវាក់រណោងណាង ទ្រង់ឱ្យបានដល់នូវព្រះនិព្វាន ព្រះអង្គតែងមានព្រះទ័យ ចង់ឱ្យបានសេចក្តីសុខ

ពុំឱ្យមានទុក្ខដល់អស់អ្នកផងទាំងឡាយ ព្រះអង្គទ្រង់ធម៌ជាទីពឹងពំនាក់នៃស្មូមយាចកទាំងឡាយ ដូចជាព្រះធរណី ជាទីពំនាក់នៃសព្វសត្វទាំងឡាយ ៗ មួយវិញទៀត ព្រះអង្គជាទីប្រជុំចូលគាល់នៃពួកស្មូមយាចក ដូចជាមហាសមុទ្រជាទីប្រជុំហូរចុះ នៃស្ទឹងទន្លេទាំងឡាយ ព្រះបាទស្រីវេស្សន្តរមហាក្សត្រថ្លៃប្រសើរនោះ ព្រះអង្គមានឧបមាដូចជាស្រះស្រង់ មានកំពង់រាបទាបស្រួល អ្នកផងចុះទៅងូតផឹកបានដោយងាយ មានទឹកថ្លាត្រជាក់ ដ៏ដេរដាសដោយផ្កាឈូកស ឈូកច្រាល ដ៏មានលំអងកេសរផ្កាជ្រុះរោយរាយផ្សាយក្លិនក្រអូបឈ្ងុយឈ្ងប់ ពុំនោះសោត មានឧបមាដូចដើមពោធិព្រឹក្ស ដើមជ្រៃ ដើមស្វាយដើមរាំង ឬដើមឈើធំ ៗ ដទៃទៀត ដែលមាននៅជិតផ្លូវជាទីត្រាច់ទៅមកនៃមហាជន ដែលនឿយហត់អស់កម្លាំង ក៏ចូលឈប់សម្រាកកាយបានតាមប្រាថ្នា ព្រោះព្រឹក្សាអស់នោះ មានម្លប់សាខាត្រឈឹងត្រឈៃត្រជាក់ស្រួលសប្បាយ ក្នុងរដូវក្តៅ មានឧបមាដូចម្តេចមិញ ព្រះបាទស្រីវេស្សន្តរមហារាជក្សត្រថ្លៃប្រសើរនោះ មានឧបមេយ្យដូច្នោះដែរ ៗ ឱ! អ្នកឯណាអើយ បានដឹងថា ឥឡូវនេះ ស្តេចគង់នៅទីណា មេត្តាប្រាប់ខ្ញុំតាជីបន្តិចវ៉ា ឱ! អ្នកឯណាអើយ មានចិត្តអាណិតជួយប្រាប់លំនៅព្រះបាទស្រីវេស្សន្តរបវរពោធិសត្វ ដោយវាចា ១ ម៉ាត់ ថា ខ្ញុំដឹងប៉ុណ្ណោះ ខ្ញុំតាជីមានបីតិត្រេកអរ រកអ្វី

ប្រៀបគ្នា ហើយអ្នកនោះ នឹងបានកុសលផលបុណ្យច្រើន នឹងត្រារាប់ពុំបានឡើយ ៗ តាជូជកស្រែកទ្រហោយំ ខ្សឹកខ្សួលរកព្រះបាទស្រីវេស្សន្តរនៅនាព្រៃធំ សម្បើមមហិមា តែម្នាក់ឯងហោង ៗ

តស្ស តំ បរិទេវនសទ្ទំ អារក្ខនត្ថាយ ឋបិតោ ចេតបុត្តោ បពិត្រអើយ ឮដ៏កាលនោះ មានថ្មើរព្រៃម្នាក់ ឈ្មោះចៅចេតបុត្រ លោកសន្មតទុកឱ្យចាំរក្សាទ្វារព្រៃ គាត់ក៏ចេះសិល្បធ្នូ បាញ់មុតមែនក្វែនស្ទាត់ គាត់អាស្រ័យធ្វើជាផ្ទះស្រាស់របង ពុំឱ្យអ្នកផងដើរចូលទៅកាន់ភ្នំគិរីវង្កតបាន គាត់ក៏បណ្ដើរនូវឆ្កែប្រមាណ ១ ស្រែ អំពីផ្លូវទៅកូវ គាត់ចូលដល់ព្រៃធំ លុះឮសូរមាត់តាជូជកទ្រហោយំ ច្រឡំនីទៅនូវសំឡេងឆ្កែវាព្រុស ចេតបុត្រក៏ម្នីម្នាក្រឡេកមើលទៅយល់ឯព្រាហ្មណ៍ស្រមូវនៅលើចុងព្រឹក្សា ទើបចេតបុត្រលាន់មាត់ថា ឱ ! អញថាជាសត្វអ្វី មិនដឹងជាព្រាហ្មណ៍អប្រិយទេហ្ន ម្ដេចក៏មកយំសោករកព្រះបាទស្រីវេស្សន្តរបវរពោធិសត្វ ថាបើដោយអញរំពឹងគិតទៅ ប្រហែលជាមកសុំព្រះរាជបុត្រាបុត្រី ឬសម្ដេចព្រះរាជមន្ទ្រីទៅពុំខាន បើដូច្នេះ អញនឹងសម្លាប់វាបង់ទៅក្នុងកាលឥឡូវនេះឯង ថាហើយ ចេតបុត្រម្នីម្នាប្រវាចាប់ធ្នូ ដំឡើងក្រិត ខាំមាត់ក្រអឺត យកកាំមកផ្ទាប់លើកត្រង់ តម្រង់ទៅកូវ ស្រដីគម្រាមថា អះព្រាហ្មណ៍អប្រិយអើយ អញមិនទុក

ជីវិតចៅឱ្យរស់នៅឡើយ ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលសូត្រសាជាបាទព្រះគាថាដូច្នេះ

តស្ស ចេតោ បដិស្សោសិ អរញ្ញេ លុទ្ធកោ ចរោ
តុម្ហេហិ ព្រហ្មេ បកតោ អតិជាតេន ខត្តិយោ
បព្វាជិតោ សកា រដ្ឋា វង្កេ វសតិ បព្វតេ ។
តុម្ហេហិ ព្រហ្មេ បកតោ អតិជាតេន ខត្តិយោ
អាទាយ បុត្តទារញ្ច វង្កេ វសតិ បព្វតេ ។
អកិច្ចការី ទុម្មេធោ រដ្ឋា វិបិនមាគតោ
រាជបុត្តំ គវេសន្តោ ពកោ មច្ឆមិវោទកេ
តស្ស ត្យាហំ ន ទស្សាមិ ជីវិតំ ឥធ ព្រាហ្មណ
អយំ ហិ តេ មយា នុន្នោ សរោ បាស្សតិ លោហិតំ ។
សិរោ តេ វជ្ឈយិត្វាន ហទយំ ឆេត្វា សពន្ធនំ
បន្ថសកុណំ យជិស្សាមិ តុយ្ហំ មំសេន ព្រាហ្មណ
តុយ្ហំ មំសេន មេទេន មត្ថលុង្គេន ព្រាហ្មណ
អាហុតឹ បគ្គហេស្សាមិ ឆេត្វាន ហទយំ តវ ។
តំ មេ សុយិដ្ឋំ សុហុតំ តុយ្ហំ មំសេន ព្រាហ្មណ
ន ច ត្វំ រាជបុត្តស្ស ភរិយំ បុត្តេ ច នេស្សសីតិ ។

ក្សិណនោះ ចេតបុត្រថ្មើរព្រៃ កំពុងត្រាច់រង្គាត់ទៅក្នុង

ព្រៃ ឮជូជកស្រែកទ្រហោយំរកព្រះបាទស្រីវេស្សន្តរបវរពោធិសត្វ ដូច្នោះកូវ ចេតបុត្រក៏ស្រែកគម្រាមទៅថា វ៉ឺយព្រាហ្មណ៍កញ្ចាស់ ម្ដេចក៏មកយំសោករកព្រះអង្គ បើដោយអញរំពឹងគិតទៅ យល់ជាព្រាហ្មណ៍កញ្ចាស់នេះឯងមករកសុំទាន ទើបវាខំត្រាច់មកដល់អាយ ក៏វាសុំអ្វីមាល្បាយ តាំងពីព្រះអង្គគង់នៅក្នុងព្រះរាជវាំង ដរាបមកគង់នៅក្នុងភ្នំគិរីវង្កត វានាំគ្នាសុំទាំងដំរីបច្ច័យនាគេន្ទ្រក្ដី ជាដំរីព្រះទីនាំង ដ៏ប្រសើរ ពួកវាសុំសព្វសុំគ្រប់ ពុំគិតប្រណី ដោយក្ដីតណ្ហាលោភលន់ទាល់តែអ្នកនគរ ខឹងជាកោលាហល នាំគ្នាក្រាបទូល ប្ដឹងផ្ដល់សម្ដេចព្រះវររាជបិតា ឱ្យស្ដេចបំបរបង់ព្រះអង្គចេញចាកព្រះនគរ ព្រះអង្គតោងនាំព្រះរាជបុត្រាបុត្រី និងព្រះរាជទេពីមកគង់ព្រៃភ្នំគិរីវង្កត ។ ព្រាហ្មណ៍កញ្ចាស់នេះឯងហើយ ជាមនុស្សអប្បលក្ខណ៍ ខំដើរស្វះស្វែងមករកសូមព្រះរាជបុត្រាបុត្រី ដូចកលបក្សី គឺ កុក រនាល កាលឯណា បានយល់ត្រីក្នុងបឹង ត្រពាំង ក្នុងរដូវប្រាំរីងទឹកហែងហួតហើយ តែងហើរមកចាប់ចឹកឆី ដរាបលុះតែអស់ ។ ព្រាហ្មណ៍អប្រិយ៍នេះឯងជាមនុស្សអន្ធពាលកំណាច អាចតាមបំផ្លាញព្រះអង្គ ជាប្រាកដ វាមិនចេះរកឆីចុកលលក់ទន្និញ ព្រាហ្មណ៍ចង្រៃអើយ កុំទន្ទឹងរកព្រះអង្គឡើយ អញពុំទុកជីវិតព្រះស្ដែងឱ្យរស់នៅ តទៅទៀតទេ អញបាញ់នឹងធ្នូឱ្យត្រូវដើមទ្រូងរូងយកថ្លើមប្រមាត់

ញាំភ្លា បូជាក្រុងពាលី ធ្វើពលីការទេពរក្សាច្រកភ្នំ ឯក្បាល ព្រះស្តែងសោត អញនឹងដោតថ្វាយអ្នកតា នៅនាព្រៃភ្នំនេះ ៗ ពះ ! ព្រាហ្មណ៍កញ្ចាស់ចង្រៃ ព្រះស្តែងស្លាប់នឹងដៃអញឥឡូវ ពុំលែងឡើយ ①

សោ តស្ស វចនំ សុត្វា រីឯតាជូជកព្រឹទ្ធាចារ្យ កាលណាឮពាក្យចេតបុត្រព្រានព្រៃស្រដីដណ្តឹង ដូច្នោះហើយ

១- បើប្រែសម្រួលសេចក្តីតាមបាលីគាថាខាងលើនេះ មានទំនងដូច្នេះ " ព្រានចេតបុត្រកំពុងដើរបាញ់សត្វក្នុងព្រៃ (បានឮសំឡេងជូជកស្រែកយំ) ក៏ឆ្លើយតបទៅថា នៃព្រះស្តែងព្រាហ្មណ៍ ព្រះបរមក្សត្រត្រូវពួកព្រះស្តែងបៀតបៀន ព្រោះទ្រង់ព្រះរាជទានដំរីរ័ត្នមង្គលដល់ពួកព្រះស្តែង ទើបគេនាំគ្នាបំបរបង់ព្រះអង្គឱ្យចេញចាកព្រះនគរ ទ្រង់នាំរាជបុត្រាបុត្រី នូវព្រះរាជទេពីមកគង់នៅភ្នំគិរីវង្កត ៗ ព្រះស្តែងនេះហើយជាមនុស្សអប្បលក្ខណ៍ឥតប្រាជ្ញា ធ្វើការដែលមិនគួរធ្វើ ហើយដើរចេញពីស្រុក ចូលមកក្នុងព្រៃ ដើម្បីស្វែងរកព្រះរាជបុត្រ ដូចកុកស្វែងរកចឹកត្រីក្នុងទឹក គ្រានេះ អញមិនទុកជីវិតព្រះស្តែងឱ្យរស់នៅទេ កូនសរដែលអញបាញ់ទៅនេះឯង នឹងហុតឈាមព្រះស្តែង អញនឹងកាត់ក្បាលព្រះស្តែង វះពុះយកបេះដូងទាំងពោះវៀនព្រះស្តែង ហើយនឹងសែនបូជាទេពតាជាម្ចាស់ផ្លូវនេះ ព្រមទាំងសាច់ឈាមព្រះស្តែងផង ៗ ព្រះស្តែងព្រាហ្មណ៍អើយ អញនឹងកាត់យកបេះដូងលើកឡើងបួងសួងបូជា ព្រមទាំងសាច់ខ្លាញ់ខាប់ខួរក្បាលរបស់ព្រះស្តែងផង ៗ ព្រះស្តែងព្រាហ្មណ៍អើយ ការដែលយកសាច់ព្រះស្តែងបូជាយញ្ញានេះ ទុកជាគ្រឿងបូជាយញ្ញាយ៉ាងល្អត្រឹមត្រូវ ម្ល៉េះហើយ ព្រះស្តែងមិនអាចនាំយកព្រះរាជបុត្រាបុត្រីនិងព្រះអគ្គមហេសីរបស់ព្រះអង្គទៅបានឡើយ " ៗ

គាត់ក៏ភិតភ័យ ញាប់ញ័រទាំងខ្លួនប្រាណ ស្មើរបាត់ព្រលឹង ខំប្រឹងស្រដីទាំងញ័រមាត់ អធិប្បាយសេចក្ដីមុសាវាទ ទៅកាន់ចេតបុត្រ ដោយបាទព្រះគាថាដូច្នេះ ថា

អទណ្ឌ្យោ ព្រាហ្មណោ ទូតោ ចេតបុត្ត សុណោហិ មេ
តស្មា ហិ ទូតំ ន ហន្តិ ឯស ធម្មោ សនន្តនោ ។
និជ្ឈត្តា សិវិយោ សព្វេ បិតា នំ ទដ្ឋុមិច្ឆតិ
មាតា ច ទុព្វលា តស្ស អចិរា ចក្ខូនិ ជីយរេ ។
តេសាហំ បហិតោ ទូតោ ចេតបុត្ត សុណោហិ មេ
រាជបុត្តំ នយិស្សាមិ យទិ ជានាសិ សំស①មេតិ ។

ចេតបុត្ត ហៃចៅចេតបុត្រជាសំឡាញ់អើយ អម្បាញ់មិញនេះ ចៅថាបាញ់ៗ តើចៅបាញ់នរណាហ៎ះ ៗ ចេតបុត្រ

១- តាមរូបបាលីគាថាខាងលើនេះ មានដំណើរសេចក្ដីដូច្នេះ " ហៃចេតបុត្រអើយ ចូរអ្នកស្ដាប់ពាក្យខ្ញុំសិន រីព្រាហ្មណ៍ជាទូត ជាអ្នកឥតទោស ហេតុនេះហើយ បានជាគេមិនដែលសម្លាប់រាជទូតទេនេះជាទំនៀមមានមកពីបុរាណ ៗ ឥឡូវនេះពួកអ្នកស្រីពិរាស្ត្រទាំងអស់គ្នាយល់ព្រមឱ្យស្ដេចត្រឡប់ព្រះនគរវិញ ទាំងសម្ដេចព្រះវររាជបិតា ប្រាថ្នាចង់ជួបព្រះអង្គ ៗ ឯសម្ដេចព្រះវររាជមាតាក៏កាន់តែទុព្វលភាពទៅ ទាំងព្រះនេត្រ ទាំងពីររបស់ព្រះអង្គមិនយូរទេនឹងទ្រុឌទ្រោមទៅ(ព្រោះទ្រង់ព្រះកន្សែងឥតស្រាក) ៗ នៃបាចេតបុត្រអើយ ចូរអ្នកស្ដាប់ពាក្យខ្ញុំ ឥឡូវ អ្នកស្រីពិរាស្ត្រអស់នោះតាំងខ្ញុំជារាជទូត ហើយចាត់បញ្ជូនមក ខ្ញុំនឹងក្រាបទូលអញ្ជើញព្រះរាជបុត្រ បើអ្នកដឹងទីប្រថាប់ សូមប្រាប់ខ្ញុំ ក្នុងកាលឥឡូវនេះផង ៗ

ឆ្លើយថា អញមាននរណាជាសំឡាញ់នឹងអញ នៅនាកណ្ដាលព្រៃនេះ ឥតអង្គីមានឡើយ នរណាស្រដីមកនឹងអញ ៗ នឹងបាញ់អ្នកនោះឯងហោង ៗ ទើបជូជកស្រដីថា ឱ! សំឡាញ់អើយ ម្ដេចក៏អ្នកស្រដីរឹងរូសប្រទូស្តពន់ប្រមាណ យល់តែឯងបានធ្ងូ ពាយងាយទំនើងតែនឹងបាញ់ នៃសំឡាញ់អើយ រីអញនេះ ពុំមែនជាស្មូមយាចក តាមមកសុំទាននោះទេ ៗ ហៃសំឡាញ់អើយ អញជាត្រកូលព្រាហ្មណ៍ធំ ឧត្តមប្រសើរក្រៃលែងព្រាហ្មណ៍ផងទាំងឡាយ អញតែងនឹងគិតការព្រះរាជពិធី តាមប្រពៃណីអំពីបុរាណ អញតែងនឹងប្រដៅសិល្បសាស្ត្រព្រះរាជបុត្រឱ្យរៀនសូត្រទាំងពុទ្ធទាំងសេយ្យ ឥឡូវនេះ ព្រះបាទស្រីសញ្ជ័យដ៏ជាព្រះវររាជបិតា មានព្រះជរារោគាព្យាធិមកបៀតបៀនព្រះកាយ ពុំសប្បាយក្នុងព្រះអង្គ ទ្រង់ព្រះចិន្តានឹករលឹកដល់ព្រះរាជបុត្រទាំងពីរព្រះអង្គ, និងព្រះចៅទាំងពីរ ជាបណ្ដូលសង្សារ ទើបមានព្រះរាជឱង្ការតម្រាស់ ត្រាស់ប្រើអញមករកអារាធនាព្រះអង្គទៅគ្រប់គ្រងយោធាសេនាមន្ត្រី គួរអ្វីអ្នកនឹងសម្លាប់អញ ថាបើអ្នកសម្លាប់អញ នឹងបានក្ដីខុសពីរប្រការ ត្បិតអញជាអ្នកនាំព្រះរាជសារ កាន់ព្រះអាជ្ញាព្រះបាទអ្នកជាម្ចាស់ ឯអញនេះជាត្រកូលព្រាហ្មណ៍ធំផង បើនឹងពិឃាដរាជទូតលោក ក៏តាមចិត្ត ឬ មួយនឹងសម្លាប់ផ្ដាច់ជីវិតសមណៈជីព្រាហ្មណ៍ ក៏ពុំ

ត្រូវនឹងប្រពៃណីអំពីបុរាណរៀងមកនោះឡើយ ។

តតោ ចេតបុត្តោ រីឯចេតបុត្រព្រានព្រៃ លុះឮសំដីជូជកព្រាហ្មណ៍ថា ជាអ្នកកាន់ព្រះរាជអាជ្ញា មកអារាធនាព្រះបាទស្រីវេស្សន្តរ បវរពោធិសត្វ ទៅគ្រប់គ្រងរាជសម្បត្តិនាបុរីពិជ័យជេតុត្តរនគរនោះ **សោមនស្សប្បត្តោ** ក៏មានចិត្តត្រេកអរឥតឧបមា **សុនខេ ពន្ធិត្វា** ទើបចេតបុត្រចាប់ឆ្កែចងខ្ទាប់ កាប់ឈើមកពាក់ជាបង្ហោងឱ្យតាជីចុះកកិបកកាបអំពីចុងព្រឹក្សា ហើយឱ្យអង្គុយលើស្លឹកឈើ ធ្វើជាកម្រាលអាសនៈ ទើបឱ្យតាជីបរិភោគភោជនាហារ ត្រាតែឆ្អែតស្កប់ស្កល់ **បដិសណ្ឋារំ ករោន្តោ** ចេតបុត្រព្រានព្រៃក៏ធ្វើសេចក្ដីសំណេះសំណាល ប្រស្រ័យនឹងតាជូជក សូត្រជាបាទព្រះគាថាដូច្នេះ

បិយស្ស មេ បិយោ ទូតោ បុណ្ណបត្តំ ទទាមិ តេ
ឥមញ្ច មធុនោ តុម្ពំ មិគសត្ថិញ្ច ព្រាហ្មណ
តញ្ច តេ ទេសមក្ខិស្សំ យត្ថ សម្មតិ កាមទោតិ ។

ហៃតាព្រឹទ្ធាចារ្យអើយ យើងបានជាស្រដីទ្រគោះគម្រោះគម្រាម ពិតជាទុច្ចរិតវាចា ស្មានជាអ្នកតាមសូមទាន បានជាយើងខឹង ពុំចេរតែអ្នកតាអត់ទោសយើង បានម្ដង ឯអស់ស្បៀងអាហារផង នឹងរកឱ្យតា តាមកម្លាំង **មធុនោ តុម្ពំ** ទាំងទឹកឃ្មុំខែប្រាំង សឹងដ៏មានឱជារស

ឆ្ងាញ់ពិសា **មិគសត្តិពហូ** ទាំងសាច់ទ្រាយឆ្អើរ ចូរអ្នកតាយកទៅគ្រាន់ជាយាបនម័ត្ត បំបាត់ស្រេកឃ្លានទៅឯមុខ **យត្ត សម្មតិ កវមនេវ** រីឯព្រះអាស្រមបរមពោធិសត្វ ព្រះអង្គសាងព្រ័តពោធិញ្ញាណ ជាទីបន្ទោបង់នូវកាមតណ្ហា ទ្រង់ប្រព្រឹត្តនេក្ខម្មបារមី ក្នុងព្រៃរហោឋាន នៅទីឯណា យើងក៏នឹងប្រាប់អ្នកតាឱ្យទៅរកព្រះអង្គ ត្រង់ទីប្រទេសនោះហោង ៗ

ជូជកបព្វំ បពិត្រអើយ អាត្មាភាពសម្តែងថ្លែងព្រះធម៌វិសេសទេសនា ព្រះមហាជាតក៏ **កណ្ឌជូជក** នោះមិញ ដ៏ប្រដាប់ប្រដានីទៅនូវព្រះគាថា ៧៩ ព្រះគាថា **និដ្ឋិតំ** ក៏ចប់បរិបូណ៌សមគួរ ដោយនូវវេលានេះឯងហោង ៗ

ចប់ កណ្ឌជូជក ទី ៥ តែប៉ុណ្ណោះ ៗ

⁂

ចម្លងចប់នៅថ្ងៃ ៥ កើត ខែស្រាពណ៍ ព.ស. ២៥៣៣
ត្រូវនឹងថ្ងៃសុក្រ ទី ២៧ ខែកក្កដា គ.ស. ១៩៩០

មហាវេស្សន្តរជាតក

ទី ៦



កណ្ឌចូឡពន

ប្រដាប់ដោយគាថា ៣៥

មហាវេស្សន្តរជាតក

ទី៦

កណ្ឌចូឡពន

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ឯវំ ចេតបុត្តោ ព្រាហ្មណំ ភោជេត្វា បាថេយ្យស្សត្ថាយ តស្ស មធុនោ តុម្ពញ្ច បក្កមិគសត្ថិញ្ច ទត្វា មគ្គេ ឋបេត្វា ទក្ខិណហត្ថំ ឧក្ខិបិត្វា មហាសត្តស្ស វសនោកាសំ អាចិក្ខន្តោ អាហ ។

ចេតបុត្តោ រីឯចេតបុត្រដ៏ជាត្រកូលព្រានព្រៃ **សុត្វា** លុះបានស្តាប់សំដីជូជកពោលពាក្យកុហកមុសាវាទថា ជារាជទូតព្រះបាទស្រីសញ្ជ័យ ប្រើមកអារាធនាព្រះបាទស្រីវេស្សន្តរបវរពោធិសត្វ ទៅគ្រប់គ្រងរាជសម្បត្តិនាជេតុត្តរនគរដូច្នោះហើយ **ព្រាហ្មណំ ភោជេត្វា** ទើបឱ្យជូជកព្រឹទ្ធាចារ្យបរិភោគអាហារផងដ៏បរិបូណ៌ ពុំយូរឡើយ **ទត្វា** ទើបឱ្យទឹកឃ្មុំនូវបាយនិងសាច់ទ្រាយឆ្អើរ ដ៏មានរសពីសា ប្រយោជន៍នឹងឱ្យជាស្បៀងអាហារតាជូជកនឹងឆីល្បៀងជីវិតទៅឯមុខដោយនូវផ្លូវព្រៃហេមពាន្តហោង **ទក្ខិណហត្ថំ ឧក្ខិបិត្វា** ទើបលើកហត្ថាឯស្តាំ ចង្អុលប្រាប់ផ្លូវទៅដោយជើងគិរីដ៏ជាទីឋានស្ងាត់ជ្រងំ សឹងតែព្រឹក្សា ទើបសូត្រជាបទ

ព្រះគាថាដូច្នេះថា ①

ឯស សេលោ មហាព្រហ្មេ　បព្វតោ គន្ធមាទនោ
យត្ថ វេស្សន្តរោ រាជា　សហ បុត្តេហិ សម្មតិ ៗ
ធារេន្តោ ព្រាហ្មណវណ្ណំ　អាសទញ្ច មសញ្ជដំ
ចម្មវាសី ឆមា សេតិ　ជាតវេទំ នមស្សតិ ៗ
ឯតេ នីលា បទិស្សន្តិ　នានាផលធរា ទុមា
ឧគ្គតា អព្ភកូដាវ　នីលា អញ្ជនបព្វតា ៗ
ធវស្សកណ្ណា ខទិរា　សាលា ផន្ទនមាលុវា
សម្បវេធេន្តិ វាតេន　សកឹ បីតាវ មាណវា ៗ
ឧបរិ ទុមបរិយាយេសុ　សង្គីតិយោវ សុយ្យរេ
នជ្ជុហា កោកិលា សង្ឃា　សម្បតន្តិ ទុមា ទុមំ ៗ
អវ្ហយន្តេវ គច្ឆន្តំ　សាខាបត្តសមីរិតា

១- តាំងអំពី " ចេត្តបុត្តោ រីឯចេតបុត្រ ។ល។ ទើបសូត្រជាបាទព្រះគាថាដូច្នេះថា " មានច្បាប់ខ្លះមានសេចក្តីប្លែកគ្នាដូច្នេះ ភោ សាធវោ ហៃសាធុសប្បុរសផងទាំងឡាយអើយ ឮដ៏កាលនោះ ចេតបុត្រស្រណុកចិត្តនឹងជូជកព្រាហ្មណ៍ ហើយកូវ ក៏ប្រដាប់ប្រដាអាហារមកឱ្យបរិភោគ ជាដើមគឺ សាច់កំភួនភ្លៅឆ្អើរក្រៀម ល្អប្រឡាក់នឹងទឹកឃ្មុំផ្អិត ហើយយកឃ្លោកមកបំពេញនូវទឹកឃ្មុំ នូវសាច់ក្រៀម ប្រយោជន៍ជាស្បៀងនៃជូជកព្រាហ្មណ៍នោះ ហើយនាំទៅបង្ហាញផ្លូវ ទើបលើកដៃស្តាំឡើងចង្អុលណែផ្លូវព្រាហ្មណ៍ថា ហៃតាព្រឹទ្ធាចារ្យអើយ រីផ្លូវនេះឯង ដើរទៅកាន់ព្រះបាទស្រីវេស្សន្តរ ចូរព្រាហ្មណ៍ឯងដើរទៅត្រង់ផ្លូវនេះឯងហោង ។

រមយន្តេច អាគន្តុំ   មោទយន្តិ និវាសនំ ។
យត្ថ វេស្សន្តរោ រាជា   សហ បុត្តេហិ សម្មតិ
ធារេន្តោ ព្រាហ្មណវណ្ណំ   អាសទញ្ច មសញ្ជដំ
ចម្មវាសី ឆមា សេតិ   ជាតវេទំ នមស្សតីតិ ។

មហាព្រហ្មេ ហៃតាព្រាហ្មណ៍ព្រឹទ្ធាចារ្យ ឯស មោះ ឯសោ បព្វតោ រីភ្នំឯណោះ សេលោ មោះ សេលមយោ តាជីអើយសឹងតែថ្មផា ផាសពាសនូវថ្មបាយក្រៀម សឹង ធំ ៗ ជាដុំខៀវស ល្អប្រុះឆ្លុះយល់ឆ្ងាយ ស្វាយក្រហមខៀវលឿង ទាំង ៥ ពណ៌ ល្អប្លែក ៗ ងងឹតអ័ព្ទមេឃបែកជាផ្សេង ភ្នំ នោះឯង លោកសន្មត ហៅឈ្មោះ គន្ធមាទន៍បព៌ត ដ៏មាននូវ គន្ធពិដោរប្រសើរ សឹងឈើក្រអូបល្វេងល្វើយ ខ្ជរខ្ជាយ សព្វ សាយនៅព្រៃប្រទេស វេស្សន្តរោ រាជា រីឯព្រះបាទស្រី វេស្សន្តរបវរពោធិសត្វ នូវរ័ត្នរាជមទ្រី ព្រះរាជបុត្រីបុត្រា ក៏ សឹងជាឧត្តមបរមសុខទាំង ៤ ព្រះអង្គ ចេញមកទ្រង់ព្រ័ត ជា តាបសនៅក្នុងពនាល័យ អើតាជីអើយ ចូរព្រះស្តែងប្រែមុខ ទៅត្រង់ផ្លូវដែលយើងចង្អុលប្រាប់ ក៏នឹងបានប្រសព្វនឹងព្រះ អច្ចុតឫសី អ្នកតែងកាន់ទម្លក់បេះផលាផល តម្កល់ដាក់កញ្ជើ សង្រែក ហើយអ្នករែកលើព្រះអង្សា ចងជដារុំព្រះកេសតាម ភេទឥសី ដណ្តប់ស្បៃស្បែកខ្លាទាំងក្រចក សំបុរច្រោលវិលវង់ អ្នកទ្រង់សំបកឈើតាងព្រះពស្ត្រស្អាត ក្រវាត់ស្បូវភ្នាំង ក្រាល

ក្រងស្លឹកឈើរងជាទីបន្ទំ អ្នកប្រណម្យនមស្ការកងអគ្គី តាមប្រពៃណីអំពីបុរាណ អ្នកគង់នៅនាឋាននោះឯងហោង ព្រឈ្មោហៃតាជូជកព្រាហ្មណ៍ព្រឹទ្ធាចារ្យ **ឯតេ ទុមា** រីឯឈើផងទាំងឡាយសងខាងផ្លូវ ប្រកបនីទៅនូវផលាផល ដោយពណ៌ទីទៃ ៗ ខ្លះខ្ចី ចាស់ ទុំ ស្រគាល ពុំដឹងបើនឹងគណនា **ឧគ្គតា** សឹងដ៏វែងវៀវលៀវខ្ពស់ ៗ **នីលា** ស្លឹកដ៏ខៀវស្រស់ដូចអញ្ជានបព៌ត ពុំដឹងកំណត់ប្រាប់តាព្រឹទ្ធាចារ្យនូវអស់ព្រឹក្សាសឹងដ៏មានមែកបែកសាខា ត្រសាយត្រសុំ **ឆទស្សភណ្ណា** ជាដើមគឺ ត្របែក ត្រសេក ស្ពឺស្ពង់ ចុងពុំរៀវ ស្លឹកខៀវ ដូចអ្នករចនា **ខទិរា** គគីរ ឆាំឆា គុយ គរ ឧទុម្ពរ សឹងដ៏ដុះស្រោងស្រាង សងខាងផ្លូវនឹងទៅគន្ធមាទនគិរី ៗ តាជីអើយ នឹងពណ៌នាងផ្កាក្តាំងងា ចម្ប៉ា ចំប៉ី មាលតី មហាហង្ស ត្រយង់ យុថ្កា ច្បារ នួនស្រី ពុំដឹងបើនឹងស្រដីរាប់ឱ្យគ្រប់ ឈ្ងុយឈ្ងប់សព្វទិសា កេសររុះរោយដោយដីឯសន្លឹក ខ្លះខ្ចី ខ្លះចាស់ ខ្លះទើបនឹងលាស់សន្លឹក ត្រូវខ្យល់បក់ត្រួយរញ្ជួយទៅមករកគ្នា ៗ **ឯទំ មាណទា** ឧបមាបីដូចមាណព ពុំដែលផឹកស្រា **សភិ បីតា** ទើបតែនឹងបានប្រទះផឹកតែម្តង ក៏កម្រើកសរសៃ សំបុរជ្រួញច្រាញ ឱ្យជាស្រៀវស្រាញ អង្រង់សិរសី វង្វេងស្មារតី ខំតែទប់ទល់រីព្រឹក្សាផង មានឧបមាដូចមាណពនុះឯងហោង ៗ ព្រឈ្មោ

ម្នាលព្រាហ្មណ៍អើយ ឯព្រៃខេត្តខេមព្រះហេមពាន្ត សឹងដ៏មានសម្ពាក់នៃបក្សាបក្សី តែងនឹងអាស្រ័យនៅ សព្វវេលា ហើរនាវេហាស័យាសយំ ចុះមកទំដោយលង្វែកនាមែកសាខា ខ្សេវខ្សាវដោយភាសាឮល្វេងល្វើយ សឹងតែសំឡេងពីរោះ **នជ្ជុហា** រីបក្សីទាំងឡាយនោះ គឺប៉ោលតោក ក្រួក តាវៅ ស្វិតចៅ ចាកក្រពាក ចង្កៀលខ្យង ត្រយង ត្រុំ ត្លុម ស្ទាំង ភូរាំង ឧកអក លលក សារិកា ឆ្មៀងរកអាហារ សំឡេងកង្កួច គ្រលួច បីដូចនូវតូរ្យតន្ត្រី ត្រែស័ង្ខ រគាំងភេរី ពិណពាទ្យ រងំសមគ្នា ទាំងសងខាងមគ្គានោះ តាជីអើយ មុខគួរស្រណោះពន់ប្រមាណ ៗ **សាខាបត្តសមេរិតា** ហៃតាជូជកអើយ រីមែកនូវសន្លឹកឈើផងទាំងឡាយ បើព្រះពាយបក់មកត្រូវ សឹងដ៏ទន្ទងទៅមករកគ្នា ហាក់ដូចមនុស្សម្នាស្រែកដង្ហោយ ហៅនូវបុគ្គលដែលដើរទៅមកទាំងឡាយ កើតមានសេចក្តីសប្បាយអភិរម្យក្នុងប្រាណនៃបុគ្គលអ្នកបានដើរទៅមកនោះឯងហោង ៗ **ចេតបុត្តា** រីឯចេតបុត្រ ដ៏ជាត្រកូលព្រានព្រៃ នាកាលប្រស្រ័យពណ៌នា អំពីព្រះអាស្រមព្រះបរមពោធិសត្វ ក៏សូត្រជាបាទព្រះគាថាដូច្នេះថា

អម្ពា① **កបិដ្ឋា បនសា   សាលា ជម្ពូ វិភេទកា**

១- បើប្រែតាមរូបសព្ទបាលីគាថានេះដូច្នេះ " ក្នុងទីបរិវេណព្រះអាស្រមព្រះបរម-

ឆ្លង . . .

ហរីតកី អាមលកា   អស្សត្ថា ពទរានិ ច ។
ចារុតិម្ពរុក្ខា ចេត្ថ   និគ្រោធា ច កបិដ្ឋនា
មធុមធុកា ថេវន្តិ   នីចេ បក្កា ចុទុម្ពរា ។
បារេវតា ភវេយ្យា ច   មុទ្ទិកា ច មធុត្ថិកា
មធុំ អនេលកំ តត្ថ   សកមាទាយ ភុញ្ជរេ ។

ពោធិសត្វនោះ មានដើមស្វាយ ដើមខ្វិត ដើមខ្នុរ ដើមរាំង ដើមព្រីង ដើមសម៉ីពិភេក សម៉ីស្រុក កន្ទួតព្រៃ ដើមពោធិ៍ ដើមពុទ្រា ដើមទម្លាប់មាស ដើមជ្រៃ ដើមក្រសាំង ដើមទំពាំងបាយជូ ដើមម័កសាង ដើមល្វា សឹងតែមានផ្លែទុំច្រាលនៅទាប ៗ ៗ ជិតបរិវេណអាស្រមនោះ មានចេកអំបូង ចេកស្អែង ចេកណាំវ៉ា មានរសឆ្ងាញ់ពីសាដូចទឹកឃ្មុំក៏មាន សំបុកឃ្មុំឥតមេឃ្មុំហ្មួងហែងក៏មាន បុគ្គលឈោងដៃបេះប្រលេះ យកមកបរិភោគខ្លួនឯងបាន ឯដើមស្វាយទាំងឡាយ នៅទីនោះ ចំពូកខ្លះកំពុងចេញផ្ការីករោយរាយ ចំពូកខ្លះជ្រុះផ្កាហើយចេញជាផ្លែ ខ្លះខ្ចី ខ្លះទុំ ទាំងពីរយ៉ាង មានពណ៌ដូចខ្នងកង្កែបក៏មាន ៗ មួយវិញទៀត ផ្លែស្វាយទុំ ៗ នៅជិតព្រះបណ្ណសាលានោះ បុរសឈរក្រោមដើម ក៏ឈោងដៃបេះយកបាន ផ្លែស្វាយទាំងខ្ចី ទាំងទុំ សុទ្ធតែមានសម្បុរល្អ ក្លិនក្រអូប រសផ្អែមជាបំផុត ខ្ញុំមានសេចក្ដីអស្ចារ្យក្រៃពេក សូរសព្ទហឹងៗឮជាក់ច្បាស់ដល់លំនៅរបស់ព្រះបាទស្រីវេស្សន្តរ ជាទីសុខសម្រាន្ត ដូចលំនៅរបស់ទេពតា ល្អល្អះសោភា ដូចឧទ្យាននន្ទនវ័ន មានដើមត្នោត ដើមដូង ដើមល្មើ មានពាសពេញក្នុងព្រៃធំ ផ្កាទាំងឡាយ តាំងនៅរវៀងរាយ ដូចជាកម្រងផ្កាដែលគេបានចងក្រងទុកហើយ ចុងព្រឹក្សាមើលឃើញច្រ្លងច្រាងដូចចុងទង់ជ័យដ៏រុងរឿងល្អដោយផ្កាទាំងឡាយមានពណ៌ផ្សេង ៗ បីដូចពពួកផ្កាយនៅលើមេឃដូច្នោះ ៗ ក្នុងព្រឹក្សា

ឆ្លង...

អញ្ញត្ថ បុប្ផិតា អម្ពា   អញ្ញេ តិដ្ឋន្តិ ទោវិឡា
អញ្ញេ អាមា ច បក្កា ច   ភេកវណ្ណា តទូភយំ ។
អថេត្ថ ហេដ្ឋា បុរិសោ   អម្ពបក្កានិ គណ្ហតិ
អាមានិ ចេវ បក្កានិ   វណ្ណគន្ធរសុត្តមា ។
អត្តេវ មេ អច្ឆរិយំ   ហិង្ការោ បដិភាតិ មំ
ទេវានមិវ អាវាសោ   សោភតិ នន្ទនូបមោ ។

នោះ មានដើមខ្លែងគង់និងអង្គាសដី ដើមបុស្សនាគតូច បុស្សនាគធំ ដើមរាជព្រឹក្ស ដើមមក្លឿ ដើមក្រស្នា ដើមរាក់ខ្មៅ ដើមទ្រនំមាន់ ដើមបេង ដើមស្រល់ ដើមក្ទម្ព និងដើមខ្ទុរសម្ល ដើមត្របែក ដើមរាំងភ្នំ សុទ្ធតែមានផ្កាជាចង្កោម ៗ ដូចកណ្ដាប់ស្រូវ កំពុងរីកស្គុសស្គាយនៅក្រោមមែកព្រឹក្សា ។ នៅជិតព្រះអាស្រមបទនោះ មានស្រះបោក្ខរណីមានសណ្ឋាន ៤ ជ្រុង នៅលើភាគផែនដីជាទីតម្រេកចិត្ត ដ៏ដេរដាសដោយផ្កាបទុមនិងឧប្បលដូចព្រះនន្ទនបោក្ខរណីនៃពួកទេពតា ។ នៅជិតស្រះនោះ មានហ្វូងសត្វតាវៅ ចាប ទំលើមែកព្រឹក្សា ពុលស្រវឹងនឹងរសផ្កាឈើ ក៏និយាយចរចា ដោយសំឡេងពីរោះ ធ្វើឱ្យព្រៃព្រឹក្សា ឮសូរស៊ានគឹកកង កាលដើមឈើមានផ្ការីក តាមរដូវកាល មានកេសរផ្កាជ្រុះរុះរាយមកនៅលើស្លឹកឈូក សឹងមានឱជារសផ្អែម ៗ ដូចទឹកឃ្មុំ ហើយកកើតទៅជាខណ្ឌស្ករ ។

មួយវិញទៀត ខ្យល់ទិសខាងត្បូងខ្យល់ទិសខាងលិច រមែងបក់បោកព្រៃព្រឹក្សាមក ធ្វើឱ្យព្រះអាស្រមបទរោយរាយដេរដាសដោយកេសរផ្កាបទុមជាតិ ហើយក្នុងស្រះបោក្ខរណីនោះសោត មានផ្លែក្រចាប់ធំ ៗ មានទាំងស្រូវសាលីកើតឯង ខ្ចីខ្លះ ចាស់ខ្លះ រុះដេរដាសនៅលើទឹក ឯទឹកក្នុងស្រះបោក្ខរណីនោះសោត ក៏ថ្លាស្អាតល្អ

ឆ្លង . . .

វិភេទកា នាឡិកេរា ខជ្ជុរីនំ ព្រហាវនេ
មាលាវ គន្ថិតា ឋន្តិ ធជគ្គានេវ ទិស្សរេ ៗ
នានាវណ្ណេហិ បុប្ផេហិ នភំ តារា ចិតាមិវ
កុដជី កុដ្ឋតគ្គរា បាដលិយោ ច បុប្ផិតា ៗ
បុន្នាគា គិរិបុន្នាគា កោវិឡារា ច បុប្ផិតា ៗ
ឧទ្ទាលកា សោមរុក្ខា អគរុភល្លិយា ពហូ
បុត្តជីវា ច កុក្កុដា អសនា ចេត្ថ បុប្ផិតា ៗ
កុដជា សលឡា នីបា កោសម្ពលពុជា ធវា
សាលា ច បុប្ផិតា តត្ថ បលាលខលសន្និភា ៗ
តស្សាវិទូរេ បោក្ខរណី ភូមិភាគេ មនោរមេ

មើលទៅឃើញហ្វូងត្រីអណ្ដើកក្ដាមជាច្រើនដែលត្រាច់ទៅមកតាមក្រុមហ្វូងវា ឯរសជាតិទឹកដែលហូរចេញពីចុងឫសឈូក មានរសផ្អែមដូចទឹកឃ្មុំ ដែលហូរចេញមកពីមើមឈូក មានរសជាតិដូចជាទឹកដោះស្រស់ ទឹកដោះរាវ ទឹកដោះខាប់ ៗ ព្រៃព្រឹក្សានោះមានគ្រឿងក្រអូប មានក្លិនផ្សេង ៗ ដែលខ្យល់បក់បោកមក រមែងក្រអូបឈ្ងុយសាយសព្វទៅ ហាក់ដូចជាព្រៃព្រឹក្សានោះ ស្រែកអញ្ជើញអ្នកដែលបានមកដល់ហើយ ឱ្យក្សេមក្សាន្តរីករាយ ដោយផ្កាឈើនិងមែកឈើដែលមានក្លិនក្រអូបទាំងឡាយ បណ្ដាហ្វូងសត្វកន្លង់សប្បាយនឹងក្លិនផ្កាឈើ តែងនាំគ្នាហើរទ្រហឹងអឹងអ័ព្ទដោយជុំវិញ ៗ

មួយវិញទៀត បណ្ដាសត្វបក្សាបក្សី ក្នុងព្រៃនោះ មានច្រើនយ៉ាង មានពណ៌ផ្សេង ៗ គ្នា ខ្លះក៏ស្រែកយំរងាវរកគ្នា ខ្លះក៏ស្រែកកៀងកាល់ញីរបស់វា មានហ្វូងបក្សាបក្សី ៤ ចំពូកទៀត ធ្វើសំបុកនៅជិតស្រះបោក្ខរណី ចំពូកទី ១ ឈ្មោះ នន្ទិកា

ឆ្លង...

បទុមុប្បលសញ្ឆន្នា ទេវានមិវ នន្ទនេ ។
អថេត្ថ បុប្ផរសមត្តា កោកិលា មញ្ជុភាណិកា
អភិនាទេន្តិ តំ វនំ ឧតុសម្បុប្ផិតេ ទុមេ ។
ភស្សន្តិ មករន្ទេហិ បោក្ខរេ បោក្ខរេ មធូ
អថេត្ថ វាតា វាយន្តិ ទក្ខិណា អថ បច្ឆិមា ។
បទុមកិញ្ជក្ខរេណូហិ ឱកិណ្ណោ ហោតិ អស្សមោ
ថូលា សិង្ឃាដកា ចេត្ថ សសាទិយា បសាទិយា ។
មច្ឆកច្ឆបព្យាវិធា ពហូ ចេត្ថ មុបយានកា
មធុំ ភិសេហិ សវតិ ខីរំ សប្បិ មុឡាលិភិ
សុរភិ តំ វនំ វាតិ នានាគន្ធសមេរិតំ ។
សម្មោទិតេវ គន្ធេហិ បុប្ផសាខាហិ តំ វនំ

(មានសត្វហត្ថីលិង្គជាប្រធាន) ចំពូកទី ២ ឈ្មោះជីវបុត្តា ចំពូកទី ៣ ឈ្មោះជីវបុត្តាបិយាចនោ (មានសត្វក្ងោកជាប្រធាន) ចំពូកទី ៤ ឈ្មោះបិយាបុត្តាបិយានន្ទា (សឹងស្រែកថ្វាយព្រះពរសព្ទសាធុការដល់ព្រះបាទស្រីវេស្សន្តរជានិច្ច) ។ ឯផ្កាឈើទាំងឡាយ តាំងនៅរៀងរាយដូចកម្រងផ្កាដែលបុគ្គលក្រងទុកល្អហើយ ចុងព្រៃព្រឹក្សាមានគួរនាដូចចុងទង់ជ័យ ទាំងមានផ្កាផ្លាស់ពណ៌ផ្សេងៗ ដូចមេជាងកម្រងផ្កាដ៏ឆ្លាតបានក្រងទុកល្អហើយ សឹងមានគ្រប់គ្រាន់នៅនាព្រះអាស្រមបទដែលព្រះបាទស្រីវេស្សន្តរព្រមទាំងព្រះមហេសីព្រះរាជបុត្រាបុត្រីទ្រង់ភេទជាព្រាហ្មណ៍ ស្លៀកដណ្តប់ស្បែកខ្លាឃ្មុំ ទ្រង់ជដា ទ្រង់កាន់ជ្រនីកនិងទម្លក់សម្រាប់ជីកមើមដំឡូង និងបេះផ្លែឈើ ស្តេចផ្ទំលើប្រឹថពី តែងទ្រង់នមស្ការព្រះអគ្គី (តាមប្រពៃណីឥសីពីបុរាណ) ។

ភមរា បុប្ផគន្ធេន សមន្តាមភិនាទិតា ។
អថេត្ត សកុណា សន្តិ នានាវណ្ណា ពហូ ទិជា
មោទន្តិ សហ ភរិយាហិ អញ្ញមញ្ញំ បកូជិនោ ។
នន្ទិកា ជីវបុត្តា ច ជីវបុត្តា បិយាចនោ
បិយា បុត្តា បិយា នន្ទា ទិជា បោក្ខរណី ឃរា ។
មាលាវ គន្ថិតា ឋន្តិ ធជគ្គានេវ ទិស្សរេ
នានាវណ្ណេហិ បុប្ផេហិ កុសលេហិ សុគន្ធិតា ។
យត្ថ វេស្សន្តរោ រាជា សហ បុត្តេហិ សម្មតិ
ធារេន្តោ ព្រាហ្មណវណ្ណំ អាសទញ្ច មសញ្ជដំ
ចម្មវាសី ឆមា សេតិ ជាតវេទំ នមស្សតីតិ ។

ព្រហ្មេ ហៃតាអាចារ្យអើយ ឯព្រៃព្រះហេមពាន្តនោះ ដ៏ប្រកបនីទៅនូវព្រៃធំ ព្រៃដង្គុំ របោះ ចន្លោះគុម្ពោត ញាត ញឹក សោកម៉ោក សឹងច្រើនក្រៃអនេក រីអស់ព្រៃព្រឹក្សា នោះ មានពណ៌ទីទៃ ៗ ពុំដឹងបើនឹងប្រាប់ តាជីអើយ យើង នឹងរាប់ឱ្យអស់សេចក្តី អម្ពា រីស្វាយព្រៃ ស្វាយស្រុកសឹង ដ៏ដុះប្រកិត ទាំងក្រសាំងនូវខ្វិតផ្លែដូចរំយោល រំដួល ពុទ្រា វិភេទកា សម៉ី ត្រៀលស្វា កន្ទួតព្រៃ កន្ទួតស្រុក ផ្លែដូច គេចាក់គរ ឧទុម្ពរ ព្និល ព្នៅ បង្គា បង្គៅ ម័កប៉ែន គូលែន សិរមាន់ ចាន់ ម័កបាត លាំងសាត ទុរេន មៀន ប្រដាក ម័កប្រែង ម័កប្រាង ម័កសាង ម័កដោក ឪឡោក

ខ្ទឹង ខ្លាស់ ដូងព្រះ ស្រឡៅ តាត្រៅ ត្រៀក ត្រាច ផ្តុក ផ្តៀក អង្កាញ់ អង្កោល កណ្តោល កណ្តាក់ ចម្បក់ រាំងភ្នំ ស្រគំ ពង្រ ញ ព្រីង ព្លូស ជន្លួស ក្រកោះ លំពោះ ក្រវាន់ ច័ន្ទន៍ក្រស្នា ភេកា ការកេស ចេកទេស ត្រយង់ សឹងដ៏ដុះរហង់ដោយមាគ៌ា ៗ **ចារុតិម្ពរុក្ខា** មង្ឃុត ល្មុត សេដា ពុទ្រា ធ្នា ធ្នុង ដងអង្គាល់ អម្ពិល ទ្រមូង គ្រញូង ក្រឡាញ់ ឯផ្កានោះមិញដូចគេព្យួរ ជាកួទាំងទង **មធុមធុកា** ភ្លូ ភ្លូង ទម្លាប់ ខ្លះខ្ចិប ខ្លះទុំ ផ្អែមលើសទឹកឃ្មុំរង្វូស្ករ បរិភោគសឹងដ៏មានរស មានដើមពុំទាបពុំខ្ពស់ ល្មមតែឈោងបេះប្រលេះនឹតាមចិត្តសប្បាយ **ផេទន្តិ** មុខគួរស្រណោះនឹងអស់ព្រឹក្សា សឹងតែផ្លែផ្កាច្រាសច្រាល ខ្លះស្រគាល ខ្លះទុំដ៏មាននៅខាងព្រះបរមសាលានោះ ៗ **ព្រហ្មេ** ហៃតាអាចារ្យអើយ **កទ្ទលិយោ** រីចេក អំពៅ ត្រាវ ដំឡូង ដូង ស្លា ដុះនៅសងខាងមាគ៌ាទៅឯមុខនោះ **ជារេចតា** មានទាំងចេកភ្លុក ចេកព្រៃ ចេកស្អែង សឹងដ៏ដុះឯងទាប ៗ ដោយមាគ៌ា ចេកជ្វា ចេករាជសីហ៍ ផ្លែវែងរទង ៗ ស្ពងអូសដោយដី ជារយ ជាពាន់ ចេកពងមាន់ ចេកអំបូង ខ្លះលេចត្រយូង ស្រគាល ទុំផ្អែមដូចទឹកឃ្មុំ ដ៏មាននៅខាងព្រះអាស្រមនោះឯងហោង ៗ **ព្រហ្មេ** ហៃតាអាចារ្យអើយ នឹងពណ៌នាឯព្រៃព្រឹក្សាច្រើនផ្សេង ៗ ពុំដឹងបើនឹងរាប់ឱ្យគ្រប់ **ទិកេឌកា**

មានក្រស្នា ចួងច័ន្ទន៍ ឈើពាន់ ដីប្លី បព្ញាកាណី ក្លាំពាក់ ក្លាំពារ ម្នាងសិលា ច័ន្ទន៍ស ច័ន្ទន៍ក្រហម ធាដឈិយោ ការកេស ចេកទេស ចម្ប៉ា នួនស្រី មាលតី មហាហង្ស បុប្ផិតា ផ្កាសឹងដ៏រីករាយ សន្លឹកត្រសុំសាខា ហាក់ដូចមនុស្សម្នារៀបរណ្តាប់ អចិន្ទូរេ ក៏មាននៅខាងព្រះអាស្រមនោះឯងហោង ៗ មួយសោត ឯស្រះស្រង់ ក៏សឹងដ៏បួនជ្រុងស្មើរិះរាប ពុំទាបខ្ពស់ដូចអ្នករចនា ទឹកថ្លាយង់យល់ដី មានផ្កាឧប្បល ចង្កុលណី លំចង់ ស្បង្ក័ជ សឹងដ៏ដុះលាយលេចគ្នា មានផ្ការីករហង់ពេញ ក្នុងស្រះបោក្ខរណីច្រើនក្រៃពន់ប្រមាណ មានហ្វុងមច្ឆាហែលវេរាទៅមករកគូជាដើមគឺ ប្លាមូ ប្លាម៉ា គុជ្រា អណ្តែងងាំង គល់រាំង រាហូ ឆ្តោ ផ្ទក់ ក្អុក ក្ញី ក្រាយ ក្លាំងហាយ ក្លាំងហាត ស្លាត ដងខ្ទែង ច្រកែង ឆ្ពិន ក្ងាន់ ទីពោ បង្គា បង្កង កំពឹស ចង្វាផង សឹងរកអាហារជាចំណី ក៏មាននៅនាស្រះស្រីនោះឯងហោង ៗ ព្រឃ្លេ ហៃតាព្រឹទ្ធាចារ្យអើយ យើងនឹងពណ៌នាឯបក្សីបក្សាផងទាំងឡាយ ក៏សឹងហើរប្រញាយទៅមក ខ្លះហើរទាបមកនាផែនដី ឆាបចំណីអាហារព័ស្តុផង យំកងរំពងនៅខាងអាស្រម សំឡេងរងំ ថ្វាយព្រះពរ ពុំដែលដាច់ខាតខាន ថា បពិត្រព្រះបាទ សូមចម្រើនសុខសួស្តី កុំបីមានទុក្ខសព្វទិវារាត្រី ឱ្យប្រកបនូវ

មហេសីបុត្រាបុត្រី ជាលីក្រស្នា សូមមានព្រះជន្មវស្សាយឺនយូរ សុខសួស្តី ដោយតេជះបារមីចតុព្រហ្មវិហារ នៃព្រះអង្គទ្រង់ព្រះរាជសម្ភារនោះឯងហោង ៗ

ឯវំ ចេតបុត្តេន វេស្សន្តរស្ស វសនដ្ឋានេ អក្ខាតេ ជូជកោបិ តុស្សិត្វា បដិសន្ថារំ ករោន្តោ គាថមាហ នាកាលចេតបុត្រព្រានព្រៃ ប្រស្រ័យពណ៌នាប្រាប់ព្រឹក្សាដល់តាព្រឹទ្ធាចារ្យសព្វសេចក្តី តាជីក៏ត្រេកអរសោមនស្សា ក៏សូត្រជាបាទព្រះគាថាដូច្នេះ

ឥទញ្ច មេ សត្តុភត្តំ មធុនា បដិសំយុតំ
មធុបិណ្ឌិកា ច សុកតាយោ សត្តុភត្តំ ទទាមិ តេតិ ។

ចេតបុត្ត ហៃចៅចេតបុត្រ ដ៏ជាត្រកូលព្រានព្រៃ ដ៏ជាក្លួយសំឡាញ់ អ្នកពិកក្សរក្សាទ្វារផ្លូវ នឹងទៅឯអាស្រមបទ អ្នកប្រាប់ឱ្យមាដឹង ប្រាគដនូវរបោះចន្លោះព្រៃ អើ! មាគាប់ចិត្តណាស់ហើយ ក្លួយសំឡាញ់មាអើយ មានឹងរកអ្វីតបស្នងសងគុណនោះពុំបានឡើយ មានតែចំណីដែលដៃនាងអមិត្តតាបនា ដ៏ជាភរិយាសំឡាញ់មា នាងរៀបរណ្តាប់ ឱ្យមកទើបជូជក កើចយកថង់យាមមកបង្អួតចេតបុត្រព្រានព្រៃ ៗ

តំ សុត្វា ចេតបុត្តោ អាហ ក្សិណនោះ ចេតបុត្រព្រានព្រៃ ស្តាប់ពាក្យព្រាហ្មណ៍ហើយ ឆ្លើយថាដូច្នេះ

តុយ្ហេវ សម្ពលំ ហោតុ នាហំ ឥច្ឆាមិ សម្ពលំ

ឥតោបិ ព្រហ្មេ គច្ឆាហិ គច្ឆ ព្រហ្មេ យថាសុខំ ៗ
អយំ ឯកបទី ឯតិ ឧជុំ គច្ឆតិ អស្សមំ
ឥសីបិ អច្ចុតោ តត្ថ បង្កទន្តោ រជស្សិរោ
ធារេន្តោ ព្រាហ្មណវណ្ណំ អាសទញ្ច មសញ្ជដំ ៗ
ចម្មវាសី ឆមា សេតិ ជាតវេទំ នមស្សតិ
តំ ត្វំ គន្ត្វាន បុច្ឆស្សុ សោ តេ មគ្គំ បវក្ខតីតិ ៗ

ហៃព្រាហ្មណ៍អើយ សដូវខៅតាក តានឹងឱ្យយើងភោក្តា ក៏យើងពុំប្រាថ្នាឡើយ ចូរយកទៅជាស្បៀង លៀងជីវិតទៅឯមុខ តាជូជកអើយ វីផ្លូវនោះត្រង់ ពុំវៀច ពុំវង្វេង ទៅមុខទៀតជាផ្លូវចង្អៀត ចុះតែជើងអ្នកមួយដើរ ចូរតាកុំថប់ តានឹងបានប្រសព្វនឹងព្រះអច្ចុតឫសី បង្កទន្តោ ធ្មេញអ្នកសស្វាចដូចជាចាន ហើយមានរោមចង្កា ឯសិរសាដ៏ពេញនីទៅនូវល្អងធូលី ដូចគេប្រឡាក់ អ្នកពាក់ស្បែកខ្លាជានិច្ចកាល ពុំដែលដាច់ខាន អ្នកសេយ្យាស លើពសុធាតាងពូកព្រំ អ្នកបង្គំហោមពិធីតាមប្រពៃណីឥសីអំពីបុរាណ អ្នកគង់នៅនាឋាននោះឯងហោង ៗ

តមត្ថំ បកាសេន្តោ សត្ថា អាហ វីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គសូត្រសានូវបាទព្រះគាថាដូច្នេះ

ឥទំ សុត្វា ព្រហ្មពន្ធុ ចេតំ កត្វា បទក្ខិណំ

ឧនត្តចិត្តោ បក្កាមិ យេនាសិ អច្ចុតោ ឥសីតិ ។

ភិក្ខវេ ម្នាលសង្ឃដ៏ខ្លាចភ័យ ក្នុងវដ្តសង្សារទាំងឡាយអើយ **ព្រហ្មពន្ធុ** រីតាព្រឹទ្ធាចារ្យដ៏ជាផៅពង្សអ្នកហីនហោច ប្រយោជន៍ចង់លោភលន់ **បនត្ថិណំ កត្វា** តាចាស់ជរាដើរប្រទក្សិណ ៣ ជុំ ចេតបុត្រហើយ **ឧនត្តចិត្តោ** ពុំលង់ឡើយ តាជីមានចិត្តរីករាយស្រដីលាថា ក្មួយសំឡាញ់មាអើយ ចូរអ្នកនៅឱ្យសប្បាយ កុំបីមានទុក្ខសោករោគ ភ័យជរាព្យាធិ មានេះនឹងលាអ្នកទៅហើយ ពុំលង់ឡើយ តាជីក៏យកសំពត់ មកក្រវាត់ព័ទ្ធចង្កេះផង យកថង់មកដាក់លើស្មា ហត្ថាប្រវាចាប់ឈើច្រត់មកទប់ប្រាណ ដើរចេញអំពីឋាននោះទៅងងក់ ៗ តាជីខំតែទប់ជីពប់ដួលខ្មោក ថង់យោគដូចគេគ្រវាត់ ភ្លាត់ធ្លាក់អំពីស្មា លាន់មាត់ថា ចុច្ចៈ ពះ ! ទប់ឱ្យបានគិតស្មានថាជាឆ្កែវាដេញ ដូចអំពីមុនមិញនោះ ខំស្រែកគម្រោះគំរើយ បង្អើល ថា ឆ្កែ ៗ បែរមុខទៅមើលលុះពុំឃើញ ទើបតាចាស់ទំពែកនៅតែជាយគ្រែង កណ្តាលរលីងហ្មត់ យកឈើច្រត់មកផ្ទប់ដើរទៅតាមមាគ៌ា **អស្សមោ** ឆ្ពោះសំដៅទៅអាស្រមនៃមហាអច្ចុតឫសី **អហោសិ** មាននៅ **យត្ថ បទេសេ** នាឋានប្រទេសណា **បក្កាមិ** តាជីក៏ដើរសំដៅទៅ **តំ បទេសំ** កាន់ឋានលំនៅ

ប្រទេសនោះឯងហោង ។

ចូឡបណ្ណាសា និដ្ឋិតា បពិត្រអើយ អាត្មាភាព សម្តែងថ្លែងព្រះធម៌វិសេសទេសនា ព្រះមហាជាតក៏ កណ្ឌចូឡពន ដ៏ប្រដាប់ប្រដានូវគាថា ៣៥ គាថា ជាគ្រឿងប្រដាប់សតិប្បញ្ញា នៃឧបាសកឧបាសិកា ក៏ចប់បរិបូណ៌ សមគួរ ដោយនូវវេលានេះឯងហោង ។

ចប់ កណ្ឌចូឡពន ទី ៦ តែប៉ុណ្ណោះ ។

⁂

ចម្លងចប់នៅថ្ងៃ ៦ កើត ខែស្រាពណ៍ ព.ស. ២៥៣៣
ត្រូវនឹងថ្ងៃសៅរ៍ ទី២៨ ខែកក្កដា គ.ស. ១៩៩០

មហាវេស្សន្តរជាតក

ទី ៧



កណ្ឌមហាពន

ប្រដាប់ដោយគាថា ៨០

មហាវេស្សន្តរជាតក

ទី ៧

កណ្ឌមហាពន

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

គច្ឆន្តោ សោ ភារទ្វាជោ   អទ្ទស អច្ចុតំ ឥសិ
ទិស្វាន តំ ភារទ្វាជោ សម្មោទិ ឥសិនា សហ ។

ភោ សាធវោ ហៃសាធុសប្បុរសផងទាំងឡាយអើយ ឰដ៏កាលនោះ រីជូជកព្រាហ្មណ៍ ដើរចេញអំពីចេតបុត្របង្ហាញផ្លូវ ទៅដល់យល់មហាឥសីមួយរូប ឈ្មោះអច្ចុតមហាឫសីកូវ ជូជកក៏មានសេចក្ដីត្រេកអរ សំណេះសំណាលជាមួយនឹងឥសី សូត្រសានូវបាទព្រះគាថាដូច្នេះ

កច្ចិ នុ ភោតោ កុសលំ   កច្ចិ ភោតោ អនាមយំ
កច្ចិ ឧញ្ឆេន យាបេថ   កច្ចិ មូលផលា ពហូ ។
កច្ចិ ឌំសា មកសា ច   អប្បមេវ សិរីសបា
វនេ វាឡមិគាកិណ្ណេ   កច្ចិ ហឹសា ន វិជ្ជតីតិ ។

ភោ តាបស បពិត្រព្រះតាបសឫសី ដ៏មានសិរីសួស្ដីប្រសើរអើយ អញខ្ញុំចង់សួរដណ្ដឹងអម្ចាស់ អំពីកាលអ្នកមកសាងផ្នួសបួសជាមហាឫសី សូត្រមន្តចម្រើនមេត្តាភាវនានៅនាព្រៃស្ងាត់ជ្រងំម្នាក់ឯង រីជំងឺអាពាធព្យាធិ ញុំាង

បៀតបៀនពាធាអ្នក នៅនាអាស្រមបទនេះឬទេ ៗ មួយសោត នាបីហៅទុក្ខភ័យចង្រៃឧបទ្រពអផ្សុកពុំស្រណុក ជាកលិយុគ នៅនាព្រៃសព្វថ្ងៃនេះ តើញាំងមានឬទេ ៗ បពិត្រព្រះតាបសឫសីអើយ នាស្វែងរកផ្លែឈើមើមឈើ មកចិញ្ចឹមអាត្មាដោយអ្នកបួស នៅនាព្រៃនេះ តើញាំងមានឬទេ ៗ មួយសោត រីមូស សុច ស្រាំង ស្រួយ ខ្មួយ ក្អែប មមង់ មមាច កន្ទេចអាលផង ផ្សំច្រឡំនីទៅនូវពស់តូច ពស់ធំ ថ្លាន់ ថ្លែន ខ្យាដំរីផង ៗ មួយសោត រីម្រឹគពាឡយង់ឃ្នងផងទាំងឡាយ ដ៏ច្រើន មានរាជសីហ៍ ដំរីព្រៃ សិង្ហ ខ្លា រមាស ទន្សោងខ្លោង គោព្រៃផង តើញាំងមានច្រើនឬទេ ចូរអ្នកថ្លែងសម្ដែងប្រាប់ ដោយនូវពំនិតហោង ៗ

តាបសោ អាហ ក្សិណនោះ តាបសឫសី ស្ដាប់ពាក្យជូជកព្រាហ្មណ៍ហើយ ក៏សូត្រជាបាទគាថាដូច្នេះ

កុសលញ្ចេវ មេ ព្រហ្មេ អថោ ព្រហ្មេ អនាមយំ
អថោ ឧញ្ឆេន យាបេមិ អថោ មូលផលា ពហូ ៗ
អថោ ឌំសា មកសា ច អប្បមេវ សិរីសបា
វនេ វាឡមិគាកិណ្ណេ ហឹសា មយ្ហំ ន វិជ្ជតិ ៗ
ពហូនិ វស្សបូគានិ អស្សមេ សម្មតោ មម
នាភិជានាមិ ឧប្បន្នំ អាពាធំ អមនោរមំ ៗ

ស្វាគតន្តេ មហាព្រហ្មេ អថោ តេ អទុរាគតំ①
អន្តោ បវិស② ភទ្ទន្តេ បាទេ បក្ខាលយស្សុ តេ ។
តិណ្ឌុកានិ បិយាលានិ មធុកេ កាសមារិយោ
ផលានិ ខុទ្ទកប្បានិ ភុញ្ជ ព្រហ្មេ វរំ វរំ ។
ឥទំបិ បានិយំ សីតំ អាភតំ គិរិគព្ភរា
តតោ បិវ មហាព្រហ្មេ សចេ ត្វំ អភិកង្ខសីតិ ។

ព្រហ្មេ ហៃព្រាហ្មណ៍អើយ រីអញមកសាងផ្នួសបួសជាមហាឫសី នៅជាអម្លុងម្លេះហើយ នាបីហៅមានជំងឺអាពាធព្យាធិអ្វីនឹងមកបៀតបៀនអញឱ្យជាទុក្ខ មិនស្រណុក នឹងសូត្រមន្តចម្រើនមេត្តាភាវនា ពុំបានដូចជាចៅដណ្តឹងសួរអញនេះ ឥតអង្តីមានឡើយ ។ មួយសោត ចៅព្រាហ្មណ៍អើយ រីនឹងស្វែងរកផ្លែឈើមើមឈើ មកចិញ្ចឹមជីវិតអាត្មាដោយនូវអ្នកបួស នៅនាព្នដ៏ព្រៃនេះ មានច្រើនហោង ។ មួយសោត ហៃចៅព្រាហ្មណ៍អើយ រីសុច ស្រួយ មមង់ មមាច កន្ទេចអាល នូវពស់ ក្អែប ខ្ទយ ខ្យាដំរីផង ដ៏មានច្រើនក្តាត់ ដ៏ពាសពេញនីទៅនូវម្រឹគពាឡសាហាវផងទាំងឡាយ ជាដើមគឺ រាជសីហ៍ ដំរីព្រៃ គោ ក្របី ខ្ទឹង សិង្ហផង នឹងអាចមកបៀតបៀនអាត្មា ដូចចៅដណ្តឹងនោះឥតអង្តីមានឡើយ ។

១- មហាវេស្សន្តរទីបនិយំ អធុនាគតន្តិបិ ទិស្សតិ ។ ២- តត្តេវ បស្សាតិបិ ទិស្សតិ ។

ព្រហ្មេ ហៃតាព្រាហ្មណ៍អើយ នាងអញមកសាងផ្នួសបួសអាស្រ័យនៅទីនេះ ជាអម្លុងម្ល៉េះហើយ តែងសូត្រមន្តចម្រើនមេត្តាភាវនា ជាច្រើនក្តាត់ហោង រីនឹងមានជំងឺអាពាធព្យាធិ ឱ្យជាទុក្ខពុំស្រណុក ដល់មួយពេលនោះ ឥតអន្លឹមានឡើយ ៗ ព្រាហ្មណ៍អើយ ចៅមកអំពីឋានឆ្ងាយ សមក្តៅក្រហាយ ចូរចៅអញ្ជើញទៅងូតផឹក ជម្រះអង្គសម្រង់ក្បាលត្រអាលចិត្ត ហើយអង្គុយសម្រាន្តហោង ៗ ហៃចៅព្រាហ្មណ៍អើយ បើព្រះស្តែងឃ្លានអាហារ ក៏អញ្ជើញព្រះស្តែងជ្រើសរើសរកផ្លែឈើឯណាទុំខ្ចីក្តី ក៏មាន ទន្លាប់ ព្នៅ បង្គោ សិរមាន់ សង្ឃ័រ ខ្វិត គុយ ស្រគំ ទុំល្អ ៗ សឹងប្រពៃឧត្តម ប្រទ្បាក់នូវទឹកឃ្មុំផ្លិត អញ្ជើញព្រះស្តែងបរិភោគចុះ ៗ ព្រាហ្មណ៍អើយ ទោះស្រេកទឹកសោត ចូរព្រះស្តែងដងទឹកនៅអាងតូចនោះ ថ្លាត្រជាក់ក្រអូប គឺអញដងមកអំពីអូរជ្រោះភ្នំវង្កត កំណត់ត្រង់ស្រះបោក្ខរណី ព្រះស្តែងកុំបីសន្ទិះចិត្តឡើយ ទោះបីបើមានប្រាថ្នាអ្វីក្តី,នោះ ចូរព្រះស្តែងថ្លែងប្រាប់អញហោង ៗ

ជូជកោ អាហ ទើបតាជូជកសូត្រនូវបាទព្រះគាថាដូច្នេះ

បដិគ្គហិតំ យំ ទិន្នំ   សព្វស្ស អគ្ឃិយំ កតំ
សញ្ជយស្ស សកំ បុត្តំ   សិវីហិ វិប្បវាសិតំ
តមហំ ទស្សនមាគតោ   យទិ ជានាសិ សំស មេតិ ៗ

ភោ តាបស បពិត្រព្រះតាបសឫសីដ៏ចម្រើនអើយ រីផ្លែឈើមើមឈើផងទាំងឡាយ គឺអ្នកប្រដាប់ជាអាហារ ក្រយាទទួលភ្ញៀវនោះ ក៏អញខ្ញុំទទួលយក គ្រាន់តែនឹងបរិភោគប៉ុណ្ណោះ បពិត្រអម្ចាស់អើយ ខ្ញុំនេះមិនប្រាថ្នាការឯទៀតឡើយ គឺព្រះបាទស្រីសញ្ជ័យដ៏ជាព្រះវររាជបិតាទ្រង់ត្រាស់ប្រើអញខ្ញុំ ឱ្យមកទូលសួរព្រះរាជបុត្រសំឡាញ់ ត្បិតទ្រង់ប្រាសមកជាយូរលង់ហើយ តើអ្នកដឹងលំនៅព្រះបាទស្រីវេស្សន្តរព្រះអង្គគង់នៅត្រង់ឋានឯណាមិញ ក៏ចូរអ្នកសម្តែងថ្លែងប្រាប់អញខ្ញុំ ដោយនូវពាក្យពិត ក៏អញខ្ញុំនឹងទៅអញ្ជើញព្រះអង្គមកឆាប់ហោង ។

តាបសោ អាហ តាបសឫសីនោះ ស្តាប់ពាក្យព្រាហ្មណ៍ស្រដីពីរោះ យល់ហាក់ដូចខ្លោះមានបើប្រាថ្នា ទើបសាស្ងូត្រ ជាបាទគាថាដូច្នេះ

ន ភវំ ឯតិ បុញ្ញត្ថំ   សិវិរាជស្ស ឱរសំ
មញ្ញេ ភវំ បត្ថយតិ   រញ្ញោ ភរិយំ បតិព្វតំ ។
មញ្ញេ កណ្ហាជិនំ ទាសី   ជាលី ទាសញ្ច ឥច្ឆសិ
អថវា តយោ មាតាបុត្តេ   អរញ្ញា នេតុមាគតោ
ន តស្ស ភោគា វិជ្ជន្តិ   ធនំ ធញ្ញញ្ច ព្រាហ្មណាតិ ។

ភោ ព្រាហ្មណ ហៃចៅព្រាហ្មណ៍អើយ ម្រាងច្នោះឡើយ រីព្រះស្តែងព្រាហ្មណ៍ឯងនេះ មកប្រាថ្នាចង់យល់ព្រះ

បាទស្រីវេស្សន្តរ ជាព្រះរាជបុត្រព្រះបាទស្រីសញ្ជ័យនោះ ថា បើអញគិតនេះ សមយល់ជានឹងប្រាថ្នាមកសុំសម្តេចព្រះរាជមទ្រី ជាស្រីប្រកបនូវលក្ខណាប្រសើរនោះ ក៏ពុំដឹង នឹងប្រាថ្នាមកសុំនាងក្រស្នាទៅធ្វើជាខ្ញុំស្រី ឬមួយមកសូមចៅជាលីទៅធ្វើជាខ្ញុំប្រុស ក៏ពុំដឹងឡើយ ៗ រីព្រះបាទស្រីវេស្សន្តរនោះ ព្រះអង្គគង់នៅនាព្រៃនេះ រីស្រូវអង្ករសំពត់សាវអាវស្បៀសឹងគ្មានឡើយ ប្រាក់មាសខ្ញុំប្រុសស្រីមួយក៏គ្មាន ដំរី សេះ រទេះ គោ ក្របី នោះសោត ក៏គ្មាន មានតែប្រពន្ធនិងកូន សឹងបួសជាមហាឫសីហើយ តើព្រះស្តែងនឹងមានបើប្រាថ្នាអ្វីទៀត ៗ

តំ សុត្វា ជូជកោ អាហ ក្សិណានោះកូវ ជូជកព្រាហ្មណ៍ ស្តាប់ពាក្យមហាឫសីស្រដីពុំពីរោះដូច្នោះ ហើយឆ្លើយវិញ សូត្រជាបាទគាថាដូច្នេះ

អកុទ្ធរូបោហំ ភោតោ នាហំ យាចិតុមាគតោ
សាធុ ទស្សនមរិយានំ សន្និវាសោ សទា សុខោ ។
អទិដ្ឋបុព្វោ សិវិរាជា សិវីហិ វិប្បវាសិតោ
តមហំ ទស្សនមាគតោ យទិ ជានាសិ សំស មេតិ(១) ៗ

ភោ តាបស បពិត្រអ្នកតាមហាឫសីអើយ អ្នកពុំទាន់ស្តាប់អស់សេចក្តីរបស់អញខ្ញុំកូវ អ្នកដៀលទ្រគោះគំរោះ

១- មានដំណើរសេចក្តីតាមទំនងបាលីគាថាដូច្នេះ " បពិត្រព្រះតាបសដ៏ចម្រើនអើយ អ្នកតាកុំអាលខឹងនឹងខ្ញុំឡើយ ខ្ញុំមិនមែនមកសូមទានទេ តែការបានជួបប្រទះនឹងព្រះ

ឆ្លង . . .

មកឱ្យអញខ្ញុំដូច្នោះនេះ ហៅពុំគួរសមទេ នែអ្នកតាអើយ អញនឹងសម្តែងថ្លែងប្រាប់អ្នកតា នាអញនេះ ជាព្រាហ្មណី មានសីលសត្យា អញខ្ញុំចង់យល់ព្រះបាទស្រីវេស្សន្តរ ជាអ្នកមានសីលពីព្យាយាមជាអ្នកបួសនោះ ក៏អញខ្ញុំនេះ តាំងពីកាលអ្នកស្រីពិរាស្ត្រ គេបំបរបង់ព្រះអង្គនោះ មិនដែលបានដំណឹង មិនដែលបានយល់ព្រះអង្គឡើយ ហេតុនេះ បានជាអញខ្ញុំមកដោយនូវព្រះបាទស្រីសញ្ជ័យព្រះអង្គប្រើមក ភន្តេ តាបស បពិត្រព្រះតាបសឫសីប្រសើរអើយ ទោះយោបីអ្នកដឹងលំនៅព្រះបាទស្រីវេស្សន្តរ ដ៏ជាក្សត្រប្រសើរនោះ ចូរអ្នកណែប្រាប់អញខ្ញុំដោយនូវពិត រីបុណ្យគុណចម្រើន ដល់អ្នកនោះ នឹងប្រាកដក្តាត់ហោង ។

សោ តស្ស វចនំ សុត្វា សទ្ទហិត្វា ហោតុ ស្វេ ទស្សិស្សាមិ តេ អជ្ជ តាវ ឥធេវ វសាហីតិ តំ ផលាផលេហិ សន្តប្បេត្វា បុនទិវសេ មគ្គំ ទស្សេន្តោ ទក្ខិណហត្ថំ បសារេត្វា អាហ ហៃសាធុសប្បុរសផង ទាំងឡាយអើយ រីព្រះអច្ចុតមហាឫសីនោះ ស្តាប់ពាក្យ

អរិយជនទាំងឡាយជាការល្អ ការនៅរួមជាមួយព្រះអរិយជន ក៏នាំឱ្យបានសេចក្តីសុខសព្វកាល ។ (តាំងអំពីកាល) ព្រះបាទសិវិរាជវេស្សន្តរ ទ្រង់ព្រាត់ប្រាសចាកអ្នកស្រីពិរាស្ត្រ ខ្ញុំពុំដែលជួបសោះឡើយ ទើបខ្ញុំមកសូមគាល់ព្រះអង្គ បើអ្នកតាជ្រាប (លំនៅរបស់ព្រះអង្គ) ចូរអ្នកតាប្រាប់ខ្ញុំផង ។

ព្រាហ្មណ៍ស្រដីដូច្នោះហើយ ក៏ជឿថាមែនពិតស្មោះ ៗ ក្សិណនោះ មហាឫសីយកអស់ផ្លែឈើទុំខ្ចីនោះ ឱ្យទៅព្រាហ្មណ៍បរិភោគស្រេចហើយ ទើបឱ្យតាជីសម្រាន្តអស់រាត្រីមួយ លុះព្រឹកឡើងកូវ នាំព្រាហ្មណ៍នោះទៅបង្ហាញផ្លូវហើយ លើកដៃស្ដាំចង្អុលប្រាប់ថា ព្រហ្មេ ហៃព្រាហ្មណ៍អើយ គន្ត្វា ចូរព្រះស្ដែងដើរទៅ ឯតំ មគ្គំ ពួដ៏ផ្លូវនេះឯងហោង ៗ

ឯស សេលោ មហាព្រហ្មេ   បព្វតោ គន្ធមាទនោ
យត្ថ វេស្សន្តរោ រាជា   សហ បុត្តេហិ សម្មតិ ៗ
ធារេន្តោ ព្រាហ្មណវណ្ណំ   អាសទញ្ច មសញ្ជំ①
ចម្មវាសី ឆមា② សេតិ   ជាតវេទំ នមស្សតិ ៗ
ឯតេ នីលា បទិស្សន្តិ   នានាផលធរា ទុមា
ឧគ្គតា អព្ភកូដាវ   នីលា អញ្ជនបព្វតា ៗ
ធវស្សកណ្ណា ខទិរា   សាលា ផន្ទនមាលុវា
សម្បវេធេន្តិ វាតេន   សកឹ បីតាវ មាណវា ៗ
ឧបរិ ទុមបរិយាយេសុ   សង្គីតិយោវ សុយ្យរេ
នជ្ជុហា កោកិលា សង្ឃា   សម្បតន្តិ ទុមា ទុមំ ៗ
អវ្ហយន្តេវ គច្ឆន្តំ   សាខា បត្តសមីរិតា
រមយន្តេវ អាគន្តុំ   មោទយន្តិ និវាសនំ ៗ

១- ចូឡវនដីកាយំ អាសទញ្ញាតិ អង្កុសំ ៗ មសន្តិ យាគុភាជនន្តិ ទិស្សតិ ៗ
២- មហាវេស្សន្តរទីបនិយំ ឆបន្តិបិ ទិស្សតិ ៗ

យត្ថ វេស្សន្តរោ រាជា   សហ បុត្តេហិ សម្មតិ
ធារេន្តោ ព្រាហ្មណវណ្ណំ   អាសទញ្ច មសញ្ជដំ
ចម្មវាសី ឆមា សេតិ   ជាតវេទំ នមស្សតិ ។
កិរេរីមាលា វិតតា   ភូមិភាគេ មនោរមេ(១)
សទ្ទលា ហរិតា ភូមិ   ន តត្ថុទ្ធំសតេ រជោ ។
មយុរគីវសង្កាសា   តូលផស្សសមូបមា
តិណានិ នាតិវត្តន្តិ   សមន្តា ចតុរង្គុលា ។
អម្ពា ជម្ពូ កបិដ្ឋា ច   នីចេ បក្កា ចុទុម្ពរា
បរិភោគេហិ រុក្ខេហិ   វនន្តំ រតិវឌ្ឍនំ ។
វេឡុរិយវណ្ណបនិភំ(២)   មច្ឆគុម្ពនិសេវិតំ
សុចិ សុគន្ធំ សលិលំ   អាបោ តត្ថបិ សន្ទតិ ។
តស្សាវិទូរេ បោក្ខរណី   ភូមិភាគេ មនោរមេ
បទុមុប្បលសញ្ឆន្នា   ទេវានមិវ នន្ទនេ ។
តីណិ ឧប្បលជាតានិ   តស្មី សរសិ ព្រាហ្មណ
វិចិត្រនីលានេកានិ   សេតាលោហិតកានិ ចាតិ ។

មហាព្រហ្មេ ហៃមហាព្រាហ្មណ៍ដ៏ចម្រើនអើយ រីភ្នំឯនាយនោះ សឹងដ៏រាបទាបរៀបរយ ពាសពេញនីទៅនូវថ្មស លោកសន្មតហៅថា ភ្នំគន្ធមាទនបព៌ត ។ មហា-

---

(១)- មហាវេស្សន្តរទីបនិយំ ករេរិមាលា វិតតា ភូមិភាគេ មនោរមេតិបិ ទិស្សតិ ។

(២)-មហាវេស្សន្តរលិនាត្ថប្បកាសិនិយំ វេឡុរិយវណ្ណសន្និភន្តិបិ ទិស្សតិ ។

ព្រាហ្មណ៍អើយ រីព្រះបាទស្រីវេស្សន្តរបវរពោធិសត្វ ព្រះអង្គទ្រង់ព្រះផ្នួសបួសជាមហាឫសី មួយអន្លើនូវព្រះរាជបុត្រាបុត្រី ព្រះរាជទេពី ព្រះអង្គទ្រង់នូវជ្រនីកទម្លក់ ថ្កក់ផ្លែឈើ ហើយអ្នកចងព្រះកេសាជាជដាមណ្ឌល ទ្រង់នូវស្បែកខ្លា ក្រវាត់ស្បូវក្លាំង មានទាំងធម្មក្រក ពំនួតភ្លើង ទ្រង់នមស្ការ បូជាព្រះភ្លើង តម្កើងរស្មីតាងចីវរព្រះបច្ចេកពោធិហោង ។

ព្រហ្មេ ហៃព្រាហ្មណ៍អើយ ខុទ្ទាខុទ្ទំ រីផ្លែឈើតូចធំផងទាំងឡាយ បតិស្សន្តិ ដ៏យល់ប្រាកដ នីលខណ្ណំ ដ៏មានពណ៌នោះខ្មៅល្អដូចខ្លង់មេឃ គឺព្រហូត ស្ដី ស្ដៅ តាត្រៅ ឈើទាល ពពាលខែ ដ៏មានផ្លែផ្កានោះផ្សេងៗ រីឈើនោះសោត សឹងដ៏មានត្របែក ត្រចៀកប្រើស គគីរ រាំងក្រសាំង ពង្រ ដកព អញ្ចាញ ពពូល ស្រូល ស្រល់ ផងទាំងឡាយ ។ ព្រាហ្មណ៍អើយ រីអស់ឈើទាំងនោះសោត កាលណាបើខ្យល់បក់មកនោះ ដ៏មានចុងឱនលំទោនទៅមក បីដូចអ្នកប្រមឹកស្រា វាឱនព្រមគ្នាដូច្នោះ ។ មួយសោត ព្រាហ្មណ៍អើយ រីសត្វបក្សីផងទាំងឡាយ ដ៏ទំយំនៅលើចុងឈើនោះ បើអ្នកផងទាំងឡាយដើរទៅដើរមក សឹងក៏ឮសព្ទពីរោះ បីដូចចម្រៀងស្មូគ៏នាយ ។ ព្រាហ្មណ៍អើយ រីព្រះបាទស្រីវេស្សន្តរ ព្រះអង្គគង់មួយអន្លើនឹងព្រះរាជបុត្រព្រះរាជទេពី តែងទ្រង់ចម្រើនមេត្រីដល់សត្វផងទាំងឡាយ ព្រះអង្គ

ចងជដាមណ្ឌលតម្កល់ព្រះភ្លើង តម្កើងតាងចីវរព្រះបច្ចេកពោធិ សង្ខាតភាវនា ពុំដែលដាច់ដល់មួយរាត្រីឡើយ ទ្រង់ប្រះសិងលើកម្រាលស្លឹកឈើ លើដីរឹងនោះហោង ។

ព្រហ្មេ ហៃព្រាហ្មណ៍អើយ វីភូមិលំនៅព្រះបាទស្រីវេស្សន្តរនោះ បីដូចអ្នកក្រងរំយោលព្យួរនូវភ្ញី បីដូចអ្នកបេះប្រឡេះ ចងព្យួរ នៅសងខាងព្រះអាស្រមបទ ៗ មួយសោត វីភូមិនោះ រាបបីដូចផ្ទៃស្គរ សឹងដុះតែស្មៅជើងក្រាស់ ព្រាហ្មណ៍អើយ វីស្មៅនោះសោត រាបខៀវល្អ បីដូចផ្នត់កក្លោកមាស វីខ្សាច់នោះសោត ក៏ល្អដូចសំឡី គរថ្ពច បញ្ជី ៧ ដង រាបស្មើពុំកន្លងនឹងគ្នាឡើយ ៗ មួយសោត ព្រាហ្មណ៍អើយ វីឈើនៅសងខាងផ្លូវនោះ ដ៏មានផ្លែនោះទុំសំយុងចុះ នៅព្នដ៏ឋានទាបហោង ៗ ព្រាហ្មណ៍អើយ វីផ្លែឈើទាំងឡាយនោះ សឹងជាគ្រឿងបរិភោគ ជាល្បែងបន្លែង នៃក្មេងទាំងពីរ គឺចៅជាលីនូវនាងក្រស្នា ៗ ហៃព្រាហ្មណ៍អើយ មួយសោត វីត្រីនិងអណ្តើកផងទាំងឡាយ សឹងដើរដោយអណ្តាប់គ្នា នៅព្នដ៏ស្រះបោក្ខរណីនោះ ៗ វីទឹកហូរចូលទៅក្នុងកំឡុងស្រះនោះសោត សឹងក្រអូបពិដោរនូវរសភ្ញី ឯស្រះបោក្ខរណីនោះ ក៏ពុំឆ្ងាយ អំពីទីអាស្រមបទព្រះបាទស្រីវេស្សន្តរនោះឡើយ ៗ ម្នាលព្រាហ្មណ៍អើយ វីស្រះបោក្ខរណីនោះសោត ដ៏ដេរដាសពាសពេញនីទៅនូវឈូកស ឈូក-

ច្រាល កុមុទ ឧត្បល លំចង់ ស្បង្ក័ជ ព្រលិត ស្គន់ កំពីងពួយផងច្រើន ៗ ហែព្រាហ្មណ៍ព្រឹទ្ធាចារ្យអើយ រីកំណើតផ្កាឧប្បលផងទាំងឡាយ ដ៏មានពណ៌នោះ ៣ ជំពូក សឹងដ៏ល្អផ្សេង ៗ ពីគ្នា ខ្លះក្រហម ខ្លះស ខ្លះខៀវ ដូចផ្កាសណ្ដែករាជមាស រីផ្កាឧប្បលទាំង ៣ ជំពូកនោះ កើតមាននាស្រះបោក្ខរណីនោះឯង ដ៏រុងរឿងល្អ បីដូចស្រះនន្ទនឧទ្យាន ឋានទេវតា នៅនាឋានចាតុម្មហារាជិកាសួគ៌នាយហោង ៗ

ឯទំ ចតុរស្សបោក្ខរណី វណ្ណេត្វា បុន មុចលិន្ទសរំ វណ្ណេន្តោ អាហ រីតាបសមហាឫសីនោះ សរសើរស្រះបោក្ខរណីនូវប្រការអម្បាលនោះហើយ ក៏មកសរសើរឯមុចលិន្ទស្រះវិញ សូត្រជាបាទព្រះគាថាដូច្នេះ

ខោវមាទ តត្ថ បទុមា សេតសោគន្ធិយេហិ ច
កលម្ពកេហិ សញ្ឆន្នោ មុចលិន្ទោ នាម សោ សរោ ៗ
អថេត្ថ បទុមា ផុល្លា អបរិយន្តាវ ទិស្សរេ
គិម្ហា ហេមន្តិកា ផុល្លា ជណ្ណុតគ្ឃា ឧបត្ថរា ៗ
សុរភី សម្បវាយន្តិ វិចិត្រា បុប្ផសណ្ឋិតា
ភមរា បុប្ផគន្ធេន សមន្តាមភិនាទិតា(១)ៗ

---

(១)- ប្រែតាមរូបបាលីដូច្នេះ " ក្នុងស្រះឈ្មោះមុចលិន្ទនោះ សឹងដេរដាសដោយផ្កាបទុមជាតិ មានសំបុរសស្អាតដូចសំពត់ខោមពស្ត្រ ហើយពាសពេញទៅដោយ ផ្កាឧប្បលចង្កុលណី មានពណ៌ផ្សេងៗគ្នា ៗ មួយសោត ផ្កាឈូកក្នុងស្រះនោះ តែងរីក

ហៃព្រាហ្មណ៍អើយ រីស្រះមុចលិន្ទនោះ ដ៏ដេរដាសពាសពេញនីទៅនូវឈូកស ឈូកក្រហម ឈូកខៀវ ដ៏មានផ្ការីករោយជម្រុះកេសរផ្កា នៅឰដ៏កំឡុងទឹកស្រះមុចលិន្ទនោះឯង ៗ មួយសោត ព្រាហ្មណ៍អើយ រីមុចលិន្ទស្រះនោះកូវទោះរដូវក្តៅក្តី ទោះរដូវរងាក្តី ក៏ផ្កាឧត្បលនោះ រីករោយប្រាកដ សឹងមាននៅនាទឹកជ្រៅទឹករាក់ ដ៏ពិដោរនីទៅនូវក្លិនភ្វីផង រីកន្លង់ឯងសោត សឹងដ៏ហើរមកក្រេបកេសរភ្វី ឰដ៏ស្រះមុចលិន្ទនោះ បីដូចត្រែសង្ខតូរ្យតន្ត្រីភ្លេងល្បែងបន្លែងនៅនាសួគ៌នាយនោះឯងហោង ៗ

អថេត្ថ ឧទកន្តស្មឹ រុក្ខា តិដ្ឋន្តិ ព្រាហ្មណ
កទម្ពា បាដលី ផុល្លា កោវិឡារា ច បុប្ផិតា ៗ
អង្កោលា កច្ចិការា ច បារិជញ្ញា ច បុប្ផិតា
វារណា វុយ្ហនា រុក្ខា មុចលិន្ទមុភតោ សរំ ៗ
សិរីសា សេតបារិសា សាធុ វាយន្តិ បទ្មកា
និគ្គណ្ឌី សរនិគ្គណ្ឌី អសនា ចេត្ថ បុប្ផិតា ៗ
បង្កុរា ពហុលា សេលា សោភញ្ជនា ច បុប្ផិតា

ស្រស់ស្រាយមិនមានកំណត់ ខ្លះក៏រីកក្នុងគិម្ហរដូវ ខ្លះរីកក្នុងហេមន្តរដូវ ដុះតាំងនៅក្នុងទឹកនោះត្រឹមក្បាលជង្គង់ ៗ ផ្ទៃទឹកនោះ ដ៏វិចិត្រល្អ ហាក់ដូចក្រាលផ្កាឈើផ្សាយក្លិនក្រអូបឈ្ងុយឈ្ងប់ ពួកមេឃ្មុំ មកន្លង់តែងហើរឆ្វៀលឆ្វាត់ ដោយជុំវិញស្រះស្រីដើម្បីត្រឹបយករសជាតិផ្កាដ៏ក្រអូប " ៗ

កេតកា កណិការា ច កណវេរា ច បុប្ផិតា ។
អជ្ជុនា អជ្ជុកណ្ណា ច មហានាមា ច បុប្ផិតា
សម្បុប្ផិតគ្គា តិដ្ឋន្តិ បជ្ជលន្តេវ កឹសុកា ។
សេតបណ្ណិ សត្តបណ្ណា(១) កន្ទលិយោ កុសុម្ភរា
ធនុតក្ការិបុប្ផេហិ សីសបាវរណានិ(២) ច ។
អជ្ជិកា សិម្ពលីរុក្ខា សល្លកិយោ ច បុប្ផិតា
សេតគេរូតគរិកា មំសិកោដ្ឋកុលាវរា ។
ទហរា រុក្ខា ទុឡ្ហា ច អកុដិលា ចេត្ត បុប្ផិតា
អស្សមំ ឧភតោ ឋន្តិ អគ្យាគារំ សមន្តតោតិ ។

ព្រាហ្មណ ហៃព្រាហ្មណ៍អើយ រីឈើផងទាំងឡាយ សឹងដ៏ដុះរៀងរាយនៅសងខាងស្រះមុចលិន្ទនោះសោត សឹងដ៏មានដើមក្ទម្ព ច្រឡំនីទៅនូវជ្រនៀង ដុះរាលរៀងដោយអណ្ដាប់ មានទាំងព្រីង ព្រូស ជន្លួស ស្វាត ស្វាយ ដ៏មានផ្ការីកស្គុសស្គាយត្រសាយឈាស់ខ្ចី មានទាំងអង្គាដី ស្រឡី ផ្ដីក រាំង ក្រសាំង ក្រូចថ្លុង ក្រូចឆ្មារ ដ៏មានពណ៌នោះល្អ ៗ នៅសងខាងស្រះមុចលិន្ទនោះហោង ។

ហៃព្រាហ្មណ៍អើយ មួយសោត រីជីរស ជីរខ្មៅ ឈូកត្រាញ់ នាកាលខ្យល់បក់មក ធុំក្លិននីទៅនូវគន្ធពិដោរ ពួដ៏

១- មហាវេស្សន្តរទីបនិយំ សត្តបណ្ណី ឆត្តបណ្ណាតិបិ ទិស្សតិ ។ ២- មហាវេស្សន្តរលិនាត្ថប្បកាសិនិយំ សីសបាវារណាហិ ចាតិបិ ទិស្សតិ ។

អាស្រមបទព្រះបាទស្រីវេស្សន្តរនោះហោង ៗ នាសងខាងព្រះអាស្រមបទនោះ ដ៏ដុះដាសពាសពេញនីទៅនូវគណ្ឋីស គណ្ឋីខ្មៅ សឹងមានផ្ការីកស្គុសស្គាយពណ្ណរាយជាប្រក្រតី ៗ ព្រាហ្មណ៍អើយ រីឈើផងទាំងឡាយ ដ៏មានសុក្រំ ច្រឡំនូវពពូលថ្ម ដកព ម្រុម ភេកា ការកេស ចេកទេស កណិការ ចម្ប៉ា ចំប៉ី ច្បាទេស ៗ

ហៃព្រាហ្មណ៍អើយ រីឈើផងទាំងឡាយ ដ៏មានត្រយឹង កំភ្លឹង ក្តាំងងា ចារ ដ៏មានផ្ការីកដូចនឹងឆេះឡើង ឋិតនៅដោយសងខាងព្រះអាស្រមបទនោះហោង ៗ ព្រាហ្មណ៍អើយ រីឈើផងទាំងឡាយ ដ៏មានសត្បារស សត្បារខ្មៅ មានទាំងចេកមាសដុះដាសនៅដី មានទាំងអង្គាដីស ក្រហម មានទាំងក្រិន្នា ពព្លា ផ្កាដកគាំ ដ៏រីកសន្ធៅឆ្អៅល្អ ដ៏មានទាំងក្រញូង ទន្លា ខ្លុង ត្បែង ពុំសែន សំរោង សំរង អំពៅព្រៃផង ទាំងក្រស្នាផង ក៏មានច្រើន ៗ រីឈើអស់នោះសោត ទោះបីទើបនឹងលំពង់ឡើងក្តី ទោះចាស់ក្តី សឹងតែស្លូតល្អ ដ៏មានចុងនោះត្រង់ល្អ ពុំមានវៀចឡើយ ៗ

អថេត្ថ ឧទកន្តស្មឹ ពហូ ជាតា ផណិជ្ជកា
មុគ្គតិយោ ករតិយោ សេទាលំ សីសកំ ពហុ ៗ
ឧទ្ធាបទត្ថំ ឧល្លុលិតំ មក្ខិកា ហិង្គុជាលិកា

១- មហាវេស្សន្តរដ្ឋកថាយំ មុទិង្គមត្តានិ វា ឧភោតិបិ ទិស្សតិ ៗ

ធាសិមកញ្ញកោ ចេត្ថ ពហូ នីចេ កលម្ពកា ។
ឯលម្ពរុក្ខសញ្ឆន្នា រុក្ខា តិដ្ឋន្តិ ព្រាហ្មណ ។
សត្តាហំ ធារិយមានានំ គន្ធោ តេសំ ន ឆិជ្ជតិ
ឧភតោ សរញ្ញ មុចលិន្ទំ វប្បា តិដ្ឋន្តិ ភាគសោ ។
ឥន្ទិវរេហិ សញ្ឆន្នំ វនន្តំ ឧបសោភិតំ
អឌ្ឍមាសំ ធារិយមានានំ គន្ធោ តេសំ ន ឆិជ្ជតិ
នីលបុប្ផិសេតវារី បុប្ផិតា គិរិកណ្ណិកា
ភលេរុក្ខេហិ សញ្ឆន្នំ វនន្តំ តុលសីហិ ច ។
សម្ពោធិតេវ គន្ធេន បុប្ផសាខាហិ តំ វនំ
ភមរា បុប្ផគន្ធេន សមន្តាមភិនាទិតា ។
តីណិ កក្ការុជាតានិ តស្មឹ សរសិ ព្រាហ្មណ
កុម្ភមត្តានិ ចេកានិ មុរមត្តានិ វា ភោតិ ។

ព្រាហ្មណ៍អើយ វីស្រះនោះសោត ដ៏មានកំពីងពួយវារវ័ណ្ណព័ន្ធលើស្មៅ ពួដ៏ទឹករាក់ជ្រៅ វីឆ្នេរស្រះនោះសោតមានទាំងសណ្ដែកបាយ ប្រពាយទេសផងច្រើន ។ ព្រាហ្មណ៍អើយ វីមុចលិន្ទស្រះនោះ មានកំពង់នោះរាប ច្រាំងនោះទាបស្រណុក បើខ្យល់បក់ទៅមក ដ៏មានរលក ខ្វាយខ្វារឡើង ៗ វីមេឃុំ ដ៏ហើរមកប្រញាយ ត្រីបយកកេសរភ្ញីផង ៗ មួយសោត ព្រាហ្មណ៍អើយ វីស្លាស្ទាប់ ស្លាធំ ម្លូភ្ទុំផងច្រើន សឹងដ៏មានទាំងសសិតទេស សសៀតទៃ

មានព្ធដ៏ឋាននោះឯង ។

ព្រាហ្មណ៍អើយ រីឈើអែមផង សឹងដ៏មានផ្លែផ្កានៅព្ធដ៏មុចលិន្ទស្រះនោះ ទោះអ្នកឯណាទៅដល់យល់ហើយ ក៏បេះប្រឡេះមកទ្រង់ លុះអស់ ៧ ថ្ងៃក្ដី ក៏ក្លិនពិដោរអប់ ត្រឡប់នោះ មិនចេះហៅស្បើយល្ហើយឡើយ ។ ព្រាហ្មណ៍អើយ រីអញ្ច័នស អញ្ច័នខ្មៅ អញ្ច័នលឿង ដ៏មានផ្ការីករុងរឿងនីទៅនូវម្លិះរួត ម្លិះលា យុថ្កា ពុកឆ្មា ម្រះព្រៅ លីងល័ខ ស្លឹកគ្រៃផងច្រើន ។ ម្នាលព្រាហ្មណ៍អើយ រីព្រៃនោះសប្បាយគាប់ចិត្តពេក រីកន្លង់ផងហើរទៅមក ត្រើបជញ្ជាក់យកកេសរភ្ជី នោះ ឮសូរសព្ទពីរោះ ដូចអ្នកប្រគំគងភេរីតូរ្យតន្ត្រី នៅនាសួគ៌នាយហោង ។

ព្រាហ្មណ៍អើយ រីមុចលិន្ទស្រះនោះសោត ដ៏មានកំណើតត្រឡាចផងមាន ៣ ជំពូក គឺត្រឡាចមួយ មានផ្លែធំប៉ុនស្គរជ្វា ឯត្រឡាចពីរ (ជំពូក) នោះសោត សឹងមានផ្លែប៉ុនសម្ភោរ សឹងដុះរៀបរៀង នាសងខាងឆ្នេរស្រះនោះឯង ។

អថេត្ថ សាសបោ ពហុកោ នាទិយោ ហរិតាយុតោ
អសី តាលាវ តិដ្ឋន្តិ ឆេជ្ជា ឥន្ទីវរា ពហូ ។
អម្ពោជា សុរិយវល្លី ច កាលិយា មធុគន្ធិយា
អសោកា មុចយន្តី ច វល្លិកោ ខុទ្ទបុប្ផិយោ ។
កោរណ្ឌកា អនោជា ច បុប្ផិតា នាគមល្លិកា

រុក្ខមារុយ្ហ តិដ្ឋន្តិ   ផុល្លា កឹសុកវល្លិយោ ។
កតេរុហា បវាសេន្តិ   យោជិកា មធុគន្ធិយា
និលិយា សុមនា ភណ្ឌី   សោភតិ បទុមុត្តរោ ។
បាដលិ សមុទ្ទកប្បាសី   កណិការា ច បុប្ផិតា
ហេមជាលាវ ទិស្សន្តិ   រុចិរា អគ្គិសិខូបមា ។
យានិ តានិ ច បុប្ផានិ   ថលជានូទកានិ ច
សព្វានិ តត្ថ ទិស្សន្តិ   ឯវំ រម្មោ មហោទធីតិ ។

ព្រាហ្មណ៍អើយ នៅជិតស្រះនោះ មានទាំងស្លែ ជីរលើងល័ខ រំដេង ខ្ញាយ ខ្ទីទឹក ខ្ទីភ្លើង ខ្ទឹមស ខ្ទឹមក្រហម មើមផ្លុងផងច្រើន មានទាំងដើមត្រៀក កម្រៀក ត្រចេក ថ្កឹក ទ្រយឹង តាត្រៅ មានទាំងឈើអែម ឱឡោក ទៀនព្រៃ ស្រឡី ស្រឡៅ ផ្តៅឆ្វាំង ទាំងចង្កូមស្កា ខ្ចាផង មានទាំងផ្កាទេស ឈើកេស ប្រមោយដំរី ស្បែង ទ្រមែង ស្នែ ស្នាច់ ជម្ពូព្រឹក្ស អធិកនូវជ្រៃ រ៉ែ រោក កន្ទ្រោក កកោះ រលួស រលាយ ពោធិ៍បាយ ត្រសាយសាខា មានទាំងត្រុំព្រៃ ចិត្តបុស្ស ព្រោះស្វា ព្រោះជារ ឈូកត្រាញ់ ភង្គី អគ្គេយ៍ឃ្វាល សហស្សគុណ ទន់ដី ច្រនៀង រវៀង ដកព ពពូលថ្ម រំដេញ ប្រផេញ ត្រៀល សឹងមានគ្រប់ពណ៌ ។ ហៃព្រាហ្មណ៍អើយ វីកំណើតផ្កាផងទាំងឡាយ នាលើគោកក្តី ក្នុងទឹកក្តី វីអស់ផ្កាផងនោះ សឹងដ៏យល់ប្រាកដពេក ឯទឹកមុចលិន្ទស្រះនោះសោត

សឹងដ៏ពិដោរថ្លាត្រជាក់ កំពង់រាប ច្រាំងនោះទាប ស្រណុក សប្បាយ ដោយនូវប្រការដូច្នេះហោង ៗ

អថស្សា បោក្ខរណីយា   បហុកា វារិគោចរា
រោហិតា នលបេ សិង្គូ①   កុម្ភិលា មករា សុសូ ។
បាឋីនា② បាវុសា មច្ឆា   ពលជា មុញ្ជរោហិតា
សវត្តា សតវត្តា ច   មង្គុរា ចាបិ កច្ឆបា ។
មធុ ច មធុលដ្ឋិ ច   តាលីយា③ ច បិយង្គុកា
កុដន្ទជា ភទ្ទមុញ្ជា   សត្តបុប្ផា ច សោវលុបា ។
សុរភិ មរុ តគរា   ពហុកោ តុង្គវល្លិយោ
បទ្មកា នារទា កោដ្ឋា   ឈាមកា ច ហរេណុកា ។
ហលិទ្ទកា គន្ធសេលា   ហិរិវេរា ច គុគ្គុលា
វិភេទកា ចោរកោដ្ឋា   កប្បុរា ច កលិង្គុកាតិ ។

ហៃព្រាហ្មណ៍អើយ វីក្នុងទឹកស្រះបោក្ខរណីនោះសោត ដ៏មានត្រីឆ្តោក ត្រីឆ្ពិន ត្រីច្រកែង ត្រីអណ្តែង ត្រីប្រា ទីពោ ឆ្តោ រាហូ នូវក្រពើ ឆ្លាម មករ ផ្សោតផង វីអស់ត្រីតូចធំផង សឹងហែបហែលទៅមក ពួដ៏កំឡុងស្រះនោះហោង ៗ ព្រាហ្មណ៍អើយ វីឆ្នេរស្រះបោក្ខរណីនោះសោត ដ៏មានឃ្មុំធំ

១- មហាវេស្សន្តរទីបនិយំ នលបេ សិង្គីតិបិ ទិស្សតិ ។ ២- អយំ គាថា មហាវនបព្វិត្ថារតោ សមាហរិត្វា អសីតិគាថាបរិបូរណត្ថាយ ឥធ លិខិតា ។ ៣- មហាវេស្សន្តរទីបនិយំ កាលិសាតិបិ ទិស្សតិ ។

ឃ្មុំផ្លិត ទំដោយឈើប្រិយង្គុ ខ្លែងគង់ ក្រវាញ ក្រវាន់ ភ្លាំពូ សំបូណ៍ល្វែង សូរភី កំញ៉ានមានទាំងវល្លិ៍បណ្ដូលពេច វំលេច ទាំងទេពទារូ មានទាំងដើមកោដ្ឋ កន្ទត ឈោត ហរតាន គ្រើល គ្រុង រង់ ព្រហូត ពពូល ពពាលខែ ដីប្លី ដ៏មានទាំងកប៌ូរ ចន្ទន៍ស ចន្ទន៍ក្រហម ។ ព្រាហ្មណ៍អើយ បើអ្នកឯណាមួយ ធ្វើសីលសូត្រមន្តភាវនា នៅនាព្រៃនោះ ក៏ស្រណុកសុខសប្បាយពេកហោង ។

អថេត្ថ សីហា ព្យគ្ឃា ច   បុរិសាលូ ច ហត្ថិយោ
ឯណេយ្យា បសតា① ចេវ   រោហិតា②សរភា មិគា ។
កោដ្ឋសុណា សុណោបិ ច   តុលិយា នឡសន្និភា
ចាមរី ចលនី លង្ឃី   ឈាបិតា មក្កដា បិចុ ។
កក្កដា កតមាយា ច   ឥក្កា គោណសិរា ពហូ
ខគ្គា វរាហា នកុលា   កាឡកេត្ថពហុត្តសោ③ ។
មហិសា សោណា សិគាលា   ចប្បកា ច សមន្តតោ
អាកុច្ឆា បចលាកា ច   ចិត្រកា ចាបិ ទីបិយោ
បេលកា ច វិឃាសាទា   សីហា គោកនិសាតកា
អដ្ឋបាទា ច មោរា ច   ភស្សរា ច កុក្កុត្ថកា ។

១- មហាវេស្សន្តរទីបនិយំ បសទាតិបិ ទិស្សតិ ។ ២- តត្ថេវ រោហិច្ចាតិបិ សិយា ។ ៣- មហាវេស្សន្តរទីបនិយំ ពហុត្តសោតិ យេកុយ្យេន ឯត្ថ មុចលិន្ទសរេ ហោន្តីតិ ទិស្សតិ ។

ចក្កោរា កុក្កុដា នាគា   អញ្ញមញ្ញំ បកុជិនោ
ពកា ពលាកា នជ្ជុហា   ឌិន្ទិភាកោញ្ច វាទិកា ។
ព្យគ្ឃិនសា លោហបិដ្ឋា   ចប្បកា ជីវជីវកា
កបិញ្ជរា តិត្តិរាយោ   កុលាវា បដិកុដ្ឋកា ។
មណ្ឌាលកា ចេលកេឡុ   ភណ្ឌុ តិត្តិរនាមកា
ចេលាវកា បិង្គលាយោ   គោដកា អង្គហេតុកា ។
ករវីកា ច សគ្គា ច   ឧហុក្ការា① ច កុក្កុហា
នានាទិជគណាកិណ្ណំ   នានាសរនិកុជិតន្តិ ។

ព្រាហ្មណ៍អើយ រីសត្វព្រៃផងទាំងឡាយ គឺ រាជសីហ៍ ដំរី សិង្ហ រមាស ខ្លាធំ ខ្លាដំបង ខ្លាឃ្មុំ មានទ្រាយ ទន្សោង ឈ្លូស រមាំង ប្រើស គោព្រៃ ខ្ទីង ចចក ស្វាន ស្វា មានទាំងកំប្រុក ឆ្មាបា ចាមរី រញ្ញី កុញ្ជរ ស្វាខោ ស្វាឌី ស្វាស្រូវ ស្វាអង្គត់ ស្វាព្រាហ្មណ៍ ជ្រូកព្រៃ មានទាំងសំពោច ទោច ឌីឡ ត្រកួត ទន្សង ត្រង បង្កួយផង សឹងឋិតនៅខាងអាស្រមបទព្រះបាទស្រីវេស្សន្តរ នោះរហោង ៗ បក្ខិនោ មួយសោត រីពួកបក្សា បក្សី ផងទាំងឡាយ ដ៏មានសត្វឥន្ទ្រី ត្មាត ខ្លែងស្រាក ខ្លែងខ្មោច ទីទុយ ក្ងោក ក្ងាន ប៉ោលតោក តាវ៉ៅ ស្វិតចៅ មានទាំងហង្ស អាឌិដ្ឋ មាន់ទោ មាន់ទឹក ប្រវឹក មាន់ព្រៃ

១- តត្ថេវ ឱហុង្ការាតិបិ ទិស្សតិ ។

ចចាត ច្រឡៀ សេកផង មានទាំងកុកគ្រោង កុកសាប់ កុកស ក្វ ក្រៀល ចង្កៀលខ្យង ក្រួច កង្កួច កងកេង ព្រះឥន្រ្ទ ស្ទាំង ភូវាំង ត្រដៀវរុិច តាដក់ ត្លុម រនាល ត្រយង ខ្លែងស្រាក ក្រសារ ទុង ទោម ទទា ចេកទុំ គ្រលេងគ្រលោង ចាបស្រុក ចាបព្រៃ គ្រលែងវែកផង ៗ

អថេត្ថ សកុណា សន្តិ នីលិកា ⑴ មញ្ជុភាណិកា
មោទន្តិ សហ ភរិយាហិ អញ្ញមញ្ញំ បកុជ្ជិនោ ៗ
អថេត្ថ សកុណា សន្តិ ទិជា មញ្ជុស្សរាសិតា
សេតក្ខិកូជា ភទ្រក្ខា អណ្ឌជា ចិត្របេក្ខណា ៗ
អថេត្ថ សកុណា សន្តិ ទិជា មញ្ជុស្សរាសិតា
សិខណ្ឌី ⑵ នីលគីវាហិ អញ្ញមញ្ញំ បកុជ្ជិនោ ៗ
កុក្កុត្ថកា កុលីរកា កោដ្ឋា បោក្ខរសាតកា
កាលទេយ្យា ពលីយក្ខា កទម្ពា សុវសាលិកា ៗ
ហលិទ្ទា លោហិតា សេតា អថេត្ថ នលកា ពហូ
វារណា ភិង្គរាជា ច កទម្ពា សុវកោកិលា ៗ
ឧក្កុសា កុររា ហំសា អាដា បរិវទេន្តិកា
ចាកហំសា អតិពលា នជ្ជុហា ជីវជីវកា ៗ
បារេវតា រវិហំសា ចាកវាកា នទីចរា

១- មហាវេស្សន្តរលិនាត្ថប្បកាសិនីយំ សាលិកាតិបិ ទិស្សតិ ៗ

២- អរញ្ញាទិវគ្គេ សិខណ្ឌីតិបិ ទិស្សតិ ៗ

វារណាភិរុទា រម្មា① ឧភោ កាលុបកុជិនោ ។
អថេត្ថ សកុណា សន្តិ នានាវណ្ណា ពហូ ទិជា
មោទន្តិ សហ ភរិយាហិ អញ្ញមញ្ញំ បកុជិនោ ។
អថេត្ថ សកុណា សន្តិ នានាវណ្ណា ពហូ ទិជា
សព្វេ មញ្ជូ និកុជន្តិ មុចលិន្ទមុភតោ សរំ ។
អថេត្ថ សកុណា សន្តិ ករវិកា នាម តេ ទិជា
មោទន្តិ សហ ភរិយាហិ អញ្ញមញ្ញំ បកុជិនោ ។
អថេត្ថ សកុណា សន្តិ ករវិកា នាម តេ ទិជា
សព្វេ មញ្ជូ និកុជន្តិ មុចលិន្ទមុភតោ សរំ ។
ឯណេយ្យបសតាកិណ្ណំ② នាគសង្ឃនិសេវិតំ
នានាលតាហិ សញ្ឆន្នំ កទលិមិគសេវិតំ ។
អថេត្ថ សាមា ពហុកា និវារោ វរកោ ពហុ
សាលី អកដ្ឋបាកោ ច ឧច្ឆុ តត្ថ អនប្បកោ ។
អយំ ឯកបទី ឯតិ ឧជុំ គច្ឆតិ អស្សមំ
ខុទ្ទំ បិបាសំ អរតី តត្ថ បត្តោ ន វិន្ទតិ ។
យត្ថ វេស្សន្តរោ រាជា សហ បុត្តេហិ សម្មតិ
ធារេន្តោ ព្រាហ្មណវណ្ណំ អាសទញ្ច មសញ្ជដំ
ចម្មវាសី ឆមា សេតិ ជាតវេទំ នមស្សតីតិ ។

១- មហាវេស្សន្តរទីបនីយំ វារណា អភិរុទរម្មាតិ បទច្ឆេទោ ។ អភិរុទរម្មាតិ រមិតព្វសទ្ទា ។ ឆន្ទានុរក្ខនត្ថំ មជ្ឈេ ទីឃោ ទិស្សតិ ។ ២- ឆន្ទានុរក្ខនត្ថំ មជ្ឈេ ទីឃោ សិយា ។

ព្រាហ្មណ៍អើយ រីអស់សត្វបក្សីផងទាំងឡាយ មាននៅនាព្រៃនោះ គឺ សារិកាកែវ យំក៏មានសំឡេងនោះពីរោះស្មោះ បីដូចជាលោកអ្នកប្រាជ្ញរាជបណ្ឌិតទេសនាធម៌ដ៏ប្រសើរ មុខគួរឱ្យត្រេកអរស្តាប់នូវសព្ទនោះពីរោះពេកហោង ៗ រីអស់សត្វបក្សីទាំងនោះសោត ក៏មានកំណើតនោះពីរដង គឺជាពងហើយញាស់ចេញមកជាកូន សឹងមានរបៀបស្លាប នូវកន្ទុយនោះល្អឥតឆ្គងឡើយ ហើយស្រែកនូវសព្ទសម្រែកបន្លឺទៅវិញទៅមក នៅនាព្រៃនោះឯង ៗ ព្រាហ្មណ៍អើយ រីសត្វទាំងឡាយ គឺ ប្រមង់ រអាត ខ្លែងស្រាក ក្អែកទឹក ប្រវីក លលក មៀម មានទាំងសេកយា សេកសោមបណ្ឌិត សេកស មានរែកណ្ដឹង ប្រមា ទោច ខ្លែងខ្មោច ទិទ្យ ភូវាំង ឥន្ទ្រី ចាមរី មានទាំងហង្សខៀវ ហង្សលឿង ហង្សស មានទាំងឧកអក សំបកទំពាំង ស្ទាំង តាវៅ ព្រហីត ស្វិតចៅ ព្រាបផង មានទាំងចាកក្រពាក ទាំងស្មោញ ទាំងខ្យង គឺខ្យងហៀន ខ្យងដែកចារ ល្មៀស គ្រំ ត្រែង ខ្យងមុខផង ៗ ព្រាហ្មណ៍អើយ កាលបើថ្ងៃរសៀលទន់ៗទៅហើយកូវ អស់រែកណ្ដឹងវាយំឮពីរោះ មុខគួរឱ្យស្រណោះពេក ៗ ព្រាហ្មណ៍អើយ រីសត្វទាំងឡាយនេះ សឹងកាច់សំបុកទុកពង នៅសងខាងស្រះមុចលិន្ទនោះ ៗ រីសត្វនាមហៅករវិកនោះសោត សឹងយំឮសព្ទឆ្លើយឆ្លងគ្នាទៅមក សឹងតែមុខគួរឱ្យស្រណោះពេក ៗ

ព្រាហ្មណ៍អើយ នៅខាងអាស្រមបទលំនៅ នៃព្រះបាទស្រីវេស្សន្តរនោះ ដ៏ពេញនីទៅនូវពពួកម្រឹគផងផ្សេងៗ គឺ សំពោច នូវស្កា វាលេងប្រឡែងប្រចាប់ចម្បាប់គ្នា ដោយភាសាវា ៗ ព្រាហ្មណ៍អើយ រីសងខាងស្រះនោះ ដ៏មានផ្តៀក ផ្តៅ ស្មៅជើងក្រាស់ លាស់ខ្ចី ស្រូវភោជន៍សាលី សឹងដុះឯង ទុំជ្រុះឯង ឥតអ្នកណាមួយទៅបង្កើតឡើយ រីអំពៅផងនោះ សោត ដ៏មានពណ៌នោះផ្សេងៗ គឺអំពៅថ្នាំងវែង អំពៅតម្លាន់ ព្រាហ្មណ៍អើយ បើអ្នកឯណាមួយដើរទៅដល់ យល់ហើយ ក៏បរិភោគឥតស្រែកឃ្លាន ដ៏មានចិត្តនោះក្សេមក្សាន្ត ពុំចង់ដើរចេញឡើយ ៗ ហៃព្រាហ្មណ៍អើយ រីផ្លូវ នឹងដើរទៅកាន់អាស្រមបទព្រះបាទស្រីវេស្សន្តរនោះ ចង្អៀត ចុះតែជើងអ្នកមួយដើរទៅក្តី ដើរមកក្តី ៗ ព្រាហ្មណ៍អើយ រីព្រះបាទស្រីវេស្សន្តរបវរបរមពោធិសត្វ ស្តេចចេញមកសាងព្រះផ្នួសបួសមួយអន្លើនឹងព្រះរាជបុត្រព្រះរាជទេពី ដ៏មានព្រះហស្តនោះកាន់ទម្លក់ថ្លក់ផ្លែឈើផង ចងព្រះកេសាជាជដាមណ្ឌល ហើយទ្រង់នូវស្បែកខ្លាទាំងក្រចក ក្រវាត់ស្បូវក្លាំង សំពះព្រះភ្លើង តាងចីវរព្រះបច្ចេកពោធិហោង ៗ

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណា ពុំទាន់ប្រាកដ បទព្រះបាលីឯណា ពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូត្រសានូវព្រះគាថា ដូច្នេះ

ឥទំ សុត្វា ព្រហ្មពន្ធុ ឥសី កត្វា បទក្ខិណំ
ឧទគ្គចិត្តោ បក្កាមិ យត្ថ វេស្សន្តរោ អហូតិ ។

ហៃភិក្ខុអើយ រីជូជកព្រាហ្មណ៍ ជាសន្តានស្មូមនោះ លុះបានស្តាប់ពាក្យអច្ចុតមហាឫសីហើយ ក៏មានចិត្តនោះត្រេកអរសាទរ ធ្វើប្រទក្សិណ ៣ ជុំហើយ ក៏លាចេញទៅ ។ រីព្រះបាទស្រីវេស្សន្តរ បវរពោធិសត្វ ស្តេចគង់សាងព្រ័តត្រង់ឋានឯណាមិញ ក៏ជូជកព្រាហ្មណ៍នោះ ឆ្ពោះមុខទៅត្រង់ឋាននោះហោង ។

ឥតិ ឥមស្មឹ មហាវនកណ្ឌេ អសីតិគាថាបដិមណ្ឌិតា មហាវនវណ្ណនា និដ្ឋិតា ហៃសាធុសប្បុរសផងទាំងឡាយអើយ អាត្មាភាពសំម្តែងថ្លែងព្រះធម៌វិសេសទេសនា ព្រះមហាជាតក៍ កណ្ឌមហាពន ដ៏ប្រដាប់ប្រដានូវគាថាទាំងឡាយ ៨០ គាថា នេះមិញ ជាគ្រឿងប្រដាប់សទ្ធាជ្រះថ្លា នៃពួកឧបាសកឧបាសិកា ឯទំ ក៏ចប់ដោយសមគួរ នៅវេលានេះឯងហោង ។

ចប់ កណ្ឌមហាពន ទី ៧ តែប៉ុណ្ណេះ ។

⁂

ចម្លងចប់នៅថ្ងៃ ៩ កើត ខែស្រាពណ៍ ព.ស. ២៥៣៣
ត្រូវនឹងថ្ងៃអង្គារ ទី ៣១ ខែកក្កដា គ.ស. ១៩៩០

មហាវេស្សន្តរជាតក

ទី ៨



កណ្ឌកុមារបព្វៈ

ប្រដាប់ដោយគាថា ១០១

មហាវេស្សន្តរជាតក

ទី ៨

កណ្ឌកុមារបព្វ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ជូជកោបិ អច្ចុតតាបសេន កថិតមគ្គេន យាវចតុរស្សបោក្ខរណីតីរំ បត្វា ចិន្តេសិ អជ្ជាតិសាយណ្ហោ ឥទានិ មទ្ទី អរញ្ញតោ អាគមិស្សតិ មាតុគ្គាមោ ហិ នាម ទានស្ស អន្តរាយករោ ហោតិ ស្វេ តស្សា អរញ្ញគតកាលេ អស្សមបទំ គន្ត្វា វេស្សន្តរំ ឧបសង្កមិត្វា ទារកេ យាចិត្វា តាយ អនាគតាយ ឯវន្តេ គហេត្វា បក្កមិស្សាមីតិ ។

ភោ សាធវោ(១) ហៃសាធុសប្បុរសផងទាំងឡាយអើយ

---

(១)- ច្បាប់មហាជាតក៏ខ្លះ មានបរិយាយប្លែកផ្សេងគ្នាដូច្នេះ " អស្សមោ វីអាស្រមភិរម្យរហោឋានសម្រាន្តរម្ងាប់កិលេស ដែលវិស្សុកម្មដ៏មានមហិទ្ធិរិទ្ធ មកនិម្មិតសាងថ្វាយព្រះវេស្សន្តរ នាកាលស្តេចចេញចរចាកព្រះរាជនិវេសន៍ មកសាងព្រះមហាភិនេស្រ្កមណ៍ក្រឹត្យ ប្រាថ្នាយកនូវបណ្តូលព្រះបារមី ជាទីទូរដ្ឋានចម្ងាយផ្លូវនោះ ៦០ យោជន៍ ។ សោ ជូជកោ រីឯជូជកព្រាហ្មណ៍អ្នកហីនហោច ជាផៅពង្សព្រាហ្មណ៍កំព្រាដើរកាត់មាគ៌ារបោះព្រៃភ្នំ អច្ចុតតាបសេន គឺអច្ចុតឫសីសិទ្ធទ្រង់នូវក្រឹត្យមង្គល អ្នកចង្អុលណែបង្ហាញលង្វែកព្រឹក្សា តាមដោយមាគ៌ាទៅផ្លូវខាងឧត្តរ ទើបជូជកចេញចាកព្រះអច្ចុតសាលា សង្វាតមកដល់មាគ៌ាមួយជាលង្វែកចង្អៀត ចុះតែជើងមួយដើរ ជូជកក្រឡេកមើលសព្វៗព្រឹក្សា ក៏លាន់ថា ឱះ ម្លេះអេះ នេះហើយជាផ្លូវទៅកាន់

ភ្លង . . .

នេះនឹងដំណាលកាលជូជកព្រាហ្មណ៍ ស្ទុះស្វែងតាមរកព្រះពោធិសត្វទៅដោយនូវផ្លូវដែលព្រះអច្ចុតមហាឫសីចង្អុលប្រាប់នោះ ក៏ព្រាហ្មណ៍ដើររៀងរាបងរាបបានដល់ស្រះបោក្ខរណីដ៏មានមុំនោះបួនរាបទាបប្រពៃស្រេចហើយនៃ ទើបព្រាហ្មណ៍យកដៃស្ទឹមចង្កេះ រិះគិតថា អជ្ជាតិសាយណ្ហេ ឱ! វេលាល្ងាចណាស់ហើយហ្ន៊! វេលានេះគាប់ជួនប្រចួបនឹងព្រះនាងមទ្រីមកអំពីព្រៃ ក៏ធម្មតាស្ត្រីតែងស្រឡាញ់កូនហើយពុំដែលសមប្រកបនឹងស្នូមផងឡើយ តែព្រះនាងមកទាន់ហើយ នឹងធ្វើឱ្យអន្តរាយដល់ទានបារមី នៃព្រះបរមពោធិសត្វប្រាកដហោង ៗ ស្វេ តស្សា អរញ្ញាគតកាលេ ហឹះ ក៏អញនឹងរលេះរលាំងអ្វីមាល្បាយ ថ្ងៃនេះ ព្រះនាងមក ថ្ងៃស្អែក តើព្រះនាងមិនចេញទៅព្រៃ ស្វែងរកផ្លែឈើនោះវិញទៀតទេឬអ្វី បើព្រះនាងចេញផុតទៅហើយ សឹមអញទៅឯក្រោយ ចូលទៅថ្កានអាស្រមបទសម្នាក់ព្រះបរមពោធិសត្វ ហើយអញនឹងក្រាបបង្គំទូលអង្វរសូមព្រះរាជបុត្រទាំងពីរ បើព្រះបរមពោធិសត្វមហាបុរសរ័ត្ន

ភ្នំគិរីវង្កត ត្រូវដូចពាក្យឥសីអ្នកប្រាប់អញ ជូជកខំច្រៀតជ្រែកដើរចូលទៅឆ្ពោះសំដៅគិរីគន្ធមាទន៍ បោក្ខរណីតីរំ បត្វា ជូជកខំសង្វាតមកដល់ឆ្នេរស្រះស្រី មានផ្កាឧត្បលចង្កុលណី ក្រហម ខៀវ ស សឹងដុះល្អជាជួររៀងរាយវាលវែងទៅឆ្ងាយ ដាច់កន្ទុយភ្នែក គាត់យល់ប្លែក ត្បិតគាត់ពុំដែលយល់ព្រៃខែត្រខេមព្រះហេមពាន្ត កើតសេចក្តីសប្បាយជាបរមសុខ ឯទឹកសោត ពុំល្អក់ដ៏ជ្រះថ្លា ជូជកគិតថា ឱ អញអើយ បានមកដល់ឋាននេះ គួរឈប់ស្លេះពិនិត្យពិចារណា សឹងធុំតែក្លិនផ្កាក្រស្នាចួងចន្ទន៍ ក្រអូបល្វេងល្វើយ យល់ជាភ្នំគន្ធមាទន៍ឯងហើយ ត្រូវដូចជាពាក្យឥសីអ្នកប្រាប់ទិសទីមក ជា

ឆ្លង . . .

ទ្រង់ព្រះរាជទានព្រះរាជបុត្រទាំងពីរ ឱ្យអញហើយ អញនឹងនាំក្មេងទាំងពីររត់បំព្រាត់ចេញមក កុំបីឱ្យសម្តេចព្រះភគវតី ព្រះនាងមទ្រីស្តេចមកទាន់អញឡើយ ៗ អថស្សាវិទូរេ ឯកំ សានុបព្វតំ អារុយ្ហ ផាសុកដ្ឋានេ និបជ្ជិ ព្រាហ្មណ៍គិតនូវប្រការអម្បាលនោះហើយ ក៏ដើរសសៀរទៅតាមចំនៀវភ្នំ ពុំឆ្ងាយនឹងអាស្រមបទព្រះពោធិសត្វនោះឡើយ ហើយក្រឡេកទៅយល់រអាងថ្មមួយ ជាថ្លុកជង្ហុកល្អ ក៏ដើរចូលទៅ ផ្គួងផ្គងនឹងខ្នងកោងកំពកប្រះខ្លួនដេកហើយ ក៏សរសើរថា ឱ! ឋាននេះស្រណុកក្សេមក្សាន្តអ្វីមាល្បាយ ហើយព្រាហ្មណ៍ ក៏ដេកលក់ទៅហោង ៗ

តំ បន រត្តឹ បច្ចូសកាលេ មទ្ទី សុបិនំ អទ្ទស បពិត្រអើយ នាកាលរាត្រីយប់នោះឯង សម្តេចព្រះភគវតីព្រះនាង

ប្រាកដ នុ៎ះហើយជាចុងជហ្វាព្រះអាស្រមបទ ៗ អជ្ជាតិសាយណ្ហេ ឥឡូវព្រះអាទិត្យក៏ទាបទៅបាំងនឹងជ្រុងសុមេរុគិរី វេលានេះ សមនាងនឹងចូលមកកាន់ទីអាស្រមបទហើយសមនឹងបីថ្នមថ្នាក់លួងលោមព្រះរាជបុត្រាបុត្រី និយាយសំណេះសំណាលដោយសេចក្តីស្នេហា ៗ មាតុគ្គាមោ ធម្មតាជាស្ត្រី ក៏រែងតែសោកស្តាយនឹងទានបារមី ពុំហ៊ានលើកយកបុត្រាបុត្រីឱ្យជាទាន ៗ ស្វេ នាថ្ងៃព្រឹកនេះ ជាថ្ងៃពេញបូណ៌ឧបោសថ ព្រះអង្គទ្រង់ព្រ័តចម្រើនសីលសេដ្ឋា ឯនាងក៏ចេញទៅព្រឹក្សារកអស់ផលាផល បើដោយអញគិតយល់ សមព្រះអង្គនឹងឱ្យទាន ត្បិតយាមនេះ ក៏បានដោគរាហូល្អ គួរគិតគួរឈប់ស្លេះដេកនៅនេះ ក៏ប្រសើរមិនខូចការ ជូជកស្លាយបរិក្ខារដើរ រឹមវាមទៅមករកថ្មឈ្មួងឆក ឱ្យត្រូវនឹងខ្នងកោង លុះឃើញឈ្មួងឆកហើយ យកខ្នងទៅល យល់ជាត្រូវល្អហើយ ទើបប្រះខ្លួនដេកលក់ស្រមុកគគ្រឹកគគ្រុក ជាសុខទៅនៅនាលំនៅឋាននោះឯងហោង ៗ តំ បន រត្តឹ ៗល ៗ

មទ្រីទ្រង់ព្រះសុបិនជាអពមង្គល យល់ដូចបុរសមួយនោះ ខ្មៅទាប មិនសុភាពដូចអ្នកផងទាំងឡាយឡើយ ហើយបុរសនោះស្លៀកសំពត់ជ្រលក់ទឹកអម្ចត់ត្រឹមចង្កេះ សៀតផ្កាច្រាលវន្ទាលនៅឰដ៏ត្រចៀកទាំងសងខាង វារត់អំភ្លាងមកខាងបរមសាលា ដ៏មានដៃកាន់នីទៅនូវគ្រឿងអាវុធថ្លា ស្រែកគំរាមថា នាងមទ្រីនៅទេហ៎ា នាងមទ្រីនៅឬទេ ហើយវារត់ចូលទៅក្នុងបរមសាលា វាភើចកន្ត្រាក់នូវសំណុំព្រះកេសាជតាមណ្ឌលនៃព្រះនាងមទ្រី ឱ្យប្រេះដួលថ្វារទៅលើក្រទ្បាមហាប្រឹថពី ហើយវាឆ្កៀលព្រះនេត្រទាំងពីរ កាត់នូវដើមព្រះអង្សាទាំងសងខាង ហើយវាវៀលវះពន្លះព្រះទ្រូង រូងយកថ្លើមបេះដូងនាំចេញទៅ ដ៏មានព្រះលោហិតនោះ ហូរស្រោចស្រពសព្វអស់ព្រះអង្គ សវ មន្ទី បពុជ្ឈិត្វា ភីតតសិតា បពិត្រអើយវីសម្តេចព្រះភគវតីព្រះនាងមទ្រី តើនឡើងអំពីក្រទ្បាបន្ទំ ដ៏មានព្រះទ័យនោះភិតភ័យញាប់ញ័រ ចំប្រប់អស់អង្គ ទ្រង់ពិចារណាថា ឱ! សប្តិនេះ វាអាស្រូវអ្វីមាល្បាយអេះ អញមិនដែលយល់សប្តិដូច្នេះសោះ បើដោយនិមិត្តសប្តិនេះ នឹងមានអពមង្គលពុំជា ឬមួយមានសិរីសួស្តីល្អទេ ៗ ក៏ឥឡូវនេះ អ្នកណានឹងចេះទាយសប្តិអញនេះ ដូចអញនៅនាជេតុត្តរនគរនាយវ៉ា អញនឹងឱ្យកវីបណ្ឌិតព្រាហ្មណ៍ព្រឹទ្ធហោរាមកជំនុំពិចារណាទាយសប្តិនេះឱ្យអញ ឥឡូវនេះ អញនៅនាព្រៃភ្នំទូគ៏មមិតរាយឆ្ងាយម្ល៉េះ តើអញនឹងធ្វើដូចម្តេច លុះព្រះនាងរំពឹងគិតដូច្នេះហើយ ទ្រង់ពិចារណាថា ទេ ! នឹងរកអ្នកចេះ

ទាយសប្តិកំណាចនេះឱ្យស្មើនឹងព្រះបាទស្រីវេស្សន្តរបរមបពិត្រ ដ៏ជាក្រឡាគម្តែងវិសេសនៃអញនេះគ្មានឡើយ បើដូច្នេះ គួរអញទៅថ្វាយបង្គំប្រណម្យព្រះអង្គ ឱ្យទ្រង់ទាយសប្តិអញនេះ ព្រះនាងទ្រង់ព្រះចិន្តានូវប្រការអម្បាលនោះហើយ ស្តេចលីលាយាត្រាចេញអំពីព្រះបរមសាលាទាំងរាត្រីនោះឯង លុះដល់ទ្វារព្រះបរមសាលាហើយ ព្រះនាងពុំហ៊ានទូលដាស់ឡើយ យកតែព្រះហស្តនោះគោះសន្លាក់ទ្វារព្រះបរមសាលានោះកូរ ៗ

អថ មហាសត្តោ តំ សទ្ទំ សុត្វា កាលនោះ ព្រះបរមពោធិសត្វមហាបុរសរ័ត្ន ព្រះអង្គឮសព្ទព្រះនាងគោះទ្វារ ទើបត្រាស់ដណ្តឹងទៅថា កោ ឯសោ នរណាហ្នឹង មកគោះទ្វារព្រះអាស្រមបទកុដី ទាំងរាត្រីថ្នារនេះ យល់ពុំជួកាលដូចសព្វដង (១) ៗ

ទើបព្រះនាងក្រាបបង្គំទូលស្នងព្រះរាជឱង្ការ ពីខាងក្រៅថា

១- មានច្បាប់មហាជាតក៏ខ្លះ មានបរិយាយប្លែកផ្សេងគ្នាដូច្នេះថា " អថ មហាសត្តោ តំ សទ្ទំ សុត្វា កាលនោះ ព្រះបរមពោធិសត្វមហាបុរសរ័ត្នព្រះអង្គតើនឡើងអំពីព្រះក្រឡាបន្ទំ ព្រះអង្គឮស័ព្ទព្រះនាងគោះទ្វារនោះហើយ ព្រះអង្គទ្រង់ព្រះចិន្តាក្នុងព្រះហឫទ័យថា អន្តិក្តីអ្វីមាល្បាយ នរណាមកគោះទ្វារព្រះបរមសាលាទាំងថ្នារនេះ មិនដែលមាន អារក្ស ទេវតា ខ្មោចបិសាច រាជភូត ឬមនុស្សឯណាមួយហ៊ានចូលមកធ្វើកលដល់អញឡើយ ថាបើ អារក្សខ្មោចបិសាចមកធ្វើកលអញ វាតែងគោះឯលើទ្វារ ថាបើមនុស្សម្នាធ្វើកល ក៏គោះពាក់កណ្តាលទ្វារ ថាបើម្រឹគបក្សាបក្សីធ្វើកល តែងគោះនៅក្រោមទ្វារ ឥឡូវនេះ វាឮសូរស័ព្ទត្រង់កណ្តាលទ្វារនេះ សមជាមនុស្សទេដែលធ្វើកលអញនោះ ទើបត្រាស់ដណ្តឹងទៅថា កោ ឯសោ នរណាហ្នឹងមកគោះទ្វារព្រះអាស្រមបទកុដីទាំងរាត្រីថ្នារនេះយល់ពុំជួកាលដូចសព្វដង "ៗ

អហំ ទេវ មទ្ទី បពិត្រព្រះសម្មតិទេព អញខ្ញុំនេះ ឈ្មោះមទ្រី ជាខ្ញុំស្រីព្រះអង្គ ៗ សម្ដេចព្រះមហាសត្វ ទ្រង់ស្ដាប់ជាក់ជាព្រះនាងមទ្រីហើយ ព្រះអង្គមានព្រះទ័យពុំស្រណុកឡើយ ទើបមានព្រះបន្ទូលទៅកាន់ព្រះនាងមទ្រីថា មទ្រីនាងអើយ នាដំណើរនាងមកកាន់អញនេះ នោះមានបំណងប៉ុនប៉ង នឹងទម្លាយក្រឹត្យវត្តប្រណិប័តន៍អញនេះឱ្យអន្តរាយមិនទេឡើយ យើងបានស្រដីប្ដេជ្ញានឹងគ្នាហើយតើ ពីកាលយើងទើបមកដល់ កម្ពុល់ជាអ្នកបួសនេះ ថាបើវេលាពុំជួកាល កុំអាលនាងមកកាន់អញឡើយ ក៏ឥឡូវនេះហេតុអ្វីឡើយក៏នាងមកកាន់អញនាវេលាពុំជួកាលដូច្នេះវឹងហ៏ះ ៗ

សម្ដេចព្រះនាងមទ្រីក្សត្រីឧត្ដមប្រណម្យទូលថា បពិត្រព្រះសម្មតិទេពមហារាជអើយ នាព្រះបន្ទូលព្រះអង្គនោះគាប់ពិត ប៉ុន្ដែសូមទ្រង់ព្រះមេត្តាស្ដាប់អញខ្ញុំសិន នឹងក្រាបបង្គំទូល ឱ្យសព្វព្រះហឫទ័យ នាអញខ្ញុំមកនេះ ហៅឆ្លងនឹងព្រះរាជអាជ្ញា ព្រះបាទបរមបពិត្រហើយ គឺមោះ អញខ្ញុំមកនេះ ពុំប្រាថ្នាដោយនូវវិស័យលោកធម៌នោះឡើយ នាអញខ្ញុំមកនេះ ត្បិតអញខ្ញុំយល់សប្ដិអាក្រក់ សូមទ្រង់ព្រះករុណា ទ្រង់ពិចារណាសប្ដិនេះឱ្យទាន ៗ ព្រះបាទស្រីវេស្សន្តរបរមបពិត្រ ស្ដេចស្ដាប់ព្រះបន្ទូលសម្ដេចព្រះនាងមទ្រីក្សត្រី ដោយនូវដំណើរដូច្នោះក្ដី ព្រះអង្គមានព្រះហឫទ័យនោះក្សេមក្សាន្ដ មានព្រះបន្ទូលថា មទ្រីអើយ ថាបើដូច្នោះ ចូរនាងថ្លែងសម្ដែងប្រាប់អញ អំពីខាងក្រៅនោះមក អញពិចារណា

សប្តិឱ្យនាងហោង ៗ ទើបសម្តេចព្រះនាងមទ្រី ថ្លែងសម្តែងសប្តិដូចព្រះនាងបានយល់នោះ សព្វគ្រប់ប្រការ ៗ

កាលនោះ ព្រះមហាក្សត្រទ្រង់ព្រះចិន្តាពិចារណា ដោយព្រះប្រាជ្ញាទិព្វ ឈ្វេងយល់ពុំកំបាំងដល់តិចឡើយ ស្ទេ នាថ្ងៃស្អែកនេះឯងហើយ នឹងមានស្មូមយាចកមួយ មកសូមកូនអញទាំងពីរ ជាទានបារមី ហៅបុត្តបរិច្ចាគ នឹងបានពេញបរិបូណ៌ នាកាលថ្ងៃស្អែកនេះ ៗ បើដូច្នេះ អញនឹងប្រាប់នាងមទ្រីដោយនូវពិតឯណាក៏បាន ត្បិតជាអ្នកសោកស្តាយ ស្រឡាញ់កូនទាំងពីរនេះណាស់ គួរអញប្រាប់បង្វែងវិញ ទើបព្រះអង្គមានព្រះបន្ទូលថា ហៃមទ្រីក្សត្រីប្រសើរអើយ កុំថប់បារម្ភនឹងសប្តិនោះឡើយ រីនាងយល់សប្តិអាក្រក់នោះ ត្បិតនាងធ្លាប់នៅនានគរបវររាជដ្ឋាននាយនោះ រែងផ្ទំលើគម្រាលពូក ព្រែព្រាំចៀមចំ បន្ទំក្រោមស្វេតច្ឆត្រពិចិត្រប្រសើរ ឥឡូវនេះ នាងមកដេកលើគម្រាលស្លឹកឈើ នៅនាមហាព្រៃថ្ពីធូលីដីខ្សាច់ ៗ មួយសោត នាងធ្លាប់បរិភោគនូវភោជនាហារសឹងតែភោជ្ជសាលីប្រហើរទន់ពីសា ប្រដាប់ទុកលើសុពណ៌ភាជន៍មាសមានឱជារសពិសាត្រកាលផ្សេង ៗ ឥឡូវនេះ នាងបរិភោគតែផ្លែឈើទុំច្រឡំនូវទឹកឃ្មុំឥតមេនេះ ហេតុនេះ បណ្តាលឱ្យទៅជារវើរវាយ យល់សប្តិអាក្រក់ គឺមោះ រីសប្តិនាងនេះល្អជាទេ កុំនាងបារម្ភឡើយ ចូរនាងទៅកាន់អាស្រមវិញចុះ ខ្លាចកូនទាំងពីរភ្ញាក់ឡើងយំរកម្តាយ ព្រះពោធិសត្វលួងលោមនាងដូច្នោះហើយ

ទើបឱ្យដំណើរនាង ត្រឡប់ទៅវិញហោង (១) ។

បពិត្រអើយ លុះព្រឹកព្រហាម តាមអរុណោទ័យថ្ងៃរះឡើងក្សូវ សម្តេចព្រះនាងមទ្រីទេវី ប្រដាប់នូវអំពើទាំងពួងដ៏គួរធ្វើ ជាដើមគឺ ដងទឹកសោយ ទឹកស្ងួន់ ទឹកលាងព្រះបាទ ទឹកស្រង់ ថ្វាយព្រះ

១- មានច្បាប់មហាជាតក៏ខ្លះទៀត មានបរិយាយប្លែកផ្សេងតទៅទៀតថា ព្រះនាងមទ្រីនឹងជាក់ក្នុងព្រះប្រាជ្ញា យល់ជាពុំត្រូវដូចព្រះអង្គទាយ ទើបព្រះនាងក្រាបថ្វាយបង្គំលាទៅឯឋានព្រះអាស្រម ហើយទ្រង់ព្រះកន្សែងពិលាប នឹងព្រះរាជបុត្រាបុត្រី ថា ហៃកូនគូកម្សត់ម្តាយអើយ នាព្រឹកភ្លឺហើយ អ្នកកុំដេកដល់ថ្ងៃ ហើយព្រះនាងដឹកដៃជាលីក្រស្នា មកលុបលាងព្រះភក្ត្រស្រេចហើយ ទើបព្រះនាងនិយាយប្រាប់កាលកើតនិមិត្តក្នុងវេលារាត្រី ថា ហៃកូនមាសម្តាយអើយ ម្តាយដេកយប់មិញនេះ យល់សប្តិពុំជា ម្តាយបានទៅក្រាបទូលព្រះវរបិតា ស្តេចទ្រង់ទំនាយ ថាជាល្អ ឯម្តាយយល់ជាក្រ ព្រួយចិត្តនឹងអ្នកណាស់ ៗ ឱហេតុតែកម្មវេរា ទើបឱ្យព្រាសនិរាសចេញឆ្ងាយ បើកាលនៅស្រុកឯនាយនោះវ៉ា ម្តាយពុំសូវគិតបារម្ភ ត្បិតមានភីលៀងមេនំចាំបម្រើគាល់ហៅ ឥឡូវ ចេញមកនៅព្រៃស្ងាត់សូន្យមានតែបងនិងប្អូនពីរនាក់ បានយល់ព្រះភក្ត្រតែព្រះវរបិតា ឯម្តាយតោងចេញទៅព្រឹក្សា ចោលអ្នកឱ្យនៅតែឯង ព្រោះតែសេចក្តីអត់ឃ្លានក្រលំបាក នាងថ្លែងពិលាបអួលអាក់ ផ្តាំព្រះរាជបុត្រ ថា៖ ហៃកូនកម្សត់ម្តាយអើយ ម្តាយនឹងចេញទៅព្រៃហើយរកអស់ផលាផល ចូរអ្នកនៅគ្រងរក្សាក្រស្នាក្សត្រី ត្បិតពុំទាន់ដឹងសេចក្តីរាក់ជ្រៅ ចូរអ្នកនៅរក្សាគ្នាណាអ្នកមាសម្តាយ ហើយបបោសព្រលឹងព្រះរាជបុត្រទាំងពីរស្រេចហើយនាងដឹកដៃជាលីក្រស្នាលីលាទៅឯអាស្រមបរមពោធិសត្វ. . . ៗ

ពោធិសត្វហើយ ព្រះនាងថ្នមព្រះរាជបុត្រទាំងពីរ បីឡើងតម្កើងតម្កល់ដល់លើព្រះឧរា ហើយបន្ទូលថា ម្នាលកូនសំឡាញ់ម្ដាយអើយ នាយប់មិញ ម្ដាយយល់សប្តិអាក្រក់ពេក កូនស្ងួនទាំងពីរម្ដាយអើយ កុំបីបាប្រហែសខ្លួនដើរទៅលេងទីទៃៗឡើយ ព្រះនាងឱ្យដំបូន្មានព្រះរាជបុត្រម្លោះហើយ ក៏ទ្រង់ពយកទៅថ្វាយព្រះមហាក្សត្រ ក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព អម្ចាស់ខ្ញុំអើយ កុំបីព្រះអង្គប្រហែសព្រះរាជបុត្រទាំងពីរ កុំឱ្យទៅលេងឆ្ងាយនឹងព្រះអង្គឡើយ ៗ សម្ដេចព្រះនាងមទ្រីក្សត្រីឧត្តម ទ្រង់បង្វែរព្រះរាជបុត្រទាំងពីរ ថ្វាយព្រះមហាក្សត្រ ដូច្នោះហើយ ទើបព្រះនាងប្រដាប់នូវករញ្ជី សង្រែក ដងវែង ជ្រនីក ទម្លក់ ពុំស្រណុកក្នុងព្រះរាជហឫទ័យ ឱ្យកខ្សួល អួលអាក់ក្នុងព្រះឱរា ទ្រង់ព្រះកន្សែង ហូរទឹកព្រះនេត្រា សស្រាក់ពព្រាក់អំភ្លាង ព្រះនាងខំទប់ យាងព្រះបាទចូលទៅក្នុងព្រៃ អាស្រ័យប្រយោជន៍នូវបេះផ្លែឈើ ជីកមើមដំឡូងផងទាំងឡាយ ព្ឋដ៏កាលនោះឯង ៗ

ជូជកោបិ ឥទានិ មទ្ទី អរញ្ញំ គតា ភវិស្សតីតិ
ហែសាធុសប្បុរសផងទាំងឡាយអើយ រីឯជូជកព្រាហ្មណ៍ភ្ញាក់ឡើងពីដេកក្រឡេកមើលទៅគិតថា ព្រឹកហើយហ្ន៎ ! អើ ! ថ្ងារនេះ សមសម្ដេចព្រះនាងមទ្រីស្ដេចលីលាទៅព្រៃ មិនទេឡើយ ហើយគួរអញចូរទៅម្ពីម្ពា ថ្វាយបង្គំប្រណម្យព្រះបាទស្រីវេស្សន្តរ ក៏បានអេះព្រាហ្មណ៍គិតដូច្នោះហើយ ចុះកកេបកកាបដោះឡើង ប្រវាបាន

ឈើច្រត់នូវថង់ស្បៀងស្ពាយឆៀង ដើរសសៀរចុះមកពីលើភ្នំនោះ ដើរទៅដោយនូវផ្លូវចង្អៀតចុះតែជើងអ្នកមួយ ដើរទន្ទប លលប ឆ្ពោះមុខទៅលំនៅអាស្រមបទនោះហោង ។

មហាសត្តោបិ បណ្ណសាលតោ និក្ខមិត្វា បាសាណផលកេ សុវណ្ណបដិមា វិយ និសីទិត្វា ចិន្តេសិ

កាលនោះ ពង្សពូជព្រះពោធិសត្វ បានទ្រង់ព្រះពិចារណាសប្តិ សម្តេចមទ្រីអំពីយប់ ទ្រង់សព្វព្រះរាជហឫទ័យថា នឹងមានស្មូម មកសូមព្រះរាជបុត្រទាំងពីរ ដូច្នោះមិញ ព្រះអង្គស្តេចចេញ អំពីបណ្ណសាលា វេលាព្រឹកព្រហាម មកគង់រង់ចាំលើដម្បារថ្ម មានព្រះអង្គល្អបីដូចព្រះរូបបដិមាមាស គិតដ៏ជាងទងបោះថ្មី ល្អប្រសើរ ព្រះអង្គទន្ទឹងទតមើលផ្លូវជូជកព្រាហ្មណ៍ថា កាលឯណាអេះ ស្មូមនឹងចូលមកសុំអញ លោកឧបមាថា ព្រះរាជហឫទ័យព្រះអង្គ គង់រង់ចាំស្មូមនោះ ដូចបុរសម្នាក់ប្រមឹកស្រា លុះព្រហាមឡើង ប្រើប្រពន្ធឱ្យទៅទិញស្រាឯផ្សារ ខ្លួនឯងអង្គុយចាំនៅមាត់ទ្វារ តែងនឹងទន្ទឹងថា មកឆាប់ៗវ៉ា អញនឹងអាលផឹក ព្រះហឫទ័យព្រះអង្គអាល័យចង់ឱ្យទាន មិនមានរួញរា ក៏មានឧបមាបីដូច្នោះហោង

បុត្តាបិស្ស បាទមូលេ កីឡន្តិ កាលនោះ សម្តេចព្រះរាជបុត្រទាំងពីរ លេងពុំឆ្ងាយនឹងព្រះបាទព្រះអង្គឡើយ ព្រះពោធិសត្វមហាបុរសរ័ត្នបពិត្រ ព្រះអង្គទតទៅនាផ្លូវឆ្ងាយបន្តិចទៅកូវយល់ជូជកព្រាហ្មណ៍ដើរតម្រង់មករកព្រះអង្គ មានព្រះរាជហឫទ័យ

ត្រេកអរក្រៃ ហាក់ដូចទានដែលបានកប់ទុកមក៧ខែហើយ ទើបព្រះអង្គមានព្រះបន្ទូលថា ឯហិ ខត ភោ ព្រាហ្មណ ហៃចៅព្រាហ្មណ៍អើយ ចូរចៅមកអាយរ៉ា អញទន្ទឹងចាំចៅទេតើ ស្ដេចមានបន្ទូលនឹងព្រាហ្មណ៍ដូច្នោះហើយ រឹងត្រេកអរក្នុងព្រះរាជហឫទ័យ បន្ទូលហៅជាលីកុមារ ដោយនូវបាទគាថាដូច្នេះ

ឧដ្ឋេហិ ជាលិ បតិដ្ឋ ពោរាណំ វិយ ទិស្សតិ
ព្រាហ្មណំ វិយ បស្សាមិ នន្ទិយោ មាភិគីររេតិ ៗ

តាត ហៃចៅជាលីបុត្រច្បងពិសីទន្ទកពន្លក ស្ងួនសំឡាញ់ឪពុកអើយ ឧដ្ឋេហិ ចូរបាដោះឡើងមកឈរ ឆ្ពោះមុខឪពុកបន្តិច ពោរាណំ វិយ ទិស្សតិ ឪពុកស្រណោះ ហាក់ដូចឪពុកនៅនាជេតុត្តរនគរ តែងឱ្យទានដល់ស្មូមយាចកផងទាំងឡាយ ចូរបារមិលមើលទៅមុខ ហាក់ដូចមានព្រាហ្មណ៍ដើរចូលមក នន្ទិយោ មាភិគីររេ ឥឡូវនេះ ឪពុកមានអំណរផ្សព្វផ្សាយ ដូចជាកាលនោះហោង ៗ

ឯចៅជាលី ស្ដាប់ព្រះបន្ទូលដូច្នោះហើយ ទើបប្រណម្យក្រាបបង្គំទូលថា

អហំបិ តាត បស្សាមិ យោ សោ ព្រហ្មា វ ទិស្សតិ
អត្ថិកោ វិយ អាយាតិ អតិថី នោ ភវិស្សតីតិ ៗ

បពិត្រព្រះវររាជបិតា ខ្ញុំព្រះអង្គក៏បានឃើញដែរ ឯបុរសនោះយល់ប្រាកដដូចជាព្រាហ្មណ៍ បពិត្រព្រះអង្គ ព្រាហ្មណ៍នេះ មកជា

ភ្ញៀវនៃយើង គឺមោះ មានបើប្រាថ្នាអ្វីមួយ មិនទេឡើយ ។ ចៅជាលីកុមារ ក្រាបទូលព្រះវរបិតាដូច្នោះហើយ ក៏ម្នីម្នាដោះឡើងរត់ទៅទទួលអស់គ្រឿងបរិក្ខារអំពីជូជកព្រាហ្មណ៍ ។ កាលនោះព្រាហ្មណ៍រមិលមើលមកយល់ព្រះរាជបុត្រ គិតថា អេះ នេះឯងហើយ ព្រះរាជបុត្រព្រះបាទស្រីវេស្សន្តរ ឈ្មោះ ចៅជាលីកុមារ អញសង្វាតមកអំពីនាយធ្លាក់អាយ ប៉ុនប៉ងនឹងសូមព្រះរាជកុមារនេះ ទៅធ្វើជាខ្ញុំនាងអមិត្តតាបនាជាភរិយានៃអញ បើដូច្នេះអញនឹងស្រដីពាក្យពីរោះផងឯណាក៏បាន ចាប់ដើមអំពីថ្ងៃនេះទៅអញនឹងស្រដីនូវពាក្យរបឹងរឹងរូស ទើបកុមារនេះខ្លាច ។ អបេហិ អបេហីតិ អច្ឆរំ បហរិ ទើបជូជកព្រាហ្មណ៍ ផ្ទាត់ក្រចកប្រុស ។ ថា ក្មេងតូចកំណាច ដោះឡើងចៀសចេញឱ្យឆាប់ បើខំតម្ងើចនៅនេះ មុខជាត្រូវនឹងឈើច្រត់រំពាត់ឫស្សី ឥឡូវនេះឯង ។ កុមារោ អបគន្ត្វា ចៅជាលីកុមារ ស្ដាប់ពាក្យព្រាហ្មណ៍ហើយគិតថា ព្រាហ្មណ៍នេះរបឹងរឹងរូសអ្វីមាល្បាយអេះ ទ្រង់ទតពិចារណាអស់ប្រឡងសរីរព្រាហ្មណ៍នោះទៅ ក៏ឃើញទោសចង្រៃអប្បល័ក្ខណ៍ ១៨ ប្រការមាននៅនឹងខ្លួនព្រាហ្មណ៍ ទើបព្រាហ្មណ៍នេះ របឹងរឹងរូសណាស់ ។

ព្រាហ្មណោបិ ពោធិសត្តំ ឧបសង្កមិត្វា បដិសន្ថារំ ករោន្តោ អាហ កាលនោះ ព្រាហ្មណ៍ ចូលទៅគាល់ព្រះពោធិសត្វ ក្រាបទូលធ្វើបដិសណ្ឋារៈ សំណេះសំណាល សូត្រជា

បាទគាថា ដូច្នេះ

កច្ចិ នុ ភោតោ កុសលំ កច្ចិ ភោតោ អនាមយំ
កច្ចិ ឧញ្ឆេន យាបេថ កច្ចិ មូលផលា ពហូ ។
កច្ចិ ឌំសា មកសា ច អប្បមេវ សិរឹសបា
វនេ វាឡមិគាកិណ្ណេ កច្ចិ ហឹសា ន វិជ្ជតីតិ ។

បពិត្រព្រះអង្គទ្រង់សីលសិក្ខា ជាមហាឫសី វិសេសប្រសើរអើយ នាព្រះករុណា មកគង់នៅកំឡុងព្រៃធំជ្រងំស្ងាត់ឆ្ងាយម្ល៉េះ តើជាផាសុកស្រណុកក្នុងព្រះអង្គជាសប្បាយ ឬមួយមានព្រះជំងឺរោគាពាធពុំស្រណុក ជាទុក្ខក្នុងព្រះខន្ធសន្តាន បពិត្រព្រះរាជឫសីអើយ នាអំពើចិញ្ចឹមជីវិត ឱ្យរស់នៅ ដោយផ្លែឈើផងទាំងឡាយ នៅព្រៃអាយនេះ ញ៉ាំងមានមូលផលាហារច្រើន គ្រាន់សន្សំសោយបានឬទេ ។ រីមូស សុច ស្រាំង ស្រួយ ខ្ទួយ ក្អែប អាសិរពិស ពស់តូច ពស់ធំ ច្រឡំនូវពស់ដែក ពស់វែក ពស់ថ្វាសទន្សោង ពស់កន្ត្រាងភ្លើង ពស់ដី ពស់ប្រមោយដំរី ថ្លាន់ភ្លីផង ញ៉ាំងមានច្រើនឬទេ ។ រីម្រឹគីម្រឹគាពាឡសាហាវយង់ឃ្នងផង តើញ៉ាំងមានមកបៀតបៀនព្រះអង្គឬទេ ។

កាលនោះ ព្រះពោធិសត្វមហាបុរសរ័ត្ន ព្រះអង្គស្តាប់ពាក្យព្រាហ្មណ៍ហើយ ទើបទ្រង់បដិសណ្ឋារៈតប ទៅជូជកព្រាហ្មណ៍ ទ្រង់សូត្រជាបាទគាថា ដូច្នេះ

កុសលញ្ចេវ នោ ព្រហ្មេ អថោ ព្រហ្មេ អនាមយំ

អថោ ឧញ្ឆេន យាបេម　　អថោ មូលផលា ពហូ ។
អថោ ឌំសា មកសា ច　　អប្បមេវ សិរីសបា
វនេ ពាឡមិគាកិណ្ណេ　　ហឹសា មយ្ហំ ន វិជ្ជតិ ។
សត្ត នោ មាសេ វសតំ　　អរញ្ញេ ជីវិសោកិនំ
ឥទំបិ បឋមំ បស្សាមិ　　ព្រាហ្មណំ ទេវវណ្ណិនំ
អាទាយ វេឡុវំ ទណ្ឌំ　　អគ្គិហុត្តំ កមណ្ឌលុំ ។
ស្វាគតន្តេ មហាព្រហ្មេ　　អថោ តេ អទុរាគតំ
អន្តោ បវិស ភទ្ទន្តេ　　បាទេ បក្ខាលយស្សុ តេ ។
តិណ្ឌុកានិ បិយាលានិ　　មធុកេ កាសមារិយោ
ផលានិ ខុទ្ទកប្បានិ　　ភុញ្ជ ព្រហ្មេ វរំ វរំ ។
ឥទំបិ បានិយំ សីតំ　　អាភតំ គិរិគព្ភរា
តតោ បិវ មហាព្រហ្មេ　　សចេ ត្វំ អភិកង្ខសិ ។

ព្រហ្មេ ហៃចៅព្រាហ្មណ៍អើយ ពីដូចអ្នកស្រីពិរាស្ត្រ គេបំបរបង់ អញមកនៅនាព្រៃអាយនេះ សុខស្រណុកសប្បាយឥតរោគាព្យាធិឧត្បាតជំងឺតម្កាត់ឡើយ ។ ព្រាហ្មណ៍អើយ យើងចិញ្ចឹមជីវិតរស់នៅសព្វថ្ងៃនេះដោយការស្វះស្វែងរកផ្លែឈើបរិភោគ ឯផ្លែឈើនោះសោត មានច្រើនក្តាត់ បរិភោគពុំចេះអស់ឡើយ ។ ព្រាហ្មណ៍អើយ រីមូស សុច ស្រាំង ស្រួយ ខ្មយ ក្អែប ខ្លា រមាំង រមាស ទន្សោង គោព្រៃ ដំរី ពស់តូច ពស់ធំ ច្រឡំនីទៅនូវពស់ដែក ពស់វែក ពស់ថ្វាសទន្សោង ពស់កន្ត្រាងភ្លើង

អាសិរពិសអស់នោះសឹងសាហាវ មានច្រើន តែវាពុំដែលមកពាធាបៀតបៀនយើងឡើយ ៗ ព្រាហ្មណ៍អើយ ប្រការមួយទៀត តាំងអំពីអ្នកស្រីពិរាស្ត្រ គេបំបរបង់យើងមកនៅព្រៃនេះ ជាចំនួន៧ខែហើយ យើងពុំដែលយល់អ្នកឯណាមួយឡើយ ទើបយល់តែចៅព្រាហ្មណ៍ឯងនេះជាប្រថម ៗ ព្រាហ្មណ៍អើយ ថ្ងៃនេះ យើងបានយល់តាជី ត្រេកអរពេញចិត្ត គិតយល់ជាព្រាហ្មណ៍ព្រឹទ្ធ កាន់ឈើច្រត់រំពាត់ឫស្សីសំបុរលឿងទុំដូចជាផ្លែព្នៅ បើដោយគិតទៅ ក៏យល់ជាប្រពៃក្រៃពេក ដូចកល់ភ្ញៀវមកដល់ថ្មី អំពីឋានចម្ងាយ អញ្ជើញតាជីជម្រះកាយញើសក្អែល លាងជើង នាររាងទឹក ចូរតាជីងូតទឹក ឱ្យត្រអាលក្សេមក្សាន្ត ៗ ចៅព្រាហ្មណ៍អើយ ក្រែងចៅឃ្លានបាយ ផ្លែឈើផងទាំងឡាយ ក៏មានច្រើន គឺ ទន្លាប់ក្រខុប សំពារ សំពួយ ស្រេចតែចៅនឹងជ្រើសរើសយកឯណាទុំៗប្រឡាក់ទឹកឃ្មុំ បរិភោគហោង ៗ

វត្វា ច បន មហាសត្តោ អយំ ព្រាហ្មណោ ន អការណេន ឥមំ មហារញ្ញំ អាគមិស្សតិ ព្រះមហាសត្វមានព្រះបន្ទូលម្ល៉ោះហើយ ព្រះអង្គគិតក្នុងព្រះហឫទ័យ ថា ព្រាហ្មណ៍នេះសង្វាតឱហាតលះបង់ស្រុក រុកព្រៃពានភ្នំក្រំថ្ម មកដល់ព្រៃធំនេះប្រយោជន៍អ្វី អញនឹងដណ្តឹងដំណើរអាការនៃព្រាហ្មណ៍នេះ ទើបមានព្រះបន្ទូលជាបាទគាថា ដូច្នេះ

អថ ត្វំ កេន វណ្ណេន កេន វា បន ហេតុនា

អនុប្បត្តោ ព្រហារញ្ញំ តំ មេ អក្ខាហិ បុច្ឆិតោតិ ។

ហៃព្រាហ្មណ៍អើយ អញនឹងដណ្ដឹងប្រស្ដែងហះ នាប្រស្ដែងលះបង់ស្រុករុកព្រៃពានភ្នំក្រំថ្មមកដល់អាយ តើដោយនូវហេតុដូចម្ដេច អញចង់ដឹងប្រស្ដែងណាស់ ចូរប្រស្ដែងថ្លែងប្រាប់ដោយនូវពាក្យពិតត្រង់ ៗ **ជូជកោ អាហ** ជូជកព្រាហ្មណ៍ស្ដាប់ព្រះបន្ទូលហើយ ក្រាបបង្គំទូលជាបាទគាថា ដូច្នេះ

យថា វារិវហោ បូរោ សព្វកាលំ ន ខីយតិ
ឯវន្តំ យាចិតាគច្ឆិំ បុត្តេ មេ ទេហិ យាចិតោតិ ។

បពិត្រព្រះមហារាជឫសីអើយ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គនឹងក្រាបទូលឱ្យសព្វព្រះរាជហឫទ័យ នាខ្ញុំព្រះអង្គនេះ ជាព្រាហ្មណ៍ចាស់ឥតកម្លាំង មិនគប្បីបើនឹងយាត្រាមកកាន់ផ្លូវឆ្ងាយម្ល៉េះទេ តែខ្ញុំព្រះអង្គឮគេថា ព្រះរាជហឫទ័យថ្លៃវិសេសត្រសុំត្រសាយ តែងទ្រង់អំណោយទានដល់ស្មូមយាចកជាប្រក្រតី ឮល្បីជាអស្ចារ្យទូទ័រដល់នគរកលិង្គរាស្ត្រនាយ ព្រះរាជហឫទ័យថ្លៃវិសេស ដែលទ្រង់ព្រះរាជសទ្ធានោះ ពុំមានឆ្អែតឆ្អន់ដល់តិចឡើយ បីដូចអំបូរមេទឹកស្ទឹង៥ សឹងពេញប្រៀបមាត់ច្រាំង ពុំដែលហែងហួតស្ងួតឡើយ ទោះយោបីមនុស្សសព្វសត្វម្រឹគបក្សីផងដងនូវក្អមថ្មនូវភាជន៍ បាចនូវក្បង់ដៃ ដងដាក់ក្រឡពិន្ទុងបាចសាច ឬដូតផឹកយ៉ាងណាក្ដី នឹងស្ងួតជ្រួតជ្រាបដាច់ទឹកយល់ដល់ដីខ្សាច់នោះ ឥតអង្គីមានឡើយ ៗ រីព្រះរាជហឫទ័យប្រពៃ ក៏ពុំមានឆ្អែតឆ្អន់នឹងយាចកនោះ ក៏មាន

គួរនាបីដូច្នោះដែរ ៗ បពិត្រព្រះមហារាជឫសីអើយ ខ្ញុំព្រះអង្គជាព្រាហ្មណ៍ចាស់ឥតកម្លាំង ពឹងតែឈើច្រត់ខំដើររុករានពានភ្នំក្រំថ្ម ប្រទះនឹងមហិង្សា ខ្លា រមាំង រមាស ទន្សោង គោព្រៃ ភិតភ័យ ខំរត់ពីមពពាម រួចមកដល់យល់ព្រះអង្គទ្រង់ធម៌សប្បុរសនេះ ប្រាថ្នាសង្វាតមកសូមព្រះរាជបុត្រទាំងពីរ សូមព្រះមហារាជព្រះរាជទានឱ្យខ្ញុំព្រះអង្គហោង (១) ៗ

តំ សុត្វា មហាសត្តោ សោមនស្សប្បត្តោ ហុត្វា

កាលនោះ ព្រះមហាសត្វ ស្តាប់ពាក្យព្រាហ្មណ៍ហើយ មានព្រះហឫទ័យត្រេកអរមហិមា បីដូចបុរសម្នាក់ ពីតូចដល់ធំ ពុំដែល

១- ត្រង់តាជូជកក្រាបទូលសុំព្រះរាជបុត្រនេះ មានច្បាប់មហាជាតក៏ខ្លះ មានសំនួនវោហារប្លែកគ្នាដូច្នេះ ជូជកក្រាបបង្គំទូលថា បពិត្រអម្ចាស់ថ្លៃព្រះរាជសម្ភារ ខ្ញុំតាជីចាស់ជរា នឹងឧបមាព្រះរាជហឫទ័យរបស់ព្រះអង្គ ថាបីដូចនូវស្ទឹងទាំង ៥ ជាអាទិ មានព្រះគង្គាជាខ្នាត ដ៏ហូរខ្លាញ់ បុរវា ដ៏ពោរពេញប្រៀបច្រាំង ពុំដែលដាច់ឡើយ បពិត្រអម្ចាស់ខ្ញុំអើយ ទោះមនុស្សម្នាមហាជនផង នឹងដងដាក់ក្រឡពិន្ទង ចុះបាចសាចងូតផឹកតាមតែចិត្តនឹកចង់ ៗ ឯស្ទឹងនោះ ពុំដែលនឹងស្រុតស្រក រីងហែងហួតដាច់ស្ងួតសូន្យសោះ ព្រះគង្គានោះ មានគុណនឹងសារពើសត្វទ្វេបាទ ចតុប្បាទផងទាំងឡាយ ថាបើកើតក្តៅក្រហាយហើយ បានងូតផឹករមែងរម្ងាប់សេចក្តីក្តៅក្រហាយ សឹងសុខសប្បាយត្រេកអរសាទរក្នុងចិត្ត មានឧបមាបីដូចព្រះរាជហឫទ័យព្រះអង្គដូច្នោះ សេចក្តីទាំងនេះ ហាក់ដូចខ្ញុំថាល្បើកលើកសរសើរព្រះអង្គ តីមោះ ខ្ញុំតាជីពោលដោយពាក្យពិត

ឆ្លង....

មានមាសដល់បីពែ មានកាលមួយថ្ងៃ មានបុរសម្នាក់យកមាស ១ ពាន់តម្លឹង ច្រកនឹងថង់ផ្ទង់ដាក់នឹងដៃបុរសនោះ ៗ មានចិត្តត្រែកអរ ដូចម្ដេចមិញ ក៏ព្រះអង្គមានព្រះរាជហឫទ័យ ត្រែកអរសាទរ មានឧបមាបី ដូច្នោះហោង ៗ ទើបព្រះអង្គនឹងធ្វើឱ្យកក្រើកអំពើកនូវព្រៃភ្នំវង្កតបព៌តដ៏មហិមា ក៏មានព្រះបន្ទូលនូវបាទព្រះគាថា ដូច្នេះ

ទទាមិ ន វិកម្បាមិ ឥស្សរោ នយ ព្រាហ្មណ
បាតោ គតា រាជបុត្តី សាយំ ឧញ្ឆាតោ ឯហិតិ
ឯករត្តឹ វសិត្វាន បាតោ គច្ឆសិ ព្រាហ្មណ ៗ
តស្សា ន្ហាតេ ឧបឃាតេ អថ នេ មាលធារិនេ

ពុំមុសា ព្រះរាជសទ្ធានិងព្រះកិត្តិយសព្ទល្បីខ្ពង់ខ្ពស់វែងឆ្ងាយ សាយសព្វប្រទេសនានា ៗ ចាប់ដើមអំពីកាលព្រះរាជសម្ភារ ព្រះអង្គចេញចាកបុរី មកសាងព្រះបារមី នាភ្នំនេះហើយ បពិត្រអម្ចាស់អើយ រីអស់ស្ងួមអ្នកកម្សត់ទុគ៌តកំព្រា ហាក់ដូចជាកំបុតជើង-ដៃ នឹងអាស្រ័យអ្នកឯណា ឱ្យបានដូចព្រះរាជសទ្ធាព្រះបរមបពិត្រនេះ ឥតអង្គឹមានឡើយ នាកាលថ្ងៃព្រះអង្គចេញមកហើយនោះ ខ្ញុំតាជី ទៅពុំទាន់ពុំបានទទួលព្រះរាជទានព្រះអង្គឡើយ ព្រះគុណអើយ ឥឡូវ ខ្ញុំតាជីខំសង្វាតឱហាតមកដល់អាយ ពុំគិតកាយចាស់ជរា បើនឹងមរណា សូមស្លាប់ក្រោមព្រះបាទ បពិត្រអម្ចាស់អើយ នឹងលាក់បាំងអ្វី ខ្ញុំតាជីប៉ងមកសូមព្រះរាជទានព្រះរាជកុមារ ទាំងពីរព្រះអង្គ សូមអម្ចាស់ទ្រង់ព្រះមេត្តាព្រះរាជទានមកខ្ញុំតាជី ជាមនុស្សកម្សត់កំព្រានាគ្រាកាលឥឡូវនេះឯងហោង ៗ

ឯករត្តឹ វសិត្វាន បាតោ គច្ឆសិ ព្រាហ្មណ ។
នានាបុប្ផេហិ សញ្ឆន្នេ នានាគន្ធេហិ ភូសិតេ
នានាមូលផលាកិណ្ណេ គច្ឆិស្សាទាយ ព្រាហ្មណាតិ ។

ហៃព្រាហ្មណ៍អើយ រីកូនអញទាំងពីរនេះ អញលើកឱ្យប្រស្ដែងចិត្តអញនឹងមានញាប់ញ័រទៅ ដោយនូវក្ដីកំណាញ់នោះ គ្មានឡើយ អញឱ្យដោយនូវចិត្តសទ្ធាស្មោះ ។ ព្រាហ្មណ៍អើយ អំពីថ្ងៃនេះទៅ ចៅជាឥស្សរកំពូលនៃកូនអញទាំងពីរនេះ តែនាងមទ្រីក្សត្រីប្រសើរ នាងទៅព្រៃពីព្រឹកព្រហាម ពុំទាន់មកដល់ អញចង់ឃាត់ចៅឱ្យនៅខានសម្រាន្តអាយ តែក្នុងរាត្រីនេះសិន រង់ចាំនាងមទ្រីមក នាងនឹងយកទៅផ្ងូតទឹកកក់ជម្រះ ហើយនាងនឹងបេះភ្ញីផ្កាផ្សេងៗ មកក្រងចងបំពាក់ ហើយនឹងយកគន្ធពិដោរផ្សេង ៗ មកលាបស្រឡាបអស់អង្គ ហើយនាងនឹងផ្ដល់ផ្លែឈើ មានរសពីសាផ្សេងៗ ឱ្យក្មេងទាំងពីរបរិភោគ ឱ្យឆ្អែតស្កប់ស្កល់ ព្រាហ្មណ៍អើយ ដល់ព្រហាមឡើង សឹមចៅនាំយកកូនអញទៅហោង ។

ជូជកោ អាហ ជូជកព្រាហ្មណ៍ ស្ដាប់ព្រះបន្ទូលព្រះមហាក្សត្រហើយ ពុំចូលចិត្ត ខ្លាចក្រែងព្រះនាងមទ្រី ពុំទ្រង់ព្រះរាជសទ្ធា ទើបក្រាបបង្គំទូលជាបាទគាថា ដូច្នេះ

ន វាសមភិរោចាមិ គមនំ មយ្ហំបិ រុច្ចតិ
អន្តរាយោបិ មេ អស្ស គច្ឆញ្ញេវ រថេសភ ។
ន ហេតា យាចយោគី នំ អន្តរាយស្ស ការិយា

ឥត្ថិយោ មន្តំ ជានន្តិ សព្វំ គណ្ហន្តិ ថាមតោ ។
សទ្ធាយ ទានំ ទទតោ មា សមទក្ខិ មាតរំ
អន្តរាយំបិ សា កយិរា គច្ឆញ្ញវ រថេសភ ។
អាមន្តយស្សុ តេ បុត្តេ មា តេ មាតរមទ្ទសុំ
សទ្ធាយ ទានំ ទទតោ ឯវំ បុញ្ញំ បវឌ្ឍតិ ។
អាមន្តយស្សុ តេ បុត្តេ មា តេ មាតរមទ្ទសុំ
មាទិសស្ស ធនំ ទត្វា រាជ សគ្គំ គមិស្សសីតិ ។

បពិត្រក្សត្រថ្លៃប្រសើរអើយ ខ្ញុំព្រះអង្គ ពុំចូលចិត្តគិតចង់ខានសម្រាន្តនៅអាយ ដូចព្រះបន្ទូលឡើយ ហើយចាំព្រះនាង នោះយល់ពុំសម ខ្ញុំព្រះអង្គនឹងក្រាបបង្គំលាទៅ ក្នុងកាលឥឡូវនេះឯង ខ្លាចក្រែងសម្ដេចព្រះនាងមទ្រីមានព្រះហឫទ័យពុំចង់ឱ្យទាន ព្រោះធម្មតាស្ត្រីតែងនាំឱ្យអន្តរាយដល់ទានបារមីរបស់បុរស ឥត្ថិយោ ធម្មតាស្ត្រីក្នុងលោកនេះ តែងមានមាយាក្លិកក្លុក គិតតែបំរុងដាក់ទុកក្នុងវដ្តសង្សារ កម្រនឹងត្រអាលលើកយកបុត្រាបុត្រីឱ្យជាទាន ឥឡូវ សូមព្រះអង្គលើកព្រះរាជបុត្រទាំងពីរ ឱ្យជាទានខ្ញុំព្រះអង្គ ដោយនូវព្រះរាជសទ្ធា កុំបីរារង់ឱ្យព្រះរាជកុមារបានយល់ព្រះមាតាឡើយ ថាបើព្រះអង្គទុកឱ្យបានយល់ព្រះមាតាហើយ នឹងធ្វើឱ្យអន្តរាយដល់ទានព្រះអង្គជាពុំខាន ៗ បពិត្រក្សត្រថ្លៃប្រសើរអើយ សូមព្រះអង្គមានព្រះបន្ទូលហៅព្រះរាជបុត្រទាំងពីរ ឱ្យវិលមកឆាប់ ៗ កុំឱ្យទាន់បានយល់សម្ដេចព្រះមាតាឡើយ ។ បពិត្រព្រះរាជឫសី

ប្រសើរអើយ ព្រះអង្គលើកព្រះរាជបុត្រទាំងពីរឱ្យជាទាន ទុកជាទ្រព្យដ៏ប្រសើរ ដល់ខ្ញុំព្រះអង្គនេះ កាលណា ព្រះអង្គសោយព្រះ ព្រះវិលាល័យក្ស័យព្រះជន្មពីជាតិនេះហើយ ព្រះអង្គនឹងទៅសោយសម្បត្តិបិតនៅឰដ៏សួគ៌ទេវលោកនាយនោះទៀងប្រាកដហោង ៗ

ព្រះបាទស្រីវេស្សន្តរបរមពោធិសត្វស្តេចស្តាប់ពាក្យព្រាហ្មណ៍ហើយ មានព្រះបន្ទូលជាបាទគាថា ដូច្នេះ

សចេ ត្វំ និច្ឆសេ ទដ្ឋុំ   មម ភរិយំ បតិព្វតំ
អយ្យកស្សបិ មេ ទេហិ   ជាលី កណ្ហាជិនា ចុភោ ៗ
ឥមេ កុមារេ ទិស្វាន   មញ្ជុកេ បិយភាណិនេ
បីតិតោ សុមនោ ចិត្តោ   ពហុំ ទស្សតិ តេ ធនន្តិ ៗ

ហៃចៅព្រាហ្មណ៍អើយ ទោះយោបីប្រស្តែង មិនចង់ខានសម្រាន្តនៅអាយ ឱ្យកូនទាំងពីរបានយល់នាងមទ្រី ជាស្ត្រីមានវត្តប្រណិប័តន៍ដ៏ប្រសើរជាភរិយានៃអញទេ ត្បិតខ្លាចមានអន្តរាយដល់ចៅ ម្នាលចៅព្រាហ្មណ៍អើយ អញសូមផ្តាំចៅ កុំបីនាំក្មេងទាំងពីរ គឺចៅជាលីនិងនាងក្រស្នា ទៅឯស្រុកកលិង្គរាស្ត្រនោះឡើយ ចូរប្រស្តែងនាំទៅឯជេតុត្តរនគរនាយ ថ្វាយព្រះបាទស្រីសញ្ជ័យជាព្រះអយ្យកោវិញ កាលណាព្រះអង្គ បានទតព្រះនេត្រឃើញកុមារទាំងពីរនេះដែលចេះសំដីពីរោះ ស្រដីមុខគួរឱ្យស្រឡាញ់សមព្រះអង្គនឹងពេញព្រះទ័យនឹងព្រះចៅទាំងពីរពន់ពេក ព្រះអង្គនឹងទ្រង់ព្រះរាជទានទ្រព្យ ឱ្យចៅព្រាហ្មណ៍ឯង ច្រើនជាពន្លឹកមិនខាន ៗ

ជូជកព្រាហ្មណ៍ ស្តាប់ព្រះបន្ទូលព្រះបរមពោធិសត្វហើយ ទើបក្រាបបង្គំទូលតាមសេចក្តីយល់របស់ខ្លួន សូត្រជាបាទគាថាដូច្នេះ

អច្ឆេទនស្ស ភាយាមិ   រាជបុត្ត សុណោហិ មេ
រាជទណ្ឌាយ មំ ទជ្ជា   វិក្កិណេយ្យ ហនេយ្យ វា
ជិន្នោ ធនញ្ច ទាសេ ច   គារយ្ហស្ស ព្រហ្មពន្ធុយាតិ ។

បពិត្រព្រះរាជបុត្រប្រសើរអើយ ខ្ញុំព្រះអង្គខ្លាចក្រែងព្រះបាទស្រីសញ្ជ័យដណ្តើមយកចៅជាលីនាងក្រស្នា របស់ខ្ញុំព្រះអង្គទៅហើយធ្វើទោស ដាក់ព្រះរាជអាជ្ញាលក់ពិន័យ ឬសម្លាប់ខ្ញុំព្រះអង្គចោលបង់ម្យៀត ឯមេអមិត្តតាបនាជាភរិយាសំឡាញ់របស់ខ្ញុំព្រះអង្គ នឹងត្អះតិះដៀលថា ព្រាហ្មណ៍កញ្ចាស់នេះ ពុំចេះដើរទេស ខូចខាតទាំងទ្រព្យធនវិនាស បាត់បង់ទាំងខ្ញុំកំដរ ។

ព្រះរាជឫសីមហាសត្វ ព្រះអង្គត្រាស់និពន្ធជាបាទគាថាដូច្នេះទៀតថា

ឥមេ កុមារេ ទិស្វាន   មញ្ជុកេ បិយភាណិនេ
ធម្មេ ឋិតោ មហារាជា   សិវីនំ រដ្ឋវឌ្ឍនោ
លទ្ធា បីតិសោមនស្សំ   ពហុំ ទស្សតិ តេ ធនន្តិ ។

ម្នាលចៅព្រាហ្មណ៍អើយ សម្តេចព្រះបរមជនកមហារាជបពិត្រស្តេចឋិតនៅក្នុងធម៌ តែងទ្រង់ចម្រុងចម្រើនដល់អ្នកស្រីពិរាស្ត្រ កាលព្រះអង្គបានទតឃើញព្រះរាជកុមារមានសំឡេងពីរោះ ចេះសំដីមុខគួរឱ្យស្នេហាស្រឡាញ់ទាំងពីរនេះហើយ ព្រះអង្គនឹងទ្រង់មានព្រះ

រាជហឫទ័យបីតិ ត្រេកអរសោមនស្ស ជាពន្លឹក មុខជាទ្រង់ព្រះរាជទានទ្រព្យសម្បត្តិដល់ចៅព្រាហ្មណ៍ឯង ជាចំនួនច្រើនពុំខាន ។

ជូកកបានស្តាប់ព្រះបន្ទូលហើយ ក្រាបបង្គំទូលស្នង ជាបាទគាថា ដូច្នេះ ថា

នាហន្តំបិ ករិស្សាមិ យំ មំ ត្វំ អនុសាសសិ
កុមារេច អហំ នេស្សំ ព្រាហ្មណិយា បរិចារិកេតិ ។

បពិត្រព្រះរាជឫសីប្រសើរអើយ ខ្ញុំព្រះអង្គពុំអាចនឹងធ្វើតាមឱវាទដំបូន្មានរបស់ព្រះអង្គបានឡើយ ខ្ញុំព្រះអង្គត្រូវតែនាំព្រះរាជកុមារទាំងពីរទៅឯនគរកលិង្គរាស្ត្រ ឱ្យធ្វើជាខ្ញុំបំរើនាងព្រាហ្មណីជាភរិយានៃខ្ញុំព្រះអង្គហោង ។

តន្តស្ស ផរុសវចនំ សុត្វា កុមារា ភីតា បិដ្ឋិបណ្ណសាលំ គន្ត្វា ព្រះរាជកុមារទាំងពីរ ឮពាក្យព្រាហ្មណ៍ស្រដីរឹងរូសមហិមា ក៏មានព្រះទ័យភិតភ័យខ្លាចពេកពន់ប្រមាណ ទើបបបួលគ្នារលះរលាំងរត់ទៅពួននៅខាងក្រោយបណ្ណសាលា តែនៅពុំសុខ ដូចកល់ជូជកព្រាហ្មណ៍នឹងតាមមកចាប់ ទើបនាំគ្នារត់ចេញពីក្រោយបណ្ណសាលាជាប្រញាប់ ចូលទៅពួននៅក្នុងដង្គំព្រៃស្ងាត់ តែនៅពុំស្រណុកឡើយ ហាក់ដូចជូជកព្រាហ្មណ៍ទៅតាមចាប់ទៀត ព្រះរាជកុមារទាំងពីរ មានអាត្មានោះញាប់ញ័ររន្ធត់ ទើបរត់ពីនោះទៅទៀត លុះរត់ទៅដល់ឆ្នេរស្រះបោក្ខរណី ទើបនាំគ្នាឈរស្លៀកសំពត់អម្ពត់ គិតដ៏អ្នកក្រងនូវស្បូវក្លាំង ឱ្យខ្ជាប់

ស្រេចហើយ ទើបស្តេចដើរថយក្រោយចុះទៅក្នុងស្រះបោក្ខរណីនោះ យកស្លឹកឈូកគ្របពីលើសិរសា បបួលគ្នាសំងំនៅស្ងៀមហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ វីអាថ៌ធម៌ឯណា ពុំទាន់ប្រាកដ បទព្រះគាថាឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលនឹងភិក្ខុផងទាំងឡាយ ដោយបាទព្រះគាថា ដូច្នេះ

តតោ កុមារា ព្យត្ថិតា សុត្វា លុទ្ទស្ស ភាសិតំ
តេន តេន បធាវឹសុ ជាលី កណ្ហាជិនា ឧភោតិ ។

ហៃភិក្ខុផងទាំងឡាយអើយ កាលនោះ ព្រះរាជបុត្រទាំងពីរ គឺចៅជាលីនិងនាងក្រស្នា ឮពាក្យព្រាហ្មណ៍ស្រដីឥតបីករុណាដូច្នោះ ក៏បបួលគ្នារត់ទៅពួនបាត់ស្ងាត់ហើយកូវ ព្រាហ្មណ៍ពុំស្រណុកសុខចិត្តនឹងព្រះបរមពោធិសត្វនោះឡើយ ព្រាហ្មណ៍អត់ទ្រាំពុំបាន ក៏ស្រដីត្លះតិះដៀលព្រះអង្គថា ភោ វេស្សន្តរ បពិត្រព្រះវេស្សន្តរអើយ ដើមឡើយ ឮល្បីល្បាញថា ជាអ្នកមានចិត្តសទ្ធា តែងនឹងប្រាថ្នាសន្សំបន្ថំព្រះបារមី យកព្រះរាជបុត្រាបុត្រីទាំងពីរ ឱ្យជាទានខ្ញុំតាជីហើយ លុះឮថា ខ្ញុំតាជីពុំព្រមនាំព្រះរាជកុមារទាំងពីរ ទៅឯជេតុត្តរនគរ ដូចព្រះបន្ទូល ហើយឮថា ខ្ញុំតាជីនឹងនាំទៅលំនៅខ្ញុំតាជីឯកលិង្គរាស្ត្រ ឱ្យទៅនៅបម្រើនាងអមិត្តតាបនាដូច្នោះកូវ ក៏ខ្វៃប្រែឱ្យកន្ទុយព្រះនេត្រព្រះរាជបុត្រ

ទាំងពីរមិញឱ្យរត់បាត់អស់ទៅ ហើយគង់នៅស្ងៀម ធ្វើជាមិនដឹងវិញ បពិត្រព្រះបាទស្រីវេស្សន្តរអើយ ខ្ញុំតាជីស្រាល់ជ្រើសរើសរកព្រះមហាក្សត្រឯណាមួយនៅនាលោកិយនេះ ចេះស្រដីភូតភរ ស្មើនឹងព្រះអង្គនេះ គ្មានឡើយ ៗ

តំ សុត្វា មហាសត្តោបិ កម្បិតោ ហុត្វា ព្រះមហាក្សត្រ ទ្រង់ព្រះសណ្ដាប់ពាក្យព្រាហ្មណ៍ស្រដីហើយ ព្រះអង្គមានព្រះហឫទ័យពុំស្រណុក កក្រើករន្ធត់អត់ពុំបាន ទ្រង់មានព្រះចិន្ដាថា ឱ! កូនអញទាំងពីរ ច្បាស់ជារត់ទៅពួនអស់ហើយ ទើបព្រះអង្គទ្រង់ប្រលោមលោមព្រាហ្មណ៍វិញថា ហៃព្រាហ្មណ៍អើយ កុំប្រស្ដែងបារម្ភនឹងក្មេងទាំងពីរនេះឡើយ អញនឹងនាំយកមកឱ្យប្រស្ដែងក្នុងកាលឥឡូវនេះឯង ទើបព្រះអង្គចេញទៅឯខាងក្រោយព្រះបរមសាលា ទ្រង់រកមើលពុំឃើញឡើយ ទ្រង់យល់ឃើញតែគន្លងស្នាមព្រះបាទ ទើបព្រះអង្គស្ដេចយាងតាមគន្លងស្នាមព្រះបាទនោះទៅ ដល់ដង្គុំព្រៃស្ងាត់ ទ្រង់ទតឃើញតែគន្លងស្នាមព្រះបាទដើរឡើងមកអំពីស្រះនោះវិញ ទើបព្រះអង្គទ្រង់ព្រះចិន្ដាពិចារណាថា នេះជាគន្លងស្នាមជើងកូនអញ ម្ដេចក៏ឃើញតែស្នាមជើងឡើងមកវិញ តែឥតអង្គីក្ដីអ្វីមាល្បាយ សមកូនអញពួននៅក្នុងទឹកទេដឹង ស្ដេចទ្រង់ជ្រាប ក្នុងព្រះហឫទ័យដូច្នេះហើយ ទើបព្រះអង្គមានបន្ទូលហៅចៅជាលីជាដើម ទ្រង់សូត្រជាបាទគាថាដូច្នេះ

ឯហិ តាត បិយបុត្ត បូរេថ មម បារមី

ហទយំ មេភិសិញ្ចថ ករោថ វចនំ មម
យាននាវាច មេ ហោថ អចលា ភវសាគរេ
ជាតិបារំ តរិស្សាមិ សន្តារេស្សំ សទេវកន្តិ ។

តាត (១) ហៃចៅជាលី ជាបុត្រច្បងពីសីទន្ទកពន្លកស្ងួនឪពុក អើយ មិយបុត្ត បាហោងជាកូនច្បងសំឡាញ់ព្រះជនកសព្វថ្ងៃ ឯហិ ចូរបាដោះឡើងពីទឹកនោះមកកាន់ឪពុក បូរេថ កូនអើយ ចូរបាជួយបំពេញទានបារមីរបស់ឪពុក ឱ្យបានពេញបរិបូណ៌ ក្នុងកាលឥឡូវនេះឯង ៗ កូនអើយ ព្រាហ្មណ៍វាដៀលត្មះឪពុកៗមានចិត្តក្តៅក្រហាយ នៅពុំស្រណុកឡើយ ថាបើ បាដោះឡើងពីទឹកមកកាន់ឪពុកហើយ ស្មើបា យកទឹក ១.០០០ ក្អម ផ្គមស្រោចលើឪពុកឱ្យត្រជាក់សប្បាយចិត្ត កូនអើយ ធម្មតាកូនវែងដោយតាមពាក្យឪពុក កូនអើយ ឪពុកទុកបាសព្វថ្ងៃ ស្មើសំពៅភេត្រាមាស

១- ច្បាប់មហាជាតក៏ខ្លះ មានបរិយាយប្លែកផ្សេងគ្នាបន្តិចដូច្នេះ " តាត ហៃចៅជាលីកូនស្ងួនសំឡាញ់ឪពុក អ្នកវែងលំហើយទុក្ខពុំឱ្យក្តៅ ចៅជាបុត្រកម្សត់រួមជីវិតព្រះបិតាៗ ឈឺខ្លោចផ្សាក្នុងចិត្ត ព្រោះត្បិតតែពាក្យព្រាហ្មណ៍ វាស្រដីផ្ដាល នៅមុខ ថា ឪពុកនេះជាមនុស្សកាចអន្ធពាល បណ្ដាលនូវមុសាវាទស្រដីឱ្យឃ្លៀងឃ្លាតបង់យសសក្តិ ឪពុកអួលអាក់ពេកក្រៃ ដូចនៃអ្នកយកភ្លើងមកបំពក់ ឱ្យឆុរឆេះ ស្មូមយាចកវាស្រដីត្មះតិះដៀលនៅមុខ ឱ្យអាស្រូវក្នុងចិត្ត ឯហិ កូនអើយ ចូរអ្នកឡើងមកជាទិព្វធារា អភិសិញ្ចថ ចូរកូនកម្សត់អ្នកជួយស្រោចស្រង់ ឱ្យត្រជាក់

ឆ្លង...

ធំចិព្កៀង សម្រាប់ចម្លងឆ្លងកាត់សមុទ្រសង្សារ ដាក់ដល់ត្រើយពោលគឺព្រះនិព្វាន ឪពុកនឹងចម្លងអស់ពពួកសត្វនិករ អមរនូវទេព្តាឥន្ទ្រព្រហ្ម មនុស្សសត្វផងទៅដាក់ព្ធដ៏ឋាននិព្វាន ទាំងអស់ហោង ៗ

កុមារោ បិតុ កថំ សុត្វា ចៅជាលី ស្តាប់ព្រះបន្ទូលសម្តេចព្រះវរបិតា ហើយគិតថា ព្រាហ្មណ៍វានឹងធ្វើអញឱ្យបានដូចបំណងចិត្តវាហើយហ: ថាបើ អញឡើងទៅ ដោយនូវពាក្យព្រះជនកអញហើយ រីខ្លួនអញនេះ នឹងលុះនៅក្នុងអំណាចព្រាហ្មណ៍ប្រាកដឯង ថាបើ អញមិនឡើងទៅទេ យល់ល្មើសនឹងព្រះបន្ទូលនៃព្រះវរបិតាពេកណាស់ ទោះយោបីព្រាហ្មណ៍នេះវានឹងសម្លាប់អញក្តី ក៏តាមចិត្តវាចុះ អញនឹងឡើងទៅថ្វាយបង្គំ កុំឱ្យព្រួយព្រះឱស្ឋហៅជាគម្រប់ពីរដងឡើយ សីសំ និហរិត្វា ចៅជាលីគិតម្ល៉ោះហើយ ក៏បើកស្លឹកឈូកអំពីព្រះសិរសា លីលាឡើងអំពី

អស់អង្គរម្ងាប់ក្តៅក្រហាយ ឱ្យបានស្បើយក្នុងកាយព្រះបិតា ៗ ប្រាថ្នាមកនេះ ជាយូរក្តាត់ ត្បិតយល់អស់សព្វសត្វនោះលិចលង់ក្នុងវដ្តសំសារ ៗ រីកាលព្រះពុទ្ធបានត្រាស់មកអំពីមុន ព្រះអង្គទ្រង់នូវព្រះគុណកែវជាយាន នាំសត្វចូលនិព្វានដូចម្តេចមិញព្រះវរបិតានឹងបំពេញឱ្យបានដូច្នោះ ៗ កូនអើយ ចូរអ្នកឡើងមកជាសំពៅមាសប្រកបនូវក្តោងក្តារដាសពាសប្រកិត មានទាំងចង្កូត បោះបង្គួតដរាបក្តារពាសដាសសន្ធប់សព្វកេត្រា មានទាំងខ្សែក្តោង ខ្សែយោងសព្វស្លាបក្តោងក្បាល កណ្តាលកន្សៃ មានទាំងខ្សែពួរយុថ្កា ខ្សែឃាត់របាត់ខារសព្វគ្រប់ហើយនៃ ព្រះវរបិតានឹងស្រាវយុថ្កាស្រាយខ្សែពួរសំពៅ បើកទៅចំពោះទិសព្រះនិព្វាន ៗ

ទឹកស្រះនោះ មកកាន់ព្រះជនក លុតព្រះជង្គង់ឱនព្រះសិរសា ក្រាបលើខ្នងព្រះបាទខាងស្តាំ ទ្រង់ព្រះកន្សែង ព្រះមហាសត្វមានព្រះបន្ទូលដណ្តឹងព្រះរាជបុត្រថា **ភគិនី តេ កុហិន្តិ** ហៃចៅជាលីបុត្រច្បង ចុះនាងក្រឹស្នាប្អូនស្រីបា តើនៅឯណា ចូរបាប្រាប់ឪពុកផង ទើបចៅជាលីងើបឡើងទូលថា **តាត ឥមេ សត្តា នាមភយេ ឧប្បន្នេ អត្តានមេវ រក្ខន្តីតិ** បពិត្រព្រះជនកអើយ ធម្មតាសត្វឯណានីមួយ តែងមានភ័យហើយ សឹងរត់បំពួនរក្សាខ្លួនទីទៃៗ ឥតដឹងដំណឹងដំនួចគ្នាឡើយ ។ ព្រះពោធិសត្វស្តាប់ពាក្យចៅជាលីហើយ ទ្រង់ព្រះចិន្តាពិចារណាថា ឱ! កូនអញទាំងពីរនេះ សមមានកតិកាសញ្ញាប្តេជ្ញានឹងគ្នាហ្ន៎! ទើបព្រះអង្គ មានព្រះបន្ទូលហៅនាងក្រឹស្នា ដោយនូវបាទព្រះគាថា ដូច្នេះ

ឯហិ អម្ម បិយា ធីតា បិយា មេ ទានបារមី
ហទយំ មេភិសិញ្ចេថ ករោថ វចនំ មម ។
យាននាវាច មេ ហោថ អចលា ភវសាគរេ
ជាតិបារំ តរិស្សាមិ ឧទ្ធរិស្សំ សទេវកន្តិ ។

អម្ម ហៃនាងក្រឹស្នាពុំងាឪពុកអើយ **បិយា ធីតា** នាងហោង ជាកូនពៅសំឡាញ់អស់ពីចិត្តឪពុក **ឯហិ** ចូរនាងដោះឡើង មកកាន់ឪពុកវ៉ា **បិយា មេ ទានបារមី** ត្រង់ហៅថាទានបារមីនោះ ជាទីស្រឡាញ់ពេញចិត្តរបស់ឪពុកពេក ។ ហៃក្រឹស្នាកូនស្រីពុំងាឪពុកអើយ នាងពុំទាន់ដឹង ជាព្រាហ្មណ៍នេះ

វាត្អះតិះដៀលឪពុក ៗ មានហឫទ័យក្តៅផ្សាមហិមា ថាបើនាងឡើងមកកាន់ឪពុកហើយ ស្នើនាងយកទឹកមួយពាន់ក្អម ថ្នមមកស្រោចស្រង់ហឫទ័យនៃឪពុកឱ្យត្រជាក់ ៗ ក្រស្នាអើយ ធម្មតាជាកូនវែងដោយតាមពាក្យឪពុក នាងឯងស្នើសំពៅមាស ធំចិំព្ងាង ឥតក្រែងកណ្តាល ប្រវាលសមុទ្រសង្សារ ជ្រៅកន្លងសម្រាប់ចម្លងដាក់ដល់ត្រើយ ពោលគឺព្រះនិព្វាន ឪពុកនេះ នឹងចម្លងអស់សត្វនិករអមរ នូវទេវតាឥន្ទ្រព្រហ្ម បន្សំប្រមូលទៅឰដ៏និព្វាន អស់ហោង ៗ

សវាបិ បិតុខចនំ សុត្វា នាងក្រស្នាស្តាប់ព្រះបន្ទូលហើយរំពឹងជញ្ជឹងគិតតែក្នុងហឫទ័យថា បងជាលីជាប្រុស ម្តេចក៏មិនរឹងទទឹងនឹងព្រះរាជឱង្ការ ចុះអញជាស្រីហើយជាប្អូនផង ម្តេចឡើយក៏របឹងរឹងរូស ឱ្យព្រះជនកត្រាស់ហៅ ជាគម្រប់ពីរព្រះឱសទោះយោបីព្រាហ្មណ៍នេះវាសម្លាប់អញក្តី ក៏តាមទំនើងចិត្តវាចុះអញនឹងឡើងទៅថ្វាយបង្គំព្រះជនកអញឥឡូវនេះ ៗ ទើបនាងក្រស្នាដោះឡើងពីទឹក មកក្រាបលើខ្នងព្រះបាទខាងឆ្វេង ទ្រង់ព្រះកន្សែង ដ៏មានទឹកព្រះនេត្រហូរសស្រាក់ធ្លាក់ទៅលើខ្នងព្រះបាទាស្អាតល្អ បីដូចទឹកថ្លាធ្លាក់ទៅលើស្លឹកឈូក ៗ រីព្រះបរមពោធិសត្វសោត ទប់ទល់ទឹកព្រះនេត្រពុំបាន ក៏ទ្រង់ព្រះកន្សែងសោយសោកនឹងព្រះរាជបុត្រទាំងពីរនោះ មហិមាក្រៃពេក ទោះបីទ្រង់មានព្រះហឫទ័យអាសូរព្រះរាជបុត្រទាំងពីរដល់ម្លោះក្តី រីត្រង់ព្រះទ័យ នឹង

កង្កួញរួញរាមិនចង់ឱ្យទាននោះ គ្មានឡើយ ព្រះអង្គយកព្រះហស្ត ដ៏ទន់ល្វន់នោះ បបោសអង្អែលព្រះបិដ្ឋិនៃព្រះរាជកុមារ ទាំងពីរនោះ ឱ្យងោះឡើងហើយ ព្រះអង្គលួងលោមថា **តាត ជាលិ កឹ ត្វំ មម ទានចិត្តភាវំ ន ជានាសិ** ហៃបាជាលី កូនស្ងួនសំឡាញ់ឪពុកអើយ បាមិនទាន់ដឹងទេឬ អំពីចិត្តគំនិតឪពុកតរៀងមក តែយល់ស្ងួមហើយ តែងតែចង់ឱ្យទាននោះ សឹងបាបានដឹងហើយ ជាលីកូនអើយ ចូរបាជួយផ្ដល់អធ្យាស្រ័យរបស់ឪពុកឱ្យលុះត្រាតែបានសម្រេចបរិបូណ៌ **គោវណោ អត្ថាវបេន្តោ ចិយ** ព្រះអង្គមានព្រះបន្ទូលដូច្នោះហើយ ទើបព្រះអង្គកាត់ថ្លៃព្រះរាជកុមារទាំងពីរ នាឋាននោះ ដូចឈ្មួញគោកាត់ថ្លៃគោ នាកណ្ដាលផ្សារ ទើបព្រះអង្គ មានព្រះបន្ទូលនឹងចៅជាលី ថា **តាត ជាលិ ភុជិស្សោ ហោតុ ភវមេវ** ហៃចៅជាលី បុត្រច្បងពីសីឪពុកអើយ នាខ្លួនបានេះ ឪពុកឱ្យបាជាខ្ញុំព្រាហ្មណ៍ហើយ ទោះបើបានឹងចង់ឱ្យខ្លួនបាបានរួចពីខ្ញុំព្រាហ្មណ៍នេះ **ព្រាហ្មណស្ស និក្ខសហស្សំ ទត្វា** ចូរបាយកមាសមួយពាន់តម្លឹង មកឱ្យព្រាហ្មណ៍នេះ ហើយបានឹងបានរួចចេញជាអ្នកជា ៗ មួយសោត ជាលីអើយ នានាងក្រស្នាជាប្អូនស្រីពុំងាតូចនេះ កបនូវលក្ខណាឆាយាល្អ មកកើតនាត្រកូលអម្បូរថ្លៃ កូនអើយ ឪពុកក្រែងអ្នកឥតអម្បូរពូជពង្សទុជ៌ន មានតែទ្រព្យយកមកចាក់ដាក់ ឱ្យព្រាហ្មណ៍យកទៅតាមចិត្ត ប្រាថ្នាធ្វើជាភរិយា សេពសម្ព័ន្ធនឹងត្រកូល

ជាន់ទាប សន្តានជាមហាក្សត្រ នឹងបាត់បង់ច្រឡំទៅជារាស្ត្រ ៗ នេះហោង ជាលីកូនអើយ ឪពុកនឹងកាត់ថ្លៃនាងក្រស្នាប្អូនស្រី នៃបានេះ ដោយនូវទ្រព្យដ៏មានតម្លៃ ឱ្យលើសលន់ ពន់ប្រមាណ ច្រើនក្រៃ កុំបីឱ្យអ្នកដទៃហីនជាតិប្រមាថបាន ជាលីកូនអើយ រី អស់ប្រជានុរាស្ត្រទាសផងទាំងឡាយឯណា នឹងមានទ្រព្យ ដល់ម្ល៉ោះ វៀរលែងតែព្រះមហាក្សត្រាធិរាជ ទើបអាចមានបាន ហេតុនេះ ជាលីអើយ បើបានឹងចង់ឱ្យនាងក្រស្នាប្អូនស្រីបា រួចចេញពីខ្ញុំព្រាហ្មណ៍នេះ បានជាអ្នកជា ចូរបាឱ្យមាស ១ ពាន់តម្លឹង និងខ្ញុំប្រុស ខ្ញុំស្រី ដំរី ពាជី គោឧសភរាជ អស់ទ្រព្យផងនីមួយ ៗ សឹងជារយៗ មួយមុខ ៗ ឱ្យទៅដៃព្រាហ្មណ៍នេះ ទើបនាងក្រស្នាប្អូនស្រីបារួចចេញ ជាអ្នកជាហោង ៗ

ឯចំ កុមារេ អគ្ឃាបេត្វា ព្រះបរមពោធិសត្វកាត់ថ្លៃព្រះរាជកុមារទាំងពីរ យ៉ាងនេះហើយ ទើបទ្រង់ប្រលោមលួងលោម នាំទៅកាន់អាស្រមបទ ហើយទ្រង់ឈោងព្រះហស្ត ចាប់យកគន្ទីទឹកមក ទើបមានព្រះបន្ទូលហៅព្រាហ្មណ៍ ថា ឯហិ ភោ ព្រាហ្មណ ហៃព្រាហ្មណ៍អើយ ចូរប្រស្តែងមកអាយរ៉ា ៗ កាលនោះ ជូជកព្រាហ្មណ៍ ឮព្រះបន្ទូលព្រះពោធិសត្វហើយ ក៏ដើរទន្ទបលលបចូលទៅជិតព្រះអង្គ ហើយថ្វាយបង្គំប្រណម្យ ទើបព្រះមហាសត្វទ្រង់តាំងព្រះហឫទ័យប្រាថ្នាព្រះសព្វញ្ញាតញ្ញាណ ហើយទ្រង់យកទឹកគន្ទីស្រោចទៅលើដៃព្រាហ្មណ៍ មានព្រះបន្ទូល ថា

ព្រាហ្មណ៍អើយ ជាលីក្រស្ណាជាកូនសំឡាញ់យើងពិត ថាបើនឹងប្រៀបផ្ទឹមនឹងជីវិតនោះ យល់ជាស្មើបាន តែយើងស្រឡាញ់សព្វញ្ញុតញ្ញាណក្រៃលែងជាងព្រះរាជបុត្រទាំងពីរ ទាំងម៉ឺន ទាំងសែនគុណ ហើយព្រះអង្គយកព្រះរាជបុត្រទាំងពីរ ព្រះរាជទាន ឱ្យទៅជាទានព្រាហ្មណ៍ៗ ក្សិណនោះ ក្រឡាមហាប្រឹថពី កម្រើកអំពើក ឯព្រះឥន្ទ្រាធិរាជ និងអស់ពពួកទេវតា មហាព្រហ្ម ក៏បន្លឺនូវសព្ទអនុមោទនាថា សាធុ! សាធុ! ថា ឱ! ព្រះវេស្សន្តរអើយ ព្រះអង្គនឹងបានត្រាស់ជាព្រះពុទ្ធ ទៀងប្រាកដហោង ៗ

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណា ពុំទាន់ប្រាកដ បទព្រះបាលីឯណា ពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គបន្ទូលសូត្រសានូវបាទព្រះគាថា ដូច្នេះ

តតោ កុមារេ អាទាយ ជាលី កណ្ហាជិនា ឧភោ
ព្រាហ្មណស្ស អទា ទានំ សិវីនំ រដ្ឋវឌ្ឍនោ ។
តតោ កុមារេ អាទាយ ជាលី កណ្ហាជិនា ឧភោ
ព្រាហ្មណស្ស អទា ចិត្តោ បុត្តកេ ទានមុត្តមំ ។
តទាសិ យំ ភឹសនកំ តទាសិ លោមហំសនំ
យំ កុមារេ បទិន្នម្ហិ មេទនី សមកម្បថ ។
តទាសិ យំ ភឹសនកំ តទាសិ លោមហំសនំ
យំ បញ្ជលិកតោ រាជា កុមារេ សុខវច្ឆិតេ
ព្រាហ្មណស្ស អទា ទានំ សិវីនំ រដ្ឋវឌ្ឍនោតិ ។

ហៃភិក្ខុអើយ នាកាលតថាគតនៅជាព្រះវេស្សន្តរបវរពោធិសត្វ ជាស្តេចធំ តែងចម្រើនអ្នកស្រុកស្រីពិរាស្ត្រ ទ្រង់យកព្រះរាជកុមារទាំងពីរ គឺចៅជាលីនិងនាងក្រស្នា ព្រះរាជទានដល់ព្រាហ្មណ៍ចាស់ជរា ក្នុងគ្រាកាលនោះ ក៏កើតជាអស្ចារ្យមហិមា ក្រឡាមហាប្រឹថពីកម្រើកកក្រើករញ្ជួយញាប់ញ័រ រីភ្នំព្រះសិនេរុរាជ ក៏សឹងឱនលំទោនកាន់ភ្នំគិរីវង្កត់បព៌ត រីព្រះឥន្ទ្រាធិរាជ ដ៏មានអំណាច ជាឥស្សរកំពូលនៃទេវតាទាំងឡាយ ក៏ទះព្រះហស្តទ្រង់ព្រះសម្រួល រីអស់ទេវតានិងមហាព្រហ្ម ក៏ពោលពាក្យ ថ្វាយសព្ទសាធុការ ដ៏អធិកពន្លឹកមហិមា នៅនាព្រៃហេមពាន្ត សឹងមានរាជសីហ៍ជាដើម ក៏សឹងស្រែកទ្រហឹងអឺងអាប់នូវសព្ទពន្លឹកក្រៃពេក ។

មហាសត្តោ ទានំ ទត្វា កាលព្រះបាទស្រីវេស្សន្តរ បរមពោធិសត្វទ្រង់ព្រះរាជទានព្រះរាជឱរសទាំងពីរ ទៅព្រាហ្មណ៍នោះហើយ ទ្រង់មានព្រះបីតិសោមនស្ស ថា ទ្រង់បានឱ្យទានជាអស្ចារ្យណាស់ ហើយស្តេចបិតទតរមិលមើលព្រះរាជកុមារ ទាំងពីរក្នុងកាលណោះហោង ។

ជូជកោបិ វនគុម្ពំ បវិសិត្វា វល្លឹ ទន្តេហិ ឆិន្ទិត្វា អាទាយ កាលនោះ ជូជកព្រាហ្មណ៍ បានព្រះរាជកុមារទាំងពីរ មកនៅក្នុងកណ្តាប់ដៃហើយកូវ ក៏ម្ពីម្ពារលះរលាំងចូលទៅក្នុងដង្គុំព្រៃ ដៃប្រវាបោចវល្លិមកខាំកាត់នឹងធ្មេញបានហើយ ប្រវាចាប់ដៃឆ្វេងនាងក្រស្នា ប្រវាចាប់ដៃស្តាំចៅជាលី បានហើយរួបក្តួបចង

ជាមួយគ្នា ហើយបណ្ដើរទៅ យកចុងវល្លិវាយដំ នៅចំពោះព្រះភក្ត្រព្រះបាទស្រីវេស្សន្តរបរវរពោធិសត្វនោះឯងហោង ៗ

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណា ពុំទាន់ប្រាកដ បទព្រះបាលីឯណា ពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានបន្ទូលនូវបាទព្រះគាថា ដូច្នេះ

តតោ សោ ព្រាហ្មណោ លុទ្ទោ   លតំ ទន្តេហិ ឆិន្ទិយ
លតាយ ហត្ថេ ពន្ធិត្វា   លតាយ អនុមជ្ជថ ៗ
តតោ រជ្ជុមាទាយ   ទណ្ឌមាទាយ ព្រាហ្មណោ
អាកោដយន្តោ តេ នេតិ   សិវិរាជស្ស បេក្ខតោតិ ៗ

រីជូជកព្រាហ្មណ៍ វាយដំព្រះរាជកុមារទាំងពីរមានសរីរៈបែកពុរពងរងឈាម ក្រហមច្រាល នៅចំពោះព្រះភក្ត្រព្រះបាទស្រីវេស្សន្តរ ៗ កាលណាតាព្រាហ្មណ៍វាយនាងក្រស្នា ចៅជាលីយកខ្នងទៅរងតាង កាលបើវាយចៅជាលី នាងក្រស្នា ក៏យកខ្នងទៅរងតាង តាជូជកចាប់អូសទាញកន្ត្រាក់នឹងខ្សែវល្លិ៍ ទៅដល់ឋានមួយពុំរាប តាព្រាហ្មណ៍ដួលស្រប៉ាប ខំប្រឹងស្ទុះក្រោកឡើងម្នីម្នា រីព្រះហស្តព្រះរាជកុមារទាំងពីរ ដែលចងនឹងវល្លិ ក៏របូតចេញទៅ ទើបព្រះរាជកុមារទាំងពីរ បបួលគ្នាម្នីម្នា រត់ទៅកាន់សម្នាក់ព្រះបរមពោធិសត្វ ថ្វាយបង្គំប្រណម្យ ហើយទ្រង់ព្រះកន្សែងសោកា ៗ

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណា

ពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ ហើយ ព្រះអង្គមានព្រះបន្ទូល ជាបាទព្រះគាថា ដូច្នេះ

តតោ កុមារោ បក្កាមុំ   ព្រាហ្មណស្ស បមុញ្ចិយ
អស្សុបុណ្ណេហិ នេត្តេហិ   បិតរំ សោ ឧទិក្ខតិ ។
វេធមស្សត្ថបត្តំវ   បិតុ បាទាភិវន្ទតិ
បិតុ បាទានិ វន្ទិត្វា   ឥទំ វចនមព្រវិ ។
អម្មា ច តាត និក្ខន្តា   ត្វញ្ច នោ តាត ទស្សសិ
យាវ អម្មំបិ បស្សេមុ   អថ នោ តាត ទស្សសិ ។
អម្មា ច តាត និក្ខន្តា   ត្វញ្ច នោ តាត ទស្សសិ
មា នោ ត្វំ តាត អទទា   យាវ អម្មាបិ ឯតិ នោ ។
តទាយំ ព្រាហ្មណោ កាមំ   វិក្កីណាតុ ហនាតុ វា
ពលង្កបាទោ អន្ធនខោ   អថោ ឱពទ្ធបិណ្ឌិកោ
ទីឃោត្តរោដ្ឋោ ចបលោ   កឡារោ ភគ្គនាសកោ ។
កុម្ភោទរោ ភគ្គបិដ្ឋិ   អថោ វិសមចក្ខុកោ
លោហមស្សុ ហរិតកេសោ   វលីនំ តិលកាហតោ ។
បិង្គលោ ច វិនតោ ច   វិកដោ ច ព្រហា ខរោ
អជិនានិបិ សន្នទ្ធោ   អមនុស្សោ ភយានកោ ។
មនុស្សោ ឧទាហុ យក្ខោ   មំសលោហិតភោជនោ
គាមា អរញ្ញំ អាគម្ម   ធនំ តំ តាត យាចតិ ។
នីយមានា បិសាចេន   កិន្នុ តាត ឧទិក្ខសិ
អស្មា នូន តេ ហទយំ   អយសា ទឡ្ហពន្ធនំ ។

យោ នោ ពន្ធេ ន ជានាសិ ព្រាហ្មណេន ធនេសិនា
អច្ចាយិកេន លុទ្ទេន យោ នោ គាវោវ សុម្ភតិ ។
ឥធេវ អច្ឆតំ កណ្ហា ន សា ជានាតិ កិស្មិញ្ចិ
មិគីវ ខីរសម្មត្តា យូថា ហីនាវ កន្ទតីតិ ។

ភិក្ខុអើយ លំដាប់នោះ ព្រះរាជកុមារទាំងពីរ ផុតរបូតពីកណ្ដាប់ដៃព្រាហ្មណ៍ ក៏នាំគ្នាមីម្ការត់មកក្រាប ក្រោមព្រះបាទានៃសម្ដេចព្រះវរបិតា មានទឹកព្រះនេត្រាហៀរហូរសស្រាក់ញាប់ញ័រចិប្រប់អស់អង្គប្រាណ ចៅជាលីសម្លឹងមើលព្រះវរបិតាហើយខំស្រដីថា បពិត្រព្រះវរបិតាអើយ សូមទានអម្ចាស់ករុណាយើងខ្ញុំបន្តិចសិនវ៉ា ទម្រាំព្រះមែនៃយើងខ្ញុំអ្នកត្រឡប់មកអំពីព្រៃ ដល់ថ្ងៃល្ងាចនឹងស្ដេចមកដល់ហើយ សូមអម្ចាស់លួងលោមព្រាហ្មណ៍ឱ្យបង្អង់បន្តិចសិន សឹមអម្ចាស់ឱ្យដំណើរយើងខ្ញុំទៅនឹងព្រាហ្មណ៍ បពិត្រព្រះវរបិតា កាលណាយើងខ្ញុំទាំងពីរ បានក្រាបលា ផ្ដាំផ្ញើអ្នកមេយើងខ្ញុំ នូវព្រះបាទអម្ចាស់រួចស្រេចហើយ សឹមយើងខ្ញុំដើរទៅតាមព្រាហ្មណ៍ ដើម្បីបំពេញព្រះបារមីទានអម្ចាស់ ឱ្យបានត្រាស់ជាព្រះពុទ្ធ ប្រាកដហោង ។ បពិត្រព្រះវរបិតា រីព្រាហ្មណ៍នេះ វាអាក្រក់ក្រៃលែងព្រាហ្មណ៍ទាំងឡាយ វាប្រកបដោយបុរិសទោស ១៨ ប្រការ អកុសលកម្មនាំមកបង្កើតនៅនាលោកិយនេះ ពលង្កបាទោ នឹងគន់រមិលមើលទៅបាទជើងនោះ ធំស្ទក់ដំបារកោងក្ងក់ អន្ធនខោ ដ៏មានក្រចកម្រាមទាំង ១០ នោះ ខ្មៅ

ស្អុយគ្រប់ទាំងអស់ **ឱពទ្ធបិណ្ឌិកោ** មានកំភួនជើងប្រកបដោយសាច់ដុំរយេងរយោង ដូចផ្លែននោងទុំ **ទីឃុត្តរោដ្ឋោ** ពពីរមាត់លើយុរយារគ្របពពីរមាត់ក្រោម **ចបលោ** កាលណាហាមាត់ស្រដីមានទឹកមាត់នោះហូរស្រស្រាក់ជោកថ្ពាល់ទាំងសងខាង **កឡារោ** មានចង្កូមសស្វាច ដុះចេញពីមាត់ ដូចជាខ្នាយជ្រូក **ភគ្គនាសកោ** ច្រមុះនោះបាក់ គន្លាក់ពុំស្មើ **កុម្ភោទរោ** ពោះធំកំប៉ោងកំប៉ោកៗប៉ុនក្អម **ភគ្គបិដ្ឋិ** មានខ្នងបាក់ កោងក្ងក់ **វិសមចក្ខុកោ** ភ្នែកស្រលៀងស្រឡៀវ ខ្ពស់ម្ខាងទាបម្ខាង មិនស្មើគ្នា **លោហមស្សុ** មានពុកចង្កាស្រមូវ រឹងដូចល្អសទង់ដែង **ហរិតកេសោ** រីសក់នោះច្រាលច្រាញ់ រមួលកង្កួញរួញលឿង មុខគួរខ្ពើម **វលីនំ** **តិលកាហតោ** តាមរាងកាយ មានសរសៃឡើងរវើមរវាម ហើយមានអាចម៍រុយ និងប្រជ្រុយពេញសព្វខ្លួន **បិង្គលោ** មានកែវភ្នែកលឿងដូចភ្នែកឆ្មា **វិនតោ** មានដងខ្លួនវៀចក្ងក់ ត្រង់កត្រង់ខ្នងនិងចង្កេះដូចជាគេធ្វើលេង **វិកដោ** ជើងទាំងពីរ ក៏កន្ធែកញែកចេញពីគ្នាខុសធម្មតា **ព្រហា ខរោ** រោមតាមសព្វខ្លួន រឹងដូចរោមជ្រូក ខុសពីវិស័យមនុស្សធម្មតា ស្លៀកពាក់ស្បែកខ្លា មិនមែនមនុស្សមុខគួរស្នែង ជាមនុស្ស ឬជាយក្ស ដែលស៊ីតែសាច់ឈាមទេ ក៏ពុំដឹង **គាមា អរញ្ញំ អាគម្ម** ចេញអំពីស្រុកមកកាន់ព្រៃនេះ មានបំណង ប៉ងចូលមកសុំទ្រព្យសម្បត្តិនឹងព្រះវរបិតា កាលព្រាហ្មណ៍បិសាចនាំយកកូន

ទៅ វាវាយដំឥតប្រណី ម្ដេចឡើយអម្ចាស់នៅស្ងៀមព្រងើយ ពុំនាំពាព្រះហឫទ័យ ហាក់ដូចជាដុំថ្មសិលា ឬហាក់ដូចគេចងរឹតដោយដែកយ៉ាងខ្ជាប់ខ្ជួន ឱ! ព្រះវរបិតាអើយ ព្រះអង្គឥតព្រះទ័យអាសូរករុណាដល់កូនបន្តិចឡើយ តាព្រាហ្មណ៍មានចិត្តកាចឃោរឃៅ ចង់បានតែទ្រព្យ ចាប់យកទៅវាយដំប្អូនក្រស្នា ឥតមេត្តាសោះឡើយ មានគួរនាដូចនាយគោបាល វាយប្រហារហ្វូងគោ ដោយឥតមានចិត្តអាណិតអាសូរ ឱ! ក្រស្នាមាសបងអើយ យើងទាំងពីរនាក់នេះ បីដូចកូនម្រឹគដែលនៅកំពុងបៅដោះមេ ហើយព្រាត់ប្រាសនិរាសចាកមេទៅ កាលបើរកមេមិនឃើញ ក៏ស្រែកយំរកមេក្នុងព្រៃព្រឹក្សា ប្រាថ្នាតែនឹងបៅដោះមេវាប៉ុណ្ណោះ ៗ ព្រះគុណអើយ កូនទាំងគូនេះ កម្សត់មកច្រើនគ្រាហើយ ពុំមានញាតិវង្សាឯណាដល់មួយឡើយ អម្ចាស់ខ្ញុំអើយ យល់តែមាតាបិតាមកគង់ក្នុងព្រឹក្សាជាសន្តោស បើពុំទ្រង់ព្រះមេត្តាប្រោសប្រណី ខ្ញុំជាលីក្រស្នាពុំដឹងបើអាស្រ័យនឹងអ្នកឯណាឱ្យក្រៃលែងលើសព្រះអង្គនេះឡើយ ៗ

កាលព្រះជាលីកុមារ ក្រាបបង្គំទូលព្រះវរបិតាយ៉ាងនេះហើយ ព្រះបាទស្រីវេស្សន្តរបវររាជឫសី ក៏ទ្រង់គង់នៅស្ងៀមមិនបានមានព្រះបន្ទូលដូចម្ដេចឡើយ ៗ ព្រះរាជកុមារទាំងពីរ ក៏សោយសោកកន្ទក់កន្ទេញយ៉ាងមហិមា ទ្រង់ព្រះកន្សែងពិលាបក្រាបទូល ដោយបាទព្រះគាថាតទៅទៀត ថា

ន មេ ឥទំ តថា ទុក្ខំ   លព្ភា ហិ បុមុនា ឥទំ
យញ្ច អម្មំ ន បស្សាមិ   តំ មេ ទុក្ខតរំ ឥតោ ។
ន មេ ឥទំ តថា ទុក្ខំ   លព្ភា ហិ បុមុនា ឥទំ
យញ្ច តាតំ ន បស្សាមិ   តំ មេ ទុក្ខតរំ ឥតោ ។
សា នូន កបណា អម្មា   ចិរំ រត្តាយ រុច្ឆិតិ
កណ្ហាជិនំ អបស្សន្តី   កុមារី ចារុទស្សនី ។
សោ នូន កបណោ តាតោ   ចិរំ រត្តាយ រុច្ឆិតិ
កណ្ហាជិនំ អបស្សន្តោ   កុមារី ចារុទស្សនី ។
សា នូន កបណា អម្មា   ចិរំ រុច្ឆិតិ អស្សមេ
កណ្ហាជិនំ អបស្សន្តី   កុមារី ចារុទស្សនី ។
សោ នូន កបណោ តាតោ   ចិរំ រុច្ឆិតិ អស្សមេ
កណ្ហាជិនំ អបស្សន្តោ   កុមារី ចារុទស្សនី ។
សា នូន កបណា អម្មា   ចិរំ រត្តាយ រុច្ឆិតិ
អឌ្ឍរត្តេ វ រត្តេ វា   នទីវ អវសុស្សតិ ។
សោ នូន កបណោ តាតោ   ចិរំ រត្តាយ រុច្ឆិតិ
អឌ្ឍរត្តេ វ រត្តេ វា   នទីវ អវសុស្សតិ ។
ឥមេ តេ ជម្ពុកា រុក្ខា   វេទិសា សិន្ទុវារិតា
វិវិធានិ រុក្ខជាតានិ   តានិ អជ្ជ ជហាមសេ ។
អស្សត្ថា បនសា ចេមេ   និគ្រោធា ច កបិដ្ឋនា
វិវិធានិ ផលជាតានិ   តានិ អជ្ជ ជហាមសេ ។
ឥមេ តិដ្ឋន្តិ អារាមា   អយំ សីតូទកា នទី

យត្តស្សុ បុព្វេ កីឡាម តានិ អជ្ជ ជហាម្ហសេ ។
វិវិធានិ បុប្ផជាតានិ អស្មឹ ឧបរិ បព្វតេ
យានស្សុ បុព្វេ ធារេម តានិ អជ្ជ ជហាម្ហសេ ។
វិវិធានិ ផលជាតានិ អស្មឹ ឧបរិ បព្វតេ
យានស្សុ បុព្វេ ភុញ្ជាម(១) តានិ អជ្ជ ជហាម្ហសេ ។
ឥមេ នោ ហត្ថិកា អស្សា ពលិពទ្ទា ច នោ ឥមេ
យេហិស្សុ បុព្វេ កីឡាម តានិ អជ្ជ ជហាម្ហសេតិ ។

រីព្រះរាជកុមារីព្រះរាជកុមារា កាលអ្នកថ្វាបង្គំលាទៅ អ្នកសៅសោករអាក់រអួលតានតឹងក្នុងឧរាទាំងបងទាំងប្អូន ព្រះវរបិតា ពុំមានព្រះបន្ទូលស្តងព្រះរាជបុត្រសោះឡើយ ទ្រង់ព្រះចិន្តាតែក្នុងព្រះរាជហឫទ័យ ឱ្យបានសម្រេចដូចក្តីប្រាថ្នា ៗ ឯចៅជាលី ក៏បន្ទូលទៅនឹងនាងក្រស្នាថា ឱ! ក្រស្នាប្អូនអើយ ព្រះវរបិតាអ្នកយកយើង ឱ្យទៅជាទានព្រាហ្មណ៍ ម្ល៉េះហើយ សមយើងនឹងបានសេចក្តីលំបាកវេទនា យើងនឹងចេញចាកទៅជាមួយនឹងព្រាហ្មណ៍ព្រឹទ្ធាចារ្យ គាត់នឹងវាយដំបែកហូរឈាម សព្វផ្លូវ ក្រស្នាប្អូនអើយ ធម្មតាសត្វនៅក្នុងលោកិយ សឹងតែជំពាក់នឹងក្តីវដ្តសង្សារ ពុំទាន់បានលុះព្រះពោធិញ្ញាណ គឺព្រះនិព្វាន ជាបរមសុខ កាលណា តែងមានរោគាព្យាធិភ័យ តាមមកទាន់អាត្មាពុំដែលរដោះ ទើបយើងត្រូវឃ្នាងខ្នោះ ច្រវាក់អន្ទាក់ ណែងណង

១- ខាទាមាតិ យុត្តតរំ ។

ចងវាយ ក៏ពុំដែលចៀសវាងបាន មានឧបមាបីដូចប្រាណយើងទាំងពីរនេះឯងហើយ ៗ ឱ! ក្រស្នាមាសបងអើយ នេះជាប្រពៃណីសព្វសព្វផង បងនេះបារម្ភ ត្បិតចាកព្រះមាតា ស្ដេចមកអំពីព្រឹក្សាដល់ព្រះអាស្រមសូន្យឈឹងជ្រងំស្ងប់ស្ងាត់ តែម្នាក់ឯង ហើយអ្នកនឹងទ្រង់ព្រះកន្សែងសោយសោកា អ្នកនឹងទួញយំ រកយើងទាំងពីរតាមដោយស្រះស្រង់ សព្វម្លប់ឈើព្រៃ បើពុំឃើញយើងទាំងពីរហើយនៃ ឱ! ក្រស្នាមាសបងអើយ សមអ្នកនឹងសោយសោកាសល់សែនអាមោក្ខពន់ប្រមាណ ននៀលប្រះប្រាណ ទួញយំ យកព្រះករដំព្រះឧរា សោកស្ដាយយើងជាកូនកម្សត់ទាំងគូមកនៅក្នុងព្រៃ អ្នកមកអំពីព្រៃ ធ្លាប់បានយល់មុខយើងទាំងពីរ អ្នកត្រេកអរក្នុងព្រះទ័យបីថ្នមអាល័យ ហើយព្រះមេអ្នកឱ្យអស់ផលាសារពើដំឡូង ត្រាវ ចេក អំពៅ បង្គៅ សិរមាន់ ចាន់ ម័ក់ប៉ែន គូលែនលាំងសាត គ្រប់សព្វពណ៌ផលា ហើយអ្នកនាំយើង ចូលអាស្រមលំនៅ ហើយអ្នកបំបៅផ្លូតទឹកដុសអស់អង្គ អ្នកយករមៀតផង់មកផាត់បំព្រង ទើបឱ្យយើងប្អូននឹងបងឆីផលាផល សឹងដ៏មានរសពីសា តាមដោយនូវអាហារព្រៃភ្នំ លុះកាលវេលាល្ងាច នឹងចូលផ្ទំ តែងពិលាបទួញយំទាំងរាត្រី ប្រាមប្រាប់ប្រដៅសព្វសេចក្ដី ពុំឱ្យមានខ្វះ ត្បិតយើងលាកលះមកនៅក្នុងព្រឹក្សា ពុំមានញាតិវង្សាឯណាដល់មួយនាក់ឡើយ អ្នកបានយល់តែមុខយើងប្អូននឹងបងនេះហើយ អ្នកគ្រាន់បានស្បើយលំហើយលំហែទុក្ខ ឥឡូវនេះ អ្នកពុំ

បានយល់មុខយើងតទៅទៀតឡើយ ឱ! ម្ល៉េះសមអ្នកនៅតែឯង សមនឹងសោកសង្រេងដួលសន្លប់អំពីល្ងាចព្រលប់ លុះដល់ព្រឹកសមអ្នកនឹងសន្ធែសន្ធឹក លុះតែអស់ព្រះកម្លាំង ដូចទឹកត្រពាំងខែប្រាំងត្រូវថ្ងៃក្តៅ ទឹកនោះក៏ស្រកស្រុតរីងហែងហួតស្ងួតខះ បាត់បង់ទៅ ក្រស្នាប្អូនអើយ ទុក្ខនេះ យូរ លង់ក្រៃលែងទុក្ខផងទាំងឡាយដែលព្រាហ្មណ៍គាត់វាយដំធ្វើទោសយើងទាំងពីរនេះទៅទៀត ឥមេ តេ ជម្ពុកា រុក្ខា ប្អូនអើយ រីដើមជម្ពូព្រឹក្ស អធិកនូវដើមពោធិ៍ បាយ ដ៏មានមែកត្រសាយត្រសុំសាខា ម្លប់ព្រឹក្សាជាលំនៅ ដ៏សប្បាយ ដ៏មានព្រីង ព្រួស ភ្លូ ភ្លង បង្កៅ ដូង ដងអង្កាល់ ជ្រៃ ជ្រៃ ខ្ពស់ត្រឈឹងត្រឈៃ ឆើតឆាយ ឫសវាដុះវែងឆ្វាយពាក់ព័ន្ធទៅមក ទាក់សៀតសឹករកគ្នា យើងតែងយកធ្វើជាទោងយោលលេង យើងច្រៀងលេងជាល្បែងក្រសាលសប្បាយ ព្រះពាយផាយផាត់ត្រជាក់ក្សេមក្សាន្ត បុប្ផាសោតសឹងមានដោយពណ៌ល្អៗ ក្រហម ខៀវ ស ល្អប្រសើរ យើងតែងតែដើរទៅបេះយកបុប្ផាមកថ្វាយសែមសៀតព្រះកេសា ប្រដាប់អស់អង្គប្រាណ ទាំងស្រះស្រង់ក៏សប្បាយ ទឹកថ្លាស្អាត មានផ្កាបទុមជាតិដុះដូចអ្នកចារ ទាំងផ្កាសត្បារ ឈូកច្រាលលឿង ស ល្អៗ ដុះជាជួរៗ ឯអស់មច្ឆាសោត ក៏មានដោយហ្វូងទីទៃៗ យើងតែងប្រស្រ័យមើលលេងជាល្បែងសព្វវេលា ឥមេ នោ ហត្ថិកា អស្សា ឱ! ស្តាយរូបម្រឹគ សេះ ដំរី គោ ទន្សាយ រមាំង ប្រើស

ទ្វាយ គុជសីហ៍ ដែលព្រះវរបិតាទ្រង់សួនព្រះរាជទាន ឱ្យយើងលេង ៗ ឥឡូវនេះ យើងបង់ល្បែង ព្រាត់ប្រាសពីទីសប្បាយ ចេញទៅនៅឆ្ងាយ ធ្វើជាខ្ញុំព្រាហ្មណ៍នេះហោង ៗ

ភិក្ខវេ ម្នាលសង្ឃដ៏ទ្រង់នូវសីល សមាធិ បញ្ញា នាកាលព្រះជាលីកុមារ កំពុងពិលាបកន្សែងក្រាបទូលព្រះវរបិតា ឯតាជូជកព្រឹទ្ធាចារ្យ ក៏តាមមកទាន់ វាយដំ ចាប់ចងព្រះរាជកុមារទាំងពីរនៅចំពោះព្រះភក្ត្រព្រះវរបិតា (១) ៗ

តមត្ថំ បកាសេន្តោ សត្ថា អាហ វីអាថ៌ធម៌ឯណា ពុំទាន់ប្រាកដ បទព្រះគាថាឯណា ពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលជាបាទព្រះគាថា ដូច្នេះ

នីយមានា កុមារា តេ   បិតរំ ឯតទព្រវុំ
អម្មំ អារោគ្យំ វជ្ជាសិ   ត្វញ្ច តាត សុខី ភវ ៗ
ឥមេ នោ ហត្ថិកា អស្សា   ពលិពទ្ធា ច នោ ឥមេ
តានិ អម្មាយ ទជ្ជាសិ   សោកន្តេហិ វិនេស្សតិ ៗ
ឥមេ នោ ហត្ថិកា អស្សា   ពលិពទ្ធា ច នោ ឥមេ
តានិ អម្មា ឧទិក្ខន្តី   សោកំ បដិវិនេស្សតីតិ ៗ

ភិក្ខវេ ហៃភិក្ខុផងទាំងឡាយអើយ រីព្រះរាជកុមារទាំង

១- ច្បាប់ខ្លះថា សោ ជូជកោ អាគន្ត្វា កាលនោះតាជូជកព្រាហ្មណ៍ព្រឹទ្ធាចារ្យ តាមមកទាន់ព្រះរាជកុមារទាំងពីរ ហើយចាប់ចងកន្ត្រាក់ វាយដំខំបណ្តើរយកទៅ ពុំមានត្រាប្រណីឡើយ ៗ

ពីរ ដែលតាជីចាស់ជរា កំពុងតែមកចាប់នាំយកទៅនោះ បានក្រាបទូលព្រះជនកដូច្នេះទៀតថា បពិត្រព្រះជនកអើយ សូមទានអម្ចាស់ត្រាស់ប្រាប់ព្រះមេយើងខ្ញុំផងថា យើងខ្ញុំទាំងពីរ ជាលីក្រស្នាសុខសប្បាយ ឥតរោគាព្យាធិមកបៀតបៀនឡើយ បពិត្រព្រះវរបិតាអើយ ឯព្រះអង្គសោត ក៏សូមឱ្យប្រកបដោយសេចក្តីសុខសប្បាយគ្រប់ទិវារាត្រី **ឥមេ នោ ហត្ថិគវា អស្សា** បពិត្រអម្ចាស់អើយ រីសំនួនដំរី ពាជី គោ គោ សិង្ហ រាជសីហ៍ ដែលអ្នកស្មូននឹងដី ឱ្យយើងខ្ញុំលេងជាល្បែងតែសព្វថ្ងៃនោះ សូមព្រះអង្គប្រគល់បង្ហាញទៅព្រះមេឱ្យទានផង ក្រែងព្រះមេយើងខ្ញុំអ្នកយល់សំនួនអស់នោះហើយ ព្រះមេយើងខ្ញុំ នឹងបន្ទោបង់សេចក្តីសៅសោកបានខ្លះ សោះអ្នកនឹងនឹករលឹកយើងទាំងពីរពន់ពេក ៗ

តតោ មហាសត្តស្ស បុត្តេ អារព្ភ ពលវសោកោ ឧប្បជ្ជិ ហទយមំសំ ឧណ្ហំ អហោសិ កាលនោះ ព្រះបាទស្រីវេស្សន្តរបវរមហាសត្វ ស្តេចស្តាប់ពាក្យព្រះរាជកុមារ ទ្រង់ព្រះកន្សែងពិលាបជាពន្លឹក ដូច្នោះ ព្រះអង្គក៏មានព្រះហឫទ័យសៅសោកអាណិតអាសូរព្រះរាជបុត្រទាំងពីរ លើសលន់ពន់ប្រមាណ មានព្រះហឫទ័យក្តៅផ្សា នៅពុំស្រណុក រអាក់រអួលក្នុងព្រះឧរា ញ័រចំប្រប់អស់ទាំងព្រះអង្គ មានឧបមាបីដូចកេសររាជសីហ៍ចាប់ដំរីសារចុះប្រេង ឬមួយដូចព្រះចន្ទ្របានចំណាប់ព្រះរាហូ **បណ្ណសាលំ បវិសិត្វា** ទើបស្តេចចូលទៅកាន់បណ្ណសាលា មានព្រះហឫទ័យ

ក្រៀមក្រំជាំព្រះភក្ត្រា ទ្រង់ព្រះចិន្តាគន់គិតអាណិតព្រះរាជបុត្រ ញាប់ញ័ររន្ធត់អស់ទាំងព្រះកាយ ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណា ពុំទាន់ប្រាកដ បទព្រះបាលីឯណា ពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលសូត្រជាបាទព្រះគាថា ដូច្នេះ

តតោ វេស្សន្តរោ រាជា ទានំ ទត្វាន ខត្តិយោ
បណ្ណសាលំ បវិសិត្វា កលូនំ បរិទេវយីតិ ។

លំដាប់នោះ ព្រះបាទស្រីវេស្សន្តរ លុះស្ដេចព្រះរាជទានព្រះរាជបុត្រទាំងពីរទៅព្រាហ្មណ៍ហើយ ស្ដេចចូលទៅក្នុងព្រះបណ្ណសាលា ទ្រង់ព្រះកន្សែងសោកាពិលាបយោបំ ច្រើនមហិមា ។ លំដាប់តពីនោះ ព្រះបរមពោធិសត្វ ទ្រង់ថ្លែងព្រះពិលាប ជាបាទព្រះគាថា ដូច្នេះ

កន្ទ្វជ្ជឆាតា តសិតា ឧបរុច្ឆន្តិ ទារកា
សាយំ សំវេសនាកាលេ កោ នេ ទស្សតិ ភោជនំ ។
កន្ទ្វជ្ជឆាតា តសិតា ឧបរុច្ឆន្តិ ទារកា
សាយំ សំវេសនាកាលេ អម្មាឆាតម្ហ ទេថ នោ ។
កថន្នុ បថំ គច្ឆន្តិ បត្តិកា អនុបាហនា
សន្តា សុណេហិ បាទេហិ កោ នេ ហត្ថេ គហេស្សតិ ។
កថន្នុ សោ ន លជ្ជេយ្យ សម្មុខា បហរំ មម
អទូសកានំ បុត្តានំ អលជ្ជី វត ព្រាហ្មណោ ។

យោបិមេ ទាសីទាសស្ស អញ្ញោ វា បន បេសិយោ
តស្សាបិ សុខិហីនស្ស កោ លទ្ធី បហរិស្សតិ ។
វារិជស្សេវ មេ សតោ ពន្ធស្ស កុមិនោ មុខេ
អក្កោសតិ បហរតិ បិយេ បុត្តេ អបស្សតោតិ(១) ។

ឱ! កូនសំឡាញ់ទាំងពីរឪពុកអើយ ថ្ងៃល្ងាចថ្ងារនេះហើយ សមបានឹងឃ្លានអាហារ នរណានឹងរមិលមើល ឱ្យអាហារអ្នកទី យល់តែតាជូជកព្រឹទ្ធាចារ្យ នឹងមានតែសេចក្តីភ័យតក់ស្លុតមហិមា អ្នកស្រេកទឹក នរណានឹងបំផឹក កូនសង្សារឪពុកអើយ នាថ្ងៃល្ងាចស្រយាលម្ល៉េះហើយ បាធ្លាប់រែងទារអាហារម្តាយ ថា បពិត្រអ្នកមេអើយ យើងខ្ញុំឃ្លានបាយ ម្តាយបាក៏រកចំណី ឱ្យទីអ្នកស្រេកទឹក ម្តាយអ្នកក៏រកទឹកឱ្យផឹក ម្ល៉េះហើយ បានឹងទារនរណាៗនឹងករុណាប្រណីឱ្យចំណីបានី ភជន្តុ បចំ គច្ឆន្តិ ឱ! កូនស្ងួនឪពុកអើយ អាសូរបាទជើងរៀវតូចដើរជាន់លើខ្សាច់ក្តៅ មុខជាពុរពងបែកហូរឈាម ត្រូវព្រាហ្មណ៍ចងវាយបណ្តើរទៅ កោ នេ ហត្ថេ គហេស្សតិ កូនអើយ នរណានឹងដឹកដៃបាកំដរដើរដោយមាគ៌ា ភចំ សោវ ន លជ្ជេយ្យ ឱ! ដូចអញគិតនេះហើយ ព្រាហ្មណ៍នោះ វាឥតខ្មាសអ្វីមាល្បាយ វាវាយបញ្ចោះ នៅមុខអញ ពុំត្រាប្រណី ហើយនាំបណ្តើរទៅលើសក្រៃលែងជាងខ្ញុំលោះនឹងប្រាក់ចាក់ពីផង់ យោបិមេ

១- វណ្ណនាយំ បន អបស្សតោតិ អការោ និបាតមត្តន្តិ ទិស្សតិ ។

ទាសីទាសស្ស អញ្ញោវ ជរា មម បេសិយោ ទោះអ្នកឯណាមួយមកធ្វើជាខ្ញុំប្រុសខ្ញុំស្រីនៃអញ ទោះយោបីខុសគាប់អម្បាលម៉ាន គេញាំងគិតក្រែងចិត្តថា ជាខ្ញុំព្រះបាទស្រីវេស្សន្តរ គេកោតខ្លាចអំណាចពុំអាចវាយដំឡើយ ៗ ឯព្រាហ្មណ៍កញ្ចាស់កន្ទ្រើសឫស្យាសាហាវយង់ឃ្នងឥតខ្មាស វាវាយដំនឹងឈើច្រត់វាត់នឹងចុងវល្លិ៍ផាល បែកឈាមហូរសស្រាក់នៅចំពោះមុខអញ ឥតចិត្តអាណិតអាសូរបន្តិចឡើយ **វារិជស្សេវ មេ សតោ ពន្ធស្ស កុមិនោ មុខេ** ជូជកព្រាហ្មណ៍វាជេរស្តី វាយដំកូនទាំងពីរជាទីស្រឡាញ់នៅចំពោះមុខអញនេះ អញក្តៅចិត្តពន់ពេកណាស់ អញគិតមើលទៅកូនអញទាំងពីរដូចកល់ត្រីចូលទ្រូ នឹងថយមកក្រោយទាល់នឹងឆ្នុករុលទៅមុខទាល់នឹងប្រើស ព្រះបរមពោធិសត្វទ្រង់ព្រះកន្សែងសោកពិលាប ដោយស្រឡាញ់ព្រះរាជបុត្រទាំងពីរលើសលន់ពន់ប្រមាណ ព្រះអង្គរិះគិតតែក្នុងកំឡុងព្រះរាជហឫទ័យ ថាព្រាហ្មណ៍កញ្ចាស់វាបៀតបៀនកូនអញអ្វីមាល្បាយអេះទ្រង់ត្រិះរិះដូច្នោះហើយ ព្រះអង្គមិនអាចទប់ទល់ព្រះកន្សែង សោកបានឡើយ ទើបទ្រង់ព្រះចិន្តាថា អាត្មាអញតាមទៅកាត់កព្រាហ្មណ៍កញ្ចាស់នោះក៏បានអេះ យកកូនអញត្រឡប់មកវិញ ក្នុងកាលឥឡូវនេះឯង ៗ

លុះព្រះមហាក្សត្រទ្រង់ត្រិះរិះដូច្នេះហើយ បែរជាទ្រង់ព្រះចិន្តាក្នុងព្រះទ័យវិញថា ធម្មតាអ្នកមានធម៌សប្បុរស តាំងចិតប្រាថ្នាជា

ព្រះពុទ្ធ នាំសត្វឆ្លងវដ្តសង្សារ បានយកកូនឱ្យទៅជាទានស្ងួមហើយ យល់តែស្ងួម វាធ្វើទុក្ខទោសកូនដល់ម្ល៉ោះកូវ ប្រឡប់ជាប្រែខ្វៃចិត្ត គំនិតគិតក្តៅក្រហាយស្តាយក្រោយ ហើយមានគំនិតគិតទៅធ្វើទុក្ខទោសគេវិញនោះ មិនសមគួរឡើយ មានព្រះបរិវិតក្កគាថា ថ្លែងព្រះតម្រិះនៃព្រះបរមពោធិសត្វនោះ ឱ្យចែងច្បាស់ ដូច្នេះថា

អាវុធ ចាបំ(១) គហេត្វាន   ខគ្គំ ពន្ធិយ វាមតោ
អានេស្សាមិ សកេ បុត្តេ   បុត្តានំ ហិ វធោ ទុក្ខោ ។
អដ្ឋានមេតំ ទុក្ខតរំ   យំ កុមារា វិហញ្ញរេ
សតញ្ច ធម្មមញ្ញាយ   កោ ទត្វា អនុតប្បតីតិ ។

ហៃភិក្ខុផងទាំងឡាយអើយ កាលព្រះបាទស្រីវេស្សន្តរបរមបពិត្រ ទ្រង់គិតរំពឹងក្នុងព្រះរាជហឫទ័យថា អញនឹងយកព្រះកៅទ័ណ្ឌ នូវព្រះខាន់សរថ្លា ស្ពាយស្មាខាងឆ្វេង ហើយអញនឹងតាមទៅសម្លាប់ព្រាហ្មណ៍ឱ្យក្ស័យជីវិត សឹមអញយកកូនអញទាំងពីរវិលមកវិញ ត្បិតវាពុំស្រឡាញ់ស្ងួនគ្រងឡើយ វាតែងបៀតបៀន វាយដំកូនអញជាពន្លឹកមហិមា ឱ្យជាទុក្ខពេកពន់ប្រមាណ ។ ព្រះបរមពោធិសត្វ ទ្រង់ខ្ញាល់នឹងព្រាហ្មណ៍នោះមហិមា តែដោយហេតុព្រះអង្គស្រឡាញ់ប្រាជ្ញាសារព៌ជ្ញតាញាណនោះ ខ្លាំងណាស់ ទើបខ្វៃប្រែព្រះរាជហឫទ័យគិតថា ឱ! បាវេស្សន្តរអើយ រីទុក្ខឯណាដែលព្រាហ្មណ៍វាវាយដំបៀតបៀនកូនទាំងពីរ រីទុក្ខមានសភាព

១- មានច្បាប់បាលីខ្លះថា " ធនូ ចាបំ " ប្រែថា បំពង់ធ្នូ ដូច្នេះក៏មាន ។

ដូច្នោះ អង្គឹជាឋានជាហេតុ នឹងទៅបៀតបៀនព្រាហ្មណ៍នោះឡើយ ធម្មតាប្រពៃណីនៃព្រះបរមពោធិសត្វ ឱ្យកូនសង្សារទៅជាទានហើយ លោកមិនដែលក្តៅក្រហាយស្តាយក្រោយឡើយ ។

រីព្រះពោធិសត្វ ព្រះអង្គរំលឹកទៅដល់ប្រពៃណីនៃព្រះពោធិសត្វអំពីបុរាណនាយ ដែលលោកប្រាថ្នាជាព្រះពុទ្ធនោះ លោកមិនដែលខានធ្វើមហាបរិច្ចាគ ទាំង ៥ ប្រការ គឺ ធនបរិច្ចាគ ១ អង្គបរិច្ចាគ ១ ជីវិតបរិច្ចាគ ១ បុត្តបរិច្ចាគ ១ ភរិយាបរិច្ចាគ(១) ១ លុះតែធ្វើមហាបរិច្ចាគនោះនែ ទើបបានត្រាស់ជាព្រះពុទ្ធហោង ។ ឯអញសោត បើមិនបានចូលក្នុងលង្វែកព្រះពោធិសត្វ អំពីបុរាណមិនបានឱ្យប្រពន្ធកូនជាទានឡើយ នាបីអញប្រាថ្នានឹងឱ្យបានត្រាស់ជាព្រះពុទ្ធនោះមិញ មិនបានឡើយ ។ កាលព្រះអង្គ ទ្រង់ត្រិះរិះដូច្នោះហើយ ទើបទ្រង់ដៀលត្មះព្រះអង្គឯងថា ហៃបាវេស្សន្តរអើយ បាមិនដឹងទេឬ ការឱ្យទានកូនទៅធ្វើជាខ្ញុំអ្នកដទៃនោះ វាជាទុក្ខ ក៏បាសឹងដឹងស្រាប់ហើយតើ ហេតុអ្វីឡើយ ក៏បាគិតទៅតាមសម្លាប់ព្រាហ្មណ៍នោះមិញ ធម្មតាអស់អ្នកផង តែគេឱ្យទានហើយ គេមិនដែលចុចថយក្រោយដូចបានេះឡើយ ។ ហេតុនេះ តាំងអំពី

១- ធនបរិច្ចាគ គឺលះបង់ទ្រព្យសម្បត្តិឱ្យជាទាន, អង្គបរិច្ចាគ·លះបង់អវយវៈតូចធំរបស់រាងកាយឱ្យជាទាន, ជីវិតបរិច្ចាគ លះបង់ជីវិតឱ្យជាទាន, បុត្តបរិច្ចាគ លើកកូនឱ្យជាទាន, ភរិយាបរិច្ចាគ លើកប្រពន្ធឱ្យជាទាន ។

ថ្ងៃនេះទៅ កុំថាព្រាហ្មណ៍វាវាយដំនាំទៅឡើយ សូម្បីវានឹងសម្លាប់កូនអញបង់ទៅក្តី ក៏ស្រេចនៅអំពើពុតវាចុះ ៗ រីព្រះបរមពោធិសត្វព្រះអង្គទ្រង់អធិដ្ឋានសមាទានខ្ជាប់នូវទានបារមី តម្កល់ទុកក្នុងព្រះហឫទ័យហើយ ទើបស្តេចចេញអំពីបណ្ណសាលា មកគង់នាមាត់ទ្វារលើតម្បារថ្ម មានព្រះអង្គនោះល្អ បីដូចរូបបដិមាមាសគិតដ៏ជាងអ្នករចនាប្រពៃពេកក្តាត់ហោង ៗ

ជូជកោបិ បពិត្រអើយ រីតាជូជកចាស់ព្រឹទ្ធាចារ្យ ដោះឡើងអំពីដួលកាលណា ក៏មីម្មាប្រវាចាប់បានឈើច្រត់ រត់ទន្ទ្រាំគម្រាមងងាម តាមមកចាប់ព្រះរាជកុមារទាំងពីរ វាយដំនៅចំពោះព្រះភក្ត្រព្រះបរមពោធិសត្វ ហើយចងនាំបណ្តើរយកទៅវិញ កាលនោះ ព្រះរាជកុមារទាំងពីរ ទ្រង់ព្រះកន្សែងសោកពិលាបមហិមា ចៅជាលីមានបន្ទូលទៅនឹងនាងក្រស្នា ដូចមានបាទព្រះគាថា ដូច្នេះ

សច្ចំ កិរេទមាហំសុ នរា ឯកច្ចិយា ឥធ
យស្ស នត្ថិ សកា មាតា យថា នត្ថិ តថេវ សោ ។
ឯហិ កណ្ហេ មរិស្សាម នត្ថត្ថោ ជីវិតេន នោ
ទិន្នម្ហាមិ ជនិន្ទេន ព្រាហ្មណស្ស ធនេសិនោ
អច្ចាយិកស្ស លុទ្ទស្ស យោ នោ គាវោវ សុម្ភតិ ។
ឥមេ តេ ជម្ពុកា រុក្ខា វេទិសា សិន្ទុវារិតា
វិវិធានិ រុក្ខជាតានិ តានិ កណ្ហេ ជហាម្ហសេ ។

អស្សត្ថា បនសា ចេមេ និគ្រោធា ច កបិដ្ឋនា
វិវិធានិ ផលជាតានិ តានិ កណ្ហេ ជហាម្ហសេ។
ឥមេ តិដ្ឋន្តិ អារាមា អយំ សីតូទកា នទី
យត្ថស្សុ បុព្វេ កីឡាម តានិ កណ្ហេ ជហាម្ហសេ។
វិវិធានិ បុប្ផជាតានិ អស្មឹ ឧបរិ បព្វតេ
យានស្សុ បុព្វេ ធារេម តានិ កណ្ហេ ជហាម្ហសេ។
វិវិធានិ ផលជាតានិ អស្មឹ ឧបរិ បព្វតេ
យានស្សុ បុព្វេ ភុញ្ជាម តានិ កណ្ហេ ជហាម្ហសេ។
ឥមេ នោ ហត្ថិកា អស្សា ពលិពទ្ទា ច នោ ឥមេ
យេហិស្សុ បុព្វេ កីឡាម តានិ កណ្ហេ ជហាម្ហសេតិ។

កណ្ហេ ហៃនាងក្រស្នាប្អូនពុំងារបងអើយ បងធ្លាប់បានឮថា អ្នកប្រាជ្ញពួកខ្លះ នាលោកិយនេះ ស្រដីមែនពិតអ្វីមាល្បាយម៉្លេះ ថាបើអ្នកឯណា កើតមកអំពីឧទរម្ដាយហើយ គឺមោះ ពុំទាន់ធំនៅជាក្មេងតូច ដូចយើងនេះឯង ល្គឹកបើម្ដាយព្រាត់ប្រាសនិរាសទីទៃហើយ ក្រស្នាមាសបងអើយ ក្មេងនោះ លោកទុកដូចជាស្លាប់ពិត ៗ មកក្រស្នាមាសបងយើងទាំងពីរ ស្លាប់ទៅប្រសើរជាង មានជីវិតរស់នៅថ្វី ព្រះវរបិតាព្រះរាជទានឱ្យទៅតាចាស់ចិត្តសាហាវយង់ឃ្នង វាយដំយើងទាំងពីរ ឥតត្រាប្រណី ដូចជាគង្វាលគោវាយហ្វូងគោ គ្មានមេត្តាប្រណីដល់តិចឡើយ ឥមេតេ ជម្ពុកា រុក្ខា ឱ! ក្រស្នាមាសបងអើយ ស្រណោះដើម

ជម្ពូព្រឹក្ស អធិកនូវមែកសាខាបុប្ផសន្លឹកស្រណុកមហិមាជាក្រយាបន្លែងយើងមិញ ឱ! ម្ល៉េះហើយ សមយើងប្រាសចេញពីឈើអស់នោះហើយ ៗ ឱ! ក្រស្នាប្អូនអើយ រីខ្នុរណាំង ក្រសាំង រាំង ជ្រៃ ព្រៃពោត ដ៏ប្រកបនូវផ្លែផ្កា ច្រើនស្កេកស្កុះ រីកស្គុសស្គាយ សឹងដ៏មានពណ៌ផ្សេងៗ សឹងប្រាសនិរាសអស់ហើយ ៗ ក្រស្នាមាសបងអើយ រីសំនួនដំរី ពាជី គោឆ្នាត់ ព្រះជនកធ្លាប់សូនឱ្យជាល្បែងលេងកម្សាន្តនៃយើង ក្រស្នាអើយ ឥឡូវ ត្រូវប្រាសនិរាសអស់ហើយ ៗ

បុន ព្រាហ្មណោ ឯកស្មឹ វិសមដ្ឋានេ បក្ខលិត្វា បតតិ បពិត្រអើយ រីជូជកព្រាហ្មណ៍នាំកុមារទាំងពីរ ដើរទៅដល់ទីមួយមិនរាបទាប ខំសង្វាតដើរខ្លាំង ពពីបពពាប ភ្លាត់ជើងជំពប់ដួលស្រប៉ាបទៅម្តងទៀត ពុំបានដោះឡើងឆាប់ ៗ អណ្តាប់នោះ ចៅជាលីនិងនាងក្រស្នា កាលណាបានរបូតចេញអំពីចំណោងព្រាហ្មណ៍ មានរាងកាយញ័ររន្ធត់សព្វអង្គប្រាណ មានឧបមាដូចមាន់ដែលគេប្រហារ ទើបព្រះរាជកុមារទាំងគូ បបួលគ្នាម៉ីម្នា រត់ទៅកាន់ព្រះវរបិតា យ៉ាងរូតរះប្រញាប់ប្រញាល់ ឥតបង្អង់ឡើយ ៗ

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណា ពុំទាន់ប្រាកដ បទព្រះគាថាឯណា ពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលនឹងភិក្ខុផងទាំងឡាយ ថា

នីយមានា កុមារា តេ ព្រាហ្មណស្ស បមុញ្ចិយ

តេន តេន បធាវិសុ ជាលី កណ្ហាជិនា ចុភោតិ ។

ភិក្ខវេ ហៃភិក្ខុផងទាំងឡាយអើយ រីចៅជាលីនិងនាងក្រស្នា កាលណាព្រាហ្មណ៍នោះដួលស្រប៉ាបទៅ ក៏បបួលគ្នារត់ចេញទៅកាន់សម្នាក់ព្រះវរបិតា មានអាត្មាញ័ររន្ធត់ ៗ កាលនោះ ជូជកព្រាហ្មណ៍ ដោះឡើងម្ដីម្ដាយ៉ាងប្រញាប់ចាប់បានវល្លិ៍នូវឈើច្រត់ រត់ទៅទាំងក្តៅចិត្ត គាត់ខឹងមហិមាដូចជាភ្លើងឆេះកល្ប ថា ពះ! អាក្មេងរបឹងរឹងរូស ប៊ុនរត់អ្វីមាល្បាយ អញនឹងវាយឱ្យបែកខ្នងឥឡូវនេះឯងមិនទៅឡើយ តាចាស់ចាប់ចងខ្ជាប់ហើយវាយនឹងឈើច្រត់ឥតត្រាប្រណី ស្រដីគម្រាមតឿន ថា បើមឹងមិនដើរ ត្រូវនឹងឈើច្រត់ជីពុកកញ្ចាស់ ឥឡូវនេះឯង ៗ

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណា ពុំទាន់ប្រាកដ បទព្រះបាលីឯណា ពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គត្រាស់នូវព្រះគាថា ដូច្នេះ ថា

តតោ សោ រជ្ជុមាទាយ ទណ្ឌមាទាយ ព្រាហ្មណោ
អាកោដយន្តោ តេ នេតិ សិវិរាជស្ស បេក្ខតោតិ ៗ

ព្រាហ្មណ៍ជរា មានចិត្តឃោរឃៅ ចាប់បានវល្លិ៍និងឈើច្រត់តាមទៅចងវាយបណ្ដើរព្រះរាជកុមារទាំងពីរ នៅចំពោះព្រះភក្ត្រព្រះបាទស្រីវេស្សន្តររាជឫសី ឥតបីមានសេចក្ដីកោតក្រែងរំល្អងចិត្តដល់តិចឡើយ ៗ

រីនាងក្រស្នា កាលណាព្រាហ្មណ៍ចាស់ ចាប់កន្ត្រាក់អូស

ទាញយកទៅ នាងក៏ងាកបែរមកទ្រង់ព្រះកន្សែងពិលាប ក្រាបទូលអង្វរព្រះជនក មុខគួរឱ្យអាសូរករុណាពន់ប្រមាណ ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណា ពុំទាន់ប្រាកដ បទព្រះបាលីឯណា ពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គបានប្រកាសសម្តែងនូវគាថា ដូច្នេះ

តំ តំ កណ្ហាជិនាវោច   អយំ មំ តាត ព្រាហ្មណោ
លដ្ឋិយា បដិកោដេតិ   ឃរេ ជាតំវ ទាសិយំ ។
ន ចាយំ ព្រាហ្មណោ តាត   ធម្មិកា ហោន្តិ ព្រាហ្មណា
យក្ខោ ព្រាហ្មណវណ្ណេន   ខាទិតុំ តាត នេតិ នោ
នីយមានា បិសាចេន   កិន្នុ តាត ឧទិក្ខសីតិ ។

ភិក្ខវេ ហៃភិក្ខុផងទាំងឡាយអើយ កាលនោះ នាងក្រស្នាទ្រង់ព្រះកន្សែង ក្រាបទូលព្រះវរបិតាថា បពិត្រព្រះជនកអើយ ព្រាហ្មណ៍នេះវាវាយខ្ញុំនឹងឈើច្រត់ឈើផ្សាមហិមា ហាក់ដូចជាខ្ញុំកើតក្នុងផ្ទះវា មិនមែនជារាជបុត្រីអម្ចាស់ឡើយ បពិត្រព្រះជនកអើយ ធម្មតាព្រាហ្មណ៍ទាំងឡាយតែងមានធម៌សប្បុរស ឯព្រាហ្មណ៍ចាស់នេះ ខុសក្រៅច្បាប់ធម៌លើសលន់ ទុជ៌នឥតសប្បុរសសោះឡើយ បពិត្រព្រះជនកអើយ តាចាស់នេះ ម្រាងវាជាព្រាហ្មណ៍ពិតពំនិតមកសូមយើងខ្ញុំទៅធ្វើជាខ្ញុំ កម្ពុល់ជាយក្សធំស្កឹមស្កៃ យកក្បៀសជាព្រាហ្មណ៍ ទម្រាំតែបានយើងទាំងពីរ យកទៅធីសាច់ទេដឹង បពិត្រព្រះជនកអើយ បើដូច្នេះតើម្តេច

ក៏ព្រះអង្គបណ្តោយឱ្យតាបិសាចនាំយកយើងទៅ   ម្តេចព្រះអង្គមិនពិចារណា អាណិតអាសូរដល់តិចឡើយ ៗ

កាលនាងក្រស្នាកុមារីក្សត្រីក្រាបទូលព្រះវរបិតាដូច្នេះហើយ ក៏ញ័ររន្ធត់អស់អង្គប្រាណ ព្រាហ្មណ៍ ក៏ចាប់អូសដឹកយកទៅ ឥតប្រណី ព្រះមហាក្សត្រ ក៏ទ្រង់ព្រះកន្សែងសោយសោកាសល់អំពល់នូវទុក្ខ កើតមានព្រះហឫទ័យក្តៅអួលអាក់ តានតឹងព្រះឧរាទាល់តែព្រះភក្ត្រាឡើងក្រហមទុំ រាលដាលដល់ព្រះនាសា ត្រាំតែដកដង្ហើមចេញចូលពុំបានស្រួល តោងដកដង្ហើមតាមព្រះឱស្ឋ ស្រក់ទឹកព្រះនេត្រទៅ សឹងជាឈាម ទើបព្រះអង្គ រំពឹងសញ្ជឹងក្នុងព្រះរាជហឫទ័យ ថា ឱ! ទុក្ខអញនេះធ្ងន់ពន់ប្រមាណមាល្បាយអេះ នេះក៏កើតមកតែអំពីសេចក្តីស្នេហាស្រឡាញ់ បើដូច្នេះ ត្រូវអញកាត់បំបាត់ចិត្តស្រឡាញ់ស្នេហា ឱ្យជ្រះស្រឡះចេញពីសង្សារវដ្ត ទើបព្រះពោធិសត្វ ព្រះអង្គយកព្រះប្រាជ្ញាសារពេជ្ជតាញាណមកបន្ទោបង់សេចក្តីស្រឡាញ់ស្នេហាបានហើយ ព្រះអង្គគង់នៅស្ងៀម ដូចតាមប្រក្រតីហោង ៗ

រីព្រះរាជកុមារទាំងពីរ តាជូជកព្រាហ្មណ៍តាមចាប់ក្រឡាប់នាំទៅឆ្ងាយទូរគម តែនៅពុំទាន់ដល់មាត់ទ្វារព្រៃនៃភ្នំគិរីវង្កត នាងក្រស្នាក្សត្រីពុំងា រឹងទ្រង់ព្រះកន្សែងយោបំពិលាប ដរាបទៅដោយមាគ៌ា ដូចមានបាទព្រះគាថាទាំងឡាយ ថាដូច្នេះ

ឥមេ នោ បាទុកា ទុក្ខា   ទីឃោ អទ្ធា សុទុគ្គមោ

នីចេ ចោ លម្ពកេ សុរិយេ ព្រាហ្មណោ ច តរេតិ នោ ។
ឱកន្ទាម្ហសេ ភូតានិ បព្វតានិ វនានិ ច
សរស្ស សិរសា វន្ទាម សុបតិត្ថេ ច អាបកេ ។
តិណា លតា ច ឱសធ្យោ បព្វតានិ វនានិ ច
អម្មំ អារោគ្យំ វជ្ជាថ អយំ នោ នេតិ ព្រាហ្មណោ ។
វជ្ជន្តុ ភោន្តោ អម្មញ្ច មទ្ទី អស្មាក មាតរំ
សចេ អនុប្បតិតុកាមា ខិប្បំ អនុប្បតេយ្យ នោ ។
អយំ ឯកបទី ឯតិ ឧជុំ គច្ឆតិ អស្សមំ
តមេវានុប្បតេយ្យាសិ អបិ បស្សេសិ នោ សហុំ ។
អហោ វត រេ ជដិនី វនមូលផលាហារិយា
សុញ្ញំ ទិស្វាន អស្សមំ តន្តេ ទុក្ខំ ភវិស្សតិ ។
អតិវេលំ នូន អម្មាយ ឧញ្ឆាលទ្ធំ អនប្បកំ
យា នោ ពន្ធេ ន ជានាតិ ព្រាហ្មណេន ធនេសិនា ។
អច្ឆាយិកេន លុទ្ទេន យោ នោ គាវោវ សុម្ភតិ
អបជ្ជ អម្មំ បស្សេមុ សាយំ ឧញ្ឆាតោ អាគតំ ។
ទជ្ជា អម្មា ព្រាហ្មណស្ស ផលំ ខុទ្ទេន មិស្សកំ
តទាយំ អាសិតោ ធាតោ ន ពាឡ្ហំ តរយេយ្យ នោ ។
សុណា ច វត នោ បាទា ពាឡ្ហំ តរតិ ព្រាហ្មណោ
ឥតិ តត្ថ វិលបឹសុ កុមារា មាតុគិទ្ធិនោតិ ។

ឱ ! អ្នកបងអើយ បាតជើងយើងទាំងពីរសឹងពុរពងរងឈាមរអាមរអាអស់ហើយ ឯណាផ្លូវឆ្ងាយមិតរាយទូគ៏ម ព្រាហ្មណ៏រឹងខំ

ស្រូតរូតវាយដំ បណ្ដើរជាខ្លាំង ទាំងព្រះអាទិត្យឋិតនៅនាឋានទាប ទៀបនឹងអស្ដង្គត កំបាំងបាត់ពីមាត់ព្រៃហើយ វេលាថ្មារនេះ យើងតែងបានយល់សម្ដេចព្រះជននី តែឯណាឡើយ យើងនឹងបានយល់ព្រះភក្ត្រទៀតៗ អ្នកបងអើយ បើដូច្នេះ មក! យើងនឹងលើកកម្បង់អញ្ជលីប្រណម្យ ស្រដីទៅនឹងអស់ទេវតា នៅនាស្រះស្រង់កំពង់ចុងឈើលើព្រៃភ្នំលតាវល្លិ៍ សូមឱ្យអ្នកធ្យានទៅទូលសម្ដេចព្រះជននីនៃយើង ថា ព្រាហ្មណ៍នេះ វានាំយើង ពីអាស្រម ដើរបង្ខំមកដល់ទ្វារព្រៃហើយ យើងទាំងពីរ ឥតមានរោគាព្យាធិអ្វីបៀតបៀនឡើយ កុំឱ្យព្រះជននីអ្នកអាឡោះអាល័យបារម្ភមកដល់យើងទាំងពីរ ទើបចៅជាលី ខំលើកព្រះហស្ដទាំងពីរទាំងចំណងនោះឡើងបង្គំប្រណម្យ សំបូងសង្រូងនូវអស់ទេវតានៅនាដងព្រៃភ្នំនោះថា ភោវន្តោ ទេវសង្ឃាយោ បពិត្រពពួកទេវតាទាំងឡាយ ដ៏ចម្រើនអើយ បណ្ដាដែលគង់នៅក្នុងកំឡុងខ្ពង់ភ្នំដង្គុំព្រៃក្ដី ស្ដេចគង់កំឡុងព្រះឆ្មាំ ចាំរក្សានូវឈើទាំងឡាយក្ដី ស្ដេចគង់កំឡុងចុងស្មៅទាំងឡាយក្ដី ស្ដេចគង់ក្នុងកំឡុងស្រះថ្លាដ៏មានបទុមាផ្កាឈូកក្ដី បពិត្រអើយ សូមទានអ្នកករុណាមេត្តាលីលាទៅទូលសម្ដេចព្រះវររាជជននីនៃយើង ទាំងពីរ ថា ប្រសិនបើអ្នកមកតាមយើងខ្ញុំ កុំបង្អង់ឱ្យយូរឡើយ សូមឱ្យស្ដេចអញ្ជើញមកឆាប់ៗ ក្រែងអ្នកពុំស្គាល់ផ្លូវត្រង់តម្រង់ពីព្រះបរមសាលាមក គ្រាន់តែចុះជើងអ្នកមួយដើរទេ បពិត្រទេព្ដា

ទាំងឡាយ សូមអញ្ជើញឱ្យអ្នកមកតាមផ្លូវនេះឯង ក្រែងអ្នកបានមកយល់យើងខ្ញុំនេះឆាប់ហោង ៗ ហៃភិក្ខុផងទាំងឡាយអើយវីព្រះរាជកុមារទាំងពីរ ទ្រង់ព្រះកន្សែងយោបំ ទូលសូមអង្វរអស់ទេវតានៅនាទ្វារភ្នំគិរីវង្កត ហេតុត្បិតមានចិត្តស្រឡាញ់អាឡោះអាល័យព្រះវរមាតាបិតា មុខគួរឱ្យអាសូរករុណាក្រៃពេកហោង ៗ

កុមារបព្វំ និដ្ឋិតំ បពិត្រអើយ អាត្មាភាពសម្តែងថ្លែងធម៌វិសេសទេសនា ព្រះមហាជាតក៏ កណ្ឌកុមារបព្វៈ ដ៏ប្រដាប់នីទៅនូវព្រះគាថា ១០១ ព្រះគាថា ក៏ចប់បរិបូណ៌សមគួរ ដោយនូវវេលានេះឯងហោង ៗ

ចប់ កណ្ឌកុមារបព្វៈ ទី ៨ តែប៉ុណ្ណោះ ៗ

⁂

ចម្លងចប់នៅថ្ងៃ ១២ កើត ខែចេត្រ ព. ស. ២៥៣៣
ត្រូវនឹងថ្ងៃសុក្រ ទី ៦ ខែមេសា គ. ស. ១៩៩០

មហាវេស្សន្តរជាតក

ទី ៩



កណ្ឌមទ្រីបព្វៈ

ប្រដាប់ដោយគាថា ៩០

មហាវេស្សន្តរជាតក

ទី ៩

កណ្ឌមទ្រីបព្វៈ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

យំ បន រញ្ញោ មហាបថវី ឧន្នាទេត្វា ព្រាហ្មណស្ស បិយបុត្តេសុ ទិន្នេសុ យាវ ព្រហ្មលោកា ឯកកោលាហលំ ជាតំ តេនាបិ កម្បិតហទយា វិយ ហិមវន្តវាសិនោ ទេវតាយោ តេសំ ព្រាហ្មណេន នីយមានានំ តំ វិលាបំ សុត្វា មន្តយិំសុ សចេ មទ្ទី សកាលស្សេវ អស្សមំ អាគមិស្សតិ សា តត្ថ បុត្តេ អទិស្វា វេស្សន្តរំ បុច្ឆិត្វា ព្រាហ្មណស្ស ទិន្នភាវំ សុត្វា ពលវសិនេហេន បទានុបទំ ធាវិត្វា មហន្តំ ទុក្ខំ អនុភវេយ្យាតិ ។

យំ សព្វញ្ញុតញ្ញាណំ វីព្រះប្រាជ្ញាសារព៌ជ្ញតាញាណ ឯណា រញ្ញោ គឺព្រះបាទស្រីវេស្សន្តរបវរពោធិសត្វ កាលព្រះអង្គតាំងព្រះហឫទ័យប្រាថ្នា តំ សព្វញ្ញុតញ្ញាណំ នូវព្រះប្រាជ្ញាសារព៌ជ្ញតាញាណនោះឯងហើយនៃ ទើបព្រះអង្គបរិច្ចាគព្រះរាជបុត្រទាំងពីរ ជាសំឡាញ់ ឱ្យទៅជាទានដល់ព្រាហ្មណ៍ នីយមានានំ ព្រាហ្មណ៍ក៏នាំចេញទៅឱ្យព្រាត់ព្រាកចាកសម្ដេចព្រះរាជមទ្រីមាតា ដ៏ជាទានបរមត្ថបារមីនៃព្រះអង្គ ក៏បង្កើត

ជាអស្ចារ្យ ក្រឡាមហាប្រឹថពីកក្រើកអំពើកញាប់ញ័រ រៀងរាល់ទៅទល់ព្រហ្មលោកនាយ ① ។

បពិត្រអើយ កាលនោះ ជូជកព្រាហ្មណ៍កំណាច អាចនាំព្រះរាជកុមារតូចៗ ទាំងពីរព្រះអង្គ ចងនឹងវល្លិ៍ហើយ នាំបណ្ដើរទៅដោយនូវផ្លូវត្រូវក្រួសខ្សាច់ក្ដៅ ដ៏មានព្រះបាទទាំងពីរពុរពងរងឈាម នឹងយាងព្រះបាទពុំបាន ព្រាហ្មណ៍ជួសាមាន្យវាយបណ្ដើរ មុខគួរឱ្យអាសូរករុណាព្រះរាជកុមារទាំងគូ ពុំដែលស្គាល់ទុក្ខលំបាក ហាលថ្ងៃក្ដៅក្រហាយ ស្រេកទឹក ឃ្លានអាហារ ឯណាព្រាត់ព្រាកចាកព្រះមាតា ពុំយល់ព្រះភក្ត្រា ដ៏មានព្រះ

១- ឯសេចក្ដីផ្ដើមកណ្ឌមទ្រីបព្វៈនេះ តាមច្បាប់មហាជាតក៏ខ្លះ មានសេចក្ដីផ្ដើមប្លែកដូច្នេះ ភោ សាធវោ ហៃសាធុសប្បុរសផងទាំងឡាយអើយ រីព្រះប្រាថ្នាសាពេជ្ញូតាញ្ញាណដ៏ប្រសើរនោះ គឺព្រះពោធិសត្វទាំងឡាយដែលប្រាថ្នាអំពីមុនមក បានត្រាស់ជាព្រះពុទ្ធដូចម្ដេចមិញ ក៏ព្រះបាទស្រីវេស្សន្តរស្ដេចយកព្រះរាជបុត្រទាំងពីរ ឱ្យទៅជាទានព្រាហ្មណ៍មិញ ក៏ទ្រង់ប្រាថ្នាសារពេជ្ញូតាញ្ញាណ ដូចព្រះពុទ្ធរៀងមកអំពីមុននោះហោង ។ ហេតុតែតេជះបារមីនោះគួរ ក្រឡាមហាប្រឹថពី ដ៏មានកម្រាសនោះ ២ សែន អធិកនីទៅនូវ ៤ ម៉ឺនយោជន៍ ពុំអាចទប់ទល់បានឡើយ កម្រើករន្ធត់បីដូចស្បែកគោគេពាសព្ទដ៏ស្គរ ដ៏ស្រែករវោទ៍ខ្ទរខ្ទារ ខ្ចរខ្ចាយ រាលដាលដល់សួគ៌ព្រហ្មលោកនាយ សឹងកើតជាកោលាហលរវល់រចល់អស្ចារ្យ ដោយតេជះបុត្តបរិច្ចាគនៃព្រះបាទស្រីវេស្សន្តរបរមពោធិសត្វខត្តិយមហាបូសីនោះហោង ។

ឱរា ហាក់ដូចនឹងបែកសព្ឋែាកចេញជា ៧ ភាគ ដ៏មានទឹកព្រះនេត្រហូរសស្រាក់សស្រោក ស្រោចទាំងពីរព្រះអង្គ ទ្រង់ព្រះកន្សែងថ្លែងពិលាប មុខគួរឱ្យអាណិតអនាថមហិមា ។ រីនាងកុមារីក្រស្នា ខំទប់ព្រះសោកាហើយ មានបន្ទូលនឹងព្រះជាលីថា បពិត្រអ្នកបងអើយ ឥឡូវនេះ មក! យើងនឹងផ្ដាំអស់ទេវតាផងទាំងឡាយថា បពិត្រទេវតាទាំងឡាយអើយ អ្នកឋិតនៅនាព្រះព្រៃនេះ ក្រែងព្រះមេយើងមកអំពីព្រៃ រកយើងពុំឃើញឡើយ ហើយអ្នកនឹងរត់តាមដោយនូវស្នាមជើងនៃយើងមក ក៏សូមឱ្យអស់ទេវតាទាំងឡាយ អ្នកអាសូរព្រមានអ្នកព្រះមេយើងផងថា យើងទាំងពីរនេះ សឹងឥតទុក្ខឥតភ័យ កុំបីអ្នកព្រួយព្រះហឫទ័យគិតមកដល់យើងទាំងពីរឡើយ ។

រីទេវតាផងទាំងឡាយ ① កាលណាបើបានឮសព្ទទំនួញ

១- តាមច្បាប់អដ្ឋកថាបាលី មានសេចក្ដីដោយសង្ខេបថា កាលនោះពួកទេវតាពិគ្រោះប្រឹក្សាគ្នាហើយ ក៏ប្រគល់ការឱ្យទេវបុត្រ ៣ អង្គថា អ្នកទាំងបី គប្បីនិម្មិតអាត្មាជារាជសីហ៍ ខ្លាធំ ខ្លាដំបង ហើយទៅពាំងខាំងផ្លូវ ដែលព្រះនាងស្ដេចមក ទុកជាព្រះនាងអង្វរសុំផ្លូវយ៉ាងណា ក៏កុំបីបើកផ្លូវឱ្យឡើយ ត្រាតែព្រះអាទិត្យអស្ដង្គតទៅ សឹមបើកផ្លូវឱ្យព្រះនាងយាងទៅកាន់ព្រះអាស្រមបទ ដោយពន្លឺដួងចន្ទ្រ ហើយត្រូវរក្សាការពារ កុំឱ្យសត្វសាហាវ មានរាជសីហ៍ជាដើម ទៅបៀតបៀនព្រះនាងបាន ដោយដាច់ខាត ។

ព្រះរាជកុមារទាំងពីរអង្គទ្រង់ព្រះកន្សែង ទៅរកព្រះវររាជមាតា មានព្រះបន្ទូលផ្តាំដូច្នោះនោះ អស់ទេវតាផង មិនអាចដើម្បីនឹងទប់ទល់នូវសំណោកនោះបានឡើយ ហើយស្រដីនឹងគ្នាថា ម្នាលគ្នាយើងទាំងឡាយអើយ ឥឡូវនេះ ព្រះបរមពោធិសត្វព្រះអង្គឱ្យទានព្រះរាជបុត្រសំឡាញ់ទាំងពីរទៅព្រាហ្មណ៍ ហេតុព្រះអង្គចង់ឱ្យបានត្រាស់ព្រះប្រាជ្ញាសារពេ៏ជ្ញតាញ្ញាណ ។ ឯព្រះរាជមទ្រីស្តេចទៅព្រៃស្វែងរកមើមឈើផ្លែឈើផង ថាបើព្រះនាង មកដល់អំពីថ្ងៃ រកព្រះរាជបុត្រពុំយល់ឡើយ ហើយព្រះនាងនឹងទូលដណ្តឹង កាលណាបើព្រះនាងបានដំណឹងហើយ សមនឹងក្រាបលាទៅដោយនូវសេចក្តីស្នេហាអាល័យ ក៏នឹងរត់ទៅតាមព្រះរាជបុត្រ ដ៏មានសំណោកនោះរន្ធត់ក្នុងព្រះហឫទ័យ មានព្រះឧរាក្តៅផ្សា សមព្រះនាងនឹងទ្រង់ព្រះកន្សែង សង្រេងសង្រែ ដរាបលុះក្ស័យព្រះជន្មាមិនទេឡើយ ម្ល៉ោះហើយ សមព្រះបរមពោធិសត្វនឹងទ្រង់ស្រងេះស្រងោច ខ្លោចផ្សាក្នុងព្រះឧរា តែមួយព្រះអង្គឯង ឱះ ឱ! ថាបើដូច្នេះហើយតើ វីសេចក្តីពិព្យាយាមឯណាឡើយ ក៏នឹងបានពេញលេញតទៅទៀតបាន បើដូច្នោះ មានតែយើងធ្វើឧបាយកល កុំឱ្យព្រះនាងមកកាន់អាស្រមអំពីថ្ងៃ បានឡើយ ទេវបុត្រគិតដូច្នោះហើយ ទើបមានបង្គាប់ប្រើទេវបុត្រទាំង ៣ អង្គ វីទេវបុត្រមួយអង្គនោះ ឱ្យនិម្មិតខ្លួនជារាជសីហ៍ អង្គមួយឱ្យនិម្មិតជាខ្លាធំ អង្គមួយទៀត ឱ្យនិម្មិតជាខ្លាដំបង ឱ្យទៅ

ក្រាបទ្រាបចាំនៅទទឹងផ្លូវចង្អៀត ទោះបីនាងអង្វរលោមទោមសូមផ្លូវដូចម្ដេចក្ដី ក៏កុំអាលបើកផ្លូវឱ្យនាងទៅបានឡើយ ហើយមើលវេលាវិកាល បើព្រះអាទិត្យទន្ទាបហៀបនឹងអស្ដង្គតហើយ សន្សឹមអ្នកទាំងឡាយ បើកផ្លូវឱ្យព្រះនាងស្ដេចមក ៗ មួយសោត ឱ្យរវាំងមើលក្រែងសត្វម្រឹគពាឡយង់ឃ្នង ឯណាមួយ នឹងមកពាធាបៀតបៀនព្រះនាងនោះ ក៏ឱ្យកម្ចាត់ចេញឱ្យឆ្ងាយ ហើយអ្នកទាំងឡាយ គប្បីពិភ័ក្តិរក្សាព្រះនាង កុំបីប្រហែសឡើយ ល្គឹកតែមានសត្វសាហាវឯណាមួយ វាមកពាធាបៀតបៀនព្រះនាងមទ្រី ឱ្យក្ស័យព្រះជន្មទៅ កាលណា ព្រះវេស្សន្តរបវររាជឥសីព្រះអង្គជ្រាបសេចក្ដីហើយ សមនឹងទ្រង់ព្រះកន្សែងសោកស្រណោះ អាឡោះអាល័យព្រះមទ្រីអគ្គមហេសី ជាស្ដ្រីមានស្មារតី តែងនឹងធ្វើវត្តប្រណិប័តន៍សព្វថ្ងៃ សមនឹងទ្រង់ព្រះសង្រេងសង្រែ ក្នុងព្រះឧរា ឯណាព្រះរាជបុត្រាបុត្រី ក៏ពុំយល់ព្រះភក្ត្រ សមអ្នកនឹងវែងជាទុក្ខខ្លោចផ្សា អនាថាកំព្រាតែមួយព្រះអង្គឯង តែងនឹងទ្រង់ព្រះសំណោកនោះ ពុំដែលដាច់ឡើយ ៗ រីក្ដីប្រាថ្នាប្រាថ្វាសារពើជ្ញូតាញាណ ក៏នឹងរសាយរលាយឃ្លាតឆ្ងាយទៅ រីអស់យើងនូវអស់សត្វផងទាំងអម្បាលម៉ាន ដែលនឹងបានដោយសារព្រះអង្គ ក៏នឹងវិលវល់អំពល់ នៅក្នុងវដ្តសង្សារ ៗ ប្រការមួយសោត ទោសនឹងមានដល់យើងផងទាំងឡាយ អម្បាលនៅក្នុងកំឡុងព្រៃនេះ ព្រះឥន្ទ្រាធិរាជ

នឹងរំដៀលថា យើងមើលបំណាំ ពុំបន្ថែបនាំជួយចាំពិភ័ក្តិរក្សាក្សត្រទាំងពីរព្រះអង្គនោះឡើយ ម្ល៉ោះហើយ អ្នកទាំងឡាយ កុំផ្សូរផ្សងយូរឡើយ ចូរបបួលគ្នាទៅឆាប់ហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ ។ **យំ អត្ថំ** រីអាថ៌ធម៌ឯណា **ន បាកដំ** ពុំទាន់ប្រាកដ **សត្ថា** រីព្រះសាស្តាចារ្យ **បកាសេន្តោ** កាលព្រះអង្គទ្រង់ប្រកាស **តំ អត្ថំ** នូវអាថ៌ធម៌នោះ **បាកដំ** ឱ្យប្រាកដ **អាហ** ក៏ទ្រង់សូត្រសាជាអាថ៌បាទព្រះគាថាដូច្នេះ

តេសំ លាលមិតំ សុត្វា   តយោ ពាឡា វនេ មិគា
សីហោ ព្យគ្ឃោ ច ទីបិ ច   ឥទំ វចនមព្រវុំ ។
មា ហេវ នោ រាជបុត្តី   សាយំ ឧញ្ឆាតោ អាគមា
មា ហេវម្ហាកំ និព្ភោគេ   ហេឋយិត្ថ វនេ មិគា ។
សីហោ ចេនំ វិហេឋេយ្យ   ព្យគ្ឃោ ទីបិ ច លក្ខណំ
នេវ ជាលិកុមារស្ស   កុតោ កណ្ហាជិនា សិយា
ឧភយេនេវ ជិយ្យេថ   បតិបុត្តេ ច លក្ខណាតិ ។

បពិត្រអើយ អស់ពពួកទេវតា បានស្តាប់សព្ទសំឡេងយោបំព្រះរាជកុមារទាំងពីរអង្គនោះហើយ ពុំលង់ឡើយ ក៏បង្គាប់ទេវបុត្រ ៣ អង្គ ឱ្យដំណែងកាយាជារាជសីហ៍ ខ្លាធំនិងខ្លាដំបង ចាំរាំងពាំងផ្លូវព្រះនាងមទ្រីរាជបុត្រី ដើម្បីកុំឱ្យស្តេចទៅកាន់បណ្ណសាលា អំពីរសៀលព្រះសុរិយា រង់ចាំដល់

ពេលព្រលប់ សឹមឱ្យស្តេចត្រឡប់ទៅ ដោយពន្លឺរស្មីនៃដួងព្រះចន្ទ្រ ហើយប្រយ័ត្នរក្សាការពារព្រះនាង កុំឱ្យសត្វសាហាវ អ្វីនីមួយមកបៀតបៀនបានឡើយ ។ ប្រសិនបើព្រះនាងដ៏ទ្រទ្រង់នូវលក្ខណា អ្នករាល់គ្នារក្សាការពារ បណ្តោយឱ្យរាជសីហ៍ ខ្លាធំ ឬខ្លាដំបងបៀតបៀនព្រះនាងឱ្យក្ស័យព្រះជន្មា មុខជាចៅផាលីនិងនាងក្រស្នានឹងក្ស័យព្រះជន្មពុំខានឡើយ ហើយព្រះវេស្សន្តរ ជាភស្តានឹងគង់នៅឯកាតែមួយព្រះអង្គឯង ម៉្លេះសមព្រះអង្គ នឹងលន្លង់លន្លោចខ្លោចផ្សាក្នុងព្រះឧរា ពុំអាចចម្រើនមេត្តាភាវនាតទៅទៀតបានឡើយ ។

បពិត្រអើយ រីទេវបុត្រទាំង ៣ អង្គ កាលបើបានទទួលបង្គាប់ទេវតាជាធំ ពុំយូរឡើយ ក៏ម្នីម្នាទៅបណ្តេញសត្វម្រឹគផងទាំងឡាយ មានរាជសីហ៍ជាដើម ឱ្យចៀសចេញឆ្ងាយ ហើយអាត្មាឯងនិមិត្តកាយាជាសត្វទាំង ៣ ដូចស្រដីមកហើយ ក៏ទៅក្រាបស្រពាប ទ្រាបចាំទទឹងផ្លូវព្រះនាងស្តេចយាងមកនោះឯង ។

បពិត្រអើយ រីសម្តេចព្រះនាងមទ្រីស្រីរ័ត្នរាជធីតា ស្តេចលីលាទៅស្វែងរកផលាផល កាលណាបើកើតមានកោលាហលអស្ចារ្យជានិមិត្តក្នុងព្រះអង្គ ទើបព្រះនាងទ្រង់ព្រះចិន្តាថា ខិ ! អញយល់សុបិននិមិត្តយប់មិញនេះ អាក្រក់ក្តាត់ បើដូច្នេះ គួរអញបេះយកផលាផលនិងមើមឈើផង ទៅកាន់អាស្រមបទអំពីថ្ងៃ ព្រះនាងមានព្រះអង្គញ័រចំប្រប់ ខំយាងព្រះបាទរកបេះសន្សំ

ផ្លែឈើនូវមើមឈើបន្តិចបន្តួចដាក់ក្នុងកញ្ជើគ្រាន់ផ្ញើក្សត្រទាំង៣ព្រះអង្គ ហើយព្រះនាងទ្រង់ព្រះកន្សែងបណ្តើរ ទ្រង់រំជួល ហាក់ដូចជាមានភិតភ័យក្នុងព្រះរាជហឫទ័យ ហើយជ្រនីកទម្លក់ក៏ជ្រុះអំពីព្រះហស្ត កញ្ជើសង្រែក ក៏ភ្លាត់របូតចេញអំពីព្រះអង្សា ព្រះនេត្រាខាងឆ្វេងរកាំ ព្រះនេត្រាខាងស្តាំកម្រើក មួយសោតវីឈើឯណាដែលឥតផ្លែ ក៏ខ្វែប្រែជាមានផ្លែទុំខ្ចី ឈើឯណាដែលមានផ្លែទុំខ្ចី ក៏ខ្វែប្រែជាឥតផ្លែវិញហោង ៗ គ្រានោះមហាមេឃ ក៏មមីរស្រទំសព្វទិសា ព្រះនាងទ្រង់ព្រះចិន្តាថា ឱ! សព្វថ្ងៃមកនោះ អញពុំដែលយល់ដូច្នេះទេ ទើបតែក្នុងថ្ងៃនេះឯង នឹងមានហេតុអ្វី ក៏មកយល់ចម្លែកដល់ម្លេះ ឬមួយនឹងមានហេតុភេទអន្តរាយដល់ខ្លួនអញ ឬកូនអញទាំងពីរ ឬមួយនឹងមានដល់ព្រះបាទស្រីវេស្សន្តរជាអម្ចាស់អញ ព្រះនាងទ្រង់ព្រះតម្រិះដូច្នេះហើយ ទើបទ្រង់ព្រះកន្សែងពិលាប ថា

ខណិត្តិកំ មេ បតិតំ ទក្ខិណក្ខិ ច ផន្ទតិ
អផលា ផលិនោ រុក្ខា សព្វា មុយ្ហន្តិ មេ ទិសា ៗ
តស្សា សាយណ្ហកាលម្ហិ អស្សមាគមនំ បតិ
អត្ថង្គតម្ហិ សុរិយេ វាឡា បន្ថេ ឧបដ្ឋហុំ⑴ៗ

១-ប្រែយកសេចក្តីតាមរូបបាលីគាថាដូច្នេះ " ជ្រនីកជ្រុះរបូតពីដៃអញ ភ្នែកខាងស្តាំកម្រើក ផ្លែឈើធ្លាប់មានផ្លែ ក៏ប្រែទៅជាឥតផ្លែ សព្វទិសងងឹតទាំងអស់ៗ កាលអញដើរមកកាន់អាស្រមបទ ក្នុងសាយណ្ហសម័យ ស្រាប់តែមានម្រឹគសាហាវមកឈរ

ឆ្លង . . .

នីចេ ឱលម្ពកេ សុរិយេ   ទូរេ ច វត អស្សមោ
យញ្ច នេសំ ផតោ ហិស្សំ   តន្តេ ភុញ្ជេយ្យ ភោជនំ ។
សោ នូន ឧត្តិយោ ឯកោ   បណ្ណសាលាយ អច្ឆតិ
តោសេន្តោ ឆារកេ ឆាតេ   មមំ ទិស្វា អនាយតី ។
តេ នូន បុត្តកា មយ្ហំ   កបណាយ វរាកិយា
សាយំ សំវេសនា កាលេ   ខីរបីតាវ អច្ឆរេ ។
តេ នូន បុត្តកា មយ្ហំ   កបណាយ វរាកិយា
សាយំ សំវេសនា កាលេ   វារិបីតាវ អច្ឆរេ ។
តេ នូន បុត្តកា មយ្ហំ   កបណាយ វរាកិយា
បច្ចុគ្គតា មំ តិដ្ឋន្តិ   វច្ឆា ពាលាវ មាតរំ(១)។

ពាំងវាំងផ្លូវ នៅវេលាព្រះអាទិត្យអស្តង្គត ៗ

១- វេលានេះ ព្រះអាទិត្យ ក៏ទន់ទាបជិតគងមាត់ព្រៃ ព្រះអាស្រម ក៏នៅឆ្ងាយឡើយ ផលាផលឯណាដែលអញនាំយកទៅពីព្រៃហេមពាន្តនេះ ដើម្បីក្សត្រទាំងបីព្រះអង្គនោះៗ ទ្រង់ធ្លាប់តែសោយផលាផលនេះឯងជាភោជនាហារ ៗ ព្រះបរមក្សត្រនោះស្តេចគង់នៅតែមួយព្រះអង្គឯងក្នុងព្រះបណ្ណសាលា ទ្រង់ប្រលោមលួងលោមក្មេងទាំងពីរនាក់ដែលស្រេកឃ្លានអាហារ ចាំមើលផ្លូវម្តាយបាត់មិនឃើញទៅដល់ព្រះអាស្រម ឱ កូនស្ងួនមាសម្តាយអើយ សមអ្នកកំព្រាវេទនាណាស់ វេលាល្ងាចថ្ងារនេះ ដល់ពេលសេពសោយភោជនាហារ នឹងបៅក្សីរម្តាយហើយ ៗ ឱ កូនស្ងួនពុំងាម្តាយអើយ អ្នកទាំងពីរកំព្រាវេទនាណាស់ វេលាល្ងាចថ្ងារនេះជាពេលសោយ នឹងស្រេកឃ្លាន ដូច

ឆ្លង...

តេ នូន បុត្តកា មយ្ហំ   កបណាយ វរាកិយា
បច្ចុគ្គតា មំ តិដ្ឋន្តិ   ហំសាវូបរិបល្លលេ ។
តេ នូន បុត្តកា មយ្ហំ   កបណាយ វរាកិយា
បច្ចុគ្គតា មំ តិដ្ឋន្តិ   អស្សមស្សាវិទូរតោ ។
ឯកាយនោ ឯកបថោ   សរា សោព្ភា ច បស្សតោ
អញ្ញំ មគ្គំ ន បស្សាមិ   យេន គច្ឆេយ្យ អស្សមំ ។

កូនម្រឹគដែលស្រេកទឹក ៗ ម្ល៉េះសមអ្នកទន្ទឹងចាំមើលផ្លូវម្តាយ បីដូចកូនគោតូចងើបងើយរកមេវា ពុំនោះបីដូចសត្វហង្សដែលជាប់នៅលើភក់ កូនស្ងួនមាសម្តាយ ចាំមើលផ្លូវម្តាយនៅជិតព្រះអាស្រម ៗ ឱ ផ្លូវដែលអញដើរទៅនេះ ជាផ្លូវតូចចុះតែជើងអ្នកមួយដើរ មិនអាចចៀសទៅខាងណាបានឡើយ ត្បិតម្ខាងមានស្រះ ម្ខាងទៀតមានបឹង អញមើលមិនឃើញមានផ្លូវឯទៀត ដែលនឹងគេចចៀសវាង ឱ្យបានដល់ទៅអាស្រម ពុំបានឡើយ ៗ ទើបព្រះនាងមទ្រីពោលពាក្យអង្វរសុំផ្លូវថា បពិត្រស្តេចម្រឹគដ៏មានកម្លាំងខ្លាំងពូកែនៅក្នុងព្រៃ អញខ្ញុំសុំសំពះអង្វរ អស់លោកសុទ្ធតែជាបងប្អូនដោយធម្មជាតិ សូមអស់លោកបើកផ្លូវឱ្យអញខ្ញុំទៅផង ៗ ខ្លួនខ្ញុំនេះ ជាភរិយារបស់ព្រះរាជបុត្តដ៏មានសិរី ដែលអ្នកស្រីពិរាស្ត្រគេបំបរបង់ ខ្លួនខ្ញុំមិនដែលមើលងាយប្រមាថព្រះរាជស្វាមី បីដូចព្រះនាងសិតាទេវី តែងអនុវត្តទៅតាមព្រះហឫទ័យព្រះរាមព្រះរាជស្វាមី ៗ សូមអស់លោកបើកផ្លូវឱ្យខ្ញុំហើយអញ្ជើញទៅជួបកូនរបស់លោក រួចដើរចេញរកស៊ីក្នុងវេលាល្ងាច ឯខ្លួនខ្ញុំក៏នឹងទៅជួបកូនទាំងពីរ គឺចៅជាលីនិងមេក្រស្នា ៗ

មិគា នមត្ថុ រាជានោ   កាននស្មិំ មហព្វលា
ធម្មេន ភាតរោ ហោថ   មគ្គំ មេ ទេថ យាចិតា ។
អវរុទ្ធស្សាហំ ភរិយា   រាជបុត្តស្ស សិរីមតោ
តញ្ចាហំ នាតិមញ្ញាមិ   រាមំ សីតាវនុព្វតា ។
តុម្ហេ ច បុត្តេ បស្សេថ   សាយំ សំវេសនំ បតិ
អហញ្ច បុត្តេ បស្សេយ្យំ   ជាលី កណ្ហាជិនំ ចុភោ ។
ពហុញ្ចិទំ មូលផលំ   ភក្ខោ ចាយំ អនប្បកោ
តតោ ឧបឌ្ឍំ ទស្សាមិ   មគ្គំ មេ ទេថ យាចិតា ។
រាជបុត្តី ច នោ មាតា   រាជបុត្តោ ច នោ បិតា(១)
ធម្មេន ភាតរោ ហោថ   មគ្គំ មេ ទេថ យាចិតាតិ ។

ឱ! អញ អស្ចារ្យចម្លែកអ្វីមាល្បាយ ជ្រនីកក៏ជ្រុះរបូតពីដៃ ភ្នែកខាងស្ដាំអញ ក៏កម្រើកញឹក ៗ ដើមឈើណាដែលធ្លាប់មានផ្លែជាពន្លឹក ក៏ប្រែខ្វែជាឥតផ្លែវិញ ឯអាកាសក៏ងងឹតអ័ព្ទសព្វទិសា ហើយព្រះនាងទ្រង់ព្រះកន្សែងបណ្ដើរ ព្រះនេត្រា

១- មួយវិញទៀត មើមឈើផ្លែឈើរបស់ខ្ញុំ មានច្រើន ទាំងអាហារភោជននេះ ក៏មានមិនមែនតិចទេ ខ្ញុំសូមបែងចែកជូនលោកពាក់កណ្ដាល ខ្ញុំសូមអង្វរ សូមឱ្យអស់លោកបើកផ្លូវឱ្យខ្ញុំផង ៗ មាតារបស់ខ្ញុំក៏ជារាជបុត្រី បិតារបស់ខ្ញុំក៏ជារាជបុត្រអស់លោកទុកជាបងប្អូនដោយធម៌ ខ្ញុំសូមអង្វរសុំអស់លោកបើកផ្លូវឱ្យខ្ញុំទៅផង ៗ

គយគន់មើលទៅព្រះអាទិត្យ ទ្រង់ព្រះចិន្តាថា ឱ! សុរិយា ក៏រសៀលរវៀលទន្ទាបទៅហើយ និមិត្តក៏កើតមានប្រាកដ បើដូច្នោះអញកុំនៅយូរឡើយ ត្រឡប់ទៅពីថ្ងៃបន្តិច ក៏បានអេះ ៗ ម្លោះហើយ ក្នុងព្រះរាជហឫទ័យនៃព្រះនាង តែងនឹងទ្រង់បារម្ភ គិតជញ្ជឹងរំពឹងទៅក្សត្រទាំង ៣ ព្រះអង្គ ព្រះនាងទ្រង់ព្រះកន្សែងបំភ្លាងយាងព្រះបាទបណ្តើរ ព្រះនេត្រតែងនឹងទ្រង់ងៀងមៀង មើលដោយនូវផ្លូវដំណើរ លុះដល់ទៅច្រកចង្អៀត ស្រាប់តែពើបពះប្រទះនឹងសត្វទាំងបី ក្រាបយកសិរសីប្រឈមមកកាន់ព្រះនាង ហើយគ្រហឹមគម្រាម ដ៏មានសព្ទខ្ទរខ្ទារ ញ័រទាំងប្រឹថពី មុខគួរឱ្យអាសូរប្រណី សម្តេចព្រះនាងមទ្រីក្សត្រី ក៏ទ្រង់ភ្ញាក់ភិតភាំងស្រឡាំងកាំងតក់ស្លុត លុតព្រះជង្គង់ចុះ ខំផ្គង់តម្រង់ព្រះស្មារតីសម្តេចក្សត្រី ព្រះនាងលើកព្រះហស្តទាំងពីរប្រណម្យ ហើយមានព្រះបន្ទូលអង្វរលោមថា បពិត្រអ្នកដ៏ជាត្រកូលរាជម្រឹគប្រសើរអើយ អ្នកហោង មានរីទ្ធអានុភាពក្រៃលែងម្រឹគសត្វចតុប្បាទទាំងឡាយ នៅនាភ្នំគិរីវង្កតនេះ អ្នកតែងមានមេត្តាដល់យើងៗ រីព្រះបាទស្រីវេស្សន្តរបវររាជត្រកូល ចូលមកកសាងព្រះផ្នួសបួសជាតាបស មានតែខ្ញុំជាសិស្សមកនៅប្រណិប័តន៍សព្វថ្ងៃ ឥឡូវនេះ ជួបវេលាវិកាលនឹងសោយផលាហារ អញខ្ញុំនឹងនាំទៅថ្វាយព្រះអង្គ នាព្រះបរមសាលា ក៏សូមអម្ចាស់ទាំងឡាយ អ្នកមេត្តាបើកផ្លូវឱ្យអញខ្ញុំនឹងទៅ ព្ធដ៏កាលឥឡូវនេះឯងហោង ៗ

វីសត្វទាំងបី កាលណាបើព្រះសវនីយ៍ ព្រះនាងអង្វរប៉ុន្មានៗក្តី ក៏មិនអាចដើម្បីនឹងបើកផ្លូវឱ្យឡើយ ហើយរឹងធ្វើជាគម្រាមនោះមហិមាក្រៃពេក ៗ វីព្រះនាងមទ្រីយល់សត្វទាំងបីគម្រាមដូច្នោះហើយ ដ៏មានព្រះអង្គនោះញ័ររន្ធត់ រមិលរកផ្លូវនឹងគេចរត់ចៀសចេញពុំបានឡើយ ហើយព្រះនាងទ្រង់ព្រះកន្សែងគិតក្រែងម្រឹគទាំងបីបៀតបៀន ឱ្យក្សិណក្ស័យព្រះជន្មា សមព្រះរាជស្វាមីនូវព្រះរាជបុត្រទាំងពីរនឹងកំព្រា ទើបព្រះនាងទ្រង់ព្រះកន្សែងពិលាប ថា ឱ ! អម្ចាស់ខ្ញុំអើយ ចាប់ដើមតាំងអំពីខ្ញុំបានមកជាបាទបរិចារិកាបម្រើព្រះអង្គ កាលគង់នៅនគរនាយឡើយ អម្ចាស់រែងតែងទ្រង់ព្រះមេត្តាអញខ្ញុំមទ្រីមិនឱ្យអន់អាក់ផ្អាក់ចិត្តឡើយ លុះចេញចាករាជសម្បត្តិទាំង៤ ព្រះអង្គ មកគង់នៅនាព្រៃភ្នំគិរីវង្កតបព៌តនេះ អញខ្ញុំតែងនឹងស្វែងរកផ្លែឈើបម្រើតែសព្វថ្ងៃ ឥតបីមានភ័យភិតគិតក្រែងសត្វម្រឹគបក្សីឯណាមួយនឹងមកបៀតបៀននោះឡើយ ៗ អម្ចាស់ខ្ញុំអើយ ឥឡូវនេះ ខ្ញុំអម្ចាស់មានភ័យនឹងរាជម្រឹគទាំងបី មកខាំងរាំងផ្លូវនឹងទៅពុំរួចឡើយ ថាបើអម្ចាស់ជ្រាបជាខ្ញុំមានភ័យហើយ សមស្តេចនឹងមកអង្វររាជម្រឹគទាំងបី ឱ្យខ្ញុំបានទៅយល់កូនខ្ញុំទាំងពីរមិនទេឡើយ ៗ ឱ ! អម្ចាស់ខ្ញុំអើយ បើឥតនឹងខ្ញុំហើយ នរណាឡើយនឹងប្រណិប័តន៍ ៗ ឱ ! អម្ចាស់ខ្ញុំអើយ វេលាថ្ងារនេះហើយ ព្រះអង្គរែងសោយផលាហារ ត្រអាលនឹង

បុត្រទាំងពីរ ៗ ឱ! កូនសំឡាញ់ទាំងពីរអើយ ថ្ងៃល្ងាចត្រជាក់ថ្ងារនេះហើយ អ្នកតែងនឹងបណ្តើរគ្នាមកលេងឯក្រៅ ចាំមើលផ្លូវម្តាយ បើបានឃើញជាក់ជាម្តាយហើយ សឹងរត់អំពីចម្ងាយ ប្រណាំងប្រជែងប្រកៀកប្រកៀងមកទទួលម្តាយសព្វថ្ងៃ ៗ ឱ! កូនសំឡាញ់ទាំងគូអើយ កាលបើម្តាយបានយល់សួនសំឡាញ់ រត់ប្រដេញគ្នាមកកាន់ម្តាយ រីទុក្ខផងទាំងឡាយក៏រសាយរលាយបាត់អស់ ទោះសេចក្តីនឿយព្រួយក្តៅក្រហាយនឿយហត់ ក៏បាត់ទៅឯង ហើយម្តាយម្ទីម្ទាដាក់អម្រែកចេញអំពីស្មា ដៃស្រវាឱបអ្នកទាំងពីរ រីនាងស្រីក្រស្នាកូនពៅពុំងា តែងនឹងប្រវាឱបម្តាយស្រដីនិយាយតាមដោយភាសាជាក្មេង ហើយសូមដោះបៅ រីចៅជាលីកូនប្រុសពិសី រវងតែងនឹងស្រដីនិយាយនឹងម្តាយ ហើយប្រវារកផ្លែឈើឯណាទុំ ៗ ល្អ ហើយបរិភោគបំភ្លាង ដៃម្ខាងបង្អួតបង្អរប្អូន កូនអើយ ឥឡូវនេះ សមអ្នកចេញមកមើលផ្លូវម្តាយដឹងអើយ បើយល់បាត់ពន់វេលាកាល ពុំឃើញម្តាយឡើយ សមអ្នកនឹងស្រែកយំ នាំគ្នាចូលទៅកាន់អាស្រមបទបរមសាលា នឹងអង្វរព្រះវររាជបិតា ថា អ្នកម្តាយខ្ញុំបាត់ពន់វេលាកាល សូម្បីព្រះវររាជបិតានឹងបបក់ព្រលឹង បបោសផាត់ផង់ធូលី ហើយលួងលោមឱ្យបរិភោគនូវផ្លែឈើមើមឈើ អម្បាលដែលសំណល់សល់នៅនោះហើយ អ្នកក៏នៅតែយំជាទុក្ខខ្សឹកខ្សួលរអាក់រអួលក្នុងឧរា លុះត្រាតែនឿយហើយផ្ទំលក់ទៅហោង ៗ

អថ តយោ ទេវបុត្តា វីទេវបុត្រទាំង ៣ អង្គ ដែលនិម្មិតអាត្មាជាសត្វទាំង ៣ កាលបើគន់មើលពេលវេលា ដឹងថាឥឡូវនេះ ជាវេលាសមគួរនឹងបើកផ្លូវឱ្យព្រះនាងហើយ ទើបនាំគ្នាក្រោកងោះឡើង ហើយគេចចៀសចេញពីផ្លូវនោះទៅ ។

តមត្ថំ បកាសេន្តោ សត្ថា អាហ វីអាថ៌ធម៌ឯណា ពុំទាន់ប្រាកដ បទព្រះបាលីឯណា ពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូល សូត្រសាជាបាទព្រះគាថា ដូច្នេះ

តស្សា សាលប្បមាណាយ ពហុំ ការុញ្ញសញ្ចិតំ
សុត្វា នេលបតឹ វាចំ ពាលា បន្ថា អបក្កមុំ ។

ភិក្ខវេ ម្នាលសង្ឃដ៏ទ្រង់នូវសីលសមាធិបញ្ញា វីទេវបុត្រទាំង ៣ អង្គ ដែលទ្រង់និមិត្តជាសត្វទាំង ៣ កាលណាបើបានស្តាប់ព្រះសវនីយ៍ព្រះនាងមទ្រីមានព្រះបន្ទូលអង្វរ សូមផ្លូវជាច្រើនដងច្រើនគ្រា ហើយដល់វេលាវិកាលផង ។ ឯថ្ងៃដែលព្រះបរមពោធិសត្វឱ្យទានព្រះរាជកុមារនោះ ជាថ្ងៃពេញបូណ៌មីឧបោសថ ចូនជាព្រះអាទិត្យអស្តង្គតផុតរស្មីទៅហើយ ព្រះចន្ទ្ររង្សី ក៏រឿងរះស្រឡះពពកមកអំពីបូព៌ាទិស ដ៏មានអស់ពពួកតារារាំហែហមចោមរោមជាបរិវារ យល់កាលសមគួរនឹងបើកមាគ៌ាឱ្យព្រះនាង ទើបនាំគ្នាចៀសចេញ ទៅកាន់ឋានវិមានអាត្មាទីទៃ ៗ វិញហោង ។

ឥមម្ហិ នំ បទេសម្ហិ   បុត្តកា បំសុកុណ្ឋិតា
បច្ចុគ្គតា មំ តិដ្ឋន្តិ   វច្ឆា ពាលាវ មាតរំ ៗ
ឥមម្ហិ នំ បទេសម្ហិ   បុត្តកា បំសុកុណ្ឋិតា
បច្ចុគ្គតា មំ តិដ្ឋន្តិ   ហំសាវូបរិបល្លលេ ៗ
ឥមម្ហិ នំ បទេសម្ហិ   បុត្តកា បំសុកុណ្ឋិតា
បច្ចុគ្គតា មំ តិដ្ឋន្តិ   អស្សមស្សាវិទូរតោ ៗ
តេ មិគា វិយ ឧក្កណ្ណា   សមន្តាមភិធាវិនោ
អានន្ទិនោ បមុទិតា   វត្តមានាវ កម្បរេ
ត្យជ្ជ បុត្តេ ន បស្សាមិ   ជាលី កណ្ហាជិនំ ចុភោ ៗ
ឆកិលីវ មិគី ឆាបំ   បក្ខី មុត្តាវ បញ្ជរា
ឱហាយ បុត្តេ និក្ខម្ម   សីហីវាមិសគិទ្ធិនី
ត្យជ្ជ បុត្តេ ន បស្សាមិ   ជាលី កណ្ហាជិនំ ចុភោ ៗ
ឥទំ នេសំ បទក្កន្តំ   នាគានមិវ បព្វតេ
ចិតកា បរិកិណ្ណាយោ   អស្សមស្សាវិទូរតោ
ត្យជ្ជ បុត្តេ ន បស្សាមិ   ជាលី កណ្ហាជិនំ ចុភោ ៗ
វាលុកាយបិ ឧកិណ្ណា   បុត្តកា បំសុកុណ្ឋិតា
សមន្តាមភិធាវន្តិ   តេ ន បស្សាមិ ទារកេ ៗ
យេ មំ បុរេ បច្ចុទេន្តិ   អរញ្ញា ទូរមាយតី
ត្យជ្ជ បុត្តេ ន បស្សាមិ   ជាលី កណ្ហាជិនំ ចុភោ ៗ
ឆកិលីវ មិគី ឆាបា   បច្ចុគ្គន្ត្វាន មាតរំ
ទូរេ មំ បដិវិលោកេន្តិ   តេ ន បស្សាមិ ទារកេ ៗ

ឥទញ្ច នេសំ កីឡនំ បតិតំ បណ្ឌុវេឡុវំ
ត្យជ្ជ បុត្តេ ន បស្សាមិ ជាលី កណ្ហាជិនំ ចុភោ ៗ
ថនា ច មជ្ឈិមេ បូរា ឧរោ ច សម្បទាលតិ
ត្យជ្ជ បុត្តេ ន បស្សាមិ ជាលី កណ្ហាជិនំ ចុភោ ៗ
ឧច្ឆង្គេ មេកោ វិចិនតិ ថនា មេកាច សម្ពតិ
ត្យជ្ជ បុត្តេ ន បស្សាមិ ជាលី កណ្ហាជិនំ ចុភោ ៗ
យស្សា សាយណ្ហសមយំ បុត្តកា បំសុកុណ្ឋិតា
ឧច្ឆង្គេ មេ វិវត្តន្តិ តេ ន បស្សាមិ ទារកេ ៗ
អយំ សោ អស្សមោ បុព្វេ សមជ្ជោ បដិភាតិ មំ
ត្យជ្ជ បុត្តេ អបស្សន្ត្យា ភមតេ វិយ អស្សមោ ៗ
កិមិទំ អប្បសទ្ទោវ អស្សមោ បដិភាតិ មំ
កាកោលាបិ ន វស្សន្តិ មតា មេ នូន ទារកា ៗ
កិមិទំ អប្បសទ្ទោវ អស្សមោ បដិភាតិ មំ
សកុណាបិ ន វស្សន្តិ មតា មេ នូន ទារកាតិ ៗ

ឮដ៏កាលនោះ ព្រះនាងមទ្រីក្សត្រីប្រសើរ ព្រះនាងយល់សត្វទាំង៣ អន្តរធានបាត់ទៅហើយ ព្រះនាងត្រេកអរ ម្ចីម្ចា ប្រវាចាប់បានដងរែកដាក់លើព្រះអង្សា ព្រះនាងលីលាមកដោយពន្លឺព្រះចន្ទ្រ លុះព្រះនាងយាងទៅដល់ឋានចង្ក្រម យល់ស្ងាត់ច្រៀបជ្រងំក្រៃពេក ប្លែកនឹងសព្វថ្ងៃ ព្រះនាងក៏អួលអាក់ក្នុងព្រះរាជហឫទ័យ ទ្រង់ព្រះកន្សែង ថា

ឱ! ឋានទីនេះហើយ កូនស្ងួនសំឡាញ់ម្តាយទាំងពីរ តែងនៅលេងធូលីដី ឈរចាំមើលផ្លូវម្តាយមកអំពីព្រៃ បើឃើញម្តាយមកពីចម្តាយ ក៏ម្នីម្នារត់ទៅទទួលម្តាយ បីដូចកូនគោរត់រកមេវា ពុំនោះសោត បីដូចកូនហង្សនៅលើភក់រង់ចាំមើលផ្លូវមេវា ឱ! កូនពុំងាម្តាយអើយ អ្នកទាំងពីរតែងមកឈរចាំទទួលម្តាយ នៅជិតព្រះអាស្រម ៗ សព្វថ្ងៃមក ម្តាយធ្លាប់ឃើញកូនស្ងួនទាំងពីររត់មកទទួល មានអាការរីករាយសប្បាយចិត្តរត់រលះរលាំងនៅជុំវិញខ្លួនម្តាយ បីដូចកូនម្រឹគរត់ឆ្លេឆ្លានៅជុំវិញមេវា មកថ្ងៃនេះ ម្តាយមិនបានឃើញបាជាលីនិងមេក្រស្នា កូនស្ងួនទាំងគូរបស់ម្តាយឡើយ ៗ ម្តាយនេះ លះបង់កូនទាំងពីរចេញទៅស្វែងរកអាហារ ឧបមាបីដូចមេពពែ ឬមេម្រឹគ ឬមេបក្សី លះបង់កូនខ្ចីឱ្យនៅក្នុងសំបុក ពុំនោះសោត បីដូចមេសិង្ហ ដែលមានចិត្តអន្ទះអន្ទែងចេញទៅស្វែងរកអាហារ លះបង់កូនតូច ៗ ហើយខ្លួនឯងចេញទៅរកស៊ី ៗ នេះហើយជាស្នាមជើង ដែលកូនទាំងពីររត់លេងប្រលែងគ្នា មានស្នាមប្រាកដ ដូចជាស្នាមសត្វហត្ថីលិង្គ នៅក្នុងច្រកភ្នំ ក្នុងរដូវភ្លៀង នេះជាគំនរខ្សាច់ដែលអ្នកទាំងពីរជញ្ជូនមកពូនលេងរោយរាយនៅជិតព្រះអាស្រម ថ្ងៃនេះ ម្តាយមិនបានរីករាយសប្បាយចិត្ត ត្បិតបាត់មុខអ្នកទាំងពីរទៅ ៗ សព្វថ្ងៃមកនោះ កូនស្ងួន ទុកជាប្រឡាក់ដីខ្សាច់និងធូលីដី គ្រាន់តែក្រឡេកឃើញម្តាយមកពីព្រៃ ក៏រត់មក

ទទួលម្នីម្នា ថ្ងៃនេះ ម្ដាយស្រងេះស្រងោចខ្លោចចិត្ត ត្បិតបាត់មុខកូនទាំងគូទៅ ៗ សព្វថ្ងៃមក កូនស្ងួនតែងចាំទទួលម្ដាយដែលត្រឡប់មកពីព្រៃឆ្ងាយ ថ្ងៃនេះ ម្ដាយមិនបានឃើញមុខជាលីមេក្រស្នាទាំងពីរឡើយ ៗ សព្វថ្ងៃមក កូនស្ងួនតែងចាំមើលផ្លូវម្ដាយ បីដូចកូនពពែ ឬកូនម្រឹគដែលផើបរកមេវា ថ្ងៃនេះ ម្ដាយមិនបានឃើញមុខកូនទាំងពីរឡើយ ៗ ឱ! នេះនែផ្លែព្នៅទុំសំបុរដូចមាស កូនស្ងួន ម្ដាយធ្លាប់បីលេង ម្ដេចក៏មកធ្លាក់ខ្ចាត់ខ្ចាយនៅទីនេះ ៗ ឱ! ដោះម្ដាយទាំងគូ ពោរពេញទៅដោយទឹកដោះ ដើមទ្រូងម្ដាយស្ទើរប្រេះធ្លាយ ៗ អ្នកណាអើយ នឹងមកប្រទាញប្រទង់ជាយសំពត់ម្ដាយ អ្នកណាអើយនឹងមកចាប់អង្អែលដោះម្ដាយ (សុំដោះបៅ) វេលាល្ងាច កូនស្ងួនតែងប្រឡាក់ដីខ្សាច់ស្រម៉ឹក រត់មកចាប់ទាញជាយសំពត់ម្ដាយថ្ងៃនេះ ម្ដាយមិនបានឃើញមុខស្ងួនឡើយ ៗ កាលពីមុនមកព្រះអាស្រមនេះ ប្រាកដស្ដែង ដូចជាមានតូរ្យតន្ត្រីមហោស្រពថ្ងៃនេះ ម្ដាយមិនបានឃើញមុខកូនកម្សត់ ទើបប្រាកដដូចអាការវិលវៃប៉ែនព្រមរស្ងួនឆ្នាំង ឱ! ព្រះអាស្រមបទ ម្ដេចក៏ស្ងប់ស្ងាត់អីម្ល៉េះ សូម្បីសត្វតាវៅ និងហ្វូងសត្វស្លាប ក្នុងព្រៃស្តុកក៏មិនមានយំរងាវរកគ្នាសោះឡើយ កូនសំឡាញ់ម្ដាយប្រហែលជាស្លាប់បាត់បង់ទៅហើយដឹងអើយ ៗ

សម្ដេចព្រះនាងមទ្រី ទ្រង់ព្រះកន្សែងពិលាប សោយសោក

អាមោក្ខពេកក្រៃ ទើបទ្រង់ព្រះចិន្តាថា ក្រែងចៅជាលី និងមេក្រស្នា ទៅនៅឯព្រះវររាជបិតា ទើបព្រះនាងលីលាទៅកាន់ព្រះអាស្រមបរមសាលា ដាក់អំប្រែកពីព្រះអង្សា ទតឃើញព្រះពោធិសត្វគង់ស្ងៀមមិនមានព្រះវាចា ទាំងមិនបានឃើញព្រះរាជឱរសព្រះរាជធីតា ក្នុងសម្នាក់ព្រះមហាពោធិសត្វឡើយ ទើបព្រះនាងលុតជង្គង់លើកកម្បង់អញ្ជលីប្រណម្យដាក់លើព្រះសិរសា ហើយដណ្តឹងព្រះពោធិសត្វ ដោយបាទព្រះគាថាដូច្នេះ

កិមិទំ តុណ្ហីភូតោសិ　　អបិ រត្តេវ មេ មនោ
កាកោលាបិ ន វស្សន្តិ　　មតា មេ នូន ទារកា ។
កិមិទំ តុណ្ហីភូតោសិ　　អបិ រត្តេវ មេ មនោ
សកុណាបិ ន វស្សន្តិ　　មតា មេ នូន ទារកា ។
កច្ចិ នុ មេ អយ្យបុត្ត　　មិគា ខាទឹសុ ទារកេ
អរញ្ញេ ឥរិណេ វិវនេ　　កេន នីតា មេ ទារកា ។
អាទុ តេ បហិតា ទូតា　　អាទុ សុត្តា បិយំវទា
អាទុ ពហិ នោ និក្ខន្តា　　ខិឌ្ឌាសុ បសុតា នុ តេ ។
នេវាសំ កេសា ទិស្សន្តិ　　ហត្ថបាទា ច ជាលិនោ
សកុណានញ្ច ឱបាតោ　　កេន នីតា មេ ទារកាតិ ។

បពិត្រព្រះរាជស្វាមីជាអម្ចាស់ខ្ញុំអើយ ហេតុអ្វី ក៏ទ្រង់គង់ស្ងៀមទ្រមឹង ពុំមានព្រះបន្ទូល ចិត្តអញខ្ញុំញាប់ញ័រចំប្រប់ ដូចក្នុងកាលយប់ ដែលបានយល់សប្តិឃើញនិមិត្តអាក្រក់ អប្រិយ

សូម្បីតែក្អែកព្រៃនិងសត្វបក្សាបក្សី ក៏មិនឮសូរយំរងាវ កូនកម្សត់របស់អញខ្ញុំ ប្រហែលជាស្លាប់បាត់បង់ទៅទេដឹងអើយ បពិត្រព្រះអយ្យបុត្រជាអម្ចាស់អើយ ឬមួយម្រឹគសាហាវ យង់ឃ្នងពាំនាំកូនអញខ្ញុំយកទៅស៊ីហើយ ឬមួយមានអ្នកណាមួយនាំចូលទៅក្នុងព្រៃជ្រៅ ឬនាំចូលទៅក្នុងវាលធំដាច់ស្រយាលដឹងអើយ ឬមួយព្រះអង្គយល់ចៅជាលី ចេះសំដីនិយាយពីរោះស្តាប់ ហើយទ្រង់ចាត់ប្រើឱ្យធ្វើជារាជទូតទៅកាន់សម្នាក់ព្រះរាជអយ្យកោ ឯជេតុត្តរនគរ ឬមួយកូនសំឡាញ់ទាំងគូ ចូលទៅផ្ទឹលក់ខាងក្នុងបណ្ណសាលា ឬមួយនាំគ្នាដើរទៅលេង ឯខាងក្រៅបណ្ណសាលា សូមព្រះអង្គទ្រង់ព្រះមេត្តាប្រោស ប្រាប់អញខ្ញុំមទ្រីឱ្យបានដឹងផង សោះសង្ស័យ សូម្បីតែសរសៃព្រះកេសានិងព្រះហស្តព្រះបាទ របស់កូនស្ងួនសំឡាញ់ម្តាយទាំងពីរក៏មិនប្រាកដ ឬមួយសត្វហត្ថីលិង្គ សកុណជាតិឯទៀតៗឆាបពាំនាំយកទៅបរិភោគក្តា អញខ្ញុំសូមទូលសួរព្រះអង្គ តើនរណា នាំយកកូនខ្ញុំទាំងគូទៅបាត់ទៅ ។

សូម្បីសម្តេចព្រះនាងមទ្រី ក្រាបទូលដណ្តឹងសួរប៉ុន្មានៗ ក្តី ព្រះមហាសត្វ នឹងមានព្រះបន្ទូលតបទៅដល់មួយព្រះឱសនោះគ្មានឡើយ ម្ល៉ោះហើយ ព្រះនាងវែងជាទុក្ខត្រួតថែមជាទ្វេភាគ ទើបក្រាបបង្គំទូលសួរតទៅទៀតថា បពិត្រព្រះសម្មតិទេព ចុះហេតុអ្វី ក៏ព្រះអង្គមិនមានព្រះបន្ទូលនឹងអញខ្ញុំៗ មានទោស

កំហុសដូចម្តេច   ហើយព្រះនាងក្រាបទូល ដោយបាទព្រះគាថា ដូច្នេះ ថា

ឥទំ   តតោ   ទុក្ខតរំ   សល្លវិទ្ធោ យថា វណោ
តញ្ច បុត្តេ ន បស្សាមិ   ជាលី កណ្ហាជិនំ ចុភោ ។
ឥទំបិ   ទុតិយំ   សល្លំ   កម្បេតិ   ហទយំ   មម
យញ្ច   បុត្តេ ន បស្សាមិ   ត្វញ្ច មំ នាភិភាសសិ ។
អជ្ជ ចេ មេ ឥមំ រត្តឹ   រាជបុត្ត ន សំសសិ
មញ្ញេ   ឱក្កន្តសន្តំ មំ   បាតោ ទក្ខសិ នោ មតន្តិ ។

បពិត្រព្រះរាជស្វាមីជាអម្ចាស់អើយ   រីទុក្ខអញខ្ញុំគ្រានេះ រែងធ្ងន់ពន់ប្រមាណ ជាងទុក្ខដែលគេបំបរបង់មកនៅព្រៃភ្នំនេះ ទៅទៀត   ព្រោះបាត់បង់ខានយល់មុខកូនទាំងពីរ គឺចៅជាលី និងមេក្រស្នា   តែគីមោះគ្រាន់អធ្យាស្រ័យ   ឯព្រះអង្គ ពុំមានព្រះបន្ទូលផងនេះ   ជាទុក្ខធ្ងន់ពន់ពេកក្រៃ   ហាក់ដូចជាព្រះអង្គ យកភ្លើងមកដុតអញខ្ញុំ   ដែលកំពុងមានភ្លើងឆេះស្រាប់ហើយ ពុំនោះសោត   បីដូចទ្រង់យកដំបងវាយថែមនូវអញខ្ញុំ ដែលធ្លាក់ចុះមកពីចុងត្នោត   ឬបីដូចទ្រង់យកព្រួញចាក់ថែម លើដំបៅដែលឈឺផ្សា ៗ   បេះដូងរបស់អញខ្ញុំនេះ   ញាប់ញ័រចំប្រប់ នឹងឈឺក្តៅផ្សា   គួរនាបីដូចអ្នកយកកាំទ្រាបលាបអាសិរពិស   ចាក់តម្រង់ត្រង់លើថ្លើមជំងឺ   ថ្ងៃនេះ   អញខ្ញុំក្តៅចិត្តខ្លោចផ្សា   ត្បិតមិនបានឃើញមុខចៅជាលី និងមេក្រស្នា   ថែមទាំង ព្រះអង្គ

ពុំមានត្រាស់ព្រះវាចានឹងអញខ្ញុំផងសោះ ទុក្ខនេះរឹងធ្ងន់ក្រៃលែង ៗ បពិត្រព្រះរាជស្វាមីអម្ចាស់ខ្ញុំអើយ ប្រសិនបើ ក្នុងយប់នេះ ពុំទ្រង់មានព្រះបន្ទូលប្រាប់ហេតុដល់អញខ្ញុំទេ មុខជាព្រឹកស្អែកនេះ ព្រះអង្គនឹងទតឃើញអញខ្ញុំក្សិណក្ស័យជីវិតិន្ទ្រីយ៍បាត់បង់ទៅ ទៀងប្រាកដហោង ៗ

អថ មហាសត្តោ កាលនោះ ព្រះមហាសត្វ ទ្រង់ព្រះសណ្ដាប់ព្រះនាងមទ្រី ទ្រង់ព្រះកន្សែងថ្លែងព្រះពិលាប ព្រះអង្គមានព្រះរាជហឫទ័យអាណិតអនាថមហិមា ទើបទ្រង់ព្រះចិន្ដាថា បើអញនៅតែស្ងៀមដូច្នេះ សមព្រះនាងនឹងបែកថ្លើមក្ស័យជីវិតប្រាកដពុំខាន បើដូច្នេះ គួរអញនិយាយសម្ដីអ្វី ឱ្យឈឺចិត្ត ទើបនឹងស្រាកស្រាលស្រយាលទុក្ខបានខ្លះ មានតែអញធ្វើជាស្រដីនូវពាក្យប្រចៃប្រចណ្ឌទ្រគោះរឹងរូស ប្រឈ្លោះផង ទើបនឹងឈឺចិត្ត ទ្រង់ព្រះចិន្ដាស្រេចហើយ ទើបស្ដេចបែរព្រះភក្ត្រមកកាន់ព្រះនាងមទ្រី ធ្វើជាទ្រង់ខ្ញាល់ មានព្រះបន្ទូល ថា

ននុ មទ្ទី វរារោហា រាជបុត្តី យសស្សិនី
បាតោ គតាសិ ឧញ្ឆាយ កិមិទំ សាយមាគតាតិ ៗ

ឱ ! មទ្រីនាងអើយ បងអរគុណនាង ដែលយកចិត្តឈឺឆ្អាលសង្វាត លះបង់ព្រះញាតិវង្សា លីលាមកនៅបម្រើប្រណិប័តន៍តែសព្វថ្ងៃ នាងសោតជាត្រកូលក្សត្រ ដ៏ទ្រង់នូវ

រូបឆោមលោមពណ៌សំបុរល្អិតល្អប្រពៃ ហៅបញ្ចពិធកល្យាណី ជាស្ត្រីឧត្តមសមនូវនរលក្សណ៍ គន់ទៅមុខមានស្រីសួស្តី មាត់ប្រិមប្រិយ កាលបើស្រដីមុខគួរឱ្យចង់ស្ដាប់ ទ្រង់នូវរូបល្អចំណាប់ គាប់ចិត្តអ្នកផងៗបានយល់ហើយ គួរឱ្យពិតពិលរមិលមើល ថាជាស្រីប្រសើរ នាមនាងមទ្រីជាអគ្គមហេសី ល្បីឮទូទ័វ ប្រាកដអំពីមុនមកបងវែងគិតថា នាងមានកិរិយាមារយាទ ក្នុងជាតិនេះ នឹងបានជាគូសាងសម្ភារបារមីទៅឰដ៏អនាគតកាល ទុកចិត្តស្និទ្ធស្នាល បណ្ដែតបណ្ដោយឱ្យត្រអាល តាមចិត្តសប្បាយពុំដឹងជានាងមានឧបាយកលលែបខាយ ធ្វើឱ្យសប្បាយភ្លេចស្មារតីៗ មទ្រីអើយ នរណាឡើយ នឹងទៅយល់ក្នុងព្រៃ មួយសោត ក្នុងព្រៃពុំដែលស្ងាត់ សឹងមានមនុស្សម្នា វិជ្ជាធរ ព្រានព្រៃ យោគាវចរ តាបសឫសី អម្បាលចិត្តនៅជាលោកិយ ពុំទាន់លុះមគ្គផល កាលបើយល់រូបនាងមទ្រីនេះដើរតែម្នាក់ឯង វានឹងមិនកោតក្រែងនរណាឡើយ វានឹងលួងលោមស្រដី តាមភាសាលោកិយប្រពៃណីនោះ លុះថ្ងៃល្ងាចត្រជាក់ ទើបនាងរកបេះផ្លែឈើ បានដាក់ក្នុងកញ្ជើ ហើយចេញមកៗ មួយសោតវីអស់ផ្លែឈើសារពើផង ក៏សឹងមានដេរដាស ពុំសូវក្រពេកទេ ហើយមានពុំឆ្ងាយ ទៀបៗនៅអាយ ក៏សឹងមាន អក្ខោ ទន្លាប់ ដង្កោ គុយ ស្វាយ ចេក អំពៅ ព្នៅទាំងឡាយ ក៏សឹងមានទៀបឋានព្រះអាស្រម គួរគិតបារម្ភមកកាន់កូន រវៀស-

រវាំងក្រែងស្រេកទឹកឃ្លានបាយ ក្រែងភ័យអន្តរាយអ្វីមួយកើតមាន ក៏នឹងបានដឹងបានឮ នេះមិនគិតដូច្នេះឡើយ ព្រងើយកន្តើយដើរ ត្រាច់ទៅលេងក្រសាលសប្បាយក្នុងព្រៃឆ្ងាយ ត្បិតផ្លែឈើទៀប នៅអាយ ពុំសូវមានឱជារស ទៅឆ្ងាយនោះវាសប្បាយ ផ្លែឈើទាំងឡាយ ទំនើងតែនឹងក្រសាល តាមដោយនូវចំណង់ចិត្ត នាង លុះដល់យប់អាធ្រាត្រងងឹត ទើបមកដោយនូវពន្លឺរស្មីព្រះចន្ទ្រ ហើយមកដណ្តឹងសួររកកូន តើនរណាដឹងជាកូនទៅឯណា នែមទ្រីអើយ ធម្មតាស្រីទាំងឡាយ ទោះមានប្តី មានកូន ថាបើ មានបើទៅទីឯណាមួយយូរបន្តិច គេរវែងនឹកមកកូន មកប្តីគេខ្លះ នេះម្តងម្តេចឡើយ មទ្រីនាងអើយ នឹកតែនឹងអាលចូលព្រៃអំពីព្រឹក រលះរលាំងភ្លេចភ្លាំងស្មារតី ឯកូននិងប្តីនៅឯក្រោយ នាងមិនមានចិត្តគិតនឹកដល់តិចឡើយ ទាំងនេះ ហេតុតែនាងយល់បងនេះបុណ្យតិច ចាករាជសម្បត្តិព្រាត់អំពីព្រះញាតិវង្សា សេនាទាហានគ្មានឡើយ ហើយមកនៅក្នុងព្រៃ ទ្រង់ផ្នួសបួសជាតាបសឥសី នឹងស្រដីខាងឯអាណាចក្រពុំបាន ទើបនាងមទ្រីហ៊ានធ្វើដូច្នេះ ទាំងនេះទាំងនោះ ហេតុតែកម្មបងឯងមានមកអំពីព្រេង នឹងស្រដីថាអ្វី ពុំបានឡើយ ៗ

បពិត្រអើយ រីព្រះបរមពោធិសត្វ ចាប់ដើមអំពីប្រសព្វនឹងព្រះនាងមទ្រី សោយរាជសម្បត្តិ លុះខ្លាត់មកនៅព្រៃគិរីវង្កតបព៌តនេះ នឹងដែលមានព្រះបន្ទូលអ្វី ជាថ្នាំងថ្នាក់អាក់ព្រះ

រាជហឫទ័យព្រះនាង ដល់ម្តងនោះ ពុំមានឡើយ ហើយព្រះនាងមទ្រីសោត នឹងដែលធ្វើអ្វីឱ្យសៅហ្មងឆ្គងនឹងព្រះរាជហឫទ័យនោះ គ្មានឡើយ ព្រះអង្គមានព្រះបន្ទូលត្រាស់បន្តុះថា ចិត្តលោកិយអម្បាលណោះ ហេតុប្រយោជន៍នឹងឱ្យព្រះនាងស្រាកស្រាន្ត រសាយព្រះសោកបុត្តវិយោគព្រាត់ប្រាសចាកពីឧរា លុះស្តេចមានព្រះបន្ទូលនូវប្រការអម្បាលណោះហើយ ទើបស្តេចធ្វើជាខ្វាល់ ឱនព្រះភក្ត្រដាក់ព្រះនេត្រ បែរព្រះបិដ្ឋិឱ្យព្រះនាង ហើយផ្តត់ព្រះក្អែនពែនព្រះបាទស្ងៀមនៅ ។

រីសម្តេចព្រះនាងមទ្រី កាលបើព្រះស្វាមី មានព្រះបន្ទូលដូច្នោះហើយ ព្រះនាងលុតព្រះជង្គង់ លើកកម្បង់អញ្ជលីករប្រណម្យ ឱនព្រះសិរសាចុះទទួលយល់ ហាក់គ្រាន់ធូរក្នុងព្រះឧរាអម្បាលទុក្ខខ្លោចផ្សាស្រយាលគ្រាន់អធ្យោគ ព្រះសំណោកនោះ គ្រាន់រសាយ ហើយព្រះនាងក្រាបទូលថា

ននុ ត្វំ សទ្ទមស្សោសិ   យេ សរំ ឃាតុមាគតា
សីហស្ស វិនទន្តស្ស   ព្យគ្ឃស្ស ច និកូជិតំ ។
អហុ បុព្វនិមិត្តំ មេ   វិចរន្ត្យា ព្រហាវនេ
ខណិត្តោ មេ ហត្ថា បតិតោ ឧគ្គីវញ្ចាបិ អំសតោ ។
តទាហំ ព្យត្ថិតា ភីតា   បុថុំ កត្វាន អញ្ជលឹ
សព្វា ទិសា នមស្សិស្សំ   អបិ សោត្ថិ ឥតោ សិយា ។
មា ហេវ នោ រាជបុត្តោ   ហតោ សីហេន ទីបិនា

នាគា វា បរាមដ្ឋា　　អច្ឆកោកតរច្ឆិភិ ។
សីហោ ព្យគ្ឃោ ច ទីបិ ច　　តយោ ពាឡ្ហា វនេ មិគា
តេ មំ បរិយាវរុំ មគ្គំ　　តេន សាយម្ហិ អាគតាតិ(១)។

បពិត្រព្រះរាជស្វាមីអម្ចាស់វិសេសខ្ញុំអើយ ចាប់ដើមអំពីអញខ្ញុំមកនៅជាបាទបរិចារិកាបម្រើ ពុំដែលបានធ្វើឱ្យសៅហ្មងឆ្គងនឹងព្រះនេត្រ ទាស់ព្រះរាជហឫទ័យ ដល់ម្ដងសោះឡើយ ក៏ហេតុតែកម្មអញខ្ញុំបានធ្វើអំពើពុំគាប់អំពីមុនមក ដល់ឥឡូវនេះ នាំឱ្យអញខ្ញុំនេះទាស់ឆ្គាំឆ្គងនឹងព្រះរាជហឫទ័យ រីទោសានុទោស

១- បើប្រែតាមរូបបាលីគាថានេះ មានទំនងសេចក្ដីដូច្នេះ " ក៏ព្រះអង្គទ្រង់មិនបានស្ដាប់ឮទេឬ នូវសម្រែកបន្លឺនៃសត្វសិង្ហ ខ្លាធំ ដ៏សាហាវ និងសត្វទ្វីបាទចតុប្បាទដែលត្រាច់មករកផឹកទឹកស្រះនេះ ។ កាលអញខ្ញុំដើរចូលទៅក្នុងព្រៃធំ ស្រាប់តែមានបុព្វនិមិត្ត (ជាចំឡែកអស្ចារ្យ) ជ្រនីកជ្រុះរបូតពីដៃ អម្រែកក៏ភ្លាត់ធ្លាក់ពីស្មា ។ ក្នុងកាលនោះ ខ្លួនអញខ្ញុំ ក៏ភិតភ័យញាប់ញ័ររន្ធត់ ទើបធ្វើអញ្ជលីប្រណម្យទៅសព្វទិស សូមសិរីសួស្ដី គប្បីមាន កុំបីឱ្យរាជសីហ៍និងខ្លា ទៅបៀតបៀនព្រះរាជស្វាមី កុំបីមានសត្វសាហាវ គឺខ្លាឃ្មុំ ឆ្កែព្រៃ ឬខ្លាដំបងប៉ឹងបៀតបៀនដល់កូនកម្សត់ឡើយ មួយវិញទៀត អញខ្ញុំដឹងថា ពីយប់មិញនេះ យល់សុបិននិមិត្តកាចក្ដាត់ ទើបតាំងចិត្តត្រឡប់មកកាន់អាស្រមអំពីថ្ងៃ លុះដើរមកដល់ច្រកបព្វតា ស្រាប់តែពើបពះប្រទះសត្វសាហាវទាំង ៣ គឺ សិង្ហ ខ្លាធំ និងខ្លាដំបង ឈររាំងពាំងផ្លូវអញខ្ញុំ ទើបអញខ្ញុំត្រឡប់មកដល់ព្រះអាស្រម ក្នុងវេលាព្រលប់ សូមទ្រង់ព្រះមេត្តាប្រោសអត់ទោស ។

ផងទាំងពួង អញខ្ញុំសូមទទួលទុកលើសិរសា សូមទ្រង់ព្រះករុណាអត់ទោសបានម្ដង ៗ មួយសោត អញខ្ញុំបានជាបាត់យូរដល់ម្ល៉េះនេះ នាអញខ្ញុំដើរមកអំពីព្រៃ ដល់ផ្លូវចង្អៀតស្រាប់តែពើបពះប្រទះនឹងស្ដេចម្រឹគទាំង ៣ គឺ រាជសីហ៍ នូវខ្លាធំ ខ្លាដំបង មកនៅស្កាត់ទទឹងមាគ៌ា នឹងរកផ្លូវចៀសចេញ ពុំរួចឡើយ ហើយគ្រហឹមគម្រាមនោះមហិមា អញខ្ញុំភិតភ័យថ្កាសមរណ៍ លើកដៃសំពះអង្វរប៉ុន្មាន ៗ ក្តី ក៏ពុំចៀសចេញឡើយ ហើយអញខ្ញុំគិតនឹកដល់អម្ចាស់នូវកូនទាំងពីរ ត្បិតអញខ្ញុំយល់សប្តិយប់មិញនោះពុំល្អ ទើបសំពះអង្វរអស់ទេពតាអារក្សរក្សាព្រៃ សូមឱ្យជួយរក្សាការពារព្រះអង្គ នូវកូនទាំងពីរ កុំឱ្យមានអន្តរាយឡើយ អម្ចាស់ខ្ញុំអើយ មិនប៉ុន្តែម្ល៉ោះឡើយ អញខ្ញុំកើតមាននិមិត្តអាក្រក់អស្ចារ្យ គឺជ្រនីកទម្លាក់ជ្រុះអំពីដៃ កញ្ជើសម្រែកជ្រុះទៅទីទៃ ឈើឯណាមានផ្លែក៏ប្រែខ្វៃជាឥតផ្លែវិញ ៗ រីភ្នែកអញខ្ញុំខាងស្តាំមិញក៏កម្រើក មួយសោត ដូចព្រះអង្គមានព្រះបន្ទូលនោះ អញខ្ញុំមានអស់ទេព្តាក្នុងព្រៃហេមពាន្ត ជាសាក្សីទិព្វញាណ បានដឹងខុសគាប់នៃអញខ្ញុំមទ្រី ៗ តែងមានស្វាមីភក្តិ មានចិត្តរួមរក្សនឹងព្រះអង្គរៀងមក ទោះបីមទ្រីជួជាតិ ក៏សឹងជ្រាបក្នុងព្រះរាជហឫទ័យ សូមទ្រង់ព្រះពិនិត្យ បើអញខ្ញុំខុសពិត សូមថ្វាយជីវិត តាមសព្វព្រះរាជហឫទ័យ រីអញខ្ញុំនេះ ប្រណិប័តន៍ តាមសុចរិតតែសព្វថ្ងៃ ពុំចេរនឹងទ្រង់

ព្រះមេត្តាប្រោសអត់ទោសអញខ្ញុំមទ្រី ក្នុងគ្រានេះម្តងហោង ៗ

ព្រះមហាសត្វ ត្រាស់នឹងព្រះនាងមទ្រីត្រឹមប៉ុណ្ណោះ ក៏មិនមានព្រះបន្ទូលអ្វីតទៅទៀត រហូតដល់ព្រះអរុណរះឡើង ៗ ឯព្រះនាងទ្រង់ព្រះកន្សែងពិលាបមានប្រការផ្សេង ៗ ថា

អហំ បតិញ្ច បុត្តេ ច   អាចរិយមិវ មាណវោ
អនុដ្ឋិតា ទិវារត្តឹ   ជដិនី ព្រហ្មចារិនី ៗ
អជិនានិ បរិទហិត្វា   វនមូលផលហារិយា
វិចរាមិ ទិវារត្តឹ   តុម្ហំ កាមា ហិ បុត្តកា ៗ
ឥទំ សុវណ្ណហាលិទ្ទំ   អាភតំ បណ្ឌុវេលុវំ
រុក្ខបក្កានិ ចាហាសឹ   ឥមេ វោ បុត្តកីឡនា ៗ
ឥទំ មូឡាលិវត្តកំ   សាលុកំ ជិញ្ចរោទកំ
ភុញ្ជ ខុទ្ទេន សំយុត្តំ   សហ បុត្តេហិ ខត្តិយ ៗ
បទុមំ ជាលិនោ ទេហិ   កុមុទំ បន កុមារិយា
មាលិនេ បស្ស នច្ចន្តេ   សិវិបុត្តានិ អវ្ហយ ៗ
តតោ កណ្ហាជិនា យាតិ   និសាមេហិ រថេសភ
មញ្ជុស្សរាយ វគ្គុយា   អស្សមំ ឧបគច្ឆន្តិយា ៗ
សមានសុខទុក្ខម្ហា   រដ្ឋា បព្វាជិតា ឧភោ
អបិ សិវិបុត្តេ បស្សេសិ   ជាលឹ កណ្ហាជិនំ ចុភោ ៗ
សមណេ ព្រាហ្មណេ នូន   ព្រហ្មចរិយបរាយនេ
អហំ លោកេ អភិសសឹ   សីលវន្តេ ពហុស្សុតេ

ត្យជ្ជ បុត្តេ ន បស្សាមិ   ជាលី កណ្ហាជិនំ ចុភោតិ ។

ខ្លួនយើងមិនប្រមាទ ខំសង្វាតតាមមកប្រណិប័តន៍ព្រះរាជស្វាមីនិងកូនគូកម្សត់ គ្រប់ទិវារាត្រី ពុំដែលឈប់ខាន បីដូចសិស្សតាមប្រណិប័តន៍គ្រូអាចារ្យទ្រទ្រង់ជដា ប្រព្រឹត្តព្រហ្មចារ្យ ត្រាច់ស្វែងរកអាហារ គឺមើមឈើនិងផ្លែឈើក្នុងព្រៃ មកផ្គត់ផ្គង់ប្រណិប័តន៍រាល់ៗថ្ងៃ ៗ ឱ ! កូនកម្សត់ម្ដាយអើយ ព្រោះស្រឡាញ់បាទាំងពីរទេតើ ៗ នេះរមៀតមានសម្បុរដូចមាស ម្ដាយរកមកបុកលម្អិតសម្រាប់ផ្ងូតទឹកឱ្យបា នេះផ្លែព្នៅទុំៗសម្បុររលើបរលង់ ម្ដាយបេះមកឱ្យបាលេង ម្ដាយបានស្រាល់ជ្រើសរើសរកផ្លែឈើទុំៗជាច្រើនមុខ យកមកទុកបម្រុង ឱ្យបាលេង អស់នេះសុទ្ធតែជាល្បែងរបស់កូនសម្លាញ់ ៗ បពិត្រព្រះបរមក្សត្រដ៏ប្រសើរ នេះគឺក្រុឱ៍ឈូក ផ្លែឈូក ផ្លែក្រចាប់ ប្រឡាក់នឹងទឹកឃ្មុំ តែល្មមមានឱជារស សូមព្រះទ្រង់យសទ្រង់សេពសោយជាមួយនឹងព្រះរាជបុត្រ ក្នុងកាលឥឡូវនេះឯង ៗ បពិត្រអម្ចាស់អើយ សូមព្រះអង្គទ្រង់ព្រះរាជទានផ្កាបទុមនេះទៅបាជាលី ឯផ្កាកុមុទនេះ សូមទ្រង់ព្រះរាជទានឱ្យមេក្រស្នាកុមារី ព្រះអង្គនឹងបានទតព្រះនេត្រកូនទាំងពីរពាក់កម្រងផ្ការាំថ្វាយ សូមព្រះអង្គត្រាស់ហៅព្រះរាជបុត្រទាំងពីរ ឱ្យចេញពីក្នុងបណ្ណសាលាមកឆាប់ៗវ៉ា មេក្រស្នានឹងអាលមកកាន់ម្ដាយឯណោះ បពិត្រព្រះបរមក្សត្រសូរ្យវង្ស សូមព្រះអង្គទ្រង់ព្រះសណ្ដាប់សម្ដី

មេក្រស្នា ដ៏មានសូរសៀងសំនៀងពីរោះ ទន់ភ្លន់ គួរឱ្យចង់ស្តាប់ ៗ យើងទាំងពីរអង្គ កាលគេបំបរបង់ចេញចាកបុរីរដ្ឋ សឹងមានសុខទុក្ខស្មើភាគគ្នា អើ ! ព្រះអង្គបានឃើញមេក្រស្នា និងបាជាលីដែរឬទេ ៗ ប្រហែលកាលពីជាតិមុនមក អញធ្លាប់ជេរប្រទេចផ្តាសាសមណព្រាហ្មណ៍ អ្នកប្រព្រឹត្តធម៌ត្រឹមត្រូវ ជាអ្នកមានសីល ជាពហុសូតក្នុងលោកនេះថា កុំឱ្យលោកឃើញបុត្រធីតារបស់ខ្លួន បានជាមកក្នុងថ្ងៃនេះ អញមិនបានជួបមុខចៅជាលីនិងមេក្រស្នាទាំងពីរឡើយ ៗ

សូម្បីព្រះនាងមទ្រីទ្រង់ព្រះកន្សែងសោយសោក ជាពន្លឹកដល់ម៉្លោះក៏ដោយ ក៏ព្រះមហាសត្វ នឹងមានព្រះបន្ទូលដល់មួយព្រះឱស្ឋផងនោះគ្មានឡើយ ៗ កាលព្រះមហាសត្វ មិនបានត្រាស់ប្រស្រ័យ ព្រះនាងមានព្រះកាយញាប់ញ័រចំប្រប់ ដើរស្វះស្វែងរកព្រះរាជបុត្រដោយពន្លឺព្រះច័ន្ទ្រ ស្តេចត្រាច់រត់រកក្នុងទីល្បែងក្រសាល មានដើមជម្ពូព្រឹក្សជាដើម ដែលព្រះកុមារធ្លាប់រត់ក្រសាលលេង ក៏ពុំឃើញ ទើបទ្រង់ព្រះកន្សែងពិលាបរៀបរាប់ដោយនូវបាទព្រះគាថាទាំងឡាយ ដូច្នេះថា

ឥមេ តេ ជម្ពុកា រុក្ខា វេទិសា សិន្ទុវារិតា
វិវិធានិ រុក្ខជាតានិ តេ កុមារា ន ទិស្សរេ ។
អស្សត្ថា បនសា ចេមេ និគ្រោធា ច កបិដ្ឋនា
វិវិធានិ ផលជាតានិ តេ កុមារា ន ទិស្សរេ ។

ឥមេ តិដ្ឋន្តិ អារាមា អយំ សីតូទកា នទី
យត្ថស្សុ បុព្វេ កីឡឹសុ តេ កុមារា ន ទិស្សរេ ។
វិវិធានិ បុប្ផជាតានិ អស្មឹ ឧបរិបព្វតេ
យានស្សុ បុព្វេ ធារឹសុ តេ កុមារា ន ទិស្សរេ ។
វិវិធានិ ផលជាតានិ អស្មឹ ឧបរិបព្វតេ
យានស្សុ បុព្វេ ភុញ្ជឹសុ តេ កុមារា ន ទិស្សរេ ។
ឥមេ តេ ហត្ថិកា អស្សា ពលិពទ្ធា ច នោ ឥមេ
យេហិស្សុ បុព្វេ កីឡឹសុ តេ កុមារា ន ទិស្សរេតិ ។

កូនអើយ ចាប់ដើមអំពីថ្ងៃនេះទៅហើយ សមម្ដាយនឹងស្ងាត់ឮតែមាត់សព្វសត្វយំនៅពាសព្រៃ ហើយម្ដាយនឹងគិត ស្រណោះអាឡោះអាល័យ លន្លង់លន្លោចខ្លោចផ្សា ក្នុងឧរាក្រៀមក្រំ ម្ល៉េះហើយសមម្ដាយនឹងយំសោកសង្រេងសង្រៃ ដរាបលុះតែក្ស័យជីវិតទៅហោង ៗ កូនអើយ ឬមួយសោត អ្នករត់ទៅលេងសព្វស្ថានល្បែងដែលតែងនឹងលេង សព្វថ្ងៃទេដឹងអើយ ម្ល៉ោះហើយ ព្រះនាងក៏រត់ទៅទាំងរាត្រី រកសព្វស្ថានល្បែងទ្រង់ព្រះកន្សែងហើយស្រែកហៅថា ឱកូនពៅម្ដាយទាំងពីរ អ្នកនៅស្ថានឯណា ចូរមកបៅម្ដាយអាយ ម្ដាយមករកអ្នក ម្ដេចឡើយ ពុំឮមាត់ឆ្លើយមកកាន់ម្ដាយ ៗ ឱ! អស់សំនូនរូបគោតូច គោធំ ច្រឡំនឹងរូបដំរី រូបរទេះផងនូវអស់ផ្កាកម្រងមាលាដែលកូនស្ងួនពុំងានាំគ្នាមកលេង ចាំមើលផ្លូវម្ដាយ នៅឋាន

អាយនេះ ៗ កូនអើយ ម្ដាយយល់ហើយ ទ្រូងម្ដាយស្ទើរប្រេះ ឱ! ថ្មានេះហើយ តើអ្នកនាំគ្នាទៅលេងស្ថានឯណា វិញទៀត ហើយ កូនអើយ សមអ្នកក្ស័យជីវិតទាំងពីរមែនពិតដឹងអើយ ៗ ម្ល៉ោះហើយ ព្រះនាងវែងជាទ្រង់ព្រះកន្សែង ថ្លែងពិលាបអាណិត អនាថ ខំយាងព្រះបាទរត់រកសព្វស្ថាន មុខគួរឱ្យមានមេត្តាប្រណី សម្ដេចព្រះមទ្រី ស្ដេចត្រាច់រកក្នុងរាត្រី តែមួយព្រះអង្គឯងស្រែក ហៅក្ដែង ៗ រកព្រះរាជបុត្រ ព្រះរាជហឫទ័យរន្ធត់ ញ័រអស់ ឥន្ទ្រិយ អស់ទាំងសត្វម្រឹគបក្សីព្ទហើយ សឹងតែភិតភ័យ ភ្ញាក់ ផ្អើល ព្រះនាងទតមៀងមើលស្មានជាព្រះរាជបុត្រ តែពុំយល់ ប្រាកដឡើយ ព្រះនាងត្រឡប់វិលមកកាន់ព្រះបរមពោធិសត្វ ហើយក្រាបទូលវិញទៀតថា បពិត្រព្រះរាជស្វាមីអម្ចាស់វិសេស ខ្ញុំអើយ ឥឡូវនេះ ខ្ញុំរត់រកកូនខ្ញុំទាំងពីរ សព្វគ្រប់អស់ឋាន ល្បែង ពុំយល់ឡើយ ពុំដឹងជាទៅឯណា ទោះកាច ទោះជា សូមទ្រង់មេត្តាបើកព្រះឱស្ឋបន្ទូលប្រាប់ខ្ញុំម្ចាស់ សោះថប់ពេក ឡើយ ឱ! អញអើយ បីដូចមេសត្វអក មានកូនទាំងគូ ឱ្យនៅ ចាំសំបុក ហើយអាត្មាឯងទៅស្វែងរកចំណីអាហារ ប្រយោជន៍ នឹងនាំមកចិញ្ចឹមកូន មកដល់សំបុកហើយ រកកូនពុំយល់ ឡើយ ហើយជាទុក្ខសោកស្ដាយកូននោះ ម្ដេចមិញ វីអញខ្ញុំ កើតទុក្ខ មានឧបមាបីដូច្នោះឯងហោង ៗ

ព្រះនាងទតព្រះនេត្រឃើញអស់ទាំងរូបសំនួនល្បែង របស់

ព្រះរាជបុត្រា បុត្រីនោះហើយ ទើបមានព្រះបន្ទូល ជាបាទព្រះគាថា ដូច្នេះ

ឥមេ សាមា សសោលូកា ពហុកា កទលីមិគា
យេហិស្សុ បុព្វេ កីឡីសុ តេ កុមារា ន ទិស្សរេ ។
ឥមេ ហំសា ច កោញ្ចា ច មយូរា ចិត្របេខុណា
យេហិស្សុ បុព្វេ កីឡីសុ តេ កុមារា ន ទិស្សរេតិ ។

ឱ! អស់សំនួនកូនម្រឹគតូច ៗ រូបទន្សាយ រូបសត្វមៀម និងរូបសត្វឈ្លូស់ ក៏មានជាច្រើន ដែលកូនស្ងួនសម្លាញ់ម្ដាយ ធ្លាប់លេងអំពីមុននេះ គឺសំនួនរូបហង្ស ក្រៀល ក្ងោក ដ៏មានព្រុយកន្ទុយល្អវិចិត្រ សុទ្ធជាល្បែងដែលបាទាំងពីរគាប់ចិត្តលេងអំពីមុន ឥឡូវ ម្ដាយពុំបានយល់មុខបាទាំងពីរឡើយ ។

លុះព្រះនាងពុំបានឃើញព្រះរាជបុត្រសម្លាញ់ទាំងពីរ ក្នុងព្រះអាស្រមបទហើយ ទើបចេញចាកព្រះអាស្រមបទ រត់ត្រឡប់ចូលទៅកាន់ព្រៃនៃបុប្ផជាត ទ្រង់ទតព្រះនេត្រ រកសព្វទីនោះ ៗ ហើយត្រាស់ថា

ឥមា តា វនគុម្ពាយោ បុប្ផិតា សព្វកាលិកា
យត្ថស្សុ បុព្វេ កីឡីសុ តេ កុមារា ន ទិស្សរេ ។
ឥមេ តា បោក្ខរណី រម្មា ចក្កវាកូបកូជិតា
មន្ទាលកេហិ សញ្ឆន្នា បទុមុប្បលកេហិ ច
យត្ថស្សុ បុព្វេ កីឡីសុ តេ កុមារា ន ទិស្សរេតិ ។

នេះគឺស៊ុមទ្រុមគុម្ពឈើតែងមានផ្ការីកគ្រប់រដូវកាល ដែលកុមារទាំងពីរធ្លាប់ក្រសាលលេង នេះគឺស្រះបោក្ខរណី ជាទីរីករាយក្សេមក្សាន្ត តែងឮសូរសព្ទយំរងាវនៃសត្វចាក្រពាក ដ៏ដេរដាសដោយផ្កាមណ្ឌាលក៏ ផ្កាបទុមនិងផ្កាឧប្បលដែលកុមារទាំងពីរធ្លាប់ក្រសាលលេងអំពីមុន តែម្តាយគយគន់រកបាទាំងពីរពុំឃើញឡើយ ៗ

លុះព្រះនាងរត់រកសព្វកន្លែង ពុំឃើញហើយ ទើបស្តេចត្រឡប់ទៅកាន់សម្នាក់ព្រះមហាសត្វជាព្រះរាជស្វាមីទៀត ទ្រង់ទតឃើញព្រះអង្គទ្រង់ជ្រប់ព្រះភក្ត្រ ពុំមានព្រះបន្ទូលដូច្នោះ ទើបព្រះនាងក្រាបទូល តវ៉ា ថា

ន តេ កដ្ឋានិ ភិន្នានិ   ន តេ ឧទកមាភតំ
អគ្គិបិ តេ ន ហាបិតោ   កិន្នុ មន្ទោវ ឈាយសិ ។
បិយោ បិយេន សង្គម្ម   សមោហំ ព្យបហញ្ញតិ
ត្យជ្ជ បុត្តេ ន បស្សាមិ   ជាលី កណ្ហាជិនំ ចុភោតិ ។

បពិត្រព្រះរាជស្វាមី សព្វថ្ងៃរៀងមក ព្រះអង្គកាប់ឧសដងទឹកយកមកទុក បង្កាត់ភ្លើងទុកក្នុងជើងក្រាន ថ្ងៃនេះ ព្រះអង្គឥតធ្វើអ្វីសោះឡើយ បានតែគង់សុបសៅច្រងូវ កិរិយារបស់ព្រះអង្គនេះ មិនជាទីគាប់ចិត្តអញខ្ញុំឡើយ ពីមុនៗមក ព្រះវេស្សន្តររាជស្វាមីហ្នឹងហើយ ជាទីស្រឡាញ់ពេញចិត្ត នៃអញខ្ញុំ មិនមានអ្នកដទៃក្រៃលែងជាងនេះឡើយ គ្រាន់តែបាន

យល់ព្រះភក្ត្រា ក៏ភ្លេចសេចក្តីនឿយព្រួយលំបាកទាំងអស់ លុះមកក្នុងថ្ងៃនេះ អញខ្ញុំបានយល់ព្រះភក្ត្រព្រះអង្គហើយ ក៏នៅតែមិនរសាយសេចក្តីសោក ព្រោះមិនបានជួបមុខកូនទាំងពីរ គឺចៅជាលីនិងមេក្រស្នានោះឡើយ (១) ។

កាលសម្តេចព្រះនាងមទ្រី ក្រាបទូលតវ៉ា យ៉ាងនេះហើយ សម្តេចព្រះមហាសត្វ ក៏នៅតែគង់នៅស្ងៀម ពុំមានព្រះបន្ទូលដល់មួយព្រះឱស្ឋឡើយ ម្ល៉ោះហើយ ព្រះនាងវែងជាទុក្ខធ្ងន់ក្រៃលែង ទ្រង់សោយសោក ខ្សឹកខ្សួលរំជួលអស់អង្គប្រាណហាក់ដូចមេមាន់ដែលត្រូវគេប្រហារ ព្រះនាងត្រាច់រត់ទៅកាន់កន្លែងមុននោះទៀត ហើយវិលមកកាន់សម្នាក់ព្រះមហាសត្វវិញ ក្រាបបង្គំទូលសួរថា

ន ខោ នោ ទេវ បស្សាមិ យេន តេ នីហតា មតា
កាកោលាបិ ន វស្សន្តិ មតា មេ នូន ទារកា ។
ន ខោ នោ ទេវ បស្សាមិ យេន តេ នីហតា មតា
សកុណាបិ ន វស្សន្តិ មតា មេ នូន ទារកាតិ ។

បពិត្រព្រះសម្មតិទេពក្សត្រថ្លៃប្រសើរអើយ អញខ្ញុំមិនឃើញកូនទាំងពីរសោះឡើយ ចុះអ្នកណានាំយកទៅ ឬមួយស្លាប់

១- ទាំងបាលីទាំងសម្រាយមិនមានក្នុងច្បាប់មហាជាតក៏ទាំងឡាយទេ នេះជាសេចក្តីស្រង់និងប្រែបំពេញតាមច្បាប់ជាតក ជាបាលីដើម ។

បាត់ទៅហើយ សូម្បីសត្វក្អែកព្រៃនិងសត្វបក្សីផងទាំងឡាយ ក៏ស្ងាត់ជ្រងំ មិនឮយំរងាវរកគ្នាសោះឡើយ កូនរបស់អញខ្ញុំប្រាកដជាស្លាប់មែនដឹងអើយ ៗ

កាលព្រះនាងក្រាបទូលសួរយ៉ាងនេះហើយ ព្រះមហាសត្វក៏ពុំមានព្រះបន្ទូលដល់មួយព្រះឱស្ឋឡើយ ៗ ព្រះនាងវែងជាទុក្ខជាសោកខ្លោចផ្សា ខំស្វះស្វែងរកព្រះរាជបុត្រាបុត្រី ស្តេចរត់ទៅកាន់ទីតំបន់នោះ ៗ យ៉ាងរហ័សរួសរាន់ ដូចសន្ទុះខ្យល់ដល់ ៣ គ្រា ៗ មានសេចក្តីដំណាលថា ទីឋានទាំងពួង ដែលសម្តេចព្រះរាជមទ្រីស្តេចត្រាច់រត់រកព្រះរាជបុត្រ ក្នុង ១ រាត្រីប៉ុណ្ណោះ បើនឹងលាត្រដាងចេញទៅជាចម្ងាយផ្លូវ ដល់ ១៥ យោជន៍ ៗ លុះវេលារាត្រីភ្លឺស្វាង ព្រះអរុណរះឡើងហើយ សម្តេចព្រះនាងមទ្រី ក៏ស្តេចត្រឡប់មកកាន់សម្នាក់សម្តេចព្រះមហាសត្វវិញ ស្តេចឈរទ្រង់ព្រះកន្សែងសោយសោក យ៉ាងក្រៃលែង ៗ

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណា ពុំទាន់ប្រាកដ បទព្រះបាលីឯណា ពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលសូត្រនូវបាទព្រះគាថាដូច្នេះថា

សា តត្ថ បរិទេវិត្វា បព្វតានិ វនានិ ច
បុន ទេវស្សមំ គន្ត្វា សាមិកស្សន្តិ រោទតិ ។
ន ខោ នោ ទេវ បស្សាមិ យេន តេ និហតា មតា

កាកោលាបិ ន វស្សន្តិ មតា មេ នូន ទារកា ។
ន ខោ នោ ទេវ បស្សាមិ យេន តេ នីហតា មតា
សកុណាបិ ន វស្សន្តិ មតា មេ នូន ទារកា ។
ន ខោ នោ ទេវ បស្សាមិ យេន តេ នីហតា មតា
វិចរន្តិ រុក្ខមូលេសុ បព្វតេសុ គុហាសុ ច ។
ឥតិ មទ្ទី វរារោហា រាជបុត្តី យសស្សិនី
ពាហា បគ្គយ្ហ កន្ទិត្វា តត្ថេវ បតិតា ឆមាតិ ។

ភិក្ខវេ ម្នាលភិក្ខុផងទាំងឡាយអើយ ភិក្ខុអើយ មុខគួរឱ្យអាសូរប្រណីសម្តេចព្រះភគវតីព្រះនាងមទ្រីវរលក្ខណ៍ អគ្គជាយា ដ៏មានសិរីសួស្តី ព្រះនាងរត់រកព្រះរាជបុត្រាបុត្រី សស្រាក់ទាំងយប់រាត្រី រកសព្វស៊ុមទ្រុមគុម្ពឈើច្រកភ្នំ និងព្រៃព្រឹក្សាផង ពុំយល់ឡើយ ហើយព្រះនាងវិលមកកាន់ព្រះអាស្រម ក្រាបទូលព្រះបរមរាជស្វាមី ទ្រង់ព្រះកន្សែងសោយសោក ព្រះអង្គពុំមានព្រះបន្ទូលដល់មួយព្រះឱស្ឋឡើយ ហើយព្រះនាងរត់ទៅរកវិញទៀត ព្រះនាងរត់ទៅរត់មក ជាច្រើនគ្រា រីឯអាហារ ព្រះនាងពុំបានសោយឡើយ ហើយទ្រង់ព្រះកន្សែងដង្ហោយស្រែកហៅ ដ៏មានព្រះសូរសៀងសំឡេងនោះ ឮទូទ័រទៅសព្វព្រៃព្រឹក្សា សត្វផងឮហើយ ក៏ភិតភ័យ ភ្ញាក់ផ្អើលគគឹក ព្រះនាងឮសន្ធឹក ក៏ទ្រង់ឈរស្តាប់ យល់ជាក់ជាសត្វហើយ ព្រះនាងក៏អួលអាក់ក្នុងព្រះឧរា ទ្រង់ព្រះកន្សែង ថា

ឱ ! មាសថ្លៃម្ដាយអើយ ម្ដាយស្រមៃឮសន្ធឹក គិតថា ជាកូន ឥឡូវសោះសូន្យ មិនយល់ស្ងួន ទន់អស់ទាំងខ្លួនស្ងួតក កូន អើយ សមម្ដាយមិនមានជីវិតរស់នៅទេដឹងអើយ ម្លោះហើយ ព្រះនាងវិលមកកាន់ព្រះបរមពោធិសត្វវិញ ព្រះនាងលើកព្រះករ គក់ព្រះឧរា ទ្រង់ព្រះកន្សែងថ្លែងព្រះពិលាប ដ៏មានព្រះសូរ សៀងខ្សាបខ្សោះ អស់ព្រះកាយពល ទល់ទុក្ខវេទនា ពុំស្រយាល តាំងអំពីព្រលប់ ពុំបានឈប់ឈរ លុះដល់ព្រះអាទិត្យ ឧទ័យរស្មីស្វាងបំព្រាងឡើង ហើយមានព្រះអង្គព្រះនាងនោះញ័រ រន្ធត់ចំប្រប់ នឹងទប់ពុំបាន ព្រះនាងខំលើកព្រះហស្ដទាំង សង ខាង ដាក់លើព្រះសិរសី ខំតម្រង់ព្រះស្មារតី ក្រាបទូល ថា បពិត្រអម្ចាស់វិសេសខ្ញុំអើយ ដើមឡើយ អញខ្ញុំមទ្រី មាន សេចក្ដីប្រាថ្នាក្នុងចិត្តគិត ថា នឹងពិភក្ដិរក្សាបម្រើប្រណិប័តន៍ ល្អងធូលីព្រះបាទ នូវកូនទាំងពីរ ដរាបលុះតែអស់ជីវិត ឥឡូវនេះ កូនខ្ញុំទាំងពីរ ក៏បាត់ទៅហើយ អញខ្ញុំខំរត់រក តាំងអំពីព្រលប់ លុះដល់ថ្មារនេះហើយ ៗ ឱ! អម្ចាស់ខ្ញុំអើយ រីទុក្ខអញខ្ញុំធ្ងន់ ពន់ប្រមាណ ទប់ពុំបានឡើយ អញខ្ញុំសូមក្រាបលា ឱ ! នរណាអើយ នឹងមកប្រណិប័តន៍អម្ចាស់ ឱ្យដូចជាអញខ្ញុំនេះ ព្រះនាងមានព្រះបន្ទូលតែម្លោះហើយ លុះផុតព្រះបន្ទូល ក៏ដួល សន្លប់ទៅលើក្រឡាមហាប្រឹថពី នៅទីចំពោះព្រះភក្ត្រព្រះបរមពោធិសត្វ ព្ធដ៏កាលនោះឯងហោង ៗ

វីព្រះបរមពោធិសត្វ ព្រះអង្គយល់ព្រះនាងដួល សន្លប់ទៅដូច្នោះហើយ ព្រះអង្គភិតភ័យក្នុងព្រះរាជហឫទ័យ ទ្រង់ព្រះចិន្តាថា ព្រះនាងក្ស័យព្រះជន្មា ស្តេចយាងចុះម្នីម្នាអំពីលើព្រះបរមសាលា ទ្រង់សោយព្រះសោកា ថា ឱះឱ! អនិច្ចាមទ្រីអើយ ម្តេចឡើយ មកក្ស័យព្រះជន្មចោលបងតែម្នាក់ឯង នៅកណ្តាលព្រៃភ្នំនេះ នរណាឡើយនឹងជួយលើកព្រះសពនាង មទ្រីអើយ បើក្ស័យព្រះជន្មនៅនគរនាយទៅវ៉ា អស់ព្រះញាតិវង្សា ក្នុងនគរទាំងពីរ នឹងមកប្រជុំព្រមគ្នាជួយលើកព្រះសពនាង ឥឡូវនេះ នៅតែបងម្នាក់ឯង កណ្តោងកំព្រា សមបងនឹងក្ស័យប្រល័យជីវិតតាមនាងជាប្រាកដមិនទេឡើយ លុះព្រះអង្គវិសាយព្រះសោកហើយទ្រង់ព្រះចិន្តា ថា មទ្រីក្ស័យជីវិតមែនពិត ឬដូចម្តេចអេះ ត្រូវអញត្រួតមើលឱ្យបានដឹងពិតប្រាកដសិន ទើបស្តេចដោះឡើង ទ្រង់យកព្រះហស្តស្តាំស្ទាបព្រះឧរារត្នរបស់ក្សត្រី ទ្រង់ជ្រាប ថា មទ្រីនេះ គ្រាន់តែសន្លប់ទេ ទើបស្តេចយកទឹកមកហើយ ទ្រង់ថ្នមលើកត្រកងព្រះសិរសាដាក់តម្កល់លើព្រះឧរូរត្នរបស់ព្រះអង្គៗ វីព្រះបរមពោធិសត្វ ចាប់ដើមតាំងអំពីព្រះអង្គ ទ្រង់ព្រះផ្នួសជាគម្រប់៧ខែហើយ ពុំដែលប៉ះពាល់ព្រះអង្គព្រះនាង ដល់ម្តងឡើយ ទើបតែថ្ងៃនេះ ព្រះអង្គភិតភ័យរលះរលាំងភ្លេចភ្លាំងព្រះស្មារតី ទ្រង់ស្ទាបព្រះឧរាក្សត្រី ថ្នមព្រះសិរសីដាក់លើព្រះឧរូរត្ន ហើយទ្រង់យកទឹកព្រះកុណ្ឌីស្រោចស្រង់ ស្រឡាបព្រះអង្គព្រះនាង ៗ

ទើបព្រះនាងភ្ញាក់ព្រះស្មារតី ភ្លឹករលឹកព្រះអង្គ ទតព្រះនេត្រយល់ព្រះរាជស្វាមី ហើយក៏វិកលព្រះអង្គថយចេញ ទូលដណ្ដឹងសួរអំពីព្រះរាជបុត្រទាំងពីរថា បពិត្រព្រះរាជស្វាមីអម្ចាស់ខ្ញុំអើយ រីព្រះរាជបុត្រាបុត្រីរបស់ខ្ញុំព្រះអង្គ តើទៅឯណាទៅ ។ ព្រះបរមពោធិសត្វ មានព្រះបន្ទូលប្រាប់ថា មទ្រីទេវីអើយ រីកូនយើងទាំងពីរនោះ បងបានឱ្យទៅធ្វើជាខ្ញុំព្រាហ្មណ៍ម្នាក់អំពីថ្ងៃម្សិលរួចទៅហើយ ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណា ពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលសូត្រសានូវបាទព្រះគាថាដូច្នេះ

តមជ្ឈ បត្តំ រាជបុត្តឹ ឧទកេនាភិសិញ្ចថ
អស្សត្ថំ នំ វិទិត្វាន អថ នំ ឯតទព្រវីតិ ។

កាលនោះ ព្រះបាទស្រីវេស្សន្តរបវររាជឫសី ទ្រង់យកទឹកប្រស់ព្រំសព្វព្រះកាយព្រះនាងមទ្រីរាជបុត្រីដែលដល់នូវវិសញ្ញី បាត់ព្រះស្មារតីក្នុងសម្នាក់ព្រះអង្គ លុះព្រះនាងភ្ញាក់ព្រះអង្គ មានព្រះស្មារតីឡើងវិញហើយ ទើបទ្រង់មានព្រះបន្ទូលប្រាប់សេចក្ដីនោះ ឱ្យព្រះនាងបានជ្រាបជាខាងក្រោយ ។

កាលព្រះនាងមទ្រី បានស្ដាប់ព្រះបន្ទូលព្រះរាជស្វាមីហើយ ទើបក្រាបទូលថា បពិត្រព្រះសម្មតិទេពក្សត្រថ្លៃប្រសើរអើយ បើព្រះអង្គទ្រង់ព្រះរាជទានព្រះរាជបុត្រទៅព្រាហ្មណ៍ កាលអញខ្ញុំ

ឱរត់រក កូន ទាំងយំសោកសស្រាក់ អស់មួយយប់ទាល់ភ្លឺ ម្តេចក៏ព្រះអង្គ ពុំមានព្រះបន្ទូលប្រាប់អញខ្ញុំអំពីដើម សោះអញខ្ញុំព្រួយចិត្តជាទុក្ខ ៗ សម្តេចព្រះមហាសត្វត្រាស់តប ថា

អាទិយេនេវ តេ មទ្ទិ ទុក្ខំ នក្ខាតុមិច្ឆិសំ
ទលិទ្ទោ យាចកោ វុឌ្ឍោ ព្រាហ្មណោ ឃរមាគតោ ៗ
តស្ស ទិន្នា មយា បុត្តា មទ្ទិ មា ភាយិ អស្សស
មំ បស្ស មទ្ទិ មា បុត្តេ មា ពាឡ្ហំ បរិទេវយិ
លច្ឆាម បុត្តេ ជីវន្តា អរោគា ច ភវាមសេ ៗ
បុត្តេ បសុញ្ច ធញ្ញញ្ច យញ្ច អញ្ញំ ឃរេ ធនំ
ទជ្ជា សប្បុរិសោ ទានំ ទិស្វា យាចកមាគតេ
អនុមោទាហិ មេ មទ្ទិ បុត្តកេ ទានមុត្តមន្តិ ៗ

ព្រះនាងមទ្រីអើយ ព្រះនាងបន្ទោសបងនេះ ក៏គួរមែនពិត តែគឺមោះ បងគិតថា មទ្រីនេះ ទើបមកអំពីព្រៃ ហើយមានបើជាទុក្ខមកអំពីនាយ បើនឹងប្រាប់ដោយពិត តាំងអំពីដំបូងហើយ នាងរឹងជាទុក្ខធ្ងន់ក្រៃលែង ទប់ទល់ពុំបាន នឹងបែកដើមទ្រូងស្លាប់ទៅ ហេតុនេះ ទើបបងធ្វើជាខឹង ៗ នាងមទ្រីអើយ ព្រាហ្មណ៍ស្ទួមចាស់ ជាអ្នកកម្សត់អត់ឃ្លាន បានមកដល់លំនៅយើងហើយ ឥតមានទេយ្យទានអ្វី ទើបបងយកបុត្រាបុត្រី ឱ្យទៅជាទានព្រាហ្មណ៍ ចូរនាងកុំភ័យព្រួយបារម្ភ ចូរខំតាំងចេតនា ត្រេកអរសោមនស្ស ចូរនាងមើលបងតាងកូន

កុំបីចងចិត្តស្នេហាជាទុក្ខសោកខ្លាំងពេកឡើយ បើយើងឥតរោគមានជីវិតរស់នៅ គង់តែនឹងបានឃើញកូនយើងជាប្រាកដ ៗ នាងមទ្រីអើយ កុំថាឡើយតែកូនប្រុស - ស្រី - សត្វ - ធញ្ញជាតិ ស្រូវអង្ករ និងទ្រព្យមានវិញ្ញាណ ឥតវិញ្ញាណដទៃទៀត ដែលមាននៅក្នុងផ្ទះ ធម្មតាសប្បុរសដែលលោកប្រាថ្នាប្រយោជន៍ដ៏ខ្ពង់ខ្ពស់ កាលបានឃើញស្មូមមកដល់ផ្ទះហើយ លោកអាចពុះទ្រូង រូងយកប្រមាត់បេះដូង លើកឱ្យជាទាន តាមដែលស្មូមត្រូវការ ៗ នាងមទ្រីអើយ ចូរនាងអនុមោទនា ត្រេកអរនឹងបុត្តទាន ដ៏ឧត្តមខ្ពង់ខ្ពស់បំផុត របស់បងនេះហោង ៗ

ទើបព្រះនាងក្រាបបង្គំទូលថ្វាយអនុមោទនា ដោយព្រះគាថា ដូច្នេះ

អនុមោទាមិ តេ ទេវ បុត្តកេ ទានមុត្តមំ
ទត្វា ចិត្តំ បសាទេហិ ភិយ្យោ ទានំ ទទោ ភវ ៗ
យោ ត្វំ មច្ឆេរភូតេសុ មនុស្សេសុ ជនាធិប
ព្រាហ្មណស្ស អទា ទានំ សិវីនំ រដ្ឋវឌ្ឍនោតិ ៗ

បពិត្រព្រះសម្មតិទេពក្សត្រថ្លៃប្រសើរអើយ អញខ្ញុំព្រះអង្គសូមអនុមោទនាបុត្តទាន ដ៏ឧត្តមរបស់ព្រះអង្គ អម្ចាស់អើយ រីកូនអញខ្ញុំនេះ អញខ្ញុំខំថែរក្សា តាំងអំពីនៅក្នុងគភ៌ ១០ ខែ លុះត្រាតែប្រសូតចេញមកហើយ ក៏អញខ្ញុំចិញ្ចឹមបីបាច់រក្សាផ្ងូតទឹក បញ្ចុកបបរបាយ អស់កិច្ចការផងទាំងឡាយ អញខ្ញុំ

សូមថ្វាយអនុមោទនានឹងបុត្តទានរបស់ព្រះអង្គ សូមឱ្យព្រះអង្គបានសម្រេចព្រះពោធិញ្ញាណ បានត្រាស់ជាព្រះពុទ្ធមួយព្រះអង្គស្រង់សត្វផងទាំងឡាយ ឰដ៏អនាគតកាល កុំបីឃ្លាតឡើយ ហើយឯព្រះអង្គសោត ចូរមានព្រះរាជហឫទ័យចម្រើននូវព្រះបីតិត្រេកអរនឹងព្រះបិយបុត្តទាន ឱ្យជាភិយ្យោភាពឡើងទៅហោង។ បពិត្រព្រះអង្គជាអធិបតីនៃប្រជាជន ព្រះអង្គតែងធ្វើសេចក្ដីចំរើនដល់អ្នកស្រីពិរាស្ត្រ គង់នៅក្នុងចំណោមមនុស្សដែលប្រកបដោយសេចក្ដីកំណាញ់ស្វិតស្វាញ ក៏ព្រះអង្គអាច ព្រះរាជទានបុត្រាបុត្រី ឱ្យទៅជាទានព្រាហ្មណ៍ បានសម្រេចដូចព្រះប្រាថ្នា ។

ព្រះបរមពោធិសត្វ មានព្រះបន្ទូលថា សាធុ សាធុ មទ្រីអើយ ពាក្យនាងនេះពីរោះ ៗ ក្រៃពេក មទ្រីអើយ ថាបើបងមិនត្រេកអរនឹងទាននោះ ម្ដេចឡើយ ក៏នឹងកើតមានអស្ចារ្យ កក្រើករំពើកញាប់ញ័រ ទាំងក្រឡាមហាប្រឹថពី នាកាលបងឱ្យកូនទៅជាទាន អំពីថ្ងៃម្សិលមិញនោះឯង ។

លំដាប់នោះ សម្ដេចព្រះនាងមទ្រី ក្រាបទូលថ្លែងហេតុអស្ចារ្យទាំងអម្បាលណោះ ដែលព្រះនាងបានទតឃើញ ជាក់ស្ដែងរួចហើយ ទើបព្រះនាងទ្រង់អនុមោទនាទានបារមីនៃព្រះមហាសត្វ ក្រាបទូលសូត្រជាបាទព្រះគាថា ដូច្នេះ

និន្នាទិតា តេ បឋវី សទ្ទោ តេ តិទិវង្គតោ

សមន្តា វិជ្ជុតា អាគូ គិរីនំ ច បដិស្សុតាតិ ។

នាកាលអញខ្ញុំទៅស្វែងរកផ្លែឈើក្នុងព្រៃ អំពីព្រឹកម្សិលមិញនោះ យល់ចំឡែកអស្ចារ្យ ទាំងមហាមេឃ ក៏មមីរទូទឹម ទាំងភ្នំ ក៏កក្រើក មានសូរស័ព្ទបន្លឺលាន់កងរំពង ទៅដល់ឋានសួគ៌ទេវលោកនាយ ផ្លេកបន្ទោរពុំជូកាល សឹងដ៏ដាលច្រវាត់ អម្ចាស់ខ្ញុំអើយ នេះមិនគឺអ្នកឯណាឡើយ គឺសេចក្តីអស្ចារ្យទានបារមីនៃព្រះអង្គមិនទេឡើយ ។

តស្ស តេ អនុមោទន្តិ ឧភោ នារទបព្វតា
ឥន្ទោ ច ព្រហ្មា ច បជាបតី ច
សោមោ យមោ វេស្សវណោ ច រាជា
សព្វេ ទេវានុមោទន្តិ តាវត្តិំសា សឥន្ទកា ។
ឥតិ មទ្ទី វរារោហា រាជបុត្តី យសស្សិនី
វេស្សន្តរស្ស អនុមោទិ បុត្តកេ ទានមុត្តមន្តិ ។

កាលនោះ អស់ទាំងពួកទេពតាទាំងពីរក្រុម ឋិតនៅភ្នំនារទបព៌ត ព្រមទាំងព្រះឥន្ទ្រ ព្រះព្រហ្ម ស្តេចប្រជាធិបតី ព្រះចន្ទ្រ ព្រះយមរាជ ព្រះវេស្សវ័ណមហារាជ និងពពួកទេវតានៅនាឋានតាវត្តិង្ស មានព្រះឥន្ទ្រាធិរាជជាអធិបតី សឹងមានបីតិត្រេកអរ ថ្វាយសព្ទសាធុការអនុមោទនា ព្រមគ្នាថា បពិត្រព្រះវេស្សន្តរក្សត្រថ្លៃប្រសើរអើយ ព្រះអង្គបរិច្ចាគទានហើយ ដោយប្រពៃក្រៃលែង ។

ឯសម្តេចព្រះនាងមទ្រីស្រីរត្នកញ្ញា ដ៏ទ្រង់លក្ខណាប្រសើរ ជាព្រះរាជបុត្រីដ៏ទ្រង់យស មានព្រះរាជហឫទ័យ ស្ម័គ្រស្មោះ ថ្វាយអនុមោទនា ចំពោះបុត្តទានបារមីដ៏ឧត្តម របស់ព្រះបរមពោធិសត្វមហាបុរសរត្ន ព្រមលួមជាមួយគ្នា ដោយនូវប្រការអម្បាលនេះហោង ៗ

មទ្ទីបព្វំ និដ្ឋិតំ បពិត្រអើយ អាត្មាភាពសម្តែងថ្លែងព្រះធម៌វិសេសទេសនា ព្រះមហាជាតក៍ **កណ្ឌមទ្រីបព្វៈ** ទី ៩ នេះមិញ ដ៏ប្រដាប់ប្រដានីទៀនូវគាថា ៩០ គាថា ឯទំ ក៏ចប់បរិបូណ៌សមគួរ ដោយនូវវេលានេះឯងហោង ៗ

ចប់ កណ្ឌមទ្រីបព្វៈ ទី ៩ តែប៉ុណ្ណោះ ៗ

⁂

ចម្លងចប់នៅថ្ងៃ ៤ រោច ខែជេស្ឋ ព.ស. ២៥៣៣
ត្រូវនឹងថ្ងៃច័ន្ទ ទី ១១ ខែមិថុនា គ.ស. ១៩៩០

មហាវេស្សន្តរជាតក

ទី ១០



កណ្ឌសក្កបព្វៈ

ប្រដាប់ដោយគាថា ៤៣

មហាវេស្សន្តរជាតក

ទី ១០

កណ្ឌសក្កបព្វៈ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ឯវន្តេសុ អញ្ញមញ្ញំ សម្មោទនីយំ កថំ កថេន្តេសុ សក្កោ ទេវរាជា ចិន្តេសិ អយំ វេស្សន្តរមហារាជា ហិយ្យោ ជូជកស្ស បថវឹ ឧន្នាទេត្វា ទារកេ អទាសិ ឥទានិ នំ កោចិ ហីនបុរិសោ ឧបសង្កមិត្វា សព្វលក្ខណសម្បន្នំ សីលវតឹ មទ្ទឹ យាចិត្វា រាជានំ ឯកកំ កត្វា មទ្ទឹ គហេត្វា គច្ឆេយ្យ តតោ ឯស អនាថោ និប្បច្ចយោ ភវេយ្យ យន្នូនាហំ ព្រាហ្មណវណ្ណេន នំ ឧបសង្កមិត្វា មទ្ទឹ យាចិត្វា បារមីកូដំ គាហាបេត្វា កស្សចិ អវិស្សជ្ជនីយំ កត្វា បុន តំ តស្សេវ ទត្វា អាគមិស្សាមីតិ ។

តេសុ ខត្តិយេសុ នាកាលព្រះបរមពោធិសត្វ ខត្តិយនរេស្សរ៍ ព្រះវេស្សន្តរបវរពុទ្ធវង្ស ទ្រង់ព្រះរាជសទ្ធា ទាំងសម្តេចព្រះជាយានារីស្រីសុន្ទរបវរក្សត្រី សម្មោទនីយំ ទាំងពីរព្រះអង្គ ទ្រង់ព្រះសោមនស្សាភិរម សន្សំព្រះបិយបុត្តទាន ទ្រង់ក្សេមក្សាន្តព្រះរាជហឫទ័យ នៅព្ធដ៏ព្រៃគន្ធមាទន៍ សក្កោ

ទើបសម្តេចព្រះអម្រិន្ទ្រឥន្ទកោសិយ ទ្រង់នឹកក្នុងកំឡុងព្រះរាជហឫទ័យ ដើម្បីជាប្រយោជន៍នៃព្រះបរមពោធិសត្វ អ្នកនឹងបានត្រាស់ព្រះសម្មាសម្ពោធិញ្ញាណ ហិយ្យោ នាថ្ងៃអម្សិលមិញនោះ ព្រះអង្គព្រះរាជទានព្រះរាជបុត្រាបុត្រី លើកយកព្រះបរមត្ថបារមីដ៏ជាមកុដនៃទាន ឱ្យទៅជូជកជាអ្នកកម្សត់ អត់ឃ្លាន លំបាកថ្មើរព្រៃ ដ៏ជាមហៃមហាឧឡារិកពេកក្រៃ នៅតែវរវត្តរាជកញ្ញាមទ្រីមហេសី អើ! បើអញនឹងស្ងៀមនៅយល់ជាបង់សេចក្តីពុំខាន ក្រែងមានអ្នកដូជាតិថយសក្តិ នឹងមកកាន់សម្នាក់ សុំព្រះអគ្គមហេសី ព្រះអង្គក៏នឹងលើកយកព្រះមទ្រីឱ្យទៅជាទាន ត្បិតទ្រង់ពុំដែលមានព្រះរាជហឫទ័យ រួញរាឡើយ ៗ ឱះ ឱ! អនិច្ចាអើយ សមនឹងសាបសូន្យព្រះវង្ស ដ៏ជាមង្គលក្សត្រី ឥតបីអ្នកនឹងប្រណិប័តន៍ឧបដ្ឋាក ក៏នឹងវំលៀងចេញចាកវត្តចរិយា ព្រះអង្គចម្រើនមេត្តា ក៏នឹងសង្វេគព្រះទ័យតែព្រះអង្គឯង វែងជាអាងខ្នាង នៅក្នុងព្រៃព្រឹក្សា អាត្មាអញនឹងស្ងៀមនៅពុំបាន ចាំភៀសប្រាណ ចុះទៅកាន់សម្នាក់ព្រះអង្គ សូមឱ្យទ្រង់ព្រះរាជទានព្រះមទ្រី ឱ្យបានគ្រាន់តែជាហេតុបន្តិចហើយ សន្សឹមអញថ្វាយសម្តេចព្រះពុទ្ធវង្សវិញ ទើបក្សត្រទាំងពីរព្រះអង្គ នឹងបានគង់នៅក្សេមក្សាន្ត សម្រាន្តព្រះរាជហឫទ័យ នៅឰដ៏ព្រះអាស្រមបទនោះឯងហោង ៗ

តមត្ថំ បកាសេន្តោ សត្ថា អាហ គឺអាថ៌ធម៌ឯណា ពុំ

ទាន់ប្រាកដ បទព្រះបាលីឯណា ពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលសូត្រសានូវបាទព្រះគាថាដូច្នេះ

តតោ រត្យា វិវសនេ សុរិយស្សុគ្គមនំ បតិ
សក្កោ ព្រាហ្មណវណ្ណេន បាតោ តេសំ អវិស្សថាតិ ។

ភិក្ខវេ ម្នាលសង្ឃដ៏ទ្រង់សីលសមាធិបញ្ញា តតោ រត្យា នាកាលអរុណោទ័យ រស្មីភ្លឺស្រឡះបំព្រាងស្រាងស្រេច សម្ដេចព្រះសហស្សនេត្រ ប្លែងភេទដោយមហិទ្ធិរិទ្ធិនិម្មិត ឱ្យដូចជាព្រាហ្មណ៍ស្ពាយយាម កាន់ឈើច្រត់រំពាត់ឫសី សំបុរលឿងទុំបន្សំនូវអស់គ្រឿងបរិក្ខារ ធ្វើអាការកិរិយា ពុំឱ្យក្សត្រទាំងពីរព្រះអង្គសង្ស័យព្រះទ័យឡើយ ដើរទន្ទបលលប ចូលដល់ហើយអង្គុយនាមុខព្រះអាស្រម លើកហត្ថាប្រណម្យនមស្ការ ក្រាបទូលសួរ ដោយបាទគាថា ដូច្នេះ

កច្ចិ នុ ភោតោ កុសលំ កច្ចិ ភោតោ អនាមយំ
កច្ចិ ឧញ្ឆេន យាបេថ កច្ចិ មូលផលា ពហូ ។
កច្ចិ ឌំសា មកសា ច អប្បមេវ សិរីសបា
វនេ វាឡមិគាកិណ្ណេ កច្ចិ ហឹសា ន វិជ្ជតីតិ ។

ភោ តាបស បពិត្រព្រះតាបសដ៏មានព្រះទ័យសប្បុរសអើយ កច្ចិ នុ ខ្ញុំតាជីសុំសួរអំពីទុក្ខសោករោគាដែលយាយីព្រះកាយ ឬមួយពុំមានសេចក្ដីក្ដៅក្រហាយ រំជួលក្នុងព្រះអង្គ ឬមួយ ស្ដេចគង់ចម្រើនមេត្តាភាវនា អស់ពាឡម្រឹគា តើញុំាង

មានមករំលាយរំលាងព្រះអាស្រម ឬមួយ ទ្រង់ចម្រើនព្រហ្មវិហារសាមគ្គីញាណ អស់សត្វផងពុំហ៊ានមកពាធាទេ មូលផលា ពហូ មួយសោត ផលាហារនៅនាឋាននេះ តើញុំាងមានបរិបូណ៌ពុំក្រគ្រាន់រកឆាន់បាន ឬពុំសូវមានទេព្រះអង្គ ទាំងមមាច មមង់ មូស សុច ស្រាំង ស្រួយ ពស់ កែ្អប ខ្ទួយ មោះមកឆីឈាមជាអាហារ ឬមួយបណ្ដាលពុំឱ្យកើតមាន ស្ដេចគង់នៅក្សេមក្សាន្តទេណា អម្ចាស់ បពិត្រពុំគួរណាស់ តាមតែទ្រង់ព្រះករុណាអត់ទោស សន្ដោសប្រោសប្រាណប្រណីខ្ញុំតាជីចាស់ជរា នាកាលគ្រានេះឯងហោង ។

ឯវំ វុត្តេបិ មហាសត្តោ កាលឥន្ទព្រាហ្មណ៍ ក្រាបបង្គំទូលយ៉ាងនេះហើយ ទើបព្រះពន្លកពុទ្ធវង្ស ទ្រង់សំណេះសំណាលរាក់ទាក់តបទៅតាជីព្រាហ្មណ៍ មានព្រះបន្ទូលសូត្រជាបាទព្រះគាថា ដូច្នេះ

កុសលញ្ចេវ នោ ព្រហ្មេ   អថោ ព្រហ្មេ អនាមយំ
អថោ ឧញ្ឆេន យាបេម   អថោ មូលផលា ពហូ ។
អថោ ឌំសា មកសា ច   អប្បមេវ សិរីសបា
វនេ វាឡមិគាកិណ្ណេ   ហឹសា មយ្ហំ ន វិជ្ជតិ ។
សត្ត នោ មាសេ វសតំ   អរញ្ញេ ជីវិសោកិនំ
ឥទំបិ ទុតិយំ បស្សាម   ព្រាហ្មណំ ទេវវណ្ណិនំ
អាទាយ វេឡុវំ ទណ្ឌំ   ធារេន្តំ អជិនក្ខិបំ ។

ស្វាគតន្តេ មហាព្រហ្មេ អថោ តេ អទុរាគតំ
អន្តោ បវិស ភទ្ទន្តេ បាទេ បក្ខាលយស្សុ តេ ។
តិណ្ឌុកានិ បិយាលានិ មធុកេ កាសមារិយោ
ផលានិ ខុទ្ទកប្បានិ ភុញ្ជ ព្រហ្មេ វរំ វរំ ។
ឥទំបិ បានិយំ សីតំ អាភដំ គិរិគព្ភរា
តតោ បិវ មហាព្រហ្មេ សចេ ត្វំ អភិកង្ខសីតិ ។

ព្រាហ្មណ៍អើយ រីទុក្ខសោករោគា ម្រឹគពាឡយង់ឃ្នង ក៏ពុំមានមកប៉ឹងបៀតបៀនពាធាយាយី នៅសព្វថ្ងៃប្រក្រតីសឹងសុខសប្បាយ ឯអស់ផលាផលផងទាំងឡាយដែលឆាន់ ក៏មានពាសពេញដោយព្រៃគ្រាន់ប្រស្រ័យបេះបានបរិភោគពុំសូវក្រណា តាជី អើ! ពីដូចយើងចេញចាកបុរីមកបួសជាតាបស សត្តនេវ មាសេ ក៏បាន ៧ ខែ ប្លាយ ហើយ អរញ្ញេ ជីវិសោកិនំ ព្រាហ្មណ៍អើយ ពុំបានយល់មុខអ្នកឯណាមួយទៅមក ដល់អាយយល់តែសត្វផងទាំងឡាយបានជាគ្នាកំដរក្នុងព្រៃ គ្រាន់កក់ក្ដៅព្រះរាជហឫទ័យល្ហែល្ហើយ ទើបតែថ្ងៃនេះ បានយល់មុខតាជីអាចារ្យប្រកបប្រការនូវស្រីសួស្ដីឧត្តមសមតាមសៃយភេទ ឥទំបិ ឧតិយំ ពុំឃ្លាតលង្វែកយូរជាគម្រប់ពីរដងបរិបូណ៌ តាំងអំពីម្សិលមិញនោះ ក្នុងចិត្តស្មោះសរត្រេកអរ ឥតឧបមា អើព្រាហ្មណ៍អើយ សង្វាតយាត្រាមកដល់អាស្រម កុំបារម្ភក្រែងចិត្តយើងឡើយណាព្រាហ្មណ៍ តាមតែចិត្តនឹកចុះ បក្ខាលយស្សុ

អញ្ជើញងូតទឹកជម្រះញើសក្អែល ឱ្យក្សេមក្សាន្តត្រអាល ភុញ្ជព្រហ្មោ អស់ផលាហារដែលឆាន់សល់អំពីម្សិលមិញ ក៏មានគ្រប់ពណ៌ទាំងឡាយ ខ្នុរ ស្វាយ ព្រីង ព្រួស ជន្លួស ព្និល ព្នៅ ត្រាវ ដំឡូង ដូង ដងអង្កាល់ មង្ឃុត ល្មុត សេដា ម័កប្រេង ម័កប្រាង លាំងសាត សីរមាន់ សឹងដ៏មានរសពីសា ពុំជូរចត់ល្វីងឡើយ ទាំងទឹកឃ្មុំផ្អែម ៗ ដ៏ជាចំណីព្រៃ តាមតែរើសឆាន់ក៏មាននៅនាឋាននេះឯងហោង ៗ

ឯវំ តេន សទ្ធឹ បដិសណ្ឋារំ កត្វា មហាសត្តោ អាហ ព្រះបរមពោធិសត្វ សំណេះសំណាល សាកសួរឥន្ទព្រាហ្មណ៍ ជាការគួរសមតាមទំនៀម ទើបមានព្រះបន្ទូល ថា

អថ កេន វណ្ណេន កេន វា បន ហេតុនា
អនុប្បត្តោសិ ព្រហារញ្ញំ តំ មេ អក្ខាហិ បុច្ឆិតោតិ ៗ

អើ ! យើងសូមសួរណាព្រាហ្មណ៍ ឯព្រៃខេត្តខេម ព្រះហេមពាន្តនេះ កម្រអ្នកឯណានឹងដើរមកដល់ តាជីចាស់ជរាទុព៌លគ្រាំគ្រា ខ្នងកោងកំពក ឧស្សាហ៍ដើរជជ្រុលជជ្រក មកដល់អាយ ខ្វល់ខ្វាយរកថ្នាំធ្វើជាគ្រូពេទ្យ ឬមួយវង្វេងផ្លូវមកដល់ឋាននេះ ឬមួយសំណេះចង់មករកយើង នៅនាឋានអាយ ចូរតាព្រាហ្មណ៍ប្រាប់យើង នាកាលឥឡូវនេះឯងហោង ៗ

ឯឥន្ទព្រាហ្មណ៍ ទ្រង់បានស្តាប់ព្រះរាជឱង្ការ ស្មានស្មោះពីរោះសោះសា ក្រាបបង្គំទូលថា បពិត្រព្រះមហារាជសម្ភារ

ដ៏ជាឥសូរបណ្តូលជិនវង្សប្រសើរអើយ រីខ្ញុំតាជីនេះ ជាមនុស្សចាស់ជរា ខ្ញុំត្រាច់លីលាមកដល់សម្នាក់ព្រះអង្គនេះ ប្រាថ្នាតែមកសុំសម្តេចព្រះនាងមទ្រីរាជកល្យាណី ដ៏ជាព្រះអគ្គមហេសីនៃព្រះអង្គ សូមទ្រង់ប្រោសព្រះរាជទានមកខ្ញុំតាជី ក្នុងកាលឥឡូវនេះ ហើយឥន្ទព្រាហ្មណ៍ក្រាបទូលសូត្រជាបាទព្រះគាថា ដូច្នេះ

យថា វារិវហោ បូរោ សព្វកាលំ ន ខីយតិ
ឯវន្តំ យាចិតាគច្ឆី ភរិយំ មេ ទេហិ យាចិតោតិ ៗ

បញ្ច មហានទិយោ បពិត្រអម្ចាស់អើយ ខ្ញុំតាជីនឹងឧបមាព្រះរាជហឫទ័យ ប្រដូចនូវមហានទីទាំង ៥ គឺ គង្គា យមុនា អចិរវតី មហី មហានទី តែងតែមានទឹកហូរ ជ្រួតជ្រាបសព្វជ្រោះជ្រលងដងស្ទឹង ហើយហូរធ្លាក់ទៅក្នុងសមុទ្រពុំដែលផុតដាច់ខានឡើយ ៗ បពិត្រអម្ចាស់អើយ សព្វសត្វមច្ឆា អណ្តើក បបែល កុម្ភីល ត្រសែ តែងមកអាស្រ័យព្រះគង្គា អស់មនុស្សម្នាប្រជាជនផង ទៅមកចុះបាចសាចងូត ផឹកដងដាក់ក្រឡ ពិនួង តាមប្រាថ្នា ព្រះគង្គានោះ ពុំដែលស្រកស្រុតរីងហែងហួតឡើយ ៗ បពិត្រអម្ចាស់អើយ គួរនាបីដូចព្រះរាជហឫទ័យព្រះអង្គ លះបង់មច្ឆរិយធម៌បាន តែងទ្រង់ប្រោសប្រាណអស់សព្វសត្វលំបាកតោកយ៉ាកផង បើចេញពាក្យសុំអ្វី ក៏សឹងបានដូចចិត្ត ទាំងនេះ ខ្ញុំតាជីពោលពាក្យពិត ពុំមុសា ៗ មួយសោត ខ្ញុំតាជី ក៏ចាស់ជរាណាស់ហើយ ពុំដូច

កាលពីមុនឡើយ ដែលខ្លួននៅកំឡោះ ឥឡូវមានរោគា មកបៀតបៀនក្នុងអង្គ ទាំងត្រចៀកក៏ថ្លង់ ភ្នែកក៏ងងឹត ទាំងញាតិសាច់ទៀបជិតក៏ស្លាប់បាត់បង់អស់ហើយ ព្រះគុណអើយ សព្វថ្ងៃនេះ នៅកំព្រាទីទ័ល ទោះបីផ្លូវកម្រឆ្ងាយប៉ុន្មានក្តីក៏មិនថា ឧស្សាហ៍ជជ្រុលជជ្រែក ឱ្យបានមកដល់អម្ចាស់ ពុំគួរណាស់ តាមតែទ្រង់ព្រះមេត្តាប្រោសអត់ទោសត្រាប្រណី ខ្ញុំតាជី សូមព្រះរាជទានសម្តេចព្រះរាជមទ្រីទៅធ្វើជាមេផ្ទះ គ្រាន់បានជាគ្នាកំដរខ្ញុំតាជីចាស់ជរាសោះស្វាត់ សូមព្រះអង្គកាត់ឱ្យជាទានយឹតយកសារពេ៌ជ្ញតាញ្ញាណ យកព្រះមទ្រីបរិច្ចាគ ឱ្យជាទានខ្ញុំតាជី នាកាលគ្រាឥឡូវនេះឯងហោង ។

ឯទំ ទុត្តេបិ មហាសត្តោ សម្តេចព្រះបរមពោធិសត្វបាន ស្តាប់ឥន្ទព្រាហ្មណ៍ក្រាបទូលថ្លែងសេចក្តីលំបាកទាំងនោះ តាំងចិត្តស្មោះចំពោះមកសូមព្រះរាជទានព្រះអគ្គជាយា នាថ្ងៃនោះ ព្រះអង្គក៏ស្មោះសរក្នុងព្រះរាជហឫទ័យ មិនមានសង្ស័យរួញរា ត្បិតអំពីថ្ងៃម្សិល ទ្រង់ព្រះរាជទានបុត្រាបុត្រីទៅជូជកព្រាហ្មណ៍ ដល់មកថ្ងៃនេះ យើងនៅក្នុងព្រៃតែម្នាក់ឯង នឹងលើកសម្តេច ព្រះនាងមទ្រី ឱ្យទៅជាទានព្រះស្តែង ដូចម្តេចបាន ព្រះអង្គនឹងមានព្រះរាជហឫទ័យធុចថយរួញរា ដូច្នេះ ឥតអន្តីខានឡើយ ហេតុតែព្រះអង្គស្រឡាញ់សារពេ៌ជ្ញតាញ្ញាណ ឧបមាបីដូច អ្នកខ្សត់ទ្រព្យ មានបុគ្គលអ្នករាប់យកមាសប្រាក់មកចាក់គរឱ្យដល់ដៃ

ព្រះកក្រញញឹមប្រិមប្រិយ មានព្រះបន្ទូលថ្លែងនូវព្រះគាថានេះថា

ទទាមិ ន វិកម្បាមិ យំ មំ យាចសិ ព្រាហ្មណ
សន្តំ នប្បដិគុយ្ហាមិ ទានេ មេ រមតេ មនោតិ ។

ម្នាលព្រះស្តែងព្រាហ្មណ៍អើយ យើងនឹងលើកសម្តេច ព្រះភគវតីនាងមទ្រី ឱ្យជាទានតាជី តាមសេចក្តីសុំ យើងមិនមានចិត្តរំភើបរួញរានឹងការបរិច្ចាគទាន ព្រោះចិត្តយើងត្រេកអរនឹងទាន ពុំដែលមានលាក់បំបាំងរបស់អ្វីនឹងស្មូមយាចកឡើយ អើតាជី កុំថាឡើយតែនាងមទ្រីជាពាហិរទាន បើមានស្មូមមកបឹងប្រាថ្នាសាច់ ស្អួត ថ្លើម ដង្ហើមប្រមាត់ ក៏នឹងកាត់ឱ្យជាទានតាមសុចរិត យកជីវិតឱ្យជាទាន ដូរយកសាពេជ្ញតាញាណសាស្តាចារ្យ ប្រាថ្នាតែបានត្រាស់ជាព្រះពុទ្ធនាំអស់សព្វសត្វឆ្លងវដ្តសង្សារ ទៅកាន់ត្រើយព្រះអមតមហានិព្វាននាយ នោះហោង ។

លុះព្រះមហាសត្វមានព្រះបន្ទូលយ៉ាងនេះហើយស្រេច ស្តេចយកព្រះកុណ្ឌីផងព្រះឧទកៈ ច្រួចលើដៃព្រាហ្មណ៍ភ្លាម ទ្រង់ព្រះរាជទានព្រះអគ្គជាយាទៅឥន្ទព្រាហ្មណ៍ពុទ្ធក៏កាលនោះឯងហោង ។ ហេតុអស្ចារ្យផ្សេង ៗ ក៏កើតមានប្រាកដព្រមល្មមគ្នា ក្នុងខណៈនោះ ដូចកាលព្រះអង្គទ្រង់ព្រះរាជទានព្រះរាជបុត្រាបុត្រី ទៅជូជកព្រាហ្មណ៍ព្រឹទ្ធាចារ្យ ។

តទត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណា ពុំ

ទាន់ប្រាកដ បទព្រះបាលីឯណា ពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលសូត្រសានូវបាទព្រះគាថាដូច្នេះ

មទ្ទី ហត្ថេ គហេត្វាន   ឧទកស្ស កមណ្ឌលុំ
ព្រាហ្មណស្ស អទា ទានំ   សិវីនំ រដ្ឋវឌ្ឍនោ ។
តទាសិ យំ ភឹសនកំ   តទាសិ លោមហំសនំ
មទ្ទី បរិច្ចជន្តស្ស   មេទនី សមកម្បថ ។
នេវស្ស មទ្ទី ភកុដី   ន សន្ធីយតិ ន រោទតិ
បេក្ខតេវស្ស តុណ្ហិយា   ឯស ជានាតិ យំ វរន្តិ ។

កាលនោះ សម្តេចព្រះមហាសត្វ ទ្រង់កាន់ព្រះករបវររាជមទ្រី រួចទ្រង់ចាប់យកព្រះកុណ្ឌី ច្រួចព្រះឧទកវារីហៀវហូរ ជាសញ្ញាថា ទ្រង់ព្រះរាជទានសម្តេចព្រះមទ្រី ទៅព្រាហ្មណ៍ជ្រះស្រឡះហើយ ដោយទ្រង់មានព្រះរាជហឫទ័យប្រកបដោយ ត្រៃហេតុបរមត្ថ ជាមហាមកុដនៃទាន ទើបមានព្រះរាជឱង្ការថា អើតាជី មទ្រីនេះជាសំឡាញ់ជាប្រធាន មានពិព្យាយាមតាមមកប្រណិប័តន៍ តាំងសាងព្រ័តនៅក្នុងព្រៃ ទុកស្មើព្រះនេត្រនៃយើងមិញ យើងមិនស្រឡាញ់ស្មើនឹងព្រះសព្វញ្ញុតញ្ញាណ បាន ១ សែនកម្លាំងទេ ឥទំ ទានំ រីទានទាំងនេះ សូមជាបច្ច័យបានត្រាស់នូវព្រះបរមាភិសម្ពោធិញាណ ជាឯកអគ្គបុគ្គល នាំសត្វឆ្លងចាកវដ្តសង្សារ ឱ្យបានដល់ត្រើយគឺព្រះនិព្វានទៅអនាគតកាលនោះឯងហោង ។

(វុត្តម្បិ ចេតំ ពាក្យនេះសមដូចបាលីគាថាដែលលោកសម្ដែងទុកក្នុងគម្ពីរចរិយាបិដក ដូច្នេះ

ជាលឹ កណ្ហាជិនំ ធីតំ   មទ្ទឹ ទេវឹ បតិព្វតំ
ចជមានោ ន ចិន្តេសឹ   ពោធិយាយេវ ការណា ៗ
ន មេ ទេស្សា ឧភោ បុត្តា   មទ្ទី ទេវី ន អប្បិយា
សព្វញ្ញុតំ បិយំ មយ្ហំ   តស្មា បិយេ អទា សហន្តិៗ

កាលតថាគតនៅជាព្រះវេស្សន្តរ បានបរិច្ចាគលះបង់ជាលីក្រស្នានិងសម្ដេចព្រះរាជមទ្រីទេវី ដ៏មានវត្តប្រណិប័តន៍ដ៏ប្រពៃឱ្យជាទានព្រាហ្មណ៍ តថាគតមិនមានចិត្តគិតសោកស្ដាយសោះឡើយ ព្រោះតថាគតប្រាថ្នាតែឱ្យបានសម្រេចព្រះពោធិញ្ញាណប៉ុណ្ណោះ ៗ មួយវិញទៀត ព្រះរាជបុត្រទាំងពីរ តថាគតមិនស្អប់ខ្ពើមទេ ទាំងសម្ដេចព្រះមទ្រីទេវីសោត ក៏មិនមែនតថាគតមិនស្រឡាញ់ដែរ ប៉ុន្តែ តថាគតស្រឡាញ់សព្វញ្ញុតញ្ញាណក្រៃលែងផាង ហេតុហ្នឹងហើយបានជាតថាគតបានឱ្យរបស់សំឡាញ់ទៅជាទានដូរយកព្រះសព្វញ្ញុតញ្ញាណក្នុងកាលនោះឯងហោង① ៗ

នាកាលព្រះបរមពោធិសត្វ ទ្រង់ព្រះរាជទានព្រះអគ្គជាយាទៅនន្ទព្រាហ្មណ៍ ក៏កើតមានអស្ចារ្យកក្រើក ញាប់ញ័រ សព្វសកលលោកធាតុ តាំងអំពីអជដាកាស ក៏កើតកោលាហល

---

① ក្នុងវង់ក្រចកនេះ មិនមានច្បាប់មហាជាតក៏សម្រាយទេ តែក្នុងទីនេះ បានស្រង់បាលីប្រែបំពេញតាមច្បាប់អដ្ឋកថាជាតកបាលីដើម ៗ

រីខ្យល់ទ្រទឹកបក់បោកទៅមកសព្វទិសទី រីទឹករងព្រះធរណី ក៏ក្តៅពុះពោររំជោរជន់ ជាចលាចលដីកម្រាស់ ២ សែន ៤ ម៉ឺនយោជន៏ ក៏ពុំអាចទប់បាន ដូចនឹងរលាយរលំលាន់គគ្រេងគគ្រាំទាំងពសុធា **មត្តខាវរណោវ ខិយ** បីដូចគជសារចុះប្រេងឧទារជ្រួតជ្រាបងាបមាត់រត់រោទ៍ ស្រែកសំទារ ពុំក្រែងខ្លាចដូចថ្មោះសារពើសត្វគោព្រៃ ប្រើស ខ្លា ទ្រាយ ទន្សាយ សិង្ហ សីហ៍បណ្តាសព្វសត្វនៅដីសឹងភិតភាំងរលះរលាំង ស្ទុះផ្លោះចេញពីលំនៅ រត់ទៅជជ្រុលជជ្រកសព្វព្រៃ រីគជសីហ៍ក៏ស្រែកសំទារអឺអឹង **ភឹសនភំ** ខ្ញរខ្ញីរទ្រហឹងជាពន្លឹក មុខគួរឱ្យភិតភ័យសូរសព្ទ អាកាសចុះអ័ព្ទងងឹតទាំងវេហាស៍ **ឈោវមហំសនំ** កើតជារងាព្រឺស្រៀវស្រាញស្ញប់ស្ញែង **អភវលខិដ្ឋុតាវ** ពុំជារដូវភ្លៀង ក៏កើតមានផ្លេកបន្ទោរងាលងាស នាអាកាសវិថី អសនីរស្មី ពព្លាម លលាម ឆ្វៀលឆ្វាត់ ដូចរត្នមណី ជុំប្រឹថពីមណ្ឌលចក្រវាឡ ក៏កើតបណ្តាលជាខ្យល់ព្យុះបោកបក់ ឮសព្ទគគ្រឹកគគឹកទាំងវេហាស៍ អស់ព្រៃព្រឹក្សាក៏បាក់ផ្ទួងផាងរលំ **សវគរវ** ទាំងសមុទ្រសាគរ ដ៏ធំធេង ក៏លាន់សំឡេងចរឆចឆា គគ្រឹកគគ្រេង បោកបែកជាផ្កាត្រែង ត្រាពាសពេញជាពពុះទាំងព្រះគង្គាអស់ហ្វូងតិមិតិមង្គលា មច្ឆាផង ក៏ហែលឆ្វៀលឆ្វាត់ វេរា ហ្វូងមករហែលជារង់ អស់ស្តេចនាគភុជង្គអនេកនានា នាងនាគីនិម្មិត្តជាមាណា បន្សាត់មកថ្វាយ ក្បែមក្សាន្តសប្បាយ តាមជលធី

សិនេរុបព្វតរាជា ទាំងភ្នំសិនេរុរាជគិរី ពុំអាចនឹងនៅ ក៏ទោរទន់ទៅមក ហាក់ដូចនឹងរលំ ដូចអភិវាទក្រាបថ្វាយបង្គំព្រះបរមពោធិសត្វ **ខេត្តន្តរេ ខិយ** បីដូចអ្នកកាន់ចុងដំបងទងផ្តៅរោលភ្លើង ហើយលើកឡើងបញ្ឈរ សឹងដ៏ទន់ទោរ ទាំងឆកាមាវចរសួគ៌ **ឆទេវគណា** ទាំងសោឡសសួគ៌ា ក៏ក្សេមក្សាន្តបូជាបុប្ផា ខ្លះប្រោយរាយសុគន្ធមាលាបារិកជាតិ នាកណ្តាលនភាកាស ក៏ប្រគំសំឡេងត្រែស័ង្ខ ភេរីតូរ្យតន្ត្រី ល្វើយល្វេង ខ្លះច្រៀងសរសើរព្រះសម្ភារ ថ្វាយសព្វសាធុការព្រះអង្គបពិត្រម្ចាស់អើយ សូមព្រះអង្គមានព្រះជន្មដ៏លង់ ១ ពាន់ ព្រះវស្សា ពុំមានអ្នកឯណាស្មើនឹងព្រះអង្គបាន ត្បិតព្រះអង្គ ជាពង្សពុទ្ធង្កុរគួរបូជា **ឯកកោលាហលំ** រីឯព្យោមា គឺព្យុះភ្លៀងខ្យល់ កក្រើកសព្វសកលលោកធាតុ តាំងអំពីអជដាកាសទៅដល់សុទ្ធាវាសមហាព្រហ្ម ក្សេមក្សាន្តអភិរម ស្មើឯកអង្គានាកាលព្រះអង្គពើកយកព្រះអគ្គជាយា ឱ្យជាឧត្តមបរមទានដល់ឥន្ទព្រាហ្មណ៍ព្រឹទ្ធាចារ្យ ក្នុងកាលនោះឯងហោង ។

ភិក្ខវេ ម្នាលសង្ឃដ៏ទ្រង់សីលសំវរៈ នាកាលសម្តេចព្រះវេស្សន្តរបវរពុទ្ធង្កុរ ព្រះអង្គព្រះរាជទានព្រះមទ្រីឱ្យទៅតាជីចាស់ជរា ទ្រង់ព្រះចិន្តាគិតបារម្ភ ត្បិតពុំសមសេចក្តី ក្រែងពុំត្រូវព្រះរាជហឫទ័យនៃព្រះអគ្គជាយា នឹងរួញរាថុចថយសទ្ធា បណ្តាលឱ្យកើតទុក្ខសោកា តាមធម្មតាប្រពៃណីលោកិយ បើក្រមុំកំឡោះ

នោះទើបសមនឹងគ្នា ឥឡូវនេះ នាងបានទៅព្រាហ្មណ៍ចាស់ជរាព្រឹទ្ធាចារ្យ ជាមនុស្សអន្ធការហីនទ្រព្យអប្បយសសក្តិ យល់ជានាងនឹងធ្លាក់ថ្លស់ ពុំពេញព្រះរាជហឫទ័យ ធម្មតាវិស័យចិត្តលោកិយផងទាំងឡាយ ពុំដែលចៀសឆ្ងាយពីគ្នា ទើបសម្តេចព្រះបរមរាជា ស្តេចឆ្មៀងព្រះនេត្រទតមើលព្រះអគ្គមហេសី ឱ្យបានជ្រាបអាការកិរិយា ៗ ឯព្រះនាងក៏បានដឹង ក្នុងព្រះប្រាជ្ញាអធ្យាស្រ័យ ដឹងក្នុងព្រះរាជហឫទ័យព្រះស្វាមី ទើបព្រះនាងលើកអញ្ជលីអភិវាទ ក្រាបបង្គំទូល ថា

កោមារី យស្សាហំ ភរិយា សាមិកោ មម ឥស្សរោ
យស្សិច្ឆេ តស្ស មំ ទជ្ជា វិក្កិណេយ្យ ហនេយ្យ វាតិ ៗ

បពិត្រម្ចាស់អើយ កុំថាតែព្រះអង្គឱ្យទានខ្ញុំ ទៅព្រាហ្មណ៍ចាស់ជរា ក្រែងអាក់អន់ចិត្ត ព្រះគុណអើយ បើព្រាហ្មណ៍គាត់ប្រាថ្នាសាច់ឈាម ថ្លើម ដង្ហើម ប្រមាត់ ក៏សូមស្តេចយកព្រះខ័នកាត់ខ្ញុំមទ្រីនេះចេញ បំពេញព្រះបារមីទាន ឬមួយក្រែងព្រាហ្មណ៍មានបើប្រាថ្នានឹងចង់យកជាទ្រព្យ គឺមាសប្រាក់ កែវកងសព្វពិធវត្ថុផងទាំងឡាយ ក៏សូមស្តេចនាំមទ្រីទៅចំណាយ យកជាទ្រព្យមកគរបំពេញព្រះរាជសទ្ធា ឱ្យទៅជាទានព្រាហ្មណ៍ ខ្ញុំមទ្រីពុំមានចិត្តរួញរា នឹងសុំយកអាសា ស្នងព្រះតេជះព្រះគុណដរាបលុះអស់ជីវិត សូមជួយបំពេញព្រះបារមីទាន សូមឱ្យព្រះអង្គបានត្រាស់ជាព្រះពុទ្ធ នាំសត្វចូលព្រះនិព្វាន បានដូចសេចក្តី

ប្រាថ្នា នាអនាគតកាលទៅហោង ។

កាលនោះ សម្តេចព្រះឥន្ទ្រាធិរាជ ទ្រង់ជ្រាបសភាពព្រះរាជអធ្យាស្រ័យដ៏ប្រសើរថ្លៃថ្លានៃក្សត្រាក្សត្រី ទាំងពីរព្រះអង្គនោះហើយ ក៏ទ្រង់ត្រាស់សរសើរព្រះបរមពោធិសត្វ ជាយ៉ាងក្រៃលែង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលសូត្រសាជាបាទព្រះគាថាដូច្នេះ

តេសំ សទ្ធប្បមញ្ញាយ ទេវិន្ទោ ឯតទព្រវិ
សព្វេ ជិតា តេ បច្ចុហា យេ ទិព្វា យេ ច មានុសា ។
និន្នាទិតា តេ បថវី សទ្ទោ តេ តិទិវង្គតោ
សមន្តា វិជ្ជុតា អាគូ គិរីនំវ បតិស្សុតា ។
តស្ស តេ អនុមោទន្តិ ឧភោ នារទបព្វតា
ឥន្ទោ ច ព្រហ្មា ច បជាបតី ច
សោមោ យមោ វេស្សវណោ ច រាជា
សព្វេ ទេវានុមោទន្តិ ទុក្ករំ ហិ ករោតិ សោ ។
ទុទ្ទទំ ទទមានានំ ទុក្ករំ កម្មកុព្វតំ
អសន្តោ នានុកុព្វន្តិ សតំ ធម្មោ ទុរន្នយោ ។
តស្មា សតញ្ច អសតញ្ច នានា ហោតិ ឥតោ គតិ
អសន្តោ និរយំ យន្តិ សន្តោ សគ្គបរាយនា ។

យមេតំ កុមារេ អទទា ភរិយំ អទទា វនេ វសំ
ព្រហ្មយានមនោក្កម្ម សគ្គេ តេ តំ វិបច្ចតូតិ ។

ភិក្ខវេ ម្នាលសង្ឃដ៏ទ្រង់សីលសិក្ខា សម្តេចព្រះអមរិន្ទ្រាធិរាជ ទ្រង់ជ្រាបសេចក្តី អំពីក្សត្រាក្សត្រីទាំងពីរព្រះអង្គ តាំងព្រះទ័យព្រះរាជសទ្ធា ព្រះឥន្ទ្រាធិរាជ ក៏ត្រេកអរក្សេមក្សាន្ត ទើបក្រាបទូលសរសើរថា បពិត្រព្រះរាជសម្ភារ **តេ បច្ចូហា** រឺអន្ទាក់នៃមារដែលមករាំងរា មិនឱ្យបានសម្រេចសម្បត្តិមនុស្សលោក សម្បត្តិសួគ៌ និងសម្បត្តិព្រះនិព្វាន ក៏ព្រះអង្គមានជ័យជម្នះឈ្នះទាំងអស់ ឥតមានសេសសល់ ទាល់តែកើតចលាចល អស្ចារ្យទាំងផ្ទៃផែនដី មានព្រះកិត្តិសព្ទល្បីរហូតទៅដល់ត្រៃទិព្វសួគ៌នាយ ទាំងផ្លេកបន្ទោរ ក៏ផាលច្រវាត់ជុំវិញព្រៃព្រះហេមពាន្ត ទាំងភ្នំនារទបព៌ត ក៏ហាក់ដូចជាមានចិត្តត្រេកអរអនុមោទនាទានបារមីនៃព្រះអង្គ ៗ (ព្រះឥន្ទ្រ ព្រះព្រហ្ម ព្រះយមរាជ ព្រះបជាបតី ព្រះចន្ទ្រ ព្រះបាទវេស្សវ័ណ ព្រមទាំងទេវតាទាំងឡាយ នាំគ្នាថ្វាយសព្ទសាធុការអនុមោទនាទានបារមីនៃព្រះអង្គ ព្រោះទ្រង់ធ្វើអំពើដែលបុគ្គលដទៃធ្វើតាមស្នាមព្រះបាទ ពុំទាន់ឡើយ ព្រះអង្គអាចព្រះរាជទានរបស់ដែលគេឱ្យបានដោយកម្រ ទ្រង់ធ្វើអំពើ ដែលគេធ្វើបានដោយកម្រ ទើបអសប្បុរសធ្វើតាមព្រះអង្គពុំបានឡើយ មានតែពួកសប្បុរស ទើបត្រាច់ទៅតាមលំអានស្នាមព្រះបាទបាន ៗ

ហេតុនេះ បានជាដំណើររបស់ពួកសប្បុរស និងរបស់ពួកអសប្បុរស រមែងប្លែកផ្សេងគ្នា គឺពួកអសប្បុរសតែងនាំគ្នាទៅនរក ឯពួកសប្បុរសតែងនាំគ្នាទៅឋានសួគ៌ ។ បពិត្រព្រះវេស្សន្តរក្សត្រប្រសើរអើយ ការដែលស្តេចត្រាច់មកគង់ក្នុងព្រៃព្រឹក្សា យ៉ាងនេះហើយ នៅតែទ្រង់ព្រះរាជសទ្ធា ទ្រង់បរិច្ចាគព្រះរាជបុត្រីបុត្រា និងព្រះអគ្គមហេសីជាទាន ពុំមានព្រះរាជហឫទ័យរួញរា ទុកជាព្រហ្មយានដ៏ប្រសើរវិសេស សូមឱ្យបុត្តទារមហាទាននេះ ចូរសម្រេចផលដល់សួគ៌នាយទៅមុខហោង ① ។

លុះព្រះឥន្ទ្រាធិរាជ ទ្រង់អនុមោទនាសរសើរនូវទានបារមីនៃព្រះមហាសត្វដោយប្រការដូច្នេះហើយ ទើបទ្រង់ព្រះតម្រិះ ថាគួរតែអាត្មាអញប្រគល់សម្តេចព្រះនាងមទ្រីទៅព្រះអង្គវិញ ក្នុងវេលាគ្រាឥឡូវនេះឯង ព្រះបាទកោសិយទេវរាជ ក៏មានព្រះរាជឱង្ការ សូត្រសានូវបាទព្រះគាថា ដូច្នេះ

នទាមិ ភោតោ ភរិយំ មទ្ទឹ សព្វង្គសោភណំ
ត្វញ្ច មទ្ទិយា ឆន្នោ មទ្ទី ច បតិនា សហ ។
យថា បយោ ច សង្ខោ ច ឧភោ សមានវណ្ណិនោ
ឯវំ តុវញ្ច មទ្ទី ច សមានមនចេតសា ។
អវរុទ្ធេត្ថ អរញ្ញស្មឹ ឧភោ សម្មថ អស្សមេ
ខត្តិយា គោត្តសម្បន្នា សុជាតា មាតុបេតិតោ

---

① ក្នុងវង់ក្រចកនេះ សេចក្តីប្រែថ្មីតាមច្បាប់អដ្ឋកថាជាតកបាលីដើម ។

យថា បុញ្ញានិ គយិរាថ ឆនន្ទា អបរាបរន្តិ ។

បពិត្រក្សត្រថ្លៃប្រសើរអើយ រីសម្ដេចព្រះរាជមទ្រីនេះ ទុកស្មើព្រះនេត្ររបស់ព្រះអង្គ ពុំនោះសោត ដូចកលជីវិត ព្រះអង្គពុំគិតឧស្សាហ៍លះបង់ឱ្យជាទាន កម្របុគ្គលឯណាមួយនឹងធ្វើបានដូចព្រះអង្គ សូមព្រះអង្គទ្រង់ព្រះមេត្តាអត់ទោសប្រោសខ្ញុំតាជី ត្បិតស្ដេចលើកយកព្រះរាជមទ្រីឱ្យទៅជាទាន ព្រះគុណនោះធំធ្ងន់ពន់ប្រមាណ ខ្ញុំតាជីទទួលព្រះរាជទានទុកលើសិរសា ត្បិតខ្ញុំតាជីក៏ចាស់ជរា រោគាក៏បៀតបៀនក្នុងខ្លួនប្រាណ ហើយជិតចួននឹងមរណា រូបក៏អន្ធការ ឥតខ្លឹមសារសូន្យសោះ នឹងទទួលព្រះរាជទាននោះ យល់ពុំគាប់ ជាទ្រព្យសទ្ធា ។ មួយសោត ព្រះអង្គ ជាអំបូរត្រកូលខត្តិយវង្ស រែងទ្រង់ព្រះរាជសទ្ធា ត្រកាលលើសលែងមនុស្សសត្វផងទាំងឡាយ បើនឹងអភិប្រាយ បីដូចស័ង្ខដ៏បរិសុទ្ធ ពុំនោះសោត បីដូចទឹកដោះដ៏មានរស្មី យល់ព្រះបារមីជាត្រកាល ខ្ញុំតាជី ក៏ត្រេកអរសោមនស្សនឹងព្រះរាជហឫទ័យ សូមថ្វាយព្រះរាជមទ្រីដល់ព្រះអង្គវិញនឹងបានបំពេញមេត្តាព្រហ្មវិហារ ពុំឱ្យមានអំពល់ ដើម្បីចម្រើនព្រះរាជកុសលឱ្យបានចម្រើនកើនទៅមុខទៀត នឹងបាននាំសត្វទៅទុកឯអម្រឹតបុរីស្រីមហានគរនិព្វានហោង ។

សម្ដេចព្រះឥន្ទ្រាធិរាជ ក្រាបទូលស្រេចហើយ ពុំលង់ឡើយ ទើបសម្ដែងព្រះអង្គឱ្យព្រះបរមពោធិសត្វជ្រាបច្បាប់ថា ព្រះអង្គ

គឺអង្គអមរិន្រ្ទាធិរាជ ហើយទ្រង់មានទេវឱង្ការ ព្រះរាជទានព្រះពរដូច្នេះ ថា

សក្កោ ហមស្មិ ទេវិន្ទោ   អាគតោស្មិ តវន្តិកេ
វរំ វរស្សុ រាជិសិ   វរេ អដ្ឋ ទទាមិ តេតិ ។

បពិត្រព្រះអង្គ ដ៏ទ្រង់នូវព្រះរាជសទ្ធាអើយ រីខ្លួនអញខ្ញុំនេះ ពុំគឺព្រាហ្មណ៍ព្រឹទ្ធាចារ្យឡើយ អញខ្ញុំនេះគឺជាកោសិយអមរិន្រ្ទាធិរាជ ឋិតនៅនាឋានត្រៃត្រឹង្សា ចុះមកទំនុកបម្រុង បំពេញទានបារមី ដើម្បីឱ្យព្រះអង្គបានសម្រេចព្រះសម្ពោធិសម្ភារ ហើយនឹងថ្វាយព្រះពរ ៨ ប្រការដល់ព្រះអង្គ នាកាលគ្រាឥឡូវនេះឯង ។

កាលសម្តេចព្រះអមរិន្រ្ទាធិរាជ កំពុងមានព្រះរាជឱង្ការនោះ ទ្រង់តំណែងប្លែងអត្តភាពជាទិព្វ មួយរំពេច មានពន្លឺរស្មីភ្លឺព្រោងព្រាយពណ្ណរាយ ឆើតឆាយ ទ្រង់ធ្យានឡើងទៅឋិតពួធ៍នភាកាស មានពន្លឺរស្មីរុងរឿងដូចកាលព្រះសុរិយាទើបរះឡើងពីទិសបូពា៌ ។

តតោ ពោធិសត្តោ កាលនោះ ព្រះបរមពោធិសត្វមហាបុរសរត្ន ស្តេចទ្រង់ជ្រាបអស់អាថ៌អម្បាលណោះហើយ កាលព្រះអង្គនឹងទទួលយកព្រះពរអំពីព្រះឥន្រ្ទា ទ្រង់ក្រាបបង្គំទូល សូត្រនូវបាទព្រះគាថាទាំងឡាយ ដូច្នេះ

វរញ្ចេ មេ អទោ សក្ក   សព្វភូតានមិស្សរ
បិតា មំ អនុមោទេយ្យ   ឥតោ បត្តំ សកំ ឃរំ

អាសនេន និមន្តេយ្យ បឋមេតំ វរំ វរេ ។
បុរិសស្ស វធំ ន រោចេយ្យំ អបិ កិព្វិសការកំ
វជ្ឈំ វធម្ហា មោចេយ្យំ ទុតិយេតំ វរំ វរេ ។
យេ វុឌ្ឍា យេ ច ទហរា យេ ច មជ្ឈិមបោរិសា
មមេវ ឧបជីវេយ្យុំ តតិយេតំ វរំ វរេ ។
បរទារំ ន គច្ឆេយ្យំ សទារបសុតោ សិយំ
ថីនំ វសំ ន គច្ឆេយ្យំ ចតុត្ថេតំ វរំ វរេ ។
បុត្តោ មេ សក្ក ជាយេថ សោ ច ទីឃាយុកោ សិយា
ធម្មេន ជិនេ បឋវី បញ្ចមេតំ វរំ វរេ ។
តតោ រត្យា វិវសនេ សុរិយស្សុគ្គមនំ បតិ
ទិព្យា ភក្ខា បាតុភវេយ្យុំ ឆដ្ឋមេតំ វរំ វរេ ។
ទទតោ មេ ន ខីយេថ ទត្វា នានុតប្បេយ្យហំ
ទទំ ចិត្តំ បសាទេយ្យំ សត្តមេតំ វរំ វរេ ។
ឥតោ វិមុច្ចមានាហំ សគ្គគាមី វិសេសគូ
អនិព្វត្តី តតោ អស្សំ អដ្ឋមេតំ វរំ វរេតិ ។

បពិត្រព្រះឥន្ទ្រាធិរាជ ដ៏ជាធំចម្បងអស់សព្វសត្វទាំងឡាយ ថាបើព្រះអង្គទ្រង់ព្រះរាជទានព្រះពរដល់យើងខ្ញុំមិញ ឯព្រះពរទី ១ សូមឱ្យព្រះវររាជបិតាសព្វព្រះរាជហឫទ័យត្រេកអរនឹងយើងខ្ញុំ កាលត្រឡប់ចេញពីព្រៃ ទៅដល់ព្រះរាជបុរី របស់ខ្លួនហើយ សូមឱ្យព្រះវររាជបិតា អញ្ជើញយើងខ្ញុំឱ្យនៅគ្រប់គ្រងរាជសម្បត្តិ

បឋមេតំ វរំ វរេ យើងខ្ញុំសូមទទួលយកព្រះពរនេះជាបឋម ។

ប្រការមួយសោត កាលយើងខ្ញុំបានគ្រប់គ្រងរាជសម្បត្តិហើយ សូមកុំឱ្យយើងខ្ញុំគាប់ចិត្តនឹងការសម្លាប់មនុស្សម្នាមហាជនផងទាំងឡាយឡើយ ទោះបីមានទោសខុសដល់ស្លាប់ ក៏សូមឱ្យយើងខ្ញុំជួយដោះទុក្ខសត្វផង ឱ្យផុតពីការសម្លាប់ ទាល់តែបាន **តតិយេតំ វរំ វរេ** យើងខ្ញុំសូមទទួលយកព្រះពរនេះជាគម្រប់ពីរ ។

ប្រការមួយសោត វីអស់មនុស្សម្នាប្រជាជនផង ទោះចាស់ក្តី ក្រមុំកំឡោះក្តី ក្មេងក្តី ដែលមានសេចក្តីក្រីក្រកម្សត់តោកយ៉ាក សូមឱ្យបានចូលមកពំនាក់អាស្រ័យយើងខ្ញុំ ទទួលយកព្រះរាជទានចិញ្ចឹមជីវិតជាសុខសប្បាយតាមប្រក្រតី **តតិយេតំ វរំ វរេ** យើងខ្ញុំសូមទទួលយកព្រះពរនេះ ជាគម្រប់ ៣ ។

ប្រការមួយសោត វីមាតុគ្រាមនាំបង្កក្តីប្រមាទ ឱ្យបាត់បង់សទ្ធារដោយក្តីតម្រេកក្នុងកាមេសុមិច្ឆាចារ ជាក្តីអកុសល សូមកុំឱ្យជិតដល់កើតក្នុងខន្ធសន្តាន សូមឱ្យយើងខ្ញុំបានស្នេហ៍ស្មាលនឹងព្រះរាជមទ្រី កុំបីលុះអំណាចស្ត្រីដទៃឡើយ **ចតុត្ថំ វរំ វរេ** យើងខ្ញុំសូមទទួលយកព្រះពរនេះ ជាគម្រប់ ៤ ។

បពិត្រសម្តេចព្រះអមរិន្ទ្រាប្រសើរអើយ យើងខ្ញុំសូមឱ្យព្រះរាជឱរសទាំងទ្វេហារ គឺចៅជាលីនិងមេក្រស្នា មានជន្មាយុយឺនយូរ ហើយសូមឱ្យបានគ្រប់គ្រងផែនដីជេតុត្តរបុរីរដ្ឋ ដោយ

នូវគន្លងធម៌នៃខត្តិយប្រពៃណី **បញ្ចមេតំ វរំ វរេ** យើងខ្ញុំសូមទទួលយកព្រះពរនេះ ជាគម្រប់ ៥ ។

ប្រការមួយសោត កាលដែលយើងខ្ញុំយាត្រាទៅដល់រាជបុរីហើយ លុះអស់ងងឹតក្នុងវេលារាត្រី ដល់ពេលអរុណរះឡើងថ្មី ក៏សូមឱ្យអាហារទិព្វកើតមានប្រាកដ ឱ្យបានគ្រប់គ្រាន់តាមកំណត់រាល់ៗថ្ងៃ **ឆដ្ឋមេតំ វរំ វរេ** យើងខ្ញុំសូមទទួលយកព្រះពរនេះ ជាគម្រប់ ៦ ។

ប្រការមួយសោត យើងខ្ញុំសូមឱ្យមានចិត្តកាត់តម្លាសទ្ធា ក្នុងការបរិច្ចាគទាន ទុកជាឱ្យទានអម្បាលម៉ាន កុំបីឱ្យចេះអស់សោះឡើយ កាលកំពុងឱ្យ ក៏សូមឱ្យមានចិត្តជ្រះថ្លា ផូរផង់ លុះលះបង់ឱ្យហើយ ក៏កុំឱ្យមានចិត្តក្ដៅក្រហាយស្ដាយក្រោយឡើយ **សត្តមេតំ វរំ វរេ** យើងខ្ញុំសូមទទួលយកព្រះពរនេះ ជាគម្រប់ ៧ ។

ប្រការមួយសោត កាលយើងខ្ញុំនឹងវិលាងខន្ធ តាមកំណត់ទិវង្គតសោយព្រះវិលាល័យ សូមឱ្យបានទៅកើតនាឋានតុសិតសួគ៌នាយ ដ៏ជាឋានវិសេស លុះច្យុតអំពីឋាននោះ ក៏សូមឱ្យបានសម្រេចព្រះបរមាភិសេកសម្ពោធិញ្ញាណ មិនមានវិលកើតវិលស្លាប់ក្នុងសង្សារភពតទៅទៀតឡើយ **អដ្ឋមេតំ វរំ វរេ** យើងខ្ញុំសូមទទួលយកព្រះពរនេះ ជាគម្រប់ ៨ រួមជាព្រះពរ ៨ ប្រការ ។ ទើបសម្ដេចអមរិន្ទ្រាធិរាជ អាចប្រសិទ្ធិ ឱ្យបាន

ដូចព្រះរាជហឫទ័យប្រាថ្នា នាអនាគតកាលនោះឯងហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលសូត្រសាជាបាទព្រះគាថាដូច្នេះ

តស្ស តំ វចនំ សុត្វា ទេវិន្ទោ ឯតទព្រវិ
អចិរំ វត តេ តាតោ បិតា តំ ទដ្ឋុមេស្សតិ ។
ឥទំ វត្វាន មឃវា ទេវរាជា សុជម្បតិ
វេស្សន្តរេ វរំ ទត្វា សគ្គកាយំ អបក្កមីតិ ។

ភិក្ខវេ ម្នាលសង្ឃដ៏ខ្លាចភ័យក្នុងវដ្ដសង្សារ សក្កោ រីសម្ដេចព្រះឥន្ទ្រាធិរាជ សុត្វា ព្រះអង្គបានស្ដាប់ព្រះរាជឱង្ការព្រះបរមពោធិសត្វ សូមព្រះពរបវរជាឧត្ដម ព្រះឥន្ទ្រា ក៏ទ្រង់អភិរមសោមនស្សា ទើបទ្រង់ទូលថា បពិត្រព្រះអង្គ ដ៏ទ្រង់ព្រះរាជសម្ភារ ព្រះអង្គគង់ឱ្យជាសុខ កុំជាទុក្ខព្រួយព្រះរាជហឫទ័យ ពុំយូរឡើយនៃ សម្ដេចព្រះវររាជបិតា ក៏នឹងរលឹកដល់ព្រះអង្គ នឹងលើកចតុរង្គសេនា ចេញមកឯភ្នំគិរីវង្កត អារាធនាឱ្យលាព្រ័តចេញពីឥសី ចូលទៅបូរីតាមដូចព្រះប្រាថ្នា អប្បមត្តោ ចូរព្រះអង្គឧស្សាហ៍ កុំប្រមាទ សង្វាតបំពេញព្រះកម្មដ្ឋាន ឱ្យបានប្រសើរទៅឯមុខ នឹងបានចម្លងសព្វសត្វ ទៅទុកដល់អម្រឹតបុរីស្រីមហានគរនិព្វាន ។ សម្ដេចព្រះឥន្ទ្រា ដ៏មានតេជះតបៈរឹទ្ធី ទត្វា លុះទ្រង់បានប្រទានព្រះពរទាំង ៨

ប្រការ ថ្វាយព្រះបរមក្សត្រាព្រះមហាវេស្សន្តរបវររាជឥសី ជាបរិបូណ៌ស្រេចហើយ មក្ខាមិ ក៏ស្តេចឡើងទៅកាន់វិមានពេជ្រយន្តជាឋានរបស់ព្រះអង្គ នាកាលនោះឯងហោង ។

សក្កបព្វំ និដ្ឋិតំ បពិត្រអើយ អាត្មាភាពសម្តែងថ្លែងព្រះធម៌វិសេសទេសនា កណ្ឌសក្កបព្វ ដ៏ប្រដាប់នូវព្រះគាថាទាំងឡាយ ៤៣ គាថា ៦ទំ ក៏ចប់បរិបូណ៌ដោយសមគួរនៅវេលានេះឯងហោង ។

ចប់ កណ្ឌសក្កបព្វៈ ទី ១០ តែប៉ុណ្ណេះ ។

⁂

ចម្លងចប់នៅថ្ងៃ ១៤ រោច ខែជេស្ឋ ព.ស. ២៥៣៣
ត្រូវនឹងថ្ងៃសុក្រ ទី ២២ ខែមិថុនា គ.ស. ១៩៩០

មហាវេស្សន្តរជាតក

ទី ១១



កណ្ឌមហារាជបព្វៈ

ប្រដាប់ដោយគាថា ៦៩

មហាវេស្សន្តរជាតក

ទី ១១

កណ្ឌមហារាជបព្វៈ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

តទា ពោធិសត្តោ ច មទ្ទី ច សម្មោទមានា សក្កទត្តិយេ អស្សមេ វសឹសុ ។

ពោធិសត្តោ ច រីព្រះបរមពោធិវង្ស ទ្រង់ព្រ័តទាំងពីរព្រះអង្គ គឺសម្តេចព្រះបរមពោធិវង្ស គ្រងពិភពរាជធានី **មទ្ទី ច** នូវសម្តេចព្រះមទ្រី ដ៏ជាអគ្គមហេសីស្រីគ្រប់លក្ខណា ដ៏ជាត្រកូលខត្តិយវង្ស **សម្មោទមានា** ក្សត្រទាំងពីរព្រះអង្គទ្រង់មានព្រះទ័យស្មោះសរ ដោយនូវព្រះពរទាំង ៨ ប្រការ **វសឹសុ** ឥតរង្កៀសក្នុងព្រះរាជហឫទ័យ ពុំមានភយន្តរាយ **អស្សមេ** ក្សេមក្សាន្តសប្បាយនៅនាព្រះអាស្រម **សក្កទត្តិយេ** ដែលព្រះឥន្ទ្រាធិរាជ រីងរីទ្ធិព្រះអង្គព្រះរាជទានឱ្យមកនោះឯងហោង ។

ជូជកោបិ កុមារេ គហេត្វា សដ្ឋិយោជនមគ្គំ បដិបជ្ជិ ។

ភោ សាធវោ ហៃសាធុសប្បុរសផងទាំងឡាយអើយ កាលនោះ តាជូជកព្រាហ្មណ៍ បានចៅជាលីនិងនាងក្រស្នាហើយ ក៏រលះរលាំងបណ្តើរទៅ ដោយនូវផ្លូវចម្ងាយ ៦០ យោជន៍នោះ ។

ទេវតា កុមារានំ អារក្ខមកំសុ ក្សិណនោះកូវ អស់ទេវតា

ទាំងឡាយ ជួយថែរក្សាកុមារទាំងពីរ ដែលតាជូជកនាំបណ្ដើរទៅ មិនឱ្យមានជំងឺឈឺថ្កាត់តាមផ្លូវឡើយ ។

ជូជកោបិ សុរិយេ អត្ថង្គមិតេ កុមារេ គច្ឆេ ពន្ធិត្វា កាលព្រះសុរិយាទន់ទាបល្ងាច ថ្ងៃបាំងនឹងជ្រុងភ្នំព្រះសិនេរុរាជគិរិន្ទរ យប់ព្រលប់សន្ធ្យា ឮតែសូរសព្ទសំឡេងមៀមទីទុយ ច្រឡំនូវសំឡេងខ្លាចយំ កងរំពងទាំងព្រៃ ។ ឯតាជូជកអប្រិយ ក៏ភ័យខ្លាចពន់ប្រមាណ ទើបគាត់ខំវាយព្រះរាជកុមារ បណ្ដើរទៅ ឥតបង្អង់សម្រាកឡើយ ។ ឱះ ឱ ! មុខគួរអាសូរចៅជាលីនិងនាងក្រស្នាអ្នកទ្រង់ព្រះសោកាពន់ប្រមាណ ទើបមានអស់ពួកទេវតាផ្ទៀងព្រះកាណ៌ស្ដាប់ឮសព្ទសូរសៀងសំឡេងជាលីនិងនាងក្រស្នា អ្នកមានព្រះទ័យអនាថអាណិត ពុំដឹងបើនឹងគិតដូចម្ដេចបានឡើយ ។ ឱ ! ទ្រូងអញអើយ ស្ទើរនឹងបែកសព្រោកប្រេះចេញ ព្រោះត្បិតព្រះរាជបុត្រទាំងគូមិញ អ្នកដើរជ្រុលជ្រក ខំប្រវារកគ្នា ឯព្រាហ្មណ៍ចាស់ជរា ក៏ភិតភ័យខ្លាចក្រែងព្យគ្ឃៈ សិង្ហ សីហ៍ ធ្វើឱ្យអន្តរាយជីវិត ទើបគាត់ចូលទៅក្នុងព្រឹក្សាហើយបោចយកលតាវល្លិផង ចងព្រះហត្ថាព្រះកុមារទាំងពីរកួបរួបរឹតជិតជាប់ផងគ្នា ផ្ដេកនៅនាគល់ឈើហើយ ពុំលង់ឡើយ ភ្នែកគាត់តែងរំពៃ ជើងដៃសឹងពានឡើងកកេប កកាប ផ្ទាសនឹងដល់ទៅប្រគាបឈើនៅលើចុងព្រឹក្សា គាត់ចងព្រះរាជកុមារទាំងពីរទុកនៅដី ឯព្រាហ្មណ៍ចាស់អប្រិយ នឿយណាស់ប្រះដេកលក់ ស្រមុកទៅ **សាខាវិដបន្តរេ** នៅនា

ប្រគាបឈើនោះឯងហោង ៗ

តស្មឹ ខណេ ឰដ៏កាលនោះ មុខគួរឱ្យស្រណោះចៅជាលី និងនាងក្រស្នាទាំងពីរ ព្រាត់ប្រាសព្រះមាតា អ្នកទួញសោករកព្រះជននី **ឯកោ ទេវបុត្តោ** មានទេវបុត្រមួយអង្គ ទ្រង់នូវចេស្តានុភាពកបនូវព្រះទ័យករុណា ប្លែងកាយាចុកចងព្រះកេសា ទ្រង់នូវកណ្ដាលហូរ័ក ពាក់ស្បែកខ្លាជាសង្វារសំបុរច្រាលវិលវង់ ទ្រង់សឹងគ្រឿងទិព្វ ដ៏មានតម្លៃ ព្រះភក្ត្រប៉ប្រែប៉ប្រិម ព្រះឱស្ឋញញឹមរួសរាយស្មោះសរ ល្អសុទ្ធសាធ ដូចកលនៃព្រះបាទស្រីវេស្សន្តរ **ឯកា ទេវធីតា** មាននាងទេពអប្សរបវរកញ្ញា នៅនារុក្ខាឋាននោះ មានចិត្តករុណា ទើបនិម្មិតកាយាឱ្យសមជាស្ត្រីឧត្តមប្រសើរ ដើរញ៉ៀងញ៉ៀងតាមទំនងចរិតក្សត្រី ដូចកលសម្ដេចព្រះនាងមទ្រី មានលក្ខណា ចងជដាជាភេទឥសី ដូចព្រះជននីនូវព្រះជនក ស្ដេចយាត្រាមកស្វែងរក **មោចេត្វា** ទើបស្រាយចំណងចេញអំពីព្រះហស្ដនៃព្រះរាជកុមារទាំងពីរស្រេច ស្ដេចគក់ព្រះឧរា ទ្រង់ព្រះសោកាពិលាបថា ឱ! អម្ចាស់ម្ដាយអើយ ម្ដេចឡើយ ក៏មកបានសេចក្ដីលំបាកពីតូចៗ ឱះ ឱ ! ព្រះកាយអ្នកដូចគេសាប់សព្វសព៌ាង្គ សឹងតែស្នាមឈាមហូរដូចគេស្រពស្រោចកាយា ទ្រូងព្រះមាតានេះស្ទើរនឹងបែកសព្លោកប្រេះចេញនាកាលគ្រានេះមិញ **ហត្ថបាទេ សម្ពាហិត្វា** ឱ! កូនសំឡាញ់ម្ដាយអើយ ចូរមកឯមាតាបិតានឹងឃ្លានពិភ័ក្តិរក្សាអស់ជំងឺក្នុងប្រាណ ឱ្យបានសះស្បើយ ពុំលង់

ឡើយ ទេពតាក៏លួងលោមបីថ្នមព្រះរាជកុមារនៃបនិត្យជិតព្រះឧរា ហើយត្រាស់ថា មេក្រស្នាសំឡាញ់ម្តាយអើយ ចូរអ្នកមកបៅបន្តិចសោះឃ្លាន ម្តាយនេះពុំមានដំណឹងថា អ្នកលំបាកដល់ម្លេះឡើយ **នហាបេត្វា** ទើបនាងទេពធីតា យកទឹកមកលបព្រះភក្រ្ត ដុះព្រះអង្គ ចងជដាផ្ចិតផ្ចង់ឱ្យមានមង្គលសួស្តី **ភោជាបេត្វា** ទើបត្រាស់ថា កូនសម្លាញ់ម្តាយអើយ អ្នកអត់អាហារល្ហិតល្ហៃ នៅក្នុងព្រៃព្រឹក្សា ឯអស់ភោជនាហារ ក៏ម្តាយយកមកផ្ញើកូនគួកម្សត់ ទើបទេវបុត្រនិងនាងទេវធីតា លួងលោមចៅជាលីនិងនាងក្រស្នា ឱ្យសោយគ្រឿងទិព្វសម្រេចស្រេចហើយ ទើបលើកព្រះហត្ថាអង្អែលបីថ្នមលួងលោម ឱ្យផ្ទំនៅលើពូកព្រំខ្នល់ខ្នើយទិព្វជាបរមសុខ អ្នកផ្ទំលក់ស្កប់ លុះដល់អរុណោទ័យ បែករស្មីបំព្រាងស្វាងជ្រះស្រឡះមេឃ ទេពតារក្សាព្រះរាជកុមារទាំងពីរ បណ្តាលឱ្យគង់ចំណងដូចដែលវិញ ក្រែងព្រាហ្មណ៍នោះមិញវានឹងខឹងឃោរឃៅជេរពោលវាយដំពុំប្រណី ។

ឯវន្តេ ទេវតា សត្តហេន ក៏ហេតុទេពតារក្សាព្រះរាជកុមារទាំងគូដោយនូវផ្លូវត្រូវជា ១៥ រាត្រី **អរោគា ហុត្វា** ពុំមានភ័យរោគាព្យាធិ ដោយតេជះបារមីនៃទេពតានូវបុណ្យព្រះរាជកុមារាកុមារី នូវបរមត្ថបារមីនៃព្រះរាជឥសីដ៏ជាព្រះវររាជបិតា កាត់តម្លាសទ្ធានោះឯង **អរុណេ** នាកាលអរុណោទ័យ រស្មីភ្លឺជ្រះស្រឡះមេឃ ក្សិណនោះ ជូជកចាស់ជរាភ្ញាក់ពព្រើត ទើបបានងើប

ក្បាលឡើង ដឹងជាភ្លឺ គាត់ថា ហឹះៗ អេះ ព្រឹកភ្លឺហើយហ្ន៎! ទើបគាត់ក្រោកពីនិទ្រា កខ្វេសកខ្វាស ពពឹប ពពាប យកទឹកមកលុបមុខខ្លួរមាត់ ទើបគាត់បរិភោគសដូវខៅតាកង្កែតស្រេចហើយ ពុំលង់ឡើយ គាត់ក៏ចុះអំពីប្រគាបឈើ **មោចេត្វា** ទើបគាត់ស្រាយលតាវល្លិផង ដែលចងព្រះហស្តព្រះរាជកុមារទាំងគូ បណ្តើរនាំទៅដោយនូវផ្លូវ គិតថានឹងដើរស្រូតទៅឱ្យរំលងទ្វារព្រៃនោះ **ទិស្វា** លុះយល់មាគ៌ាបែកជាពីរ ផ្លូវមួយនោះនឹងទៅឯក្រុងពិជ័យជេតុត្តរនគរ ផ្លូវមួយទៀតនោះនឹងទៅនគរកលិង្គរាស្ត្រដ៏ជាឋាននៃអាត្មា ទើបទេពតាបញ្ឆលចិត្ត ឱ្យគាត់ឆ្ងើងឆ្ងល់សង្ស័យ ស្មានផ្លូវដែលទៅជេតុត្តរនគរ គិតថាជាផ្លូវនឹងទៅកលិង្គរាស្ត្រវិញ ជាប្រាកដ ទើបគាត់នាំព្រះរាជបុត្រទាំងពីរទៅដោយនូវមាគ៌ា **អឌ្ឍមាសេ** ថាបើគណនា មាន ១៥ ថ្ងៃ ទើបបានដល់ក្រុងពិជ័យជេតុត្តរនគរនោះឯងហោង ។

តំ ទិវសំ បច្ចូសកាលេ លុះព្រឹកឡើងថ្ងៃ១៥កើត ជាថ្ងៃឧបោសថ **រវេវ សត្វយោ** ឯព្រះបាទក្រុងស្រីសញ្ជ័យ ដ៏ទ្រង់រឹទ្ធិ នាកាលព្រះបរមបពិត្រ ស្តេចនឹងបានយល់ព្រះរាជនត្តានត្តាទាំងពីរព្រះអង្គ ទ្រង់ព្រះសុបិននិមិត្តជាអស្ចារ្យ ហាក់ដូចព្រះអង្គគង់នៅនាក្រឡាព្រះគំនាល់ កណ្តាលផ្ទៃរោង ថ្កើងដោយនូវព្រះបារមីចេស្តា មានអស់សេនាមាត្យគង់គាល់ដោយនូវរបៀបត្រៀបត្រា ជំនុំពិចារណារាជការផ្ទៃក្រោម ។ **ឯកោ បុរិសោ**

មានបុរសម្នាក់ **កណ្ហោ** រូបរាងខ្មៅស្រមាកធាត់ធំមហិមា **ទ្វេ បទុមានិ អាហរិត្វា** មានដៃកាន់នូវបទុមាផ្កាឈូកទាំងពីរទ្រង់ទតរមិលមើលយល់ផ្កាមួយនោះក្រពុំ ឯបទុមមួយនោះរំសាយកេសរពិដោរល្វេងល្វើយ **រញ្ញោ ហត្ថេ ឋបេសិ** បុរសនោះឯងយកមកថ្វាយដាក់បូជានៅនាព្រះហស្ត **បិឡន្ធតិ** ក្នុងព្រះសុបិននោះថា ព្រះអង្គទទួលយកមកសៀតនៅនាព្រះកាណ៌ទាំងសងខាងល្អប្រសើរ **រេណូ កស្សិត្វា** រីឯលំអងកេសរ ក៏ជ្រុះលើព្រះឱរាកេសរផ្កាមានក្លិនក្រអូបពុំស្បើយ **បាតោវ ច** លុះព្រឹកឡើងហើយស្តេចត្រាស់ឱ្យហៅហោរាព្រឹទ្ធាចារ្យ មកដល់ស្រេច ទើបស្តេចមានព្រះរាជឱង្ការប្រាប់ហោរាព្រឹទ្ធាចារ្យតាមដោយនូវបុព៌និមិត្តទើបពួកហោរាក្រាបបង្គំទូលថា បពិត្រព្រះរាជសម្ភារ រីនិមិត្តនេះត្រូវកាលល្អណាស់ អម្ចាស់ **ចិរប្បវុដ្ឋា** ព្រះរាជវង្សាអម្ចាស់ដែលព្រាត់ព្រាកចាកចេញទៅឆ្ងាយជាអម្លុងយូរ ឥឡូវនេះ នឹងវិលមកពឹងព្រះបរមពោធិសម្ភារព្រះអង្គ ជាប្រាកដពុំខានឡើយ ៗ ទើប⑴ ស្តេចមានព្រះរាជហឫទ័យត្រេកអរពន់ប្រមាណ យល់

១- មានមហាជាតក៏ច្បាប់ខ្លះថា សោ បាតោវ សីសំ នហាត្វា នានគ្គរសភោជនំ ភុញ្ជិត្វា អត្តានំ អលង្ករិត្វា មហាវិនិច្ឆយេ និសីទិ បពិត្រអើយ ពួដ៏កាលនោះ វីព្រះបាទស្រីសញ្ជ័យ ស្តេចស្តាប់មន្ត្រីហោរាផងទាំងឡាយទាយពីរោះស្មោះ ទ្រង់

ភ្លង . . .

បានដូចព្រះបំណង ទើបស្ដេចចូលទៅកក់ស្រង់ទ្រង់ព្រះសុគន្ធពិដោរ ឈ្ងុយឈ្ងប់សព្វព្រះកាយ ស្លុះព្រះឆាយ សិតព្រះកេសា ហើយស្ដេចសោយព្រះក្រយាស្ងោយ ដ៏មានឱជារស រួចស្រេច ស្ដេចលីលាចេញទៅគង់នៅនាព្រះរាជគំនាល់ អស់សេនាមាត្យគាល់ត្រៀបត្រា ស្ដេចទ្រង់ព្រះចិន្ដាពិចារណាអំពីរាជការផ្ទៃក្រោម នោះឯងហោង ។

ឮដ៏កាលនោះ ទេវតាបញ្ចូលចិត្តជូជកព្រាហ្មណ៍ ឱ្យដឹកនាំព្រះរាជកុមារទាំងពីរព្រះអង្គទៅត្រង់មុខព្រះលាន អស់មនុស្សផងទាំងឡាយ ក៏ពុំបានសាកសួរសេចក្ដីនៃតាចាស់ជរា ជាមនុស្សអប្រិយ គាត់នាំព្រះរាជបុត្រាបុត្រី ទៅជិតព្រះរាជវាំង ក៏ព្រោះទេវតាបំបាំងក្នុងចិត្តឱ្យភ្លេចភ្លាំងទាំងស្រីទាំងប្រុសគ្រប់គ្នា ឱ្យជាពុំបានសាកសួរឱ្យដឹងដំណើរ ឯព្រាហ្មណ៍ក៏បណ្ដើរព្រះរាជកុមារទាំងគូ ចូលទៅដល់មុខព្រះលាន ។

រាជា សត្វាយោ ទើបសម្ដេចព្រះបរមក្សត្រក្រុងស្រីសញ្ជ័យ ស្ដេចទតព្រះនេត្រទៅយល់ព្រះរាជនត្តានត្តាទាំងគូ ស្ដេចពុំស្គាល់ ទើបត្រាស់ជាអាថ៌បាទព្រះគាថាដូច្នេះ

សព្វព្រះរាជហឫទ័យ ហាក់ដូចជាបានយល់ព្រះចៅទាំងពីរ ហើយស្ដេចចេញទៅកក់ស្រង់ជម្រះព្រះអង្គស្រេច ស្ដេចសោយនូវភោជនាហារ ដ៏មានឱជារសប្រសើរផ្សេង ៗ ហើយស្ដេចទ្រង់នូវគ្រឿងមកុដរួចស្រេច ស្ដេចឡើងគង់លើអាសនា នាផ្ទៃរោង ឱ្យអស់មុខមន្ត្រីផងគាល់ជំនុំពិភាក្សា ដូចប្រក្រតីនោះហោង ។

កស្សេតំ មុខមាភាតិ ហេមំ វុត្តត្តមគ្គិនា
និក្ខំវ ជាតរូបស្ស ឧក្កាមុខបហំសិតំ ៗ
ឧភោ សទិសបច្ចង្គា ឧភោ សទិសលក្ខណា
ជាលិស្ស សទិសោ ឯកោ ឯកា កណ្ហាជិនា យថា ៗ
សីហា ពិលាវ និក្ខន្តា ឧភោ សម្បត្តិរូបកា
ជាតរូបមយាយេវ ឥមេ ទិស្សន្តិ ទារកា ៗ

ភោ អមច្ចា ហែអស់សេនាមាត្យផងទាំងឡាយអើយ រី ព្រាហ្មណ៍បណ្តើរក្មេងទាំងពីរនោះ តើជាបុត្រនៃអ្នកឯណាហ៎ះមើល ទៅយល់ថ្លៃថ្លាប្រសើរបវរសុទ្ធស្អាត ហេមមិវ ដូចសុវណ្ណជាតិ ជម្ពូនទ វុត្តត្តមគ្គិនា គិតដ៏ត្រូវរន្ទះថ្ងៃដ៏មាននូវរស្មីនោះពព្រាល ពព្រាយ និក្ខំវ ជាតរូបស្ស ពុំនោះសោតព្រះភក្ត្រ បីដូចកល មាសនព្វគុណ បហំសិតំ គិតដ៏នាយជាងទងរំលាយនៅក្នុងមាត់ ឆ្គារ៍ ដ៏មានទឹកនោះរលេមរលង់ត្រចង់ត្រចះជ្រះថ្លាឥតរាគី ឧភោ សទិសបច្ចង្គា ព្រះរាជកុមារាកុមារីទាំងពីរ អ្នកទ្រង់នូវព្រះឆោម បវរ ព្រះករទន់ភ្លន់ បើនឹងគន់ទៅ ក៏យល់ល្អប្រសើរ ស្រស់ស្រួល មុខគួរឱ្យអាសូរករុណា អ្នកបណ្តើរគ្នាមកទាំងគូ ឧភោ សទិសលក្ខណា ទ្រង់នូវលក្ខណាល្អដូចគ្នា ហាក់ដូចពុម្ពមួយ ពុំមាន ឃ្លាតឃ្លៀងល្អៀងដល់តិចឡើយ ឯកោ ឯកា ឯកុមារា ហាក់ ដូចជាបាជាលីចៅសម្លាញ់អញ មួយតូចនោះមិញ ដូចនាងក្រស្នា ត្រូវដូចពាក្យហោរាទំនាយ មានរូបឆោមឆាយឥរិយា លំនាំ

សមសារសមជាកូនត្រកូលក្សត្រ ទើបពុំគិតក្រែងខ្លាច អាចដើរមកដល់នេះ **សីហា ពិលាវ និក្ខន្តា** យាត្រាបីដូចកលកេសររាជសីហ៍ ដ៏មានរឹទ្ធិមហិមា ចេញអំពីគូហាកែវប្រសើរ ដ៏មានដំណើរល្អដូច្នោះ **ឧភោ សម្បត្តិរូបកា** អស់អង្គកាយានោះ ក៏មានពណ៌សម្បុរល្អយល់អើតឆាយ **ជាតរូបមយាវេតេ ឥមេ ទិស្សន្តិ ទារកា** បីដូចជាសុវណ្ណដ៏មានរស្មី អញនឹងបានយល់រាជកុមារីកុមារា អ្នកយាត្រាមកដល់ជាប្រាកដ ឥឡូវនេះឯង ។

បពិត្រអើយ ព្ធដ៏កាលនោះ ព្រះបាទក្រុងស្រីសញ្ជ័យនរិន្ទរាជាឥស្សរចមក្សត្រ ព្រះអង្គសរសើរព្រះរាជនត្តានត្តា ដោយនូវបាទព្រះគាថាបីបទស្រេចហើយ ពុំយូរឡើយ ត្រាស់ប្រើអមាត្យមួយឱ្យចេញទៅយកជូជកព្រាហ្មណ៍ចាស់ជរាជាអ្នកអន្ធការ ហើយយកព្រះរាជកុមារទាំងពីរចូលមកថ្វាយព្រះអង្គជាប្រញាប់ ។ ក្សិណនោះ អមាត្យស្ដាប់ព្រះរាជឱង្ការហើយ ពុំលង់ឡើយ ក៏រត់ចេញទៅចាប់យកព្រាហ្មណ៍ នូវព្រះរាជកុមារមកថ្វាយដោយនូវព្រះបរមរាជឱង្ការ ។ ឯព្រះបាទក្រុងស្រីសញ្ជ័យ កាលណាបើព្រាហ្មណ៍ចាស់ជរាមកដល់ហើយ ព្រះអង្គពុំឱ្យអមាត្យរាជសេនា ដណ្ដឹងឡើយ ព្រះអង្គត្រាស់ដណ្ដឹងផ្ទាល់នឹងព្រះឱស្ឋព្រះអង្គឯងឱ្យប្រាកដសូត្រជាបាទព្រះគាថា ដូច្នេះ

កុតោ នុ ត្វំ ភារទ្វាជ ឥមេ អានេសិ ទារកេ
អជ្ជ រដ្ឋមនុប្បត្តោ កុតោ អាគច្ឆសិ ព្រាហ្មណាតិ ។

អើព្រាហ្មណ៍អើយ អញចង់ដណ្ដឹងព្រះស្ដែង ព្រាហ្មណ៍ឯងជាពូជពង្សវង្សាអ្នកស្ងូមសូមទាន ចូរព្រះស្ដែងប្រាប់អញឱ្យបានដឹងតែដោយនូវពិតកុំមុសា ឥមេ អានេសិ ទារកេ រីឯកុមារីកុមារានេះ តើព្រាហ្មណ៍បានមកអំពីឋានឯណាហ៊ឹះ អជ្ជ រដ្ឋមនុប្បត្តោ នាំមកប៉ុន្មានថ្ងៃហើយ ទើបបានដល់ពិជ័យជេតុត្តរបវររាជធានី ណ៎ាព្រាហ្មណ៍ ចូរព្រះស្ដែងប្រាប់អញតាមពិត ។

មយ្ហន្តេ ទារកា ទេវ ទិន្នា ចិត្តេន សញ្ជយ
អជ្ជ បណ្ណរសា រត្តិ យតោ លទ្ធា មេ ទារកាតិ ។

ជូជកោ អាហ ជូជកឮហើយក៏ភិតខ្លាច ពុំអាចនៅស្ងៀមបានឡើយ ហើយក្រាបទូលស្នងព្រះរាជឱង្ការថា សញ្ជយ បពិត្រព្រះភូមិន្ទនរនាថ ព្រះបាទនារាយណ៍នរបតីស្រីសម្មតិទេព មហារាជក្សត្រថ្លៃប្រសើរអម្ចាស់ខ្ញុំអើយ រីឯព្រះរាជកុមារទាំងពីរនេះ គឺព្រះបាទស្រីវេស្សន្តរព្រះអង្គទ្រង់ព្រះតម្លាសទ្ធាឱ្យទានមកខ្ញុំតាជី ចិត្តេន ត្បិតព្រះអង្គមានព្រះរាជហឫទ័យត្រេកាលសោមនស្សនឹងដូរយកព្រះប្រាជ្ញាសាពេ៌ជ្ញូតាញ្ញាណ យតោ លទ្ធា នាកាលទទួលព្រះរាជទានខាងឯខ្នើតបណ្ណរសី ខ្ញុំតាជីនាំមក បណ្ណរសទិវសា បាន ១៥ ថ្ងៃហើយអម្ចាស់ ។

កេន វាចាយ បេយ្យេន សម្មា ញាយេន សទ្ទហេ
កោ តេ តំ ទានមទ្ទទា បុត្តកេ ទានមុត្តមន្តិ ។

រាជា អាហ ទើបមហាក្សត្រត្រាស់ថា អើតាជីអើយ ចូរ

ឆ្លើយវិញទៀតមើល ត្បិតអញយល់ពុំសម ធម្មតាប្រពៃណីសត្វក្នុងវដ្តសង្សារទាំងឡាយ នៅនាលោកិយ ឯបុត្រាបុត្រី ទុកស្មើនឹងជីវិត ដូចម្តេចក៏គិតកាត់ឱ្យជាទាន ដូច្នេះបាន កេន វាចាយ បេយ្យេន ឬមួយព្រាហ្មណ៍លួងលោមដោយនូវវាចាឯណា ព្រះទ័យព្រះអង្គ កាត់តម្លាសទ្ធាស្រាប់ពិតមែន តែម្តេចក៏យកបុត្រឱ្យជាទាន យល់ជាពុំដែលមាន ប្លែកក្រៅវិស័យជាអស្ចារ្យ បើដូច្នោះតើព្រះស្តេងនឹងយកអ្វីមកជាបន្ទាល់សាក្សី សន្ធហេ ឱ្យអស់មុខមន្ត្រីគេជឿជាក់ប្រាកដផងមើល ណ៎ាព្រាហ្មណ៍ ៗ

យោ យាចតំ បតិដ្ឋាសិ ភូតានំ ធរណីរិវ
សោ មេ វេស្សន្តរោ រាជា បុត្តេនាសិ វនេ វសំ ៗ
យោ យាចតំ គតិ អាសិ សវន្តីនំវ សាគរោ
សោ មេ វេស្សន្តរោ រាជា បុត្តេនាសិ វនេ វសន្តិ ៗ

ជូជកោ អាហ ជូជកក្រាបបង្គំទូលថា បពិត្រអម្ចាស់ តាមតែទ្រង់ព្រះមេត្តាប្រណី សេចក្តីទាំងនេះ ខ្ញុំពុំដឹងបើនឹងគិត តែដោយនូវពិតពុំមុសា ត្បិតព្រះអង្គគង់នៅព្រៃឆ្ងាយ ពន់ប្រមាណសូមទានពុំរេចរ តែនឹងទ្រង់ព្រះមេត្តាអធ្យាស្រ័យ ៗ យោ វេស្សន្តរោ ឯសម្តេចព្រះវេស្សន្តរពោធិវង្ស ព្រះអង្គតែងជាទីពឹងពំនាក់នៃមនុស្សសត្វគោកយាកលំបាកផងទាំងឡាយ ធរណីរិវ ដូចកលប្រឹថពី មួយសោត ដូចកលសមុទ្រសាគរ រីអស់សព្វសត្វផងទាំងឡាយ ក៏តែងតែអាស្រ័យព្រះអង្គ ដ៏មាននូវព្រះគុណ ជា

ឧឡារមហាឧត្តម ជាបឋមបរមក្សត្រ ឥតមានអ្នកឯណាមួយស្មើនឹងព្រះអង្គបាន ទើបព្រះរាជទានព្រះរាជកុមារទាំងពីរ ឱ្យមកខ្ញុំព្រះអង្គ ដោយនូវពិតឥតមុសា តាមតែទ្រង់ព្រះមេត្តាករុណាប្រណី ខ្ញុំតាជីចាស់ជរា នាកាលគ្រានោះឯងហោង ៗ

ទុក្ខំ វត ភោ រញ្ញា   សញ្ជេន   យសមេសិនា
កថន្នុ បុត្តកេ ទជ្ជា   អរញ្ញេ   អវរុទ្ធកេ ៗ
ឥមំ ភោន្តោ និសាមេថ   យាវន្តេត្ថ សមាគតា
កថំ វេស្សន្តរោ រាជា   បុត្តេទាសិ វនេ វសំ ៗ
ទាសំ ទាសិញ្ច សោ ទជ្ជា   អស្សំ ចស្សតរី រថំ
ហត្ថិញ្ច កុញ្ជរំ ទជ្ជា   កថន្នុ បុត្តកេ ទជ្ជា ៗ
សុវណ្ណំ រជតំ សិលំ   មុត្តា វេឡុរិយា មណិ
បវាឡរតនំ ទជ្ជា   កថំ សោ ទជ្ជ ទារកេតិ ៗ

កាលនោះ អស់សេនាមាត្យផង បានស្ដាប់ជូជកព្រាហ្មណ៍ដោះសា ដោយដំណើរសេចក្ដី យកព្រះមហាវេស្សន្តរជាបន្ទាល់សាក្សី ក៏យល់ពិតពុំមុសា ទើបព្រមគ្នានិន្ទាថា ភោន្តោ នគរវាសិនោ ហៃអស់អ្នកនគរ បណ្ដានៅពិជ័យជេតុត្តរ យាវន្តេត្ថ សមាគតា អម្បាលអ្នកមកជួបជុំគ្នា នៅនាឋាននេះទាំងប៉ុន្មាន សព្វេ តើអ្នកទាំងពួង ញុំាងយល់នូវសេចក្ដី ដូចម្ដេចប៉ាះ និសាមេថ ចូរអ្នកពិនិត្យពិចារណាដំណើរសេចក្ដីនៃព្រះបាទស្រីវេស្សន្តរ ទុក្ខំ ព្រះអង្គធ្វើអំពើកម្មពុំតាម

ប្រពៃណីអំពីបុរាណរៀងមក **សន្ទេន ឃរមេសិនា** កាលអំពីមុនពុំទាន់បានបួសជាឫសីមុនី នៅនៃព្រះស្រីពិជ័យជេតុត្តរនគរសោយរាជសម្បត្តិ ម្តេចក៏កាត់ដំរីបច្ច័យនាគេន្ទ្រគជសារល្អត្រកាលជាតិកុញ្ជរ ជាទីនាំងសម្រាប់ព្រះនគរបវររាជធានី ឱ្យទៅជាទាន ទើបបានជាគេក្រេវក្រោធអស់ទាំងព្រះនគរ បំបរបង់ឱ្យព្រាត់ព្រះញាតិវង្សា ទៅនៅអនាថាក្នុងព្រៃទូរដ្ឋាន ក៏អាល័យអ្វីតែនឹងទានមាល្បាយ ពុំដឹងស្តាយកូនទាំងពីរនេះឡើយពុំគិតប្រពៃណី ឯព្រះហឫទ័យក៏កន្រ្ទឹសឫស្យា គួរឯណា ក៏យកបុត្រឱ្យទានដូច្នេះហ៎ះ **ឱរសំ ឱរសិញ្ចូ សោ ឱជូ** ឯធម្មតាប្រពៃណីក្សត្រ បើនឹងមានចិត្តកាត់តម្លាសទ្វាធ្វើជាទាន ក៏មានតែឱ្យនូវរាជយាន រទេះ សេះ ដំរី ឱ្យខ្ញុំប្រុសខ្ញុំស្រីរបស់ទ្រព្យសព្វពិធរតន៍ផងទាំងឡាយ **ទជំ សោ ឧជូ ឱរសេ** អើអេះនេះម្តេចក៏មកផ្តាច់សាច់កូនឱ្យទៅជាទាន ពុំមានគិតឡើយ អើ ! អស់គ្នាយើងអើយ ព្រះបាទស្រីវេស្សន្តរនេះអ្នកធ្វើឱ្យខុសសណ្តាប់ច្បាប់ព្រះមហាក្សត្រអំពីបុរាណរាជ្យរៀងមកនោះណាស់ហោង

កាលនោះ ព្រះជាលីកុមារជិនវង្ស ដ៏ទ្រង់នូវកតញ្ញូតា ដឹងគុណព្រះវររាជមាតាបិតា **សុត្វា** កាលណាបើឮអស់មុខមន្ត្រីគេស្រដីនិន្ទាដល់ព្រះបិតាដូច្នោះហើយ **អសហន្តោ** ពុំអាចដើម្បីនៅស្ងៀមបានឡើយ ទើបឆ្លើយដោះសាការព្រះបិតា **ឧបត្ថម្ភេន្តោ** **ទិយ** ឧបមាបីដូចពិទ្យាធរដ៏ពូកែឆុតឆាប់ បាន

និម្មិតនូវជើងដែមួយពាន់ ឱបក្ដំព្រះសិនេរុរាជ ពុំឱ្យរលើងរលំជាចលាចល ព្រោះត្បិតខ្យល់ប្រល័យលោក បក់បោកមក ពុំឱ្យអន្តរាយឡើយ ទើបអ្នកក្រាបទូលអធិប្បាយ សូត្រជាបាទព្រះគាថា ដូច្នេះ

យស្ស នាស្ស យវេ ឃាសោ   អស្សា វាស្សតរី រថោ
ហត្ថី ច កុញ្ជរោ នាគោ   កឹ សោ ឧដ្ឋា បិតាមហា ។
យស្ស នាស្សស្ស មេ សីលំ   សុវណ្ណំ រជតំ មណិ
បតាឡរតនញ្ចេវ   កឹ សោ ឧដ្ឋា បិតាមហាតិ ។

បិតាមហា បពិត្រសម្ដេចព្រះរាជអយ្យកោអើយ ម្ដេចឡើយក៏ពួកអាមាត្យនាំគ្នានិន្ទាសម្ដេចព្រះវរបិតាខ្ញុំ ហេតុត្បិតអ្នកទៅនៅក្នុងព្រៃព្រឹក្សា យស្ស នាស្ស យវេ ឃាសោ នាកាលសម្ដេចព្រះវររាជបិតាចេញចាកបុរី ពុំមានអ្វី ជាទ្រព្យសម្បត្តិសព្វពិធរ័តន៍ ខ្ញុំប្រុសខ្ញុំស្រី ដំរី សេះ រទេះ គោក្របី នឹងធ្វើជាទានដូចអស់ត្រកូលក្សត្រអំពីបុរាណរាជ្យរៀងមកឡើយ បពិត្រសម្ដេចព្រះអយ្យកោអើយ រីឯព្រះរាជហឫទ័យ សម្ដេចព្រះវររាជបិតាតែងនឹងកាត់តម្លាសទ្វាធ្វើទាន បានយល់តែមុខបុត្រាបុត្រី ជាពាហិរទាន ក្រៃលែងនឹងអស់ទានផង បាន ១០០ កម្លាំង តាំងព្រះរាជហឫទ័យ នឹងដូរយកព្រះសព្វញ្ញាតញ្ញាណ ឱ្យបានត្រាស់ជាព្រះពុទ្ធតាមប្រពៃណីព្រះពុទ្ធអំពីបុរាណ ស្ពាងព្រះបារមីទាន តាមព្រះរាជហឫទ័យ ប្រាថ្នាឱ្យបានមគ្គផល ម្ដេចឡើយក៏ពួកមនុស្ស

អកុសល មកត្មះតិះដៀលនិន្ទាដល់ព្រះវររាជបិតាខ្ញុំ មិនដឹងទេឬជាប្រទីបផ្កាលារកែវ ជាពន្លឺអស់សព្វសត្វ ម្ដេចឡើយ ក៏មកស្អាត់ស្រដី ការអ្វីមកស្រដីឆោឡោអឹងកង ឯសម្ដេចព្រះអយ្យកោ តើយល់ព្រមដូចពាក្យអស់មុខមន្ត្រីហើយឬអ្វីណាំអម្ចាស់ ។

កាលនោះ សម្ដេចព្រះអយ្យកោ ទ្រង់ជ្រាបជាចៅជាលីតូចព្រះទ័យ ទើបព្រះអង្គប្រស្រ័យនូវពាក្យបរិហារ តាមដោយនូវព្រះប្រាថ្នារម្ងាប់ក្ដីក្រោធ យកទោសមកជាគុណ ថា ដូច្នេះ

ទានមស្ស បសំសាម   ន ច និន្ទាម ពោតក
កថន្នុ ហទយំ អាសិ   តុម្ហេ ទត្វា វនិព្វកេតិ ។

ពោតក ហៃជាលីដ៏ជាចៅសម្លាញ់អើយ អើអេះអ្នកនេះមិញហ្ន៎ ក៏មានប្រាថ្នាដឹងអធ្យាស្រ័យ កុំអាលស្រដីក្រេវក្រោធធ្វើជាទោស ន ច និន្ទាម អស់អ្នកទាំងឡាយសោត គេពុំរកកលកាច់កិនញុះញង់ ចង់ត្មះតិះដៀលឪពុកអ្នកទេ បសំសាម គេសឹងតែសរសើរអស់ទាំងព្រះនគរ សាទរជួយអនុមោទនាថា ព្រះបិតាអ្នកនេះ មានចិត្តកាត់តម្លាសទ្ធាប្រសើរពន់ប្រមាណ អាចយកបុត្រឱ្យទៅជាទាន ពុំមានរួញរា តុម្ហេ ទត្វា វនិព្វកេ នាកាលព្រះវររាជបិតាឱ្យទានអ្នកមកជាទាសាទាសីនៃព្រាហ្មណ៍តាមប្រាថ្នា តើញុាំងសោមនស្សប្រិមប្រិយ ឬមានព្រះរាជហឫទ័យសៅហ្មង ចងជាទោស ពុំក្សេមក្សន្ដ ម្ដេចក៏ហ៊ាន កាត់អ្នកឱ្យជាទានបាន ពុំមានអាល័យឡើយ ហៃចៅសម្លាញ់អើយ

ចូរអ្នកប្រាប់ព្រះអយ្យកោឱ្យបានដឹង នាកាលឥឡូវនេះឯង ។

បិតា មយ្ហំ មហារាជ   អម្ហេ ទត្វា វនិព្វកេ
សុត្វាន កលូនំ វាចំ   អម្មកណ្ហាយ ភាសិតំ ។
ទុក្ខមស្ស ហទយំ អាសិ   អថោ ឧណ្ហំបិ អស្សសិ
រោហិណី ហេវ តាម្ពក្ខី   បិតា អស្សូនិ វត្តយិ ។
យន្តំ កណ្ហាជិនាវោច   អយំ មំ តាត ព្រាហ្មណោ
លដ្ឋិយា បដិកោដេតិ   ឃរេ ជាតំវ ទាសិយំ ។
ន ចាយំ ព្រាហ្មណោ តាត   ធម្មិកា ហោន្តិ ព្រាហ្មណា
យក្ខោ ព្រាហ្មណវណ្ណេន   ខាទិតុំ តាត នេតិ នោ
នីយមានា បិសាចេន   កិន្នុ តាត ឧទិក្ខសីតិ ។

កាលនោះ ព្រះជាលី ក្រាបបង្គំទូលសម្តេចព្រះអយ្យកោ អយ្យិកាអំពីនាងក្រស្នាពិលាប ក្រាបទូលអង្វរព្រះវររាជបិតា ដូចមានសេចក្តីនៅក្នុងកណ្ឌកុមារបព្វឯណោះ មកក្រាបបង្គំទូលសម្តេចព្រះអយ្យកោ ឱ្យទ្រង់ព្រះសណ្តាប់សព្វគ្រប់ប្រការ ។

រាជា សញ្ជយោ រីឯព្រះបាទស្រីសញ្ជ័យ ព្រះអង្គយល់ព្រះរាជនត្តានត្តា អមុញ្ចន្តេយេវ នៅជាទាសាទាសី នៃព្រាហ្មណ៍នោះឯង ពុំលង់ឡើយ ព្រះអង្គត្រាស់ដណ្តឹង ថា

រាជបុត្តី ច វោ មាតា   រាជបុត្តោ ច វោ បិតា
បុព្វេ មេ អង្កមារុយ្ហ   កិន្នុ តិដ្ឋថ អារកាតិ ។

ហៃចៅជាលីក្រស្នាសំឡាញ់ជីតាអើយ អើព្រះជនកនៃអ្នក

រាជបុត្តោ ក៏ជាពង្សវង្សក្សត្រា ជារាជបុត្របណ្តាល **រាជបុត្តី** ទាំងព្រះមាតា ក៏ជាត្រកូលក្សត្រី កបកល្យាណីសុរិយវង្ស មុញ្ច ពីដើម អ្នកតែងទ្រង់អស់គ្រឿងប្រដាប់អាត្មា បើបានយល់ព្រះអយ្យកោអយ្យិកា ក៏តែងតែនឹងផ្តេកផ្តិត បើនឹងគាល់សោតក៏ជិតពុំដែលឆ្ងាយ ឱ្យបានតែសប្បាយតម្រេកព្រះហឫទ័យ ពីដួចចេញចាកព្រះអយ្យកោអយ្យិកាទៅនៅព្រៃ ពុំទាន់ជាយូរ បានប៉ុន្មានខែ ម្តេចក៏មកប្រែខ្វៃ ប្លែកទាំងឥរិយា លំនាំសមសារជាអ្នកក្រៅ ហាក់ដូចជាពុំដែលទៅមកស្គាល់គ្នា ហាក់ដូចមិនមែនសាច់ញាតិហះ ។

ទើបព្រះជាលីកុមារ ក្រាបបង្គំទូលសម្តេចព្រះអយ្យកោ ថា

រាជបុត្តី ច នោ មាតា   រាជបុត្តោ ច នោ បិតា
ទាសា មយំ ព្រាហ្មណស្ស   តស្មា តិដ្ឋាម អារកាតិ ។

បពិត្រព្រះអង្គ ដ៏ទ្រង់ព្រះមេត្តាប្រណី រាប់យើងខ្ញុំជាលីក្រស្នា នេះ ជាត្រកូលខត្តិយវង្ស យើងខ្ញុំជាលីក្រស្នា ក៏អរនឹងព្រះគុណពន់ប្រមាណ នឹងយកអ្វីមកប្រៀបផ្ទឹមពុំបានឡើយ **ទាសា មយំ** បពិត្រអម្ចាស់អើយ តែយើងខ្ញុំនៅជាទាសាទាសីព្រាហ្មណ៍នៅឡើយ ក្រែងព្រះអង្គបានអាស្រូវកាស ហើយក្រែងអស់មន្ត្រីនូវអាណាប្រជានុរាស្ត្រ គេត្មះតិះដៀល និន្ទាដល់ព្រះវររាជបិតា **តស្មា តិដ្ឋាម អារកា** យើងខ្ញុំខ្លាចព្រះចេស្តាបារមី ទើបគាល់នៅតែពីចម្ងាយ ព្រោះសេចក្តីតែប៉ុណ្ណោះឯងអម្ចាស់ ។

ទើបព្រះបាទក្រុងស្រីសញ្ជ័យ   មានព្រះបន្ទូលថា

មា សម្មេវំ អច្ចុត្ត   ឌយ្ហតេ ហទយំ មម
ចិតកាយំច មេ កាយោ   អាសនេ ន សុខំ លភេ ។
មា សម្មេវំ អច្ចុត្ត   ភិយ្យោ សោកំ ជនេថ មំ
និក្ខិណិស្សាមិ ទព្វេន   ន វោ ទាសា ភវិស្សថ ។
កិមគ្ឃិយំ ហិ វោ តាត   ព្រាហ្មណស្ស បិតា អទា
យថា ភូតំ មេ អក្ខាថ   បដិបាទេន្តុ ព្រាហ្មណន្តិ ។

អើ! ចៅជាលីសំឡាញ់ជីតាអើយ ម្ដេចឡើយ ក៏ចៅចេះស្រដីថែទាំចាំពាក្យពេចន៍សព្វសេចគ្រេចវាចា ហាក់បញ្ញៀសត្រូវដល់ជីតានេះផងហៈ អច្ចុត្ត ជីតានេះនឹងសុំឃាត់អ្នក កុំឱ្យអ្នកស្រដីខ្លីខ្លាឱ្យឈឺផ្សាក្នុងចិត្ត ឌយ្ហតេ ហទយំ មម ប្រដូចអ្នកយកភ្លើងមកគរដុតឱ្យក្ដៅក្រហាយ ចិតកាយំច មេ កាយោ បីដូចយកជីតាទៅដាក់ក្នុងភ្លើងជើងក្ករឱ្យរោលរាលឆុរឆេះជាពពុះផេះផង់ធូលី អាសនេ ន សុខំ លភេ ទោះនឹងដើរ នឹងដេក នឹងឆី នឹងចុក ពុំមានសុខឡើយ ហៃចៅសំឡាញ់អយ្យកោអើយ អ្នកស្រដីនោះមិញស្មោះស្មើឱ្យជីតាជាទុក្ខសោកសល់អំពល់ក្នុងចិត្ត គិតដ៏មានច្បាប់ឯណាដែរឬ ក្សត្រាទៅជាខ្ញុំគេ ដូចអ្នកស្រដីនោះ យល់ពុំសម សត្វហង្សនឹងច្រឡំដោយហ្វូងក្អែកយល់ប្លែកក្រៅវិស័យ ន វោ ទាសា ជីតានឹងលោះអ្នកឱ្យរួចចេញអំពីខ្ញុំព្រាហ្មណ៍ តាមតម្លៃ កុំសង្ស័យបារម្ភក្រៀមក្រំ

ក្នុងចិត្តគិតជាទុក្ខពេកឡើយ និមត្តិយំ នាកាលព្រះបិតាអ្នកឱ្យអ្នកជាទាសាទាសីនៃព្រាហ្មណ៍នោះ តើព្រះបិតាកាត់ថ្លៃប៉ុន្មាន ៗ ម្នាក់ហ្ន៎ៈ យថាភូតំ ចូរអ្នកក្រាបទូលជីតា ឱ្យបានដឹងប្រាកដ បដិបាទេន្តុ សោះព្រះជីតាអផ្សុកជាទុក្ខក្នុងចិត្ត គិតនឹងឱ្យថ្លៃទៅយាចកឱ្យស្រឡះ សោះមានមន្ទិលណាចៅអើយ ។

ចៅជាលីស្តាប់ហើយ ក្រាបបង្គំទូលស្នងព្រះរាជឱង្ការថា

សហស្សគ្ឃំ ហិ មំ តាត ព្រាហ្មណស្ស បិតា អទា
អគ្ឃំ កណ្ហាជិនំ កញ្ញំ ហត្ថិអាទិសតេន ចាបិ ។

បពិត្រព្រះករុណា នាកាលសម្តេចព្រះវររាជបិតា ព្រះរាជទានខ្ញុំអម្ចាស់ត្រាស់កាត់ថ្លៃ ថា សហស្សគ្ឃំ ជាសុវណ្ណ១ ពាន់តម្លឹង តែថ្លៃខ្លួនខ្ញុំម្ចាស់ កណ្ហាជិនំ កញ្ញំ ឯនាងក្រស្នានារី ហត្ថិអាទិសតេន ច ព្រះអង្គកាត់ថ្លៃជាខ្ញុំប្រុស-ស្រី ដំរី សេះ រទេះ គោឧសភរាជ មួយមុខមួយរយ ៗ នូវមាសឆ្អិនមួយពាន់តម្លឹងស្មើគ្នា ។

ទើបព្រះអង្គត្រាស់ថា អើប៉ុណ្ណោះទេហ្ន៎ ! ទើបស្តេចត្រាស់បង្គាប់ពួកភ្នាក់ងារ ថា

ឧដ្ឋេហិ កត្តេ តរមានោ ព្រាហ្មណស្ស អវាករិ
ទាសីសតំ ទាសសតំ គវំ ហត្ថូសភំ សតំ
ជាតរូបសហស្សញ្ច បោតានំ ទេហិ និក្កយំ ។
តតោ កត្តា តរមានោ ព្រាហ្មណស្ស អវាករិ

ទាសីសតំ ទាសសតំ គវំ ហត្ថិសតំ សតំ
ជាតរូបសហស្សញ្ច ភោគានំ ទាសិ និក្ខយន្តិ ៗ

វឺយ! ចៅភ្នាក់ងារ ចូរកុំយូរ ទៅឱ្យឆាប់ៗ យកទ្រព្យ អំពីព្រះរាជឃ្លាំង ដោយភ្នាក់ងារទីទៃៗ អញនឹងឱ្យថ្លៃចៅអញ ព្រាហ្មណស្ស អទាសិ ទើបអស់ភ្នាក់ងារ ឮព្រះរាជឱង្ការ ដូច្នោះហើយ ពុំយូរឡើយ ក៏រត់ទៅវៃៗ យកមាសត្ថិនពីរពាន់ តម្លឹង និងខ្ញុំស្រី ១០០ ខ្ញុំប្រុស ១០០ គោបាព្រោះ ១០០ មេគោ ឆ្នាត់ ១០០ ដំរី ១០០ សេះ ១០០ រទេះ ១០០ មកឱ្យជូជក ព្រាហ្មណ៍ស្រេចហើយ ទើបស្ដេចព្រះរាជទានប្រាសាទ ៧ ជាន់ ឱ្យជារង្វាន់ជូជកព្រាហ្មណ៍ព្រឹទ្ធាចារ្យ នាកាលនោះឯងហោង ៗ

តមត្ថំ បកាសេន្តោ សត្ថា អាហ ៗ យំ អត្ថំ វីអាថ៌ ធម៌ឯណា ន បាកដំ ពុំទាន់ប្រាកដ សត្ថា វីព្រះសាស្ដាចារ្យ បកាសេន្តោ កាលព្រះអង្គសម្ដែង តំ អត្ថំ នូវអាថ៌ នោះ បាកដំ ឱ្យប្រាកដ អាហ ក៏ទ្រង់សូត្រជាអាថ៌បាទ ព្រះគាថា ដូច្នេះ

និក្កីណិត្វា នហាបេត្វា ភោជយិត្វាន ទារកេ
សមលង្ករិត្វា ភណ្ឌេហិ ឧច្ចង្គេ ឧបវេសយុំ ៗ
សីសំ ន្ហាតេ សុចិវត្ថេ សព្វាភរណភូសិតេ
រាជា អង្កេ ករិត្វាន អយ្យកោ បរិបុច្ឆថ ៗ
កុណ្ឌលេ ឃុសិតេ មាលេ សព្វាលង្ការភូសិតេ

រាជា អង្កេ ករិត្វាន ឥទំ វចនមព្រវិ ។
កច្ចិ ឧភោ អរោគា តេ ជាលិ មាតាបិតា តវ
កច្ចិ ឧញ្ឆេន យាបេន្តិ កច្ចិ មូលផលា ពហូ ។
កច្ចិ ឌំសា មកសា ច អប្បមេវ សិរីសបា
វនេ ពាឡមិគាកិណ្ណេ កច្ចិ ហឹសា ន វិជ្ជតីតិ ។

រាជា សញ្ជយោ រីឯព្រះបាទស្រីសញ្ជ័យ និក្ខីណិត្វា នាកាលព្រះអង្គលោះព្រះចៅទាំងពីរស្រេចហើយ ពុំលង់ឡើយ ស្តេចបីថ្នមលោមព្រះចៅទាំងពីរ ថើបព្រះសិរសា អង្អែលអស់អង្គ ទើបឱ្យព្រះញាតិវង្សា នូវអស់ព្រះស្នំតូចធំជំទាវ នាងខុនណាងផងទាំងឡាយ រៀបខ្វល់ខ្វាយទទួលព្រលឹងជាលីក្រស្នា សឹងតែស្រីកញ្ញាប្រិមប្រិយ សឹងតែកូនមន្ត្រីល្អៗឧត្តម សមនូវរូបរាងបញ្ចង់ ស្អាងអង្គប្រដាប់ប្រដា ដោយនូវអាត្មាទីទៃ ៗ ស្រេចហើយនៃ ក្រាបថ្វាយបង្គំទូល ចាំទទួលព្រះរាជឱង្ការ ហើយឱ្យជាលីក្រស្នាស្រង់ជម្រះព្រះកាយ បំបាត់ក្តៅក្រហាយ ឱ្យកើតស្រីសួស្តីមង្គលឧត្តម ទើបឱ្យអស់ស្រីព្រះស្នំជម្រះ ដុសខាត់ព្រះអង្គ អស់ស្រីផងបបួលគ្នាត្រេកអរសាទរ ខ្លះយកទឹកសុគន្ធពិដោរ ស្រោចស្រពព្រះកាយ នាងខ្លះលើកព្រះឆាយ ឆ្លុះព្រះអង្គ ខ្លះយកសុគន្ធរស ផាត់ផង់ភក្ត្រា ព្រះភីលៀងយកប្រេងប្រុងព្រះកេសាកេសី អស់អង្គព្រះរាជកុមារាកុមារី សឹងពិដោរល្វេងល្វើយ ហើយទើបព្រះភីលៀងចុកចងព្រះកេសាកេសី ដ៏មាននូវ

រស្មីនោះរលេមរលង់ត្រចង់ត្រចះជ្រះថ្លា **ភោជយិត្វាន ធារកេ** ប្រដាប់ព្រះរាជនត្តានត្តាស្រេចហើយ ស្តេចឱ្យសោយភោជនាហារដ៏មានឱជារស **សមលង្ករិត្វា** ហើយទើបប្រដាប់ប្រដាព្រះរាជកុមារ **ភណ្ឌេន** ឱ្យទ្រង់គ្រឿងពិចិត្រ និងរត្នមណី ភ្លឺព្រោងព្រាយ **សុចិទត្តេ** ព្រះភូសាប៉ាក់ឆ្លាក់ជាកនកៈក្លាយ ឆាឆាយប៉ាក់ជាបញ្ចពណ៌ យល់ជាស័ក្តិសម **កុណ្ឌលេ** ទ្រង់នូវព្រះមកុដដ៏ឧត្តមថ្លៃថ្លាប្រដាប់ប្រដានូវតាងគុលីកុត្រី ស្នៀតសក់សុពណ៌បាទុក៏ សឹងល្អរចនា **ឃុសិតេ** ឯព្រះហត្ថាទ្រង់នូវព្រះកងករច្រើន មានពណ៌ប្លែកៗ ច្រាលឆ្អៅ **មាលេ** ទើបឱ្យសម្តេចព្រះចៅអ្នកទ្រង់នូវមាលា **សព្វាលង្ការភូសិតេ** សឹងរចនាដោយកែវកែមផ្កាក្រងចងប្រដាប់ព្រះរាជកុមារ ជាសង្វារផ្ទិមអម្ពរ យល់ប្រសើររុងរឿងទាំងពីរស្រស់ស្រួល មុខគួរឱ្យអាសូរករុណា **រវេវ សេទ្ធេ ភរិត្វា** ទើបព្រះអង្គ ដ៏ជាឥសូរក្រុងពិជ័យជេតុត្តរនគរបវររាជធានី ពព្រះជាលីចៅសម្លាញ់ឯព្រះអយ្យិកាមិញ ពនាងក្រស្នា ទើបត្រាស់បង្គាប់ថា ឱ្យអស់អ្នកពិសេសឆ្វេងស្តាំទាំងឡាយ ឱ្យខ្វល់ខ្វាយ រៀបរណ្តាប់អស់ភោជនាហារផង ត្បិតអញនឹងរៀបចងព្រះហស្តចៅអញ ទាំងពីរៗ សម្តេចព្រះអយ្យិកា ក៏ត្រេកអរក្សេមក្សាន្ត ទើបបានរៀបបូជាគ្រោះ រំដោះចង្រៃសារពើភ័យទុក្ខព្រួយ ឱ្យបានជាសុខសម្រឹទ្ធី ទើបត្រាស់ថា ស្រីៗ ថ្ងៃនេះ ជាថ្ងៃសួស្តីឧត្តម

ជាបឋមបូក្សជា ៗ សម្តេចព្រះអយ្យកោ ព្រះអយ្យិកា ព្រះញាតិវង្សាព្រមគ្នាស្រេចហើយ ទើបស្តេចហៅព្រលឹងជាលីក្រស្នា ថា ព្រលឹងអើយ ! ចាប់ដើមតាំងអំពីព្រាត់ប្រាសចេញពីបុរី ទៅនៅព្រៃ ជ្រោះជ្រលងដងស្ទឹង បឹងបួទួលទី យកតែខ្មោចព្រៃមកជាគ្នា យល់តែអស់ពាឡម្រឹគា ព្យគ្ឃៈ សិង្ហ សីហ៍ ដំរី ប្រើស ទ្រាយ ទន្សាយ ខ្លោងខ្លា ៗ ព្រលឹងអើយ ! នេះហេតុវេរា ឱ្យព្រាត់ប្រាសចេញទៅ ឯព្រះអយ្យកោ អយ្យិកា នៅរងតែទុក្ខ ស្រក់តែទឹកភ្នែកជានិច្ចកាល នឹងបរិភោគអាហារ ក៏ពុំមានរសពីសា ក្នុងទ្រូងក្តៅផ្សា ដូចមនុស្សឥតវិញ្ញាណ ពួតែសព្វ ពត៌មានបាន ៧ ខែនេះហើយ ទើបថ្ងៃនេះ បានស្បើយរដោះទុក្ខ ព្រោះបានយល់មុខអ្នកជាចៅទាំងពីរ ៗ ព្រលឹងអើយ ! កុំទៅសព្វជ្រោះជ្រលងដងស្ទឹង អ្នកកុំខឹងនឹងអយ្យកោ អយ្យិកា ចូរអស់ខ្មោចព្រាយមកយកក្រយាបូជាគ្រឿងផង ឱ្យអ្នកបានគ្រងសព្វពិធរត្ន សម្បត្តិវេហ៍ពល ហើយអស់កុសលព្រះអយ្យកោអយ្យិកា មកជួយពិភ័ក្តិរក្សាការគ្រង កុំឱ្យមានទុក្ខសោករោគភ័យផងទាំងឡាយ ៗ ព្រលឹងអើយ ! កុំព្រាត់ប្រាសទៅអំពីអយ្យកោអយ្យិកា នូវព្រះញាតិវង្សា ឱ្យមានទីឃាយុយឺនយូរ បាន ១០០ ព្រះវស្សា ឱ្យមានយសសក្តាធិការសម្ភារបារមី ឱ្យគ្រងពិជ័យជេតុត្តរ ស្នងព្រះវររាជមាតាបិតា ព្រះអយ្យកោ អយ្យិកា ក៏នឹងបានផ្ញើខ្មោចលើអ្នកជាចៅ ៗ ទើបអស់ព្រះស្នំក្នុងក្រៅ

ក៏ឱ្យពរថ្វាយជ័យ អស់មុខមន្ត្រី ហោរា ព្រឹទ្ធាចារ្យ ក៏សឹងថ្វាយស័ព្ទសាធុការពរ ទ្រហឹងអឹងកង អស់ភ្លេងផង ក៏ប្រគំអឹងអាប់ សមនូវស័ព្ទត្រែស័ង្ខ រគាំង ភេរី តូរ្យតន្ត្រី ថ្វាយជ័យព្រះរាជកុមារទាំងពីរអង្គនុ៎ះឯងហោង ។

រីសម្ដេចព្រះអយ្យកោ អយ្យិកា នូវព្រះញាតិវង្ស កាលណាបើបានថ្វាយជ័យព្រះរាជកុមារ ស្រេចនូវប្រការអម្បាលនោះហើយ ពុំលង់ឡើយ ទើបត្រាស់ដណ្ដឹងព្រះជាលីថា ព្រះជនកព្រះជននីអ្នក ទៅនៅព្រៃ តើញុំាងប្រស្រ័យផ្លែឈើមើមឈើនូវសារពើបណ្ណាការ ជាអាហារបរិភោគ ផ្សារព្រៃ តើញុំាងប្រស្រ័យបានឬទេ មួយសោត ពាឡម្រឹគា សឹងសាហាវយង់ឃ្នង តើញុំាងមកបៀតបៀនពាធាយាយី ឱ្យជាទុក្ខពុំសុខក្សេមក្សាន្ត ឬឥតអន្តី មានឡើយ ហើយបានសេចក្ដីលំបាកតោតយ៉ាក ធ្ងន់ស្រាល មានប្រការនោះម្ដេច ៗ ណ៎ាចៅអើយ ចៅកុំលាក់ឡើយ ចូរចៅក្រាបទូលព្រះអយ្យកោអយ្យិកា នាកាលឥឡូវនេះឯងហោង ។

ទើបព្រះជាលីកុមារក្រាបទូល អំពីទុក្ខសោករោគភ័យ នូវសេចក្ដី

ពិធីហៅព្រលឹងព្រះរាជកុមារទាំងពីរនេះ មិនមានពោលទុកក្នុងជាតកបាលីទេ មានតែក្នុងច្បាប់មហាជាតក៏សម្រាយ ៗ (សេចក្ដីត្រង់នេះ សឱ្យឃើញថាជាសេចក្ដីរៀបរៀងផ្សែផ្សំតាមទំនៀមទម្លាប់របស់ស្រុក) ។

លំបាកសព្វសេចគ្រេច អំពីសម្តេចព្រះវររាជមាតាបិតា នៅនាព្រៃព្រះហេមពាន្ត មកនិទានថ្វាយសម្តេចព្រះអយ្យកោ អយ្យិកា ប្រាថ្នាឱ្យស្តេចលើកអស់រេហ៍ពលសកលសេនាយោធា ចេញទៅអារាធនាសម្តេចព្រះវររាជមាតាបិតា ឱ្យវិលមកគ្រងព្រះនគរ នាកាលគ្រានេះ ទើបព្រះជាលីកុមារ ក្រាបបង្គំទូល ថា

អថោ ឧភោ អរោគា តេ   នេច មាតាបិតា មម
អថោ ឧញ្ឆេន យាបេន្តិ   អថោ មូលផលា ពហូ ។
អថោ ឌំសា មកសា ច   អប្បមេវ សិរីសបា
វនេ វាឡមិគាកិណ្ណេ   ហឹសា នេសំ ន វិជ្ជតិ ។
ខន្តាលុកលម្ពានិ   វិឡាលិតក្កលានិ ច
កោលំ ភល្លាតកំ ពេល្លំ   សា នោ អាហច្ច បោសតិ ។
យញ្ចេវ សា អាហរតិ   វនមូលផលហារិយា
តំ នោ សព្វេ សមាគន្ត្វា   រត្តឹ ភុញ្ជាម នោ ទិវា ។
អម្មា ច នោ កិសា បណ្ឌុ   អាហរន្តី ទុមប្ផលំ
វាតាតបេន សុខុមាលី   បទុមំ ហត្ថគតមិវ ។
អម្មាយ បតនូកេសា   វិចរន្ត្យា ព្រហាវនេ
វនេ វាឡមិគាកិណ្ណេ   ខគ្គទីបិនិសេវិតេ ។
កេសេសុ ជដំ ពន្ធិត្វា   កច្ឆេ ជល្លមធារយិ
ចម្មវាសិ ឆមា សេតិ   ជាតវេទំ នមស្សតីតិ ។

បិតាមហា បពិត្រសម្តេចព្រះអយ្យកោអយ្យិកាជាអម្ចាស់

អើយ រីព្រះវររាជមាតាបិតានៃយើងខ្ញុំនោះ ព្រះអង្គគង់ជាសុខ
សប្បាយ ផ្សារជាអ្នកកម្សត់ទុគ៌តអត់ឃ្លាន អម្ចាស់អើយ ទ្រង់
តែងស្វែងរកផ្លែឈើមើមឈើនោះ សឹងមានច្រើនៗ មួយសោត
រីមូស ទាក ស្រាំង ស្រួយ ក្អែប ខ្មួយ មមង់ មមាច កន្ទេចអាល នូវសារពើពស់តូចធំ ច្រឡំនឹទៅនូវម្រឹគផង ទាំងឡាយ
ជាដើម គឺ ខ្លាតូច ខ្លាធំ ខ្លាឃ្មុំ ខ្លាដំបង ទន្សាយ ទន្សោង
រមាស រមាំង គោព្រៃ រាជសីហ៍ ដំរី សិង្ហ សឹងដ៏ស្រែកទ្រហឹងអឺងអាប់ ឮសព្ទសំឡេងទាំងយប់ទាំងថ្ងៃ សឹងតែសាហាវ
ពន្លឹក តែគឺមោះឥតមកបៀតបៀនក្សត្រទាំងពីរព្រះអង្គដោយ
នូវតេជះដែលទ្រង់តែងចម្រើនមេត្តាភាវនា មួយសោត គួរ
អាសូរព្រះមេនៃយើងខ្ញុំព្រះអង្គ ទ្រង់ចងព្រះកេសា ជាតាបសឫសី
ទន្ទឹងតែព្រឹកព្រហាមស្រាង ស្រេចឡើងហើយ ស្តេចទ្រង់យក
នូវកញ្ជើ សង្រែក ដងរែក ជ្រនីក ទម្ពក់ ស្តេចត្រាច់ដើរចូលព្រៃ
អាស្រ័យស្វែងរកជីកដំឡូងដូង ដំឡូងដៃខ្លា ដំឡូងស្បា ដំឡូង
ទៀន ដំឡូងពងប្រវឹក ដំឡូងពងលលក ហើយដើររកបេះ
ប្រលេះថ្ពក់យកនូវផ្លែស្រគំ គុយ គូលេន ធូរេន ដូង ស្លា មង្ឃុត
ល្មុត សេដា នូវអស់ផ្លែឈើផងទាំងឡាយ ទុកក្នុងកញ្ជើ ហើយ
រែកនាំមកចិញ្ចឹមយើងខ្ញុំទាំងបីអង្គានៅនាអាស្រមបរមសាលា
នោះហោង ៗ

បពិត្រព្រះជីតាអម្ចាស់ខ្ញុំអើយ រីព្រះនាងមទ្រី ជាព្រះមេ

នៃយើងខ្ញុំ មុខគួរអាសូរក្រៃពេក ទន្ទឹងតែព្រឹកឡើងហើយ ស្តេចដើរចូលព្រៃស្វែងរកផ្លែឈើមើមឈើ ដ៏មានសម្បុររាងកាយនោះស្គមលឿង ដោយត្រូវខ្យល់ត្រូវថ្ងៃ ព្រោះអ្នកធ្លាប់តែនៅស្រណុកសុខសប្បាយ លុះព្រះមេនៃយើងខ្ញុំ ដើរចូលព្រៃណាស់ទៅ ក៏មានព្រះកេសានោះជ្រុះស្តើងរលីង ដោយសសិតវារីតរួត ហើយជាប់ជំពាក់នឹងមែកព្រឹក្សាផង ព្រះមេនោះមានសម្បុរជាំដាំរលាករលោច ដូចផ្កាឈូកដែលគេកាន់ឈ្លី បពិត្រព្រះជីតាអើយ រីសម្បុរព្រះមេនៃយើងខ្ញុំ ក៏មានឧបមាដូចផ្កាឈូកនោះ ៗ

រីព្រះជាលីកុមារ ក្រាបទូលអំពីដំណើរទុក្ខព្រះវរមាតា នូវប្រការអម្បាលនោះ ហេតុតែមានព្រះហឫទ័យរលឹកព្រះវរមាតាច្រើនក្តាត់ ហើយមានបំណងចង់ឱ្យព្រះអយ្យកោអយ្យិកា ទៅអញ្ជើញមកកូវ ទើបព្រះជាលីកុមារ ពោលចោទព្រះអយ្យកោអយ្យិកា សូត្រជាបាទព្រះគាថាដូច្នេះ

បុត្តា បិយា មនុស្សានំ លោកស្មឹ ឧទបជ្ជិសុំ
ន ហិ នូនម្ហាកំ អយ្យស្ស បុត្តេ សិនេហោ អជាយថាតិ ៗ

បពិត្រព្រះជីតាអម្ចាស់អើយ ដូចយើងខ្ញុំសូមក្រាបបង្គំទូលឥឡូវនេះ ធម្មតាកូនប្រុសស្រី ដែលកើតមកនាលោកិយនេះ រមែងជាទីស្រឡាញ់ពេញចិត្តរបស់មាតាបិតា ចុះឯព្រះបាទស្រីវេស្សន្តរ ព្រះវររាជបិតានៃយើងខ្ញុំ ម្រាងពុំមែនជាព្រះរាជបុត្រ

អម្ចាស់ទេឬ ទើបអម្ចាស់ពុំសព្វព្រះរាជហឫទ័យអាល័យអាសូរករុណាដល់តិចឡើយ ៗ

រីព្រះបាទស្រីសញ្ជ័យ ស្តេចទ្រង់ព្រះសណ្តាប់ពាក្យព្រះជាលីកុមារក្រាបទូលដូច្នោះហើយ ក៏ស្តេចនឹករលឹកយល់ទោសរបស់ព្រះអង្គជាក់ច្បាស់ ទើបត្រាស់ថា

ទុក្កដញ្ច ហិ នោ តាត ភូនហច្ចំ កតំ មយា
យោហំ សិវីនំ វចនា បព្វាជេសិ អទូសកំ ៗ
យំ មេ កិញ្ចិ ឥធ អត្ថិ ធនំ ធញ្ញញ្ច វិជ្ជតិ
ឯតុ វេស្សន្តរោ រាជា សិវិរជ្ជេ បសាសតូតិ ៗ

តាតក ម្នាលចៅសម្លាញ់ជីតាអើយ ហេតុតែជីតាយកពាក្យអ្នកស្រីពិរាស្ត្រ បំបរបង់បិតាបាឱ្យចេញទៅនៅនាភ្នំគិរីវង្កត រីអំពើនោះ ហៅថា ជីតាធ្វើខុសឆ្គងណាស់ ៗ ក៏ឥឡូវនេះជីតានឹងប្រើបា ឱ្យនាំអស់ពលសកលយោធាផង ចេញទៅអារាធនាព្រះបិតាបាមកសោយរាជសម្បត្តិ បិតជាឥស្សរកំពូលលើអស់រាស្ត្រផងទាំងឡាយ នៅនាក្រុងពិជ័យជេតុត្តរមហានគរវិញហោង ៗ

ក្សិណនោះ ព្រះចៅជាលីកុមារបានស្តាប់ព្រះបន្ទូលព្រះជីតាហើយ ក៏មានចិត្តអំណរត្រេកអរមហិមា ទើបក្រាបបង្គំទូលវិញថា

ន ទេវ មយ្ហំ វចនា ឯហិតិ សិវិសុត្តមោ
សយមេវ ទេវោ គន្ត្វាន សិញ្ច ភោគេហិ អត្រជន្តិ ៗ

បពិត្រព្រះជីតាអម្ចាស់ខ្ញុំអើយ នាអម្ចាស់មានព្រះតម្រាស់ដូច្នោះនោះ ស្នោះឆ្នោះពីរោះពេកណាស់ រីសម្តេចព្រះវររាជបិតានៃយើងខ្ញុំនោះ ព្រះអង្គទ្រង់នូវព្រះប្រាជ្ញាច្រើនពេកក្តាត់ ធ្វើម្តេចឡើយ ព្រះអង្គនឹងយកពាក្យអញខ្ញុំជាក្មេងតូចដូច្នេះ សូមអម្ចាស់ស្តេចលីលាទៅអញ្ជើញ ដោយព្រះអង្គឯង ហើយស្តេចប្រគល់ថ្វាយរាជសម្បត្តិដល់ព្រះវររាជបិតា អញខ្ញុំនោះ ប្រាកដជាស្តេចនឹងថ្កានរាជបុរីពិជ័យជេតុត្តរវិញពុំខាន ។

តមត្ថំ បកាសេន្តោ សត្ថា អាហ ។ យំ អត្ថំ រីអាថ៌ធម៌ឯណា ន បាកដំ មិនទាន់ប្រាកដ សត្ថា រីព្រះសាស្តាចារ្យ បកាសេន្តោ កាលព្រះអង្គសម្តែង តំ អត្ថំ នូវអាថ៌ធម៌នោះ បាកដំ ឱ្យប្រាកដ អាហ ក៏ព្រះឈ្មោះមារាធិរាជ អាចបន្ទូលសានូវអាថ៌បាទព្រះគាថាដូច្នេះ

តតោ សេនាបតឹ រាជា   សញ្ជយោ អជ្ឈភាសថ
ហត្ថី អស្សា រថា បត្តិ   សេនា សន្នាហយន្តុ នំ
នេគមា ច មំ អន្វេន្តុ   ព្រាហ្មណា ច បុរោហិតា
តតោ សដ្ឋីសហស្សានិ   យោធិនោ ចារុទស្សនា
ខិប្បមាយន្តុ សន្នទ្ធា   នានាវត្ថេហលង្កតា ។
នីលវត្ថធរា នេកេ   បីតា នេកេ និវាសិតា
អញ្ញេ លោហិតឧណ្ហីសា   សុទ្ធា នេកេ និវាសិតា
ខិប្បមាយន្តុ សន្នទ្ធា   នានាវត្ថេហលង្កតា ។

ហិមវា យថា គន្ធរោ   បព្វតោ គន្ធមាទនោ
នានារុក្ខេហិ សញ្ឆន្នោ   មហាភូតគណាលយោ ។
ឱសធេហិ ច ទិព្វេហិ   ទិសា ភាតិ បវាតិ ច
ឧយ្យមាយន្តុ សន្នទ្ធា   ទិសា ភន្តុ បវន្តុ ច ។
តតោ នាគសហស្សានិ   យោជយន្តុ ចតុទ្ទស
សុវណ្ណកច្ឆេ មាតង្គេ   ហេមកប្បនិវាសសេ ។
អារុឡ្ហា គាមណីយេហិ   តោមរង្កុសបាណិភិ
ឧយ្យមាយន្តុ សន្នទ្ធា   ហត្ថិក្ខន្ធេហិ ទស្សិតា (១) ។

១- បើនឹងប្រែឱ្យសមសួនតាមរូបបាលីគាថានេះដូច្នេះ " កាលនោះ ព្រះបាទស្រីសញ្ជ័យមានព្រះរាជឱង្ការ បង្គាប់សេនាបតីជាចមទ័ពឱ្យចាត់វណ្ដាប់ទ័ព ប្រកបដោយពលដំរី ពលសេះពលរថ ពលថ្មើរជើង ឱ្យសព្វគ្រប់ថា ចូរបង្គាប់ឱ្យពួកអ្នកនិគមជនបទនិងព្រាហ្មណ៍បុរោហិតទាំងឡាយទៅតាមអញរាល់គ្នា តអំពីនោះ ត្រូវចាត់ឱ្យពួកយោធាទាហានមានស័ក្តិរុងរឿងថ្លៃថ្លា ដែលជាសហជាតិនឹងកូនអញឱ្យបានសព្វគ្រប់ទាំង ៦ ម៉ឺន ព្រមដោយអាវុធយុទ្ធភណ្ឌ ស្លៀកពាក់ឱ្យមានពណ៌ផ្សេង ៗ គ្នា ពួក ១ ស្លៀកពាក់សំពត់ពណ៌ខៀវ ពួក ១ ស្លៀកពាក់ពណ៌លឿង ពួក ១ ស្លៀកពាក់ពណ៌ក្រហម ពួក ១ ស្លៀកពាក់ពណ៌ស ដង្ហែចេញទៅយ៉ាងរួសរាន់ ៗ ភ្នំគន្ធមាទន៍ តាំងនៅក្នុងព្រៃហេមពាន្ត ដ៏ដេរដាសដោយរុក្ខជាតិនានា ជាលំនៅនៃពួកសត្វធំ ៗ មានរុក្ខជាតិជាថ្នាំទិព្វ ច្រាលរន្ទាលផ្សាយក្លិនក្រអូបឈ្ងុយឈ្ងប់សព្វទិសា មានឧបមាយ៉ាងណា ឯពួកយោធារបស់អញ ត្រូវតែងខ្លួនស្លៀកពាក់មានពណ៌ផ្សេង ៗ គ្នា ប្រដាប់ដោយអាវុធយុទ្ធភណ្ឌ ក៏រុងរឿងថ្លៃថ្លាល្បីទៅសព្វទិសដូច្នោះដែរ ៗ តបន្ទាប់មក ចូរចាត់រកដំរីរូបរាងធំ ៗ មួយម៉ឺនបួនពាន់ សុទ្ធតែចងខ្សែដង្គន់មាស មានគ្រឿងប្រដាប់ប្រដាសឹងមាស ពួកទម័កមានដៃកាន់តោមរនិងកង្វេរឡើងជិះលើកដំរីត្រៀមចេញទៅឱ្យសព្វគ្រប់ ៗ

តតោ អស្សសហស្សានិ   យោជយន្តុ ចតុទ្ទស
អាជានីយេ ច ជាតិយា   សិន្ធវេ សីឃវាហនេ ។
អារុឡ្ហា គាមណីយេហិ   ឥល្លិយាចាបធារិភិ
ឧប្បមាយន្តុ សន្នទ្ធា   អស្សបិដ្ឋេ អលង្កតា ។
តតោ រថសហស្សានិ   យោជយន្តុ ចតុទ្ទស
អយោសុកតនេមិយោ   សុវណ្ណចិត្រពោក្ខរេ ។
អារោបេន្តុ ធជេ តត្ថ   ចម្មានិ កវចានិ ច
វិប្ផាលេន្តុ ច ចាបានិ   ទឡ្ហធម្មា បហារិនោ
ឧប្បមាយន្តុ សន្នទ្ធា   រថេសុ រថជីវិនោតិ (១) ។

រាជា សញ្ជយោ (២) បពិត្រអើយ ព្ធដ៏កាលនោះ

១- បន្ទាប់អំពីនោះ ចូរចាត់សេះជាតិអាជានេយ្យ និងជាតិសិន្ធព ដ៏មានល្បឿនជាចំណាប់ប្រមាណ ១ ម៉ឺន ៤ ពាន់ ព្រមដោយគង្វាលសេះ ប្រដាប់ប្រដា ដោយគ្រឿងអលង្ការឡើងជិះបំផាយ មានដៃកាន់ខែលនិងកៅទណ្ឌសព្វគ្រប់ សឹមលើកចេញទៅ ។ តមកទៀត ចូរចាត់ក្បួនរថ ១ ម៉ឺន ៤ ពាន់ ជារថមាំទាំ មានកាំកង់ស្រោបដែក មានតួរថវិចិត្រដោយមាស មានទង់ជ័យដោតនៅគ្រប់ ៗ រថ ,មានពួកខ្មាន់ធ្នូដ៏ស្ទាត់ជំនាញ រហ័សរវាងវៃក្នុងការប្រើរថសឹក ចូរត្រៀមខែល ក្រោះ និងកៅទណ្ឌ ទុកឱ្យសព្វគ្រប់ ពលថ្មើរជើង ពលដំរី ពលសេះ ពលរថ ចូរនាំគ្នាឱ្យឃ្មាត ចាត់ចែង ឱ្យបានព្រមគ្នា ក្នុងគ្រានេះឯង ។

២- តាំងអំពី " រាជា សញ្ជយោ បពិត្រអើយ ។ល។ មានច្បាប់មហាជាតក៏ខ្លះ មានបរិយាយប្លែកផ្សេងគ្នា ដូច្នេះ " ភិក្ខវេ ហៃភិក្ខុផងទាំងឡាយអើយ

ឆ្លង...

ព្រះបាទស្រីសញ្ជ័យ ព្រះអង្គបានជ្រាបអំពីព្រះជាលីកុមារ ក្រាបទូលដោយនូវដំណើរសេចក្ដីលំបាក នៅក្នុងព្រៃ ក៏ទ្រង់ប្រណីអាសូរករុណាដល់ព្រះរាជបុត្រីបុត្រាពន់ប្រមាណ **អឌ្ឍភាវសថ** ទើបមានព្រះរាជឱង្ការបង្គាប់មុខមន្ត្រីចតុស្តម្ភ តាមដោយនូវភ្នាក់ងារ **ភោ អមច្ចា** ហៃអស់សេនាមាត្យផង ទាំងឡាយអើយ ចូរព្រះស្ដែងតាត់តែងសំបុត្រ តាមដោយនូវកំណត់រាជការមុខក្រសួងទីទៃឆាប់ ៗ វៃ ៗ រៀបប្រដាប់ប្រដា ត្បិតអញនឹងយាត្រាទៅឯភ្នំគន្ធមាទន៍ អារាធនាសម្ដេចព្រះឱរសា ឱ្យ

ព្ធដ៏កាលនោះ ព្រះបាទស្រីសញ្ជ័យ ស្ដេចនឹងចេញទៅអញ្ជើញព្រះរាជបុត្រ អំពីភ្នំគិរីវង្កតបព៌តនោះ ស្ដេចមានព្រះបន្ទូល ទៅនឹងអស់ព្រាហ្មណ៍ព្រឹទ្ធបណ្ឌិតកវី មន្ត្រីវៃឈ្លាសដឹងអធ្យាស្រ័យវែបម្រើ ទោះស្រុកតូចស្រុកធំ និគមស្រុកក្រៅលំនៅជនបទក្នុងក្រៅរាជធានី ទើបព្រះអង្គមានព្រះបន្ទូលថា អាមាត្យអើយ ចូរបាទៅស្រឹតស្រាល់ជ្រើសរើសរក យកសឹងកម្លោះក្លោះពាលពូកែទាហាន ហានក្លាមានកម្លាំងខ្លាំងដោយចំពូកនីមួយ ៗ នោះ ឱ្យបាន ១ ម៉ឺន ៦ ពាន់ ចូរបានាំមកឱ្យឆាប់ ត្បិតអញប្រញាប់ទៅនាភ្នំគិរីវង្កតបព៌ត អញ្ជើញព្រះបាទស្រីវេស្សន្តរ ឱ្យចរចូលមកព្រះនគរវិញហោង ៗ មួយសោត អាមាត្យអើយ រីឯសេនាខ្លះឱ្យមានដៃកាន់នីទៅនូវគ្រឿងប្រដាប់ប្រដា ទាំងសម្លៀកបំពាក់សោតទៀត ក៏ឱ្យផ្សេង ៗ គ្នា ទោះអ្នកឯណាមួយស្លៀកខ្មៅ ឱ្យមានអាវខ្មៅ មួកក៏ខ្មៅផង អ្នកឯណាស្លៀកស ឱ្យមានអាវស មួកក៏សផង អ្នកឯណាស្លៀកលឿង ឱ្យមានអាវលឿង មួកក៏លឿងផង អ្នកឯណាស្លៀកក្រហម ឱ្យមានអាវក្រហម មួកក៏ក្រហម សឹងឱ្យស្លៀកឆ្លាស់ពណ៌គ្រប់គ្នា ៗ មួយសោត អាមាត្យអើយ ត្រូវឱ្យប្រដាប់នីទៅនូវគ្រឿងសុគន្ធពិដោរទាំងឡាយ មានក្រចេះចួង

ឆ្លង . . .

លាព្រ័តចេញអំពីឥសី នឹងប្រគល់បុរីរាជដ្ឋាន ហើយនឹងបានអភិសេកឯកឧត្តមបរមក្សត្រា នាកាលគ្រានេះឯង ៗ **នេគមា ច មំ អន្វេន្តុ** ចូរអាជ្ញានាំព្រះរាជឱង្ការទៅប្រាមប្រាប់អស់ចៅហ្វាយស្រុកឯក ទោ ត្រី ចត្វា បណ្ដាមាននៅស្រុកក្រៅលំនៅជនបទនានា ខ្មែរ ភូមា មន ង៉ូវ ឱ្យមកស្មោះសរជួបជុំឱ្យរៀបប្រដាប់ប្រដា តាមដោយប្រទេសភាសាភ្នាក់ងារ ចាម ជ្វា វិលន្ទា លង្កា អង្គ្រីស ពទ៌ុគែស អារ៉ាប់ ចិន ចាម ព្រាហ្មណ៍ កូឡា ហង្សា យួន ជប៉ុន សឹងដ៏គ្រប់គ្រាន់ ព្រម

ច័ន្ទន៍ក្លាំពាក់ក្រស្នា ដោយអាត្មាទីទៃ ៗ ឱ្យមានក្លិនពិដោរអប់ត្រឡប់គ្រប់គ្នា ត្បិតយើងទៅទៀបភ្នំគន្ធមាទន៍បព៌ត ដ៏មានឈើលើភ្នំនោះ សឹងមានផ្លែផ្កា មានក្លិនពិដោរផ្សេង ៗ ដ៏ជាលំនៅនៃកិន្នរីកិន្នរាផង តែងមកច្រៀងរាំលេង ដោយដងព្រៃស្រោង ដោយជើងភ្នំ លើភ្នំនោះហោង តតោ នាគសហស្សានិ យោជយន្តុ ចតុទ្ទស ហៃអាមាត្យអើយ រីដំរីនោះសោត ឱ្យប្រមូលយកអស់ដំរីផង តែស្រាល់ជ្រើសរើសដំរីឯណាធំ ៗ មានភ្លុកក្បួសមនូវកន្ទុយល្អ ឱ្យបាន ១ មុឺន៤ពាន់ ដ៏ប្រដាប់នូវគ្រឿងផងទាំងឡាយ ជាដើម គឺ ដង្គួន់ខ្សែរឆាក់ក្រពាក់លំញាង ស្នាប់មុខស្រោមភ្លុកសឹងដ៏ពាសផាសទៅទាំងខ្លួន សឹងមាសប្រាក់ដ៏មានចម្លាក់ក្បាច់រចនារំលេចនូវកែវមណីរីភ្នាក់ងារដ៏ជិះសោត ឱ្យប្រដាប់ក្រោះក្រាល សង្វារមាស ក្បាលពាក់មួកមាសរំលេចនូវកែវមណីរតន៍ មានរស្មីភ្លឺរុងរឿង ឡើងជិះដំរីមួយម្នាក់ ៗ ដោយភ្នាក់ងារបរមកឱ្យឆាប់ ៗ ប្រញាប់ហៃអញនឹងចេញទៅទទួលព្រះបាទស្រីវេស្សន្តរ ចូលមកនគរវិញហោង ៗ តតោ អស្សសហស្សានិ យោជយន្តុ ចតុទ្ទស រីអស់សេនាសេះនោះសោត ក៏ឱ្យជ្រើសរើសរកសេះឯណាដែលមានកម្លាំងរហ័សវៃក្រៃស្មើខ្យល់ ឱ្យបាន

ឆ្លង ...

ព្រើសសព្វប្រទេសភាសា សន្នទ្ធា ចូរប្រដាប់ឱ្យមានសិរីសួស្ដី ពិជ័យសង្គ្រាម តាមយោគយាមយាត្រា ឯអស់យោធាទាំងមួយម៉ឺនបួនពាន់ សឹងដ៏ហានក្លា មានថ្វីដៃ ធ្វើសឹកមានជ័យជម្នះឈ្នះអស់សត្រូវបាក់បបខ្លបខ្លាច អាចអង់នីរព័ទ្ធ ខ្លះក៏ស្ទាត់ខាងឯសណ្ដំ ខ្លះកាន់អាគម មហាចាំងង៉ាងបំបាំងកាយ ខ្លះកាន់មហារលាយរលួយ សឹងដ៏ឆុត ៗ ខ្លះកាន់មហាទល់ហាត់មើលមេឃឆាយ ខ្លះកាន់ទាំងព្រាយបញ្ចៀសគង់ប្រេះ សឹងដ៏មានតបះពុំក្រែងខ្លាច អាចចូលកណ្ដាលសឹកសាម តាមកាត់

---

១ ម៉ឺន ៤ ពាន់ ប្រដាប់ផ្គួរផ្គាប់ ចងបុស្សនាំងទាំងប៉ែកឈ្នាន់ខាន់ ជីបត្រីប សូត្រ សាយសែមតែមមុខកញ្ចក់ កនកៈភ្ញីវល្លិពីរពណ៌ នូវខ្សែឃ្លុំត្រសុំបង្ហៀរ ដ៏មានខ្សែរឹត អុករឹតផង ខ្សែហាងខ្សែហាក្រទ្បាចង្ក្រង់ ចងរំយោលអស់អង្គផ្គង់ សឹងដ៏មាសដាលដាំរំលេចនូវកែវមណីរ័តន៍ ៗ រីសេនាសេះនោះសោត ឱ្យប្រដាប់ស្លៀកពាក់នូវអាវសំឡី ដ៏មានក្បាលពាក់នូវមួកក្បូរក្បាច់ រំលេចនូវកែវមណីរ័តន៍ ដ៏មានដៃកាន់នីទៅនូវទួនសេលោ ឱ្យជិះនាំមកឱ្យឆាប់ ៗ ត្បិតអញប្រញាប់នឹងចេញទៅទទួលព្រះវេស្សន្តរអំពីភ្នំគិរីវង្កតបព៌តនោះហោង ៗ តតោ រថសហស្សានិ យោជយន្តុ ចតុទ្ទស អណ្ដាប់នោះ រីសេនារទេះសោត ឱ្យប្រដាប់បាន ១ ម៉ឺន ៤ ពាន់រទេះ គ្រប់គ្រឿងកាំ សឹងដែក ព្រែកទ្រូពងផ្ចង់ខ្ចង់ទ្រាយផ្ទោះផ្ទៀរ សឹងមាសដាលដាំរំលេចរចនានូវកែវមណីរ័តន៍ ពិចិត្រកម្រាលក្រាលនូវស្បែកខ្លាឃ្មុំ ផ្សំនូវកណ្ដឹងចង្ក្រង់ផ្គង់នូវរូបគ្រុឌនាគ រីអ្នកជិះរាជរថសោត ក៏ឱ្យពាក់សឹងក្រោះក្រាលកម្រាលសង្វារមាស ពាក់ត្បូងសឹងពេជ្ររំលេចនូវកែវមណីរ័តន៍ប្រពៃ ដៃកាន់សេលោកៅទណ្ឌព្រះខ័នជ័យ ជន្លួញគ្រប់ដៃបរមកឱ្យឆាប់ៗ អញនឹងទៅទទួលព្រះវេស្សន្តរអំពីភ្នំគិរីវង្កតបព៌តនាយហោង ៗ

ក្បាលសត្រូវពុំមានភ្លឹក ខ្លះចេះព្យូហ៍សឹកឧបាយកល ដោយនូវយោបល់ល្បួងលោម ឱ្យសត្រូវទាំងពួង បាក់បបខ្លបខ្លាច ដោយនូវអំណាចចេស្តា ៗ រុឹយ ៗ អស់យោធាផងទាំងឡាយ អម្បាលដែលកើតថ្ងៃមួយនឹងកូនអញ **ចារុទស្សនា** ដ៏មានអាត្មាល្អឆើតឆាយ អម្បាលនៅស្រុកជិតឆ្ងាយសព្វតំបន់ **សន្នទ្ធា** ចូរឱ្យរៀបគ្នាដោយនូវចំពូកឆ្វេងស្តាំ **នានាវណ្ណេហិ លក្ខិតា** យោធាមួយចំពូកវិញទៀត ឱ្យមានកំណត់ស្លៀកពាក់សំពត់នីលពស្ត្រ ឋានខ្មៅ បញ្ចុះនីទៅនូវលេខយន្តមហាអង្គរ័ក្ស សឹងដ៏ប្រសិទ្ធិសក្តិចេស្តា អាចការសារពើអាវុធ ក្នុងសង្គ្រាម ដ៏មានដៃកាន់នីទៅនូវទួនកៅទណ្ឌ ស្ទុះលោតរន្ទាន់ ចេញទៅ **បីតា នេកេ និខាសិតា** យោធាធំចំពូកមួយវិញទៀត ឱ្យស្លៀកសំពត់កោសេយ្យពស្ត្រ ឋានលឿង ពាក់អាវផាយ យល់ល្អវិសេសឧត្តមសមនូវផ្កាក្លែបក្លាយ លាយបញ្ចពណ៌ យល់ពព្រាលពព្រាយ យល់ត្បូងពិទាយបទុមរាគរ័តន៍ គិតដ៏អ្នកឆ្អែជាឡៀវយល់ល្អថ្លៃថ្លា ៗ យោធាមួយចំពូកវិញទៀតកាន់ខែលមាសមានក្បូរក្បាច់ រំលេចល្អួសលាយបញ្ចពណ៌ យល់សក្តិសម **សុទ្ធា នេកេ និខាសិតា** យោធាមួយចំពូកវិញទៀត ឱ្យស្លៀកសំពត់ខោមពស្ត្រឋានស ល្អឧត្តមសមនឹងយសសក្តា **ហិមវា យថា** ឧបមាបីដូចព្រៃហេមពាន្ត ជាឋានបរិវារនៃភ្នំគិរីវង្កត សឹងដ៏មានទំហំខ្ពស់ធំ ទ្រង់នូវសុគន្ធរស ១០

ប្រការ ប្រកបនូវព្រឹក្សាផលាហារ ពុំដឹងបើនឹងគណនា ព្រឹក្សាដ៏ដុះស្រោងស្រោងស្រឹងត្រឈឹង ត្រសុំត្រសាយ **មហាភូតគណាលយោ** ជាទីពំនាក់ទេវតា ពិទ្យាធរ កិន្នរ ឥន្ទ ព្រហ្ម យម យក្ស គ្រុឌ នាគ ផងទាំងឡាយ តែងនឹងក្រសាលសប្បាយ ជាទីលំនៅ កបនីទៅនូវសព្វពិធរ័តន៏កែវកងពៃទូរ្យស្ទូរ្យការ សឹងដ៏មានរស្មីភ្លឺព្រោងព្រាយ **យថា** នោះតើឧបមាដូចម្តេច **តេ យោធា** រីឯអស់យោធា ស្តេចឱ្យប្រដាប់សម្រាប់កាយ យល់ល្អឆើតឆាយផ្សេង ៗ ដោយនូវពណ៌ទីទៃ ៗ ប្លែក ៗ ពីគ្នា ឧបមាបីដូចព្រៃហេមពាន្តនោះឯងហោង ៗ

ភោ អមច្ចា ហៃអាមាត្យទាំងឡាយអើយ រីអស់ទាហានសេនាអម្បាលរក្សាបម្រុងរាស្ត្រនៅក្នុងព្រះនគរនូវអស្សតរសិន្ធព គ្រប់ទាំង ១ ម៉ឺន ៤ ពាន់ សឹងដ៏ល្អឧត្តម សមនូវលក្ខណាកាយានោះវែងជរជាយ មានកន្ទុយធំយារ ភ្នែកមូលស្អាត មានមារយាទនោះល្អ **អាជានីយេ** គិតដ៏ជាអាជានេយ្យ ដឹងចូលចេញដេញថយពុំព្រួយប្រើ បើនឹងធាក់នឹងខាំក៏ឥតខ្លាចក្រែងសឹកសត្រូវ បើនឹងបរបំផាយចូលទៅក៏ឆៀបឆាប់ប្រញាប់ រួសរាន់ទាន់ចិត្ត **សិន្ធវេ** គិតដ៏ជាសេះសិន្ធពមានត្រកូលអំបូរមានទាំងកម្លាំង ឡើងទាំងសម្បុរខៀវ ស ល្អប្លែក ៗ មានសម្រែកនោះខ្លាំង **អារុឡ្ហា** មានទាំងនាយសារថីជិះជាន់តាមក្បួន ដែកាន់ទួនកៅទណ្ឌាកែក្រោយ រីឯប្រដាប់កាយពាជី សឹងដ៏ល្អឧត្តម

ឃ្លុំបង្ហៀររឹតអុករឹតថង ខ្សែហោងខ្សែហាង សងខាងប្រដាប់ បើកឈ្នាន់ខាន់ជីបត្រឹមប៉ាក់ សឹងដ៏ល្អថ្លៃថ្លា សឹងដ៏សុវណ្ណា ប្រដាប់នូវរ័តន៍រាយផ្កាយ សឹងពោធិ៍បុស្សនាំង មានទាំងកណ្ដាលឈ្នាន់ជិះជាន់ បើកបរប្រយ័ត្នការសារពើអាវុធ ក្នុងសង្គ្រាម ឥស្លិយាវចរបធវរិកិ ដ៏មានដៃកាន់នីទៅនូវទួនកៅទណ្ឌ ចូរប្រដាប់ឱ្យគ្រប់គ្រាន់ ឱ្យបានទាន់អញនឹងចេញទៅ នាកាលឥឡូវនេះឯងហោង ៗ

លាជា ឱលោកិយា បុប្ផា   មាលាគន្ធវិលេបនា
អគ្ឃិយានិ ច តិដ្ឋន្តុ   យេន មគ្គេន ឯហិតិ ៗ
គាមេ គាមេ សតំ កុម្ភា   មេរយស្ស សុរាយ ច
មគ្គម្ហិ បដិតិដ្ឋន្តុ   យេន មគ្គេន ឯហិតិ ៗ
មំសា បូវា ច សំកុល្យា   កុម្មាសា មច្ឆសំយុតា
មគ្គម្ហិ បដិតិដ្ឋន្តុ   យេន មគ្គេន ឯហិតិ ៗ
សប្បិ តេលំ ទធិ ខីរំ   កង្គុបិដ្ឋា ពហូ សុរា
មគ្គម្ហិ បដិតិដ្ឋន្តុ   យេន មគ្គេន ឯហិតិ ៗ
អាឡារិកា ច សូទា ច   នដនដ្ដកគាយិនោ
បាណិស្សរា កុម្ភថូនិយោ   មុទ្ទិកា សោកឈាយិកា ៗ
អាហញ្ញន្តុ សព្វវីណា   ភេរិយោ ទិន្ទិមានិ ច
ខរមុខានិ ធមន្តុ   នទន្តុ ឯកបោក្ខរា ៗ
មុទិង្គា បណ្ឌវា សំខា   គោធា បរិវទេន្តិកា

ឥន្ទិវរានិ ច ហញ្ញន្តុ កុដុម្ពា ឥន្ទិវរានិ ចរតិ(១)។

រវជវ សព្វយោ ឯព្រះបាទស្រីសញ្ជ័យ ស្តេចមានព្រះរាជហឫទ័យត្រេកអរមហិមា ស្តេចបង្គាប់យោធាផងទាំងឡាយឱ្យខ្វល់ខ្វាយជម្រះមាគ៌ាដែលស្តេចនឹងលីលាទៅ ៗ រីឯទទឹងផ្លូវឱ្យបាន ៨ យោបំគោឧសភរាជ កុំឱ្យខ្ពស់កុំឱ្យទាប ឱ្យរាបដូចផ្ទៃស្គរ ឱ្យមានភ្ញាក់ងារសង់ព្រះពន្លានូវទីដំណាក់ លុះដល់ទីដាក់ ឱ្យបាន ៣ យោជន៍ ស្តេចគង់ស្រង់សោយ ឱ្យមាន

១- បើប្រែជាសម្រាយតាមរូបបាលីដូច្នេះ កងទ័ពសិវិរដ្ឋមានកម្លាំង អាចកម្ចាត់បង់នូវរាជសត្រូវ សឹងបានចាត់ជាក្បួនទ័ពស្រេចហើយ មានព្រះជាលីកុមារជាអ្នកនាំផ្លូវ បានយាត្រាសំដៅទៅកាន់ភ្នំគិរីវង្កតបពិត ៗ កុញ្ជរដ៏ប្រសើរមានអាយុ ៦០ ឆ្នាំ មានខ្សែយោងចងរឹតសព្វគ្រប់ បន្លឺសព្ទកោញ្ចនាទគម្រាមដ៏អឹងកងខ្ទរខ្ទារ ៗ សេះអាជានេយ្យទាំងឡាយ ក៏ស្រែកឮសព្ទសម្រែកគឹកកង សំឡេងកង់រាជរថក៏ឮស្នូររំពងផង់ផុយធូលី ក៏ហុយឡើងចាប់ផ្ទៃមេឃ ៗ ព្រះបាទស្រីសញ្ជ័យ ស្តេចព្រមដោយរាជបរិវារអស់នោះ ស្តេចចូលកាន់ព្រៃធំ ដ៏បរិបូណ៌ដោយព្រឹក្សាជាតិ ដ៏មានមែកនិងស្លឹកស្គុកស្គម្ភ ដ៏ដេរដាសដោយផ្លែផ្កានានា មានជ្រោះជ្រលងដងអូរ ទឹកហូរមិនដាច់ក្នុងព្រៃនោះ មានសត្វបក្សីបក្សាមានពណ៌ផ្សេង ៗ មានសំឡេងពីរោះក្បោះក្បាយចាប់ទំនៅលើព្រឹក្សា ដ៏មានផ្លែផ្កាតាមរដូវកាល ស្រែកហ៊ោកញ្ជ្រៀវខ្ទេវខ្ទារ មុខគួរឱ្យស្រណោះ ៗ ព្រះបាទស្រីសញ្ជ័យព្រមដោយរាជបរិវារទាំងនោះ ស្តេចត្រាច់ទៅតាមមាគ៌ាជារយៈផ្លូវ ៦០ យោជន៍ កន្លងវេលាជាច្រើនយប់ច្រើនថ្ងៃ ទើបស្តេចដល់ប្រទេសជាទី ដែលព្រះបាទស្រីវេស្សន្តរ ស្តេចគង់នៅនោះហោង ៗ

ព្រះដំណាក់ស្ដេចគង់បញ្ឈប់ ឱ្យមានគ្រប់ទាំងរោងដំរី **ធជា ឱលោកិយា** ហើយប្រដាប់ប្រដាពាសសឹងពិដានស ឱ្យល្អបរិសុទ្ធ ឱ្យក្រាលក្រងចងនីទៅនូវផ្កាភ្ញី មាននូវលាជបាចរាយ ជុំឋាន ឱ្យមានទង់ជ័យ ចាមរ បៃមន សែនត្វ័ន អភិរម្យ **មាលាគន្ធវិលេបនំ** ឱ្យមាននូវគ្រឿងពិដោរ គឺសុគន្ធរសស្រស់ប្រពៃសម្រាប់នៅនៃរោងទឹកស្រង់ ហើយឱ្យសង់រន្ទាភ្លើង ដោយនូវពណ៌ទីទៃ ៗ **នដនដ្ដកគាយិនោ** ឱ្យមានតូរ្យតន្ត្រីពិណពាទ្យប្រគំ សមនូវសព្ទចម្រៀងច្រៀងរាំបម្រើ **បាណិស្សរេ** សារពើកំប្លែង ដោយនូវពណ៌ល្បែងផ្សេងៗឱ្យគ្រប់ **សោកឈាយិកា** ឱ្យមានសព្វសារពើល្បែងសម្រាប់ច្រៀងរាំ សឹងដ៏ខ្វែនស្ទាត់ស្នព្រ័ត្រហក់ងារ ប៉ាវខុនខោល យន្ដជើតស្បែកផ្សេង ៗ លោតកព្លោងម៉ូងត្រុំផ្ទាគូផ្ទារាយ នាងក្រាយប្រះស្និលពាំត្បាល់ ប្រដាល់ប្រកាប់ ចំបាប់ត្រីវិស័យ គ្រប់ល្បែងមហោស្រពសម្រាប់អភិសេកឱ្យមានសព្វគ្រប់ កុំឱ្យខ្វះឡើយ **សតំ កុម្ភា** ឱ្យភ្នាក់ងារ ដាក់សារពើអាហារនៅរៀងសងខាងមាគ៌ា ដែលស្ដេចនឹងលីលាដោយនូវផ្លូវដល់មាត់ទ្វារព្រៃ ឱ្យបានអស់ពលអាស្រ័យបរិភោគ **មច្ឆសំយុត្តា** ឱ្យអស់ភ្នាក់ងារប្រដាប់ប្រដាមច្ឆមំសា អាហារឱ្យគ្រប់គ្រាន់ **សប្បិ តេលំ ទធិ ខីរំ** ទាំងប្រេងម្សៅ សឹងក្លិនពិដោរ ឈ្ងុយឈ្ងប់ ដាក់សម្រាប់នៅខាងផ្លូវ ដែលអញនឹងទៅឯព្រះរាជបុត្រអញ ឯភ្នំគិរីវង្កតនោះឯង ៗ នាកាលព្រះ

បាទស្រីសញ្ជ័យនរេន្ទ្រាធិបតីស្រីសុរិយោវង្ស ព្រះអង្គឱ្យរៀបអស់រេហ៍ពលសកលយោធាស្រេច ស្ដេចនឹងយាត្រាចេញទៅភ្នំគិរីវង្កតបពិតរាជដ្ឋាន នាកាលគ្រានោះឯងហោង ។

ជូជកោ បមាណាតិក្កន្តំ ភុញ្ជិត្វា បពិត្រអើយ រីជូជកព្រាហ្មណ៍ព្រឹទ្ធាចារ្យ គាត់យល់ចំណីភោជនាហារដែលស្ដេចព្រះរាជទានផ្សារ ដោយជូជកគាត់ទើបនឹងមកអំពីអត់ឃ្លាន ហើយគាត់ជាមនុស្សឥតខ្មាស បរិភោគទាល់តែចាក់ច្រាសចើស លើសចុងដង្ហើម មើលទៅគួរតែស្ញើមនឹងភ្នែកគាត់ស្លើតស្លក់ តេជោធាតុនឹងបក់ឱ្យឆេះរលួយអាហារពុំទាន់ ជូជកគាត់បែកពោះស្លាប់នាកាលនោះឯងហោង ។ (១)

អថ រាជា តស្ស សរីរកិច្ចំ ការាបេត្វា បពិត្រអើយ ព្ឌ៏កាលនោះ ព្រះបាទស្រីសញ្ជ័យ ស្ដេចឱ្យធ្វើបុណ្យរំលាយសពតាជូជកនោះហើយ ទើបស្ដេចឱ្យរាជអាមាត្យប៉ាវគង សួររកញាតិផៅពង្សរបស់តាជូជកសព្វស្រុកជាគម្រប់ ៧ ថ្ងៃ ក៏ឥតមានអ្នកឯណាមួយទទួលជាញាតិសន្តានរបស់ព្រាហ្មណ៍នោះឡើយ ។ រីអស់ព្រះរាជទ្រព្យអម្បាលនោះ ដែលលោះព្រះរាជកុមារនោះមិញ ក៏បង្វិលមកជាព្រះរាជទ្រព្យវិញហោង ។ (២)

---

(១)- រឿងជូជកបរិភោគអាហារនេះ ចូរមើលៈ " បរិយាយដោយឡែក នៃរឿងជូជកបរិភោគអាហារ " នៅខាងចុងកណ្ឌនេះឯង ត្រង់ទំព័រ ៤៣១ ដល់ ៤៣៦ ។

(២)- មានមហាជាតក៏ខ្លះមានសេចក្ដីពិស្ដារបន្ថិចទៀតថា " ក្សិណនោះ គាប់

ឆ្លង...

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណា ពុំទាន់ប្រាកដ បទព្រះបាលីឯណា ពុំបានថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលសូត្រសានូវបាទព្រះគាថា ទាំងឡាយ ដូច្នេះ

សា សេនា មហតី អាសិ ឧយ្យុត្តា សិវិវាហិនី
ជាលិនា មគ្គនាយេន វង្កំ បាយាសិ បព្វតំ ៗ
កោញ្ចំ នទតិ មាតង្គោ កុញ្ជរោ សដ្ឋិហាយនោ
កច្ឆាយ ពជ្ឈមានាយ កោញ្ចំ នទតិ វារណោ ៗ
អាជានិយា ហសិស្សឹសុ នេមិឃោសោ អជាយថ
នភំ រជោ អច្ឆាទេសិ ឧយ្យុត្តា សិវិវាហិនី ៗ
សា សេនា មហតី អាសិ ឧយ្យុត្តា ហារិហារិនី
ជាលិនា មគ្គនាយេន វង្កំ បាយាសិ បព្វតំ ៗ
តេ បាវិសុំ ព្រហារញ្ញំ ពហុសាខំ មហោទកំ
បុប្ផរុក្ខេហិ សញ្ឆន្នំ ផលរុក្ខេហិ ចូភយំ ៗ
តត្ថ វិន្ទុស្សរា វគ្គូ នានាវណ្ណា ពហូ ទិជា
កូជន្តមុបកូជន្តិ ឧតុសម្បុប្ផិតេ ទុមេ ៗ
តេ គន្ត្វា ទីឃមទ្ធានំ អហោរត្តានមច្ចយេ
បទេសន្តំ ឧបាគច្ឆុំ យត្ថ វេស្សន្តរោ អហូតិ①ៗ

ចូនជាព្រាហ្មណ៍នៅស្រុកកលិង្គរាស្ត្រទាំង ៨ នាក់នាំយកដំរីបច្ច័យនាគេន្ទ្រ មកថ្វាយវិញ ព្រមល្មមនឹងឫក្សពេលាស្តេចយាត្រាចេញទៅ ពួធ៏កាលនោះឯងហោង"ៗ

១- បើប្រែសេចក្តីឱ្យសមរម្យតាមរូបគាថាដូច្នេះ " ព្រះបាទស្រីសញ្ជ័យ មានព្រះ

ភ្លង ...

សត្តមេ និទសេ លុះគម្រប់ជា ៧ ថ្ងៃ ចូនស្តេចនឹងលីលាយាត្រា ឯអស់មន្ត្រីយោធា ក៏ឱ្យត្រួតត្រា តាមកំណត់សេនារាជរថពាជី កុញ្ជរ សឹងរឹកវរខ្នាន់ខ្នាប់ សឹងដ៏កាន់នូវកាំភ្លើងធ្នូស្នា រៀបជាជួរជាសង្កាត់ តាមដោយអណ្តាប់ឆ្វេងស្តាំ បើនឹងរាប់ជា ១២ អក្ខោភិនី ៗ ឯអស់នារីស្នំបរិវារ សឹងដ៏ត្រអាលក្សេមក្សាន្ត ត្បិតនឹងបានមើលព្រឹក្សព្រៃ ដោយនូវនាសងខាងមាគ៌ា ៗ ឯភ្នាក់ងារព្រះសិទ្ធិរស ក្រចេះចួងច័ន្ទន៍ ព្រះពស្ត្រព្រះស្រី សឹងក្រមុំព្រហ្មចារី សមនូវរូបរាង នូវជំទាវ នាងខុនណាង ចាស់ទុំក្រមុំសាវកែ សឹងដ៏តាមដង្ហែទៅតាមមាគ៌ា សឹងដ៏ប្រដាប់ប្រដាអាត្មា ស្រេចស្រស់ ស្រឡាបលាបនូវសុគន្ធរស ក្រចេះចួងច័ន្ទន៍សុគន្ធពិដោរ ដើរដោយអណ្តាប់ នឹងរាប់ជាមុឺន ជាសែន ទៅដោយនូវផ្លូវ បីដូចកលស្រី នៅនាសួគ៌ា ដ៏មានសិរីសួស្តី ៗ លុះព្រឹកព្រាងស្រាងព្រះរស្មីស្រេច ទើបសម្តេចព្រះបាទ

រាជឱង្ការថា វេស្សន្តរកូនអញ ស្តេចយាងតាមផ្លូវ ត្រូវអ្នកទាំងឡាយឱ្យរាយលាជបាចផ្កា ឱ្យតាក់តែងទីកន្លែងដោយមានកម្រងផ្កា គ្រឿងក្រអូប គ្រឿងលាបតាំងគ្រឿងបូជាទទួលស្តេច ៗ ក្នុងស្រុកនីមួយ ត្រូវឱ្យចាត់តាំងក្អមសុរាមេរ័យមួយរយៗ រាយនៅតាមមាគ៌ា មានទាំងមំសាហារ និងនំល្វ នំកុម្មាសដែលគេផ្សំនឹងសាច់ត្រី ៗ ត្រូវរៀបចំឱ្យមានទឹកដោះរាវ ទឹកដោះខាប់ និងទឹកដោះស្រស់ ព្រមទាំងសុរា ដែលធ្វើពីស្រូវស្រងៃ ទុករៀងរាយតាមផ្លូវឱ្យច្រើន ៗ ត្រូវឱ្យមានពួកពិសេស ជាភ្នាក់ងារខាងបង្អែមនិងចំអាប តាំងជប់លៀងប្រជាជនទូទៅ ឱ្យមានមហោស្រព ច្រៀងរាំគ្រប់ប្រភេទ នាំឱ្យកើតមានសេចក្តីរីករាយបំបាត់សោក ឱ្យពួកមហោរីលេងប្រគំព្រមទាំងស្គរធំស្គរតូចគ្រប់យ៉ាង និងល្បែងតូរ្យតន្ត្រីគ្រប់ប្រការ ៗ

ស្រីសញ្ជ័យ នូវព្រះអគ្គមហេសី ព្រះរាជនត្តានត្តា ស្តេចចូលទៅកក់ស្រង់ទ្រង់នូវព្រះសុគន្ធរសព្រះពស្ត្រព្រះភូសា ប្រដាប់ប្រដាព្រះកាយាស្រេចហើយ ពុំលង់ឡើយ អស់ភ្នាក់ងារ ប្រគំត្រែ ស័ង្ខរគាំងភេរីតូរ្យតន្ត្រីពិណពាទ្យ ដោយនូវខ្នាតតូចធំ សំឡេងរងំល្វេងល្វើយ ទើបអស់អ្នកភ្លេង ក៏លេងដោយនូវពួកទីទៃៗ ស្តេចមកគង់ឰដ៏ព្រះរាជយានរត្ន ព្រះជាលីគង់គជេន្ទ្រ ជាមគ្គនាយកនាំក្សត្រយាត្រា ឯព្រះអយ្យិកាគង់ព្រះរាជយានស្រីសុពណ៌សិវិកា រស្មីឆាឆាយច្រាលឆ្អៅ ឯអស់យោធា ក៏លើកទ័ពចេញទៅគគុកគគឹកឆ្វេងស្តាំមុខក្រោយ ដោយនូវអណ្តាប់ ស័ព្ទក្រើកអំពើក ខ្ញៀវខ្ញារ ខ្ទរខ្ទារទាំងពសុធា ដើរដោយនូវជំពូកទីទៃៗ ៗ ដំរីរាជរថ ពលរមត់ថ្មើរជើង បើកបរអស្សតរសិន្ធពរាជ សឹងដ៏ខ្លោះខ្លាំង ភុញួរេវ រីឯកុញ្ជរកែវបវរជារាជយានប្រសើរ① សដ្ឋិហាយនេវ កើតកបលក្ខណា មានអាយុ ៦០ ឆ្នាំ សឹងដ៏ត្រេកអររេរាទ៍រំពងទ្រហឹងស័ព្ទចតុរង្គអឹងអាប់ខ្ទារខ្ទរ ៗ ឯអស់អម្បាលកំណាន់អស្សតរ បើកបរដោយក្បួន ឯខ្លួននោះ សឹងតែ

១- គឺដំរីរ័តន៍បច្ច័យនាគេន្ទ្រ ដែលព្រះបាទស្រីវេស្សន្តរព្រះរាជទានទៅពួកព្រាហ្មណ៍ នៅស្រុកកលិង្គរាស្ត្រ ដែលជាហេតុនាំឱ្យបណ្តារាស្ត្រខឹង នាំគ្នាបំបរបង់ព្រះអង្គ ឱ្យទៅនៅភ្នំគិរីវង្កតបព៌ត ៗ អំណើះកាលតមក ស្រុកកលិង្គរាស្ត្រ មានភ្លៀងធ្លាក់ជោកជាំ តាមរដូវកាលហើយ ទើបពួកព្រាហ្មណ៍ នាំដំរីនោះ ទៅថ្វាយព្រះបាទស្រីសញ្ជ័យវិញ ឯដំរីនោះ ក៏បានចូលមកក្នុងក្បួនហែនេះដែរ ៗ អដ្ឋកថា ៗ

ប្រដាប់នូវក្រោះមាស **នេមិឃោសោ** ពេញពាសតាន់តាប់សំឡេងសូរសព្ទកង់រាជរថ ព្រទ្រហឹងអឹងអាប់ញាប់ញ័រទាំងពសុធា **នតំ រទោ** រឺផុយផង់ធូលីហើរទៅនាវេហាស៍ ឯអាកាស ក៏សឹងដ៏ស្រទំ ត្រជាក់ស្រណុកសកល ខ្យល់បក់មកត្រសៀករំភើយផ្សព្វផ្សាយសប្បាយក្សេមក្សាន្ត ឥតមានទុក្ខសោករោគា ស្តេចលីលាទៅនឹងពល ១២ អក្ខោភិនី ៗ ឯចៅជាលីដ៏ជាមគ្គនាយកនាំស្តេចយាត្រា ស្តេចទតសព្វព្រឹក្សាផងទាំងឡាយ សប្បាយអភិរម្យសោមនស្សា គគីរ ឆាំឆា ស្វាក្របី ស្រឡី ស្រឡៅត្រាច តាត្រៅ ត្រើល ត្រង់ រង់ ព្រហូត រោក រាក់ ក្លាំពាក់ក្លាំពា ក្រស្នា ចួងច័ន្ទន៍ សឹងដ៏ដុះតាន់តាប់នៅក្នុងព្រៃ ពហុ**សាខំ** ដ៏មានលំពង់លូតលាស់សាខា ផ្លែផ្កាច្រាសច្រាល រន្ទាលស្រគាល ទុំខ្ចី ដោយនូវសងខាងមាគ៌ា ហាក់ដូចមានចិត្តទន់ទោរមកថ្វាយស្តេចទតសប្បាយក្សេមក្សាន្តព្រះទ័យ ទតអស់បក្សីបក្សាចុះនៅនាព្រៃព្រឹក្សា ទំយំគគឹករកគូជាដើម គឺ ហ៊ូពូសេកយា សារិកា ក្ងាន ក្ងោក ប៉ោលតោក តាវៅ សំឡេងក្រអៅពីរោះល្វេងល្វើយ ដូចកលអ្នកបន្លែងក្នុងព្រៃ ចាប់ចឹកចំណីដោយកលបក្សីបក្សា **តេ មោះ ចត្តារោ ខត្តិយា** រឺឯក្សត្រាក្សត្រីទាំង ៤ ព្រះអង្គ ស្តេចគង់ក្នុងព្រៃជាច្រើនរាត្រី មានព្រះទ័យក្សេមក្សាន្តសោមនស្សា **វេស្សន្តរោ រាជា** រឺឯព្រះបាទស្រីវេស្សន្តរបវរពោធិសត្វ ស្តេចទ្រង់ព្រ័ត នៅនាងណោមិញ

ក្សត្រទាំង ៤ ព្រះអង្គ ស្ដេចបរព្រះទីនាំង តំ បេឆសំ ឆ្ពោះសំដៅទៅលំនៅប្រទេសនោះឯងហោង ៗ

មហារាជបព្វំ និដ្ឋិតំ បពិត្រអើយ រីយើងស្រដីសរសើរ ពណ៌នា កណ្ឌមហារាជបព្វៈ ដ៏ប្រដាប់ប្រដានូវគាថា ៦៩ គាថា ក៏ចប់បរិបូណ៌សមគួរ ដោយនូវវេលានេះឯងហោង ៗ

ចប់ កណ្ឌមហារាជបព្វៈ ទី ១១ តែប៉ុណ្ណេះ ៗ

⁂

ចម្លងចប់នៅថ្ងៃ ១០ រោច ខែជេស្ឋ ព.ស. ២៥៣៣
ត្រូវនឹងថ្ងៃអាទិត្យ ទី ១៧ ខែមិថុនា គ.ស. ១៩៩០

បរិយាយដោយឡែក អំពីរឿងជូជកបរិភោគអាហារ

អថ ជូជកោ បមាណាតិក្កន្តំ ភុញ្ជិត្វា ជិរាបេតុំ អសក្កោន្តោ កាលមកាសិ បពិត្រអើយ ព្ធដ៏កាលនោះ ព្រះបាទស្រីសញ្ជ័យ ព្រះអង្គរណ្ដាប់ប្រមូលទ្រព្យស្រេចហើយ ទើបស្ដេចឱ្យរៀបប្រដាប់ប្រដា នូវចំណីភោជនាហារឱ្យជូជកឆី នីទេ។ នូវ ត្រីកប់ ត្រីអាំង សម្លទំពាំង ម្ជូរប្រហើរ ត្រីឆ្អើរ ត្រីស្ងោរ ហើយផ្លែត្រៀល ១ ត្រក ដូងបក ៥ ជើងត្រុំ នំបញ្ចុក ១ កញ្ជើ រវាង បបរនោះ ៥ ថ្លាង ទើបព្រាហ្មណ៍អំពះនូវផ្អកត្រីក្រឹម តម្រឹមនឹងក្ដឹបស្វាយ មាត់ជីព្រាហ្មណ៍រីករាយញញឹមញញែម ក្អកគ្រហែម ជីព្រាហ្មណ៍ លិទ្ធអណ្ដាតភ្លែម ៗ ទើបព្រាហ្មណ៍ អង្គុយច្រហោងទះក្លៀកផ្ទូង ៗ ថា ឱះ អេះ ពះណ្ហើយ វាតិចទេ វាតិចទេ ព្រាហ្មណ៍ស្រដីដូច្នោះ ទើបជីព្រាហ្មណ៍ប្រវាចំកោង ខ្ទង អំពះនូវគ្រាក់ត្រីពោ ដែលគេទុក ៧ ថ្ងៃ អំពះនូវអំបុកស្រូវថ្មី ៥ ស្បោង អំពះនូវទឹកឃ្មុំនោះ ៣ ពិន្ទង អំពះនូវចេក ៤ ស្ទង ជីព្រាហ្មណ៍អំពះនូវជ្រក់ថ្វាន់ ១ ថ្លាង អំពះនូវបាយដំណើប នោះ ១ ចង្អេរគ្រាង នូវបាយឱ្យាយ ១ កញ្ជើរវាង អំពះនូវសតូវនោះ ១ ជើង អំពះនូវពោតលីងនោះ ១ ផ្លូន អំពះនូវពោតស្ងោរ ១ ស្លឹក ជីព្រាហ្មណ៍ផឹកទឹកម្លេម ៗ អំពះនូវផ្អកបង្កងនោះ ១ ពាង អំពះនូវសម្លជ្រូកនោះ ៣ ថ្លាង កាលឯណា ជីព្រាហ្មណ៍ អំពះអស់ហើយ ម្ល៉ោះហើយ ហៅអស់ខ្ញុំប្រុសស្រី ឱ្យយកចំណីមក

ថែម ព្រាហ្មណ៍ពមឆីអស់រលីង ទើបហៅទៅមេហឹងកន្ធរ ឱ្យមកក្បិតខ្នង ជីព្រាហ្មណ៍អំពះនូវខៅពងនោះ ៥ ឆ្នាំងបាយ អំពះនូវនំផលអាយប្រប៉ុនថ្នក្រាន បោះទៅរលាយ ៗ ម៉្លោះវា ក្រហល់ក្រហាយ ជីព្រាហ្មណ៍ផឹកទឹក ពុំទាន់លែងមាត់ ជីព្រាហ្មណ៍ឆីស្លាទាំងស្មែង ម្លូទាំងត្របក កំបោរទាំងអក ស្លាជ្វាទាំងដុំ ឯថ្នាំទាំងផ្នត់លាបនូវក្រមួនមាត់នោះ ១ ចាន ក៏ហេតុតែជីព្រាហ្មណ៍អំពះចំណីលើសនឹងខ្នាត ម៉្លោះហើយ ជីព្រាហ្មណ៍ដេកថ្ងូរហ៊ឺ ៗ ឈឺចុកកន្លះព្រាហ្មណ៍ណាស់ លើកដៃសំពះបង្វរខ្មោចដូនខ្មោចតាថា ឱ! លោកអើយ អាសូរករុណាឱ្យខ្ញុំមានជីវិតរស់រួច ទៅដល់យល់នាងអមិត្តតាបនា ដ៏ជាភរិយាក្រមុំសម្លាញ់ខ្ញុំហោង ៗ

ផងនោះ មានអាមាត្យ ១ ឈ្មោះសិវិក្កុរាម វារត់ទន្ទ្រាមទៅទូលព្រះបាទស្រីសញ្ជ័យ ថា បពិត្រអម្ចាស់អើយ ឥឡូវព្រាហ្មណ៍ចង្រៃ ឆីចំណីច្រាសផ្ទៃ ច្រឡើសលើស លើចុងដង្ហើមហើយឈឺជាទូរន់ពន់ប្រមាណ មានពោះនោះធំកំប៉ោងក្រៃពេកហោង ៗ អណ្ដាប់នោះ ស្ដេចឱ្យមេមត់ទាំង៤នាក់ទៅមើលជម្ងឺជូជកព្រាហ្មណ៍ នាមឈ្មោះប៉ៃប៉ោះ ជាអ្នកដណ្ដឹងជម្ងឺរោគា នាមឈ្មោះប៉ៃរ៉ា ជាអ្នកហៅព្រលឹង នាមឈ្មេះប៉ៃសុកកំព្រឹង និងយាយមាន់ខ្វាក់ ជាអ្នកបោសព្រលឹង មកហើយជីព្រាហ្មណ៍ មកហើយជីព្រាហ្មណ៍ ឯងមិនមកប៉ាំរ៉ាំង ឆាំងប៉ាំរ៉ៃ ស្លាប់ក៏មិនប៉ៃ រស់ក៏មិនពូវ បើពោះជីព្រាហ្មណ៍ឯង វាធំទ្រលូ ៗ

ប្រើអញធ្វើម្ដេច បន្ទិចបរមគ្រូមកមើលជំងឺព្រាហ្មណ៍ ទើបបរមគ្រូដណ្ដឹងជំងឺជូជកនុព្រាហ្មណ៍ថា ជីព្រាហ្មណ៍អើយ ជីព្រាហ្មណ៍ដូនតាបាតើឈ្មោះអ្វីខ្លះ ៗ ទើបជូជកខំអត់ដង្ហើមថា អ្នកអើយ រីដូនខ្ញុំ ១ ឈ្មោះដូនល្វា ជីតាខ្ញុំ ១ ឈ្មោះតាគគីរ ចំណោរអំពីនោះទៅ មានមាខ្ញុំ ១ ឈ្មោះមាខ្យង មានបងខ្ញុំ ១ ឈ្មោះបងអក្កិធី ប្អូនស្រីខ្ញុំ ១ ឈ្មោះមេម្លេះ ឯខ្លួនខ្ញុំនេះ ឈ្មោះជូជកព្រាហ្មណ៍ កើតឆ្នាំខាល ថ្ងៃអង្គារ មកពានលើទន្សាឯង ៗ

ទើបបរមគ្រូបណ្ដោយថា អេះជីព្រាហ្មណ៍ ជីឯងពុំទាន់ចាស់ គ្រោះជីឯងកាចណាស់ ព្រះម្ឫត្យូវមកសង្កត់ក ត្បិតជីព្រាហ្មណ៍ឯងអំពះលើត្រីខ្ទប់គេទុក ៣ ថ្ងៃ គ្រោះជីកាចក្រៃណាតាជី ៗ ឱ្យអ្វីអញ ៗ នឹងមើលឱ្យជា ទើបជូជកនុព្រាហ្មណ៍ថា អ្នកអើយ រីទ្រព្យខ្ញុំនៅអាយនេះ សឹងតែមានច្រើន ខ្ញុំនឹងឱ្យរង្វាន់ខាន់ខៅអ្នកហោង ៗ អណ្ដាប់នេះ ទើបបរមគ្រូ ទៅរកថ្នាំបន្សាប យកនូវអាចម៍កុក អាចម៍ខ្វែក អាចម៍ក្អែក អាចម៍ត្មាត អាចម៍ចាប អាចម៍ព្រាប អាចម៍មាន់ អាចម៍ទា អាចម៍ឆ្កែ អាចម៍ឆ្មា ដាក់នឹងត្រឡោក ហើយពពោកក្បាល ព្រាហ្មណ៍ខំអត់ដកដង្ហើម យកដៃទៅស្ទាបក្បាល ហើយមកហិតល្បងលងមើល ហើយថា ឱះអះពះណ្ហើយ អាចម៍ទេវ៉ា អាចម៍ទេតើ ទើបបរមគ្រូទៅយកផ្ដៅ ១ ក្រពើ ទៅរឹតរួត ត្រង់បែង ចងពោះព្រាហ្មណ៍នោះស្រេច ៗ

លុះដល់ថ្ងៃរសៀលបន្តិច ព្រាហ្មណ៍ធ្លាយពោះផូង ដំរីរោង ភ្ញាក់ធ្លាក់ទាំងទម័ក បាក់ទាំងកង្វេរ សឹងដ៏រោទ៍សម្លេងទម្លាក់ បំពង់ចំហុងចមូរ អ្នកផងសឹងដ៏រត់ដណ្ដឹងគ្នា ថា ម្នាលគ្នា យើងទាំងឡាយអើយ ស័ត្វអ្វីហះ អ្នកខ្លះឆ្លើយថា គេបាញ់កាំភ្លើងមេរៀម ថាយើលោកថា កុំឱ្យបាញ់មិញ តើម្ដេចឡើយ មកបាញ់ធ្វើឱ្យកោលាហលរវល់អស់ទាំងផ្ដាស មិនចេះខ្មាសគេ ៗ នឹងយកទៅច្រកឃ្នាងក ថ្ងៃនេះមិនលែងឡើយ ខ្លះស្ដាប់ហើយឆ្លើយថា លលាក់លលើពភ្លើដូច្នេះ ព្រាហ្មណ៍នឹចំណី ធ្លាយពោះមិនថាឡើយ ទៅថាគេបាញ់កាំភ្លើងមេរៀមវិញ ៗ

អណ្ដាប់នោះ មានអាមាត្យមួយ រត់ទៅទូលព្រះបាទស្រីសញ្ជ័យថា បពិត្រក្សត្រថ្លៃប្រសើរអើយ រីព្រាហ្មណ៍ចង្រៃបែកផ្ទៃក្ស័យជីវិតពិតហោង ៗ អណ្ដាប់នោះ ស្ដេចឱ្យលើកខ្មោចជូជកនុព្រាហ្មណ៍ ធ្វើនូវភ្នំយោងកន្ទេលនបស្ទប គ្រប់ខ្មោចជូជកនុព្រាហ្មណ៍ស្រេច យកនូវកន្ទេលទាំងបាច់ សឹងតែកណ្ដុរវាកាត់ដាចដាច់ នាមឈ្មោះប៉ែម៉ា ជាអ្នកកណ្ដៀតកញ្ជើស្លា នាមឈ្មោះប៉ែវ៉ា ជាអ្នកកាន់ចានបញ្ចុះកំពង់ ឱ្យខ្សំគម្លង់ ជាអ្នកប្រាយលាជ ខុនជែកំណាច ជាអ្នកកាន់ទង់ព្រលឹង ឱ្យតាអីកំព្រឹង ជាអ្នកទូលខ្សែភ្លាំង ឱ្យតាអុករំខាំង ជាអ្នកកាន់ធ្នូ ឱ្យស្លួសមូទូ នូវខុនរស់ទម្លាយលោង ជាអ្នកសែងជើងកោសខ្មោចជូជកនុព្រាហ្មណ៍ លុះសែងខ្មោចព្រាហ្មណ៍នោះ ទៅ

ដល់វត្តជីវែង ៗ ថា ខ្មោចព្រាហ្មណ៍នេះចង្រៃ ប្រវាឈើព្រៃ ដេញវាយខ្មោចព្រាហ្មណ៍អប្បលក្ខណ៍ ម្លោះហើយ ប្រវា កន្ទ្រាក់គ្រវាត់គ្រវែង សែងទៅដល់វត្តតាជី រីឯតាជី រលះ រលាំងយកដែមកបាំងជាផ្លិត យកនិស៊ីទន៍មកពាក់ជាចីពរឈរ បង្សុកូល តាជីសូត្រថា **ករណី ករុណា យានីឆភូតា** ៗ ទើបឧបាសកថា តាជីសូត្រខុស ទើបបណ្ឌិតយស ថា អេះ តាជីសូត្រមិនចាំ បណ្ឌិតគាំថា តាជីសូត្រភ្លេច ទើបបណ្ឌិត ពេជ្រថា តាជីសូត្របភ្លែ ទើបឯបណ្ឌិតនៃថា អេះ តាជី ទើបរៀន តាជីអៀនប្រៀនគាត់មិនចេះខ្មាសគេ ៗ រីឯតាជី ខឹងហើយប្រកែក ឧបាសកសម្លក់ក្រឡេតមើលទៅឯសាមណេរ ឱ្យគេប្រគេនទានច្រើន ឯសាមណេររត់ទៅច្រាន តាជីម្រើង ពុំបាន ដួលទៅក្នុងភក់ទឹកស្រខក់ អស់ឧបាសកសើចទ្រហឹង អឹងកង តាជីថា ចុច្ចះអះពះ គ្នាយើង ល្បងលងនឹងកម្លាំង ជីពុកកញ្ច្រាស់មើលហះ ម្លោះហើយ ពលផងទាំងឡាយ វា ផ្អើលរត់ប្រញាយ ដុតខ្មោចព្រាហ្មណ៍កំណាចពុំសុស គ្រាប់ ភ្លៀងបង្អុររលត់ឯភ្លើងអស់ គាស់ឯខ្មោចព្រាហ្មណ៍នោះ ទម្លាក់ទៅក្នុងអូរ មានឆ្កែឈ្មោល ១ ឈ្មោះអាធូ ឆ្កែញី ១ ឈ្មោះមេគោរាត វាប្រទង់ប្រទាញជើង ឈ្លើងទាមក្អែក ក្អែកចោះពោះ ហេតុតែព្រាហ្មណ៍ប្រមាថចៅជាលី នូវនាង ក្រស្នានោះមិញ ព្រាហ្មណ៍ធ្លាក់ទៅមហានរកនាយហោង ៗ

រាជា តស្ស សរីរកិច្ចំ ការាបេត្វា បពិត្រអើយ ព្ឋដ៏កាលនោះ ព្រះបាទស្រីសញ្ជ័យ ព្រះអង្គឱ្យរាជអាមាត្យប៉ាវគងស្គររកញ្ញាតិការផេ់ពណ៌ សព្វស្រុកគម្រប់ ៧ ថ្ងៃ រកអ្នកឯណាដឹង ថា ជាសាច់សន្តាននឹងព្រាហ្មណ៍នោះគ្មានឡើយ ៗ រឹអស់ព្រះរាជទ្រព្យអម្បាលនោះ ដែលលោះព្រះរាជកុមារនោះមិញ គិតដ៏ចេរវិលមកជាព្រះរាជទ្រព្យវិញហោង ៗ

ចប់ បរិយាយដោយឡែក អំពីរឿងជូជកបរិភោគអាហារ តែប៉ុណ្ណោះ ៗ

~~~~~~~~~~~~~~~
~~~~~~~~~~~~~~~

មហាវេស្សន្តរជាតក

ទី ១២



កណ្ឌឆក្សត្រ

ប្រដាប់ដោយគាថា ៣៦

មហាវេស្សន្តរជាតក

ទី១២

កណ្ឌឆក្សត្រ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ជាលិកុមារោបិ មុចលិន្ទស្សតីរេ ខន្ធាវារំ និវាសាបេត្វា ចតុទ្ទស រថសហស្សានិ អាគតមគ្គាភិមុខានេវ ឋបាបេត្វា តស្មិំ តស្មិំ បទេសេ សីហព្យគ្ឃទីបិខគ្គាទីសុ អារក្ខំ សំវិទហិ ។

ភោ សាធវោ ហៃសាធុសប្បុរសផងទាំងឡាយអើយ កាលនោះ ព្រះជាលីកុមារជាមគ្គុទ្ទេសក៍ដ៏វិសេស នាំផ្លូវព្រះមហាក្សត្រទាំងពីរព្រះអង្គទៅដល់មុចលិន្ទស្រះហើយ ព្រះជាលីកុមារ ក៏រណ្តាប់តាក់តែងឱ្យដាក់ទ័ពទាយ រាយចំណត ចតចាំព្រះមហាក្សត្រជាស្រេច រីឯរទេះទាំងមួយម៉ឺនបួនពាន់ ក៏ឱ្យបន្ទិលចំពោះមុខទៅកាន់ផ្លូវដំណើរដែលមក ប្រយោជន៍ដើម្បីនឹងឱ្យទៅចាំពិភ័ក្តិរក្សាអស់ពលផង កុំបីឱ្យសត្វទាំងឡាយមានរាជសីហ៍ ខ្លាធំ ខ្លាដំបង រមាស ជាដើម ចូលមកបៀតបៀនបានឡើយ ហត្ថិអាទីនំ សទ្ទោ មហា អហោសិ បពិត្រអើយ រីស័ព្ទដំរី សេះ រទេះ មួយអន្លើនូវអស់ពលផងទាំងឡាយ សឹងឮសន្ធឹកនោះមហិមាក្រៃពេក ។

អថ មហាសត្តោ តំ សទ្ទំ សុត្វា កាលនោះ ព្រះមហាក្សត្រទ្រង់ជ្រាបហើយ ទ្រង់ព្រះចិន្តាពិចារណាថា ឱ ! សត្រូវផងទាំងឡាយអើយ សមវារទៅចោមរោមចាប់សម្លាប់ឯសម្តេចព្រះវរបិតាអញហើយ សមវាមកចោមរោម ចាប់សម្លាប់ឯអញនេះផង ។ ព្រះអង្គទ្រង់ព្រះតម្រិះថា ឱ ! អញអើយ សមនឹងក្ស័យប្រល័យជីវិតដោយពួកសត្រូវនេះឯង មិនទៅឡើយ ព្រះអង្គទ្រង់ព្រះចិន្តាពិចារណានូវប្រការអម្បាលណោះហើយ ព្រះអង្គភិតភ័យខ្លាច ពុំអាចដើម្បីទប់ទល់តម្កល់អាត្មាភាពនោះបានឡើយ លុះដល់ចាប់ព្រះហស្តព្រះនាងមទ្រីនាំឡើងទៅលើកំពូលភ្នំវង្កតកូវ ទ្រង់ទតរមិលមើលទៅអស់សេនាយោធាផងទាំងឡាយនោះហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គបន្ទូលនឹងអស់ភិក្ខុផងទាំងឡាយ ទ្រង់សូត្រសាជាបាទព្រះគាថា ដូច្នេះ

តេសំ សុត្វាន និគ្ឃោសំ ភីតោ វេស្សន្តរោ អហុ
បព្វតំ អភិរុហិត្វា ភីតោ សេនំ ឧទិក្ខតិ ។
ឥង្ឃ មទ្ទិ និសាមេហិ និគ្ឃោសោ យាទិសោ វនេ
អាជានីយា ហសិស្សន្តិ ធជគ្គានេច ទិស្សរេ ។
ឥមេ នូន អរញ្ញម្ហិ មិគសំយានិ លុទ្ទកា

ខាគុរាហិ បរិក្ខិត្វា សោណ្ឌេ ឃាតេត្វ តាវទេ
ខិក្តោសមានា តិប្បាហិ ហន្តិ នេសំ ខរំ ខរំ ៗ
តថា មយំ អទូសកា អរញ្ញេ អចរុន្ធកា
អមិត្តហត្តដ្ឋគតា បស្ស ទុព្វលឃាតកន្តិ ៗ

ភិក្ខុអើយ វីព្រះបាទស្រីវេស្សន្តរ ឮស័ព្ទពលសាកលយោធាសេនាព្រះបាទស្រីសញ្ជ័យ ដ៏ជាសម្តេចព្រះវរបិតា នោះហើយមានព្រះរាជហឫទ័យភិតភ័យខ្លាច មិនអាចដើម្បីនឹងទប់ទល់តម្កល់អាត្មាភាពបានឡើយ ហើយទ្រង់ចាប់ព្រះហស្តព្រះនាងមទ្រីឡើងទៅលើកំពូលភ្នំនោះ ហើយមានព្រះបន្ទូលថា មទ្រីនាងអើយ ចូរនាងពិតពិលរមិលមើលទៅអស់សេនាសត្រូវផងទាំងឡាយ នាងអើយ នាងស្តាប់ឯស័ព្ទដំរី ស័ព្ទសេះ ស័ព្ទរទេះ នាងអើយ ចូរនាងរមិលមើលទៅឯចុងទង់ជ័យនោះ យល់ប្រកិតមកថា ឱ! ដូចអញគិតនេះហើយ នាយើងទាំងពីរនេះ ឧបមាបីដូចសត្វម្រឹគត្រូវព្រានព្រៃ វាមកចោមរោមស្ទាក់ព័ទ្ធជុំវិញ ហើយធ្វើអន្ទាក់ចាក់ជង់សង់ចម្រូង ជីកអណ្តូង រំលុងហើយ វាចូលមកបង្អើលឱ្យរត់ទៅត្រូវរំលុង ត្រូវចម្រូង ចូលអណ្តូងរំលុងវា នោះហើយ វាយកលំពែងស្នែងក្របីមកចាក់ ឱ្យក្ស័យប្រល័យជីវិតស្រេចហើយ វាយកទៅធ្វើជាចំណីអាហារវាហោង នោះតើមានប្រការដូចម្តេចមិញ នាយើងទាំងពីរនេះ នឹងលុះក្នុងកណ្តាប់ដៃសត្រូវនោះ មានឧបមេយ្យដូច្នោះហោង វីព្រះ

ពោធិសត្វ ហេតុតែភ័យខ្លាចស្លាប់នោះមិញ លុះដល់ទ្រង់ព្រះកន្សែងថ្លែងពិលាប ដោយនូវប្រការអម្បាលណោះហោង ៗ

ក្សិណនោះ ព្រះនាងមទ្រីទតរមិលមើលទៅអស់សេនាយោធាផងទាំងឡាយ ព្រះនាងស្គាល់ជាក់ជាពលសកលយោធាសេនាមាត្យ អាត្មាឯងដូច្នោះហើយ ព្រះនាងទូលលោមព្រះបរមពោធិសត្វ ថា

អមិត្តា នប្បសហេយ្យុំ អគ្គីវ ឧទកណ្ណវេ
តថេវ ត្វំ វិចិន្តេហិ អបិ សោត្ថិ ឥតោ សិយាតិ ៗ

បពិត្រព្រះសម្មតិទេពមហារាជក្សត្រថ្លៃប្រសើរអើយ ព្រះអង្គភ័យខ្លាចអ្វីនឹងសត្រូវនោះ មានឧបមាបីដូចអ្នកយកភ្លើងគប់ទាំងពាន់ទៅរោលទឹកសមុទ្រ ផ្នាសបីនឹងក្តៅដល់តិចនោះ ឥតអ្តីមានឡើយ ៗ បពិត្រមហារាជអើយ ព្រះអង្គភ្លេចហើយហៈ នាសម្តេចព្រះឥន្ទ្រាធិរាជប្រទានព្រះពរព្រះអង្គមិញតើ ថាទោះយោបីសត្រូវមក អំពីទឹកក្តី អំពីគោកក្តី អំពីស្តាំក្តី អំពីឆ្វេងក្តី នឹងមកចោមរោមព្រះអង្គប៉ុន្មាន ៗ ក្តី នោះក៏នឹងមកបៀតបៀនព្រះអង្គពុំបានឡើយ សឹងន៏មកថ្វាយបង្គំប្រណម្យ សុំពរអំពីព្រះអង្គឯងវិញអេះ ① ៗ

១- តាមអដ្ឋកថាជាតកបាលីថា ព្រះនាងមទ្រីក្រាបទូល រំលឹកព្រះពោធិសត្វ ថា បពិត្រព្រះមហារាជ ព្រះពរឯណាដែលព្រះឥន្ទ្រាធិរាជ ទ្រង់ប្រទានដល់ព្រះអង្គ ថា ព្រះវររាជបិតានឹងស្តេចមកទទួលព្រះអង្គ សូមទ្រង់ពិចារណាដល់ព្រះពរនោះចុះ ៗ

ឯព្រះពោធិសត្វ កាលណាបើបានឮព្រះនាងមទ្រីទូលមិនឱ្យភិតភ័យខ្លាចនូវសត្រូវនោះឡើយ ព្រះអង្គបន្ទោបង់នូវទុក្ខសោកស្រេចហើយ ស្ដេចលីលាចុះមកអំពីលើភ្នំ មួយអន្លើនឹងព្រះនាងមទ្រី ទៅគង់នៅនាទ្វារព្រះបរមសាលារបស់ព្រះអង្គវិញហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលសូត្រសាននូវបាទព្រះគាថាដូច្នេះ

តតោ វេស្សន្តរោ រាជា ឱរោហិត្វាន បព្វតា
និសីទិ បណ្ណសាលាយំ ឧជ្ជុំ កត្វាន មានសន្តិ ។

ភិក្ខុអើយ កាលនោះ ព្រះបាទស្រីវេស្សន្តរ ស្ដេចចុះមកអំពីភ្នំ មួយអន្លើនឹងព្រះនាងមទ្រី មកគង់នៅនាព្រះបរមសាលា ព្រះអង្គតម្រង់នូវព្រះស្មារតីនោះខ្ជាប់ហើយ មិនភិតភ័យខ្លាចសត្រូវនោះឡើយ ។

ក្សិណនោះ ព្រះបាទស្រីសញ្ជ័យមានព្រះបន្ទូលនឹងព្រះនាងផុស្សតីទេវីថា នាងអើយ បើយើងទាំងពីរចូលទៅព្រមគ្នាតែម្ដងហើយ សមបាវេស្សន្តរនឹងកើតទុក្ខសោកនោះច្រើនមហិមាក្រៃពេក ហេតុនេះហោង នាងឱ្យអញទៅជាមុន ឱ្យបាវេស្សន្តរបន្ទោបង់នូវទុក្ខសោកហើយ សន្សឹមនាងទៅឯក្រោយអញ កាលបើនាងទៅបានបន្តិចហើយ សន្សឹមឱ្យចៅជាលីនិងមេក្រស្នា លីលាទៅជាអណ្ដាប់អណ្ដោយក្រោយនាងហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គសម្ដែងនូវបាទព្រះគាថា ដូច្នេះ

និវត្តយិត្វាន រថំ　　វុដ្ឋាបេត្វាន សេនិយោ
ឯកំ អរញ្ញេ វិហរន្តំ　　បិតា បុត្តំ ឧបាគមិ ។
ហត្ថិក្ខន្ធតោ ឱរុយ្ហ　　ឯកំ សោ បញ្ជលីកតោ
បរិកិណ្ណោ អមច្ចេហិ　　បុត្តំ សិញ្ចិតុមាគមិ ។
តត្ថទ្ទស កុមារំ សោ　　រម្មរូបំ សមាហិតំ
និសិន្នំ បណ្ណសាលាយំ　　ឈាយន្តំ អកុតោ ភយន្តិ ។

ភិក្ខុអើយ កាលនោះ ព្រះមហាក្សត្រ ឱ្យប្រែបង្វិលព្រះរាជរថទៅក្រោយ ហើយស្ដេចលីលាទៅកាន់សម្នាក់ព្រះរាជបុត្រ មួយអន្លើនឹងអស់អាមាត្យផងទាំងឡាយ កាលណាបើស្ដេចលីលាចូលទៅដល់ហើយ ស្ដេចចុះអំពីលើដំរីរ័តន៍មង្គល ហើយស្ដេចយកនូវព្រះពស្ត្របរិសុទ្ធស្ពាយឆៀងលើព្រះអង្សា លីលាចូលទៅ ដើម្បីនឹងអភិសេកព្រះរាជបុត្រនោះហោង ។ ព្រះអង្គទ្រង់ទតឃើញព្រះរាជឱរសទ្រង់ភេទបព្វជិត គង់ចូលឈានយ៉ាងខ្ជាប់ខ្ជួន ក្នុងព្រះបណ្ណសាលា ឥតមានកិតភ័យអ្វីឡើយ ។

តញ្ច ទិស្វាន អាយន្តំ　　បិតរំ បុត្តគិទ្ធិនំ
វេស្សន្តរោ ច មទ្ទី ច　　បច្ចុគ្គន្ត្វា អវន្ទិសុំ ។
មទ្ទី ច សិរសា បាទេ　　សសុរស្សាភិវាទយិ

មទ្ទី អហញ្ហ តេ ទេវ បាទេ វន្ទាមិ តេ ហុសា
តេសុ តត្ថ បលិសជ្ជ បាណិនា បរិមជ្ជថាតិ ៗ

កាលនោះ ព្រះបាទស្រីវេស្សន្តរ ព្រះអង្គគង់នៅនាព្រះបរមសាលា មួយអន្លើនឹងព្រះនាងមទ្រី ព្រះអង្គទតទៅយល់សម្តេចព្រះវរបិតាមកអំពីចម្ងាយហើយ ក៏ស្ទុះរត់ទៅទទួលសម្តេចព្រះវរបិតា ព្រះអង្គថ្វាយបង្គំស្រេចហើយ ទើបព្រះនាងមទ្រីថ្វាយបង្គំប្រណម្យ ទូលថា បពិត្រព្រះសម្មតិទេពមហារាជក្សត្រថ្លៃប្រសើរអើយ ខ្ញុំអម្ចាស់ឯងឈ្មោះនាងមទ្រី ជាកូនប្រសាព្រះអង្គ ខ្ញុំអម្ចាស់មកក្រាបថ្វាយបង្គំក្រោមព្រះបាទព្រះអង្គ ៗ

ក្សិណនោះ ព្រះបាទស្រីសញ្ជ័យ យកព្រះហស្តដ៏ទន់ល្វន់បីដូចក្រពុំឈូករ័ត្ន មកសណ្ឋិតលើព្រះបិដ្ឋិ បបោសអង្អែលព្រះនាងមទ្រីដ៏ជាកូនប្រសា ហើយទ្រង់ព្រះកន្សែងពិលាប អាណិតអនាថ មុខគួរឱ្យអាសូរករុណាពេកហោង ៗ លុះព្រះអង្គបន្ទោបង់នូវទុក្ខសោកស្រេចហើយ ស្តេចក៏គង់នៅ ជាសុខសប្បាយ ធ្វើប្រស្រ័យសាកសួរទទួល មួយអន្លើនឹងព្រះរាជបុត្រសូត្រជាបាទព្រះគាថា ដូច្នេះ

កច្ចិ នោ កុសលំ បុត្ត កច្ចិ បុត្ត អនាមយំ
កច្ចិ ឧញ្ឆេន យាបេថ កច្ចិ មូលផលា ពហូ ៗ
កច្ចិ ឌំសា មកសា ច អប្បមេវ សិរីសបា
វនេ វាឡមិគាកិណ្ណេ កច្ចិ ហីសា ន វិជ្ជតីតិ ៗ

បុត្ត ម្នាលកូនសម្លាញ់អើយ ពីដូចអ្នកមកនៅឋានអាយនេះ តើសុខសប្បាយជាទេឬ ឬមួយក្រែងមានជំងឺអាពាធព្យាធិរោគាជរាមកបៀតបៀនអ្នកទាំងពីរ រឺទុក្ខសោករោគភ័យចង្រៃឧបទ្រពផងទាំងឡាយ តើញាំងមានឬទេ ៗ ប្រការមួយសោត នឹងស្វែងរកផ្លែឈើមើមឈើផងទាំងឡាយ មកចិញ្ចឹមជីវិត តើញាំងមានឬទេ រឺមូស សុច ស្រាំង ស្រួយ ខ្ទួយ ក្អែប មមង់ មមាច កន្ទេចអាល នូវពស់តូចពស់ធំ ច្រឡំ នូវម្រឹគពាឡសាហាវយង់ឃ្នង តើញាំងបឹងមកបៀតបៀនអ្នកទាំងពីរឬទេ ៗ

កាលនោះ ព្រះពោធិសត្វ ស្តាប់ព្រះបន្ទូលសម្តេចព្រះវររាជបិតាហើយ ក្រាបបង្គំទូល ថា

អត្ថិ នោ ជីវិកា ទេវ សា ច យាទិសិ កីទិសា
កសិរា ជីវិតា ហោម ឧញ្ឆាចរិយាយ ជីវិតំ ។
អនិទ្ធិនំ មហារាជ ទមេត្យស្សំវ សារថិ
ត្យម្ហា អនិទ្ធិកា ទន្តា អសមិទ្ធិ ទមេតិ នោ ។
អបិ នោ កីសានិ មំសានិ បិតុ មាតុ អទស្សនា
អវរុទ្ធានំ មហារាជ អរញ្ញេ ជីវិសោកិនន្តិ ។

ទេវ បពិត្រសម្តេចព្រះវររាជបិតា ក្សត្រថ្លៃប្រសើរអើយ រីយើងទាំងពីរ មកនៅព្រៃអាយ ដើម្បីនឹងស្វែងរកផ្លែឈើមើមឈើផងទាំងឡាយចិញ្ចឹមជីវិត បពិត្រព្រះមហារាជអើយ

រីនាងមទ្រីជាបុត្រប្រសារបស់ព្រះអង្គ តែងនឹងស្វែងរកផ្លែឈើពុំដែលដាច់ឡើយ បីដូចនាយសារថីទូន្មានសេះអាជានេយ្យ ឱ្យបានរបបបែបបទប្រពៃនោះ មានប្រការដូចម្ដេចមិញ រីនាងមទ្រី តែងនឹងស្វែងរកនោះ ពុំដែលខ្ជិលឡើយ មានប្រការដូច្នោះដែរ ៗ បពិត្រព្រះមហារាជអើយ រីយើងទាំងពីរនេះ អ្នកស្រីពិរាស្ត្រគេបំបរបង់មកនៅនាព្រៃ ស្វែងរកចិញ្ចឹមជីវិតរស់នៅប្រឡំនឹងទុក្ខសោកច្រើនក្រៃ ៗ បពិត្រមហារាជអើយ ហេតុតែនាងមានសេចក្ដីព្រួយលំបាកមហិមា ឯណានាងក៏ព្រាត់ប្រាសកូនជាទុក្ខសោក ដ៏មានខ្លួនស្គាំងស្គម ថមថយកម្លាំងលឿងទាំងសម្បុរ ពុំយល់ដូចប្រក្រតីឡើយ ៗ រីព្រះពោធិសត្វព្រះអង្គសម្ដែងប្រាប់ព្រះវររាជបិតា ដោយនូវសភាពជាអ្នកកម្សត់ទុគ៌ត នូវប្រការអម្បាលណោះហើយ ព្រះអង្គបន្ទូលសួរពត៌មានអំពីព្រះរាជបុត្រ ទ្រង់សូត្រជាបាទព្រះគាថា ដូច្នេះ

យេហិ តេ សិវិសេដ្ឋស្ស   ទាយាទាប្បត្តមានសា
ជាលី កណ្ហាជិនា ចុភោ   ព្រាហ្មណស្ស វសានុគា
អច្ចាយិកស្ស លុទ្ទស្ស   យោ នេ គាវោវ សុម្ភតិ ៗ
តេ រាជបុត្តិយា បុត្តេ   យទិ ជានាថ សំសថ
បរិយាបុណាថ នោ ខិប្បំ   សប្បទដ្ឋំវ មាណវន្តិ(១) ៗ

១- បើប្រែតាមរូបបាលីគាថានេះ ដូច្នេះ " កុមារទាំងពីរ គឺចៅជាលីនិងមេក្រស្នា ជារជ្ជទាយាទ មិនទាន់បានសម្រេចដូចប្រាថ្នារបស់ព្រះអង្គជាកំពូលនៃសិវិរដ្ឋ

ឆ្លង . . .

បពិត្រសម្តេចព្រះវរបិតាក្សត្រថ្លៃប្រសើរអើយ រីក្មេងទាំងពីរ គឺចៅជាលីនិងមេក្រស្នា ជាចៅដំណរាជ្យព្រះអង្គនោះ អញខ្ញុំឱ្យទៅជាទានព្រាហ្មណ៍ហើយ ក្រែងព្រះអង្គបានឃើញយល់ផង សូមទានព្រះអង្គសម្តែងថ្លែងប្រាប់យើងខ្ញុំឱ្យឆាប់ កុំបីយូរឡើយ ថាបើព្រះអង្គមិនសម្តែង ថ្លែងប្រាប់ហើយ សមយើងខ្ញុំទាំងពីរនឹងក្ស័យប្រល័យជីវិតប្រាកដហោង ៗ

រាជា អាហ ក្សិណនោះ ព្រះបាទស្រីសញ្ជ័យ ព្រះអង្គជ្រាបហើយ មានព្រះបន្ទូលថា

ឯតេ កុមារា និក្កីតា ជាលី កណ្ហាជិនា ចុភោ
ព្រាហ្មណស្ស ធនំ ទត្វា បុត្ត មា ភាយិ អស្សសាតិ ៗ

ម្នាលបាអើយ រីកុមារទាំងពីរ គឺចៅជាលីនិងមេក្រស្នា អញលោះរួចចេញអំពីព្រាហ្មណ៍ហើយ កុំបាចប់បារម្ភឡើយ ចូរបាដកដង្ហើមចេញចូលឱ្យធូរស្រួល សុខសប្បាយទៅហោង ៗ

តំ សុត្វា មហាសត្តោ បដិលទ្ធស្សាសោ បិតរា សទ្ធឹ បដិសន្ថារមកាសិ កាលនោះ ព្រះមហាសត្វជ្រាបហើយ មានព្រះរាជហឫទ័យនោះ ត្រេកអរសាទរ ធ្វើបដិសណ្ឋារៈ ប្រស្រ័យសាកសួរ ទទួលមួយអន្លើនឹងសម្តេចព្រះវររាជបិតា ថា

ធ្លាក់ទៅនៅក្នុងអំណាចរបស់ព្រាហ្មណ៍ ជាមនុស្សកំណាចកាចសាហាវ វាវាយដំបណ្តើរទៅដូចសត្វគោ ៗ បើព្រះអង្គទ្រង់ជ្រាប ឬបានដំណឹងខ្លះ សូមទ្រង់មេត្តាប្រោស ត្រាស់ប្រាប់ឱ្យយើងខ្ញុំបានដឹងឆាប់ផង បីដូចគ្រូពេទ្យ ប្រញាប់រក្សា ជំងឺមនុស្សដែលត្រូវពស់ចឹក ” ៗ

កច្ចិ នុ តាត កុសលំ   កច្ចិ តាត អនាមយំ
កច្ចិ នុ តាត មេ មាតុ   ចក្ខុ ន បរិហាយតីតិ ។

តាត បពិត្រសម្តេចព្រះវររាជបិតាធិរាជក្សត្រថ្លៃប្រសើរអើយ រីព្រះអង្គគង់នៅនគរឯនាយនោះ តើញុំាងមានជំងឺអាពាធព្យាធិរោគាជរា មកបៀតបៀនព្រះអង្គឬទេ ។ រីទុក្ខភ័យចង្រៃឧបទ្រពផងទាំងឡាយ ញុំាងកើតមានឬទេ ។ មួយសោត រីព្រះនេត្រសម្តេចព្រះវរមាតាខ្ញុំ តើងងឹតហើយ ឬនៅឡើយទេ ។

រាជា អាហ ទើបសម្តេចព្រះមហាក្សត្រ មានព្រះបន្ទូល ថា

កុសលញ្ចេវ មេ បុត្ត   អថោ បុត្ត អនាមយំ
អថោ ច បុត្ត តេ មាតុ   ចក្ខុ ន បរិហាយតីតិ ។

ម្នាលកូនអើយ រីជំងឺអាពាធព្យាធិរោគា នឹងមានមកបៀតបៀនយើងនោះ ឥតអង្គីមានឡើយ រីទុក្ខសោក រោគភ័យចង្រៃផងទាំងឡាយ នឹងមានមកដល់ខ្លួនយើងនោះ ឥតអង្គីមានឡើយ រីព្រះនេត្រសម្តេចព្រះវរមាតាបានោះ ពុំទាន់ងងឹតនៅឡើយទេ ។

មហាសត្តោ អាហ   ព្រះមហាសត្វឆ្លើយ ថា

កច្ចិ អរោគំ យោគ្គន្តេ   កច្ចិ វហតិ វាហនំ
កច្ចិ ផីតោ ជនបទោ   កច្ចិ វុដ្ឋិ ន ឆិជ្ជតីតិ ។

បពិត្រសម្តេចព្រះវរបិតាអើយ រីគោក្របី ដំរីសេះយានជំនិះជំនាន់ អាចនាំព្រះអង្គទៅមកនោះ គង់នៅឬទេ ៗ ប្រការមួយសោត រីស្រុកក្រៅលំនៅជនបទ ផងទាំងឡាយ ញុំាងកើតមានភ្លៀងផ្គរប្រពៃ សំបូរនៃស្រូវអង្ករមាសប្រាក់ឬទេ ៗ ប្រការមួយសោត អស់មនុស្សម្នា មហាជន ផងទាំងឡាយ សុខសប្បាយជាទេឬ ៗ

រាជា អាហ រីព្រះបាទស្រីសញ្ជ័យ ព្រះអង្គទ្រង់ព្រះសណ្តាប់ហើយ មានព្រះបន្ទូល ថា

អថោ អរោគំ យោគ្គម្មេ អថោ វហតិ វាហនំ
អថោ ផីតោ ជនបទោ អថោ វុឌ្ឍិ ន ឆិជ្ជតីតិ ៗ

ហៃកូនស្ងួនសម្លាញ់ឱពុកអើយ រីគោក្របី ដំរីសេះ រទេះនូវអស់យានជំនិះជំនាន់អញ អាចនាំទៅមកបាននោះ សឹងគង់នៅល្អ ៗ រីស្រុកក្រៅលំនៅជនបទនោះផងសោត សឹងដ៏កើតភ្លៀងផ្គរប្រពៃ សម្បូរនូវស្រូវអង្ករ មាសប្រាក់នោះច្រើន ពុំដែលដាច់ឡើយ ៗ

ឯតំ តេសំ តិណ្ណំ ខត្តិយានំ សល្លបន្តានញ្ញេវ ក្សិណនោះ ព្រះមហាក្សត្រទាំងបីព្រះអង្គមានព្រះបន្ទូលសំណេះសំណាលនូវប្រការអម្បាលណោះហើយ ទើបព្រះនាងសុបារសុប្បតី ដ៏ជាសម្តេចព្រះវរមាតា ព្រះនាងលីលាចូលទៅ មួយអន្លើនូវអស់ស្រីព្រះស្នំក្រមការ សឹងដ៏មកចោមរោម ជាបរិវារ

ប្រយោជន៍ដើម្បីនឹងលីលាទៅកាន់សម្នាក់ព្រះរាជបុត្រ នោះហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលជាបាទព្រះគាថា ដូច្នេះ

ឥច្ចេវំ មន្តយន្តានំ មាតា នេសំ អនិស្សរា
រាជបុត្តី គិរិទ្វារេ បត្តិកា អនុបាហនា ។
តញ្ច ទិស្វាន អាយន្តឹ មាតរំ បុត្តគិទ្ធិនី
វេស្សន្តរោ ច មទ្ទី ច បច្ចុគ្គន្ត្វា អវន្ទិសុំ ។
មទ្ទី ច សិរសា បាទេ សស្សុយា អភិវាទយិ
មទ្ទី អហញ្ហិ តេ អយ្យេ បាទេ វន្ទាមិ តេ ហុសាតិ ។

ភិក្ខុអើយ រីព្រះនាងសុបារសុប្បតីដ៏ជាសម្តេចព្រះវរមាតា ព្រះនាងលីលាចូលទៅ ដោយនូវព្រះបាទទទេ ឥតសុពណ៌បាទុក៏ទៅដល់ទ្វារព្រៃភ្នំគិរីវង្កតនាហៀបទៀបនឹងដល់ព្រះបរមសាលា ក៏ព្រះពោធិសត្វនូវសម្តេចព្រះនាងមទ្រីទតទៅយល់សម្តេចព្រះវរមាតាមកដល់ប្រាកដ ហេតុតែសេចក្តីរឭកព្រះវរមាតានេះច្រើនណាស់មិញ ក៏ស្ទុះផ្លោះ រត់ទៅទទួល ហើយក្រាបថ្វាយបង្គំ ។ ព្រះនាងមទ្រីក្រាបថ្វាយបង្គំប្រណម្យ ទូលថា បពិត្រព្រះមែអម្ចាស់អើយ ខ្ញុំអម្ចាស់នេះឯង ឈ្មោះនាងមទ្រី ជាកូនប្រសាព្រះអង្គ មកក្រាបថ្វាយបង្គំប្រណម្យនៅក្រោមល្អងធូលីព្រះបាទ ។

ក្សិណនោះ ព្រះនាងសុបារសុប្បតី ទ្រង់ព្រះកន្សែង ពិលាប អាណិតអនាថ មួយអន្លើនឹងព្រះនាងមទ្រីនោះឯងហោង ៗ

វីក្សត្រទាំងបួនព្រះអង្គ បន្ទោបង់នូវទុក្ខសោក គង់បាន បន្តិចទៅកូវ ចៅជាលីនិងនាងក្រស្នាក៏លីលាមកមួយអន្លើនឹង អស់ក្មេងប្រុសស្រីដ៏ចោមរោមជាបរិវារ ៗ ក្សិណនោះ ព្រះនាងមទ្រី ទតទៅយល់ព្រះរាជបុត្រទាំងពីរនោះហើយ ក៏ពុំអាចដើម្បីនឹងទប់ទល់តម្កល់អាត្មាភាពបានឡើយ សឹងស្ទុះផ្លោះទៅទទួលកូន បីដូចសត្វម្រឹគភ្លឹករលឹកកូន មានប្រការនោះម្ដេចមិញ វីព្រះនាងមទ្រី ស្ទុះផ្លោះរត់ទៅទទួលកូននោះ មានឧបមេយ្យដូច្នោះហោង ៗ

តមត្ថំ បកាសេន្តោ សត្ថា អាហ វីអាចិធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ មានព្រះបន្ទូលសូត្រសានូវបាទព្រះគាថា ដូច្នេះ

មទ្ទិញ្ច បុត្តកា ទិស្វា ទូរតោ សោត្ថិមាគតា
ភន្តា អភិធាវិសុ វច្ឆា ពាលាវ មាតរំ ៗ
មទ្ទី ច បុត្តកេ ទិស្វា ទូរតោ សោត្ថិមាគតេ
វារុណីវ បវេធេន្តី ថនធារាភិសិញ្ចថាតិ ៗ

ហៃភិក្ខុអើយ កាលនោះ ព្រះរាជបុត្រទាំងពីរ បានមកអំពីចម្ងាយដោយសិរីសួស្ដី គ្រាន់តែក្រឡេកឃើញសម្ដេចព្រះមទ្រី ជាព្រះវរមាតា ក៏ស្ទុះផ្លោះមកទទួលព្រះមាតា ទ្រង់ព្រះ

កន្សែងថ្លែងពិលាប បីដូចកូនគោស្ទុះផ្លោះទៅទទួលមេវាដូច្នោះ ។ ឯសម្តេចព្រះនាងមទ្រី គ្រាន់តែទតឃើញព្រះរាជបុត្រ ទាំងពីរមកពីចម្តាយ ក៏មានរាងកាយញាប់ញ័ររន្ធត់ បីដូចមេមត់ខ្មោចជាន់ ព្រះនាងទ្រង់ព្រះកន្សែងពិលាបពន់ពេកក្រៃ មួយអន្លើនឹងព្រះរាជបុត្រាបុត្រី ដ៏មានព្រះសរីរៈញាប់ញ័រចំប្រប់ ទ្រង់ដួលសន្លប់ទាំងជំហរនៅលើក្រឡាមហាប្រឹថពី ។ រីព្រះរាជកុមារទាំងពីរ កាលណាបានយល់សម្តេចព្រះវរមាតាដួលសន្លប់ទៅដូច្នោះហើយ ក៏ទ្រង់ព្រះកន្សែង លុះដល់ដួលសន្លប់ទៅលើព្រះវរមាតានុ៎ះឯង ។ ខណៈនោះ រីទឹកព្រះក្សីរ ក៏ហូរចេញពីព្រះស្តនទាំងសងខាង ហូរចូលទៅក្នុងព្រះឱស្ឋនៃព្រះរាជបុត្រាបុត្រី ថាបើគ្មានទឹកព្រះក្សីរហូរចូលព្រះឱស្ឋទេ សមព្រះរាជបុត្រទាំងពីរនឹងក្សិណក្ស័យប្រល័យជីវិតនោះទៀងប្រាកដហោង ។ រីព្រះបាទស្រីវេស្សន្តរ ទតទៅយល់ព្រះរាជបុត្រ និងព្រះរាជទេពី សឹងសន្លប់ដួលទៅដូច្នោះ ក៏ទ្រង់ស្ទុះទៅ ទ្រង់ព្រះកន្សែងថ្លែងពិលាប លុះដល់សន្លប់ដួលទៅ ដូចចៅជាលីនិងមេក្រស្នានោះឯង ។ រីសម្តេចព្រះវរមាតាបិតា កាលណាបើបានយល់សម្តេចព្រះរាជបុត្រទាំងពីរ នូវសម្តេចព្រះចៅទាំងពីរដួលសន្លប់ទៅ ដូច្នោះហើយ ស្តេចក៏ទ្រង់ព្រះកន្សែងថ្លែងពិលាប សឹងដ៏ដួលសន្លប់ទៅនៅព្ឋដ៏ឋាននោះឯង ។ រីអាមាត្យទាំង ៦ ម៉ឺន មួយអន្លើនូវអស់ពលផងទាំងឡាយ កាលណាបើបានយល់ព្រះមហាក្សត្រ

ទាំង ៦ អង្គ សឹងដ៏សន្លប់ទៅហើយ ក៏មិនអាចដើម្បីនឹងទប់ទល់តម្កល់អាត្មាភាពបានឡើយ សឹងដ៏ទ្រហោយំ ដំទ្រូងសន្លប់ ទៅអស់ទាំងប្រឡូងព្រះបរមសាលា មានឧបមាបីដូចខ្យល់យុគន្តវាត បោកបក់ព្រៃសាលវ័ន ឱ្យដួលក្រាបរាបទៅ មានប្រការនោះដូចម្តេចមិញ ៗ រីទំនួញស័ព្ទយោបំ នាំឱ្យអស់អាមាត្យទាំង ៦ ម៉ឺននោះ ដួលសន្លប់ទៅ ក៏មានឧបមេយ្យដូច្នោះហោង ៗ

រីក្រឡាមហាប្រឹថពីសោត សឹងដ៏កក្រើកអំពើក ទាំងភ្នំគិរីវង្គតបព៌ត ៗ រីមហាសមុទ្រទាំងបួនសោត សឹងដ៏ពុះពារជោរជន់រំជិរំជែងរលកបោកបែកជាផ្កាត្រែង ច្រឡើសលើស ក្រៃលែងនឹងមាត់ច្រាំង ៗ រីភ្នំព្រះសុមេរុរាជបព៌ត ដ៏មានកំពូលឱនលំទោនទៅមក បីដូចចុងដំបងទងផ្តៅ គិតដ៏អ្នកបោះទៅក្នុងពពុរភ្លើង ឱ្យខ្លោចលំអោចសំបក ហើយយកមកបញ្ឈរ ដ៏ទន់ល្វន់ល្វាសទៅវិញទៅមកនោះ មានប្រការដូចម្តេចមិញ រីភ្នំព្រះសុមេរុរាជ ក៏មានឧបមេយ្យដូច្នោះឯង ៗ បពិត្រអើយ រីស័ព្ទកោលាហល អំពល់រវល់ជាមួយនឹងក្រឡាមហាប្រឹថពី សឹងកើតមានរៀងរាប ដរាបទៅដល់ឆកាមាវចរសួគ៌ទេវលោកនាយហោង ៗ

អថ សក្កោ ទេវរាជា ច ខត្តិយា សបរិសា វិសញ្ញិនោ ជាតា តេសុ ឯកោបិ ឧដ្ឋាយ កស្សចិ សរីរេ ឧទកំ សិញ្ចិតុំ សមត្ថោ នាម នត្ថិ...

បពិត្រអើយ កាលនោះ សម្តេចព្រះឥន្ទ្រាធិរាជ យល់ក្សត្រទាំង ៦ អង្គ សន្លប់ទៅហើយ ទ្រង់ព្រះចិន្តាពិចារណាថា ខេវ ក្សត្រទាំង ៦ អង្គនេះមិញ សឹងដ៏សន្លប់អស់ហើយហ្ន៎! ថាបើអញយកទឹកកុណ្ឌីទៅស្រោចស្រង់ក្សត្រទាំង ៦ អង្គនោះ ក៏នឹងមានព្រះជន្មរស់ឡើងវិញហើយ សមអស់ពលទាំងនោះ នឹងក្ស័យប្រល័យជីវិតប្រាកដ ៗ ក៏បើដូច្នោះ អញនឹងបង្អុរនូវភ្លៀងបោក្ខរព័ស៏ឱ្យធ្លាក់ចុះមកហើយ អស់ពលផងទាំងនោះ ក៏នឹងមានជីវិតរស់ឡើងវិញ ៗ ព្រះឥន្ទ្រទ្រង់ព្រះចិន្តានូវប្រការអម្បាលនោះហើយ ក្សិណនោះ មហាមេឃឯងក៏ដាលឡើងជោរជក់ភ្លៀងបង្អុរធ្លាក់ចុះមក ថាបើអ្នកឯណា ចង់ទទឹក អើក៏ភ្លៀងនោះទទឹក ថាបើអ្នកឯណាមិនចង់ឱ្យទទឹក អើក៏ភ្លៀងនោះរមៀលជ្រុះចេញ បីដូចទឹករមៀលធ្លាក់ចេញ អំពីស្លឹកឈូក ពុំអាចដិតជាប់នូវសរិលកាយអ្នកនោះឡើយ ៗ

កាលនោះ ព្រះមហាក្សត្រទាំង ៦ ព្រះអង្គ កាលណាបើបានត្រូវភ្លៀងបោក្ខរព័ស៏ ដិតដួចដល់នូវសរិល ដូច្នោះហើយ ក៏មានដង្ហើមចេញចូលធូរជាសុខសប្បាយ ហើយព្រះពោធិសត្វឯង បានដោះឡើងផ្គុំជំនុំនឹងអស់ព្រះញាតិផង នូវអាមាត្យទាំង ៦ ម៉ឺន មួយអន្លើនឹងពលផងទាំងឡាយ ក៏មានជីវិតរស់ឡើង ក្នុងកាលនោះហោង ៗ

តមត្ថំ បកាសេន្តោ សត្ថា អាហ វីអាចិធម៏ឯណា

ពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលសូត្រសានូវបាទព្រះគាថាដូច្នេះ

សមាគតាន ញាតីនំ មហាឃោសោ អជាយថ
បព្វតា សមនាទឹសុ មហី អាកម្បិតា អហុ ។
វុដ្ឋិធារំ បវត្តេន្តោ ទេវោ បាវស្សិ តាវទេ
អថ វេស្សន្តរោ រាជា ញាតីហិ សមគច្ឆថ ។
នត្តារោ សុណិសា បុត្តោ រាជា ទេវី ច ឯកតោ
យទា សមាគតា អាសុំ តទាសិ លោមហំសនំ ។
បញ្ជលិកា តស្ស យាចន្តិ រោទន្តា ភេរវេ វនេ
វេស្សន្តរញ្ច មទ្ទិញ្ច សព្វេ រដ្ឋា សមាគតា
ត្វំ នោសិ ឥស្សរោ រាជា រជ្ជំ ការេថ នោ ឧភោតិ ។

ភិក្ខុអើយ កាលណាព្រះញាតិរាជវង្សានុវង្សទាំងឡាយស្ដេចមកជួបជុំព្រមព្រៀងគ្នាហើយ ក៏កើតមានស័ព្ទគឹកកងរំពងឡើង ជាយ៉ាងក្រៃលែង ភ្នំទាំងឡាយ ក៏បន្លឺសូរស័ព្ទញាប់ញ័រ ទាំងក្រឡាមហាប្រឹថពី ក៏កក្រើកអំពើករពេកក្រៃ ៗ មហាមេឃ ក៏បង្អុរភ្លៀងធ្លាក់ចុះមកគគុក គគាក់ ក្នុងមួយរំពេចនុ៎ះឯង ៗ កាលនោះ ព្រះបាទស្រីសញ្ជ័យ នូវព្រះនាងសុបារសុប្បតីរាជទេវី ព្រះរាជឱរស ព្រះរាជសុណិសា និងព្រះរាជនត្តាទាំងពីរព្រះអង្គ សឹងដ៏មានដង្ហើមចេញចូលធូរស្រួលហើយ ស្ដេចដោះឡើងមកផ្ដុំជំនុំគ្នាឰដ៏ឋានមួយ លុះពួក

ព្រះញាតិមកសមាគមជុំគ្នាហើយ ក៏កើតមានហេតុជាអស្ចារ្យប្រាកដគួរស្ញប់ស្ញែង បណ្តាអស់មុខមន្ត្រីសេនាបតី នូវអស់ពលផងទាំងឡាយ សឹងដ៏លើកកម្ពង់អញ្ជលីដាក់លើសិរសី ក្រាបថ្វាយបង្គំប្រណម្យ អារាធនានិមន្តព្រះបាទស្រីវេស្សន្តរបវររាជឥសី នូវសម្តេចព្រះនាងមទ្រីថា បពិត្រក្សត្រថ្លៃប្រសើរអើយ សូមព្រះអង្គស្តេចលីលាថ្កានព្រះនគរ ហើយស្តេចកាន់យកនូវស្វេតច្ឆ័ត្ររាជសម្បត្តិ ឋិតនៅជាឥស្សរកំពូលនៃយើងខ្ញុំទាំងឡាយនេះហោង ៗ

ឆខត្តិយបព្វំ និដ្ឋិតំ បពិត្រអើយ អាត្មាភាពសម្តែងថ្លែងព្រះធម៌វិសេស្សទេសនា **កណ្ឌ ឆក្សត្រ** នេះមិញ ដ៏ប្រដាប់ប្រដានីទៅនូវគាថា ៣៤ គាថា ក៏ចប់បរិបូណ៌សមគួរ ដោយនូវវេលានេះឯងហោង ៗ

ចប់ កណ្ឌឆក្សត្រ ទី ១២ តែប៉ុណ្ណេះ ៗ

⁂

ចម្លងចប់នៅថ្ងៃ ១៣ រោច ខែជេស្ឋ ព.ស. ២៥៣៣
ត្រូវនឹងថ្ងៃពុធ ទី ២០ ខែមិថុនា គ.ស. ១៩៩០

មហាវេស្សន្តរជាតក

ទី ១៣



កណ្ឌនគរកណ្ឌ

ប្រដាប់ដោយគាថា ៤៨

មហាវេស្សន្តរជាតក

ទី ១៣

នគរកណ្ឌ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

តំ សុត្វា មហាសត្តោ បិតរា សទ្ធឹ សល្លបន្តោ ឥមំ គាថមាហ ។ មហាសត្តោ ព្ធដ៏កាលនោះ ព្រះមហាសត្វ សុត្វា លុះទ្រង់បានព្រះសណ្ដាប់ព្រះរាជឱង្ការសម្ដេចព្រះវរមាតាបិតាអារាធនា ឱ្យស្ដេចលាព្រ័តចេញអំពីឥសីចូលទៅគ្រងបុរីរាជធានីដូចដើម ព្រះអង្គលើកករប្រណម្យសម្ដេចព្រះវររាជមាតាបិតា ក្រាបទូលដោះសា ដោយនូវបាទព្រះគាថា ដូច្នេះ

ធម្មេន រជ្ជំ ការេន្តំ   រដ្ឋា បព្វាជយិត្ថ មំ
ត្វញ្ច ជានបទា ចេវ   នេគមា ច សមាគតាតិ ។

បពិត្រ (១) ព្រះអង្គដ៏ជាក្សត្រធំឧត្តម ប្រសើរអើយ

១- មានច្បាប់មហាជាតក៏ខ្លះ មានទំនងសេចក្ដីដូច្នេះ " ថាបពិត្រសម្ដេចព្រះវរបិតាធិរាជក្សត្រថ្លៃប្រសើរអើយ រីអស់អ្នកស្រុកតូចស្រុកធំ អ្នកនិគមជនបទ នូវអស់មុខមន្ត្រីសេនាបតីតូច-ធំមកជំនុំគ្នាព្រមនឹងព្រះអង្គ ហើយបំបរបង់ខ្ញុំ ឱ្យចេញលែងសោយរាជសម្បត្តិស្វេតច្ឆត្រ ខ្ចាត់មកនៅនាព្រៃសំសានឋានស្ងាត់ ជាអ្នកត្រមោច ថាបើខ្ញុំប្រវាយកនូវស្វេតច្ឆត្ររាជសម្បត្តិឋិតនៅជាស្ដេចឡើងវិញហើយ ហៅថាមិនប្រកបដោយគន្លងធម៌អំពីបុរាណនោះឡើយ " ។

ដើមឡើយ ព្រះអង្គទ្រង់ព្រះមេត្តាប្រោសប្រាណ ព្រះរាជទានឱ្យគ្រងស្វេតច្ឆ័ត្ររដ្ឋរាជបុរី ឱ្យស្រដីទូន្មានអស់អាណាប្រជារាស្ត្រកូវ ពុំឱ្យធ្វើក្រៅព្រះរាជក្រឹត្យ ខុសនឹងព្រះរាជអាជ្ញា ហើយព្រះអង្គថា អស់អាណាប្រជារាស្ត្រទាំងឡាយ សឹងតែក្តៅក្រហាយខឹងនឹងអញខ្ញុំណាស់ ថាត្បិតអញខ្ញុំឱ្យដំរីមង្គលទៅជាទានឧត្តម ជាបរមទាន ទើបគេនាំគ្នាបំបរបង់ ឱ្យព្រាត់ប្រាសនិរាសចាកចោលរាជសម្បត្តិខ្វាត់ចេញមក អញខ្ញុំខំដើរជ្រុលជ្រកមកនៅនាព្រៃអាយ ជាព្រៃស្មសានឋានស្ងាត់ហើយ បពិត្រអម្ចាស់អើយ ឥឡូវនេះ ព្រះអង្គទ្រង់ព្រះចិន្តាដូចម្តេច ក៏បានជាស្តេចមកអារាធនាអញខ្ញុំ ដែលព្រះអង្គថាជាអ្នកខុស ពុំត្រូវ ឱ្យទៅសោយរាជសម្បត្តិ ដូចអំពីដើមវិញខ្ញុំអម្ចាស់ ពុំពេញចិត្តឡើយ ៗ

អណ្តាប់នោះ ព្រះបាទក្រុងស្រីសញ្ជ័យ បានទ្រង់ស្តាប់សេចក្តីនៃព្រះរាជបុត្រា ព្រះមហាវេស្សន្តរបវរខត្តិយាមហាឫសីព្រះអង្គតបសេចក្តីស្នងព្រះរាជឱង្ការដូច្នោះហើយ ពុំលង់ឡើយព្រះអង្គរិះរកបរិហារបណ្តាល ដើម្បីនឹងឱ្យព្រះរាជបុត្រទន់ព្រះទ័យ ទើបមានព្រះបន្ទូលសូត្រនូវបាទព្រះគាថា ដូច្នេះ

ទុក្ខជញ្ញ ហិ នោ បុត្ត ភូនហច្ចំ កតំ មយា
យោហំ សិវីនំ វចនា បព្វាជេសឹ អទូសកន្តិ ៗ

បុត្ត ថាហៃកូនស្ងួនតែមួយ ជាត្រួយត្រួលបណ្តូលពន្លក

ហឫទ័យ បីដូចនយនាមាសឪពុកអើយ ហេតុត្បិតបិតានេះ ធ្វើឱ្យអ្នកមានសេចក្ដីអំពល់ទល់ទុក្ខ ពុំសុខសប្បាយ ចេញមកនៅព្រៃអាយនេះ ព្រោះតែជឿយកពាក្យអ្នកស្រីពិរាស្ត្រវាញុះញង់ ឱ្យបំបរបង់កូនស្ងួនចេញមកនៅភ្នំគិរីវង្កត កម្សត់តែ ៤ អង្គ តវត ហៃកូនស្ងួនសម្លាញ់ឪពុកអើយ ទោសទាំងនេះ គួរខុសណាស់ហើយ តាមតែអ្នកអត់ទោសប្រោសបិតា នាកាលគ្រាឥឡូវនេះហោង ។

ព្រះបាទស្រីសញ្ជ័យ មានព្រះរាជឱង្ការតែម្ល៉ោះហើយ ព្រះអង្គក៏លើករាជសម្បត្តិថ្វាយព្រះរាជឱរស ហើយមានព្រះបន្ទូលថា

យេន កេនចិ វណ្ណេន   បិតុ ទុក្ខំ ឧទព្វហេ
មាតុយា ភគិនិយាបិ   អបិ បាណេហិ អត្តនោ ។
តស្មា ទោសំ អភត្វាន   វចនំ ត្វំ ករោហិ មេ
ឥសិលិង្គំ នីហរិត្វា   រាជវេសំ អគណ្ហាសីតិ(១)។

ម្នាលកូនស្ងួនសម្លាញ់ពេញចិត្តស្មើជីវិតនៃព្រះបិតា បើបុគ្គលឯណាកើតមកជាបុរសរ័ត្ន ឥតសង្ស័យនៅនាលោកិយ មានសេចក្ដីឧស្សាហ៍ ពុំគិតជីវិត កាត់ចិត្តចេញមកជម្រះទុក្ខសោក

១- តាមរូបបាលីមានសេចក្ដីប្រែដូច្នេះ " ធម្មតាកូនប្រុសដែលមានចិត្តកតញ្ញាកតវេទី គួរគប្បីលះបង់ជីវិតខ្លួន ជួយដោះទុក្ខសោករបស់មាតាបិតានិងបងប្អូនស្រី ដែលកើតឡើងដោយហេតុណានីមួយក៏ដោយ ហេតុនេះ ចូរបាកុំប្រកាន់ទោសបិតា ចូរបាធ្វើតាមពាក្យរបស់ព្រះបិតា លាចេញពីភេទឥសី កាន់យកភេទជាក្សត្រវិញ " ។

រោគភ័យក្តីមន្ទិលក្នុងប្រាណ ៗ តស្នូវ ហេតុនោះ បាកុំបីមានចិត្តខឹងជាគំនុំចងទោសានុទោសផងទាំងឡាយ ចូរធ្វើតាមពាក្យបិតា លាចេញអំពីភេទព្រះតាបស ចូរកូនប្រុសអ្នកទ្រង់គ្រងរាជសម្បត្តិរាជដ្ឋាន តាមបុរាណប្រពៃណីអំពីដើមរៀងមក ឱ្យក្សេមក្សាន្ត នឹងបានជាទីពំនាក់ព្រាហ្មណ៍ ព្រឹទ្ធបណ្ឌិតកវី មុខមន្ត្រីអាមាត្យ នូវអស់រេហ៍ពលសកលយោធាផងស្នងបិតា នៅកាលគ្រានេះឯង ៗ

សម្តេចព្រះមហាវេស្សន្តរបវរពុទ្ធង្កុរបណ្តូលពុទ្ធវង្ស កាលព្រះអង្គនឹងទទួលយករាជសម្បត្តិ តែចាំក្រាបទូលស្នងព្រះរាជឱង្ការសម្តេចព្រះវររាជបិតា ឱ្យបានអស់មន្ទិលពិភាល់សង្ស័យ ៗ ឯព្រះបាទស្រីសញ្ជ័យ ក៏រមែងជាអង្វរលួងលោម ពុំឱ្យអាក់អន់ ទើបសម្តេចព្រះរាជបុត្រ ទទួលអញ្ជើញ តាមព្រះរាជឱង្ការត្រាស់ថា សាធុ ! សាធុ ! ៗ

កាលនោះ ឯអស់អាមាត្យទាំង ៦ មុឺន ដែលកើតរួមថ្ងៃមួយនឹងព្រះអង្គ លុះបានឮសេចក្តីថា ព្រះអង្គទទួលអញ្ជើញដូច្នោះហើយ សហជាតអាមាត្យទាំងនោះ លើកករប្រណម្យថ្វាយបង្គំព្រះបរមរាជា ក្រាបទូលថា **មហារាជ** បពិត្រព្រះអង្គ ដ៏ទ្រង់នូវគុណាតិរេកជាឯកលើត្បូងយើងខ្ញុំអម្ចាស់អើយ អញ្ជើញព្រះអង្គទៅស្រោចស្រង់នូវទឹកអប់ ត្រឡប់នូវគន្ធពិដោរ បន្តោបង់នូវញើសក្អែលក្តៅក្រហាយ ឱ្យសប្បាយព្រះអង្គស្រេចហើយ

អញ្ជើញស្តេចទទួលយកស្វេតច្ឆ័ត្ររាជសម្បត្តិ ឋិតនៅជាអម្ចាស់នៃយើងខ្ញុំហោង ។

រីព្រះបរមពោធិសត្វខត្តិយវង្សទ្រង់នូវកតិកាព្រះអង្គទ្រង់ត្រាស់ថា ហៃអាមាត្យទាំងឡាយអើយ ចូរឈប់បន្តិចសិន ទើបស្តេចចូលទៅក្នុងព្រះបរមសាលា ផ្លាស់អស់គ្រឿងព្រះអម្ពរឥសីចេញអំពីព្រះអង្គ ហើយស្តេចទ្រង់ព្រះពស្ត្រព្រះភូសាបរិសុទ្ធ ប្រដូចនូវពណ៌សង្ខ រួចស្តេចចេញមកគង់នាមុខព្រះអាស្រម ហើយស្តេចធ្វើប្រទក្សិណព្រះបរមសាលា ៣ ជុំ ទើបមានព្រះបន្ទូលថា ឱះឱ! ព្រះបរមសាលានេះអើយ ជាទីពឹងអាស្រ័យនៃយើង ប្រមាណបាន ៩ ខែ និង ១៥ រាត្រី ទើបបានសាងបរមត្ថបារមីសមណធម៌ បានឱ្យសម្តេចព្រះមទ្រី នូវព្រះរាជបុត្រាបុត្រី ទៅជាទាន លុះករក្រើកទៅដល់ភវគ្គព្រហ្ម នូវអស់ទេវតាសព្វឋាន ព្រោះត្បិតយើងបានអាស្រ័យបរមសាលានេះឯង ជាលំនៅ អំពីនេះទៅហើយ សមព្រះបរមសាលានេះនឹងនៅទំនេរ ឥតអ្នកឯណាមួយនៅឡើយ ។ ឱ! ម្ល៉េះហើយ សត្វទាំងឡាយ នឹងមកយាយីរឹងព្រះកុដីក៏នឹងស្ងាត់ជ្រងំ ពុំមានអ្នកពិភ័ក្តិរក្សា ម្ល៉េះហើយ សមនឹងបាក់ទ្រុឌទ្រោមទៅជាអសារឥតការ ទើបព្រះអង្គលើកព្រះករបវរដាក់លើព្រះកេសវិសេសបង្គំដោយបញ្ចាង្គប្រតិស្ឋាននៅខាងមុខព្រះបរមសាលា ហើយព្រះអង្គឋិតនៅនាឋាននេះឯង ។

បពិត្រអើយ ព្ធដ៏កាលនោះ មានខ្មាន់ព្រះកេស ចូលទៅ

ក្រាបថ្វាយបង្គំ ហើយចម្រើនព្រះកេសាជម្រះព្រះលោមា នៃព្រះបរមពោធិសត្វនោះ ៗ លុះស្រេចហើយ ក៏អភិសេកស្រោចស្រង់ទ្រង់នូវគ្រឿងប្រដាប់សម្រាប់ក្សត្រា ល្អរុងរឿង បីដូចជាព្រះឥន្ទ្រាធិរាជសោយរាជសម្បត្តិឋិតនៅនាឋានទេវលោកនាយ ៗ

តេន វុត្តំ ហេតុនោះ ទើបលោកនាំយកបាលីក្នុងគម្ពីរចរិយាបិដក មកសម្ដែងថា

តតោ វេស្សន្តរោ រាជា រជោជល្លំ បវាហយិ
សព្វំ វត្តំ ចជេត្វាន រាជវេសមធារយិ ៗ

ភោ សារីបុត្ត ហៃធម្មសេនាបតីស្រីសារីបុត្ត កាលនោះ ព្រះបាទវេស្សន្តរបវរពោធិសត្វខត្តិយាធិបតី ស្រីសុរិយោវង្ស អង្គនារាយណ៍នរបតី ស្រីសម្មតិទេព មហារាជក្សត្រថ្លៃប្រសើរនោះ លុះព្រះអង្គជម្រះព្រះកេសាស្រេច ស្ដេចទ្រង់នូវទឹកអប់ ត្រឡប់នីទៅនូវក្រចេះចួងចន្ទន៍ លំពាន់ក្រស្នា គូរាជេន ឈ្មុសទេសវិសេសសឹងដ៏ល្វែង អប់ត្រឡប់នីទៅនូវគន្ធពិដោរ ស្ដេចប្រាសលះលែងនូវគ្រឿងប្រដាប់សម្រាប់ជាអ្នកបួសនោះហើយ ទ្រង់ក៏កាន់យកនូវស្វេតច្ឆ័ត្រ ជាស្ដេចប្រកបនូវយសបរិវារ ជាអធិកពន្លឹកមហិមាក្រៃពេកហោង ៗ

បពិត្រអើយ ព្ធដ៏កាលនោះ រីឯព្រះតេជះព្រះយសខ្ពស់វែងឆ្ងាយ ល្បីឮខ្ចរខ្ចាយសាយសព្វព្រះនគរ បើព្រះអង្គ នឹងទតព្រះនេត្រទៅកាន់ទិសឯណានីមួយក្ដី ក៏សឹងកក្រើកអំពើកញាប់ញ័រ

ដល់ឋាននោះ ព្រោះព្រះអង្គទ្រង់បានបំពេញទានបរមត្ថបារមី ដ៏ក្សេមក្សាន្តក្នុងព្រះហឫទ័យ ។ អស់ទាំងព្រាហ្មណ៍ ព្រឹទ្ធ បណ្ឌិត ហោរា បុរោហិត ព្រមទាំងមុខមន្ត្រីសេនាបតី សេដ្ឋី នាំគ្នាមកជួបជុំសូត្រស្តុតី ថ្វាយវុឌ្ឍិមង្គលពលីការ នមស្ការចម្រើនព្រះពរជ័យ ថ្វាយព្រះបរមពោធិសត្វស្រេចហើយ ប្រគំនូវស័ព្ទសូរតូរ្យតន្ត្រី ដ៏មានស័ព្ទសូរពន្លឹក គគ្រឹកគគ្រេង មានឧបមាបីដូចរលកនៅកណ្តាលមហាសមុទ្រ ។ អណ្តាប់នោះ នាយដំរី ក៏ប្រដាប់គជសារ ដ៏ក្រាលនីទៅនូវកម្រាលដ៏វិចិត្រ ចងនូវដង្គន់ស្នាប់មុខ ចង្កុំភ្លុកកូបហាង លំញ៉ាងដងក្រពាត់ សឹងដ៏ប្រដាប់ដំាត្បូងនីលរ័ត្ន មានរស្មីព្រោងព្រាយ នាំចូលទៅថ្វាយព្រះអង្គ ទើបស្តេចទ្រង់នូវព្រះខ័នថ្លា ហើយស្តេចឡើងគង់លើហត្ថីរ័ត្ន ដ៏ធំធាត់មាឧមាំក្លាហាន ។ ឯអស់សេនាជំនិតព្រះអង្គទាំង ៦ ម៉ឺននោះ ក៏មកចោមរោមជាយសបរិវារជុំវិញព្រះអង្គ ស្តេចលីលាទៅគង់ឯព្រះពន្លាជ័យ ព្ធដ៏កាលនោះ ។

បពិត្រអើយ ព្ធដ៏កាលនោះ រីអស់ស្រីរ័ត្នកញ្ញាផង ទាំងឡាយ ក៏នាំគ្នាតាក់តែងព្រះសរិលកាយសម្តេចព្រះនាងមទ្រី ជាអគ្គមហេសីស្រីខត្តិយវង្ស ស្រោចស្រង់ទ្រង់នូវគ្រឿងប្រដាប់សម្រាប់ក្សត្រី អភិសេកជាឯកអគ្គមហេសី ទើបនាំគ្នាសូត្រស្តុតី ចម្រើនព្រះពរជ័យមង្គល ថា សូមព្រះបាទស្រីវេស្សន្តរពិភ័ក្តិរក្សាព្រះម៉ែនាងម្ចាស់ ឱ្យបានសេចក្តីសុខក្សេមក្សាន្ត ក្នុងព្រះ

រាជហឫទ័យ ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលសូត្រសានូវបាទព្រះគាថា ដូច្នេះ

សីសន្ហាតោ សុចិវត្ថោ　　សព្វាលង្ការភូសិតោ
បច្ចយំ នាគមារុយ្ហ　　ខគ្គំ ពន្ធិ បរន្តបំ ។
តតោ សដ្ឋីសហស្សានិ　　យោធិនោ ចារុទស្សនា
សហជាតា បរិកិរិសុ　　នន្ទយន្តា រថេសភំ ។
តតោ មទ្ទីបិ ន្ហាបេសុំ　　សិវិកញ្ញា សមាគតា
វេស្សន្តរោ តំ បាលេតុ　　ជាលី កណ្ហាជិនា ចុភោ
អថោបិ តំ មហារាជា　　សញ្ជយោ អភិរក្ខតូតិ ។

ភិក្ខវេ ហៃភិក្ខុសង្ឃផងទាំងឡាយអើយ វេស្សន្តរោ រាជា រីឯព្រះបាទសម្ដេចព្រះវេស្សន្តរបវរខត្តិយសូរ្យវង្ស លុះស្រង់ព្រះសុគន្ធរសស្រេច ស្ដេចទ្រង់ប្រដាប់ព្រះអង្គ ទ្រង់នូវស្នាប់ព្រះឧរូ ជើងជរ សឹងដ៏ប៉ាក់ឆ្លាក់ល្អស្រេចស្រស់ ទើបស្ដេចទ្រង់នូវព្រះពស្ត្រព្រះភូសាសម្រាប់ក្សត្រ ក្រវាត់នូវជើងបាទ ហើយស្ដេចទ្រង់មកុដអារាមរន្ទាម ព្រះសុវងកងក កុណ្ឌល សឹងដ៏ល្អវិចិត្រ ទើបទ្រង់ព្រះទម្រង់ត្បូងនីលរ័ត្នវិចិត្រ នូវពៃទូរ្យសូរ្យកាន្ត ដ៏មានតម្លៃនគរមួយ សម្រាប់រាជាភិសេកជាឯកអគ្គមហាក្សត្រ ទ្រង់នូវគ្រឿងរ័ត្នបញ្ចកកុធភណ្ឌទាំង៥ ស្រេច ស្ដេចគង់លើ

ទែនមណីរ័ត្ន បាំងនូវស្វេតច្ឆ័ត្រក្លស់ក្លំអភិរម បន្សំនូវអស់គ្រឿងខ្ពស់ ទើបអស់អាមាត្យសេនា ចៅពញា ព្រះហ្លួង ឃុន ហ្មឺនទាំងពួង នូវអាមាត្យដែលកើតថ្ងៃជាមួយនឹងព្រះអង្គទាំង ៦ ម៉ឺន គាល់ព្រះមហាក្សត្រ ដោយនូវជួរសង្កាត់ទីទៃ ៗ ៗ   ឯអង្គព្រះអគ្គមហេសី គឺសម្ដេចព្រះមទ្រី ក៏ទ្រង់នូវគ្រឿងប្រដាប់ប្រដាផ្ទិមអម្ពរសឹងដ៏ល្អឧត្ដម   ឯអស់ព្រះស្នំ ក៏សឹងដ៏ស្លៀកដណ្ដប់តាមដោយនូវប្រដាប់ទីទៃ ៗ នូវអស់ស្រីអករ័យាយ ចាស់ទុំ សឹងរណ្ដាប់ដោយនូវកំណាន់ជាពាន់ជាម៉ឺន មាននូវរូបល្អប្រសើរ ហែសម្ដេចព្រះនាងមទ្រីមកអភិសេកជាឯកអគ្គមហេសី ៗ ទើបអស់ព្រាហ្មណាចារ្យ មកស្រោចស្រង់ព្រះអង្គទាំងពីរ ដោយទឹកស័ង្ខ ទឹកទង់ដែង អស់ទាំងភ្លេងតូរ្យតន្ត្រីពិណពាទ្យរងំ សមនូវសំឡេងស្គរ គងអស់អាមាត្យមន្ត្រីផង សឹងដ៏លើកករប្រណម្យ ក្រាបថ្វាយបង្គំថ្វាយព្រះពរ ស្រដីដោយនូវបទព្រះបាលីថាដូច្នេះ ទេស្សន្តរេវរជាវ   ថា   សូមឱ្យព្រះបាទស្រីវេស្សន្តរ បវរមហាក្សត្រធាលេតុ   ចូរព្រះអង្គរក្សាសម្ដេចព្រះនាងមទ្រី ដ៏ជាព្រះអគ្គមហេសី   ឱ្យត្រេកអរសាទរស្មោះសរអភិរម   កុំបីមានទុក្ខសោករោគា ឯព្រះជាលីក្រស្នា ក៏សូមឱ្យក្សេមក្សាន្តឱ្យបានថែរក្សាព្រះវរមាតាបិតា   ឰដ៏អនាគតកាល ទៅឯភ្នែកនោះហោង ៗ

តមត្ថំ បកាសេន្តោ សត្ថា អាហ ①រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលសូត្រនូវបាទព្រះគាថាដូច្នេះ

ផឧញ្ញ បច្ចយំ លទ្ធា បុព្វេ កិលេសមត្តនោ
អានន្ទិយំ បរិចរីសុ រម្មណីយេ គិរិព្វជេ ។
ផឧញ្ញ បច្ចយំ លទ្ធា បុព្វេ កិលេសមត្តនោ
អានន្ទចិត្តា សុមនា បុត្តេ សង្គម្ម លក្ខណា ។
ផឧញ្ញ បច្ចយំ លទ្ធា បុព្វេ កិលេសមត្តនោ
អានន្ទចិត្តា បីតិតា សហ បុត្តេហិ លក្ខណាតិ ។

ហៃភិក្ខុអើយ កាលនោះ ព្រះបាទស្រីវេស្សន្តរ នូវព្រះនាងមទ្រី កាលណាបើបានជួបប្រសព្វនឹងព្រះរាជបុត្រទាំងពីរ មួយអន្លើនឹងអស់រេហ៍ពលផងទាំងឡាយ ជាបច្ច័យហើយ មានព្រះរាជហឫទ័យត្រេកអរសោមនស្សា ទ្រង់ភ្លឹករលឹកទៅដល់សេចក្តីលំបាកវេទនាអំពីមុន កាលស្តេចនៅក្នុងព្រៃព្រឹក្សានោះ ទើបស្តេចមានព្រះរាជឱង្ការឱ្យនាំយកស្គរអានន្ទភេរីទៅទូងទូទាំងសព្វច្រកព្រៃភ្នំក្រំថ្ម ផ្សាយពត៌មានឱ្យមហាជនបានដឹងថា ទ្រង់

---

①- បទ " តមត្ថំ ៗល។ " នេះ ក្នុងច្បាប់មហាជាតក៏ខ្លះ មិនមានទេ, សូម្បីក្នុងបាលីអដ្ឋកថាវេស្សន្តរជាតកខ្លះក៏មិនមានប្រាកដដែរ តែក្នុងទីនេះ បានចម្លងចេញពីគ[illegible] សម្រាយដែលមានបទ " តមត្ថំ ៗល។ " ហើយមានដំណើរសេចក្តីសម[illegible] គ្នានតាមលំនាំសេចក្តីហូរហៃជាលំដាប់តទៅ ៗ

ប្រោសព្រះមេត្តាឱ្យអ្នករាល់គ្នាលេងល្បែងមហោស្រព សព្វតំបន់ជាទីក្សេមក្សាន្តសប្បាយតាមប្រាថ្នា ។ ឯសម្ដេចព្រះនាងមទ្រី ដ៏ទ្រទ្រង់នូវព្រះលក្ខណាល្អពិសី កាលព្រះនាងបានជួបជុំព្រះរាជបុត្រាបុត្រីទាំងពីរហើយ ក៏មានព្រះទ័យត្រេកអរ សោមនស្សា ទើបព្រះនាងមានព្រះសវនីយ៍ទៅនឹងព្រះរាជបុត្រទាំងពីរ ដោយនូវបាទព្រះគាថា ថាដូច្នេះ

ឯកភត្តា បុរេ អាសី　　និច្ចំ ថណ្ឌិលសាយនី
ឥតិ មេ តំ វតំ អាសិ　　តុម្ហំ កាមា ហិ បុត្តកា
តំមេវតំ សមិទ្ធជ្ជ　　តុម្ហេ សង្គម្ម បុត្តកា
មាតុជំបិ តំ បាលេតុ　　បិតុជំបិ ច បុត្តកា
អថោបិ តំ មហារាជា　　សព្វាយោ អភិរក្ខតុ ។
យំ កិញ្ចិត្ថិ កតំ បុញ្ញំ　　មយ្ហញ្ចេវ បិតុច្ច តេ
សច្ចេន តេន កុសលេន　　អជរោ ត្វំ អមរោ ភវាតិ ។

បុត្តកា ① ថា ហៃនាងក្រស្នាបាជាលី កូនស្ងួនសំឡាញ់

១- មានច្បាប់ខ្លះថា " ថាហៃកូនសំឡាញ់ទាំងពីរម្ដាយអើយ កាលព្រាហ្មណ៍នាំបាទាំងពីរទៅ ម្ដាយនៅអាយ ម្ដាយបរិភោគតែម្ដងមួយពេល ធ្វើអស់អញ្ចលំគេញអាត្មា ហើយម្ដាយកាច់ស្លឹកឈើមកសសាប់ទ្រាប់ដេក ដោយនូវក្រឡាមហាប្រឹថពី សាងវត្តចរិយាប្រាថ្នាឱ្យបានយល់បាទាំងពីរ ក៏ឥឡូវនេះ វត្តប្រណិប័តន៍នោះបានសំរឹទ្ធិបរិបូណ៌ដូចក្ដីប្រាថ្នា ឱ្យបានយល់បាទាំងពីរ ហើយចំណេរអំពីនេះទៅ ក៏ចូរបាពិភ័ក្តិរក្សាយើងទាំងពីរ មួយអន្លើនឹងព្រះបាទស្រីសញ្ជ័យ ដ៏ជាព្រះជីតាបានោះឯងហោង " ។

ម្ដាយទាំងពីរអើយ កូនអើយ នាកាលម្ដាយព្រាត់ព្រាកចាកចេញអំពីស្រុក ម្ដាយដើរជ្រុលជ្រកមកនៅព្រៃ ក៏ប្រស្រ័យតែឃើញមុខកូនស្ងួនសំឡាញ់ទាំងពីរ រីទុក្ខទាំងឡាយនោះមិញក៏អន្តរធានបាត់ទៅ កូនអើយ ម្ដាយតាំងចិត្តស្វែងរកផលា ដ៏ជាអាហារទាំងឡាយ ឯភា ៥ ម្ដាយដើរតែម្នាក់ឯង ពុំក្រែងជីវិត គិតប្រាថ្នាតែយកមកចិញ្ចឹមកូនគូកម្សត់ ក្រែងអត់ឃ្លានម្ដាយថ្នមពុំឱ្យមានហ្មង ប៉ឹងបានជាគូកម្សត់នៅក្នុងព្រៃ ៗ ឱ! ហេតុតែកម្មវិបាកអ្វីអើយ ក៏ឱ្យព្រាត់ព្រាកចាកកូនសង្សារ អំពីកាលព្រះបិតាអ្នកឱ្យទៅជាទាន ជូជកព្រាហ្មណ៍ព្រឹទ្ធាចារ្យ ទទួលយកបាទៅ ម្ដាយនេះតែងនៅជាទុក្ខខ្លោចផ្សា ពុំមានស្រាកស្រាន្ត រីអស់ផលាហារ ក៏ពុំបានបរិភោគ្ដា តែងតែសោកាទួញយំឥតស្បើយ លុះវេលាល្ងាចហើយ ម្ដាយគិតដល់អ្នកទាំងពីរដល់ម្ដាយពុំយល់មុខ ទុក្ខក៏កើតឡើងជាថ្មី ម្ដាយដេកនៅដីផ្ទាល់ប្រឹថពី រីឯក្ដីស្រឡាញ់នៃជននី នូវព្រះវរបិតានោះ ពន់ប្រមាណ ត្បិតបានពិភ័ក្ដិរក្សាកូនសំឡាញ់ រីសម្ដេចព្រះអយ្យកោព្រះអយ្យិកានោះមិញ ក៏មានព្រះរាជហឫទ័យសោមនស្សា នឹងព្រះរាជនត្ដោនត្ដា ពុំឱ្យហ្មង ៗ ប្រការមួយសោត រីកុសលផលបុណ្យនៃព្រះវររាជមាតាបិតានូវអស់អ្នកទាំងពីរ បានធ្វើប៉ុន្មាន ៗក្ដី សូមឱ្យជួយពិភ័ក្ដិរក្សាបា កុំបីមានព្យាធិរោគាជរាមកបៀតបៀនបាបានឡើយ ហើយឱ្យបាបានស្នងគ្រងព្រះនគរ តាង

ព្រះវរបិតានោះតទៅ (១) ។

បពិត្រអើយ ព្ឋដ៏កាលនោះ ព្រះនាងសុបារសុប្បតីទេវីទ្រង់មានព្រះតម្រិះក្នុងព្រះចិន្តាថា តាំងអំពីថ្ងៃនេះតទៅ ព្រះនាងមទ្រីដ៏ជាព្រះសុណិសាកូនប្រសារអញ ទ្រង់ព្រះភូសា និងប្រដាប់ តាក់តែងអាត្មា ដោយគ្រឿងអលង្ការដ៏ត្រកាលទាំងពួងនេះ លុះព្រះនាងទ្រង់ព្រះចិន្តាដូច្នេះហើយ ក៏ឱ្យចាត់ចែងវណ្ដាប់គ្រឿងអលង្ការទុកក្នុងស្អុគរួចហើយនែ ទើបចាត់បញ្ជូនទៅព្រះរាជទានព្រះនាងមទ្រី ប្រយោជន៍ដើម្បីនឹងឱ្យទ្រង់ជាប្រដាប់សំរាប់អាត្មាព្រះអង្គនាង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលសូត្រសានូវបាទព្រះគាថា

១- មានច្បាប់ខ្លះមានសេចក្តីលើសកើនពីនោះទៅទៀតថា " ម្លោះហើយ ព្រះពោធិសត្វនិងព្រះនាងមទ្រី ចូលទៅគាល់សម្តេចព្រះវររាជមាតាបិតា ក្រាបទូល ថា បពិត្រព្រះសម្មតិទេពមហារាជក្សត្រថ្លៃប្រសើរអើយ សូមព្រះអង្គគិតខ្មីឃ្មាតសង្វាតធ្វើបុណ្យកុសល ចំណេរអំពីនេះទៅ កុំបីភ្លេចស្មារតីឡើយ នាយើងខ្ញុំទាំងពីរនេះ បានធ្វើអំពើកុសលផលបុណ្យនោះច្រើនហើយ ថប់តែព្រះអង្គក្រែងនឹងលិចលង់ផុង ទៅព្ឋដ៏ភ័យចតុរាបាយនរកនាយហោង "។ សេចក្តីប៉ុណ្ណោះនេះ មិនមានប្រាកដ ក្នុងបាលីវេស្សន្តរជាតកទេ ហើយក្នុងច្បាប់សម្រាយខ្លះទៀត ក៏មិនមានដែរ ក្នុងទីនេះ មិនចម្លងយកមកដាក់ក្នុងរឿង គ្រាន់តែធ្វើនយលក្ខណៈ ជាគ្រឿងសម្គាល់ទុក ។

ទាំងឡាយដូច្នេះ ៗ

កប្បាសិកញ្ច(១) កោសេយ្យំ(២)   ខោមកោដុម្ពរានិ ច(៣)
សស្សុ សុណ្ហាយ បាហេសិ   យេហិ មទ្ទី អសោភថ ៗ
តតោ ខោមញ្ច(៤) កាយូរំ   អង្គទំ(៥) មណិមេខលំ(៦)
សស្សុ សុណ្ហាយ បាហេសិ   យេហិ មទ្ទី អសោភថ ៗ
តតោ ខោមញ្ច(៧) កាយូរំ   គីវេយ្យំ(៨) រតនាមយំ
សស្សុ សុណ្ហាយ បាហេសិ   យេហិ មទ្ទី អសោភថ ៗ
ឧណ្ណតំ(៩) មុខផុល្លញ្ច(១០)   នានារត្តេ ច មាណិយេ(១១)
សស្សុ សុណ្ហាយ បាហេសិ   យេហិ មទ្ទី អសោភថ ៗ
ឧគ្គត្ថនំ(១២) គិង្គមកំ(១៣)   មេខលំ(១៤) បដិបាទុកំ(១៥)
សស្សុ សុណ្ហាយ បាហេសិ   យេហិ មទ្ទី អសោភថ ៗ
សុត្តញ្ច សុត្តវជ្ជញ្ច(១៦)   ឧបនិជ្ឈាយ សេយ្យសិ(១៧)
អសោភថ រាជបុត្តី   ទេវកញ្ញាវ(១៨) នន្ទនេ ៗ
សីសន្ហាតា សុចិវត្ថា   សព្វាភរណភូសិតា
អសោភថ រាជបុត្តី   តាវត្តីសាវ អច្ឆរា ៗ
កទលី វាតច្ឆុបិតា(១៩)   ជាតា ចិត្តលតាវនេ
ទន្តាវរណសម្បន្នា(២០)   រាជបុត្តី អសោភថ ៗ
សកុណី មានុសិនីវ(២១)   ជាតា ចិត្តប្បត្តា បតិ
និគ្រោធបក្កពិម្ពោដ្ឋី   រាជបុត្តី អសោភថាតិ ៗ

តាំងពី១ដល់២១ ចូរមើលនយលក្ខណៈនិងសេចក្តីអធិប្បាយខាងក្រោយនគរកណ្ឌនេះ ៗ

ភិក្ខវេ ហៃភិក្ខុសង្ឃដ៏ទ្រង់ព្រ័តដោយនូវគន្លងធម៌ ឥតោ អណ្តាប់នោះ ព្រះនាងសុបារសុប្បតី ទ្រង់គិតក្នុងព្រះរាជហឫទ័យ ថា សម្តេចព្រះនាងមទ្រីដ៏ជាព្រះរាជបុត្រីស្រីសុណិសា លាព្រ័ត ចេញអំពីតាបសឫសី ហើយ ក៏ព្រះនាងនឹងទ្រង់គ្រឿងប្រដាប សំរាប់ព្រះអគ្គមហេសី ទើបសម្តេចព្រះនាងសុបារសុប្បតីយកគ្រឿង ទាំងឡាយឱ្យសម្តេចព្រះសុណិសា គឺព្រះពស្ត្រកាសិកពស្ត្រ នូវព្រះ ពស្ត្រកោទុម្ពរពស្ត្រ កោសេយ្យពស្ត្រ ខោមពស្ត្រដ៏ល្អបរិសុទ្ធគិត ដ៏អ្នកប៉ាក់ឆ្លាក់នីទៅនូវល្អសមាសជាជរ សឹងដ៏ល្អស្រស់ស្រេច សម្តេចព្រះនាងសុបារសុប្បតី រើសផ្គង់បម្រុងព្រះរាជទាន ៗ ប្រការមួយសោត សម្តេចព្រះនាងមទ្រី ដែលបានលាព្រ័តចេញ អំពីតាបសឫសី ជាអគ្គមហេសីឧត្តម សមជានឹងទ្រង់អស់គ្រឿង ប្រដាប់សម្រាប់ ឱ្យគួរជាអគ្គមហេសី ទើបសម្តេចព្រះនាងសុបារ សុប្បតី ព្រះរាជទានជាដើម គឺ មកុដអារាមរន្ទាម ព្រះសុរងកង ព្រះហ៊ូរ័ក ត្រសាល់ស្មៀតសក់ ស្តាប់ទ្រាប់ព្រះជង្ឃ ចិញ្ចៀនព្រះ ទម្រង់ សឹងដ៏ដាំនូវត្បូងបុស្សរ បទុមរាគរ័ត្ន មុក្តារ័ត្នប្រពាលរ័ត្ន សឹងដ៏មានរស្មីនោះច្រវាត់ស្មើរនឹងស្រក់ ព្រះសុពណ៌បាទុក៍ សឹងដ៏មានរចនា ទាំងសុគន្ធមាលាក្រចេះចួងចន្ទន៍ លំពាន់ពុំសែន គូរាជេន ឈ្មុសទេស សឹងដ៏ជាគ្រឿងវិសេស សម្រាប់ទ្រង់ ៗ សម្តេចព្រះនាងសុបារសុប្បតី សឹងផ្គង់ព្រះរាជទានសម្តេចព្រះ នាងមទ្រីនោះឯងហោង ៗ

ទើបសម្តេចព្រះនាងមទ្រីស្រីសុភលក្ខណា ទទួលអស់គ្រឿងប្រដាប់ប្រដា មកទ្រង់ប្រដាប់ព្រះអង្គល្អបវរ ដូចស្រីទេពអប្សរបវរកញ្ញាឋិតនៅនាត្រៃត្រឹង្សាសួគ៌ឋាន ដ៏មានដងខ្លួននោះក្លៀវក្លំ រវៀវមូល បីដូចបណ្តាលចេកមាសអភិកាសកើតព្ធដ៏ព្រៃចិត្តលតាវ័ន គិតដ៏ត្រូវខ្យល់មណ្ឌវាត បោកបក់ទន់ទោរទេរវិញទៅមក មានប្រការដូចម្តេចមិញ រីសម្តេចព្រះនាងមទ្រី ក៏មានលំអដូរថ្កោះ ៗ រីព្រះទន្តទាំង ៤០ នោះ រៀងញឹកញាប់ ដូចអ្នកប្រដាប់នីទៅនូវពេជ្ររ័ត្ន ដ៏មានផ្លូវព្រះឱស្ឋនោះញញឹមប្រិមប្រិយល្អ បីដូចផ្លែព្រៃមាសបាសទុំ សមនូវកម្ពស់ទ្រង់ទ្រាយប្រពៃ បីដូចស្រីសួគ៌ មុខគួរឱ្យពិតពិលរមិលមើលក្រៃពេក ៗ

តស្សា ច នាគមានេសុំ   នាតិវុឌ្ឍំវ កុញ្ជរំ
សត្តិក្ខមំ សរក្ខមំ   ឦសាទន្តំ ឧរូឡ្ហវំ ។
សា មន្ទី នាគមារុហិ   នាតិវុឌ្ឍំវ កុញ្ជរំ
សត្តិក្ខមំ សរក្ខមំ   ឦសាទន្តំ ឧរូឡ្ហវន្តិ ។

កាលនោះ នាយហត្ថីក៏នាំដំរីធំធាត់ឧទារល្អបវរ មានភ្លុកស្តាំនោះងទន្ទាំ ដូចចន្ទោលរាជរថ មានចិត្តទាហានហានក្លានឹងសឹក ពុំភ្លឹកនូវកាំភ្លើងថ្កើងកណ្តាលរឿណរង្គ សឹងដ៏ប្រដាប់ផ្ចង់ដោយគ្រឿងចងកញ្ចាងមាសល្អឧត្តម នាំមកថ្វាយសម្តេចព្រះនាងមទ្រីស្រីរ័ត្នកញ្ញា ទើបព្រះនាងលីលា ឡើងគង់លើព្រះទីនាំងគជសារ ៗ ឯអស់ស្រីជាបរិវារ ក៏សឹងដ៏ព្រមចិត្តមិត្តមូល

ខ្លះក្រាបពិតទូលញញឹមប្រិមប្រិយ ខ្លះលើកដៃថ្វាយបង្គំ សមនូវរូបនោះល្អល្អះគាប់គួរ ខ្លះក៏សើចស្រួលផ្អៀងផ្អង ខ្លះដើរញ៉ៀង ញ៉ង ផ្សារស្រី ហៃសម្តេចព្រះនាងមទ្រីក្សត្រីមកឯទ័ពចំណាតស្រេច ស្តេចទាំងពីរព្រះអង្គ មានព្រះទ័យសោមនស្សា នឹងអស់បរិវារនោះច្រើនពន់ប្រមាណ នៅឋានចំណាតនោះឯង ។

រីឯព្រះបាទស្រីសញ្ជ័យ ដ៏ជាសម្តេចព្រះវរបិតា លុះបានអភិសេកសម្តេចព្រះឱរសាស្រេច ស្តេចមានព្រះទ័យនោះត្រេកអរសាទរពន់ប្រមាណ ទើបស្តេចចេញទៅប្រពាតព្រៃព្រឹក្សា នឹងអស់ពពួកសេនាទាហានប្រមាណ ១២ អក្ខោភិនី នូវអស់ស្រីព្រះស្នំទ្រង់ទតអស់ភ្នំ នូវរុក្ខជាតិទាំងឡាយ ខ្លះទើបរំសាយកេសរផ្កា ខ្លះដុះស៊ែមកែមលើគ្នា មានផ្លែសឹងដ៏ទុំ ៗ ឯអស់ស្រីព្រះស្នំ ក៏សឹងរត់ដណ្តើមគ្នា បេះប្រឡេះលេងជាផាសុកសប្បាយទីទៃ ៗ ទើបស្តេចចេញមកអំពីព្រៃនោះ ឡើងទៅលើភ្នំ ជាសប្បាយ លោះលាយក្នុងព្រះរាជហឫទ័យ នឹងអស់ព្រៃព្រះហេមពាន្ត សឹងដ៏មានបក្សាបក្សីបញ្ចុកចំណីកូនវា ខ្លះក៏ស្រែកដោយភាសារងំ ខ្លះក៏ទំយំទ្រពករកគូវា សឹងដ៏មានសំឡេងនោះពីរោះ ៗ ឯអស់អ្នកដង្ហែទាំងនោះ ក៏សឹងត្រេកអរសោមនស្សាផ្អៀងត្រចៀក ស្តាប់សព្វសត្វទាំងឡាយ សឹងដ៏មានតម្រេកចិត្ត ៗ ទើបស្តេចទតសត្វម្រឹគីម្រឹគា ប្រើសទ្រាយ ទន្សាយ ទន្សោងខ្លោង គោព្រៃ ច្រើនក្រៃពន់ប្រមាណ ទើបបានព្រះអង្គទតឧទកធារា ដោយនាច្រក

ជ្រោះចន្លោះភ្នំ សឹងដ៏មានផ្កាបទុមច្រាសច្រាលដេរដាស សឹងដ៏ដុះឆ្លូកឆ្លាស់ដោយពណ៌ទីទៃ ៗ ឧត្បលចង្កុលណី លំចង់ ស្បង្កឹជ សឹងដ៏ដុះលាយលេចគ្នាទាំង ៥ ពណ៌ ដ៏រហង់ៗ ៗ ឯអស់ស្រីផង ក៏សឹងត្រេកអរពន់ប្រមាណ ខ្លះបេះបានផ្កា ខ្លះបេះផ្លែ មកឆីជាសប្បាយនឹងអស់ស្រីព្រះស្នំទាំងឡាយ នៅឋាននោះឯង ៗ

ក៏ហេតុតែតេជះព្រះមេត្តាបារមីនៃព្រះបរមពោធិសត្វ បណ្តាលឱ្យពួកម្រឹគសាហាវ មានរាជសីហ៍ និងខ្លាធំជាដើម ព្រមទាំងបក្សីបក្សានៅនាព្រៃព្រះហេមពាន្ត មិនចេះបៀតបៀនគ្នា ទៅវិញទៅមកដល់តិចឡើយ តែងមានចិត្តអាណិត ស្រឡាញ់គ្នាទៅវិញទៅមកហោង ៗ

តមត្ថំ បកាសេន្តោ សត្ថា អាហ វីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលសូត្រសាន្នូវបាទព្រះគាថាដូច្នេះ

សព្វម្ហិ តំ អរញ្ញម្ហិ   យាវន្តេត្ថ មិគា អហុ
វេស្សន្តរស្ស តេជេន   នាញ្ញមញ្ញំ វិហេឋយុំ ៗ
សព្វម្ហិ តំ អរញ្ញម្ហិ   យាវន្តេត្ថ ទិជា អហុ
វេស្សន្តរស្ស តេជេន   នាញ្ញមញ្ញំ វិហេឋយុំ ៗ
សព្វម្ហិ តំ អរញ្ញម្ហិ   យាវន្តេត្ថ មិគា អហុ
ឯកជ្ឈំ សន្និបាតីសុ
វេស្សន្តរេ បយាតម្ហិ   សិវីនំ រដ្ឋវឌ្ឍនេ ៗ

សព្វម្ហិ តំ អរញ្ញម្ហិ យាវន្តេត្ថ ទិជា អហុ
ឯកជ្ឈំ សន្និបាតិសុ
វេស្សន្តរេ បយាតម្ហិ សិវីនំ រដ្ឋវឌ្ឍនេ ។
សព្វម្ហិ តំ អរញ្ញម្ហិ យាវន្តេត្ថ មិគា អហុ
នាស្សុ មញ្ជូនិ កុជីសុ
វេស្សន្តរេ បយាតម្ហិ សិវីនំ រដ្ឋវឌ្ឍនេ ។
សព្វម្ហិ តំ អរញ្ញម្ហិ យាវន្តេត្ថ ទិជា អហុ
នាស្សុ មញ្ជូនិ កុជីសុ
វេស្សន្តរេ បយាតម្ហិ សិវីនំ រដ្ឋវឌ្ឍនេតិ ។

ភិក្ខវេ ហៃភិក្ខុសង្ឃផងទាំងឡាយ ដ៏ទ្រង់នូវព្រ័ត ក្នុងបវរពុទ្ធសាសនា វីសត្វម្រឹគា រាជសីហ៍ គជសីហ៍ រមាំង រមាស ប្រើស· ទ្រាយ ទន្សាយ ទន្សោង ឈ្លូសផង ឯសារពើសត្វចតុប្បាទ គឺគជសារ គោ តោ សិង្ហ សីហ៍ មហិង្សា ខ្លា អស្សមុខី យក្ខិនី ខ្មោច ព្រាយ សារពើសត្វទាំងឡាយ នៅក្នុងព្រៃ នូវសារពើបក្សីបក្សា មយូរា រាជហង្ស ក្រៀល ចង្កៀលខ្យង ត្រយង ត្រុំ ត្លុម ស្ទាំង ភូវាំង អុក អក លលក ទទា នូវអស់ម្រឹគីម្រឹគា ប៉ុន្មានៗ ក្តី អម្បាលអាស្រ័យ នៅខាងមាត់ចង្វាត់អាស្រមនៃព្រះបរមពោធិសត្វ សឹងដ៏មានចិត្តស្រឡាញ់គ្នា ពុំហ៊ានពាធាបៀតបៀនឱ្យជាហេតុជាមន្ទិល ដូចកាលអំពីមុន ហេតុតេជះបុណ្យជាត្រកាលព្រះរាជសម្ភារនៃ

ព្រះបាទស្រីវេស្សន្តរនោះឯង ។

អណ្តាប់នោះ សារពើសត្វផង ដឹងសេចក្តីជាព្រះរាជឫសីស្តេចនឹងក្រឡាប់ចូលទៅព្រះនគរវិញ ។ អស់សត្វអម្បាលនៅក្នុងព្រៃព្រះហេមពាន្ត ក៏សឹងមកជួបជុំ ពុំបានឃំរងារទ្រពករកគ្នា សឹងព្រួយចិត្តជាទុក្ខ ទំនៅស្ងួតស្ងប់ ស្ងោរស្ងប់ស្ងើរពុំមានជីវិត គិតថា ឱ ! អំពីដើមបានព្រះបាទស្រីវេស្សន្តរបវររាជឫសី ព្រះអង្គមានព្រះមេត្រីករុណា គ្រងរក្សាយើងទាំងឡាយសឹងជាសុខក្សេមក្សាន្ត ពុំមានបៀតបៀនគ្នាឡើយ ។ ឱ ! អំពីនេះទៅហើយ តើនឹងបានអ្នកឯណាជាទីពឹងអាស្រ័យ នៃសារពើសត្វបក្សាបក្សី ដូចនៃព្រះមហាវេស្សន្តរ បវរពោធិសត្វនោះ ឥតអង្គីមានឡើយ ។

សញ្ជយោ នរិន្ទោ រីឯព្រះបាទស្រីសញ្ជ័យបរមបពិត្រជាមកុដលើត្បូង អស់អ្នកស្រីពិរាស្ត្រផង **កីឡិត្វា** ព្រះអង្គស្តេចប្រពាត នៅក្នុងព្រៃព្រះហេមពាន្ត ជាសុខក្សេមក្សាន្តប្រមាណមួយខែហើយ ទើបមានព្រះរាជឱង្ការ ឱ្យហៅអស់មុខមន្ត្រីសេនាបតីដ៏ជាធំមក ហើយមានព្រះរាជឱង្ការថា ហៃអស់អ្នកទាំងឡាយអើយ **រាជមគ្គោ** រីអស់ផ្លូវទាំងពួង ដែលសម្តេចព្រះវេស្សន្តរបវរពោធិសត្វរាជបុត្រនៃយើង អ្នកនឹងចូលទៅថ្កានព្រះនគរបវររាជដ្ឋានសឹងដ៏ឆ្ងាយ តើអ្នកទាំងឡាយប្រុងប្រៀបរៀប ប្រដាប់ប្រដាស្រេចបរិបូណ៌ហើយ ឬនៅ

ឡើយទេ ចូរអ្នកទាំងឡាយ ប្រាប់អញឱ្យបានដឹង ក្នុងកាលឥឡូវនេះឯង ។

អស់មុខមន្ត្រីសេនាបតីទាំងនោះ លុះបានស្តាប់ព្រះរាជឱង្ការដូច្នេះហើយ ក្រាបថ្វាយបង្គំទូលថា ទេវ បពិត្រសម្តេចព្រះនរិន្ទនរនាថនារាយណ៍នរបតីស្រីសម្មតិទេពមហាក្សត្រថ្លៃប្រសើរអើយ មគ្គោ រីឯមាគ៌ានោះ យើងខ្ញុំជាខ្ញុំល្អងធូលីព្រះបាទរៀងប្រដាប់ប្រដាស្រេច អញ្ជើញស្តេចក្រឡាប់ចូលទៅព្រះនគរវិញ បានតាមសព្វព្រះរាជហឫទ័យ ។

អណ្តាប់នោះ ព្រះបាទក្រុងស្រីសញ្ជ័យ ព្រះអង្គបានជ្រាបសេចក្តីដូច្នោះហើយ ពុំលង់ឡើយ ស្តេចឱ្យអញ្ជើញព្រះរាជបុត្រា បុត្រី នូវព្រះចៅទាំងពីរ ហើយព្រះអង្គឱ្យយកស្គរជ័យភេរីវាយប្រោមប្រាប់អស់រេហ៍ពលសកលយោធា សេនាទាហាន ឱ្យបានដឹងគ្រប់គ្នាថា ស្តេចលើកព្យូហ៍យាត្រាចេញអំពីព្រៃថ្កានព្រះនគរពិជ័យជេតុត្តរ ទើបព្រះបាទសម្តេចព្រះវេស្សន្តរ ស្តេចព្រះរាជដំណើរទៅ ជាមួយនឹងរាជបរិវារយ៉ាងធំសម្បើម ណែនណាន់តាន់តាប់ បើនឹងរាប់ជារយៈផ្លូវ តាំងអំពីភ្នំគិរីវង្កតដរាបដល់ក្រុងពិជ័យជេតុត្តរនោះ ជាចម្ងាយ ៦០ យោជន៍ ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះអង្គបានត្រាស់ហើយ មានព្រះបន្ទូលនូវបាទគាថាដូច្នេះ

បដិយត្តោ រាជមគ្គោ វិចិត្តោ បុប្ផសណ្ឋតោ
វសិ វេស្សន្តរោ រាជា យត្ថ យាវ ជេតុត្តរា ។
តតោ សដ្ឋីសហស្សានិ យោធិនោ ចារុទស្សនា
សមន្តា បរិកិរិំសុ
វេស្សន្តរេ បយាតម្ហិ សិវីនំ រដ្ឋវឌ្ឍនេ ។
ឱរោធា ច កុមារា ច វេសិយានា ច ព្រាហ្មណា
សមន្តា បរិកិរិំសុ
វេស្សន្តរេ បយាតម្ហិ សិវីនំ រដ្ឋវឌ្ឍនេ ។
ហត្ថារោហា អនីកដ្ឋា រថិកា បត្តិការកា
សមន្តា បរិកិរិំសុ
វេស្សន្តរេ បយាតម្ហិ សិវីនំ រដ្ឋវឌ្ឍនេ ។
ករោដិយា ចម្មធរា ឥល្លិហត្ថា សុវម្មិកា
បុរតោ បដិបជ្ជិសុ
វេស្សន្តរេ បយាតម្ហិ សិវីនំ រដ្ឋវឌ្ឍនេ ។
សមាគតា ជានបទា នេគមា ច សមាគតា
សមន្តា បរិកិរិំសុ
វេស្សន្តរេ បយាតម្ហិ សិវីនំ រដ្ឋវឌ្ឍនេតិ ។

ភិក្ខវេ ហៃភិក្ខុផងទាំងឡាយអើយ រាជមគ្គោ វីមាគ៌ាដែលស្ដេចព្រះរាជដំណើរនោះ ពួកប្រជាជន នាំគ្នាជួយតាក់តែង ឱ្យបានរាបទាបស្មើល្អប្រពៃ ប្រដាប់ប្រដា ដោយ

ដើមចេក ក្អមទឹក អធិកនីទៅដោយទង់ជ័យរាជវ័តិឆត្រផ្កាកម្រង ចងរំយោល មានក្លិនពិដោរសព្វទិសា រហូតរយៈផ្លូវ ៦០ យោជន៍ តាំងពីភ្នំគិរីវង្កតដែលស្តេចប្រថាប់ ដរាបដល់ជេតុត្តរនគររាជបុរី ៗ

លុះបានឫក្សពារពេលាល្អ ទើបសម្តេចក្សត្រាក្សត្រី ទាំង ៦ ព្រះអង្គ ស្តេចឡើងគង់លើគជសារ អស់ទាំងពួកសេនាអាមាត្យសហជាតទាំង ៦ ម៉ឺន ក៏ប្រដាប់តាក់តែងរាងកាយ ដ៏ល្អរុងរឿងដោយគ្រឿងមាស ដៃកាន់ធ្នូស្នានូវគ្រឿងសព្វយុទ្ធ មានចិត្តមុះមុតក្លាហាន តាមហែព្រះបាទស្រីវេស្សន្តរបរមក្សត្រ រៀបជាជួរជាសង្កាត់ ដោយនូវចង្វាត់ទីទៃ ៗ នៅនៃសងខាងមាគ៌ានោះ ដើម្បីដង្ហែស្តេចថ្កានព្រះនគរ តបន្ទាប់មក ពួកស្រីព្រះស្នំ ព្រះរាជកុមារ ព្រះញាតិវង្សានុវង្ស នូវពួកបុត្រអាមាត្យ បន្ទាប់មកទៀត ដល់ពួកឈ្មួញ គហបតី នូវពួកព្រាហ្មណ៍ព្រឹទ្ធាចារ្យ ទើបដល់ទៅពួកពលដំរី ពលសេះ ពលរថពលថ្មើរជើង សឹងនាំគ្នាចោមរោមហែហាមតាមស្តេច ៗ ពួកសេនាទាហាន មានកាយពាក់សុទ្ធតែគ្រឿងក្រោះ សំណាញ់ក្បាលពាក់មួកទង់ដែង ដៃកាន់ខែលដាវលំពែង ជាក្បួនហែនាំមុខ ចំណែកខាងប្រជាជនអ្នកស្រុកអ្នកនិគម នូវអ្នកជនបទដែលតាមហែហាមព្រះបាទស្រីសញ្ជ័យ ក៏ដើរហែតាមក្បួនក្រោយដោយលំដាប់គ្នាមក ទើបមានព្រះរាជឱង្ការ ឱ្យលើកចតុរង្គសេនាយាត្រាតាមរាជមាគ៌ាដែលបានរៀបចំបម្រុងទុកនោះឯង ៗ

កាលនោះ ព្រះបាទស្រីវេស្សន្តរបវរពោធិសត្វខត្តិយវង្ស នូវព្រះបាទក្រុងស្រីសញ្ជ័យ នូវព្រះនាងសុបារសុប្បតីរាជទេវី ព្រះរាជបុត្រាបុត្រី នូវសម្តេចព្រះសុណិសា ស្តេចលីលាយាត្រាទៅក្នុងមួយថ្ងៃបានចម្ងាយផ្លូវ ១ យោជន៍ ត្រូវជា ៦០ យោជន៍ ជាប្រាកដកំណត់បាន ២ ខែ ទើបស្តេចបានដល់ពិជ័យជេតុត្តរបវររាជដ្ឋាននោះឯងហោង ។

តមត្ថំ បកាសេន្តោ សត្ថា អាហ វីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ចែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូល ថា

តេ បាវិសុ បុរំ រម្មំ ពហុបាការតោរណំ
ឧបេតំ អន្នបានេហិ នច្ចគីតេហិ ចូភយំ ។
ចិត្តា ជានបទា អាសុំ នេគមា ច សមាគតា
អនុប្បត្តេ កុមារម្ហិ សិវីនំ រដ្ឋវឌ្ឍនេ ។
ចេលុក្ខេបោ បវត្តិត្ថ អាគតេ ធនទាយកេ
នន្ទិប្បវេសិ នគរេ ពន្ធមោក្ខោ អឃោសថាតិ ។

ភិក្ខវេ ហៃភិក្ខុផងទាំងឡាយអើយ វីក្សត្រទាំង ៦ ព្រះអង្គ ស្តេចចូលទៅដល់ក្រុងពិជ័យជេតុត្តរ ចូលក្នុងព្រះនគរ ដ៏ក្សេមក្សាន្តសប្បាយពុំមានជាទុក្ខ ស្តេចឡើងគង់លើប្រាសាទដ៏ប្រសើរស្អាងស្អាត ហើយស្តេចទតព្រះនេត្ររមិលមើលទៅព្រះនគរ នូវអស់ជហ្វាដងក្តារខ្លោងទ្វារនាងច្រាល អម្បាលដែល

ផាងរចនា សឹងដ៏ល្អវិចិត្រ ដ៏មានប្រការនោះផ្សេង ៗ រីក្នុងព្រះនគរសោត គិតដ៏អ្នកប្រដាប់នីទៅនូវភោជនាហារ មានរសពីសាផ្សេង ៗ ហើយមានល្បែងច្រៀងរាំ នូវរបាំផងទាំងឡាយសឹងមានច្រើន ព្រះអង្គទតទៅយល់ហើយ មានព្រះរាជហឫទ័យសោមនស្សសាទរ រីអស់នគរតូច-ធំ និគមស្រុកក្រៅលំនៅជនបទ នាកាលសម្តេចព្រះបាទស្រីវេស្សន្តរបរពុទ្ធវង្ស ស្តេចចូលមកដល់ក្នុងព្រះនគរហើយ រីអស់មហាជនផងទាំងឡាយ សឹងដ៏មានចិត្តនោះត្រេកអរសាទររួសរាយ នាំដង្វាយសួយរែមកថ្វាយព្រះមហាបុរសរ័ត្នវិសេសនោះ ច្រើនក្រៃពេក ៗ រីព្រះបរមពោធិសត្វនោះសោត ព្រះអង្គឱ្យទូងនូវភេរី ក្នុងព្រះនគរ ប្រាមប្រាប់បង្គាប់អស់អាណាប្រជារាស្ត្រ ផងទាំងឡាយឱ្យស្រាយខ្នោះផោះឃ្នាង ច្រួលច្រវាក់អន្ទាក់ណែងណាង អស់ទាំងចំណងសត្វផងទាំងឡាយ កុំបីឱ្យមាននៅក្នុងព្រះនគរនោះឡើយ ៗ

កាលនោះ ព្រះបរមពោធិសត្វ ស្តេចចូលក្រឡាព្រះបន្ទំបរមសុខសួស្តី ក្នុងរាត្រីហៀបនឹងព្រឹកព្រាង ស្វាងព្រះសុរិយា ទើបស្តេចទ្រង់ព្រះចិន្តានឹកក្នុងព្រះរាជហឫទ័យថា ឱ! ថ្ងៃព្រឹកនេះ សមស្មូមផងទាំងឡាយ វាឮពត៌មានថា អញបានមកដល់ព្រះនគរហើយ សមព្រហាមស្អែកនេះឯង វានឹងមកចោមរោមសុំអញពុំខាន បើដូច្នោះ តើអញនឹងបានទ្រព្យអ្វី ឱ្យទាន

ស្ហូមផងទាំងឡាយនោះ នាកាលព្រះអង្គទ្រង់ព្រះតម្រិះដូច្នោះហើយ ក៏ក្តៅទៅដល់អាសនៈសម្តេចអមរិន្ទ្រាធិរាជ ព្រះអង្គអាចគិតពិចារណាជ្រាបសភាព ដោយព្រះទិព្វយោបល់ នូវប្រការអម្បាលនោះហើយ ពុំយូរឡើយ ព្រះអង្គបណ្តាលនូវមហាមេឃឯង ឱ្យជោរជន់នូវទឹក បង្អុរនូវភ្លៀងរត្នទាំង ៧ ប្រការ ឱ្យធ្លាក់ចុះមក ឯលិច ឯកើត ឯជើង ឯត្បូង ព្រះរាជមន្ទីរនោះប្រមាណស្មើចង្កេះ ទីក្រៅអំពីនោះប្រមាណស្មើជង្គង់ ។

បុន ទិវសេ លុះព្រឹកឡើងហើយ ព្រះអង្គឱ្យអាមាត្យទៅប្រោមប្រាប់អស់មនុស្សម្នា មហាជនផងទាំងឡាយ ថា ទ្រព្យធ្លាក់ចុះត្រង់ផ្ទះសម្រាសរបង របស់បុគ្គលឯណា ក៏ឱ្យបុគ្គលនោះជញ្ជូនយកទុកជាទ្រព្យរបស់ខ្លួនចុះ ។ បើធ្លាក់ក្នុងឋានពុំមានម្ចាស់ ព្រះអង្គឱ្យកើបជញ្ជូនយកមកគរទុកក្នុងព្រះឃ្លាំង ព្រះអង្គនឹងបានទ្រង់ព្រះរាជសទ្ធា ធ្វើបុណ្យឱ្យទាន ដរាបលុះដល់កំណត់អស់ព្រះជន្មទិវង្គតទៅ ។

តមត្ថំ បកាសេន្តោ សត្ថា អាហ រីអាថ៌ធម៌ឯណាពុំទាន់ប្រាកដ បទព្រះបាលីឯណាពុំទាន់ថែងច្បាស់ លុះព្រះបានត្រាស់ហើយ ព្រះអង្គមានព្រះបន្ទូលនូវបាទព្រះគាថាដូច្នេះ

ជាតរូបមយំ វស្សំ ទេវោ បាវស្សិ តាវទេ
វេស្សន្តរេ បតិដ្ឋម្ហិ សិវីនំ រដ្ឋវឌ្ឍនេ ។
តតោ វេស្សន្តរោ រាជា ទានំ ទត្វាន ខត្តិយោ

កាយស្ស ភេទា សប្បញ្ញោ សគ្គំ សោ ឧបបជ្ជថាតិ ។

ភិក្ខវេ ម្នាលសង្ឃដ៏ខ្លាចភ័យក្នុងវដ្តសំសារ **វេស្សន្តរេ** នាកាលព្រះបាទស្រីវេស្សន្តរបវរខត្តិយវង្ស តែងទ្រង់ធ្វើសេចក្ដីចម្រើនដល់ពួកអ្នកស្រីពិរាស្ត្រ លុះស្ដេចចូលដល់ព្រះនគររាជបុរី សម្ដេចអមរិន្ទ្រកោសីយ ក៏ទ្រង់បង្អុរនូវភ្លៀងរ័ត្នទាំង ៧ ប្រការ ឱ្យធ្លាក់ចុះមកក្នុងព្រះរាជធានីមួយរំពេច ។ កាលនោះ ព្រះបាទស្រីវេស្សន្តរបរមក្សត្រ ទ្រង់មានព្រះប្រាជ្ញាដ៏ប្រសើរឧត្តម តែងទ្រង់អប់រំបន្សំទានបារមី រៀងរាបដរាបដល់អស់ព្រះជន្មទិវង្គតទៅ ព្រះអង្គក៏បានទៅកើតនៅនាតុសិតសួគ៌ាទេវលោកនាយ បានជាទេវបុត្រ ១ ព្រះអង្គ ទ្រង់ព្រះនាមករណ៍បវរថា សន្តុស្សិតទេបុត្រ ប្រាកដហោង ។

សត្ថា រីឯព្រះអរហំសម្មាសម្ពុទ្ធ ដ៏ជាមកុដឥស្សរកំពូលត្រៃភព **អាហរិត្វា** លុះព្រះអង្គនាំនិទាន ព្រះធម៌វិសេសទេសនាមហាវេស្សន្តរជាតក ដ៏ប្រដាប់ប្រដានីទៅនូវគាថាមួយពាន់ ទើបព្រះអង្គមានព្រះពុទ្ធដីកាថា **ភិក្ខវេ** ហៃភិក្ខុសង្ឃផងទាំងឡាយ **មហាមេឃោ** រីមហាមេឃបណ្ដាលឱ្យនូវភ្លៀងបោក្ខរពស៌ជាអស្ចារ្យ ធ្លាក់ចុះមកក្នុងសមាគមនៃព្រះញាតិតថាគតនោះ ពុំតែឥឡូវនេះឡើយ ភិក្ខុអើយ អំពីដើមមក កាលដែលតថាគតនៅជាព្រះបាទស្រីវេស្សន្តរនោះ ក៏មានភ្លៀងបោក្ខរពស៌ធ្លាក់ចុះមក ដូច្នេះដែរ ។ លុះទ្រង់

សម្តែងនូវចតុរារិយសច្ចធម៌ចប់ស្រេចហើយ ៗ រីអស់មនុស្សម្នាមហាជនផងទាំងឡាយ ក៏បានលុះសោតា សកិទាគា អនាគា អរហត្ត. នោះច្រើនពន់ប្រមាណ ទើបព្រះអង្គជំនុំប្រជុំជាតកថា

តទា ជូជកោ ទេវទត្តោ រីជូជកព្រាហ្មណ៍ លុះក្រឡាប់ជាតិចេរវិលវឹងមក បានជាទេវទត្ត ៗ

អមិត្តតាបនា ព្រាហ្មណី ចិញ្ចមាណវិកា រីនាងអមិត្តតាបនា ជាប្រពន្ធជូជកព្រាហ្មណ៍នោះ ក្រឡាប់ជាតិចេរវិលវឹងមក បានជានាងចិញ្ចមាណវិកា ៗ

ចេតបុត្តោ ឆន្នោ រីឯចេតបុត្រ តែងជាអ្នកចាំទ្វារផ្លូវព្រះបរមពោធិសត្វនោះមិញ លុះក្រឡាប់ជាតិចេរវិលវឹងមក បានជាមហាឆន្ន ៗ

អច្ចុត្តតាបសោ សារីបុត្តោ រីអច្ចុត្តមហាឫសី តែងនឹងបង្ហាញផ្លូវជូជកព្រាហ្មណ៍ លុះក្រឡាប់ជាតិចេរវិលវឹងមក បានជាមហាសារីបុត្រ ៗ

សក្កោ អនុរុទ្ធោ រីសម្តេចអមរិន្ទ្រាធិរាជ តែងនឹងឱ្យឱវាទដំបូន្មានព្រះបរមពោធិសត្វ លុះក្រឡាប់ជាតិចេរវិលវឹងមក បានជាអនុរុទ្ធាចារ្យ ៗ

វិស្សកម្មោ ច មោគ្គល្លានោ រីព្រះវិស្សកម្មទេវបុត្រ ដែលនិម្មិតព្រះអាស្រមថ្វាយ លុះក្រឡាប់ជាតិចេរវិលវឹងមក បានជាមហាមោគ្គល្លាន ៗ

មគ្គរុម្ហិ សីហោ ឧបាលិ រីទេវតា ដែលនិម្មិតអាត្មាជារាជសីហ៍ ចាំរាំងរាផ្លូវព្រះនាងមទ្រីនោះ លុះក្រឡាប់ជាតិចេរវិលវឹងមក បានជាឧបាលី ៗ

ព្យគ្ឃរាជា សីវលិ រីឯទេវតា ដែលនិម្មិតអាត្មាជាខ្លាធំ ចាំរាំងផ្លូវព្រះនាងមទ្រីនោះ លុះក្រឡាប់ជាតិចេរវិលវឹងមក បានជាព្រះសីវលី ៗ

ទីបិ ច មុល្លិនាគោ រីឯទេវតា ដែលនិម្មិតជាខ្លាដំបង ចាំពាំងរាំងផ្លូវព្រះនាងមទ្រី លុះក្រឡាប់ជាតិចេរវិលវឹងមក បានជាមុល្លនាគ ៗ

ទេវោ កច្ចាយនោ រីទេវបុត្រ ដែលនិម្មិតជាព្រះវេស្សន្តរ ទៅស្រាយចំណងចៅជាលីនោះ លុះក្រឡាប់ជាតិចេរវិលវឹងមក បានជាមហាកច្ចាយនៈ ៗ

ទេវធីតា វិសាខា ពុទ្ធុបាសិកា រីនាងទេពធីតា ដែលនិម្មិតជាព្រះនាងមទ្រី ទៅស្រាយចំណងនាងក្រស្នា លុះក្រឡាប់ជាតិចេរវិលវឹងមក បានជានាងពែសាខាពុទ្ធុបាសិកា ៗ

បច្ចយនាគោ វារណោ កស្សបោ សំយវុឌ្ឍោ រីឯដំរីបច្ច័យនាគេន្ទ្រនោះ ក្រឡាប់ជាតិចេរវិលវឹងមក បានជាមហាកស្សបសង្ឃព្រឹទ្ធាចារ្យ ៗ

ករេណុកា កិសាគោតមី រីឯមេដំរី លុះក្រឡាប់ជាតិចេរវិលវឹងមក បានជានាងកិសាគោតមី ៗ

មទ្ទរាជា មហានាមោ រីព្រះបាទមទ្ទរាជ លុះក្រឡាប់ជាតិចេរវិលវឹងមក បានជាមហានាម ។

អញ្ញតរោ មហាមច្ចោ អានន្ទោ ពុទ្ធុបដ្ឋាកោ រីឯមហាមាត្យ ដែលប្រដាប់ប្រដាទានថ្វាយព្រះបរមពោធិសត្វនោះ លុះក្រឡាប់ជាតិចេរវិលវឹងមក បានជាអានន្ទ ។

ទានវេយ្យាវច្ចាមច្ចោ អនាថបិណ្ឌិកុបាសកោ រីឯអាមាត្យ ដែលជាអ្នកខ្វល់ខ្វាយក្នុងការបរិច្ចាគទានថ្វាយព្រះបរមពោធិសត្វនោះ លុះក្រឡាប់ជាតិចេរវិលវឹងមក បានជាអនាថបិណ្ឌិកឧបាសក ។

សញ្ជយនរិន្ទោ សុទ្ធោទនមហារាជា រីឯព្រះបាទស្រីសញ្ជ័យនរិន្ទរាជនោះ លុះក្រឡាប់ជាតិចេរវិលវឹងមក បានជាព្រះបាទស្រីសុទ្ធោទនមហារាជ ពុទ្ធបិតា ។

ផុស្សតី ទេវី សិរិមហាមាយា រីឯនាងសុបារសុប្បតីទេវីដ៏ជាព្រះវររាជមាតាព្រះបរមពោធិសត្វ លុះក្រឡាប់ជាតិចេរវិលវឹងមក បានជាព្រះនាងសិរិមហាមាយាពុទ្ធមាតា ។

មទ្ទី ទេវី យសោធរា រាហុលមាតា រីនាងមទ្រីទេវីដ៏ជាព្រះវររាជមាតាចៅជាលី និងនាងក្រស្ណា លុះក្រឡាប់ជាតិចេរវិលវឹងមក បានជានាងយសោធរា រាហុលមាតា ។

ជាលិកុមារោ រាហុលោ រីចៅជាលីកុមារនោះ លុះក្រឡាប់ជាតិចេរវិលវឹងមក បានជារាហុលកុមារ ។

កណ្ហាជិនា ឧប្បលវណ្ណា រីនាងក្រស្នារាជកញ្ញា លុះក្រឡាប់ជាតិចេរវិលវឹងមក បានជានាងឧប្បលវណ្ណា ។

សេសបរិសា ពុទ្ធបរិសា រីបរិសទ្យសំណល់ សល់លែងអំពីនោះ លុះក្រឡាប់ជាតិចេរវិលវឹងមក បានជាបរិសទ្យរបស់តថាគត ។

វេស្សន្តរោ មហារាជា បន អហមេវ សម្មាសម្ពុទ្ធោ រីព្រះបាទស្រីវេស្សន្តរមហារាជនោះ មិនគឺអ្នកដទៃឡើយ **អហមេវ** គឺអង្គអញតថាគតហ្នឹងឯង ដ៏បានត្រាស់ប្រាជ្ញាសព៌េជតាញ្ញាណ ជាទីពំនាក់នៃសត្វលោកផងទាំងឡាយ ។

វេស្សន្តរជាតកំ ហៃសាធុសប្បុរសផងទាំងឡាយអើយ ថាបើបុរសបុគ្គលឯណា បានស្តាប់ត្រាប់ត្រង រងរសអាថ៌ធម៌វិសេសទេសនាមហាវេស្សន្តរជាតកនេះហើយ ក៏សឹងរដោះ ប្រាសចាកទុក្ខសោករោគភ័យចង្រៃឧបទ្រពផងទាំងឡាយ ទោះនៅក្នុងលោកិយ ក៏ប្រសើរ លុះអនាគតកាលទៅឯក្តែក ក៏សឹងបានលុះសោតា សកិទា អនាគា អរហត្តផល បានដល់សម្បត្តិព្រះនិព្វាន ដ៏ជាឋានបរមសុខក្សេមក្សាន្តប្រសើរនោះទៀងប្រាកដហោង ។

នគរកណ្ឌំ និដ្ឋិតំ បពិត្រអើយ អាត្មាភាពសម្តែងថ្លែងព្រះធម៌វិសេសទេសនាមហាជាតក៏ **កណ្ឌ នគរកណ្ឌ**

ដ៏ប្រងាប់ប្រងានូវគាថា ៤៨ គាថា ក៏ចូរជាបច្ច័យនៃទាយកឧបាសកឧបាសិកា ចប់ជាសូវរេចបរិបូណ៌ សមគួរដោយនូវវេលានេះឯងហោង ។

ចប់ កណ្ឌានគរកណ្ឌ ទី ១៣ តែប៉ុណ្ណោះ ។

⁂

ចម្លងចប់នៅថ្ងៃ ១០ រោច ខែអាសាធ ព. ស. ២៥៣៣
ត្រូវនឹងថ្ងៃអង្គារ ទី ១៧ ខែកក្កដា គ. ស. ១៩៩០

បាលីគាថានិងសេចក្ដីប្រែខាងក្រោមនេះ មិនមានក្នុងច្បាប់មហាជាតក៏សម្រាយទេ ឃើញមានតែក្នុងច្បាប់មហាជាតក៏បាលី ថ្លែងសេចក្ដីប្រាប់ចំនួនថា ក្នុងកណ្ឌនីមួយ ៗ ដូចជាបញ្ជីរឿងរបស់មហាវេស្សន្តរជាតក ដូច្នេះ

តស្សុទ្ទានំ

ឯកូនវីសតិ គាថា　ទសវរេ មនោរមេ
ហិមវន្តេ ចតុត្តឹស-　សតគាថា បកាសិតា ៗ
នវាធិកា ច ទ្វេ សតា　ទានកណ្ឌេ អសេសតោ
គាថាយោ សត្តបញ្ញាស　វនប្បវេសេ មហេសិនា ៗ
នវសត្តតិ គាថាយោ　ជូជកម្ហិ បកាសិតា
បញ្ចត្តឹសប្បមាណាវ　ចូឡវនេ មនោរមេ ៗ
មហាវនេបិ អសីតិ　វុត្តា គាថា មហេសិនា
កុមារេកសតំ គាថា　ធម្មរាជេន សត្ថុនា ៗ
នវុតិ មទ្ទិបព្វស្មឹ　គាថាយោ សមុទីរិតា
តេចត្តាឡីស គាថាយោ　សក្កបព្វវរេ តម្ហិ ៗ
មហារាជេ នវសដ្ឋី　គាថាយោ ច បមាណតោ
ឆក្ខត្តិយម្ហិ ឆត្តឹស　គាថាយោ សមុទីរិតា ៗ
តតោ នគរកណ្ឌម្ហិ　ចត្តាឡីស អដ្ឋាធិកា
គាថា វេស្សន្តរស្សេវ　ជាតកស្ស សុសព្វសោ ៗ

(បញ្ជីរឿងនៃវេស្សន្តរជាតកនោះដូច្នេះ) ក្នុងកណ្ឌទសពរមានរឿងពីរោះចាប់ចិត្ត សម្ដេចព្រះភគវន្តបពិត្រទ្រង់ប្រកាសថា មានគាថា ១៩ ៗ ក្នុងកណ្ឌហេមពាន្ត ទ្រង់សម្ដែងថា មានគាថា ១៣៤ ៗ ក្នុងទានកណ្ឌ សម្ដេចព្រះមហេសីទ្រង់ស្រដីថា ទាំងអស់មានគាថា ២០៩ ៗ កណ្ឌវនប្បវេសន៏ ទ្រង់សម្ដែងថា មានគាថា ៥៧ ៗ កណ្ឌជូជក សម្ដេចព្រះមហេសី ទ្រង់ស្រដីថា មានគាថា ៧៩ ៗ កណ្ឌចូឡពន មានរឿងជាទីរីករាយនៃចិត្ត សម្ដេចព្រះបរមបពិត្រទ្រង់សម្ដែងថា មានគាថា ៣៥ ៗ ឯកណ្ឌមហាពន ព្រះដ៏មានបុណ្យទ្រង់ត្រាស់ថា មានគាថា ៨០ ៗ កណ្ឌកុមារ ព្រះធម្មរាជាបរមសាស្ដាចារ្យ ទ្រង់សម្ដែងថា មានគាថា ១០១ ៗ កណ្ឌមទ្ទីបព្វៈ ព្រះអង្គទ្រង់សម្ដែងថ្លែងថា មានគាថា ៩០ ៗ កណ្ឌសក្កបព្វៈ ដ៏ប្រសើរនោះ មានគាថា ៤៣ ៗ កណ្ឌមហារាជ ព្រះអង្គពោលអាងថា មានគាថា ៦៩ ៗ ដោយប្រមាណ កណ្ឌឆក្សត្រ មានគាថា ៣៦ ៗ ក្នុងនគរកណ្ឌ ក្រោយបង្អស់ ព្រះទ្រង់យសទ្រង់សម្ដែង ថា មានគាថា ៤៨ ៗ (នេះចំនួនគាថាទាំងឡាយ) នៃវេស្សន្តរជាតក ចប់ដោយសព្វគ្រប់តែប៉ុណ្ណោះឯង ៗ

អក្សរសង្ខេប
នៃសេចក្តីអធិប្បាយស័ព្ទក្នុងកណ្ឌនគរកណ្ឌ

អ. វ. ជ. អដ្ឋកថាមហាវេស្សន្តរជាតក
ម. វ. ទ. មហាវេស្សន្តរទីបនី
ម. ល. ប. មហាវេស្សន្តរលីនត្ថប្បកាសិនី

ពាក្យអធិប្បាយស័ព្ទ

អំពី គ្រឿងប្រដាប់ និងការសរសើរព្រះរូបឆោមព្រះនាងមទ្រី ត្រង់គាថាដែលមានបង់លេខតាំងពី ១ ដល់ ២១ ទំព័រ ៤៥៤-៤៥៥ ។

១- កប្បាសិកំ = សំពត់ដែលត្បាញដោយអំបោះសំឡី ។ កប្បាសិកញ្ញាតិ កប្បាសសុត្តនិយសុត្តេហិ វាយិតវត្ថំ ។ អ. វ. ជ. ។

២- កោសេយ្យំ = សំពត់ដែលត្បាញដោយសរសៃសូត្រ។ កោសេយ្យន្តិ សហបាណកសុត្តតយំ វត្ថំ ។ តំ សេតញ្ច រត្តញ្ច បីតញ្ច នីលញ្ច ពលារូបមិគរូបាទិផាលំ (ពាឡមិគរូបាទិផាលំ ឬ ពលាការូបមិគរូបាទិផាលំ ?) វិចិត្តំ ហោតិ ។ អ. វ. ជ. ។ កោសោ នាម កិមិគព្ភោ ។ តតោ ជាតត្តា កោសេយ្យំ ។ កោសេយ្យំ វត្ថំ កិមិជំ នាមាតិ តដ្ដីកានយោ ។ កោសេយ្យន្តិ សុវណ្ណខចិតកោសេយ្យន្តិ កុសរាជវណ្ណនានយោ ។ ម. វ. ទ. ។

៣- **ខោមកោទុម្ពរានិ ច** = សំពត់ខោមពស្ត្រ និងសំពត់កោទុម្ពរពស្ត្រ ។ ខោមកោទុម្ពរានិ ចាតិ ខោមញ្ច កោទុម្ពរញ្ច តត្ថ ខោមវត្ថំ នាម ខោមរដ្ឋេ ឧប្បន្នវត្ថំ តំ សតសហស្សគ្ឃនិកំ បរិសុទ្ធំ សេតវត្ថំ ហោតិ ។ កោទុម្ពរវត្ថំ នាម កោទុម្ពររដ្ឋេ ឧប្បន្នវត្ថំ តំ សហស្សគ្ឃនិកំ លោហិតកំ ហោតិ ។ អ.វ.ជ. ។ ខោមន្តិ ខោមវាកេហិ កតសុត្តន្តិ សុត្តវិញ្ញត្តិសិក្ខាបទវណ្ណនា ។ ខោមន្តិ ខោមសុត្តេហិ វាយិតំ ខោមបដចីវរន្តិ បឋមកឋិនសិក្ខាបទដីកា ។ ខោមទុកុលន្តិ ទ្វយំ ទុកុលខ្យេ វត្ថ ឧមាយ វិការោ ខោមំ ឧមា នាម អតសី ។ តព្ពក្កលសម្ភវំ វត្ថំ ខោមាទយោ បន បដា តចតោ ជាតាតិ នវវគ្គដីកានយោ ។ កោទុម្ពរានីតិ កោទុម្ពររដ្ឋេ ឧប្បន្នានីតិ ទានកណ្ឌវណ្ណនា ។ ខោមរដ្ឋេ កោទុម្ពររដ្ឋ ឧប្បន្នានីតិ សីហឡដ្ឋកថា ។ ម.វ.ទ.។

៤- **ខោមញ្ច កាយូរំ** = គ្រឿងប្រដាប់សម្រាប់ពាក់កជាវិការៈនៃមាស ។ តត្ថ ខោមញ្ច កាយូរន្តិ សុវណ្ណមយំ គីវប្បសាធនំ ។ ខោមញ្ច កាយូរន្តិ ទ្វីសុ ពាហាសុ មណិគណ្ឋេសុ ច អាមុត្តសុវណ្ណវលយំ ។ អ.វ.ជ. ។ ខោមញ្ច កាយូរន្តិ សុវណ្ណមយំ គីវប្បសាធនន្តិ ឥទដ្ឋកថា ។ កាយូរន្តិ គីវាយំ បិលន្ធនប្បសាធនន្តិ សេលជាតកវណ្ណនា ។ ម.វ.ទ. ។

៥- **អង្គទំ មណិមេខលំ** = ត្រសាល់សម្រាប់ពាក់ ពួដ៏ត្រចៀកទាំងសងខាង និងខឹមខាត់សម្រាប់រឹតចង្កេះស្ត្រី ។ អង្គទំ

មណិមេខលន្តិ អង្គទាភរណញ្ច មណិមយមេខលញ្ច ។ អង្គទន្តិ ទ្វីសុ កណ្ណេសុ បសាធនំ ។ អ. វ. ជ. ។ អង្គទំ មណិមេខលន្តិ អង្គទាភរណញ្ច មណិមយំ មេខលញ្ចាតិ ឥទដ្ឋកថា ។ កាយូរំ អង្គទំ ពាហូមូលវិភូសនន្តិ តិក្កំ សោវណ្ណបកណ្ឋភូសនេ ។ បកណ្ឋោ នាម កប្បុរស្សុ បរិភាគោ ។ មេខលាតិ ឥត្ថិកដ្យាភរណេ ។ មេហនស្ស ខស្ស មាលា មេខលា ។ មេហនេ ឥន្ទ្រិយស្ស មាលាត្យត្ថោ ។ អដ្ឋយដ្ឋិប្បមាណញ្ហិ ឥត្ថិកដ្យាភរណំ មេខលា នាមាតិ នវវគ្គដីកានយោ ។ ម. វ. ទ. ។

៦- **មណិមេខលំ** = ខឹមខាត់ចង្កេះ ។ មណិមេខលន្តិ កដិយំ សាដកស្ស បរិវេធកំ ទីឃបដបាមង្គំ ។ អ. វ. ជ. ។ ស័ព្ទនេះមានសេចក្ដីពិស្ដារនៅក្នុងនយលក្ខណៈ លេខ ៥ រួចមកហើយ ។

៧- **ខោមញ្ច កាយូរំ** = ក្រវិលកមាស ឬ ចិញ្ចៀនមាស ។ ខោមញ្ច កាយូរន្តិ សុវណ្ណមយំ វនខជ្ជូរិផលសណ្ឋានំ គីវប្បសាធនមេវ ។ ខោមញ្ច កាយូរន្តិ ហត្ថបាទង្គុលីសុ អាមុត្តមណិកោដិកំ ចូឡសុវណ្ណវលយំ ។ អ. វ. ជ. ។

៨- **គីវេយ្យកំ** = ខ្សែសយពេជ្រពាក់ក ។ គីវេយ្យកន្តិ គីវាមុត្តមុត្តាបន្តិកំ រតនាមយន្តិ គីវាមុត្តរតនបន្តិកំ ។ អ. វ. ជ. ។ រតនាមយន្តិ អបរម្បិ រតនាមយំ គីវេយ្យន្តិ ឥទដ្ឋកថា ។

កណ្ឋភូសា តុ គីវេយ្យន្តិ នរវគ្គោ ៗ ម. វ. ទ. ៗ

៩- **ឧណ្ណតំ** = ស្ពៀតសក់មាស ៗ ឧណ្ណតន្តិ ឯកំ បសាធនំ ៗ បច្ឆតោ ចូឡាយ បសាធនំ ឧជុកញ្ច វង្កញ្ច សុវណ្ណមាលំ ៗ អ. វ. ជ. ៗ ឧណ្ណតន្តិ ឯកំ បសាធនំ ៗ ម. វ. ទ. ៗ

១០- **មុខផុល្លំ** = ក្បាំងមាស ៗ មុខផុល្លន្តិ នលាតន្តេ តិលកមាលាភរណំ ៗ បុរតោ ច ចូឡាយ អលង្កតំ វិកសិតំ សុវណ្ណបុប្ផំ ៗ នលាតន្តេ តិលកមាលាភរណន្តិ កេចិ ៗ អ. វ. ជ. ៗ មុខផុល្លន្តិ នលាតន្តេ តិលកមាលាភរណន្តិ ឥទដ្ឋកថា ៗ មុខផុល្លំ នាម សុវណ្ណមយោ មុខាលង្ការោ ៗ ម. វ. ទ. ៗ

១១- **នានារត្តេ** = សុទ្ធតែជាកែវមណីមានពណ៌ផ្សេង ៗ នានារត្តេតិ នានាវណ្ណេ មាណិយេតិ មាណិមយេ ៗ នានារត្តេ ច មាណិយេតិ នានារត្តវិចិត្តេ អលង្ការេ ៗ អ. វ. ជ. ៗ

១២- **ឧគ្គត្ថនំ គិង្គមកំ** = គ្រឿងប្រដាប់ដោះ, គ្រឿងប្រដាប់ស្មា ៗ ឧគ្គត្ថនំ គិង្គមកន្តិ ឯតានិបិ ទ្វេ អាភរណានិ ៗ ឧគ្គត្ថនន្តិ បយោធរយុគលេ បសាធនំ ៗ អ. វ. ជ. ៗ ឧគ្គត្ថនន្តិ ថនាលង្ការំ ៗ ម. វ. ទ. ៗ

១៣- **គិង្គមកំ** = គ្រឿងប្រដាប់សម្រាប់ពាក់នៅស្មា ៗ គិង្គមកន្តិ គិង្គមកេ អលង្ការយុគលំ ៗ អ. វ. ជ. ៗ គិង្គមកន្តិ អង្សតលេ សណ្ឋានលគ្គិកំ ៗ ម. វ. ទ. ៗ

១៤- **មេខលំ** = ស្លឹកពោធិ៍ចាក់ដោយអំបោះមាសប្រាក់ ។ មេខលន្តិ សុវណ្ណរជតមយំ មេខលំ ។ មេខលន្តិ មេហានស្ស បរិច្ឆាទនំ អស្សត្ថបត្តសណ្ឋានំ នានាសុត្តំ តុន្ទកបដំ ។ អ. វ. ជ. ។ មេខលន្តិ សុវណ្ណរជតមយំ ។ ម. វ. ទ. ។

១៥- **បដិបាទុកំ** = ស្បែកជើងមាស ។ បដិបាទុកន្តិ សុវណ្ណបាហនយុគលំ ។ អ. វ. ជ. ។ បដិបាទុកន្តិ បាទប្បសាធនំ ។ បាទង្គទំ មញ្ជីរា បាទកដកំ នូបូរោតិ ចតុក្កំ ឥត្ថីចរណភូសនេ ។ ម. វ. ទ. ។

១៦- **សុត្តញ្ញ សុត្តខជ្ជញ្ញ** = គ្រឿងប្រដាប់ទាំងដោតក្រងដោយខ្សែ ទាំងមិនបានដោតក្រងដោយខ្សែ ។ សុត្តញ្ញ សុត្តវជ្ជញ្ញាតិ សុត្តារុឡ្ហញ្ញ អសុត្តារុឡ្ហញ្ញ បសាធនំ ។ បាលិយំ បន សុប្បញ្ញ សុប្បវជ្ជញ្ញាតិបិ លិខិតំ ។ សុត្តញ្ញ សុត្តវជ្ជញ្ញាតិ សុត្តារុឡ្ហញ្ញាភរណំ បាហេសីតិ សម្ពន្ធោ ។ អ. វ. ជ. ។

១៧- **ឧបនិជ្ឈាយ សេយ្យសិ** = គន់មើលគ្រឿងប្រដាប់អង្គមានទ្រង់ទ្រាយឧត្តមថ្លៃថ្លា ។ ឧបនិជ្ឈាយ សេយ្យសីតិ ឯតំ សុត្តារុឡ្ហញ្ញ អសុត្តារុឡ្ហំ តំ តំ ឱនដ្ឋានំ ឱលោកេត្វា អលង្ករិត្វា ឋិតា សេយ្យសិ ឧត្តមរូបធរា មទ្ទី ទេវី ទេវកញ្ញាវ នន្ទនេ អសោភថ ។ ឧបនិជ្ឈាយ កម្មសាធនេ ត្វាបច្ចយោ ហោតិ អញ្ញេហិ ឱលោកិតាតិ វុត្តំ ។

សេយ្យសីតិ វរតរា ឧត្តមរូបធរា វា ។ អ. វ. ជ. ។ ឧបនិជ្ឈាយ សេយ្យសីតិ ឯវំ សុត្តាវុឡ្ហញ្ច អសុត្តាវុឡ្ហញ្ច អាភរណំ តន្តិ ឱនដ្ឋានំ ឱលោកេត្វា អលង្ករិត្វា ឋិតា សេយ្យសិ ឧត្តមរូបធរា មទ្ទី ទេវកញ្ញាវ នន្ទនេ អសោកថាតិ ឥទដ្ឋកថា ។ ឯត្ថ ច សុត្តមយំ សុប្បំ នាម កប្បាសិកាទិ ។ អសុត្តមយំ សុប្បវជ្ជិ នាម សុវណ្ណមយគីវាបសាធនាទិ ។ អលង្ករិត្វាតិ សេសោ ។ សេយ្យា ឯវ សេយ្យសិ ឧត្តមរូបធរាត្យត្ថោ ។ ម. វ. ទ. ។

១៨- **ទេវកញ្ញាវ** = បីដូចស្រីទេពកញ្ញា ។ ទេវកញ្ញាវាតិ ទេវច្ឆរា វិយាតិ តដ្ដីកា ។ នន្ទនេតិ នន្ទនវនេតិ ចូឡវនវណ្ណនា ។ នន្ទនំ មិស្សកំ ចិត្តលតា ផារុសកន្តិ ចតុក្កំ សក្កស្ស ឧយ្យានេ ។ នន្ទិយតីតិ នន្ទនន្តិ សគ្គកណ្ឌដីកានយោ ។ អច្ឆរាតិ ទេវកញ្ញា វិយ ។ ម. វ. ទ. ។

១៩- **វាតច្ឆុបិតា** = (ល្វាសល្វន់ទន់ភ្លន់ ដូចដើមចេក) ដែលត្រូវខ្យល់បក់ ។ វាតុច្ឆុបិតាតិ ចិត្តលតាវនេ ជាតា វាតសម្ផុដ្ឋា សុវណ្ណកទលី វិយ តំ ទិវសំ សា វិជម្ភមានា អសោកថ ។ វាតច្ឆុបិតាតិ មន្ទវាតេរិតា បិលិតា សុវណ្ណកទលី វិយ សា វិជម្ភមានា ។ អ. វ. ជ. ។ វាតច្ឆុបិតាតិ វត្តព្វេ មជ្ឈេ ទីឃំ កត្វា វាតាឆុបិតាតិ វុត្តំ ។ ឥទដ្ឋកថាយំ វាតច្ឆុបិតាតិ ចិត្តលតាវនេ ជាតា វាតសម្ផុដ្ឋា សុវណ្ណកទលី

វិយ តំ ទិវសំ សា វិជ្ឈមានា អសោភថាតិ វុត្តំ ។ ម. វ. ទ. ។

២០- **ទន្តាវរណសម្បន្នា** = ប្រកបដោយបបូរមាត់មានរបៀបល្អ ។ ទន្តាវរណសម្បន្នាតិ ពិម្ពផលសទិសេហិ រត្តទន្តាវរណេហិ សមន្នាគតា ។ ទន្តាវរណសម្បន្នាតិ ពិម្ពផលសទិសេហិ រត្តទន្តាវរណេហិ សមន្នាគតាតិ ឥទដ្ឋកថា ។ ទន្តាវរណាតិ បណ្ឌរានំ ទន្តានំ អាវរណភូតា តវ ឱដ្ឋាតិ អលម្ពសដីកា ។ ទន្តាវរណំ ឱដ្ឋោ អធរោ ទសនច្ឆទោតិ ចតុក្កំ ឱដ្ឋេ ។ ទន្តេ អាវរតិ ឆាទយតីតិ ទន្តាវរណន្តិ នវវគ្គដីកានយោ ។ ម. វ. ទ. ។

២១- **សកុណី មានុសិនីវ ជាតា ចិត្តបត្តា បតិ**= បីដូចសកុណីមានរាងជាស្រីមនុស្ស មានរោមដ៏ល្អវិចិត្រ ហិចហើររាំរែកលើវេហាស៍ ។ សកុណី មានុសិនីវ ជាតា ចិត្តបត្តា បតីតិ យថា មនុស្សសរីរេន ជាតា មានុសិនី នាម សកុណីបិ ចិត្តបត្តា អាកាសេ បត្តមានា បក្ខេ បសារេត្វា គច្ឆន្តី សោភតិ ឯវំ សា រត្តឱដ្ឋតាយ និគ្រោធពិម្ពបក្កសទិសឱដ្ឋា អសោភថាតិ ឥទដ្ឋកថា ។ ម. វ. ទ. ។

⁂

រាយនាមសប្បុរសជនដែលបានជួយឧបត្ថម្ភក្នុងការបោះពុម្ព សៀវភៅធម៌ផ្សាយជាធម្មទាន មានដូចតទៅនេះ ៖

	នាមត្រកូល	*ចំនួនបច្ច័យ*
១-	ព្រះតេជះគុណ **ធម្មសត្ថា ប្រាក់ ថន**	១៣០ ដុល្លារ
២-	ព្រះតេជះគុណ **សួរ គូ**	១៦០ "
៣-	ព្រះតេជះគុណ **មហាឃោសានន្ទោ**	៣០ "
៤-	ព្រះតេជះគុណ **សៅ ឃន**	៣០០ "
៥-	ព្រះតេជះគុណ **ខិប្បញ្ញោ គីម ទ្រីវ**	១០០ "
៦-	**ភិក្ខុវិនយធរោ មហា យិន នឿន**	៣០០ "
៧-	ភិក្ខុ ម៉ង់ ម៉ិន	៣០០ "
៨-	ភិក្ខុ សែម សុឃឿន	៣០០ "
៩-	ភិក្ខុ ជុំ មាច	៣០០ "
១០-	ភិក្ខុ គីម កាង	២២០ "
១១-	ភិក្ខុ អ៊ុយ ប៊ុន ឆឿន	២២៤ "
១២-	ភិក្ខុ សោម សុភា	៥០ "
១៣-	ភិក្ខុ ប៉ាង ឃឿន	១៥០ "
១៤-	ភិក្ខុ ទូច ផលមាន	១២០ "
១៥-	ភិក្ខុ សែង ស៊ី សុវណ្ណា	៣៦០ "
១៦-	ភិក្ខុ ទឹម ញ៉ុល	៥០ "
១៧-	ភិក្ខុ សុខ រស់	១០០ "
១៨-	ភិក្ខុ ទ្បោ ហោ	៩០ "
១៩-	ភិក្ខុ សង្ឃពោធិ៍	៥០ "
២០-	ភិក្ខុ គីម ហឿង	២០០ "
២១-	ឧបាសិកា ហែម យឹន	៥០ "

២២-	ឧបាសិកា ផៅ សារៀប និងបុត្រធីតា	៥០០	ដុល្លារ
២៣-	ឧបាសិកា សរ សឹង	៥០	"
២៤-	ឧបាសិកា ផា ស៊ីម	៥	"
២៥-	ឧបាសិកា ម៉ៅ និង គ្រួសារ	៥	"
២៦-	ឧបាសិកា ហ៊ិន	១០	"
២៧-	ឧបាសិកា លឹម សុខ គីម	២៥	"
២៨-	ឧបាសិកា ស្រីម	៥	"
២៩-	ឧបាសិកា នាង សាត	២០	"
៣០-	ឧបាសិកា ប្រាក់ មល់	២០	"
៣១-	ឧបាសិកា កុល ស៊ីម	២០	"
៣២-	ឧបាសិកា អ៊ិន ស៊ិន	៥០	"
៣៣-	ឧបាសិកា សឿ ហែល	៨០	"
៣៤-	ឧបាសិកា ស្វាយ ឡាង	៦០	"
៣៥-	ឧបាសិកា សួន ពេជ្រ	៣០	"
២៦-	ឧបាសិកា ឆាយ តាំង	១០	"
៣៧-	ឧបាសិកា រ៉ា ហៀក	១០	"
៣៨-	ឧបាសិកា ង៉ែត	៤០	"
៣៩-	ឧបាសិកា ឈឹត យា	១០	"
៤០-	ឧបាសិកា រឿន	៧	"
៤១-	ឧបាសិកា សុខ អេង	៨	"
៤២-	ឧបាសិកា មិន	៧	"
៤៣-	ឧបាសិកា សេង	១១៥	"
៤៤-	ឧបាសិកា រ៉ត	៥៥	"
៤៥-	ឧបាសិកា កាន់ សារ៉ាន់	៦០	"
៤៦-	ឧបាសិកា ណាប់ ធូក	២៥	"

៤៧-	ឧបាសិកា ថោង មុំ	២០	ដុល្លារ
៤៨-	ឧបាសិកា រឹត រុំា	១០០	"
៤៩-	ឧបាសកា ឧបាសិកា វត្តឈើរី	៧០	"
៥០-	ឧបាសកា ឧបាសិកា នៅ ម៉ែម ហ៊ើស	៦០	"
៥១-	អ្នកស្រី ហាច	១០	"
៥២-	អ្នកស្រី ហួរ	៥	"
៥៣-	អ្នកស្រី ឈុន យ៉េន	១០	"
៥៤-	លោកស្រី ប៉ាន់ រីណេ	២០	"
៥៥-	លោក ឡៀម រ៉ិន និងគ្រួសារ	១០០	"
៥៦-	លោក យស សាហ៊ុល និងគ្រួសារ	១០០	"
៥៧-	នាង សារី	៥	"
៥៨-	បុណ្យកតញ្ញូ នាងកញ្ញា ម៉ែន សារូ	៥០	"
៥៩-	បុណ្យកតញ្ញូ កូនតាអាចារ្យ ប៉ើ រី	១០០	"
៦០-	លោកយា - តា វត្តសាន់តាអាណា	១២៨	"
៦១-	លោក គឹម សាខន និងគ្រួសារ	១០០	"
៦២-	ប្អូន មុនីនិង លោកតា ឡាំ រឿង	២២០	"
៦៣-	បុណ្យផ្ទះ តាគង់ ហួត និងគ្រួសារ	១០០	"
៦៤-	ឧបាសក ឈុន	៥	"
៦៥-	ឧបាសក មី ហ៊ាន	៤០	"
៦៦-	ឧបាសក ឡាង	៥	"
៦៧-	ឧបាសក តូច អោក	៤០០	"
៦៨-	ឧបាសក ភន ឈាង ម៉ុង និងគ្រួសារ	៥០	"
៦៩-	អាចារ្យ វង គឹម ហួន	៤៦០	"
៧០-	អាចារ្យ ទីវ ឡាក់នរ	១៩០	"
៧១-	លោកតា ណោរ វត្តអែរ៉ាប់	៤០០	"

៧២-	លោកយាយ	ខៀវ ណារ	២០	ដុល្លារ
៧៣-	លោកយាយ	ឌុច សាម៉ីន	៣០	"
៧៤-	លោកយាយ	ជួរ ណាង	២០	"
៧៥-	លោកយាយ	អែម ទៀក	៥០	"
៧៦-	លោកយាយ	ង៉ូយ	២០	"
៧៧-	លោកយាយ	តាន់ ឈីវ គឹម	៥០	"
៧៨-	លោកយាយ	ប៊ុន តូ	២០	"
៧៩-	លោកយាយ	ពិន ប៉ុក	៥០	"
៨០-	លោកយាយ	ណាម ឫទ្ធិ (សុរុធី)	២០	"
៨១-	លោកយាយ	ពេជ្រ អូន (ឧត្តមា)	៥០	"
៨២-	លោកយាយ	អែម ថែម	២០	"
៨៣-	លោកយាយ	ទា សារីន (ហិរិមា)	២០	"
៨៤-	ឧបាសក	សយ មាន និងអៀមម៉ន	២០	"
៨៥-	អាចារ្យផ្លោក- ស៊ាងឡុង ព្រមទាំង ឧបាសិកា ឈាង-សាម៉ីន និងបុត្រធីតា		១០០	"

****

ធម្មទានឈ្នះអស់ទានទាំងពួង

សៀវភៅដែលនឹងបោះពុម្ពមានដូចតទៅ

១- សៀវភៅភាណវារកិច្ចវត្តព្រឹក-ល្ងាច

២- សៀវភៅសាមណេរវិន័យ

៣- សៀវភៅចាតុប្បារិសុទ្ធិសីល

៤- សៀវភៅពិធីប្រែបាលី

* * *

មេត្តាធម៌

មេត្តាធម៌ ជាធម៌ត្រជាក់អាចរម្ងាប់នូវជម្លោះ និង សេចក្ដីប្រកួតប្រកាន់ ដែលជារបស់ក្ដៅ ឱ្យរលត់ទៅបាន ប្រៀបដូចជាទឹកសម្រាប់លត់ភ្លើងដែលកំពុងតែឆេះ ។

មេត្តាធម៌ ទុកដូចជាថ្នាំឱសថយ៉ាងវិសេសវិសាល អាចបន្សាបបង់នូវពិសកាច គឺកោធៈនិងព្យាបាទបានពិត ។

មេត្តាធម៌ ទុកដូចជាមន្តអាគមយ៉ាងខ្លាំងពូកែស័ក្កិសិទ្ធិ អាចឱ្យសម្រេចនូវប្រយោជន៍គ្រប់ប្រការបាន ។

ទុក្ខប្បត្តា ច និទ្ទុក្ខា ភយប្បត្តា ច និព្ភយា
សោកប្បត្តា ច និស្សោកា ហោន្តុ សព្វេបិ បាណិនោ ។

សត្វទាំងឡាយទាំងពួងដែលដល់ហើយនូវសេចក្ដីទុក្ខសូមឱ្យជាសត្វបាត់សេចក្ដីទុក្ខទៅ ដែលដល់ហើយនូវភ័យ សូមឱ្យជាសត្វបាត់ភ័យទៅ ដែលដល់ហើយនូវសេចក្ដីសោក សូមឱ្យជាសត្វបាត់សេចក្ដីសោកទៅ ។